

ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់សិស្ស

អក្សរសាស្ត្រខ្មែរ

១២



គ្រឹះស្ថានបោះពុម្ពនិងចែកចាយ

ក្រសួងអប់រំ យុវជន និងកីឡា

អក្សរសាស្ត្រខ្មែរ

ថ្នាក់ទី ១២

បោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

គណៈកម្មការនិពន្ធ លោក យិន ធី លោកស្រី ម៉ៅ តាន់ណារី
លោក ព្រៃ សំបូរ លោកស្រី ប៊ី គីមសែន
លោក យ៉ង់ កំសាន លោក ណន ម៉ារ៉ាឌី

អ្នកទាយអត្ថបទ លោក សេង តុងបុត្តា

វិចិត្រករ លោក ឃុន សុវណ្ណរិទ្ធី

អ្នករៀបរៀង លោកជំទាវ ទន់ សាអ៊ីម

អ្នករចនាទំព័រ លោក គង់ ចិត្រា

គណៈកម្មការពិនិត្យ លោកបណ្ឌិត នៅ ស៊ុន លោកស្រី ជា រដ្ឋា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ១៨១៧ អយក.ប្រក. ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

ត្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បោះពុម្ពឆ្នាំ ២០១៦

ISBN 9-789-995-001-391

អារម្ភកថា

សៀវភៅអក្សរសាស្ត្រខ្មែរថ្នាក់ទី ១២ នេះ បាននិពន្ធឡើងស្របតាមកម្មវិធីសិក្សាថ្មី របស់ក្រសួងអប់រំ យុវជន និងកីឡា។ សៀវភៅនេះពង្រឹងនិងពង្រីកបន្ថែមទៀតទៅលើសមត្ថភាពទាំងបួនគឺ សមត្ថភាពស្តាប់ និយាយ អាន និងសរសេរឱ្យកាន់តែស៊ីជម្រៅនិងមានលក្ខណៈឯកទេស ដើម្បីផ្សារភ្ជាប់ទៅនឹងការសិក្សានៅឧត្តមសិក្សាផងនិងត្រៀមអាជីពផង។

សៀវភៅនេះបង្ហាញអំពីប្រធានបទសំខាន់ៗស្តីពី វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងការសិក្សាអក្សរសាស្ត្រ-អក្សរសិល្ប៍ជាគោលក្នុងការសិក្សាបំណិនច្រើនបែបដូចជា ការសង្ខេប សំយោគ តែងសេចក្តី វិភាគអត្ថបទជាដើម ដែលមានកំរិតខ្ពស់ហើយកាន់តែស៊ីជម្រៅ ថែមទៀត។ សៀវភៅនេះនឹងជួយបង្កើនចំណេះដឹងអ្នកសិក្សាឱ្យបានទូលំទូលាយតាមរយៈ ការសិក្សាអត្ថបទអក្សរសិល្ប៍ប្រជាប្រិយ បុរាណ ទំនើប អត្ថបទអត្ថាធិប្បាយ ពាក្យរាយ ពាក្យកាព្យ ល្ខោន ចម្រៀង របាំ វេយ្យាករណ៍ និងសិល្ប៍វិធីតែងនិពន្ធសម្បូរបែបរបស់អ្នកនិពន្ធកវីជាតិល្បីៗ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅអក្សរសាស្ត្រខ្មែរថ្នាក់ទី ១២នេះនឹងក្លាយជាធនធានដ៏មានតម្លៃសម្រាប់ប្អូនៗនិងជួយបង្កើនជាមពលសិក្សា ហើយនាំប្អូនៗឱ្យស្គាល់ច្បាស់នូវមរតកជាតិខ្មែរដ៏រុងរឿង ថ្លៃថ្នូរ តាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន។

សូមប្អូនៗទទួលបានជោគជ័យជានិច្ចក្នុងការសិក្សា។

គណៈកម្មការនិពន្ធ

បញ្ជីអត្ថបទ

ទំព័រ

១. អក្សរសិល្ប៍ខេមរនិយម ១

២. អក្សរសិល្ប៍ព្រាហ្មណ៍និយម ៣៥

៣. អក្សរសិល្ប៍ពុទ្ធនិយម ៦៥

៤. សិល្បៈ ៩១

៥. ល្ខោន ១២៧

៦. សិលាចារឹកនិងរបាំ ១៥៧

៧. ប្រពៃណីទំនៀមទម្លាប់ ១៧៣

៨. កំណាព្យ ១៩៩

៩. ទំនាក់ទំនងរវាងអក្សរសិល្ប៍ខ្មែរនិងបរទេស ២២៥


១០. អក្សរសិល្ប៍បរទេស ២៤៧


មេរៀនទី



អក្សរសិល្ប៍ខេមរនិយម







តាំងពីយូរលង់ណាស់មកហើយ ក្រៅពីជំនឿផ្សេងៗ ខ្មែរយើងបានទទួលឥទ្ធិពលពីសាសនាធំៗពីរ គឺព្រាហ្មណ៍សាសនានិងព្រះពុទ្ធសាសនា ។ ទោះបីបច្ចុប្បន្ន មានវប្បធម៌បរទេសមួយចំនួនកំពុងតែផ្សព្វផ្សាយឥទ្ធិពលរបស់ខ្លួនមកលើសន្តានចិត្តប្រជាជនខ្មែរយើងក៏ដោយ ក៏លទ្ធិសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនានៅតែដក់ជាប់ក្នុងផ្នត់គំនិត ជំនឿ ប្រពៃណី ទំនៀមទម្លាប់ សីលធម៌សង្គម អក្សរសាស្ត្រ អក្សរសិល្ប៍ជាដើម ។ ទន្ទឹមនឹងនេះ ស្មារតីជាតិនិយមក៏នៅតែលេចធ្លោឡើង តាមរយៈស្នាដៃជាច្រើនរបស់កវីនិពន្ធខ្មែរ ដែលមិនទទួលឥទ្ធិពលពីសាសនាឬមនោគមវិជ្ជាបរទេសណាមួយឡើយ ។ អក្សរសិល្ប៍បែបនេះ គេចាត់ជាអក្សរសិល្ប៍ខេមរនិយម ។ អក្សរសិល្ប៍ខេមរនិយមឬខ្មែរនិយម ជាស្នាដៃអក្សរសិល្ប៍ដែលបង្ហាញពីផ្នត់គំនិត ជំនឿ ប្រពៃណី ទំនៀមទម្លាប់ មុខរបរ បញ្ហាសង្គម និងជីវភាពរស់នៅរបស់ប្រជាជនខ្មែរក្នុងសម័យកាលនីមួយៗ ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីលក្ខណៈអក្សរសិល្ប៍ អត្ថបទដកស្រង់រឿងទុំទាវ វិធីបង្កើតកាព្យរូបារម្មណ៍ និងលក្ខណៈខ្លះៗនៃរឿងក្នុងគោលខេមរនិយម ។ អ្នកនឹងបានសិក្សាបន្ថែមទៀតទៅលើលក្ខណៈមួយចំនួនរបស់ភាសាខ្មែរ ការនិយាយសំយោគ និងសំណេរតែងសេចក្តីពិភាក្សា ។

ឥន្ទ្រិយរូបារម្មណ៍ក្នុងកំណាព្យ (វិធីបង្កើតកាព្យរូបារម្មណ៍)

ក្នុងការតាក់តែងកំណាព្យ កវីនិពន្ធតែងតែប្រើរូបារម្មណ៍ផ្សេងៗ ប្រយោជន៍ទាក់ទាញអ្នកអាន អ្នកស្តាប់ ឱ្យជក់ចិត្ត ហាក់ដូចជាបានឃើញនឹងភ្នែក ស្តាប់ឮនឹងត្រចៀក បានប៉ះស្ទាបអង្អែលដោយផ្ទាល់ដៃ ឬមានអារម្មណ៍បានភ្លក់រសជាតិ បានស្គាល់ក្លិនជាដើម។

ឥន្ទ្រិយរូបារម្មណ៍ គឺជារូបារម្មណ៍ដែលកើតពីពាក្យសំដីឃ្លោងឃ្លា ប្រយោគរបស់កវីនិពន្ធ ធ្វើឱ្យរំភើបចំពោះគ្រឿងវិញ្ញាណទាំងឡាយដូចជា ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយៈ គឺវិញ្ញាណទាំង ៥ របស់អ្នកអានឬអ្នកស្តាប់។ ឥន្ទ្រិយរូបារម្មណ៍មានចក្ខុរូបារម្មណ៍ សោតរូបារម្មណ៍ ឃានរូបារម្មណ៍ ជីវ្ហារូបារម្មណ៍ កាយរូបារម្មណ៍។

ក. ចក្ខុរូបារម្មណ៍

ចក្ខុរូបារម្មណ៍ គឺជារូបារម្មណ៍ដែលកើតមានឡើង ដោយសារពាក្យសំដីកាព្យឃ្លោង ដែលធ្វើឱ្យចក្ខុឥន្ទ្រិយរំភើបផ្តិតជាប់អារម្មណ៍ឡើង ក៏ហាក់ដូចជាធ្វើឱ្យចក្ខុបានឃើញរូបរាង ហេតុភេទដូចជាជាក់ច្បាស់នឹងភ្នែកដែរ។

ចក្ខុរូបារម្មណ៍ក្នុងកំណាព្យកើតឡើងបានដោយសារអត្ថបទកាព្យ ដែលប្រកបដោយសិល្បវិធី ធ្វើឱ្យអ្នកអាន អ្នកស្តាប់រំភើបផ្តិតជាប់អារម្មណ៍ហាក់ឃើញនូវរូបរាង សោភ័ណភាព ចលនារាង សកម្មភាព ហេតុការណ៍ ពណ៌សម្បុរ ប្រតិស្ឋឡើងរស់រវើកផ្ទាល់នឹងក្រសែភ្នែកគេតែម្តង។ ការបង្ហាញរូបរាង សកម្មភាព ហេតុការណ៍ ពណ៌សម្បុរត្រូវប្រកបទៅដោយតថភាព ហើយមានលក្ខណៈជាប់ស្និតទៅនឹងសោភ័ណដែលជាសិល្បឧត្តមគតិណាមួយ តំណាងគំនិតរីកចម្រើនជឿនលឿនបំរើមនុស្សជាតិ។

- **ចក្ខុរូបារម្មណ៍ដែលបង្ហាញរូបរាង** : ការរើសយករូបរាងកាយមកបង្ហាញត្រូវឱ្យស្របទៅនឹងការពិតឬមានសភាពអស្ចារ្យមានទំហំវិសាលភាពធំធេងដែលធ្វើឱ្យអារម្មណ៍មកប៉ះនឹងតួចក្ខុ។ កវីជ្រើសរើសយកចំណុចសំខាន់ៗមកបង្ហាញ ទោះបីពណ៌នាល្អឬអាក្រក់ ធំ តូច អស្ចារ្យក្តី ត្រូវឱ្យឃើញរូបរាងល្អឬអាក្រក់ ធំ តូច អស្ចារ្យនោះមកសណ្ឋិតជាប់ក្នុងអារម្មណ៍ ហើយហាក់ដូចជាបានឃើញផ្ទាល់នឹងភ្នែក។

  ឧទាហរណ៍ : រូបរាងដែលមានតេជានុភាព

  - "យល់នាគមួយស្មើគីរី"
  - រីកូខ័ន ខែងមហិមា រូបរូបពូតា ស្រមើងស្រមេះស្តើមស្តៃ" (រាមកេរ្តិ៍ខ្សែទី ១)

- "ខរខឹង ករកាន់ កាច់ភ្នំ សិលាធាតុ ប្របោះប្របាច សាចសង" (រាមកេរ្តិ៍ខ្សែទី ១)
- "ដល់ដកបពូតាកាន់ទ្រង់ បោះអង្គត្រូវអង្គ នរបតីដេញដំ ..." (រាមកេរ្តិ៍ខ្សែទី ៣)

ឧទាហរណ៍ : រូបវាង ពណ៌សម្បុរ ដែលមានសោភ័ណភាព

ជើងសោតត្រសួល ដួចចេកមាសមូល ទ្រវាងសង្ហា
ដំណើរនាងលះ រូតរះឧស្សាហ៍ ស្ងាហាប់ខ្លាំងក្លា
ការពារសត្រូវ[(១)] ។

(ដកស្រង់ពីកំណាព្យខ្មែរភាគ ២ ក្រសួងអប់រំ ឆ្នាំ ១៩៨៤)

- **ចក្ខុរូបារម្មណ៍ដែលបង្ហាញពណ៌សម្បុរ :** ដើម្បីបង្កើតសោភ័ណភ្ពី ជាមតិនិយមភ្ពីជានិមិត្ត សម្រាប់សម្គាល់ថាល្អឬអាក្រក់ភ្ពី ករីតែងតែយកពណ៌ផ្សេងៗមកធ្វើជាឧបករណ៍រំលេច ដើម្បីបង្កើតចក្ខុរូបារម្មណ៍ដល់អ្នកអាន ។ ក្នុងការលើកយកពណ៌មកបង្ហាញនេះ ករីមានគោលបំណងនឹងយកពណ៌ជានិមិត្តរូប ក្នុងការសម្គាល់មតិគំនិតទស្សនៈផ្សេងៗ ។ ម្យ៉ាងទៀត ករីបានយកពណ៌នេះមករំលេចគ្នា ធ្វើឱ្យឃ្លាល្បះនៃការពណ៌នានោះមានភាពរស់រវើក ដើម្បីពន្លឹចចក្ខុរូបារម្មណ៍ឱ្យកាន់តែច្បាស់ឡើងថែមទៀត ។
  - ពណ៌ក្រហម : សម្គាល់ទឹកចិត្ត ឬវីរភាពអង់អាចក្លាហាន សេចក្តីស្នេហាដ៏មោះមុត ស្មោះត្រង់ កំហឹងពុះពារ ឬជាជំនឿស៊ប់លើឧត្តមគតិណាមួយ ។
  - ពណ៌បៃតង : សម្គាល់សេចក្តីសង្ឃឹម ។
  - ពណ៌ខៀវ : សម្គាល់មេត្រីភាព តម្លៃផ្លូវចិត្តនៃតួអង្គ ។
  - ពណ៌លឿង : សម្គាល់ភាពជ្រះថ្លា សូប់ស្ងាត់ខាងផ្លូវកាយនិងផ្លូវចិត្ត(តាមការនិយមរបស់ជនជាតិអាស៊ី) ។ អឺរ៉ុបសម្គាល់ការបែកបាក់ ផិតក្បត់ អស់សង្ឃឹម ។
  - ពណ៌ស : សម្គាល់ភាពបរិសុទ្ធ សន្តិភាព សូប់ស្ងាត់ ។
  - ពណ៌ខ្មៅ : សម្គាល់ទុក្ខសោក ព្រួយបារម្ភ ចិត្តអាក្រក់ ខិលខូច កាចសាហាវ អស់សង្ឃឹម ។
  - ពណ៌ស្វាយ : សម្គាល់ភក្តីភាព ឬតម្លៃនៃចំណេះ ។

---

(១) : ការពារមាតុភូមិកុំឱ្យសត្រូវឈ្លានពាន

ឧទាហរណ៍ : ពណ៌សម្បុរជាមតិនិយម ឬនិមិត្តរូប

ឧបមាបុប្ផាពិពណ៌	ច្បារនោះគឺឆ្ការ	ក៏ឆេះកំឡុងភ្លើងច្រាល ។
រីផ្កានោងនៅកណ្តាល	ដូចសុពណ៌កាល	រំលាយមាសមានរស្មី ។
រីផ្កាចំប៉ាពិសី	ប្រាណប្រុតលើភ្វី	ននោងរាយរីកបុប្ផា ។
នោះគឺនព្វគុណសុវណ្ណា	ផ្សាយផ្សំតែមគ្នា	រលាយច្រឡំរស្មី ។
រីអង្គកន្លង់បក្សី	គឺធ្យូងអប្រិយ	និលាមន្ទិលពុំថ្កើង ។

(រាមកេរ្តិ៍ ខ្សែទី ២ ទំព័រ ៣)

តាមការពណ៌នាខាងលើនេះ កវីបានបង្ហាញឱ្យឃើញដូចតទៅ ៖

- ពណ៌ក្រហមនៃឆ្ការ : សម្គាល់ទឹកចិត្តស្នេហាបរិសុទ្ធរវាងព្រះរាមនិងសីតា និងភាពសុខដុមក្នុងគ្រួសាររវាងព្រះរាម សីតា និងព្រះលក្ខ្មណ៍ ។
- ពណ៌ខ្មៅនៃសត្វកន្លង់ : សម្គាល់ភាពអាក្រក់ ដែលនាំមកនូវការរំខានរបស់នាងកៃកេសី ដែលធ្វើឱ្យមានភាពកករលួនក់ ជាមន្ទិលក្នុងគ្រួសារ ។

ឧទាហរណ៍ : ពណ៌សម្បុរក្នុងចក្ខុរូបារម្មណ៍ ។

- "ចាំធ្មេញខ្មៅជិត ដូចអ្នកប្រកិត និលវ៌ត្ថ្លៃ បងគន់សម្គាល់នៃ អម្ពាលរូបដ៏ប្អូនបង បងចាំសម្បុរប្អូន ក្រៃលែងស្រលិត លឿងខៀវដ៏កន្លង វាល្អែកសម្បុរដ៏បីដង មួយថ្ងៃផ្សឹងៗ បំព្រងទុំ" (រាមកេរ្តិ៍ខ្សែទី ៤)

ដើម្បីបង្កើតចក្ខុរូបារម្មណ៍ គេអាចធ្វើការបង្ហាញ ឬពណ៌នា ដោយប្រើវិធីពីរយ៉ាងគឺ :

១. ការបង្ហាញរូបរាង : រើសយករូបរាងកាយផ្នែកខាងក្រៅ មកបង្ហាញត្រូវឱ្យស្របទៅនឹងធម្មជាតិនៃមនុស្ស គឺជ្រើសរើសចំណុចសំខាន់ៗមកបង្ហាញ ឬពណ៌នា ។

២. ការបង្ហាញពណ៌សម្បុរ : លើកយកពណ៌ផ្សេងៗមកធ្វើជាឧបករណ៍រំលេច ដើម្បីបង្កើតសោភ័ណឬមតិនិយម ដែលជានិមិត្តសម្រាប់សម្គាល់ថាសភាវៈល្អ ឬអាក្រក់ ។

២. សោតរូបារម្មណ៍

សោតរូបារម្មណ៍ គឺជារូបារម្មណ៍ដែលកើតឡើងដោយពាក្យពេចន៍ ឃ្លាប្រយោគដែលមានសូរសំឡេងរណ្តំស្រៈ រណ្តំព្យញ្ជនៈ ស្របទៅជាមួយសូរសំឡេងធម្មជាតិ សម្រែកសត្វ ព្យុះ រន្ទះជាដើម ធ្វើឱ្យសោតិន្ទ្រិយរំភើប ។ ការរំភើបនេះបង្កើតបានជារូបារម្មណ៍មួយបែបហៅថាសោតរូបារម្មណ៍ ។ សូរសព្ទពីរោះកើតឡើងដោយសារកវីចេះធ្វើឱ្យមានសូរស្រៈ រណ្តំព្យញ្ជនៈ ជួនរណ្តំ និងជួនផ្ចងរណ្តំព្យាង្គ ឬត្រាប់សូរតាមសំឡេងធម្មជាតិ ដើម្បីបង្កើតសោតរូបារម្មណ៍ក្នុងកំណាព្យរបស់ខ្លួន ។

- រណ្តំព្យញ្ជនៈ ស្ថិតនៅត្រង់កវីចេះជ្រើសរើសយកព្យញ្ជនៈដដែលៗមកប្រើក្នុងឃ្លាកាព្យរបស់ខ្លួន ។

ឧទាហរណ៍ទី ១ :

ខុនខែងខឹងខួនខឹងខាំ មាត់ភ្លាងងាំងាំ ត្របាក់ត្របែងផ្លែងកាំ ។
កោះសរសក្តិផ្លែងបីទន្ទាំ ខុនចក្រព្រះហស្តស្តាំ ត្រីគ្រាសគ្រាសបោះបាច ។

(រាមកេរ្តិ៍ខ្សែទី ៣)

ឧទាហរណ៍ទី ២ :

បានឃើញតែមុខទុក្ខបងបាត់ កុំកែវគិតកាត់គេចតែគៀង
បែរបៀតបងបីបមបាយបៀង លួកលាន់លោមលៀងលេងលងល ។

(សព្វសិទ្ធិ ទំព័រ ៧៤)

- រណ្តំស្រៈ ស្ថិតនៅត្រង់កវីចេះយកសូរស្រៈដដែលៗ មកប្រើនៅក្នុងឃ្លាកាព្យរបស់ខ្លួន ។ គេពុំសូវបានជួបប្រទះភាពរណ្តំស្រៈសុទ្ធនៅក្នុងកាព្យខ្មែរទេ តែច្រើនប្រទះឃើញ គេប្រើបញ្ចូលគ្នានូវភាពរណ្តំព្យញ្ជនៈនិងភាពរណ្តំស្រៈ ។

ឧទាហរណ៍ :

ឱកូនពុំងា ធម្មតាអ្នកជា ឱ្យរៀនថែទាំ
រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរកសន្សំ
លក់ចេញទិញចូល ។

(ច្បាប់បណ្តាំបិតា)

- **ព្យាង្គជួនរណ្តំក្នុងឃ្លា**

ឧទាហរណ៍ :

ប្រសិនបានប្រាណមកប្រកបវិញនេះ រួមសំណេះកេះសំណាលកាលហួសទៅ
បងបីនោមដោមដុងឆើតទើតលើស្ពៅ នាយប់ជ្រៅនៅយប់ជ្រុលពុលតណ្ហា ។

(កម្ពុជាសុរិយាលេខ ៧ ឆ្នាំ ១៩៥០)

- **ការត្រាប់តាមដំណើរធម្មជាតិខាងក្រៅ** គឺស្ថិតនៅត្រង់កវីចេះយកសូរស្រៈនិងសូរព្យញ្ជនៈទៅត្រាប់តាមសូរសំឡេងធម្មជាតិខាងក្រៅដូចជា សូរសំឡេងសត្វយំឬសូរសព្ទធម្មជាតិនានាមកតាក់តែងជាឃ្លាល្បះធ្វើឱ្យសោតិន្ទ្រិយអ្នកអានឬអ្នកស្តាប់ញាប់ញ័រ ហាក់ដូចជាបានឮសំឡេង សកម្មភាព ឬចលនាដែលគេរៀបរាប់នោះនឹងត្រចៀកតែម្តង ។

ឧទាហរណ៍ :

ភ្លៀងស្រក់ស្រឹបៗមិនឈប់ឈរ ភ្លៀងហូរតាមទសូរតក់ៗ
កង្កែបកូបៗតាមដើមកក់ ខ្យល់បក់ហ៊ឺៗតាមបង្អួច ។
បក់តាមមែកឈើឮសូរគ្រោវ រត់រ៉ាវទៅឆ្ងាយសូរគ្រលួច
រត់តាមប្រហោងហាក់ដូចហួច រត់កួចសក់នាងសូរឮញួយ ។

(ចិត្តក្រមុំ ស្នាដៃលោកកេង វ៉ាន់សាក់)

ស្រឹបៗ ជាសូរភ្លៀងធ្លាក់តិចៗមានសូរស្រាល តក់ៗ ជាសូរទឹកភ្លៀងស្រក់តិចៗ នៅលើទ ។ កូបៗ ជាសំឡេងត្រាប់សូរតាមសត្វកង្កែប ។

- ការត្រាប់តាមជំណើរធម្មជាតិខាងក្នុង គឺស្ថិតនៅលើកវិចេះយកសំឡេងស្រៈនិងព្យញ្ជនៈមកត្រាប់តាមចលនានៃចិត្តគំនិត មនោសញ្ចេតនាជ្រួលច្របល់ ទុក្ខវេទនា ឬការឈឺចាប់ កំហឹង ឆាបឆេះជាដើម មកបង្ហាញធ្វើឱ្យអ្នកអាន ឬអ្នកស្តាប់ញាប់ញ័រ ហាក់ដូចជាបានទទួលរងផ្ទាល់តែម្តង ។

ឧទាហរណ៍ទី ១ :

មេឃភ្លឺខ្មៅជិត ផ្គរលាន់ក្នុងចិត្ត រងំឥតសូរ
ស្ទឹងជន់សួតចែស ភ្នំប្រេះជាអូរ ទឹកភ្នែកជន់ជោរ
ហូរលិចភូមិស្ថាន ។

(កំណាព្យមើលផែនដីខ្មែរ លោក ជួន មេីន)

ឧទាហរណ៍ទី ២ :

អើតអើមដកកច្រហាមាត់ ចង់ចេញប្រាកដគ្មានគេហៅ
ស្តុតស្តឹងម្នាក់ឯងដោយក្មេងសាវ ស្ទុះចូលយកអាវពាក់ពានា ។
នេនយល់ដូច្នេះក្នុងពោះព្រួច តាំងកួចកើតទុក្ខចុកឱរា
ឱរូបហ្នឹងហើយទាវពុំងា មិនងាកបំពាបំពេរន ។

(រឿងទុំទាវ ភិក្ខុសោម)

ដើម្បីបង្កើតសោតរូបារម្មណ៍ គេអាចប្រើវិធីខាងក្រោម : រណ្តំព្យញ្ជនៈ រណ្តំស្រៈ ព្យាង្គជួនរណ្តំក្នុងឃ្លា ការត្រាប់សូរតាមធម្មជាតិខាងក្រៅ ការត្រាប់សូរតាមធម្មជាតិខាងក្នុង ។

គ. ឃានន្ទិងជីវ្ហារូបារម្មណ៍

ឃានន្ទិងជីវ្ហារូបារម្មណ៍គឺជារូបារម្មណ៍ដែលកើតឡើងដោយសារពាក្យពេចន៍ឃ្លាឃ្លោងស្របទៅនឹងក្លិននិងរសជាតិដែលកវីនិពន្ធប្រើប្រាស់ជាសញ្ញារំលឹកឱ្យនឹកភ្នកឬនឹកឃើញដល់វត្ថុភេទនិងចំណង់ចិត្តទាក់ទងនឹងឃាន:និងជីវ្ហាវិញ្ញាណតែម្តង ។

ឧទាហរណ៍ :

ដំណើរទុំទុកស្ទេះបង្អង់ ថ្លែងទៅទាវផ្ចង់ប្រុងអាត្មា
តាំងពីទុំឃ្លាតឃ្លាកាយា ទាវកើតទុក្ខាពុំមានក្សាន្ត ។
ចំណីបាយទឹកមិននឹកនា សាច់ជ្រូក មាន់ ទា ពោរពេញថាន
សល់នៅក្រៀមផ្ទេសស៊ីមិនបាន រំខានវិយោគសោយសោកា ។

ឃ. កាយរូបារម្មណ៍

កាយរូបារម្មណ៍ក្នុងកំណាព្យដែលកើតមកពីកាយិន្ទ្រិយ ដោយកវីនិពន្ធបានលើកយកកាយារម្មណ៍ផ្សេងៗមករៀបរាប់ដូចជា រលឹង រលោង ត្រជាក់ ក្តៅ ទន់ភ្លន់ ស្រលួន រៀវឆ្មារ ។ល។

ឧទាហរណ៍ :

ថ្លែងពីទាវទុក្ខពុំសុខសោះ នឹកឡើងស្រណោះទុំដោយនូវ
យល់ឃួរសូប់ស្ងាត់បាត់ស្នុះក្តៅ ព្រះពាយផាត់ត្រូវរហើយប្រាណ ។

- ដើម្បីបង្កើតឃានន្ទិងជីវ្ហារូបារម្មណ៍ កវីបានតាក់តែងដោយប្រើពាក្យពេចន៍ ឃ្លោងឃ្លាស្របទៅនឹងក្លិន រសជាតិសម្រាប់រំឭកឬធ្វើឱ្យអ្នកអាន-អ្នកស្តាប់ហាក់ដូចជាបានស្រង់ក្លិននិងភ្លក្សរសជាតិពិតៗ ។
- ដើម្បីបង្កើតកាយរូបារម្មណ៍កវីបានប្រើពាក្យពេចន៍ក្នុងកាព្យរបស់គាត់ធ្វើឱ្យអ្នកអាន-អ្នកស្តាប់ហាក់ដូចជាបានប៉ះពាល់ផ្ទាល់

លំហាត់

១. ចូរអ្នកស្រាវជ្រាវអត្ថបទកាព្យដែលមានបង្ហាញពីចក្ខុរូបារម្មណ៍ សោតរូបារម្មណ៍ ឃានន្ទិងជីវ្ហារូបារម្មណ៍ និងកាយរូបារម្មណ៍ ។

២. ចូរអ្នកតែងកំណាព្យបទពាក្យ ៧ ឬបទកាកគតិដែលប្រើចក្ខុរូបារម្មណ៍និងសោតរូបារម្មណ៍ ឱ្យបានយ៉ាងតិចប្រាំវគ្គ ។



លក្ខណៈជាតិនៃអក្សរសិល្ប៍

អ្នកធ្លាប់បានសិក្សារួចមកហើយពីលក្ខណៈមនុស្ស លក្ខណៈសង្គម លក្ខណតថៈ និងលក្ខណៈអន្តរជាតិក្នុងអក្សរសិល្ប៍។ ពេលនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតពីលក្ខណៈជាតិក្នុងអក្សរសិល្ប៍។

អក្សរសិល្ប៍មានលក្ខណៈជាតិ គឺជាស្នាដៃបង្ហាញពីតម្លៃពិសេសរបស់ជាតិមួយ ដែលខុសប្លែកពីបរទេស តាំងពីជំនឿ ទំនៀមទម្លាប់ ប្រពៃណី ទស្សនៈ ចិត្តគំនិត និងអាកប្បកិរិយាផ្សេងៗ។ គេចាត់អក្សរសិល្ប៍មានលក្ខណៈជាតិ គឺជាស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលទ្រទ្រង់ព្រលឹងជាតិឱ្យស្ថិតស្ថេរជាអមតៈ។



ចូរអ្នកអានអត្ថបទដកស្រង់ខាងក្រោមនេះ ៖

១. ត្បិតពាក្យអ្នកក្តី	ទាំងពីរស្រដី	ដណ្តើមឈ្លោះគ្នា
អាងអួតដឹងអ្នក	នេះជាក់ជាតិជា	ទិព្វសាក្សីថា
	ដឹងឮឃើញថាំ។	
២. ព្រះច្បាប់ត្រូវយក	សាក្សីនេះមក	សួរតាមចំណាំ
ឱ្យទៀងប្រាកដ	ដោយសត្យដោយធម្ម	ដឹងឮឃើញថាំ
	មែនពិតឬទេ។	
៣. បពិត្រទេព្រ័ក្ស	ប្រសិនបើអ្នក	បន្ទាល់វៀចវេរ
យល់ត្បិតញាតិឯង	ឬក្រែងចិត្តគេ	ទុច្ចរិតរិះរេ
	ស៊ីសំណូកគ្នា។	
៤. ដឹងឮឃើញថាំ	តាមដោយចំណាំ	ហើយស្តីវែកវា
ថាពុំដឹងឮ	ឮឃើញខាងណា	ឃើញថាំប្រែថា
	ពុំឃើញពុំដឹង។	
៥. សូមអស់ទេព្រ័ក្ស	មានរិទ្ធីសក្តិ	ផ្តិចផ្តាញឱ្យមាំ
ឱ្យរងទុក្ខា	វេទនារងកម្ម	ក្នុងជាតិនេះទ្រាំ
	ដល់បរលោកនាយ។	

៦. កាលខ្លួនរស់នៅ ពីថ្ងៃនេះទៅ សូមទេពទាំងឡាយ
បំផ្ទិចបំផ្លាញ ឱ្យឈឺឆ្អាត់ឆ្អាយ ភ្លើងឆេះអន្តរាយ
អស់អន្តរធាន ។

៧. ព្រាត់ម្តាយអាពុក ព្រាត់ស្រែព្រាត់ស្រុក ព្រាត់ធនព្រាត់ធាន
ព្រាត់កូនព្រាត់ចៅ ព្រាត់ផៅសន្តាន រន្ទះបាញ់ប្រាណ
ក្បិណក្បុយបាត់បង់ ។

៨. ទោះបីស្លាប់ទៅ ឱ្យទៅកើតនៅ នានរកនាយ
រងកម្មនៅនា ចតុរោបាយ ក្នុងជ្រាំជ្រៅឆ្ងាយ
រូបរងវេទនា ។

៩. ទោះបីដោះពី នរកនោះនឹ ទៅកើតជាតិណា
កុំឱ្យប្រទះ នឹងព្រះពុទ្ធា ឱ្យកើតនៅជា
ប្រេតសត្វតិរច្ឆាន ។

១០. ទោះមកកើតជា មនុស្សវិញក្តីណា ខ្សោយអត់សន្តាន
ជាខ្ញុំបំរើ គេប្រើឥតក្សាន្ត កុំឱ្យគេមាន
ប្រណីមេត្តា ។

១១. មួយសោតបើអ្នក ណាកាចអបលក្ខណ៍ ពាក្យពុំសត្យា
ចិត្តចោរទុច្ចរិត គន់គិតពីការ លន់តួស្មារលា
ពីព្រះប្រណិធាន ។

១២. នេះបើទេពតា ណាយកស្មារលា មេត្តាប្រោសប្រាណ
ឱ្យទេពនោះស្រុត ច្យុតចុះចាកឋាន ទៅបង្កើតប្រាណ
ក្នុងមហាអវចី ។

១៣. បពិត្រទេពតា បើអ្នកឯណា ស្លួតត្រង់សេចក្តី
សូមអស់អារក្ស ទេព្រ័ក្សភពត្រៃ ទោះមេសក្តី
ចំរើនពរ៉ា ។

១៤. ឱ្យភប់សម្បត្តិ សំបូរសុវត្ថិ អតិរេកគណនា
ស្ថិតស្ថេរយឺនយូរ បរិបូរទីឃា- យុយឺនព្រមប្រា-
កជកាលនេះម្តង ។

១៥. លុះលែងជាតិទៅ	ផលនាំសំដៅ	ដួចចិត្តបំណង
ឱ្យបានសម្បត្តិ	តុសិតឥតហ្មង	មានបរិវារផង
	ច្រៀងរាំបំរើ ។	
១៦. នីអស់ទុក្ខភ័យ	ឧបទ្រពចង្រៃ	បាបពៀរអំពើ
អំពីបុព្វជាតិ	ស្ពាងស្ពានប្រសើរ	ប្រសិនណាបើ
	អ្នកនោះចេតនា ។	

(ដកស្រង់ពីសៀវភៅភាសាខ្មែរសម្រាប់គ្រូថ្នាក់ទី ១២ ចោះពុម្ពឆ្នាំ ២០០១)

អត្ថបទដកស្រង់នេះ បានបង្ហាញពីផ្នត់គំនិតដែលជាលក្ខណៈជាតិខ្មែរដូចតទៅ :

ខ្មែរយើងតែងមានជំនឿទៅលើពាក្យសម្បថដែលត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិមុនពេលដែល ៖

- កាត់ក្តី (នៅសាលាជំនុំជំរះក្តី)
- ឡើងកាន់តំណែង (នៅស្ថាប័ននីមួយៗ)
- មុនចេញទៅសមរភូមិ (នៅបន្ទាយ)
- ខ្មែរយើងនិយមជឿទៅលើអ្នកតា ឬវត្ថុសក្តិសិទ្ធិដូចជា ទេព្រ័ក្ស អារក្ស មេស ... ។
- ខ្មែរជឿថា មានកើតមានស្លាប់ មានកម្មពៀរវេរា ដូចស្រមោលតែងអន្ទោលតាមប្រាណ
- ខ្មែរយើងមានជំនឿថា មានកម្មពៀរវេរា ហើយទាក់ទងនឹងឋានទាំងបី គឺឋាននរក (តិរច្ឆាន ប្រេត អសុរកាយ) ឋានមនុស្សលោក និងឋានទេវលោក ។

ទាំងអស់នេះ សុទ្ធសឹងជាផ្នត់គំនិតដែលប្រជាជនខ្មែរទូទៅប្រកាន់ទុកជាជំនឿកន្លងមកជារៀងដរាប ។ នេះជាលក្ខណៈជាតិខ្មែរសំខាន់ៗ ហើយនៅតែនិយមរហូតមក ។

លក្ខណៈជាតិនៃអក្សរសិល្ប៍ គឺជាលក្ខណៈពិសេសរបស់ជាតិមួយ លេចធ្លោខុសពីជាតិដទៃ ដែលស្តែងចេញតាមរយៈអក្សរសិល្ប៍ ។

- **លក្ខណៈជាតិក្នុងអក្សរសិល្ប៍បែបខមរនិយម(ខ្មែរនិយម)**

អក្សរសិល្ប៍ខមរនិយមនេះ ស្លែកពីចលនាអក្សរសិល្ប៍ដទៃទៀតដោយពុំបានយកគោលនិយមពីលទ្ធិណា ឬសាសនាណាឡើយ គឺជាការនិយមយកហេតុការណ៍ដែលគេធ្លាប់ឃើញពិតក្នុងសង្គមជាតិខ្មែរមកឆ្លុះបញ្ចាំងតាមរយៈស្នាដៃអក្សរសិល្ប៍ ។

- **អត្ថន័យ**

គោលបំណងសំខាន់បំផុត នៃអក្សរសិល្ប៍បែបខេមរនិយម បង្ហាញបញ្ហាជីវភាពជាក់ស្តែងរបស់មនុស្សក្នុងសង្គមស្របទៅតាមវប្បធម៌អរិយធម៌ខ្មែរយើង ។ ពិសេសខ្លឹមសារ នៃស្នាដៃប្រភេទនេះទាក់ទងទៅនឹងសង្គមបរិយាកាសខ្មែរ គឺទំនៀមទម្លាប់ ប្រពៃណី ប្រវត្តិសាស្ត្រ ភូមិសាស្ត្រខ្មែរជាដើម ។ ដំណើររឿងកើតឡើងក្នុងភូមិស្រុក ឬទីកន្លែងណាមួយ ដោយមានទំនាក់ទំនងទៅនឹងការប្រកបអាជីវកម្មរបស់ខ្មែរដែលជារឿងតថៈ ។

រឿងរ៉ាវនិងទំនាស់វិបត្តិដែលឆ្លុះបញ្ចាំងក្នុងអក្សរសិល្ប៍បែបខេមរនិយម(ខ្មែរនិយម) គឺជាទំនាស់ដែលកើតមានក្នុងជីវភាពរស់នៅរបស់ជនគ្រប់ស្រទាប់វណ្ណៈ ដែលតែងតែកើតមានក្នុងសង្គម ដូចជា ទំនាស់រវាងខ្លួនឯងឬទំនាស់ជាមួយអ្នកដទៃ ទំនាស់រវាងខ្លួនឯងនិងគ្រួសារ ទំនាស់រវាងអ្នកដទៃនិងគ្រួសារខ្លួន ទំនាស់រវាងខ្លួននិងសង្គម ។ល ។

ជាទូទៅ ការដោះស្រាយបញ្ហានៅក្នុងអក្សរសិល្ប៍បែបខេមរនិយមគឺតួអង្គពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ជំនះផ្លូវកាយ ផ្លូវចិត្ត ដើម្បីផ្ចាញ់ឧបសគ្គក្នុងសង្គម ឬធម្មជាតិ ។

ជម្រៅខ្លឹមសារនៃរឿង គឺជាបញ្ហាចោទចំពោះមនុស្សលោកិយបច្ចុប្បន្ន ហើយយកការអប់រំឱ្យបុគ្គលខ្លួនខិតខំព្រិះរិះដោះស្រាយបញ្ហាក្នុងសង្គមមនុស្ស ។ សាច់រឿងទាំងមូល គឺជារឿងរ៉ាវជាក់ស្តែងរបស់ខ្មែរគ្រប់សម័យកាលសង្គម ហើយប្រើវិធីដោះស្រាយបញ្ហាតាមលក្ខណៈស្របទៅនឹងបរិបទនៃសង្គមនីមួយៗដែលជារឿងពិតរបស់សង្គមខ្មែរ ។

- **អត្ថរូប**

អត្ថបទអក្សរសិល្ប៍បែបខេមរនិយមនេះ ច្រើនតែជាអត្ថបទដែលសរសេរជារឿងប្រលោមលោក ជាពាក្យកាព្យ ពាក្យរាយក្តីក៏ជារឿងសម្រាប់អានកម្សាន្តកែអផ្សុក តែបង្កប់គតិអប់រំទូន្មានប្រៀនប្រដៅទៅរកផ្លូវរីកចម្រើន ។ ភាសាក្នុងរឿងច្រើនយកពាក្យសំដីរបស់ប្រជាជនសាមញ្ញ ឬពាក្យអ្នកស្រុកជាន់កណ្តាល ជាន់ខ្ពស់ ដោយពុំសូវយកភាសាបាលីសំស្ក្រឹតដែលពិបាកអានមកប្រើឡើយ ។

- ការផ្តើមរឿង : ការផ្តើមរឿងក្នុងស្នាដៃអក្សរសិល្ប៍បែបខេមរនិយមមិនកំណត់ ។
- ដំណើររឿង : អ្នកនិពន្ធច្រើនតែនិទានខ្លួនឯង គឺការនិទានតាមបែបបុរសទី ៣ ។
- ការបញ្ចប់រឿង : បង្ហាញពីឧត្តមគតិរឿងនិងការអប់រំដល់អ្នកអាន អ្នកសិក្សាតាមរយៈសុភាសិត ប្រពៃណីទំនៀមទម្លាប់ ។ល ។

ប៉ុន្តែ ចំពោះស្នាដៃប្រលោមលោកវិញ ការបញ្ចប់រឿងមានឈ្នះ មានចាញ់ទៅតាមការពិតជាក់ស្តែងនៃបញ្ហាដែលអ្នកនិពន្ធឆ្លុះបញ្ចាំង ជាទូទៅអំពើល្អឈ្នះអំពើអាក្រក់ ។

- **អត្ថរស**

តម្លៃរបស់ស្នាដៃអក្សរសិល្ប៍ខេមរនិយម ស្តែងចេញពីការឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង ការអប់រំសីលធម៌និងស្មារតីជាតិនិយមពិតៗ តាមរយៈភាពប៉ិនប្រសប់របស់អ្នកនិពន្ធ ។

លំហាត់

ចូរអ្នកអានអត្ថបទដកស្រង់ខាងក្រោម ដើម្បីបង្ហាញពីលក្ខណៈជាតិនៃអក្សរសិល្ប៍ ដែលស្តែងឡើងតាមរយៈអត្ថបទនេះ ៖

[...] ដើម្បីជានុយទាក់ចិត្តកូនខ្មែរ ពេលនោះលោកបូដ្ឋាំង បានប្រកាសប្រាប់ខ្មែរដែលស្ម័គ្រចិត្តចូលទៅបំរើក្នុងកងទ័ពបារាំងថា បើនរណាស្ម័គ្រចិត្តធ្វើទាហានបារាំងត្រូវបានប្រាក់ខែ ៨០រៀលក្នុងមួយខែ។ ដល់ត្រឡប់មកស្រុកខ្មែរវិញ បើប្រទេសបារាំងច្បាំងឈ្នះអាល្លឺម៉ង់នឹងរកការឱ្យធ្វើគ្រប់ៗគ្នាតាមសមត្ថភាពរបស់ខ្លួន។ ពេលនោះមានខ្មែរភាគច្រើនស្ម័គ្រចិត្ត ទៅជួយច្បាំងថៅហ្វាយបារាំង។ បារាំងវើសទាហានបានល្មមគ្រប់ចំនួនហើយ នាយទាហានស្ម័គ្រចិត្ត ទៅនៅក្នុងថែវព្រះវិហារព្រះកែវមរកតហើយនិងហាត់យុទ្ធសាស្ត្រខ្លះផង។ ទាហានទាំងនោះមានចិត្តក្លាហានណាស់ រហូតដល់លែងដឹងស្គាល់ទំនៀមទម្លាប់ខ្មែរ លែងគោរពទំនៀមខ្មែរ អ្នកខ្លះស្រែកហ៊ោឡែឡឺធ្វើឫកតាមបារាំងឱ្យហើយព្រោះជិតបានទៅស្រុកបារាំង។ អ្នកខ្លះហាត់រៀនដើរពីងទ្រូងឱ្យហើយ ដើម្បីទៅដល់ស្រុកបារាំងកុំឱ្យឈ្លើយពេក រីឯអ្នកខ្លះទៀតខំហាត់និយាយបារាំង។ ទាហានជាច្រើននៅក្នុងព្រះវិហារព្រះកែវ ធ្វើឱ្យទីវត្តអារាមបាត់សេចក្តីស្ងប់ស្ងាត់។ តាមជំនឿអ្នកផ្លាប់តែជឿ ទាហានបារាំងដែលនៅក្នុងថែវវិហារព្រះកែវមរកតមានខ្លះចុះអាចម៍ ខ្លះឈឺពោះ ខ្លះគ្រុនញាក់ញ័រ ព្រោះទាហានទាំងនោះមិនជឿវត្ថុស័ក្តិសិទ្ធិ។ តាមការសង្កេតមើលទៅនៅពេលនោះ អ្នកគ្រុនញញឹញញ័រច្រើនតែទាហានរបុលរប៉ូច ឯទាហានដែលចេះគោរពស្គាល់ខុសត្រូវទំនៀមទម្លាប់ខ្មែរ បានសុខសប្បាយរហូតច្បាំងអាល្លឺម៉ង់ឈ្នះបានត្រឡប់មកស្រុកវិញ។ នៅពេលដែលទាហានមានចុះរាកឈឺពោះជាដើមនោះ ទាល់តែមានធ្វើរៀបពិធីសូមខមាលទោសវត្ថុស័ក្តិសិទ្ធិ ទើបទាហានទាំងនោះលែងឈឺពោះ លែងមានគ្រុនរងា។ ទាហាននាំគ្នាហាត់ដើរ ហាត់គំនាប់ ហាត់កាន់កាំភ្លើងរាល់ល្ងាច ... ។ ចំណែកនារីដែលមានសង្សារត្រូវទៅដែរនោះ បានបង្ហូរទឹកភ្នែកបក់ដៃហៅសង្សារឱ្យត្រឡប់មកវិញឆាប់ៗ ពិសេសលួចនិយាយនឹងអ្នកតាដងកើ "សូមលោកតាជួយមើលសង្សារកុំឱ្យបាត់បង់មរតកនៅស្រុកបារាំង"។ ... បន្ទាប់ពីកំណែននិងការតំឡើងពន្ធ នាម៉ឺន ប្រជារាស្ត្រចាប់មានចិត្តភ្ញៀវក្រហាយបន្តិចម្តងៗ ជាហេតុនាំឱ្យកើតរឿងខ្លះៗ។ ... នៅវេលាម៉ោង ៩ យប់ ស្រាប់តែមានផ្លេកបន្ទោរភ្លែតដូចជាគេពុះមេឃ ហើយបន្តិចមកស្នូរស្ទើរតែកក្រើកធរណី។ មិនយូរប៉ុន្មានសំឡេងពីរមាត់មួយទៅមាត់មួយថា រន្ទះបាញ់ចេតិយព្រះវិហារព្រះកែវមរកតខាងត្បូង។ ... តាមជំនឿថានឹងកើតចលាចល ឬមានកើតហេតុទ្ភិក្សក្នុងស្រុក។ [...]

(ដកស្រង់ចេញពីរឿងភូមិតិរច្ឆាន ឆ្នាំ ១៩៨៧ បោះពុម្ពដោយក្រសួងអប់រំ)

សិក្សាអត្ថបទរឿងទុំទាវ



ក. សិក្សាពាក្យគន្លឹះ

- គ្រឿងបរិក្ខារ (ន) : គ្រឿងប្រដាប់សម្រាប់ប្រើប្រាស់ ។
- ប្រណម្យ (កិ) : លើកកម្ពង់អញ្ជលីសំពះ ។
- និមន្ត (កិ) : អញ្ជើញសូមឱ្យទៅ សូមឱ្យមក ។
- ជ្រះសន្ដាង (គុ) : ជ្រះស្អាត ដែលល្អសមរម្យមិនឆ្គង ។
- សាមណេរ (ន) : បព្វជិតពុទ្ធសាសនិកអ្នកកាន់សីល ១០(លោកនេន) ។
- ស្បង់អង្សៀក (ន) : កាសាវព័ស្ដ្រសម្រាប់បព្វជិតពុទ្ធសាសនិកស្លៀកជានិច្ច ។
- ប្រគេន (កិ) : លើកឱ្យដល់ដៃក្នុងហត្ថបាស ប្រគេនចង្ហាន់លោក ។
- ក្មេងសាវ (ន) : ពេញជំទង់ក្រមុំ ឬកំលោះ ។
- ចង្ក្រម (ន) : ដំណើរដើរទៅមក ដំណើរទៅមកៗ គឺដំណើរទៅហើយដើរមកវិញ យឺតៗ ច្រើនបកច្រើនសា ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងចលនាអក្សរសិល្ប៍គោលខេមរនិយម លក្ខណៈជាតិនៃអក្សរសិល្ប៍ វិធីបង្កើតរូបារម្មណ៍ក្នុងកំណាព្យ ។

គ. សង្ខេបរឿងទុំទាវ

ទុំដែលជាកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់នៅស្រុកបាភ្នំ ខេត្តព្រៃវែង។ ទុំបានបួសរៀនជាមួយមិត្តម្នាក់ឈ្មោះពេជ្រនៅវត្តវិហារធំ។ ទាំងពីរនាក់ មានចំណេះខាងមន្តអាគម ផ្ចុំប៉ី និងធ្វើតោកលក់។ ដោយឡែក ទុំមានរូបឆ្នីលូក់ ព្រមទាំងមានសំឡេងយ៉ាងពីរោះ។ ថ្ងៃមួយមិត្តទាំងពីរបានសុំលោកគ្រូយកតោកទៅលក់តួងឃ្មុំ។ ទុំស្នួតបានពីរោះ ធ្វើឱ្យអ្នកស្រុកតួងឃ្មុំឈឺនរមកស្តាប់។ នាងនោជាភិលៀងរបស់នាងទាវបានឃើញទុំ ដែលមានរូបស្អាតនិងមានសំឡេងពីរោះក៏កួចចិត្តស្នេហា តែដោយដឹងថាខ្លួនមានឋានៈទាបក៏ខំសង្កត់ចិត្ត ត្រឡប់ទៅជម្រាបទាវវិញ។ នាងទាវបានដឹងដំណឹងនេះភ្លាមក៏អង្វរម្តាយឱ្យទៅនិមន្តនេនទុំ មកស្នួតនៅផ្ទះរបស់ខ្លួន។ ទុំក៏បានស្នួតនៅផ្ទះនាងទាវ ហើយស្នួតយ៉ាងពីរោះធ្វើឱ្យនាងទាវចាប់ចិត្តស្រឡាញ់ រួចក៏យកផាហ៊ុម ជន្លាប់ និងស្លាបារីមកប្រគេនទុំ ដោយបានប្រាថ្នាសុំឱ្យបានជួបរួមរក្សជាមួយនឹងទុំទៀតផង រីឯទុំក៏កួចចិត្តស្រឡាញ់រូបទាវវិញដែរ។ លុះដល់ពេលត្រឡប់ទៅដល់វត្តវិញ ទុំបានរកឧបាយកលសុំលោកគ្រូសឹក ប៉ុន្តែលោកគ្រូពុំព្រមឱ្យសឹក ដោយធ្វើការទស្សន៍ទាយទៅឃើញថា បើសឹកខែបុស្សនឹងត្រូវស្លាប់ ហើយសឹកខែពិសាខនឹងត្រូវធ្វើធំ។ ទុំក៏បានទៅតាមម្តាយឱ្យទៅជួយអង្វរលោកគ្រូ ហើយនៅតែពុំបានសម្រេច ក៏លួចសឹកម្នាក់ឯងនៅក្នុងព្រៃក្បែរដំបូក រួចក៏ប្រញាប់ប្រញាល់បបួលពេជ្រវិលទៅតួងឃ្មុំវិញ។ ជាភ័ព្វសំណាងរបស់អ្នកទាំងពីរនៅពេលនោះម្តាយទាវមិននៅផ្ទះ ទុំក៏បានឡើងលើផ្ទះ ហើយបានរួមរក្សជាមួយទាវក្នុងពេលនោះទៅ។

ក្រោយពេលនោះ អរជូនដែលជាចៅហ្វាយខេត្តតួងឃ្មុំព្រមទាំងភរិយា បានចូលមកស្តីដណ្តឹងនាងទាវឱ្យម៉ឺនងួន ជាកូនប្រុសរបស់ខ្លួន។ ទន្ទឹមនឹងនោះទុំនិងពេជ្រ ត្រូវព្រះរាជាឱ្យចូលគាល់បម្រើក្នុងវាំង ដោយប្រទានងារជាម៉ឺនឯក ព្រោះទុំចេះស្នួតបានយ៉ាងពីរោះ។ ជាមួយនោះព្រះរាជា ទ្រង់ចង់បានស្រីស្អាតយកមកធ្វើជាស្នំឯក ក៏បានជ្រើសរើសចំលើនាងទាវ ដែលជាសង្សាររបស់ទុំ។ នាងទាវក៏ត្រូវបានចៅហ្វាយខេត្តអរជូន ចាត់ចែងនាំយកទៅថ្វាយព្រះរាជា។ រឿងនេះបានធ្វើឱ្យម្តាយទាវសប្បាយចិត្តយ៉ាងខ្លាំង ព្រោះបានធ្វើម្តាយក្មេកស្តេច។ នៅពេលបានជួបគ្នា នៅចំពោះព្រះភក្ត្រព្រះរាជា ទុំក៏ស្រែកច្រៀងរៀបរាប់តំណាលសព្វ តាំងពីខ្លួនធ្លាប់រួមស្នេហាជាមួយទាវថ្វាយព្រះរាជា។ ឯទាវវិញក៏សំដែងអាកប្បកិរិយាក្នុងនាមទុំ ជាសង្សាររបស់ខ្លួនដែរ។ ទីបំផុតព្រះរាជាសម្រេចព្រះទ័យផ្សំផ្គុំអ្នកទាំងពីរជាគូស្វាមីភរិយានាពេលនោះទៅ។ ការណ៍នេះបានធ្វើឱ្យម្តាយទាវនឹកខឹងតូចចិត្តជាខ្លាំង ហើយវិលត្រឡប់ទៅស្រុកកំណើតវិញទាំងក្តីមួម៉ង។

ពេលមកដល់ស្រុក ម្តាយទាវបានរកឧបាយកលនាំទាវមកវិញ ដោយក្លែងសំបុត្រថាឱ្យទាវមកជាប្រញាប់ ព្រោះគាត់មានជំងឺជាទម្ងន់ ហើយត្រូវការនាងមករៀបចំសែនព្រេន។ ក្រោយពីបានទទួលដំណឹងនេះ នាងទាវក៏ប្រញាប់លាទុំជាប្តី ធ្វើដំណើរជាមួយនោមកមើលម្តាយ។ លុះមកដល់ផ្ទះ នាងទាវត្រូវម្តាយបង្ខំឱ្យរៀបការជាមួយម៉ឺនងួន។ ទាវអស់ក្តីសង្ឃឹម ក៏សរសេរសំបុត្រមួយច្បាប់ឱ្យគេយកទៅជូនប្តី ឱ្យមកជួយនាង។

ទុំបានទទួលដំណឹងហើយរន្ធត់ចិត្តយ៉ាងខ្លាំង ក៏ទៅទូលព្រះរាជាសូមលាទៅជួបទាវជាប្រពន្ធ។ ព្រះអង្គទ្រង់បានប្រទានព្រះរាជសារដល់ទុំនិងពេជ្រដើម្បីយកទៅឃាត់អរជួនឱ្យបញ្ឈប់អាពាហ៍ពិពាហ៍នោះជាបន្ទាន់។ ពេលមកដល់ផ្ទះនាងទាវ ទុំឮសូរភ្លេងការក៏ស្រងាកចិត្តវង្វេងអស់ស្មារតី។ ទុំបានផ្លាស់សម្លៀកបំពាក់ក្លែងខ្លួនជាអ្នកច្រៀង ហើយយករាជសារមកក្រវាត់នៅនឹងចង្កេះ រួចឡើងទៅលើផ្ទះការច្រៀងអន្ទងឱ្យទាវចេញមកចាក់ស្រាឱ្យខ្លួនផឹក។ ពេលផឹកស្រាស្រវឹងទុំបានប្រកៀកប្រឌិបជាមួយទាវ នៅចំពោះមុខភ្ញៀវ ធ្វើឱ្យម្តាយទាវខឹងច្រលោតយ៉ាងខ្លាំង ហើយប្រថំអរជួនឱ្យចាប់ទុំយកទៅសម្លាប់ចោល។ ទុំត្រូវគេសម្លាប់ចោលនៅក្រោមដើមពោធិ៍ជើងខាល។

កាលបើដឹងថា ទុំត្រូវគេសម្លាប់ នាងទាវបាននាំនាងនោទៅតាមរកទុំ។ លុះឃើញខ្មោចទុំហើយ ពួកនាងនាំគ្នាចាក់សម្លាប់ខ្លួនឯង ស្លាប់លើសាកសពរបស់ទុំ។ ពេជ្របាននាំដំណឹងដ៏សោកសៅនេះទូលថ្វាយព្រះរាជាជាបន្ទាន់។ ព្រះរាជាខ្ញាល់ខ្លាំងណាស់ ទ្រង់កោះប្រជុំអស់សព្វមុខមន្ត្រី ហើយទ្រង់យាងទៅជំនុំជំរះក្តីនេះដោយផ្ទាល់។ ទ្រង់បានដាក់ទោសរាស់ក្បាល ពួកអរជួន ហើយបញ្ជូលប្រជារាស្ត្រស្រុកតួងឃ្មុំជាអ្នកងារទាំងអស់។

ឃ. អត្ថបទ

[...]ដល់ផ្ទះម្តាយទាវចុះមកនាប់
ដល់ដីឱនក្រាបប្រណម្យនៅ
ថាទានលោកម្ចាស់និមន្តត្រូវ
ឥឡូវឈប់រង់ស្រង់ទឹកអាង។
ទឹកអប់ត្រឡប់ធុំគន្ធរស
សាប៊ូជូតដុសជ្រះសន្លាង
ក្រអូបសាប៊ូក្លិនដោយយ៉ាង
ដោយយល់សំណាងសាមណេរនេន។
ស្រង់ស្រេចផ្លាស់សង្ហរអង្សីកពាក់
ឡើងផ្ទះដល់ដាក់អង្គពន់ពេន
លើកបាទបត់បែបកែបប្រគេន
ប្រគល់លោកនេនប្រគេនស្លា។
ប្រាកដចេះបទយ៉ាងម្តេចខ្លះ
កុំអន់អៀនខ្មាសសូមមេត្តា
និមន្តស្នូតឬមើលសាស្ត្រា
យើងខ្ញុំប្រាថ្នាចង់ស្តាប់ម្តង។
ឱ្យអស់ចំណេះចេះយ៉ាងណា
តាមលោកមេត្តាស្រាយចំណង
ចំណាំម្តេចខ្លះខ្ញុំប៉ុនប៉ង
សន្តានមកផងស្តាប់រាល់គ្នា។

រួចនេនស្តាប់ជាក់ភ្លាក់ព្រើតប្រឹង
ភ្នែកគន់សម្លឹងទៅមាត់ទ្វារ

យល់ទាវឈរស្ទុបជើរវេរា
ស្ទុះស្ទាចូលក្នុងស្លុងចេញក្រៅ ។

អើតអើមដកកច្រហាមាត់
ចង់ចេញប្រាកដគ្មានគេហៅ

ស្តូតស្លឹងម្នាក់ឯងដោយក្មេងសាវ
ស្ទុះចូលយកអាវពាក់ពានា ។

នេនយល់ដួច្នោះក្នុងពោះព្រួច
កាន់កួចកើតទុក្ខចុកឱរា

ឱរូបហ្នឹងហើយទាវពុំងា
មិនងាកបំពាបំពេរន ។

តាំងថានមោតស្បូបីបទ
ពីរោះប្រាកដខ្លះក្រាបឱន

ស្នូតក័ណ្តូមទ្រីកាលជ្រកកោន
លំទោនលាព្រះលះចូលព្រៃ ។

ត្រាច់កាត់ក្នុងដងដែនបព្វតា
រកបេះផលាពនាល័យ

មានរុក្ខទេវាផងដទៃ
បំភ័យស្តូតស្ងន់ភ័ន្តភាំងភិត ។

ដល់ដួលដាក់អង្គទ្រង់វិយោគ
ទួញយំឱនឈ្ងោកគួរអាណិត

អនាថត្រជាក់ហើយល្ងាចឥត
លោកណាជួយគិតជីវិតខ្ញុំ ។

ប្រាសព្រះព្រោះលះមកឆ្ងាយហើយ
អម្ចាស់ថ្លៃអើយម្ល៉េះក្រាលក្រំ

ព្រួយប្រឹងគិតកូនខានចង្រ្កម
កូនយំទាររកយកអ្វីឱ្យ ។

ស្រែកឃ្លានគ្មានសល់ផលផ្លែឈើ
ម្ល៉េះហើយទ្រង់ដើរក៏ដង្ហោយ

ហៅខ្ញុំពីព្រឹកនឹកខានសោយ
សមដោយតាមកូនសួន្យស្ងប់ស្ងាត់ ។

នេនស្នូតច្រូតកាត់កែទំនង
រំលងយកខាងរឿងបរមត្ថ

ឈប់ឆាន់ស្លាមួយរតិចក្តាត់
បាសកប្រតិបត្តិសត្វញាតិញោម ។

បាសកកាលនោះស្រុះស្រួលស្រេច
ខ្លះស្តាប់គាំងដាច់ទាំងជុះនោម

ពីរោះស្រណោះផ្អើលជៀវចោម
ប្រឈមឈរឈប់មួយមុខផ្ទះ ។

ហើយថាមេត្តាប្រាយប្រោសសត្វ
ខ្លះខិតចូលជិតគិតចង់ឈ្នះ

លើកហត្ថទាំងសងផ្គងសំពះ
សូមមន្តអម្ចាស់ច្បាស់រឿងអ្វី ។

មេត្តាកុំលាក់ជាក់ជាចេះ
ទុំមានតម្រិះត្បិតឃើញស្រី

ទាវយកជាហ៊ុមព្រែកម្ចី
ជន្លាប់ទិញថ្មីបារីស្លា ។

បត់បែរតែងស្រាប់ថាប់លើកផ្គង
បិទទូលបីដងប៉ងប្រាថ្នា

ថាសូមតេជៈព្រះករុណា
សូមដួចសច្ចាចិន្តាផ្សង ។

សូមជួយឱ្យជួបរួបរួមកាយ
កុំឱ្យឃ្លាតឆ្ងាយដួចបំណង

ជាតិនេះជាតិណាសត្យាប៉ង
បានដួចបំណងចងមេត្រី ។

ទាវរៀបផ្គងស្រេចចាប់កាន់ដើរ ដល់មកជិតស្មើនឹងនោស្រី
ថាហាកនោបងចូរប្រណី ប្រគេនបារីស្លាផាហ៊ុម ។
ឱ្យខ្ញុំជាគុណជាបុណ្យខ្លះ កុំឱ្យខ្ញុំខូះទ្រព្យចូលជុំ
ជាតិនេះជាតិក្រោយឱ្យមានធំ កុំបីឱ្យខ្ញុំក្រតទៅ ។
នេនទុំទទួលគ្រឿងបរិក្ខារ ស្រេចស្រាយយកស្លាឆាន់រួចនៅ
ឈប់អង់បន្តិចសែកប្រេងម្សៅ រំលឹកដល់ទៅមន្តសាវិកា ។
លិនថោងករវិករំលឹករក សម្ពីលីហៅយកមណីចិន្តា
លូកយកប្រទាលឆាន់នឹងស្លា សូត្រសាគ្រប់សព្វចប់ជាម្តង ។
រួចនេនទុំស្នូត្រស្រូតបង្ហើយ សូត្រហើយនឹករករឿងប្ហួនបង
ឃើញត្រង់ព្រាហ្មណោចោរកន្លង នាំកុមារចងនឹងវល្លិវែ ។

(ដកស្រង់ចេញពីរឿង ទុំទាវ "ព្រះបទុមត្ថេរ សោម" របស់ពុទ្ធសាសនាបណ្ឌិត្យ ព.ស ២៥១៤)

សំណួរ

១. តើអត្ថបទដកស្រង់ខាងលើនេះ ស្ថិតក្នុងចលនាអក្សរសិល្ប៍បែបណាមួយ ? ចូរអ្នករកអំណះអំណាងមកបញ្ជាក់ឱ្យបានច្បាស់លាស់ ។

២. តាមរយៈអត្ថបទដកស្រង់នេះ តើកវីបានប្រើវិធីតែងសំខាន់ៗអ្វីខ្លះ ? ចូរបង្ហាញពីវិធីនោះឱ្យបាន ៥យ៉ាងតិច ដោយរកឧទាហរណ៍ពីក្នុងអត្ថបទនេះមកបញ្ជាក់ផង ។

៣. ចូរអ្នកបង្ហាញពីលក្ខណៈអក្សរសិល្ប៍ តាមរយៈអត្ថបទដកស្រង់នេះ ។

៤. តើក្នុងសម័យកាលនោះ ជនជាតិខ្មែរបានទទួលឥទ្ធិពលពីសាសនាណាខ្លះ ? ចូរអ្នកធ្វើការបញ្ជាក់តាមរយៈអត្ថបទនេះ ។

៥. ចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរ នាសម័យនោះ ។

៦. ដោយផ្អែកលើវគ្គ "លិនថោងករវិករំលឹករក សម្ពីលីហៅយកមណីចិន្តា លូកយកប្រទាលឆាន់នឹងស្លា សូត្រសាគ្រប់សព្វចប់ជាម្តង" ចូរអនុវត្តលំហាត់ខាងក្រោម ៖

ក. ដោយសិក្សាពាក្យ ១ព្យាង្គរកទំនាញសូរ គ្មានទំនាញសូរ ព្រមទាំងពីមូលហេតុឱ្យបានច្បាស់លាស់ ។

ខ. ដោយសិក្សាពាក្យ ១ព្យាង្គ រកបញ្ចូក អ-អ៊ ឬសូរស្រៈពួក "អ" សូរស្រៈពួក "អ៊"និងសូរស្រៈពួក "អ-អ៊" (ក្នុងសូរស្រៈនីមួយៗសិក្សាតែ ១ពាក្យ) ។

គ. ដោយសិក្សាពាក្យ ១ព្យាង្គ រកព្យាង្គជួនក្នុងវគ្គ ជាព្យាង្គ (បិទខ្ជី-វែង ឬបើកខ្ជី-វែង) ហើយសរសេរជាសូរវិទ្យាអន្តរជាតិ API ដោយប្រាប់ពីទម្រង់និងសទ្ទ ។



វិវត្តន៍នៃភាសាខ្មែរ

ឃ្លាសាច។ចគតនចបំភែកអ៊ីអាច្រកអាចំញ្ជាតា ។ នេះគំពេះហាចង្ហាប្រាំង្ច ។ យេបត្តអំធាលួនេះបានគតអាត្តូចិខ្លាក្បាច្ច
គរាចគេលាគាភ្លើន្ទាយអាយុះន្តុត្តអាន្ត្រូភតាំគតុច្ចតង្ច្រលាំច្រះបានគអាត្រូចគេដ៏តាំត្តូនិអច្ចាត្រាំស្ទួយ្យាប្រង្វាំនេចតសគលេស្លេយ
ច្រះត្តម្ដាំច្ចាតុសចាបគតគ្នេះភ្លាំតាច្រះស្លេដ៏ច្រះតុត្តុតុច្ចាលាតាយ្យា ។ យេបដ៏ង្ហាបច្ចិតគាត្រូចគេដ៏ញ្ជីតគាំគេតិចាំលេយ៉ាង្ច្ចាំ
ខ្ចំង្ច្រាំសំន្តុច្ចង្ច្រាំន្ទេច្រោបាប្រគាគចោដ៏ ។ ន៎អ៊ែបាលួរាំគេរគគាភ្លើយតគ្នូលាំច្រះបានគអាត្រូចគេដ៏ភ្ញូនិអច្ចាត្រាំស្ទួយ្យាប្រង្វាំនេចត
នោគគាំបាំយេបដ៏ច្រាំគន្ទេ ។ គាចាគជាដ៏ចាច្ចាយេបដ៏ច្រាំគច្ចាយ្យាដ៏ន្តុសង្ខាដ៏ភ្ញាឈាង្ច្រាំស្ទួច្ចាអាយុះលោគុគាភ្លើង្ច្រាំគលេដ៏ចាំចាច្ច ។ គាច្រាំគ
ចាំចាច្ចចំយេបដ៏ស្ទួចាំតុស្ទួចាំង្ច្រាំនំអ៊ូប្តាំយេបលួរអ្នកគស្ទួអាំគាំគាច្ចាំយេប្ច ។ គាអាយុះយេបដ៏កាចាំច្ចាន្តច្រាគគាយ្យាគេរាល្លេះគគាយេដ៏
ប្រគារលេបាយេបដ៏ស្ទួបដ៏គេគុគគាំបំយេដ៏ន្ទេ ។ គាចាគជាត្រាគគាយ្យាតាគាត្រូចគេដ៏ភ្ញូនិអច្ចាគាន្ទួលាប្រាយេបដ៏ទៅនាគ
ឃ្លាយចំអានិ ឥត្តំបានគចគ្នេះលើង្ច្រាំដ៏ស្ទួតាញ្ជាតគាះបច្ចាប្រគាំង្ច្រាំនិគេ ។ គាយេច្ចាំអាំបាលួនេះគាមាច្ចាន្តស្ទួង្ច្រាំគេរគបាច្ចាប្រគាំ
ង្ច្រាំនេះបាំយគាត្រូចគេដ៏ង្ហើគពាំគស្ទេយ៉ាច្រះតម្ដាំច្រាំង្ច្រាំស្ទួលេដ៏ឧយ៉ាដ៏ច្រាំគលេដ៏ច្ចាំង្ហាយ៉ាប្រគារ ។ គាយេបដ៏មាច្ចាគគាយ
គបាំង្ហាំង្ហាគ៎ាគោលាប្រគាំង្ច្រាំគេរគោលេនេះគាលេដ៏យេដ៏គាគច្ចាគ្នាច្រាំគគាគគារាប៊ាច្រះតាង្ច្រាំង្ច្រាំត្យាគាធិលេយ៉ ។ គាគាយេដ៏ង្ហេរគេគាច្ចាប្រ
គាំង្ហាំនេះគាគាត្រូចលេដ៏គាត្រូចគេដ៏ង្ហើគពាំប្រយ៉ាបាលនច្រះបុត្យាលុគ៎ាន្ទេគលេដ៏សំបុរលាអ្នើគាគុលេយេដ៏បោគុលេដ៏ស្ទា
ន៎គគ៎ាំគគ្នលាំច្រះជាន្ទេគាត្រូចគេដ៏គ៎ាំគូន៎ាច្រាំស្ទួយ្យាប្រម្ដាំគេបគសគគស្ទេយ៉ាច្រះតម្ដាំង្ហាត្យាគុសាចន្ទេគគ ។ ចំយាយគេត្តគស្ទាំន៎ាគ្នាំ
លេដ៏គាគ្នេលេត្តគាំចំនគាលោគគ៎ាំលើ្ងេគយារលោគ ។

ក. សិក្សាពាក្យគន្លឹះ

- ទិទ្យាស្ថានជាតិខេមរយានកម្ម (ន) : ឈ្មោះស្ថាប័នជាតិមួយ ដែលមានភារៈត្រួតពិនិត្យរាល់ការប្រើប្រាស់និងការបង្កើតពាក្យខ្មែរឱ្យបានត្រឹមត្រូវ ។
- ពុទ្ធសាសនាមហាយាន (ន) : គោរពប្រតិបត្តិតាមចរិយាវាទ គឺតាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា ។ និកាយមហាយានជឿថា មានពោធិសត្វធំៗជាច្រើនអង្គមិនទាន់ចូលបរិនិព្វាន ហើយបិតនៅក្នុងលោកនេះ ចាំជួយសង្គ្រោះសត្វលោក(លោកកេសូរៈ មញ្ជុស្រី សមន្តភទ្រ ក្សិតិគភ៌ វជ្របាណី ...) ។
- ពុទ្ធសាសនាហីនយាន (ន) : គោរពប្រតិបត្តិតាមពុទ្ធោវាទ ដែលព្រះពុទ្ធទ្រង់បានសំដែងរួចមកហើយ(ក្នុងគម្ពីរព្រះត្រៃបិតក) ។ និកាយហីនយានគោរពព្រះពុទ្ធសមណគោតម ដែលបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយដែលបានចូលបរិព្វានទៅហើយ ។
- សូរព្យញ្ជនៈអយោសៈ (ន) : អក្សរដែលមានសំឡេងមិនគឹកកងមាន ១១តួ គឺ កខ , ចឆ , ដឋ , តថ , បផ , ស ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះអ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងនឹងការវិវឌ្ឍនៃភាសាខ្មែរ យល់ដឹងពីវិធីបង្កើតពាក្យក្នុងភាសាខ្មែរនិងលក្ខណៈពិសេសនៃភាសាខ្មែរ ។

គ. អត្ថបទ

១. ការវិវត្តនៃភាសាខ្មែរ

ភាសាខ្មែរមានវិវត្តន៍បីលើកធំៗ គឺភាសាខ្មែរបុរាណតាំងពីកំណកំណើតរហូតមកដល់សតវត្សទី ១៤ ភាសាខ្មែរកណ្តាលសតវត្សទី ១៥ដល់សតវត្សទី ១៩និងភាសាខ្មែរបច្ចុប្បន្ន សតវត្សទី១៩តរៀងមក ។ នៅសម័យអាណាព្យាបាលបារាំង ភាសាខ្មែរបានថយល្បឿននៃវិវត្តន៍របស់ខ្លួន ហើយរត់សំងំក្នុងវត្តអារាម ដែលមានព្រះសង្ឃជួយថែរក្សាទុកឱ្យ ។ ពេលនោះ គេបង្ខំឱ្យរៀនភាសាបារាំងជាយាន ជាផ្លូវការដែលជាហេតុនាំឱ្យខូចប្រយោជន៍ភាសាជាតិ ។ នៅសម័យឯករាជ្យ ភាសាខ្មែរបានប្រកាសឱ្យប្រើជាផ្លូវការ ។ កំណើតគណៈកម្មការរបប្បធម៌មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ វិទ្យាស្ថានខេមរយានកម្ម ជំរុញឱ្យមានការបង្កើតពាក្យថ្មីៗជាច្រើនទៀត ដើម្បីប្រើការឱ្យទាន់សម័យនិយម ។ គេប្រទះឃើញពាក្យបរទេសជាច្រើននៅលាយឡំក្នុងភាសាខ្មែរ ។ ល្បាយភាសានេះ កើតឡើងនៅពេលដែលខ្មែរមានទំនាក់ទំនងនឹងបរទេស ។ គេកត់សម្គាល់ថា កាលណាភាសាមានអាយុកាន់តែវែង ល្បាយភាសាក៏កាន់តែមានច្រើនឡើងៗដែរ ។ ឯភាសាដែលនៅលាយឡំក្នុងភាសាខ្មែរមាន ភាសាសំស្ក្រឹតហូរចូលមកក្នុងភាសាខ្មែរតាមរយៈព្រាហ្មណ៍សាសនា ពុទ្ធសាសនាមហាយាន និងពុទ្ធសាសនាហីនយានប្រើភាសាសំស្ក្រឹត ។ ភាសាបាលីហូរចូលមកក្នុងភាសាខ្មែរ តាមរយៈពុទ្ធសាសនាហិនយានប្រើភាសាបាលី ។ ភាសាបារាំងហូរចូលមកក្នុងភាសាខ្មែរ តាមរយៈអាណាព្យាបាលបារាំងនិងតាមរយៈខេមរយានកម្ម ។

២. លក្ខណៈពិសេសខ្លះៗនៃភាសាខ្មែរ

ក. ក្នុងភាសាខ្មែរមានមូលភេទពីរ គឺមូលភេទ **អ** និងមូលភេទ **អ៊** វាចែកសូរស្រៈនិងព្យាង្គខ្មែរជាពីរពួកធំៗ គឺពួក **អ**និងពួក**អ៊** ។ ឯសូរស្រៈមាន ពួក**អ** ពួក**អ៊** និងពួក**អ-អ៊** ។ ដូចជាពួក**អ** មានសូរស្រៈពួក **អ** គឺ **ɒ: , ɒ , a: , a , ę , ɛi , œ , œ: , ǫ , ǫ: , aə: , ę: , aɛ , ai , ao: , au** ហើយចំពោះសូរព្យាង្គពួក **[អ]** មាន កា [ka:] បី [bɛi] សូរ [sǫ:] ជាដើម ។ រីឯសូរស្រៈពួក**អ៊**គឺ **ɒ: , ɒ , i:ə , iə , oa: , i , i: , ɯ , ɯ: , u , u: , ð: , e: , ɛ: , ɛ , ei , o: , əu** ហើយចំពោះសូរព្យាង្គពួក**អ៊** មាន គា [kiə:] ពី [pi:] ទូ [tu:] ជាដើម ។ ចំណែកសូរស្រៈពួក **អ-អ៊** មានគឺ **uə: , ɯ:ə , i:e** ជាមួយនោះសូរព្យាង្គពួក **[អ-អ៊]** គឺ កួរ [ku:ə] គួរ [ku:ə] ខឿន [khhɯ:ən] ជឿន [chɯ:ən] ជៀស [chi:es] ចៀស [ci:es] ។

ខ. ចំពោះសូរព្យញ្ជនៈអឃោសៈ (ថ្លង់) មាន ១១គឺ k , kh , c , ch , p , ph , s , h , ? ។ ចំណែកសូរព្យញ្ជនៈឃោសៈ(ព្ញ) មាន ១០ គឺ d , b , ŋ , ɲ , n , m , j , r , l , v ។

គ. ការបន្លឺសំឡេង : ក្នុងការបន្លឺសំឡេងភាសាព្យាង្គខ្មែរយើងគ្មាន "ស្នៀង"ទេមានន័យថា ភាសាខ្មែរយើងពុំមានបម្រែបម្រួល កម្ពស់សូរទាបឬខ្ពស់ ដើម្បីបង្កើតពាក្យច្រើនម៉ាត់ផ្សេងគ្នា (មាន-ន័យផ្សេងគ្នា)នោះទេ ។ ភាសាវៀតណាម ឡាវ ចិនជាដើម តែងប្រើ "ស្នៀង" នេះដើម្បីបង្កើតពាក្យ ឱ្យកាន់តែច្រើនទៀត ។ ក្នុងភាសាខ្មែរ "សូរសង្កត់" នៃពាក្យពីរព្យាង្គឋិតនៅលើព្យាង្គទី ២ជាដរាប ។

ឧទាហរណ៍ : ពាក្យថា កន្លែង [ក់ន លែង]

- ក្នុងពាក្យបីព្យាង្គ "សូរសង្កត់" ឋិតនៅលើព្យាង្គទី ២និងទី ៣ :
  - កន្ទាំងហែ [ក់ន ទាំង ហែ]
  - កន្ទុយលិន [ក់ន ទុយ លិន]
- ក្នុងពាក្យ ៤ព្យាង្គ "សូរសង្កត់" ឋិតនៅលើព្យាង្គទី ២និងទី ៤ :
  - កន្ទាំងបាយស [ក់ន ទាំង បាយ ស]
  - កញ្ជើបាយដាច [ក់ញ ជើ បាយ ដាច]

សូរសង្កត់ក្នុងភាសាខ្មែរ ពុំមែនសម្រាប់បំប្លែកន័យពាក្យនោះទេ តែសម្រាប់សម្គាល់ចុងបញ្ចប់ ពាក្យទៅវិញ ។

ឃ. ការបង្កើតពាក្យ : ក្នុងការបង្កើតពាក្យ ខ្មែរមានវិធីកំលាយពីរយ៉ាង គឺវិធីកំលាយដោយ ផ្នត់ដើមនិងវិធីកំលាយដោយផ្នត់ជែក ។

ផ្នត់ដើមឋិតនៅខាងដើមពាក្យឬស ។

- ផ្នត់ដើមអាចជាសទ្ទទម្រង់ [ព-] :

- [ក-] + ជះ	>	ខ្ជះ		[ប-] + គួ	>	ផ្គួ
- [ក-] + សោះ	>	ខ្សោះ		[ប-] + សាយ	>	ផ្សាយ
- [ក-] + ចាំង	>	ក្ចាំង		[ប-] + ងាក	>	ផ្ងាក
- [ច-] + បូត	>	ច្បូត		[ម-] + ចត់	>	ម្ចត់
- [ច-] + កាង	>	ឆ្កាង		[ម-] + ជួរ	>	ម្ជួរ
- [ត-] + ក្បៀប	>	ថ្ក្បៀប		[ស-] + រៀវ	>	ស្រៀវ
- [ត-] + រ៉ុយ	>	ត្រុយ		[ស-] + អាប់	>	ស្អាប់
- [ត-] + រៀប	>	ត្រៀប		[ស-] + ទុល	>	ស្ទុល

- ផ្គត់ដើមអាចជាព្យាង្គទម្រង់ [ពស-] :

- [ក-]	+	កាយ	>	កកាយ	[គ-]	+	គ្រាំ	>	គគ្រាំ
- [ក-]	+	កូរ	>	កកូរ	[ង-]	+	ងក់	>	ងងក់
- [ច-]	+	ចឹក	>	ចចឹក	[ជ-]	+	ជីក	>	ជជីក
- [ច-]	+	ច	>	ចាក់	[ញ-]	+	ញឹម	>	ញញឹម
- [ត-]	+	តួង	>	តតួង	[ទ-]	+	ទាក់	>	ទតាក់
- [ត-]	+	តះ	>	តតះ	[ប-]	+	ប៉ាច់	>	ប៉ប៉ាច់
- [ប-]	+	បោស	>	បបោស	[ព-]	+	ព្រាយ	>	ពព្រាយ
- [ប-]	+	បក់	>	បបក់	[ម-]	+	មីះ	>	ममីះ
- [ស-]	+	សិត	>	សសិត	[រ-]	+	យោង	>	រយោង

- ផ្គត់ដើមអាចជាព្យាង្គទម្រង់ [ពសព-]

- [ក់ង-]	+	វៀច	>	កង្វៀច	[ក់ម-]	+	បាក់	>	កំបាក់
- [ច់ម-]	+	ទយ	>	ចំទយ	[គ់ម-]	+	រល	>	គំរល
- [ប់ន-]	+	ដើរ	>	បណ្តើរ	[ច់ង-]	+	អូរ	>	ចង្អូរ
- [ប់ម-]	+	បាក់	>	បំបាក់	[ជ់ញ-]	+	ជក់	>	ជញ្ជក់
- [ស់ម-]+		បក	>	សំបក	[ជ់ម-]	+	ទប់	>	ជំទប់
- [អ់ង-]+		គប់	>	អង្គប់	[ដ់ង-]	+	ការ	>	ដង្ការ
- [អ់ង-]+		រុត	>	អង្រុត	[រ់ង-]	+	ទិល	>	រង្វិល
- [អ់ម-]+		ពុះ	>	អំពុះ	[ល់ម-]	+	ហាត់	>	លំហាត់

- ផ្គត់ដើមអាចជាព្យាង្គទម្រង់ [ពពស-]

- [ប្រ-]	+	ទាញ	>	ប្រទាញ	[ក្រ-]	+	ចាប់	>	ក្រចាប់
- [ប្រ-]	+	ចាក់	>	ប្រចាក់	[គ្រ-]	+	ជួរ	>	គ្រជួរ
- [ស្រ-]	+	កា	>	ស្រកា	[ច្រ-]	+	ពើង	>	ច្រពើង
- [ស្រ-]	+	ងាក	>	ស្រងាក	[ត្រ-]	+	ដុស	>	ត្រដុស

ផ្គត់ជែកបិតនៅកណ្តាលពាក្យឬស ។

- ផ្គត់ជែកអាចជាសទ្ទទម្រង់ [-ព-]

- [-ន-]	+	កើយ	>	ខ្នើយ	[-ម-]	+	កើត	>	ខ្មើត
- [-ន-]	+	ចុក	>	ឆ្នុក	[-ម-]	+	ចាំ	>	ឆ្នាំ

- [-ប-] + លង > ល្បង [-ម-] + ជួញ > ឈ្មួញ
- [-ប-] + លោត > ល្បោត [-ម-] + សេរ > ស្មេរ

• ផ្តត់ជែកអាចជាសទ្ទទម្រង់ [-ស / ព-]

- [-អ៊ិ ន-] + រាប > រនាប [-អ៊ិ ប-] + រង > របង
- [-អ៊ិ ន-] + រាំង > រនាំង [-អ៊ិ ប-] + រាំង > របាំង

• ផ្តត់ជែកអាចជាសទ្ទទម្រង់ [-សព-]

- [-អ៉ម-] + ត្រូវ > តំរូវ [-អ៊ិ៉ង-] + ព្រោះ > ពង្រោះ
- [-អ៉ម-] + ត្រាយ > តំរាយ [-អ៊ិ៉ង-] + ធ្វើ > ទង្វើ
- [-អ៉ន-] + ខ្លះ > កន្លះ [-អ៉ង-] + ខ្វាក់ > កង្វាក់
- [-អ៊ិ៉ម-] + ជ្រុះ > ជំរុះ [-អ៉ង-] + ខ្វះ > កង្វះ
- [-អ៊ិ៉ម-] + ជ្រាប > ជំរាប [-អ៉ន-] + ខ្លះ > កន្លះ
- [-អ៊ិ៉ន-] + ភ្លឺ > ពន្លឺ [-អ៉ន-] + ភ្លឺក > ពន្លឺក

• ផ្តត់ជែកអាចជាព្យាង្គនិងសទ្ទទម្រង់ [-សព / ព-]

- [-អ៉ ម / ន-] + កក > កំណក [-អ៊ិ៉ ម / ន-] + គិត > គំនិត
- [-អ៉ ម / ន-] + សោក > សំណោក [-អ៊ិ៉ ម / ន-] + ពិត > ពំនិត

ង. ថ្នាក់ពាក្យ : ម្យ៉ាងទៀតខ្មែរយើង មានថ្នាក់ពាក្យមួយបែប គឺ "រនាប់" ។ រនាប់ មានច្រើនយ៉ាងដូចជា :

- ក្បាល សម្រាប់ប្រើក្នុងការរាប់សត្វ សៀវភៅ : មាន់ប្រាំក្បាល សៀវភៅមួយក្បាល ។
- នឹម សម្រាប់ប្រើក្នុងការរាប់សត្វសម្រាប់ទឹម : គោមួយនឹម(មួយគូពីរក្បាល)ក្របីពីរនឹម ។
- អង្គ សម្រាប់ប្រើក្នុងការរាប់ព្រះសង្ឃ : ព្រះសង្ឃដប់អង្គ ។
- ចំរៀក សម្រាប់រាប់អ្វីៗ ដែលបានមកអំពីការច្រៀក : ត្រីងៀតមួយចំរៀក ឈើពីរចំរៀក ។

ចំណែកគុណនាមខ្មែរវិញ យើងអាចប្រើជាកិរិយាស្តួលរបស់ល្អះបាន ។ យើងហៅថា "គុណនាមកិរិយា" ។

- កុមារសុក ឧស្សាហ៍ណាស់ ។
- កសិករភូមិយើង ប៉ិនប្រសប់ ក្នុងការងារស្រែចំការ ។

ជំនួយកិរិយាមានច្រើនយ៉ាង តែជំនួយខាងស្តាំកិរិយាមានលក្ខណៈគួរចាប់អារម្មណ៍ :

- ជំនួយប្រាប់ទិសដៅ : សុកចេញទៅហើយ ។
- ជំនួយប្រាប់លទ្ធផល : វារកឃើញ ។

- ជំនួយប្រាប់លទ្ធភាព : វាដើរកើត ។

ច. សម្ព័ន្ធ : ភាសាខ្មែរជាភាសាអរិភត្តិ ។ ពាក្យខ្មែរពុំប្រែប្រួលយ៉ាងនេះ យ៉ាងនោះម្តងតាមមុខងារវាឡើយ គឺវានៅតែដដែលតាមជាតិកំណើតរបស់វាជានិច្ច ។ ទីកន្លែងរបស់ពាក្យបញ្ជាក់ឱ្យដឹងមុខងាររបស់វា ។

ក្នុងកន្សោមនាមខ្មែរយើង ធាតុបង្គោល គឺនាមធាតុទីមួយ ។ ឯធាតុរណប គឺធាតុទីពីរនិងធាតុបន្តខាងស្តាំ ។

- តុល្អ "តុ" ជាធាតុបង្គោល ឯ "ល្អ" ជាធាតុរណប ។
- តុល្អនេះ "តុ" ជាធាតុបង្គោល ឯ "ល្អ" ជាធាតុរណប ។

ក្នុងកន្សោមកិរិយាខ្មែរយើង ធាតុបង្គោល គឺកិរិយាធាតុទីមួយ ។។ ឯធាតុរណប គឺធាតុទីពីរទីបី ... ដូចជា កម្មបទ គុណកិរិយា កម្មដទៃទៀតជាដើម ។

- សំដើរលឿន ។
- **វាហូបបាយយឺតៗ ។**

ក្នុងកន្សោមគុណនាម គុណនាមជាធាតុទីមួយ គុណកិរិយាជាធាតុរណប :

- គាត់មានចំណេះជំនាញណាស់ ។
- យើងមានចម្លាក់ល្អៗណាស់ ។

ក្នុងកន្សោមកិរិយា គុណកិរិយាទីមួយជាធាតុបង្គោល គុណកិរិយាទីពីរជាធាតុរណប :

- ពួសំ ធ្វើការលឿនណាស់ ។
- វាសរសេរយឺតពេក ។

ចំពោះល្បះខ្មែរ ។ ***ឧទាហរណ៍ :***

- តុសនេះ ខ្ពស់ណាស់ ។ ("ខ្ពស់" ជាគុណនាមកិរិយា)
- តុនេះ ស ល្អណាស់ ។ ("ស" ជាគុណនាម កិរិយា ឯ "ល្អ" ជាគុណកិរិយា)
- ភ្លៀងធ្លាក់យ៉ាងខ្លាំង (ភ្លៀងជានាម) ។
- មេឃភ្លៀងយ៉ាងខ្លាំង (ភ្លៀងជាកិរិយា) ។

ដូចនេះ ទីកន្លែងរបស់ពាក្យ ក្នុងកន្សោមពាក្យឬក្នុងល្បះអាចកំណត់ថ្នាក់របស់ពាក្យ (នាម គុណនាម គុណកិរិយា ...) ។

តន្ត្រីភាពនៃសូរភាសាខ្មែរបង្កើតបានភាពពីរោះ ។ ក្នុងភាសាខ្មែរ តន្ត្រីភាពនេះកើតឡើងពីសូរសួនគ្នានៃ :

- សទ្ទ ព្យាង្គ និងពាក្យរាយ ពាក្យកម្រងកែវ
  - វិធីរណ្តំ : ពពែ កកាយ សសិត គ្រប់គ្រាន់ ទាក់ទង ... ។
  - វិធីជួន : តយង៉ាយ ត្រឡែងកែង ស៊ុលគឃុល ដើរហើរ ... ។
  - វិធីផ្ទួន : ស្រគុកគុក ទ្រមាកមាក ត្រតៗ អៅៗ ... ។
  - វិធីជួនរណ្តំ : ពិតពិលរមិលមើល សំបួងសង្រួង ... ។
  - វិធីផ្ទួនរណ្តំ : គ្រលឹងគ្រលោង ស្រគត់ស្រគំ ត្រឡុងត្រឡាយ ... ។
  - វិធីផ្ទួនជួនរណ្តំ : កុំខ្វើកតាមខ្យល់ កុំខ្វល់តាមរលក ... ។
- ពាក្យរាយ ពាក្យកម្រងកែវ
  - ពាក្យរាយ : ពពែ ពពក ទទាក់ទទាម គ្រលឹងគ្រលោង ... ។
  - ពាក្យកម្រងកែវ (ពាក្យសួរសួនសេរី) : ជូជកស្រដី "ឱ! សំណាញ់អើយ! ម្តេចក៏ស្រដីរឹងរូសប្រទូសពន់ប្រមាណ យល់តែឯងបានធ្ងន់ពាយងាយទំនងតែនឹងបាញ់។ នែសំណាញ់អើយ! រីអញនេះពុំមែនជាស្នូមយាចកតាមមកសុំទាននោះទេ។ ហៃសំណាញ់អើយ! អញជាត្រកូលព្រាហ្មណ៍ធំឧត្តមប្រសើរក្រៃលែង ព្រាហ្មណ៍ផងទាំងឡាយអញតែងនឹកគិតការព្រះរាជពិធីទាមប្រពៃណីបុរាណ ... ។
  - សុភាសិត : តក់ៗពេញបំពង់ ឆុងៗកំពប់អស់។
  - ពាក្យបណ្តៅ : ឯកអង្គទ្រង់នាមឯក ខ្ពស់អនេក ទាបជាងស្មៅ។
  - អត្ថបទរឿង : រីឯឈើផងទាំងឡាយសងខាងផ្លូវ ប្រកបនីនូវផលាផល។
  - ពាក្យរៀល : ចេះមិនឈ្នះត្រង់ ត្រង់មិនឈ្នះទាល់ កលមិនឈ្នះគិត វិទ្ធិមិនឈ្នះរោគ ... ។

(ដកស្រង់ចេញពីវិវត្តន៍នៃភាសាខ្មែរ ក្នុងសៀវភៅអរិយធម៌ខ្មែរឆ្នាំ ២០០៥ សូមុយឃៀង)

សំណួរ

១. តើភាសាខ្មែរមានវិវត្តន៍ប៉ុន្មានលើក ? ចូរបង្ហាញពីស្ថានភាពភាសាខ្មែរតាំងពីសម័យអាណានិគមបារាំងនិងសម័យក្រោយមកទៀតតាមរយៈអត្ថបទនេះ។

២. ក្នុងភាសាខ្មែរ គេអាចចែកសូរស្រៈបានប៉ុន្មានយ៉ាង ? តើមានអ្វីខ្លះ ?

៣. តើគេអាចស្គាល់មូលភេទ អ-អ៊ិ អាចដោយប្រការណាខ្លះ ? ចូររកឧទាហរណ៍មកបញ្ជាក់។

៤. បើយោលទៅតាមអត្ថបទនេះ តើពាក្យខ្មែរ អាចបង្កើតដោយវិធីណាខ្លះ ? ចូរបង្ហាញពីវិធីនីមួយៗភ្ជាប់ជាមួយឧទាហរណ៍មកបញ្ជាក់។

៥. ដូចម្តេចហៅថា វិធីជួនរណ្តំ វិធីផ្ទួនរណ្តំ វិធីផ្ទួនជួនរណ្តំ ? ចូររកឧទាហរណ៍មកបញ្ជាក់ ដោយកត់សូរឱ្យត្រឹមត្រូវ។

៦. ចូរអ្នកធ្វើការប្រៀបធៀបរវាងវិធីជួនរណ្តំនិងវិធីផ្ទួនរណ្តំ ហើយវិធីផ្ទួននិងផ្ទួនជួនរណ្តំ។



សំយោគទស្សន:

សំយោគទស្សន: គឺជាការប្រមូលយកគំនិត ឬអត្ថន័យនៃទស្សន:ដទៃទៀតមកធ្វើជាមូលដ្ឋាន ក្នុងការវិភាគបញ្ហាណាមួយឱ្យមានភាពសមហេតុផល។ រាល់ព្រឹត្តិការណ៍ដែលកើតមាននៅក្នុងសង្គម មានការសំដែងខុសៗគ្នា អាស្រ័យទៅលើចំណេះដឹង ស្ថានភាពរបស់មនុស្សម្នាក់។ ដូចនេះ ដើម្បីជៀសផុតពីការបញ្ចេញទស្សន:ខុសទៅលើហេតុការណ៍ណាមួយ គេចាំបាច់ស្វែងយល់ពីព្រឹត្តិការណ៍ដទៃទៀត ដើម្បីសិក្សាសំយោគប្រមូលផ្តុំមកធ្វើជាមូលដ្ឋានសម្រាប់វិភាគ។

ចូរអ្នកធ្វើការសង្កេតលើទស្សន: ដែលធ្វើការសំយោគលើទស្សន:បញ្ហាដើមកំណើតជាតិខ្មែរ :

មានសម្មតិកម្មជាច្រើន ដែលមិនចុះសម្រុងគ្នាលើបញ្ហាដើមកំណើតជាតិខ្មែរ។ អ្នកស្រាវជ្រាវខ្លះសរសេរថា ខ្មែរជាឥណ្ឌាទី ២ ដោយគេឃើញខ្មែរកាន់សាសនានិងទំនៀមទម្លាប់ខ្លះបែបឥណ្ឌា ដូចជា ពិធីកោរជុក ពិធីបូជាសពជាដើម។ អ្នកស្រាវជ្រាវខ្លះទៀត បានអះអាងថា នៅសម័យបុរេប្រវត្តិសាស្ត្រ ខ្មែរបានធ្វើដំណើរពីទិសខាងជើង គឺពីប្រទេសទីបេ ចុះមកតាំងលំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ ទន្ទឹមនឹងនេះ ក៏មានអ្នកប្រាជ្ញមួយចំនួនបានសន្និដ្ឋានថា ខ្មែរបានកកើតនៅលើតំបន់ទឹកដីឥណ្ឌូចិននេះ គ្រាន់តែបានទទួលឥទ្ធិពលពីវប្បធម៌ឥណ្ឌានៅសតវត្សទី ១ នៃគ្រិស្តសករាជតែប៉ុណ្ណោះ។

តើការពិតនៃបញ្ហាដ៏សំខាន់នេះ ស្ថិតនៅត្រង់ណា ? តើយើងមានភស្តុតាងអ្វីសម្រាប់គាំទ្រឬបដិសេធការវិភាគព្រឹត្តិការណ៍ខាងលើដែរឬទេ ?

ដោយសារតែអ្នកនិពន្ធបរទេសមួយចំនួន បានសង្កេតឃើញថា ខ្មែរប្រកាន់សាសនាឥណ្ឌា គឺព្រាហ្មណ៍សាសនានិងព្រះពុទ្ធសាសនា ហើយថែមទាំងបានប្រើអក្សរសំស្ក្រឹតនិងទំនៀមទម្លាប់ឥណ្ឌាខ្លះ ដើម្បីគ្រប់គ្រងប្រទេស ដោយយករបបរាជានិយមជារបបនយោបាយ ទើបមានអ្នកនិពន្ធខ្លះសរសេរថា ខ្មែរជាឥណ្ឌាទី ២ "ជនជាតិខ្មែរកាសេមៀរបានរត់ចេញពីប្រទេសកំណើតរបស់ខ្លួន ហើយបានចូលមកនៅក្នុងទឹកដីខ្មែរសព្វថ្ងៃ"។ នេះជាមតិរបស់លោក **អាដេម៉ា ឡឺក្លែ** និងលោកបណ្ឌិត **ឆត្រាប្រេមឫទ្ធី**។ អ្នកនិពន្ធខ្លះទៀត ថែមទាំងហ៊ានអះអាងថា ខ្មែរមានទីតាំងនៅជើងភ្នំទីបេចុះមកភូមិភាគអាស៊ីអាគ្នេយ៍ នាដើមសតវត្សទី ១នៃគ.ស. ដូចជាទស្សន:របស់លោក **ហាង់ រីខេង**និងលោក **អេ ចែនអាយម៉ូនីញ្ញ**។រីឯអ្នកវិភាគវិទ្យាសាស្ត្រក៏មានការយល់ឃើញខុសប្លែកពីមតិខាងលើ។ តាមទ្រឹស្តីរបស់លោកវេជ្ជបណ្ឌិត ជក **អូលីវីយេ** "ខ្មែរជាជនជាតិពិសេសមួយ ដែលស្ថិតនៅក្នុងអំបូរ មនខ្មែរ ហើយជនជាតិនេះបានកើតឡើងនិងរស់នៅលើជ្រោយឥណ្ឌូចិននេះតែម្តង ខុសពីជនជាតិយួនចិន ឡាវ និងភូមា ដែលមានទីលំនៅដើមរបស់ខ្លួននៅស្រុកចិនភាគខាងត្បូង ហើយស្ថិតក្នុងអំបូរចិន

បុរាណ ឬម៉ុងហ្គោលឡូអ៊ីត" ។ ម្យ៉ាងទៀតអ្នកស្រាវជ្រាវនេះ បានបន្ថែមថា អំបូរមនខ្មែរកើតពីការកាត់ផ្សំរវាងពួកមេឡានេស៊ីយាងនិងពួកឥណ្ឌូនេស៊ីយាង ដែលរស់នៅពាសពេញលើសុវណ្ណភូមិនិងនៅលើកោះនានានៃឈូងសមុទ្រថ៉ាស៊ីភិច មានសម្បុរខ្មៅស្រអែម ។ បុព្វហេតុដែលបណ្តាលឱ្យមានគេហ៊ានសន្និដ្ឋានបែបនេះ គឺមកពីគេរកឃើញលលាដ៍ក្បាលដែលមានលក្ខណៈ មេឡានេស៊ីយាង មានអាយុចាស់ជាង លលាដ៍ក្បាលនៃពួកឥណ្ឌូនេស៊ីយាង ។

តាមពិតលើផ្នែកលើមនុស្សជាតិវិទ្យា យើងអាចសន្មតថា ពួកឥណ្ឌូនេស៊ីយាង គឺពួកមនខ្មែរតែម្តង ពីព្រោះមនខ្មែរស្ថិតនៅក្នុងក្រុមមនុស្សឥណ្ឌូនេស៊ីយាង គ្រាន់តែមានភាសាខុសគ្នាប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពួកគេជាលទ្ធផលនៃការវិវឌ្ឍកុលសម្ព័ន្ធនានា ដែលបានរស់នៅតៗគ្នាតាំងពីសម័យមុនមក ។ មូលហេតុនេះ បណ្តាលមកពីការឃ្លាតគ្នាជាច្រើនម៉ឺនឆ្នាំ ក្រោយពីជ្រោយឥណ្ឌូចិនត្រូវបានកាត់ផ្តាច់ចេញពីអាំងស៊ូឡាំងដោយទឹកជំនន់ដែលជាលទ្ធផលនៃការផ្លាស់ប្តូរអាកាសធាតុពីត្រជាក់ទៅជាក្តៅដូចសព្វថ្ងៃ ។

ចំពោះលោកវេជ្ជបណ្ឌិត ជក អូលីវីយេ ខ្មែរមិនមែនជាជនជាតិចិន យួន ឬឥណ្ឌាទេ ។ សាសន៍ខ្មែរស្ថិតនៅក្នុងអំបូរមនខ្មែរ ហើយចំពោះអ្នកប្រាជ្ញរូបនេះ ក្នុងពាក្យពួជសាសន៍ឥណ្ឌូនេស៊ីយាង យើងត្រូវបញ្ចូលជនជាតិឥណ្ឌូនេស៊ីយាង ដែលសព្វថ្ងៃនៅប្រទេសឥណ្ឌូនេស៊ី មនខ្មែរ និងពួកខ្មែរលើទាំងអស់ដូចជា ពួកព្នង ស្ទួច ខា រដែ ចារាយ កួយ ឬព័រ ព្រមទាំងពួកមនុស្សដែលរស់នៅតាមព្រៃភ្នំភីលីពីនដូចជា ពួកកាសាយសួយនិងពួកដាយាក នៅប្រទេសឥណ្ឌូនេស៊ីផង ។ ការសន្និដ្ឋានរបស់លោកវេជ្ជបណ្ឌិតខាងលើនេះ ពឹងផ្អែកទាំងស្រុងលើការសិក្សាយ៉ាងហ្មត់ចត់នៃឆ្អឹងខ្មោចនិងលលាដ៍ក្បាល ដែលគេរកឃើញនៅភូមិភាគឥណ្ឌូចិន ។ ជាការពិតណាស់ ពួកមេឡានេស៊ីយាង ជាបុព្វបុរសនៃឥណ្ឌូនេស៊ីយាងមនខ្មែរ ។ ម្យ៉ាងទៀត មនុស្សបុរាណទាំងនេះ ថ្វីត្បិតតែរស់នៅដាច់ឆ្ងាយពីគ្នាក៏ដោយ ក៏ប៉ុន្តែស្ថិតនៅក្នុងក្រុមមនុស្សដែលមានពួជសាសន៍តែមួយ ។

ជាពិសេសទៅទៀត កត្តាដ៏សំខាន់មួយដែលបញ្ជាក់ពីការឯកភាព ផ្នែកពួជសាសន៍នៃជនជាតិមនខ្មែរ គឺប្រភេទឈាមម្យ៉ាង អេម៉ូក្លូប៊ីនអ៊ី (Hémoglobin-E) ដែលគេបានរកឃើញនៅក្នុងសរសៃឈាមរបស់ពួកគេ ។ ជាពិសេស ខ្មែរដែលរស់នៅតាមខ្ពង់រាប ឬតាមកោះដែលមិនបានទទួលឥទ្ធិពលវប្បធម៌ពីក្រៅនិងឥទ្ធិពលពីរង្វង់ព្រំដែនខ្មែរបច្ចុប្បន្ននិងមានជនជាតិខ្មែរយើងជាច្រើនលាននាក់ទៀតដែលកំពុងរស់នៅប្រទេសថៃនិងប្រទេសវៀតណាមខាងត្បូង ។ សហគមន៍ខ្មែរទាំងនោះ នៅរក្សាទំនៀមទម្លាប់ភាសារបស់ខ្លួនយ៉ាងជាប់លាប់នៅឡើយ ។ សូមបញ្ជាក់ថា ជនជាតិចាមដែលសព្វថ្ងៃនេះកាន់សាសនាអ៊ីស្លាមក៏មានប្រភេទឈាមដ៏ពិសេសនេះដែរ ។

(ដកស្រង់ចេញពីប្រវត្តិសាស្ត្រកម្ពុជាពីបុព្វសម័យ ដល់សតវត្សទី ៨ និពន្ធដោយបណ្ឌិត ម. គ្រាណេ ឆ្នាំ ១៩៩៦)

អត្ថបទដកស្រង់នេះ នាំឱ្យយើងមើលឃើញពីទស្សនៈរបស់អ្នកស្រាវជ្រាវដូចតទៅ ៖

- អ្នកនិពន្ធខ្លះថា ខ្មែរជាឥណ្ឌាទី ២ ដោយឃើញថាខ្មែរកាន់សាសនានិងទំនៀមទម្លាប់បែបឥណ្ឌា ដូចជា ពិធីកោរជុក ពិធីបូជាសពជាដើម ។
- អ្នកស្រាវជ្រាវខ្លះទៀត បានអះអាងថា នៅសម័យបុរេប្រវត្តិសាស្ត្រ ខ្មែរបានធ្វើដំណើរពីទិសខាងជើង គឺពីប្រទេសទីបេចុះមកតាំងលំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ ។
- អ្នកប្រាជ្ញមួយចំនួនបានសន្និដ្ឋានថា ខ្មែរកើតនៅតំបន់ទឹកដីឥណ្ឌូចិននេះ គ្រាន់តែបានទទួលឥទ្ធិពលវប្បធម៌ពីពួកឥណ្ឌានៅសតវត្សទី ១ នៃគ្រិស្តសករាជតែប៉ុណ្ណោះ ។
- លោក អាដេម៉ា ឡឺគ្លែនិងលោកបណ្ឌិតឆត្រាប្រេមឫទ្ធី សន្និដ្ឋានថា ខ្មែរជាឥណ្ឌាទី ២ "ជនជាតិខ្មែរកាសេមៀរបានរត់ចេញពីប្រទេសកំណើតរបស់ខ្លួន ហើយបានចូលមកនៅក្នុងទឹកដីខ្មែរសព្វថ្ងៃ" ។
- លោក ហាង់ រីខេងនិងលោក អេ ចែនអាយម៉ូនីញ្ញ អះអាងថាខ្មែរមានទីតាំងនៅជើងភ្នំទីបេចុះមកភូមិភាគអាស៊ីអាគ្នេយ៍ នាដើមសតវត្សទី ១នៃគ.ស. ។
- លោកវេជ្ជបណ្ឌិត ជក អូលីវីយេថា ៖
  - ខ្មែរជាជនជាតិពិសេសមួយ ដែលស្ថិតនៅក្នុងអំបូរមនខ្មែរ ជនជាតិនេះបានកើតឡើងនិងរស់នៅលើជ្រោយឥណ្ឌូចិននេះតែម្តង ខុសពីជនជាតិយួន ចិន ឡាវ និងភូមា មានទីលំនៅដើមនៅស្រុកចិនភាគខាងត្បូង ហើយស្ថិតក្នុងអំបូរចិនបុរាណ ឬម៉ុងហ្គោលឡូអ៊ីត ។
  - អំបូរមនខ្មែរកើតពីការកាត់ផ្សំរវាងពួកមេឡានេស៊ីយាងនិងពួកឥណ្ឌូនេស៊ីយាង ដែលរស់នៅពាសពេញលើសុវណ្ណភូមិនិងនៅលើកោះនៃឈូងសមុទ្រប៉ាស៊ីភិចមានសម្បុរខ្មៅស្រអែម ។
  - បុព្វហេតុដែលបណ្តាលឱ្យគេហ៊ានសន្និដ្ឋានបែបនេះ គឺមកពីគេរកឃើញលលាដ៍ក្បាលដែលមានលក្ខណៈមេឡានេស៊ីយាងនៅឥណ្ឌូចិន ។ លលាដ៍ក្បាលនៃពួកមេឡានេស៊ីយាងមានអាយុចាស់ជាងលលាដ៍ក្បាលនៃពួកឥណ្ឌូនេស៊ីយាង ។
- បើផ្អែកលើមនុស្សជាតិវិទ្យា គេអាចសន្និដ្ឋានថា ៖
  - ពួកឥណ្ឌូនេស៊ីយាង គឺពួកមនខ្មែរតែម្តង ពីព្រោះមនខ្មែរស្ថិតនៅក្នុងក្រុមមនុស្សឥណ្ឌូនេស៊ីយាង គ្រាន់តែមានភាសាខុសគ្នាប៉ុណ្ណោះ ។
  - ពួកគេជាលទ្ធផលនៃការវិវឌ្ឍកុលសម្ព័ន្ធនានា ដែលបានរស់នៅតៗគ្នា តាំងពីសម័យមុនមក ។ មូលហេតុនេះ បណ្តាលមកពីការឃ្លាតគ្នាជាច្រើនម៉ឺនឆ្នាំ ក្រោយពីជ្រោយឥណ្ឌូចិនត្រូវ

បានកាត់ផ្តាច់ចេញពីអាំងស៊ូឡាំង ដោយទឹកជំនន់ដែលនាំមកនូវលទ្ធផលនៃការផ្លាស់ប្តូរ អាកាសធាតុពីត្រជាក់ទៅជាក្តៅដូចសព្វថ្ងៃ ។

- វេជ្ជបណ្ឌិត ជក អូលីវីយេថា ខ្មែរមិនមែនជាជនជាតិចិន យួន ឬឥណ្ឌាទេ ។ សាសន៍ខ្មែរស្ថិតក្នុងអំបូរមនខ្មែរ ហើយចំពោះអ្នកប្រាជ្ញរូបនេះ ក្នុងពាក្យពួជសាសន៍ឥណ្ឌូនេស៊ីយាង យើងត្រូវបញ្ចូលជនជាតិឥណ្ឌូនេស៊ីយាង ដែលសព្វថ្ងៃនៅប្រទេសឥណ្ឌូនេស៊ីមនខ្មែរនិងពួកខ្មែរលើទាំងអស់ដូចជា ពួកឮង សួច ខា រដែ ចារាយ កួយ ឬព័រព្រមទាំងពួកមនុស្សដែលរស់នៅតាមព្រៃភ្នំតីលីពីនដូចជា ពួកកាសាយ សួយ និងពួកដាយាក នៅប្រទេសឥណ្ឌូនេស៊ីយាងផង ។

ការសន្និដ្ឋានរបស់លោកវេជ្ជបណ្ឌិតខាងលើនេះ ពឹងផ្អែកទាំងស្រុងលើការសិក្សាយ៉ាងហ្មត់ចត់នៃឆ្អឹងខ្មោចនិងលលាដ៍ក្បាល ដែលគេរកឃើញនៅភូមិភាគឥណ្ឌូចិន ។ ជាការពិតណាស់ ពួកមេឡានេស៊ីយាង ជាបុព្វបុរសនៃពួកឥណ្ឌូនេស៊ីយាងមនខ្មែរ ។

ម្យ៉ាងទៀត មនុស្សបុរាណទាំងនេះ ថ្វីត្បិតតែរស់នៅដាច់ឆ្ងាយពីគ្នាក៏ដោយ ក៏ប៉ុន្តែស្ថិតនៅក្នុងក្រុមមនុស្សដែលមានពូជសាសន៍តែមួយ ។

តាមទស្សនៈអ្នកស្រាវជ្រាវខាងលើនេះ អាចឱ្យយើងធ្វើការសំយោគចំពោះដើមកំណើតខ្មែរដូចខាងក្រោមនេះ :

- ដូច្នេះខ្មែរស្ថិតនៅក្នុងអំបូរមនខ្មែរ ហើយពួកឥណ្ឌូនេស៊ីយាងជាពួកមនខ្មែរតែម្តង ព្រោះឥណ្ឌូចិនក្នុងសម័យបុរាណនៅជាប់នឹងអាំងស៊ូឡាំង ជាពិសេសពួកគេមានប្រភេទឈាមម្យ៉ាង គឺ អេម៉ូក្លូប៊ីន អ៊ី (Hémoglobin E) ដែលគេបានរកឃើញនៅក្នុងសរសៃឈាមរបស់ពួកគេ ដូចខ្មែរដែរ ។ ពោលគឺខ្មែរដែលរស់នៅតាមខ្ពង់រាប ឬតាមកោះមិនបានទទួលឥទ្ធិពលវប្បធម៌ពីក្រៅ ហើយខ្មែរដែលរស់នៅតាមវាលទំនាបសុទ្ធសឹងតែមានប្រភេទឈាមតែមួយ ។

ដូច្នេះ ដើម្បីនិយាយសំយោគទស្សនៈមួយចំនួនឱ្យបានត្រឹមត្រូវយើងគប្បី :

- ប្រមូលទស្សនៈ ព័ត៌មាន ព្រឹត្តិការណ៍ ... ដែលមាននៅក្នុងស្នាដៃ ឬជាកម្រងអត្ថបទ ។
- ដកស្រង់គំនិត ឬទស្សនៈដែលជាសម្មតិកម្មដាក់តាមលំដាប់ ដើម្បីធ្វើជាមូលដ្ឋានក្នុងការវិភាគ ឬការពិចារណា ។
- ទាញសេចក្តីសន្និដ្ឋានមួយយ៉ាងសមស្រប ចេញពីទស្សនៈទាំងនោះ ដោយផ្តល់យោបល់បន្ថែមបើចាំបាច់ ។

លំហាត់

ចូរអ្នកចែកជាក្រុម ដើម្បីនិយាយសំយោគទស្សនៈមួយចំនួនឱ្យបានត្រឹមត្រូវ ដោយលើកយកគំនិតក្នុងអំណានទី ២ "វិវឌ្ឍន៍នៃភាសាខ្មែរ" ។



តែងសេចក្តីបែបពិភាក្សា

តែងសេចក្តីបែបពិភាក្សា ជាតែងសេចក្តីមួយបែបដែលចោទឡើងនូវបញ្ហាឬលើកឡើងនូវប្រធានបទមួយដែលអ្នកសរសេរត្រូវពិភាក្សាដោយមតិស្របនិងមតិផ្ទុយ ហើយត្រូវមានការអះអាងយ៉ាងរឹងមាំ។ មតិស្របនិងមតិផ្ទុយត្រូវប្រឈមជាមួយបញ្ហាជានិច្ច ព្រោះវាបានបណ្តុះការត្រិះរិះពិចារណានិងអភិវឌ្ឍប្រាជ្ញាញាណរបស់សិស្ស ការសង្កេតពិនិត្យ វិនិច្ឆ័យ ការរិះគន់ ការពិសោធ ការស្រាវជ្រាវជាដើម។ ប្រធានបែបនេះតម្រូវឱ្យយើងវែកញែកហេតុផល រកខុស រកត្រូវ រកល្អ ឬអាក្រក់ មានប្រយោជន៍ឬគ្មានប្រយោជន៍... ដើម្បីធ្វើការវិនិច្ឆ័យថាមតិណាមួយត្រឹមត្រូវជាង។ ដោយហេតុថា មតិប្រធានទាំងនោះ :

- ជួនកាលមតិទី ១ (មតិស្រប) ជាមតិត្រឹមត្រូវ។
- ជួនកាលមតិទី ២ (មតិផ្ទុយ) ជាមតិត្រឹមត្រូវ។
- ជួនកាលមតិទី ១ (មតិស្រប) និងមតិទី ២ (មតិផ្ទុយ) រួមគ្នាទើបត្រឹមត្រូវ។
- ជួនកាលមតិទី ១ (មតិស្រប) និងមតិទី ២ (មតិផ្ទុយ) មិនទាន់ត្រឹមត្រូវទាំងពីរឬរួមគ្នាហើយមិនទាន់គ្រប់ជ្រុងជ្រោយទៀត ត្រូវបន្ថែមគំនិតដទៃទៀតទើបពេញលេញ។

ជាទូទៅប្រធានពិភាក្សាស្ថិតនៅលើគោលការណ៍នៃទ្រឹស្តីបដិសំយោគ ដែលមានធាតុទំនាស់បីធ្វើឱ្យរីកចម្រើន គឺ :

- មតិទី ១ ឬមតិស្រប
- មតិទី ២ ឬមតិផ្ទុយ
- មតិរួម ឬមតិសំយោគឬមតិពិភាក្សា

ប៉ុន្តែក្នុងករណីខ្លះទៀត មតិរួមឬមតិសំយោគនោះ អាចជាមតិពិភាក្សាទៅវិញ ប្រសិនបើក្នុងចំណោមមតិទី ១និងមតិទី ២មានមតិណាមួយខុសទាំងស្រុង ឬត្រូវទាំងស្រុង។ ក្នុងមតិទាំងបីនេះ មតិដែលអ្នកធ្វើតែងសេចក្តីលើកយកមកអះអាង មិនមែនជាមតិរបស់បុគ្គលបីនាក់នោះទេ។ មតិទាំងបីនេះស្ថិតនៅក្នុងផ្នែកតួសេចក្តី ដែលត្រូវធ្វើអធិប្បាយវែកញែក ដោយមានវិធីអនុវត្តយ៉ាងត្រឹមត្រូវ។

១. ចំពោះមតិទី ១ឬមតិស្រប : គឺជាមតិដែលអធិប្បាយពន្យល់សម្របសម្រួលតាមមតិប្រធានដោយមិនរកមតិជំទាស់ឡើយ។ ពោលគឺ អ្នកធ្វើតែងសេចក្តីត្រូវធ្វើការបកស្រាយឱ្យស្របទៅតាមមតិប្រធាន ទោះបីជាការគិតរបស់យើងមិនស្របជាមួយក៏ដោយ។

២. ចំពោះមតិទី ២ឬមតិផ្ទុយ : គឺជាមតិដែលអធិប្បាយអះអាងប្រឆាំងនឹងមតិរបស់ប្រធាន។ ក្នុងការបរិយាយផ្នែកនេះ យើងត្រូវទាញយកមតិដែលប្រឆាំងនឹងមតិរបស់ប្រធានមកអះអាងបញ្ជាក់ ទោះបីជាការគិតរបស់យើង មិនស្របនឹងមតិផ្ទុយនេះក៏ដោយ។

ប៉ុន្តែចំពោះមតិទី ២ ឬមតិផ្ទុយនេះ ជួនកាលគ្រាន់តែជាការបំពេញទៅលើគំនិតរបស់មតិស្របតែប៉ុណ្ណោះ មិនទាមទារឱ្យប្រឆាំងនឹងមតិទី ១ឬមតិស្របឡើយ ព្រោះមតិទី ១ឬមតិស្របនោះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។

៣. មតិរួមឬមតិសំយោគ : គឺជាការសំយោគរវាងមតិទី ១ (ឬមតិស្រប) និងមតិទី ២ ឬមតិផ្ទុយមកថ្លឹងថ្លែង ។ មតិនេះមានច្រើនបែបយ៉ាង ៖

- ជួនកាលមតិរួម ឬមតិសំយោគឱ្យតម្លៃទៅលើមតិទី ១ ឬមតិស្រប ហើយផាត់ចោលមតិទី ២ ឬមតិផ្ទុយ ។
- ជួនកាលមតិរួម ឬមតិសំយោគឱ្យតម្លៃទៅលើមតិទី ២ ឬមតិផ្ទុយ ហើយផាត់ចោលមតិទី ១ ឬមតិស្រប ។
- ជួនកាលមតិរួម ឬមតិសំយោគ ទាញយកចំណុចត្រឹមត្រូវលើមតិទី ១ ឬមតិស្របខ្លះហើយមតិទី ២ ឬមតិផ្ទុយខ្លះ ។
- ជួនកាលមតិរួម ឬមតិសំយោគផាត់ចោលមតិទី ១ ឬមតិស្របនិងផាត់ចោលមតិទី ២ ឬមតិផ្ទុយ ហើយលើកយកមតិថ្មីមួយទៀតមកបង្ហាញវិញ **(មិនសូវមាន)** ។
- ជួនកាលមតិរួម ឬមតិសំយោគដោះស្រាយទំនាស់រវាងមតិទី ១ ឬមតិស្របនិងមតិទី ២ឬមតិផ្ទុយ **(មិនសូវមាន)** ។

ការឱ្យតម្លៃទៅលើមតិណាមួយថា ជាមតិត្រឹមត្រូវ ឬសមហេតុសមផល គឺស្ថិតនៅលើសមត្ថភាពអ្នកតែងសេចក្តី យល់ប្រជានច្បាស់លាស់ គឺមានគំនិតនិងវប្បធម៌ទូលំទូលាយច្បាស់លាស់ ។

ប្រធាន : មានមតិមួយពោលថា "ចង់ក្លាយជាអរិយប្រទេស ត្រូវអាស្រ័យលើការអភិរក្សវប្បធម៌ជាតិ" ។ ឯមតិមួយទៀតយល់ថា "ចង់ក្លាយជាអរិយប្រទេសពិតប្រាកដ ត្រូវស្ថិតនៅលើការអភិវឌ្ឍនៃវប្បធម៌ជាតិ" ។

ចូរពិភាក្សា ដោយរកឧទាហរណ៍មកបញ្ជាក់ ។

ជាតិសាសន៍នីមួយៗ ក្នុងលោកយើងនេះ តែងតែមានបំណងចង់ឱ្យប្រទេសជាតិខ្លួនឈានទៅរកភាពជឿនលឿន រីកចម្រើនជានិច្ច ដើម្បីឱ្យក្លាយទៅជាអរិយប្រទេសដូចជាប្រទេសនានា ។ ស្របនឹងបំណងប្រាថ្នាខាងលើនេះក៏មានមតិមួយពោលថា "អរិយប្រទេស អាស្រ័យដោយការអភិរក្សវប្បធម៌ជាតិ" ។ ប៉ុន្តែមានមតិខ្លះទៀតយល់ថា "អរិយប្រទេសពិតប្រាកដ ស្ថិតនៅលើការអភិវឌ្ឍនៃវប្បធម៌ជាតិនោះ" ។

តើមតិទាំងពីរខាងលើនេះ មួយណាសមហេតុសមផលជាង ?

ជាបឋមនៃការបកស្រាយមតិប្រធានខាងលើនេះ យើងគប្បីស្វែងយល់ន័យរបស់ពាក្យគន្លឹះប្រធានជាមុន។ "អរិយប្រទេស" គឺសំដៅទៅលើប្រទេស ដែលប្រកបទៅដោយការរស់នៅមានសណ្តាប់ធ្នាប់ល្អ ឬជាសេចក្តីរុងរឿងរីកចម្រើនជឿនលឿន។ រីឯ "អភិរក្ស" គឺជាការថែរក្សាយ៉ាងម៉ត់ចត់ ដោយប្រុងប្រយ័ត្នឱ្យគង់វង្ស។ ចំណែក "ការអភិវឌ្ឍ" មានន័យថាកែច្នៃឬសម្របសម្រួលឱ្យមានភាពជឿនលឿន ហើយ "វប្បធម៌ជាតិ" គឺសំដៅទៅលើការផ្សំបណ្តុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីឱ្យបានលូតលាស់ចម្រើន។ ដូចនេះ តាមមតិទីមួយរបស់ប្រធានមានន័យថា ប្រទេសមួយដែលមានភាពរុងរឿង សណ្តាប់ធ្នាប់នៃការរស់នៅល្អ ដោយសារតែចេះថែរក្សាការពារវប្បធម៌ជាតិខ្លួនឱ្យគង់វង្ស។ ឯមតិទីពីរមានន័យថា ភាពរុងរឿងរបស់ប្រទេសជាតិមួយអាស្រ័យដោយមានការអភិវឌ្ឍវប្បធម៌ជាតិខ្លួនទើបប្រសើរ។

ជាការពិត មុននឹងវាយតម្លៃទៅលើជាតិសាសន៍ណាមួយ ឬប្រទេសណាមួយថា រុងរឿងឬអន់ថយ គឺស្ថិតនៅលើប្រវត្តិនៃជាតិសាសន៍នោះ ដែលមានវប្បធម៌ដ៏សម្បូរបែប យូរអង្វែង ជាពិសេសមានលក្ខណៈអភិរក្សយ៉ាងប្រសើរបំផុតស្របទៅតាមទម្រង់នៃវប្បធម៌បុរាណនោះ។ ប្រសិនបើគេពុំបានថែរក្សាវប្បធម៌ឱ្យបានត្រឹមត្រូវទេ ប្រទេសនោះនឹងអស់តម្លៃ ដោយគេគិតថាជាជាតិសាសន៍នោះទើបតែកើតឡើងក្រោយពីប្រទេសនានាក្នុងលោកជាមិនខាន។ ដោយហេតុថា ការអភិរក្សវប្បធម៌ជាតិ គឺជាការរក្សាបានន្ទូវព្រលឹងជាតិ ឬជាមោទនភាពជាតិ ជាសញ្ញាបញ្ជាក់ថា ជនជាតិខ្មែរជាជាតិសាសន៍មានមរតកវប្បធម៌ជាតិដ៏រុងរឿងជាយូរមកហើយ។ ប្រទេសខ្មែរយើងជាអរិយប្រទេសមួយក្នុងប្រវត្តិសាស្ត្រនៃសម័យអង្គរកន្លងមក។ ការប្រែក្លាយជាអរិយប្រទេសនេះ ក៏ដោយសារតែខ្មែរយើងចេះរក្សាបានល្អនូវវប្បធម៌ជាតិ។ រីឯលើវិស័យទំនៀមទម្លាប់វិញ ខ្មែរយើងក៏រក្សាបានរហូតបច្ចុប្បន្ននូវពិធីមង្គលការ ពិធីច្រត់ព្រះនង្គ័ល ឬការគោរពពាក្យសត្យាជាដើម។ ក្នុងអក្សរសិល្ប៍ខ្មែរក៏បានឆ្លុះឱ្យឃើញនៅក្នុងរឿង រាមកេរ្តិ៍ ហើយត្រូវបានបុព្វបុរសយើងចារឆ្លាក់នៅលើជញ្ជាំងប្រាសាទនានា។ ទិដ្ឋភាពទាំងនេះត្រូវបានជនជាតិខ្មែរប្រតិបត្តិតាម ហើយត្រូវបានគេចាត់ទុកថា ប្រទេសនេះជាអរិយប្រទេស ដែលធ្លាប់មានអរិយធម៌ដ៏រុងរឿងកន្លងមក។

សរុបមក ការអភិរក្សវប្បធម៌ជាតិ គឺជាការថែរក្សាវប្បធម៌ល្អៗរបស់ជាតិឱ្យមានជីវិតពីជំនាន់មួយទៅជំនាន់មួយឱ្យបានគង់វង្ស ទុកសម្រាប់មនុស្សជំនាន់ក្រោយ។

តើជាការពិតឬទេដែលគេយល់ថា ការអភិរក្សវប្បធម៌ជាតិ គឺជាកត្តាសំខាន់បំផុតក្នុងការកំណត់លក្ខណៈអរិយប្រទេសនោះ ?

ផ្ទុយទៅវិញ បើយោលទៅតាមមតិទីពីរយើងបានឃើញថា អរិយប្រទេសពិតប្រាកដ គឺស្ថិតនៅលើការអភិវឌ្ឍនៃវប្បធម៌ជាតិនោះទៅវិញ ពីព្រោះនៅលើលោកយើងនេះពុំមានជាតិសាសន៍ណាមួយដែលអាចរស់នៅដោយប៉ុមព័ទ្ធខ្លួនឯងបានទេ គឺចាំបាច់ត្រូវមានការប្រាស្រ័យទាក់ទងគ្នាតាមរយៈ វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ទៀតផង។ ហេតុនេះហើយ ទើបបណ្តាលឱ្យកើតមានការផ្តិតយកទិដ្ឋភាពនៃវប្បធម៌ផ្សេងៗនេះឡើង។ យ៉ាងណាមិញលើវិស័យអក្សរសាស្ត្រ ទោះបីខ្មែរយើងមានតាំងពីបុរាណកាលមកក៏ដោយ ក៏ខ្មែរជៀសមិនផុតពីការទទួលយក ឬបង្កើតបន្ថែមនូវពាក្យថ្មីៗទៀតដើម្បីសេចក្តីត្រូវការរបស់ខ្លួនដូចជា រ៉េស៊ីដង់ ណៃយ៉ូ ស៊ីតូផ្លាស ឬអ៊ីដ្រូសែនជាដើម។ រីឯជំនឿវិញ ជួនកាលគេក៏បានការកែប្រែចំណុចអន់ថយខ្លះៗ ដើម្បីឱ្យមានលក្ខណៈវិទ្យាសាស្ត្រនិងជឿនលឿន ព្រោះជំនឿខ្លះអាចនាំឱ្យយើងជួបបញ្ហាអវិជ្ជមានទៀតផង។

សរុបមក ការអភិវឌ្ឍវប្បធម៌ជាតិ គឺជាកិច្ចការសំខាន់ណាស់ ដើម្បីធ្វើឱ្យសង្គមមានការរីកចម្រើន ឬក្លាយជាអរិយប្រទេស។ ប៉ុន្តែការអភិវឌ្ឍវប្បធម៌ជាតិ ក៏មិនត្រូវធ្វើឱ្យបាត់បង់អត្តសញ្ញាណរបស់ជាតិខ្លួនឡើយ។

ជារួមទាំងមតិទីមួយនិងមតិទីពីរ សុទ្ធតែមានអំណះអំណាងសមស្រប។ ដើម្បីឱ្យសង្គមមួយក្លាយជាអរិយប្រទេសពិតប្រាកដ គេត្រូវចេះរក្សាការពារវប្បធម៌ជាតិផង ហើយត្រូវកែលំអចំណុចខ្វះចន្លោះនៃវប្បធម៌របស់ខ្លួនដែលនាំឱ្យសង្គមជាតិមិនជឿនលឿន ដើម្បីឱ្យវប្បធម៌មានភាពសម្បូរបែបហើយទាន់សម័យនិយមដោយធ្វើយ៉ាងណាឱ្យរក្សាបាននូវដួងព្រលឹងរបស់ជាតិ។ ការសម្រេចវិធីខាងលើនេះ ពិតជាអាចជំរុញឱ្យសង្គមជាតិទាំងមូលជឿនលឿនយ៉ាងពិតប្រាកដ។

ផ្អែកលើការបកស្រាយខាងលើនេះយើងអាចបញ្ជាក់បានថា មតិនីមួយៗនៃប្រធានសុទ្ធតែវិជ្ជមាន ប៉ុន្តែមិនទាន់ពេញលេញនៅឡើយទេ។ ទោះជាយ៉ាងនេះក្តី ក៏មតិទាំងពីរបស់ប្រធាននេះបានផ្តល់វិភាគទានក្នុងការអប់រំយុវជនយើងឱ្យចេះត្រិះរិះពិចារណាលើចំណុចវិជ្ជមាននិងអវិជ្ជមាន ដើម្បីជាទុនក្នុងការអភិរក្សនិងអភិវឌ្ឍន៍ជាតិយើងឱ្យសម្បូររុងរឿងដូចអរិយប្រទេសនានាលើសកលលោក។

គំរោងតែង

១ . ផ្តើមសេចក្តី

- លំនាំបញ្ហា : ជាតិសាសន៍នីមួយៗ តែងចង់ឱ្យប្រទេសជាតិខ្លួនឈានទៅដល់ភាពរុងរឿងដូចអរិយប្រទេសនានា។

- ចំណូលបញ្ហា : ជាមួយនឹងបំណងប្រាថ្នានេះ មានមតិមួយពោលថា "អរិយប្រទេស អាស្រ័យដោយការអភិរក្សវប្បធម៌ជាតិ" ។ ឯមតិមួយទៀតយល់ថា "អរិយប្រទេសពិតប្រាកដ ស្ថិតនៅលើការអភិវឌ្ឍនៃវប្បធម៌ជាតិនោះ" ។
- ចំណោទបញ្ហា : តើមតិទាំងពីរខាងលើនេះ មួយណាសមហេតុសមផលជាង ?

២ . គួរសេចក្តី

- ឃ្លាភ្ជាប់សេចក្តី : ជាបឋមនៃការបកស្រាយគំនិតប្រធាន យើងគប្បីស្វែងយល់ន័យពាក្យគន្លឹះប្រធានជាមុនសិន ។
- ពន្យល់ពាក្យ : "អរិយប្រទេស" ជាប្រទេសប្រកបដោយសណ្តាប់ធ្នាប់ល្អរុងរឿង ..." ។ "ការអភិរក្ស" គឺជាការថែរក្សាយ៉ាងម៉ត់ចត់មិនឱ្យបាត់បង់ភាពដើម ។ "ការអភិវឌ្ឍ" គឺការកែច្នៃឬសម្របសម្រួលឱ្យមានភាពជឿនលឿន ។ "វប្បធម៌ជាតិ" ការផ្សាំបណ្តុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីឱ្យបានលូតលាស់ចម្រើន ។
- ពន្យល់ន័យ : មតិទីមួយមានន័យថា ប្រទេសដែលភាពរុងរឿងដោយសារតែគេចេះថែរក្សាការពារវប្បធម៌ជាតិខ្លួនឱ្យគង់វង្ស មតិទីពីរមានន័យថា ភាពរុងរឿងរបស់ប្រទេសជាតិមួយអាស្រ័យមានការកែច្នៃវប្បធម៌របស់ជាតិខ្លួន ។
- បកស្រាយ :

មតិទី ១ : "អរិយធម៌ប្រទេស អាស្រ័យដោយការអភិរក្សវប្បធម៌ជាតិ" ព្រោះការអភិរក្សវប្បធម៌ជាតិ គឺ :

- រក្សាបាននូវព្រលឹងជាតិ ឬជាការមានទភាពជាតិ ។
- ជាសញ្ញាបញ្ជាក់ថា ជនជាតិនោះជាជាតិសាសន៍មានមរតកវប្បធម៌ច្បាស់លាស់ ។
- មិនមែនលួចចម្លងពីជាតិសាសន៍ណាមួយទេ តែជាវប្បធម៌ជាតិខ្លួនពិតៗ ។
- ..... ។

ឧទាហរណ៍ : ចំពោះវប្បធម៌ជាតិរបស់ជនជាតិខ្មែរបានឃើញថា ៖

- ខ្មែរធ្លាប់ជាអរិយប្រទេសមួយក្នុងប្រវត្តិសាស្ត្រនៃសម័យអង្គរកន្លង ។
- ខ្មែរចេះរក្សាបានល្អនូវសិលាចារឹក ឬប្រាសាទដែលមានអត្ថន័យផ្សេងៗ ។
- ខ្មែររក្សាបាននូវវិស័យទំនៀមទម្លាប់ ពិធីមង្គលការ ពិធីច្រត់ព្រះនង្គ័ល ... ។
- ក្នុងអក្សរសិល្ប៍ខ្មែរក៏បានឆ្លុះឱ្យឃើញក្នុងរឿង រាមកេរ្តិ៍ (បុព្វបុរសយើងចារឆ្លាក់នៅលើជញ្ជាំងប្រាសាទនានា) ។

សរុបមតិទី ១ : ការថែរក្សានិងការពារវប្បធម៌ជាតិ គឺជាកិច្ចការសំខាន់ ដើម្បីអាចវិនិច្ឆ័យថាជនជាតិនោះ រុងរឿង ឬអន់ថយ ។

សំណួរភ្ជាប់សេចក្តី : ការអភិរក្សវប្បធម៌ជាតិពិតជាកត្តាសំខាន់ក្នុងការកំណត់ថាជាអរិយប្រទេស ។

សរុបមតិទី ២ : "អរិយប្រទេសពិតប្រាកដ ស្ថិតនៅលើការអភិវឌ្ឍនៃវប្បធម៌ជាតិនោះ" ព្រោះពុំមានជាតិសាសន៍ណាមួយ ដែលអាចរស់នៅដោយហ៊ុមព័ទ្ធខ្លួនឯងទេគឺ :

- ត្រូវប្រាស្រ័យទាក់ទងគ្នា (នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ឬវប្បធម៌) ។
- មូលហេតុនេះបណ្តាលឱ្យកើតមានការផ្តិតយកទិដ្ឋភាពនៃវប្បធម៌ទៅវិញទៅមក ។
- អ្វីៗតែងមានការប្រែប្រួលដោយជៀសមិនផុត ដើម្បីតម្រូវទៅតាមស្ថានភាពជាក់ស្តែង ។
- ..... ។

ឧទាហរណ៍ : ចំពោះវប្បធម៌ជាតិរបស់ជនជាតិខ្មែរបានឃើញថា ៖

- វិស័យអក្សរសាស្ត្រខ្មែរយើងមានផ្នាប់មានតាំងពីបុរាណកាលមក តែខ្មែរជៀសមិនផុតពីការទទួលនិងបង្កើតបន្ថែមពាក្យថ្មីៗទៀតដើម្បីបំពេញសេចក្តីត្រូវការ(រ៉េស៊ីដង់ ណៃយ៉ូ ស៊ីតូផ្លាស ឬអ៊ីដ្រូសែន) ។
- វិស័យជំនឿ គេក៏ត្រូវតែមានការកែប្រែចំណុចអសកម្មខ្លះៗ ដើម្បីឱ្យមានលក្ខណៈវិទ្យាសាស្ត្រ (លើព្រហ្មលិខិត លើព្រេងវាសនា ឬលើកម្មផល) ។

សរុបមតិទី ២ : ការអភិវឌ្ឍវប្បធម៌ជាតិជាការសំខាន់ ព្រោះបានដឹកនាំសង្គមក្លាយទៅជាអរិយប្រទេស ។

សំយោគ : មតិទាំងពីរសុទ្ធតែមានអំណះអំណាងសមស្រប គឺដើម្បីឱ្យសង្គមមួយក្លាយជាអរិយប្រទេសពិតប្រាកដ ត្រូវចេះរក្សាការពារវប្បធម៌ជាតិផង ហើយត្រូវកែលំអរាល់ចំណុចណាដែលជាកត្តាវិជ្ជមាននាំឱ្យវប្បធម៌ជាតិមិនជឿនលឿន ។

៣ . បញ្ចប់សេចក្តី

- វាយតម្លៃប្រធាន : មតិនីមួយៗនៃប្រធានសុទ្ធតែមានចំណុចវិជ្ជមាន តែមិនទាន់ពេញលេញនៅឡើយទេ ។
- មតិផ្ទាល់ខ្លួន : មតិនេះបានផ្តល់ការអប់រំដល់យុវជនយើងឱ្យចេះពិចារណា វិភាគលើចំណុចវិជ្ជមាននិងអវិជ្ជមាន និងនាំឱ្យស្គាល់ពីភាពរុងរឿងរីកចម្រើននៃនៃសង្គមមួយពិតប្រាកដក្នុងកិច្ចការពារជាតិនិងកសាង ។

អក្សរសិល្ប៍ព្រាហ្មណ៍និយម



អក្សរសិល្ប៍ព្រាហ្មណ៍និយម គឺជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា។ រឿងក្នុងគោលព្រាហ្មណ៍និយម គឺជារឿងមានលក្ខណៈអស្ចារ្យ អច្ឆរិយៈហួសពីសមត្ថភាពរបស់មនុស្សទៀតផង។ គោលគំនិតជាចំបង ឬមូលបញ្ហារឿងបែបព្រាហ្មណ៍និយម គឺបង្ហាញពីមហិទ្ធិឫទ្ធិអំណាចរបស់តួអង្គដ៏ខ្លាំងពូកែ ដែលជាតួអង្គតំណាងអាទិទេព។ មធ្យោបាយដើម្បីយកជ័យជំនះ គឺសង្គ្រាម។ ចំណែកតួអង្គឯកបុរស គឺជាកំពូលបុរសខ្លាំងពូកែបុរសឯក ខ្លាំងលើសគេលើត្រៃភព។ ចំណែកតួអង្គឯកស្រីជាកំពូលនារីល្អលើសគេ ល្អលើសទេពកញ្ញានៅស្ថានសួគ៌ ហើយជាអ្នកដែលមានឥទ្ធិពលលើកំពូលបុរសដែលជាតួអង្គឯក។ តួអង្គអាក្រក់តំណាងភាវៈអាក្រក់(យក្ស ...)ជាអ្នកមានកំហុសហើយត្រូវទទួលការផ្តន្ទាទោសពីតំណាងសភាវៈល្អ (តួអង្គអវតារអស់ព្រះអាទិទេព)ឬនៅទីបញ្ចប់តំណាងសភាវៈអាក្រក់ត្រូវបរាជ័យជានិច្ច។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាស្វែងយល់អំពីគោលសំខាន់ៗនៅក្នុងសាសនាព្រាហ្មណ៍ លក្ខណៈសំគាល់អក្សរសិល្ប៍ព្រាហ្មណ៍និយម លក្ខណៈអក្សរសិល្ប៍ ស្នាដៃអក្សរសិល្ប៍ព្រាហ្មណ៍និយម អត្ថបទខ្លះៗនៃអក្សរសិល្ប៍ខ្មែរនិងសំណេរបំពេញលិខិតរដ្ឋបាលផ្លូវការមួយចំនួន។

គោលសំខាន់នៃសាសនាព្រាហ្មណ៍

សាសនាព្រាហ្មណ៍បានផ្សាយមកដល់ប្រទេសកម្ពុជាយើង តាមរយៈពួកឈ្មួញនិងអ្នកផ្សព្វ ផ្សាយសាសនារបស់ជនជាតិឥណ្ឌា។ សាសនាព្រាហ្មណ៍ចូលមកដល់ប្រទេសកម្ពុជា ហើយរីកចម្រើន នៅក្នុងរវាងសតវត្សទី ១ នៃគ.ស.។ សាសនាព្រាហ្មណ៍ចែកជា ៣សម័យធំៗ គឺសម័យវេទនិយម (១៥០០ឆ្នាំដល់៥៥០ឆ្នាំមុនគ.ស. គឺក្នុងសម័យអាណាចក្រភ្នំ) សម័យព្រាហ្មណ៍និយម (៥៥០ឆ្នាំមុន គ.ស. ដល់សតវត្សទី ១០នៃគ.ស.) សម័យហិណ្ឌូនិយម (សតវត្សទី ១០នៃគ.ស.រហូតមក)។

១ . វេទនិយម

វេទនិយម គឺលទ្ធិបុរាណនៅប្រទេសឥណ្ឌាដែលនិយមឱ្យតម្លៃលើ "គម្ពីរវេទ"។ ចំណេះវិជ្ជា គ្រប់បែបយ៉ាង របៀបរស់នៅ ទំនៀមទម្លាប់ប្រពៃណី គោលការណ៍អប់រំ គ្រប់គ្រងស្រុកទេសរៀបចំ សង្គម ក៏មានអធិប្បាយនៅក្នុងគម្ពីរវេទនេះដែរ។ សាសនាព្រាហ្មណ៍ចូលមកប្រទេសឥណ្ឌាតាមរយៈ ការលុកលុយរបស់ពួកអារ្យន ដែលជាជនជាតិមួយរស់នៅក្នុងតំបន់អាស៊ីកណ្តាល។

ក. វេទ

គេទុកគម្ពីរវេទ ជាគម្ពីរមានតម្លៃបំផុត ហើយគេរៀនតៗគ្នាដោយ "មុខបាឋ" គឺទន្ទេញផ្ទាល់ពីគ្រូ។ វេទមាន ៣ចំណែកតាមពិតមាន ៤ចំណែក តែគេនៅតែហៅថា "ត្រៃវេទ" ឬត្រ័យវិទ្យា(វិជ្ជា ៣ប្រការ" គឺឫគ្វេទ សាមវេទ យជុរវេទ និងអថរ្វវេទ។ គេចាត់ទុកវេទទាំងបីនេះ ជាទេវឱង្ការទិព្វ ថ្លៃវិសេសនៃអាទិទេពហៅថា "ស្រុតិ" (ការស្តាប់ឮមក)។

- ឫគ្វេទ : ជាវេទសំខាន់ជាងគេសម្រាប់សូត្របួងសួងសរសើរទេវៈដូចជា ព្រះឥន្ទ ព្រះរុទ្រៈ ព្រះវាយុ ព្រះអគ្គិ ព្រះអាទិត្យ ព្រះធរណី ព្រះចន្ទ ព្រះភារុណ ។ល។ ដើម្បីឱ្យទេវៈសប្បាយ ចិត្តហើយជួយឱ្យសម្រេចបំណងផ្សេងៗ។
- សាមវេទ : សាមវេទសម្រាប់ ៖
  - សូត្រសរសើរទេវៈមានព្រះចន្ទ ព្រះយម ព្រះព្រហស្បតិ៍ ...
  - ច្រៀងនៅក្នុងស្រុកភូមិ ព្រោះនាំឱ្យកើតជ័យមង្គលសិរីសួស្តី
  - ច្រៀងនៅក្នុងព្រៃ ព្រោះនាំឱ្យវៀរចាកចង្រៃអន្តរាយដល់ស្រុកភូមិ
  - ពន្យល់ឱ្យចេះធ្វើបទ ឱ្យចេះផ្លាស់ប្តូរបទ ... ។

ពួកហិណ្ឌូយល់ថា សាមវេទមានប្រយោជន៍សំខាន់ណាស់ ព្រោះបានជាពន្លឺខាងប្រវត្តិសាស្ត្រ តួរ្យតន្ត្រីនៃប្រទេសឥណ្ឌា ព្រមទាំងបានជាពន្លឺមើលពិធីបុណ្យផ្សេងៗពីបុរាណ ដែលមិនមែនជារបស់ពួកអារ្យន ។

- យជុិវេទ : សម្រាប់សូត្រក្នុងពិធីបូជាយញ្ញនិងសម្រាប់ពន្យល់ឱ្យចេះធ្វើវិធី (ពិធីបុណ្យក្នុងសាសនា) ។
- អថវ៌វេទ : វេទនេះមិនមែនជាវេទស្តីពីពិធីវិធី ឬពិធីបួងសួងដូចវេទទាំង ៣ដើមនោះ តែជាវេទស្តីពីមន្តអាគមគាថា សែកឱ្យមានអាយុវែង ជាជំងឺ មានទ្រព្យសម្បត្តិ ស្ត្រីស្រឡាញ់ បន្ទន់ចិត្ត បណ្តេញខ្មោចបិសាច ឧបទ្រពចង្រៃ ឱ្យឈឺចុកចាប់ (ធ្មប់អាប)ជាដើម ។

ខ. អត្ថបទវេទ

វេទនីមួយៗចែកចេញជា ៤ផ្នែក ៖

- សំហិតា អត្ថបទនិយាយពីការបួងសួង ការបូជា និងការគោរពសរសើរទេវៈ ។
- ព្រាហ្មណៈ អត្ថបទពន្យល់ឱ្យចេះបូជា បួងសួង សូត្រសរសើរ ធ្វើវិធី ធ្វើពិធីបូជាយញ្ញ ប្រើមន្ត ។ ក្រៅពីនេះ ព្រាហ្មណៈនិយាយពីព្រហ្មន ព្រះព្រហ្ម ព្រាហ្មណ៍ សំសារ(ការកើតស្លាប់) ការចែកវណ្ណៈជា ៤ ៖
  - វណ្ណៈព្រាហ្មណ៍ កើតចេញពីព្រះឱស្ឋព្រះព្រហ្ម ជាអ្នកបួសនិងបង្រៀនវេទ ប្រើសម្លៀកបំពាក់ពណ៌ស ។
  - វណ្ណៈក្សត្រ កើតចេញពីកំភួនដៃព្រះព្រហ្ម ជាអ្នកចំបាំង គ្រប់គ្រងនគរ ប្រើសម្លៀកបំពាក់ក្រហម ។
  - វណ្ណៈវៃស្យៈ កើតចេញពីភ្លៅព្រះព្រហ្ម ជាអ្នកធ្វើការរកស៊ីទូទៅ ប្រើសម្លៀកបំពាក់ពណ៌លឿង ។
  - វណ្ណៈសូទ្រៈ កើតចេញពីជើងព្រះព្រហ្ម ជាអ្នកបំរើគេ ប្រើសម្លៀកបំពាក់ខ្មៅ ។ គេមានចែកជាពួកក្រៅវណ្ណៈថែមទៀតគឺពួក ចណ្ឌាល ។ ពួកចណ្ឌាលនេះ គេចាត់ទុកជាមនុស្សមិនល្អ ចង្រៃ ព្រោះមិនដឹងជាវណ្ណៈណាច្បាស់លាស់ ដោយពួកនេះកើតចេញពីស្រឡាយកាត់រវាងវណ្ណៈមួយនិងវណ្ណៈមួយទៀត ព្រាហ្មណៈឱ្យតម្លៃលើការកាប់សម្លាប់បូជា ។ ការបូជាខ្លួនឯងថ្វាយអាទិទេពរឺតតែប្រសើរ ។ ដំបូងគេកាប់សម្លាប់មនុស្សបូជា ក្រោយមកគេកាប់សម្លាប់សត្វបូជាវិញ ។

- អារណ្យកៈ អត្ថបទពន្យល់ពីការរស់នៅក្នុងព្រៃដូចជា ការប្រព្រឹត្តរបស់អ្នកបួសនៅក្នុងព្រៃ ការប្រព្រឹត្តតឹងរ៉ឹងរបស់តាបស ឬសី ការស្ងឹងស្ងាធ៏អប់រំចិត្តឱ្យល្អ ។ល។ សម័យអារណ្យកៈ គេឱ្យតម្លៃលើការប្រតិបត្តិល្អ ការបួស ការអប់រំចិត្តនៅក្នុងព្រៃស្ងាត់ ។ ឯការបូជា ពិធីធ្វើរឺតជាការបន្ទាប់បន្សំ ។
- ឧបនិស័ទៈ អត្ថបទនិយាយពីទស្សនវិជ្ជា គឺពន្យល់ពីលោក ចិត្ត អាត្ម័ន ព្រហ្ម័ន សំសារ សុខ ទុក្ខ តបៈ យោគៈ ។ល។ ព្រាហ្មណ៍ពន្យល់ឱ្យចែកជីវិតជា "អាស្រម" ៤ យ៉ាងគឺ ៖
  - ព្រហ្មចារ្យ គឺការព្រឹត្តល្អ ធ្វើចិត្តឱ្យស្អាតបរិសុទ្ធដូចព្រហ្ម ត្រូវសិក្សាគម្ពីរវេទជាមួយពួកព្រាហ្មណ៍ ។
  - គ្រហស្ថ គឺការនៅផ្ទះមានប្តីប្រពន្ធ ប្រកបកិច្ចការចិញ្ចឹមជីវិតឱ្យបានលូតលាស់ចម្រើន ។
  - វនប្រស្ថ គឺជាការចាកចេញទៅនៅក្នុងព្រៃ ដើម្បីសិក្សាអប់រំចិត្តឱ្យកាន់តែប្រសើរ ។
  - សន្យាស គឺជាការបួសពេញលេញ ។

២ . ព្រាហ្មណ៍និយម

ព្រាហ្មណ៍និយម គឺជាលទ្ធិដែលបន្តពីវេទនិយម ។ ពួកព្រាហ្មណ៍បានកែច្នៃទស្សនៈទ្រឹស្តីឱ្យកាន់តែល្អឡើងស្របតាមសម័យនិងតាមចំណង់ចំណូលចិត្តមនុស្ស ហើយបានរៀបចំចងក្រងទស្សនៈទ្រឹស្តីទាំងនោះឱ្យមានក្បួនខ្នាតត្រឹមត្រូវ ដើម្បីប្រកួតប្រជែងនឹង "ពុទ្ធនិយម" ។ គម្ពីរថ្មីនេះឈ្មោះថា ធ្មាប់មនុ (កើតចន្លោះ ២០០ឆ្នាំមុនគ.ស. និង ២០០ឆ្នាំក្រោយគ.ស.) ជាអំណោយរបស់អាទិទេព ។ ពួកព្រាហ្មណ៍ក្តី ក្សត្រិយ៍ក្តី មនុស្សទូទៅក្តីត្រូវធ្វើអំពើល្អជាមួយមនុស្ស សត្វ រុក្ខជាតិ លើកលែងតែការសម្លាប់សត្វបូជាយញ្ញ ។ ត្រូវចៀសវាងអំពើអបាយមុខមានសេពសុរាជាដើម ។ ប្តីប្រពន្ធស្រឡាញ់គ្នាស្មោះត្រង់នឹងគ្នា ។ ការផិតក្បត់មានទោសកំហុសធ្ងន់បំផុត ។ ក្នុងសម័យព្រាហ្មណ៍និយម គេសង្កេតឃើញមានពហុសូតវិជ្ជាដូចជា ៖

- វេយ្យាករណ៍ : ចងក្រងភាសាសំស្ក្រឹត ជាក្បួនសំខាន់នៅក្នុងសតវត្សទី ៤ មុនគ.ស. ។
- វចនានុក្រមវិទ្យា : វចនានុក្រមដែលមានអាយុច្រើនជាងគេ កើតក្នុងរវាងសតវត្សទី ៤ និងទី ៦ មុនគ.ស. (រៀបតាមប្រធានបទដូចជា នរក សួគ៌ ទឹក ដី ...) ។
- កាព្យវិទ្យា : កើតតាំងពីសតវត្សទី ១០ នៃគ.ស. (រៀបរាប់ពីចំណាប់ចួន ចំនួនព្យាង្គ ចំនួនឃ្លា ...) ។
- នាដ្យវិទ្យា : វិជ្ជាសិក្សាសិល្បៈល្ខោន ។ គេជួបប្រទះវិជ្ជានេះក្នុងរវាងសតវត្សទី ៧ នៃគ.ស. (រៀបរាប់ពីកាយវិការ សម្លៀកបំពាក់ ការតុបតែងឆាក ...) ។

- អត្ថវិទ្យា : វិជ្ជាសិក្សាពីប្រយោជន៍ តម្លៃ ឬគោលដៅដែលទាក់ទងនឹងអាយុជីវិតប្រទេសជាតិដូចជា នយោបាយ សេដ្ឋកិច្ច ការគ្រប់គ្រង សង្គមកិច្ច ការសិក្សាអប់រំ ... ។ គេប្រទះឃើញអត្ថបទសំខាន់ៗនៃវិជ្ជានេះប្រហែលសតវត្សទី ៤មុនគ.ស. ។
- កាមវិទ្យា : គឺជាវិជ្ជាពន្យល់ពីស្នេហា ។ គេជួបប្រទះវិជ្ជានេះ នៅមុនសតវត្សទី ៧ ។ អត្ថបទសំខាន់ៗទាក់ទងនឹងពហូសូតវិជ្ជា គឺមហាភារតៈ បុរាណៈ តន្ត្រៈ រាមាយណៈ ធម្មសាស្ត្រៈ ។

៣ . ហិណ្ឌូនិយម

ហិណ្ឌូនិយម ជាលទ្ធិដែលបន្តពីព្រាហ្មណ៍និយម ។ លទ្ធិនេះ សំយោគរវាងវេទនិយមនិងព្រាហ្មណ៍និយម ។

បញ្ហាពុទ្ធិ ភាវៈ សុខៈ ក្នុងសាសនាព្រាហ្មណ៍

១ . បញ្ហាពុទ្ធិ

ក. វេទនិយម

- ប្រភពនៃពុទ្ធិ
  - ស្រុតិ : គម្ពីរវេទបង្កើតឡើងដោយអាទិទេព ។ "មនុ" ជាមនុស្សដើមបង្អស់ដែលទទួលវិជ្ជាវេទពីអាទិទេពដោយស្រុតិ (ការបង្ហាញប្រាប់ឱ្យចេះឯង) ។
  - ស្មឹតិ : មនុបានឱ្យវិជ្ជាវេទទៅពួកឫសី ដោយវិធីទន្ទេញឱ្យចាំមាត់ឱ្យឈ្មោះថាស្មឹតិ ។ ពួកឫសីបង្រៀនវេទដល់ពួកព្រាហ្មណ៍ដោយឱ្យទន្ទេញចាំមាត់បន្ត ។
  - អត្ថាធិប្បាយ : ព្រាហ្មណ៍ផ្សាយវិជ្ជាបន្តដោយអត្ថាធិប្បាយពន្យល់ ។
- លក្ខណៈនៃពុទ្ធិ : ចំណេះវិជ្ជាខ្ពង់ខ្ពស់បំផុត មានអត្ថន័យផុតវិស័យមនុស្សធម្មតារកឃើញ ឬបង្កើតបានពុទ្ធិក្នុងគម្ពីរវេទ ជាពុទ្ធិបរិសុទ្ធអាចចាប់បានសច្ចៈខ្ពង់ខ្ពស់ ហើយជាពុទ្ធិត្រឹមត្រូវគ្រប់កាលៈទេសៈ ។ សច្ចៈដែលពុទ្ធិនេះរកឃើញ គឺជាសច្ចៈបឋមថេរជានិច្ច ។

ខ. ព្រាហ្មណ៍និយម

- ប្រភពនៃពុទ្ធិ
  - ស្រុតិ : ពុទ្ធិខ្ពង់ខ្ពស់ជាអំណោយរបស់អាទិទេពឱ្យមនុស្សនិងឫសីដោយស្រុតិ ។
  - ស្មឹតិ : ពួកឫសីបានបង្រៀនវេទដល់ពួកព្រាហ្មណ៍ដោយស្មឹតិ ។
  - អនុភូតិ : ជាពុទ្ធិបានមកពីការពិចារណាស្រាវជ្រាវរកឃើញដោយពួកព្រាហ្មណ៍ ។

- **សភាពនៃពុទ្ធិ**
  - សភាពទី ១នៃពុទ្ធិ ជាត្រៃយិវិទ្យា គឺអធិប្បាយពន្យល់ក្នុងគម្ពីរវេទ ។
  - សភាពទី ២នៃពុទ្ធិ ពហូសូតវិជ្ជា គឺជាវិជ្ជាច្រើនបែបយ៉ាងដែលគេរៀបចំឡើងជាអត្ថាធិប្បាយ ជាពាក្យរាយឬជាបទគាថាសម្រាប់បង្រៀន ។ វិជ្ជានេះ ក៏ចេញមកពីគម្ពីរវេទដែរ ។
  - សភាពទី ៣នៃពុទ្ធិ កម្រងទស្សនៈ ៦យ៉ាង គឺទស្សនៈមិមំសា ជាការពិចារណារកខុសត្រូវលើការអនុវត្តមន្តអាគមគាថាលើព្រហ្មនិងលើពិធីបូជាយញ្ញ ។ ទស្សនៈវេទន្តៈ គឺជាទស្សនៈកំពូលវេទ ។ ទស្សនៈសំខ្យា គឺជាទស្សនៈឱ្យតម្លៃលើការវិភាគ ការរាប់ចំនួន ជាទស្សនៈពហុធាតុនិយម ។ ទស្សនៈយោគៈ គឺជាទស្សនៈទូន្មាន ។ ទស្សនៈវៃសេសិកៈ គឺជាទស្សនៈបរមាណូនិយមឬតថនិយម ។ ទស្សនៈន្យាយៈ គឺជាទស្សនៈតថនិយមឱ្យតម្លៃលើការផ្គុំធាតុទឹក ដី ភ្លើង ខ្យល់ ដើម្បីបង្កើតលោក ។
- **លក្ខណៈនៃពុទ្ធិ** : ពុំប្លែកគ្នាពីសម័យវេទនិយមឡើយ គឺពុទ្ធិដែលបានមកពីអាទិទេពជាពុទ្ធិខ្ពង់ខ្ពស់ ពុទ្ធិដែលជាអត្ថាធិប្បាយរបស់ព្រាហ្មណ៍ក៏ខ្ពង់ខ្ពស់ដែរ ។ ពុទ្ធិដែលពួកព្រាហ្មណ៍ស្រាវជ្រាវរកឃើញពុំសូវមានតម្លៃទេនិងពុទ្ធិផ្សេងៗទៀតរឹតតែមានលក្ខណៈអន់ថយទៅទៀត (ពុទ្ធិក្នុងពុទ្ធនិយម ពុទ្ធិក្នុងជេននិយម ...) ។

គ. ហិណ្ឌូនិយម

សម័យហិណ្ឌូនិយមបន្តពីសម័យព្រាហ្មណ៍និយម គឺឱ្យតម្លៃលើស្រុតិឬគម្ពីរវេទទាំង ៤អត្ថបទផ្សេងៗរបស់ពួកព្រាហ្មណ៍ ពហូសូត្រ កម្រងទស្សនៈទាំង ៦ វណ្ណៈទាំង ៤ ការបែងចែកជីវិតអាស្រមទាំង ៤នៅអនុវត្តបន្ត តែគេប្រើពាក្យ កាមៈ អថិៈ ធម៌ៈ មោក្សៈជំនួសវិញ និងឱ្យតម្លៃលើទស្សនៈឯកទេវនិយមផង ពហុវេទនិយមដូចសម័យមុនដែរ ។

២ . បញ្ហាតាវៈ

ក. វេទនិយម

ភាវៈសំដៅយកលោកមនុស្ស សត្វ ធម្មជាតិ ទេវៈ កាយ ចិត្ត អាត្ម័ន ។ល។

- អំពីលោកឬលោកៈ លទ្ធិវេទចែកលោកជាបីប្រភេទ គឺទេវលោក មនុស្សលោក និង បាតាលឬនរក ។ លោកទាំងបី មានទំនាក់ទំនងគ្នាជាដរាប ។ ទេវៈអាចចុះមកជួយធ្វើអន្តរាគមន៍ការពារសេចក្តីសុខដល់មនុស្ស ឱ្យរង្វាន់ដល់ជនដែលខ្លួនពេញចិត្ត ហើយផ្តន្ទាទោសដល់មនុស្សដែលខ្លួនមិនពេញចិត្ត ។

- អំពីទេវៈ មានព្រះឥន្ទ្រ ព្រះអាទិត្យ ព្រះពិរុណ ព្រះយម ព្រះហស្បតិ៍ ព្រះចន្ទ ព្រះរុទ្រ ព្រះអគ្គិនិងព្រះកុវេរៈ។ ទីកន្លែងអាទិទេពមាន ឋានសួគ៌ ឋានមនុស្ស និងលើអាកាស។
- អំពីមនុស្សនិងធម្មជាតិ មនុស្សចែកជា ៤វណ្ណៈ។ ពួកក្រៅវណ្ណៈមានឈ្មោះថាចណ្ឌាល។ មនុស្សនិងធម្មជាតិកើតឡើងដោយសារអាទិទេព។ ធម្មជាតិសុទ្ធតែមានកំលាំង មានជីវិត មានព្រលឹង មានចេតនាដូចមនុស្សដែរ ហើយមានទេវៈមួយអង្គជាតំណាងដូចជា ទឹក ដី ភ្លើង ខ្យល់ ភ្លៀង ផ្គរ រន្ទះ ជំងឺ ... ។ មនុស្សតែងតែបួងសួង បូជាយញ្ញសុំឱ្យទេវៈតំណាងធម្មជាតិជួយផ្តល់សេចក្តីសុខចម្រើនដល់ខ្លួន។
- អំពីអាទិទេព(លោកវាទ) ក្នុងសម័យវេទដើមបង្អស់ (រវាង ១៥០០-១០០០ឆ្នាំមុនគ.ស.) អាទិទេពដើមឈ្មោះបុរុសៈបានបង្កើតលោកដោយធ្វើពិធីបូជាយញ្ញខ្លួនលោក គឺកាត់ខ្លួនជាបួនកំណាត់ ៣ភាគបោះទៅបង្កើតជាស្ថានសួគ៌និង ១ភាគបោះមកក្រោមបង្កើតជា ដី ទឹក ភ្លើង ខ្យល់ មនុស្សសត្វ គម្ពីរវេទ វណ្ណៈ ចក្រវាល ទិស។ល។ ក្នុងសម័យព្រាហ្មណៈ(រវាង ១០០០ -៧៥០ឆ្នាំមុនគ.ស.) អាទិទេពដើមឈ្មោះប្រជាបតិ បានបង្កើតលោកតាមវិធីបូជាយញ្ញឬតាមតបៈ គឺការដុតកំដៅខ្លួនលោកឱ្យក្តៅ។ ក្នុងសម័យឧបនិស័ទ (រវាង ៧៥០-៥៥០ឆ្នាំមុនគ.ស.) អាទិទេពដើមឈ្មោះព្រហ្មន បានបង្កើតធម្មជាតិ មនុស្ស សត្វ វត្ថុ សភាវៈគ្រប់យ៉ាង។

ខ. ព្រាហ្មណ៍និយម

- អំពីលោក គេនិយមចែកលោកជា ៣ប្រភេទ គឺទេវលោក មនុស្សលោក និងបាតាលឬនរក។
- អំពីមនុស្ស មនុស្សចែកជាពីរប្រភេទ គឺ ៖
  - មនុស្សខ្ពង់ខ្ពស់ មានកាយចិត្តបរិសុទ្ធ មានវិជ្ជាខ្ពង់ខ្ពស់ បានបួសរៀនធ្វើសមាធិឈានលះបង់ប្រយោជន៍លោកិយ អ្នកខ្លះបានសម្រេចមោក្សៈ (បរមសុខ)។
  - មនុស្សធម្មតា ជាប់ជំពាក់នឹងកិលេសតណ្ហា លោភចង់បាន ច្រណែនឈ្នានីស ខឹងច្រើន លួងខ្លៅមិនអាចលះបង់ប្រយោជន៍លោកិយបានដល់ពួកមនុស្សក្នុងវណ្ណៈទាំង ៤។
- អំពីអាទិទេព ទស្សនៈមិមំសានិងវេទន្តៈ គឺព្រហ្មនជាអាទិទេពបង្កើតទេវៈនិងសភាវៈឯទៀត។ ទស្សនៈផ្សេងៗ (យោគៈ ន្យាយៈ វៃសេសិកៈ) គឺឥស្សរៈជាអាទិទេពធំជាងគេ។ ទស្សនៈត្រីមូរតិ គឺការលើកតម្កើងអាទិទេព ៣អង្គ គឺព្រហ្ម វិស្ណុ និងសិវៈ។ ព្រះព្រហ្មជាវិស្វកម្មបង្កើតលោក។ វិស្ណុជាអ្នកថែរក្សាលោក។ ព្រះសិវៈជាអ្នកបង្កើតនិងបំផ្លាញលោក។ ការនិយមឱ្យតម្លៃលើអាទិទេពទាំង ៣អង្គនេះដោយយល់ថា ព្រះឥស្សរៈបែងភាគមកជាអាទិទេពទាំង ៣អង្គនេះ។

គ. ហិណ្ឌូនិយម

- **អំពីលោក** ពួកហិណ្ឌូយល់ស្របតាមវេទនិយមនិងព្រាហ្មណ៍និយម។ លោក:ពុំមានអ្វីជាការពិតជាទៀងទាត់ ពីព្រោះជាមាយា ជាសភាវ:ក្លែងក្លាយ។
- **អំពីអាទិទេពនិងទេវ:** ព្រហ្ម័នជាអាទិទេពធំ ជាតថភាពចុងក្រោយបង្អស់ ដែលមិនអាចប្រែប្រួល មិនវិនាស។ ទេវ:សំខាន់ៗមានវិស្ណុ ព្រហ្ម សូរ្យ: គណេស ... ។ ហិណ្ឌូនិយមឱ្យតម្លៃលើភក្តី គឺការគោរពទេវ:មានរូបរាងខ្លាំងជាងសម័យមុន រហូតដល់រៀបចំតុបតែង ធ្វើឱ្យទេវ:មានឈ្មោះ មានប្រពន្ធកូន មានគ្រឿងអលង្ការ។ល។ ចំណែកសិល្ប:សូនរូប គូរឆ្លាក់រូបទេវ: សម្រាប់គោរពបូជាក៏រីកចម្រើនដុះដាលខ្លាំងឡើង។ អាទិទេពត្រីមូរតិ គឺព្រហ្ម វិស្ណុ សិវ:។

ព្រហ្ម : ព្រហ្ម័នបានបង្កើតព្រហ្មមុនគេ ហើយព្រហ្មក៏បានចាប់ផ្តើមកសាងលោកបន្តទៀត គឺបានបែងភាគទៅជាទេវ:ផ្សេងៗដូចជា វិស្ណុ សិវ: ចន្ទ អង្គារ ពុធ អគ្គិ វាយុ មនុស្ស សត្វ ធម្មជាតិ គម្ពីរវេទ។ល។ ព្រហ្មមានឈ្មោះមួយទៀតថា ហិរណ្យគភ៌ ពីព្រោះមានជំនឿខ្លះថាព្រហ្មបានបង្កើតលោកចេញពីស៊ុតមួយដែលព្រហ្មបានធ្វើឱ្យអណ្តែតនៅលើអាកាស រួចបំបែកជាពីរ គឺទេវលោកកើតចេញពីស៊ុតមួយចំហៀង ឯមនុស្សលោកនិងបាតាលកើតចេញពីស៊ុតមួយចំហៀងទៀត។ ព្រហ្មមានមហេសីឈ្មោះ សរស្វតី និងបុត្រឈ្មោះទក្ស: ភគ៌ុឬភឫគុ និងសំធ្យាឬសន្ធិយា។ រូបកាយមានមុខ៤ ដៃ៤ (កាន់គម្ពីរវេទ ឬផ្កាឈូក សម្បុរផ្កាឈូក) ជួនកាលជារូបឈរ ជួនកាលជារូបអង្គុយលើផ្កាឈូកដែលដុះចេញពីផ្ចិតរបស់វិស្ណុ។ សម្លៀកបំពាក់ពណ៌ស។ កេតនភណ្ឌមានថូ ផ្តាំ កងចក្រ។ យានជំនិះគឺសត្វហង្ស។

វិស្ណុ : អ្នកគ្រប់គ្រងនិងថែរក្សាលោក។ ឋិតនៅក្នុងចិត្តមនុស្ស ដើម្បីជួយគ្រប់គ្រងណែនាំចិត្តមនុស្ស។ វិស្ណុ អាចកើតមកជាអវតារជួយថែរក្សាការពារមនុស្ស។ ពេលភ្លើងឆេះកល្ប សភាវ:លោក: ត្រូវវិស្ណុថែរក្សាទុកឱ្យចាប់កំណើតឡើងវិញ ពេលពិភពថ្មីកើតឡើង។ វិស្ណុជួនកាលគេហៅឈ្មោះនារាយណ៍ ហរិ ភគវ័ន្ត អនន្ត។ មហេសីឈ្មោះស្រី ជាតំណាងសោភណភាពនិងលក្ខ្មីជាតំណាងទ្រព្យសម្បត្តិ បុត្រឈ្មោះកាម:។ រូបកាយជាមនុស្ស មានក្បាល១ មុខ១ ជួនកាលមានដៃ២ ជួនកាលមានដៃ៤ ជួនកាលមានដៃ ៨។ សម្លៀកបំពាក់ពណ៌លឿង ឯមួកវាងមូល។ កេតនភ័ណ្ឌមានកងចក្រ ដំបងឬមោង ខ្សែស័ង្ខ ដុំមូល(ផែនដី) ...។ យានជំនិះ គឺសត្វគ្រុឌ។ វិមាន គឺឋានវៃកុណ្ឋ:។ អវតារព្រះវិស្ណុមាន១០ គឺមត្ស្យ:ជាត្រី។ កូម៌:ជាអណ្តើក វរាហ:ជាជ្រូកព្រៃ នរសិង្ហជាមនុស្សសិង្ហ វាមន:ជាមនុស្សតឿ បរសុរាមជាព្រះរាមកាន់ពូថៅ ព្រះរាមជាមនុស្សទេវ:។ ក្រីស្ណជាមនុស្សខ្មៅ។ ពុទ្ធ:ជាព្រះពុទ្ធ(ការពិតព្រះពុទ្ធពុំមែនជាអវតារវិស្ណុឡើយ)។ កល្គិនជាមនុស្សសេះ។

សិវៈ ជាអ្នកបង្កើតលោកផងនិងបំផ្លាញលោកផងមានឈ្មោះ មហាទេវៈ ហរៈ មហេស្វរៈ រុទ្រៈ ឥស្វរៈ ឧគ្រៈ អឃោរៈ ភៃរវៈ ឥសូរ។ ភៃរវៈ ជាសិវៈបែងភាគមានក្បាល១០ មានពោះធំ សម្បុរខ្មៅ មានពស់វែកព័ទ្ធជុំវិញខ្លួន ចូលចិត្តកាប់សម្លាប់។ មហេសីឈ្មោះ ទុគ៌ាឧមាឬឧមាភគវតី គោរី កាលី ទេវី កុមារី ចន្ទី បវិតី មហាទេវី(ស្រីទេពអប្សរដ៏ប្រសើរ)។ មានបុត្រឈ្មោះ ស្កន្ទៈ ជាទេវៈខាងសង្គ្រាមមានក្ងោកជាយានជំនិះ គណេស ជាទេវៈខាងបញ្ញា មានខ្លួនមនុស្ស ក្បាលដំរីមានភ្លុក១ ដៃ៤ គង់លើកណ្តុរ ជាមេគណៈនៃពួកទេវៈ។ និមិត្តរូប គឺលិង្គតម្កល់លើឧមាយោនីជានិមិត្តរូបនៃការបង្កើតលោក។ រូបកាយមានមុខ១ តែអាចបែងភាគបានមុខ៥ ជាឫសីមានសក់បួងមានពុកមាត់ស្រួចកាន់ផ្តាំ។ មនុស្សក្មេងពាក់មួកវាងមូលមានសញ្ញាអូម ឬរូបចំណិតលោកខែនៅពីមុខផ្នួងសក់(គ្រឿងសម្គាល់រាប់ខែ) មានភ្នែកទីពានៅលើថ្ងាស(អគ្គីនេត្រ)។ ក្បូរត្រគង់លើបល្ល័ង្ក ឬអ្នករាំស្តេចល្ខោន(សិវនាដរាជ)។ តាមរយៈចលនារបាំនេះ ឥសូរបង្កើតលោក ឬបំផ្លាញលោកដៃ ២ (ដៃ៤ ដៃ៨ ឬដៃ១០) ភ្នែក ៣។ មានសម្បុរសតែកខៀវ។ ពាក់កម្រងឆ្អឹងលលាដ៍ក្បាល (គ្រឿងសម្គាល់សម្រាប់កប្បយុគ)។ ពាក់នាគឬពស់ជាសង្វារ(គ្រឿងសម្គាល់រាប់ឆ្នាំ)។ សម្លៀកបំពាក់ ស្បែកខ្លា ឬស្បែកដំរី។ កេតនភណ្ឌមាន ត្រីសូល ខ្សែផ្តាំ ស្គរ កូនដប លលាដ៍ក្បាល...។ យានជំនិះ គឺគោនន្ទិន។ វិមាននៅលើកំពូលភ្នំកៃលាស។

៣ . បញ្ហាសុខៈ

ក. វេទនិយម

សុខៈមានពីរប្រភេទ : សាមញ្ញសុខ គឺសុខក្នុងលោកិយ។ បរមសុខ គឺសុខក្នុងបរលោកដែលគេឱ្យតម្លៃថាខ្ពង់ខ្ពស់បរិសុទ្ធបិតថេរ។

បុព្វហេតុនៃទុក្ខ

- ទុក្ខកើតឡើងដោយសារកម៌ន ពេលណាអាត្ម័នដាច់ចេញពីព្រហ្ម័ន ហើយចូលទៅនៅជាមួយធាតុលោកៈ ពុំបរិសុទ្ធ ពេលនោះមានកម៌នដែលនាំកើតទុក្ខ។
- ទុក្ខកើតឡើងដោយសារៈសំសារ បើអាត្ម័នពុំបានវិលទៅជួបនឹងព្រហ្ម័នវិញភ្លាមទេ អាត្ម័នត្រូវនៅវិលវល់ពីជាតិមួយទៅជាតិមួយទៀត។ ការវិលវល់នៃអាត្ម័នដូច្នេះហៅថា សំសារៈដែលជាប្រភពនៃទុក្ខ។

- ទុក្ខកើតឡើងដោយអវិជ្ជា គឺការលង់ខ្លៅមិនយល់ថា អាត្ម័ននិងព្រហ្ម័នជាសភាវៈតែមួយ ហើយមិនដឹងថាត្រូវធ្វើយ៉ាងណា ដើម្បីឱ្យអាត្ម័នអាចទៅជួបនឹងព្រហ្ម័នវិញបាន ។ ដូច្នេះអវិជ្ជាជាប្រភពនៃសេចក្តីទុក្ខ ។

វិធីបង្កើតសុខៈ វិធីបង្កើតសុខៈមានពីរប្រភេទ ៖

- វិធីបង្កើតសុខៈធម្មតា គេជឿថា សុខកើតឡើងដោយសារអាទិទេព ។ ដូច្នេះត្រូវប្រកាន់វណ្ណៈធ្វើពិធីបូជាយញ្ញ រៀនវេទ និងសូត្រមន្តអាគមនិងបំពេញតបៈ ។
- វិធីបង្កើតបរមសុខ ត្រូវអនុវត្តវេទវិធីនេះឱ្យម៉ត់ចត់ ដើម្បីសម្រេចមោក្សៈ គឺការរួចផុតពីទុក្ខទោសពីការវិលកើត វិលស្លាប់ក្នុងសំសារៈ ។ សុខៈវិធីដែលព្រាហ្មណ៍ទូន្មានឱ្យអនុវត្តឆ្ពោះទៅរកបរមសុខ គឺ :
  - សុខវិធីទី ១ : វិធីបង្កើតសុខធម្មតា នៅតែត្រូវអនុវត្តបន្តជាបន្ទាប់បន្សំ
  - សុខវិធីទី ២ : ត្រូវបួសជាតាបសឬសី ហើយអនុវត្តឬសីវិធី ២ គឺតបៈនិងយោគៈ
  - សុខវិធីទី ៣ : ការបង្កើតវិជ្ជា ។ វិជ្ជាបរិសុទ្ធឬពុទ្ធិខ្ពង់ខ្ពស់ គឺជឿថាមានអាទិទេពជាអ្នកខ្លាំងពូកែសព្វយ៉ាងជាអ្នកបង្កើតលោកនិងជឿថាអាត្ម័ននិងព្រហ្ម័នជាសភាវៈតែមួយ ។

ខ. ព្រាហ្មណ៍និយម

ទុក្ខកើតមកពីបុព្វហេតុ៤យ៉ាង គឺសំសារៈ កម៌ិន អវិជ្ជា តណ្ហា ។

ទស្សនៈមិមំសានិងវេទន្តៈ សំសារៈ គឺអាត្ម័នធាតុបរិសុទ្ធ ត្រូវនៅលាយឡំជាមួយធាតុលោកៈគ្រោតគ្រាត ។ ការវិលកើតស្លាប់ ដែលនាំឱ្យកើតទុក្ខមានប្រភពមកពីកម៌ិន ។ កម៌ិន គឺនៅពេលដែលអាត្ម័នបែងចេញពីព្រហ្ម័នភ្លាម ក៏កើតមានកម៌ិនភ្លាមដែរ ។ អវិជ្ជាជាបុព្វហេតុនាំឱ្យមានទុក្ខដែរ ។ តណ្ហា គឺមានអវិជ្ជាត្រូវតែមានតណ្ហា ដែលជាប់ជំពាក់នឹងលោកៈចង់បានសុខក្នុងលោកិយ ដែលជាសុខក្លែងក្លាយ ។ ហេតុនេះតណ្ហានាំឱ្យកើតទុក្ខ ។

ទស្សនៈសំខ្យា សំសារ គឺបុរុសៈ(អាត្ម័ន)រួមនឹងប្រកៃតិ(រូបកាយ) នាំឱ្យកើតសំសារ ។ កម៌ិន គឺការរួបរួមបុរុសៈនិងសភាវៈដើម គឺប្រកៃតិ ។ អវិជ្ជា គឺការយល់ថាមានអាទិទេពឈ្មោះព្រហ្ម័ននិងព្រហ្ម័នជាសភាវៈតែមួយ ។ ឯវិជ្ជា គឺការយល់ថាប្រកៃតិជាសភាវៈដើមបង្អស់បង្កើតសភាវៈទៀត ។ ការកាប់សម្លាប់បូជា ការសេពសុរា ក៏ជាបាបកម្មឃោរឃៅនិងផ្តល់ទុក្ខដែរ ។

វិធីបង្កើតសុខៈ ដើម្បីសម្រេចមោក្ស: ឬបរមសុខត្រូវអនុវត្តវិធីសំខាន់ៗដូចជា បំបាត់កម៌ន ដែលជាប្រភពនៃសំសារ ប្រព្រឹត្តតាមវិធី ឬករណីយកិច្ចរបស់ព្រាហ្មណ៍បួសជាតាបសធ្វើសមាធិ ឈានបង្កើតវិជ្ជាបរិសុទ្ធបំបាត់តណ្ហា ។

គ. ហិណ្ឌនិយម

ហិណ្ឌនិយមជាលទ្ធិទទួលឥទ្ធិពលពីលទ្ធិវេទនិយមនិងព្រាហ្មណ៍និយម ។ គេសង្កេតឃើញថា លទ្ធិនេះ មានលក្ខណៈពិសេសរបស់ខ្លួនត្រង់ការសង្កត់ខ្លាំងលើតម្លៃភក្តី ដើម្បីសម្រេចបរមសុខ ។ គ្រាន់តែមានជំនឿមោះមុត ស្រលាញ់អាទិទេព ផ្តេកផ្តួលនឹកដល់អាទិទេពគ្រប់នាទីអាចសម្រេចមោក្ស:បាន ។

(ដកស្រង់ពីអរិយធម៌ខ្មែរសាកលវិទ្យាល័យជាតិគ្រប់គ្រងគ.ស. ២០០៥ សូ មុយឃៀង ទិតសៀង ជាឈិន)

សំណួរ

១. តើសាសនាព្រាហ្មណ៍ចែកជាប៉ុន្មានសម័យកាលធំៗ ? អ្វីខ្លះ ?


២. តើគម្ពីរវេទមានអ្វីខ្លះ ? ចូរបង្ហាញមុខងារនៃគម្ពីរនីមួយៗ ។

៣. តាមសាសនាព្រាហ្មណ៍ តើអវតារព្រះវិស្ណុមានប៉ុន្មាន ? អ្វីខ្លះ ?

៤. ចូរបង្ហាញពីបុព្វហេតុនៃទុក្ខ តាមលទ្ធិវេទនិយម ។

៥. ចូរបង្ហាញពីវិធីបង្កើតសុខៈតាមវេទនិយម ។

រឿងរាមកេរ្តិ៍



ក. សិក្សាពាក្យគន្លឹះ

- កាឡកិណី (គុ) : មនុស្សចិត្តខ្មៅ មនុស្សចង្រៃ ។
- កុណ្ឌី (ន) : ប្រដាប់សម្រាប់ទឹកច្រូច ទឹកោទឹក ។
- កេសរ (ន) : លំអងផ្កា ។
- គជសា (ន) : ដំរី ។
- គន្ធា (ន) : ក្លិនក្រអូប ។
- ចង្ក្រម (ន) : ដំណើរទៅមកៗ ។
- ភមរ (ន) : កន្លង់ ។
- មយូរី (ន) : ក្ងោកញី ។
- មធុករ (ន) : សត្វធ្វើនូវទឹកផ្អែម មានឃ្មុំជាដើម ។
- មរណ៍ (កិ) : ស្លាប់ ។
- មាគ៌ា (ន) : ផ្លូវ ។
- មុសាវាទ (ន) : ការនិយាយកុហក ។
- ជង្ឃ (ន) : ស្មងជើង ។

- ជេដ្ឋា (ន) : បង ។
- តក្កមា (កិ) : តក់ស្លុត ស្លន់ស្លោ ។
- តេជ (ន) : អំណាច អនុភាព ។
- ទុគ៌ម (ន) : ឆ្ងាយ ផ្លូវឆ្ងាយ ។
- ទេពី (ន) : ប្រពន្ធ ។
- ឧទី (ន) : ស្ទឹង ទន្លេ ។
- ឧពុគុណ (ន) : ឈ្មោះមាសទឹក ៩ ឈ្មោះផ្កាយគ្រោះទាំង ៩មាន ព្រះអាទិត្យ ព្រះចន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ រាហ៊ុ និងកេតុ ។
- នរបតី (ន) : ព្រះរាជា អ្នកជាម្ចាស់នៃមនុស្ស ។
- បព៌ត (ន) : ភ្នំ ។
- បរិពារ (ន) : បរិវារ សេនា រេហពល៍ ។
- បុស្ប៊ី ឬបុស្បា (ន) : ផ្កា ។
- បូជាយញ្ញ (ន) : ពិធីក្នុងព្រហ្មញ្ញសាសនា ដែលធ្វើនេះបួងសួងថ្វាយអាទិទេពដោយកាលពីបុរាណគេដុតមនុស្សទាំងរស់ តែក្រោយមកគេដុតសត្វវិញ ។
- ប្រថមា (ន) : ដំបូង បឋម ។
- ពនេចរ (ន) : អ្នកដើរក្នុងព្រៃ ។
- ពិសុទ្ធឬវិសុទ្ធ (គុ) : ឥតមន្ទិល បរិសុទ្ធ ។
- ព្រះនេត្រ (ន) : ភ្នែក ។
- ព្រះឱស (ន) : មាត់ ។
- ភាវនា (កិ) : ស្ទឹងស្មារ៉ី ចម្រើនធម៌ ។
- ភូធរ (ន) : អ្នកទ្រទ្រង់ផែនដី ស្តេច ។
- ម្រិត្យូ (ន) : សេចក្តីស្លាប់ ។ បាលីថា "មតៈ" សំស្ក្រឹត "ម្រិត្យុ" ។
- រាជរថអស្សពាហ៍ (ន): រទេះសេះរបស់ស្តេច ។
- រូហាន (ន) : ដូច ដូចជា បីដូច ។
- លីលា (កិ) : ដើរ ។
- វាតា (ន) : ខ្យល់ ។
- វន្ទីយ (កិ) : ថ្វាយបង្គំ ការសំពះ ការគំនាប់ ។

- វុឌ្ឍ (គុ) : ចម្រើន ។
- សត្យាឬសត្យ (ន) : សច្ចៈ សេចក្តីទៀងត្រង់ ។
- សង្ហារ (ន) : ខ្សែរវិចិត្រពាក់ឆៀងខ្លួន ។
- សិរឬសិរសា (ន) : ក្បាល ។
- សុន្ទរ (គុ) : ល្អប្រពៃ ពីរោះ ។
- សុពណ៌បាទា (ន) : ស្បែកជើង ។
- សុវណ្ណា (ន) : មាស ។
- សែយ (គុ) : ប្រសើរវិសេស គម្ពីរសែយ ។
- សំស្ការ (គុ) : សង្ការ ការលើកសពធ្វើឈាបនកិច្ច ។
- ស្រីស្រីង្គារ (ន) : ស្រីស្អំ ស្រីដែលស្អាតគួរឱ្យស្រឡាញ់ ។
- សោយទិវង្គត (កិ) : ស្លាប់ ។
- ហឫទ័យ (ន) : ដួងចិត្ត បេះដូង ចិត្ត ។
- អធ្វា (ន) : ផ្លូវ ដងផ្លូវ ។
- អនន្ត (ន) : ច្រើនហួសប្រមាណ ដែលមិនចេះចប់ ។
- អនុជាឬអនុជ (ន) : ប្អូន ។
- អភិវាទ (កិ) : ថ្វាយបង្គំ ការសំពះ ការគំនាប់ ។
- អម្ពរ (ន) : សំពត់ គ្រឿងស្លៀកពាក់ អាកាស ។
- ឧទា (គុ) : សំបើម ពន្លឺក ក្រៃលែង ។
- ឧរៈ ឱរា (ន) : ទ្រូង ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលសិក្សាអត្ថបទរឿងនេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងលក្ខណៈអក្សរសិល្ប៍ព្រាហ្មណ៍និយម វិធីតែងនិពន្ធ គោលសំខាន់ៗនៅក្នុងព្រាហ្មណ៍សាសនា និងវិធីតែងនិពន្ធមួយចំនួន ។

គ. សង្ខេបអត្ថបទ

នៅនគរពូយុធ្យា ព្រះបាទទសរថជាក្សត្រមានមហេសី ៣អង្គ គឺនាងកោសកល្យាណ នាងកៃកេសី និងនាងសមុទ្រ ។ ព្រះរាជបុត្រ មានព្រះរាមជាបុត្រនាងកោសកល្យាណ ព្រះភរតជាបុត្រនាងកៃកេសី ឯព្រះលក្ខ្មណ៍និងព្រះសុត្រុតជាបុត្រនាងសមុទ្រ ។ ព្រះរាមនិងព្រះលក្ខ្មណ៍ទៅរៀនសិល្ប៍ជាមួយឥសីពិស្វាមិត្ររហូតចប់គម្ពីរវេទ ។

ថ្ងៃមួយ យក្សកាកនាសូរបានកាឡាខ្លួនជាក្អែកខ្មៅមកឆាបបំផ្លាញហោមពិធី។ ឥសីពិស្វាមិត្រ ក៏ជបធ្នូសរឱ្យព្រះរាមបាញ់សម្លាប់កាកនាសូរនោះទៅ។ នៅនគរមិថិលានាងសីតា ជាបុត្រីរបស់ព្រះជនកមានវ័យគ្រប់ការ។ ព្រះអង្គបានរៀបចំពិធីលើកធ្នូសរ ដើម្បីរើសគូស្រករឱ្យនាង។ ឥសីពិស្វាមិត្របាននាំព្រះរាមនិងព្រះលក្ឃ្មណ៍ទៅលើកធ្នូសរទទួលបានជោគជ័យ ហើយបានរៀបអភិសេកជាមួយនាងសីតា។ នៅតាមផ្លូវត្រឡប់មកទៅឰយុធ្យា ព្រះរាមបានផ្ទាញ់រាមបរមសូរ។ ព្រះបាទទសរថ មានបំណងឱ្យព្រះរាមស្នងរាជ្យ ប៉ុន្តែនាងកៃកេសីជំទាស់ដោយសំអាងលើពាក្យសច្ចៈ ហើយបានបណ្តេញព្រះរាមឱ្យទៅនៅក្នុងព្រៃ។ ព្រះរាម ព្រះលក្ឃ្មណ៍ និងនាងសីតាធ្វើដំណើរចូលព្រៃ បានជួបនឹងកូខ័នរួចបន្តដំណើរទៅភ្នំចិត្រកូដដើម្បីបួសជាឥសី។ នៅតាមផ្លូវព្រះរាមជួបនឹងឥសី ពារទ្វាទ្យ ដែលបានពន្យល់ទ្រង់អំពីទ្រីស្តីព្រាហ្មណ៍និយមខ្លះៗ ហើយបានបង្ហាញផ្លូវទៅភ្នំចិត្រកូដ។ នៅឰយុធ្យា ព្រះបាទទសរថទ្រង់សោយទិវង្គត។ នាងកៃកេសីបានបញ្ជោតព្រះភរិតឱ្យគ្រងរាជ្យសម្បត្តិ តែព្រះភរិតមិនព្រម ហើយក៏បានទៅយាងព្រះរាមឱ្យមកសោយរាជ្យវិញ តែព្រះរាមបដិសេធ ព្រោះទ្រង់គោរពពាក្យសច្ចៈ។ ក្សត្រទាំងបីអង្គបានយាងទៅព្រៃភ្នំទណ្ឌការណ្យ ក៏បានជួបនឹងយក្សមួយឈ្មោះពិរាធ។ ពិរាធចូលឆក់យកនាងសីតា តែត្រូវព្រះរាមថ្លែងសរសម្លាប់ទៅ។ ថ្ងៃមួយ នាងសូរបនខាជាប្អូនស្រីយក្សក៏បានមកសុំស្នេហាពីព្រះលក្ឃ្មណ៍ ដោយកំហឹងព្រះលក្ឃ្មណ៍ក៏កាត់ដៃ កោរសក់នាងសូរបនខា។ នាងបានស្រែកឮដល់ក្រុងខរជាបង។ ក្រុងខរបានបញ្ជូឱ្យ ខុនទសណ៍ចូលច្បាំង បន្ទាប់មកត្រីមុខចុងក្រោយ គឺក្រុងខរខ្លួនឯង។ ប៉ុន្តែយក្សទាំងនោះត្រូវវិនាសដោយធ្នូសរព្រះរាម។ នាងសូរបនខាក៏យកដំណឹងនេះទៅប្រាប់ក្រុងរាពណ៍ជាបងនិងបានបញ្ចុះបញ្ចូលឱ្យក្រុងរាពណ៍ទៅឆក់យកនាងសីតាមកធ្វើជាមហេសី។ ក្រុងរាពណ៍បានប្រើកលល្បិចចាប់យកនាងសីតាទៅ។ ពេលហោះទៅវិញរាពណ៍បានយកជ័យជំនះលើគ្រុឌឈ្មោះជតាយុ។ ក្រុងរាពណ៍ក៏យកនាងសីតាទៅទុកក្នុងសួនអសោក។

នៅក្នុងព្រៃហោមពាន្ត មានស្តេចក្របីមួយឈ្មោះមហិង្សរាជ បានសម្លាប់ក្របីឈ្មោលទាំងអស់ទោះជាកូនខ្លួនក៏ដោយ ហើយប្រមូលយកក្របីញីមកធ្វើប្រពន្ធ។ មានមេក្របីមួយឈ្មោះសន្តគីរី បានកើតកូនឈ្មោលមួយឈ្មោះទូភី។ មេក្របីនេះបានភៀសខ្លួនសំងំក្នុងព្រៃនិងឱ្យកូនខំហាត់រៀនយុទ្ធវិធីរហូតបានសម្រេច។ ទូភីបានប្រហារជីវិតឪពុក ហើយបន្តធ្វើដូចឪពុកដែរ។ ថ្ងៃមួយទូភីបានប្រយុទ្ធជាមួយពាលីជាស្តេចស្វា។ ទូភីចាញ់ក៏ស្លាប់ពេលនោះទៅ។ ពេលតាមរកនាងសីតា ព្រះរាមព្រះលក្ឃ្មណ៍បានទទួលយកហនុមានធ្វើជាកូនថៅ។ ហនុមានបានស្នើឱ្យព្រះរាមជួយដោះស្រាយរឿងពាលីនិងសុគ្រីពដែលជាបងប្អូននឹងគ្នា។ ព្រះរាមបានសម្លាប់ពាលី ហើយចងសម្ព័ន្ធភាពជាមួយ

សុគ្រីព។ សុគ្រីពបានកេណ្ឌពលស្វាថ្វាយព្រះរាម។ ព្រះរាមបានចាត់ឱ្យហនុមានទៅស៊ើបការណ៍នៅក្រុងលង្កា។ ក្រោយពីបានជួបនាងសីតារួចមក ហនុមានបានដើរបំផ្លាញក្រុងលង្កា ព្រមទាំងសម្លាប់យក្សជាច្រើននាក់។ ពេលបានដំណឹងពីហនុមានហើយ ព្រះរាមក៏បានចងសម្ព័ន្ធភាពជាមួយមហាជម្ពូដើម្បីសុំទ័ពជំនួយ។ មហាជម្ពូបានឱ្យខុនធីលនិងខុនធលចូលរួមជាមួយ។ បានទ័ពច្រើនហើយព្រះរាមក៏ឱ្យទ័ពស្វាសង់ស្ពានកាត់សមុទ្រទៅកោះលង្កា។

ក្រុងរាពណ៍ទូងស្គរប្រមូលទ័ព រួចបញ្ជាភិភេគឱ្យទាយពីវាសនានគរលង្កា។ ភិភេគបានគន់គូរហើយក៏ស្នើក្រុងរាពណ៍យកនាងសីតាទៅថ្វាយព្រះរាមវិញ។ រាពណ៍ខឹងខ្លាំងណាស់ក៏ដោះស្បែកជើងវាយក្បាលភិភេគ។ ភិភេគក៏រត់ទៅចូលនឹងព្រះរាម។ រាពណ៍បានប្រើល្បិចជាច្រើន ដើម្បីធ្វើសង្គ្រាមជាមួយព្រះរាមដូចជា ឱ្យយក្សរុក្ខសេនទៅយាមព្រៃ ដើម្បីកុំឱ្យទ័ពស្វាបេះផ្លែឈើ។ ចម្បាំងក៏កើតឡើង ទ័ពយក្សនិងទ័ពស្វាស្លាប់ទាំងអស់។ រាពណ៍ភិតភ័យក៏ប្រើល្បិចមួយទៀត ដោយយកនាងសីតាហោះទៅលើអាកាសបញ្ឆឺចិត្តព្រះរាម។ ដោយមានភិភេគជាអ្នកប្រាប់ការពិត ព្រះរាមក៏សូត្រមន្តឱ្យរាពណ៍ចុកពោះសន្លប់លើរាជរថ។ ព្រះរាមចាត់ឱ្យអង្គទយកសារទៅថ្វាយក្រុងរាពណ៍ ដើម្បីធ្វើសង្គ្រាម ប៉ុន្តែទំនាស់ក៏កើតមានឡើង អង្គទត្រូវបានក្រុងរាពណ៍ទះមួយដៃសន្លប់។ រាពណ៍បានចាត់កុម្ភកាណ៌ឱ្យចេញច្បាំង។ កុម្ភកាណ៌បានយកមោងសត្តិចោលត្រូវជើងព្រះលក្ស្មណ៍យ៉ាងធ្ងន់ធ្ងររហូតដល់សន្លប់ក៏កើតជាដំបៅដុះឫសចាក់ដល់ឋានបាតាល។ ភិភេគបញ្ជាឱ្យហនុមានទៅរកថ្នាំនៅព្រៃហោមពាន្តនិងថ្មមួយដុំនៅក្រោមក្បាលដំណេកក្រុងរាពណ៍ ព្រមទាំងឃាត់ដំណើរព្រះអាទិត្យ។ ព្រះលក្ស្មណ៍បានជាសះស្បើយ ហើយបានចេញច្បាំងទៀត រហូតសម្លាប់កុម្ភកាណ៌បាន។ ក្រុងរាពណ៍បានឱ្យឥន្ទ្រជិតមកច្បាំងបន្ត។ ឥន្ទ្រជិតបានថ្លែងសរនាគបាសចាប់ទ័ពស្វានិងព្រះលក្ស្មណ៍ជាប់។ ព្រះរាមបានគំរាមទៅស្ពានលើឱ្យជួយ ដោយប្រកាសថាព្រះអង្គនឹងគ្រវែងធ្នូសរទៅស្ពានលើឱ្យឆេះខ្ទេចខ្ទីអស់។ ទេវតាភ័យក៏ទៅអង្វរព្រះព្រហ្មឱ្យលែងគ្រុឌ ដើម្បីដេញនាគឥន្ទ្រជិត។ ក្រុងរាពណ៍បានភៀសខ្លួនឡើងកំពូលភ្នំសួពិសពីនាគ ដើម្បីសម្លាប់ទ័ពព្រះរាម តែត្រូវហនុមានបំផ្លាញមន្តអាគមនោះចោលអស់។ ក្រុងរាពណ៍បានបញ្ជាឱ្យឥន្ទ្រជិតចេញច្បាំងម្តងទៀត តែត្រូវព្រះលក្ស្មណ៍ថ្លែងសរសម្លាប់។ ពេលដឹងថាឥន្ទ្រជិតស្លាប់ ក្រុងរាពណ៍ក៏សម្រេចចិត្តយកនាងសីតាទៅប្រហារជីវិត ប៉ុន្តែមានមន្ត្រីយក្សម្នាក់ឈ្មោះវុក្ខសៈឃាត់ ដោយអះអាងថា ទំនៀមទម្លាប់មិនអនុញ្ញាតឱ្យសម្លាប់មនុស្សឥតទោសទេ។ ក្រុងរាពណ៍បញ្ជាឱ្យកូនទាំង ១០ចេញច្បាំងម្តងមួយៗ លុះត្រាតែស្លាប់អស់។ អស់សង្ឃឹម ក្រុងរាពណ៍ក៏ទៅចងស្ពានមេត្រីជាមួយមិត្តម្នាក់ឈ្មោះមូលីមឱ្យច្បាំងបន្តទៀត។

ថ្ងៃមួយនាងសីតាបានគូររូបក្រុងរាពណ៍តែលុបវិញមិនជ្រះ ព្រោះចាញ់បោកយក្ខិនីឈ្មោះ "អាតុល័យ" ជាប្អូនក្រុងរាពណ៍តាមសងសឹក។ នៅពេលព្រះរាមវិលមកវិញនាងបានយកក្តារគំនូរនោះទៅលាក់ក្រោមក្រលាបន្ទំរបស់ស្វាមី។ ព្រះរាមក្តៅក្រហាយផ្ទំមិនលក់។ លុះរកក្តារគំនូរឃើញ ព្រះរាមបានបញ្ជាឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅសម្លាប់ទាំងរាត្រី។ ព្រះលក្ស្មណ៍លើកព្រះខ័ន សម្លាប់នាងសីតា ប៉ុន្តែព្រះខ័ននោះក្លាយទៅជាកម្រងផ្កាដោយសច្ចធម៌នាងជួយ។ ពេលនោះព្រះឥន្ទ្របានកាឡាខ្លួនជាមហិង្សាមកនាំនាងសីតាទៅកាន់អាស្រមឥសីវជ្ជប្រិត។ លុះគំរប់ទសមាសនាងបានប្រសូតបានបុត្រមួយអង្គ។ ថ្ងៃមួយនាងសីតាបានយកកូនទៅកំពង់ទឹកដោយពុំឱ្យឥសីដឹង។ ឥសីបើកភ្នែកឡើងពុំឃើញចៅភិតភ័យណាស់ ក៏រៀបចំជបក្មេងមួយទៀតឱ្យដូចរាជកុមារមុន។ កុមារជបនោះឈ្មោះ "ជប្បលក្ស្មណ៍" ហើយបុត្របង្កើតនាងសីតាឈ្មោះ "រាមលក្ស្មណ៍"។ អាយុបានដប់ឆ្នាំរាជកុមារចេះសិល្ប៍មន្តយ៉ាងស្ទាត់ជំនាញ។ រាមលក្ស្មណ៍បានថ្លែងសរកំទេចដើមរាំងធ្វើឱ្យពួកទេវៈរំជើបរំជួលគ្រប់ទិសទី។ ព្រះរាមបានឱ្យហោរាទស្សន៍ទាយ។ ហោរពុំគ្រាន់តែទូលថា មានអ្នកឫទ្ធិល្បាងសិល្ប៍ប៉ុណ្ណោះទេ ប៉ុន្តែសុំឱ្យព្រះរាមលែងសេះ "អស្សតរ" ឱ្យដើរចេញដោយមានរាជសារភ្ជាប់ទៅនឹងក ហើយនិងឱ្យហនុមានដើរចាំឃ្លាំមើលផង។ ឯសេចក្តីក្នុងសារនោះមានជាអាទិ៍ថា "បើនរណាពុំថ្វាយបង្គំសេះព្រះរាមទេ នោះត្រូវចាប់យកទៅធ្វើទោស"។ រាជកុមារឃើញសេះរបស់ព្រះរាម ក៏ចាប់ជិះលេង។ ពេលនោះ ហនុមានស្ទុះមកចាប់រាជកុមារ ប៉ុន្តែត្រូវរាជកុមារវាយវាត់នឹងធ្នូសរដួលសន្លប់។ ក្រោយមក ហនុមានបានកាឡាខ្លួនជាកូនស្វាព្រៃតូចមួយចូលទៅលួងលោមបញ្ឆោតចាប់ក្មេងទាំងពីរ តែត្រូវរាជកុមារវាយសន្លប់ទៀត។ ព្រះរាមបានបញ្ជាឱ្យ ហនុមាននាំព្រះភិរុតនិងព្រះសុត្រុតទៅច្បាំងចាប់កុមារ។ ដំបូងរាជកុមារឈ្នះ តែបន្ទាប់មករាមលក្ស្មណ៍ត្រូវសរដួលសន្លប់។ ហនុមានបានចាប់រាមលក្ស្មណ៍ទៅថ្វាយព្រះរាម។ ចំណែកឯជប្បលក្ស្មណ៍រត់រួចខ្លួន។ ព្រះរាមចាត់ឱ្យសេនាចងរាជកុមារបណ្តើរអារក្រោសនៅជុំវិញរាជធានី ហើយនឹងត្រូវសម្លាប់រវាងបីថ្ងៃទៀត។ ជប្បលក្ស្មណ៍បានទៅតាមរកបង លុះទៅដល់ជិតក្រុងឮយុធ្យាជប្បលក្ស្មណ៍បានអធិដ្ឋានឱ្យទេវៈជួយ។ ព្រះឥន្ទ្របានចាត់ឱ្យនាងទេពរម្ភាឱ្យមកជួយ។ នាងទេពរម្ភាបានចូលទៅរំដោះរាមលក្ស្មណ៍បាន។ ព្រះរាមបាននាំចតុរង្គទៅតាមចាប់រាជកុមារ ប៉ុន្តែសង្គ្រាមមិនចាញ់ឈ្នះឡើយ។ ក្រោយមកក្សត្រទាំងអស់ដឹងសាវតាររបស់ខ្លួន។ ព្រះរាមព្យាយាមតាមអង្វរនាងសីតា ប៉ុន្តែត្រូវបាននាងអនុញ្ញាតឱ្យជួបត្រឹមព្រះភក្ត្រនិងពាក្យសំដីខ្លះៗប៉ុណ្ណោះ។ ព្រះរាមដឹងថាយកជ័យជំនះលើពាក្យសត្យរបស់នាងពុំបានក៏រកមធ្យោបាយសុំបុត្រ ដើម្បីឱ្យសីតាទៅតាម តែនាងមិនទៅ។ រាជកុមារបានអង្វរមាតាឱ្យវិលមកវិញ។ ប៉ុន្តែនាងសីតាបដិសេធ។ ជាចុងក្រោយព្រះរាមបានប្រើល្បិចចូលកោតបញ្ឆោតនាងសីតា ប៉ុន្តែនៅតែបរាជ័យ នាងសីតាក៏បានទៅរស់នៅឯឋានភុជង្គនាគពីពេលនោះទៅ។



ស្លឹកខ្លះខ្លោចខ្លះបីក្រហាម ស្បូវស្មៅត្រែងទ្រោម វិនាសនូវភ្លើងព្រៃដាល ។
តេជៈព្រះបាទភរនាថ៌ ពង្សពោធិសម្ភារ ក៏នាំទេពីលីលា ។
មើលមានព្រៃព្រឹក្សសាខា សងខាងមាគ៌ា សឹងប្រែត្រជាក់ដ៏សប្បាយ ។
លូតលាស់មេលាលេចលាយ ដុះដាលរឿងរាយ រូហានរបៀបភិរម្យ ។
ស្រោចស្រឹងឈរឈើងដង្កុំ ស្លឹកស្លោកបីត្រសុំ ត្រសាយត្រសៀកវាតា ។
បក់បោកក្លិនរសគន្ធា ធូរធុំសោះសា ឈ្មុយឈ្ងប់ត្រឡប់ខ្ចាយខ្ចរ ។
រោះរៃមធុរាមធុករ ភមរាភមរ ទ្រហឹងត្រាច់ត្រងត្រឹមផ្កា ។
សព្ទដូចតន្ត្រីសេពា ឮល្វែងអធ្វា ស្រងាត់ព្រះព្រៃពនេចរ ។
សូរ្យសែងចាំងចែងឯអម្ពរ ដូចព្រះចន្ទ្រចរ ត្រចះក៏ពេញបូណ៌មី ។
ពុំអាចនូវក្តៅក្សត្រទាំងបី ហេតុព្រះបារមី សម្តេចនារាយណ៌លីលា ។
ស្តេចត្រាច់ដោយដងមាគ៌ា ទៅឃល់ដើមច្បា មានផ្កាតែមួយច្រាស់ច្រាល ។
មានទងនន្ទោងវាវារ ផ្ការីកដ៏ត្រកាល តែមួយទៅលើផ្កាច្បា ។
ច្បាដុះជិតដើមចម៉្បា ចម៉្បាសោតមានផ្កា តែមួយក៏រីកតម្រួត ។
លើផ្កានន្ទោងជាក់ជួត ជិតជាបីត្រួត តម្រូវនូវកេសរគន្ធ ។
មានកន្លង់ពីរសោតសម្ផ័ន្ធ ជិតជាបីព្រួត ត្រឹបត្រងលំអងបុស្បី ។
ក្សិណនោះព្រះបាទនរបតី បង្ហាញរាជទេពី ថាសៃមេមើលអស្ចារ្យ ។
ឧបមាបុប្ផាពិព័រណ៌ ច្បានោះគឺឆ្ពរ ក៏ឆេះកំឡុងភ្លើងច្រាល ។
រីផ្កានន្ទោងនៅកណ្តាល ដូចសុពណ៌កាល រំលាយមាសមានរស្មី ។
រីផ្កាចម៉្បាពិសី ប្រាណប្រូតលើភ្នី ននោងរាយរីកបុប្ផា ។
នោះគឺនព្វគុណសុវណ្ណា ផ្សាផ្សំកែមគ្នា រលាយច្រឡំរស្មី ។
រីអង្គកន្លង់បក្សី គឺធ្យូងអប្រិយ នីលាមន្ទិលពុំថ្លើង ។
រីត្រួបកផ្កាច្បាច្រាលឡើង នោះគឺអណ្តាតភ្លើង ក៏ឆេះនៃឆ្ពរនោះណា ។
អង្គអញ្ជងងដូចផ្កាច្បា ជាឆ្ពរធានា អាចអត់នូវកម្តៅអគ្គិ ។
ននោងនោះគឺសីតាទេពី ចម៉្បាដ៏ពិសី គឺអង្គព្រះលក្ខ្មណ៍អនុជា ។
នាយើងទាំងបីអង្គា ឯកចិត្តចិន្តាដូចឆ្ពរនូវ មាសនោះហោង ។

រីកន្លង់នោះគឺធ្យូងផង ជាមន្ទិលហ្មង ដូចពាក្យនាងកែកេសី ។
ស្តេចចង់ប្រាថ្នាបុស្បី លោមរាជទេពី ពន្លកដង្កើមហាឫទ័យ ។
យាងយាត្រាត្រាច់ព្រឹក្សព្រៃ កន្លែងកន្លៃ សុវណ៌វនោវនេចរ ។
ដូចមហាមរកតដ៏បវរ ផ្លាសរស្មីស្មរ ដ៏រឿងទាំងព្រៃព្រឹក្សា ។
ស្តេចយល់បុស្បុស្សនានា រីកកេសរដ៏ជា សុរោធសុគន្ធាធរ ។
កន្លង់ទាំងគួភមរ ត្រងត្រឹបកេសរ ជញ្ជាបននៀលគន្ធាយក ។
កន្លង់ញីនោះសៀតស៊ក ជ្រៀតជ្រែកនូវត្របក បុស្សនាគបុប្ផាភាយករ ។
ល្អិតល្អងផង់ខ្ចាយខ្ចរ រុំភ្នែកភមរ ក៏ធ្មេចមមីមួម៉ៅ ។
ពុំយល់ផ្លូវផ្លោះហើរទៅ ឆ្ងាត់ឆ្ងៀលទំនៅ ទ្រហឹងវង្វេងវិលវល់ ។
រីកន្លង់ឈ្មោលមិញដឹងកល កន្លង់ញីពុំយល់ វេហាស៍នឹងហើរទៅស្ថាន ។
ឆ្ងៀលឆ្ងាត់រង្គាត់ដៅដាន សៀរទំទៀបប្រាណ ទ្រហឹងបន្លឺសព្ទឱ្យ ។
កន្លង់ញីឮហើយហើរដោយ ដល់ជិតតាមក្រោយ ទៅលុះដួចចិត្តចិន្តា ។
ស្តេចបង្ហាញអាយ៌អគ្គជាយា មេមើលភមរា ក៏នាំនៃភមរីហើរ ។
ដូចប្អូនមិត្រមាសដ៏ប្រសើរ អាចត្រាច់ព្រៃដើរ ក៏តាមអញ្ជបងនេះណា ។
រួមអង្គរួមឯកមេគ៌ា រួមស្ថាននិទ្រា ពុំគិតលំបាកពនេចរ ។
បើស្ថិតនៅនគរ ដូចកលកេសរ ក៏រុំភមរបក្សី ។
ហើយនឹងកើតអង្គឯងអប្រិយ មានមន្ទិលស្រី ជំណិះជំនៀលលោកផង ។
មេអាចស្ងះស្វែងតាមបង ដើរដោយនូវគន្លង កន្ទៃសាពើជ្ជពោញ្ញាណ ។
បងនឹងនាំមេកន្លង់លែងស្ថាន អវិជ្ជាបីបង្ខាន បង្វែងបង្វិលភពចក្រ ។
បងនឹងនាំមេមាសទៅដាក់ ដល់ស្ថានឥតជំពាក់ គឺមហានិរោធនិព្វាន ។
ស្តេចលោមព្រះប្អូនកល្យាណ បណ្តើរទៅបាន ដល់ស្ថានមណ្ឌលស្រះស្រី ។
មានបុស្សបោស្យ៌បោក្ខរណ៌ ក្រពុំប៉ិចពី គង្គាត្រៀបត្រីមទងត្រឹង ។
សឹងកូនថ្មើរព្រៃលេងទ្រហឹង ហែលហិចទៅរឹង កញ្ជ្រោកកញ្ជ្រៀវព្រមគ្នា ។
ខ្លះដេកដើមបទុមា ទាំងក្រពុំផ្កា បណ្តាលបណ្តែតទៅមក ។
គាប់កាលខ្យល់បក់នូវរលក ដើមឈូករសាត់មក ជំពាក់ទាំងទងទើរនៅ ។
មានមយូរីហើរទៅ ហេតុសត្វដ៏កម្លៅ ក៏យល់មទុមទងស្រស់ ។
ត្រូវខ្យល់យល់ហាក់ដូចរស់ គិតស្មានថាពស់ ក៏ចឹកចាប់ពាំនាំទៅ ។
ទើរទុកសំបុកដ៏លំនៅ បក្សីខ្លួនខ្លៅ ពុំដឹងដើមទងឈូកឡើយ ។

មានកូនពីរពេញក្រាសហើយ កូននោះយំឆ្លើយ មកមេទារភស្តុភោក្តា ។
ឯមេមយូរីឆ្លើយថា ហៅកូនពុំងា កុំយំអារម្មណ៍ទួញទារ ។
ថ្ងៃនេះម្តាយបានអាហារ ត្រកល់ត្រកាល ចំណីចំណង់នេះចម្លែក ។
ក្សិណមេមយូរីចឹកចែក ចំពុះពាំមែក នៃទងបទុមបីរាយ ។
ពុំបានបរិភោគសប្បាយ កូនខឹងនឹងម្តាយ បង្កើតជាទោសមួយសា ។
ថាទន្ទឹងអាហារ លុះល្ងាចឥតការ ពុំបានអាហារភោក្តា ។
ស្តេចស្តាប់កូនក្លោកថា បង្កើតទោសា នៃមេមយូរីបីកង្វល់ ។
ស្តេចបង្ហាញទេពីនិមល ហៅមេមាសយល់ នៃបក្សីមយូរបុត្រ ។
មួយនោះដូចថៅភិរុត មួយទៀតប្រាកដ ដូចថៅសុត្រុតប្អូនអញ ។
សមនឹងរកបងឯងសំណាញ់ បន្ទោសម្តាយមិញ គឺអញនាងកែកេសី ។
ព្រះលោមព្រះរាជទេពី អាឃើអគ្គមហេសី បណ្តើរដោយដងព្រៃភ្នំ ។
ទៅទៀតមណ្ឌលអាស្រម ស្ថានរ័ត្នចង្ក្រមន៍ នៃមហាឫសីស្មើងស្មាធិ ។
ព្រះនាមឥសីពាទ្យាទ្យ ផ្គត់ភ្នែនព្រះបាទ ចម្រើនចតុពាទ្យសាស្ត្រ ។
ទ្រង់ជដាមណ្ឌលអភិសេក ព្រះអង្គកាយពាតពាស នូវស្បែកម្រីគគិតដ៏ធ្ងើ ។
ស្តាយឆៀងសឹងសំបកឈើ សិទ្ធិស័ក្តិនូវអំពើ អំពល់ពិធីកុណ្ឌការ ។
អស់អញលំគេញដោយនូវធម្មា ចម្រើនពេសពណ៌ ជាមហាឫសីស្ងាត់ស្ងែង ។
មានពុកចង្កាគិតដ៏វែង មើលមុខគួរស្ញែង មហាឫសីសាស្ត្រសុទ្ធិ ។
ទាំងព្រះព្រហ្មសឹងដ៏ធំបំផុត ពិធីពព្រត មហាមុនីនិក្ខមិ៍ធ្យាន ។
ទោះនឹងធ្វើសិល្ប៍សាស្ត្របាន បរិបូណ៌មែនមាន តេជៈតបៈបុណ្យក្រៃ ។
យល់ព្រះពោធិសត្វថ្លៃ ព្រំព្រួយហឫទ័យ ក៏ត្រេកត្រអាលអរក្តាត់ ។
ដូចបុរសមួយមានតម្កាត់ ទៀបហៀបនឹងបាត់ ជីវិតនឹងលុះមរណា ។
យល់ព្រះដូចយល់ពេទ្យា យកឱសថថាទិព្យ ទេពព្រួសប្រស់ប្រោសប្រាណ ។
ថាទោះបាបអញមែនមាន តេជៈអញបាន ព្រះសព្វពុទ្ធង្កួលថ្លៃ ។
អស់បាបទាំងនោះសឹងក្សីយ អង្គអញឥតភ័យ វេរានុវេរវិងស្ងួង ។
ទោះបាបបុរាណចាំបង ច្រើនជាន់កន្លង ពុំអាចនឹងរកដ៏វេរា ។
ស្រេចព្រះមុនីចិន្តា ទ្រង់ឆត្រនាយា ឈើច្រត់កុណ្ឌីចរ ។
ចេរចាកមណ្ឌលស្ថានបរម៍ សាលាសាទរ ទៅគង់ស្ថានដ៏ឥសីចង្ក្រម ។
ទើបព្រះនារាយណ៍រាជឧត្តម បេះបុស្ប៍ក្រពុំ បទុមទាំងទងមាលា ។

ចរចូលបីដ៏ទូលបុប្ផា ថ្ងាត់ថ្ងាយអភិវាទ៍ នៃមហាឫសីដ៏មុនី ។
ព្រះមុនីអរឧបចក្រី ត្រេកត្រិះមេត្រី សំណេះសំណាលសួរថា ។
ហៅក្សត្រទ្រង់ឫទ្ធិចេស្តា ស្តេចមកពីឯណា ក៏នាំស្រីរតន៍ដ៏ប្រសើរ ។
អញនឹងចង់ដឹងដើមដំណើរ ស្តេចត្រាច់ព្រៃដើរ ត្រមោចព្រះរាមអនុជា ។
ហើយព្រះអង្គពីរពង្សក្សត្រា សឹងប្រែប្រាណជា មហាឫសីមុនីនាថ ។
ទ្រង់សំបកឈើពាក់សង្ហារ បង់ពីភពការ មកមានប្រការកលម្តេច ។
ទើបព្រះមុនីរាជសារពើជ្ញ ប្រាប់ពីប្រការកិច្ច មហាឫសីអស់អាថ៌ ។
ទើបមហាឫសីសង្ឃរ ថាបាបបុរាណការ វេរាចៀសចាកពុំបាន ។
វិស័យសត្វកើតក្នុងស្ថាន ភពចក្រប្រែប្រាណ ប្រដូចទិវារាត្រី ។
ក្សិណភ្លឺសាយសព្វទិសទី ដោយតេជះរស្មី ពន្លឺនៃព្រះសុរិយា ។
លុះព្រះសួរ្យសោតយាត្រា ក៏បាំងជ្រុងមហា សុមេរុមណ្ឌលបីស្រឡាប់ ។
ប្រែជាងងឹតឈឹងឈ្លប់ អន្ធការសោតសព្វ ទិសានុទិសពុំយល់ ។
នេះគណនាដូចកម្មផល កុសលអកុសល អំពល់អំពើមុខ ។
បង្កើតកាលកបន្តវសុខ ហើយបង្កើតទុក្ខ ពុំដែលនឹងចាកចៀសឡើយ ។
លុះបាននិញ្ជនជាបង្ហើយ នោះនៃទើបស្បើយ រំដោះលែងជរាមរណ៍ ។
ព្រះមហាឫសីសាទរ នាំព្រះភូធរ ទេពីនូវព្រះអនុជា ។
ចូលទៅក្នុងបរមសាលា ថ្វាយភោជន៍ផលា ទាំងបីព្រះអង្គសោយសាន្ត ។
ស្តេចផ្ទំនៅអាស្រមស្ថាន សុខស្តល់ក្បែមក្សាន្ត បង់អស់មួយរាត្រីកាល ។
លុះព្រឹកស្រាងស្រេចភូបាល ស្តេចតើនបីត្រអាល ជំរះព្រះអង្គសោភា ។
ស្តេចនាំទេពីអនុជា បង្គំព្រះមហា ឥសីនឹងលាចរឹចរ ។
ព្រះមហាមុនីសិទ្ធិករ ចម្រើនព្រះពរ សម្តេចព្រះនារាយណ៍រាមា ។
ព្រះឫសីដណ្តើងវឹងថា នាអ្នកលីលា មកនៅកំឡុងព្រះព្រៃ ។
ធ្វើក្រត្យក្រមតបៈគុណត្រៃ ព្រ័ទសិល្ប៍សាស្ត្រសែយ ប្រពៃពិធីកាយកម្ម ។
លុះអំឡុងអំបាលខែឆ្នាំ ហើយស្តេចក៏និងនាំ ទេពីអនុជភូធរ ។
វិលវឹងត្រាច់ព្រៃពនេចរ ចូលថ្ពាន់ព្រះនគរ ពិភពបុរីរាជស្ថាន ។
ទើបស្តេចទូលស្នងវឹងថ្ពាន ថាខ្ញុំទៅបាន លុះបួនដណ្តប់ឆ្នាំណា ។
ស្រេចហើយវិលវឹងយាត្រា ថ្ពាន់ស្រីពូយុធ្យា ពិភពមណ្ឌលស្ថានស្ថិត ។
សូមលាព្រះបាទដ៏បពិត្រ មុនីសាស្ត្រសុចរិត ស្តេចណៃនៃមាគ៌ាស្ថាន ។

ពីនេះទៅតើចម្ងាយប៉ុន្មាន យើងខ្ញុំក៏នឹងបាន ដល់ចិត្រកូដបពិត ។
ព្រះមុនីប្រាប់ដោយនូវកំណត់ ថាដប់យោជន៍គត់ គណនាស្តេចទៅពីអាយ ។
លុះកណ្តាលផ្ទៃវាយវែនាយ ធាធំទូលាយ លលឹមលលៀកសោតសល់ ។
ទូរគមក្រក្រៃដើរដល់ ផ្លូវនោះអំពល់ នូវខ្សាច់ក្រួសក្រៀមក្តៅក្តាត់ ។
ប្រណីទេពីរូបវ័តន៍ ឥឡូវអញសូមឃាត់ ស្តេចគង់នៅស្ថាននេះណា ។
ទោះនឹងធ្វើព្រតព្រឹទ្ធសាស្ត្រា អញឯងធានា ពុំឱ្យព្រួយព្រះហឫទ័យ ។
ស្តេចស្តាប់ព្រះមុនីមានមៃ ត្រីឃាត់ក្សត្រថ្លៃ ក៏ស្តេចបន្ទូលស្នង ។
បពិត្រគួរខ្ញុំនៅហោង ពុំគួរនឹងកន្លងព្រះ ឱស្ថពិសេសចិន្តា ។
មោះខ្ញុំស្ថាននេះណា ទៀបនឹងពួយុធ្យា ចំណេរឮព័ត៌មាន ។
ទៅទាល់ផៅពង្សដ៏សន្តាន បងប្អូនខ្ញុំមាន នឹងមករកឯងខ្ញុំឯងហោង ។
ស្រេចព្រះបន្ទូលសាសង ពុំឱ្យមានឡង នឹងព្រះឥសីលីលា ។
ស្តេចថ្វាយនមស្សការអភិវាទ៍ ប្រទក្សិណលា មហាមុនីចរចេរ ។
ស្តេចត្រាច់ព្រៃលុះលេចដល់ឆ្នេរ គង្គាគម្ពីរ ពន្លឺកដ៏មហានទី ។
រីឈ្មោះស្ទឹងនោះនាមពី ព្រេងហៅកាលតី នទីទូលាយជ្រាលជ្រៅ ។
ព្រះអង្គចុះស្រង់បន្ទោ មន្ទិលសោះក្តៅ បន្ទូលនឹងព្រះអនុជវ័តន៍ ។
ហែលក្បួណ៍ស្ទឹងនេះធំក្តាត់ បារម្ភក្រែងសត្វ ឃារីគរចរពារធា ។
អាសូរសីតាបងបា សមនឹងកើតភយា ម្រាំងឡើយនឹងអាចឆ្លងបាន ។
ព្រះលក្បួណ៍ស្តាប់ព្រះបន្ទូលថ្កាន ហេតុព្រះអង្គមាន ហាឫទ័យបម្រុងជេស្ឋា ។
ពុំឱ្យព្រួយព្រះចិន្តា ស្តេចយកខ័នថ្នា ទៅកាត់ក្របែលឈើចង ។
ជាក្បួនមានត្រែទែនផ្គង បេះបុស្ប៍ក្រាលក្រង ទាំងទងមាលាបីសសាប់ ។
ជាព្រះក្រាលទិព្វស្រេចស្រាប់ លើទែនទិព្វគាប់ នូវក្បួនដ៏ពិចិត្រ ។
ថ្វាត់ថ្វាយព្រះបាទដ៏បពិត្រ ពីរព្រះអង្គស្ថិត ព្រះលក្បួណ៍ក៏ហែលនាំឆ្លង ។
ទៅបានត្រើយត្រាណដួចបំណង ក្សត្រក្សាន្តឥតហ្មង ទាំងបីព្រះអង្គយាត្រា ។
ត្រាច់ត្រង់ព្រៃព្រឹក្សបព្ភតា លុះលេចអធ្វា ស្តេចគាត់បទវាលវែងនាយ ។
ស្ទឹងភ្លើងព្រៃឆេះព្រោងព្រាយ ច្រាល់ច្រាស់ផ្សែងផ្សាយ ចំហាយព្រះសូរវង្សី ។
ស្តេចធ្យានសូត្រសានស្តូតី ដោយតេជៈពរពី ព្រះពិស្ណុមិត្រអភិទេស ។
ទិព្វមន្តខ្លឹមគុណដ៏វិសេស ស្ថាននោះនិរទេស ចំហាយព្រះសូរ្យយាត្រា ។
ត្រជាក់ដួចព្រះចន្ទនាយា លួតលាស់ព្រឹក្សា បុប្ផាផលផងបីរំយុរ ។

ដូចនន្ទឧទ្យានស្ថានសួគ៌ សួគ៌គិតដ៏គួរ កន្លែងសម្តេចឥន្ទ្រា ។
អស់ថ្មើរព្រៃស្ងែងម្រីគា សោតសឹងប្រែជា មេត្តាអាសូរសត្វផង ។
រីអស់សត្វម្រឹគយង់ឃ្នង សឹងជាសត្រូវផង បំបាត់ជីវិតគ្នាមិញ ។
សឹងប្រែចិត្តជាសំណាញ់ ស្នាលស្នេហ៍ស្និទ្ធវិញ ដោយភាសាសត្វមេត្រី ។
គជបុត្រចៅមេរាជសីហ៍ គជរាជហត្ថី បំបៅបុត្ររាជសីហ៍ភ្លា ។
កូនប្រើសប្រែចៅមេខ្លា មេប្រើសប្រែជា បំបៅបុត្រខ្លាស្នេហ៍ស្និទ្ធ ។
អស់ម្រឹគបក្សីសុចរិត ក្សេមក្សាន្តមូលមិត្រ រក្សាសុបាលស្នេហ៍ស្នង ។
ទោះភ្លែបខ្ចីយពស់ពិសផង សព្វសត្វយង់ឃ្នង នូវពិសដ៏ឃោរឥតប្រាណ ។
ទោះខាំទោះកំសួលប្រួលប្រាណ អ្នកណាបើបាន ទៅត្រូវនូវពិសបីចំហុត ។
ដូចអ្នកយកទិព្វដ៏ឱសថ មកព្រួសប្រាកដ កំណត់រូបរោគាពាធ ។
សាន្តសុសសព្វសារពើព្យាធី អង្គឯងស្ងែងស្អាត និមិត្តអប្រិយដ៏ពិសស្តែង ។
ទោះបីមើមផលរុក្ខរែង ពិសពស់ពុលស្ងប់ស្ងែង ក្រៃលែងអាសិរពិសផង ។
សឹងប្រែប្រាណរសវឹងហោង មធុករដ៏កន្ទង ក្រអូបក្រអែបក្លិនក្លាយ ។
ស្តេចលីលាមាគ៌ានោះចម្ងាយ សឹងសូរភីភាយ ត្រលប់ត្រលោមគន្ធា ។
តេជបារមីតា ស្តេចស្តែងជាតិជា ឥសូរកំពូលពុទ្ធពង្ស ។ [...]



សំណួរ

១. ចូរបង្ហាញពីប្រភពនិងប្រភេទរបស់អត្ថបទដកស្រង់នេះ ។
២. ចូរបង្ហាញពីលក្ខណៈព្រាហ្មណ៍និយមនៅក្នុងអត្ថបទដកស្រង់នេះ ។
៣. តើអត្ថបទនេះមានតួអង្គណាខ្លះ ?
៤. ចូរបង្ហាញពីកាលអាកាសរបស់អត្ថបទនេះ ។
៥. ចូរបង្ហាញពីវិធីតែងនិពន្ធ (ពណ៌នាវិធី សំវាទវិធី ឧបមានវិធី បដិវិធី វចនវិធី ...) ដែលអ្នកនិពន្ធប្រើក្នុងអត្ថបទដកស្រង់នេះ ។
៦. ចូរសង្ខេបអត្ថបទនេះជាពាក្យរាយ ។

រំលើកបញ្ញត្តិ : លក្ខណៈអក្សរសិល្ប៍

១ . លក្ខណៈមនុស្ស

លក្ខណៈមនុស្សក្នុងអក្សរសិល្ប៍ គឺលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយទៅតាមសកម្មភាពធម្មតារបស់មនុស្ស ដោយបង្កើតជាបញ្ហានៅក្នុងរឿងហៅថា "បញ្ហាមនុស្ស" ។ ម្យ៉ាងទៀត ទោះបីជាអ្នកនិពន្ធលើកយកតួអង្គប្រភេទណាមកបង្ហាញក៏ដោយ ក៏តួអង្គនោះតំណាងឱ្យមនុស្សដែរ ។ ការចោទនិងដំណោះស្រាយរកលក្ខណៈមនុស្សមានឈ្មោះថា ជាការស្រាវជ្រាវរកមនុស្សលក្ខណៈនៅក្នុងស្នាដៃអក្សរសិល្ប៍ ។

២ . លក្ខណៈសង្គម

លក្ខណៈសង្គមរបស់អក្សរសិល្ប៍ស្ថិតនៅលើអត្ថបទដែលលើកយកបញ្ហាមនុស្សក្នុងសង្គមណាមួយមកចោទនិងដោះស្រាយតាមសភាពលក្ខណៈរបស់ខ្លួន ទោះបីចម្រើនក្តី ធម្មតាក្តី ឬអន់ថយក្តី ។ មតិយោបល់ទាំងឡាយដែលបានចោទនិងដោះស្រាយក្នុងអត្ថបទភាគច្រើនត្រូវតំណាងឱ្យសង្គមារម្មណ៍ណាមួយ ហើយទ្រទ្រង់នូវមូលទស្សនៈសង្គមនោះសម្រាប់ដោះស្រាយបញ្ហាក្នុងសង្គមរបស់ខ្លួន ។ ដូច្នេះ តួអង្គនីមួយៗមិនត្រូវតំណាងតែមតិយោបល់និងសកម្មភាពរបស់ខ្លួនមួយនៅក្នុងរឿងទេ តែត្រូវតំណាងសង្គមារម្មណ៍ ឬមនុស្សភាគច្រើន ។ ហេតុដូច្នេះហើយបានជាគេពោលថា "អក្សរសិល្ប៍ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងនូវគតិភាពសង្គម" ។ ជារួម តាមរយៈស្នាដៃអក្សរសិល្ប៍យើងអាចយល់បានច្បាស់ពីបញ្ហាសង្គម ទស្សនៈសង្គមដែលទ្រទ្រង់សម័យកាលនីមួយៗតាមរយៈការឆ្លុះបញ្ចាំងរបស់ស្នាដៃនេះ ។

៣ . លក្ខណៈឥណ្ណៈ

អក្សរសិល្ប៍ គឺជាការឆ្លុះបញ្ចាំងនូវរូបភាពមនសិការសង្គម ដូច្នេះអក្សរសិល្ប៍ត្រូវតែឆ្លុះបញ្ចាំងនូវមូលដ្ឋានជាក់ស្តែងមួយជាដាច់ខាត ។ នៅក្នុងសង្គមមានវណ្ណៈ មូលដ្ឋានជាក់ស្តែងនេះសម្តែងឡើងនូវការតស៊ូវណ្ណៈ ហើយកំណត់វណ្ណៈច្បាស់លាស់ ។ ចរិតលក្ខណៈនេះ បានស្តែងឡើងតាមរបៀបរស់នៅ ទឹកចិត្ត ស្មារតី សញ្ចេតនា ផលប្រយោជន៍សេដ្ឋកិច្ចរបស់មនុស្ស ដែលស្ថិតក្នុងស្រទាប់វណ្ណៈសង្គមខុសគ្នា ។ ដោយស្នាដៃអក្សរសិល្ប៍មានលក្ខណៈវណ្ណៈ ដូច្នេះអ្នកនិពន្ធដែលជាអ្នកបង្កើតស្នាដៃអក្សរសិល្ប៍ពិតជាត្រូវស្ថិតនៅក្នុងស្រទាប់វណ្ណៈណាមួយជាកំណត់ ។ នៅគ្រប់សម័យកាលសង្គមអក្សរ

សិល្បៈប្រភេទណាក៏ដោយសុទ្ធតែបម្រើផលប្រយោជន៍វណ្ណៈណាមួយនិងជាអ្នកនាំពាក្យរបស់អ្នកណាមួយជានិច្ច។ ហេតុនេះ ទើបស្នាដៃអក្សរសិល្បៈណាក៏ដោយ ចរន្តអក្សរសិល្បៈណាក៏ដោយ ខឿនអក្សរសិល្បៈណាក៏ដោយ សុទ្ធតែមានលក្ខណៈវណ្ណៈ។ ពេលដែលអ្នកនិពន្ធបានយល់ច្បាស់ពីផលប្រយោជន៍និងតួនាទីរបស់គេ ហើយគេនឹងអះអាង ប្តូរផ្តាច់ប្រើប្រាស់ប៉ាកការបស់ខ្លួនធ្វើជាអាវុធតស៊ូដើម្បីជ័យជំនះរបស់វណ្ណៈមួយ ពេលនោះវណ្ណៈបានរីកចម្រើន ហើយក្លាយទៅជាលក្ខណៈបក្ស។ ដើម្បីកំណត់លក្ខណៈវណ្ណៈរបស់អក្សរសិល្បៈ យើងត្រូវពិនិត្យទៅលើគំនិត សញ្ចេតនា ឧត្តមគតិ សោភ័ណដែលផុសចេញពីស្នាដៃនោះ។ លក្ខណៈវណ្ណៈស្តែងឡើងតាមរយៈវិធីនិម្មិតកម្មរបស់អ្នកនិពន្ធទៅតាមរចនាបថវិធីនិងកម្លាំងទឹកចិត្តទៅលើវណ្ណៈរបស់គេផងដែរ។ នៅក្នុងសង្គមមានវណ្ណៈ អ្នកនិពន្ធក្នុងក្របខណ្ឌនៃសមាជិកវណ្ណៈមួយតែងទទួលការបណ្តុះបណ្តាលមនោគមវិជ្ជាអំពីវណ្ណៈរបស់និងមានទស្សនៈនយោបាយ បម្រើនយោបាយគេជានិច្ច។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អ្នកនិពន្ធកវីសិល្បករមួយចំនួនក៏មិនសុទ្ធតែចំណុះឱ្យវណ្ណៈរបស់ខ្លួនគ្រប់បញ្ហានិងពេលវេលាដែរ។ ដូច្នេះ លក្ខណៈវណ្ណៈនៅក្នុងមនសិការរបស់មនុស្សម្នាក់ៗក៏មានការវិវត្តដែរ។

៥ . លក្ខណៈប្រជាជន

ស្នាដៃអក្សរសិល្បៈ ដែលមានលក្ខណៈប្រជាជន ជាស្នាដៃយកចិត្តទុកដាក់លើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទាំងជីវភាព ភាសា ស្មារតី សម្ភារៈ... ។ មានន័យថា ស្នាដៃអក្សរសិល្បៈដែលមានលក្ខណៈប្រជាជននិយាយយ៉ាងច្រើនពីផ្នត់គំនិត សតិអារម្មណ៍ ព្រលឹង ចំណង់ចំណូលចិត្តរបស់ប្រជាជន ហើយជាងនេះទៅទៀត បានចេញមុខការពារយ៉ាងប្តូរផ្តាច់នូវផលប្រយោជន៍ប្រជាជនប្រឆាំងនឹងអំពើកេងប្រវ័ញ្ចសព្វបែបយ៉ាងនៃក្រុមឱកាសនិយមនិងវណ្ណៈជិះជាន់។ ម្យ៉ាងទៀត ស្នាដៃប្រភេទនេះទាមទារផងដែរនូវការបង្ហាញពីមនោសញ្ចេតនា ឧត្តមគតិ និងសុច្ឆន្ទៈ ព្រមទាំងលើកកំពស់នូវបញ្ហាខាងលើនេះ ដើម្បីបម្រើនូវសេចក្តីត្រូវការក្នុងជីវភាពប្រជាជននិងមានអត្ថន័យសង្គមយ៉ាងធំធេងប្រកបដោយលក្ខណៈប្រជាធិបតេយ្យទៀតផង។ ពិសេសទៅទៀត អ្នកនិពន្ធបានប្រើភាសា ពាក្យពេចន៍ ដែលមហាជន ប្រជាជនចូលចិត្ត ស្រួលអាន ស្រួលស្តាប់ ងាយយល់។ ចំណែកស្នាដៃអក្សរសិល្បៈដែលគ្មានលក្ខណៈប្រជាជនជាអក្សរសិល្បៈដាច់ចេញពីប្រជាជន និពន្ធឡើងដើម្បីតែបុគ្គល ដើម្បីវណ្ណៈរបស់គេ។

៥ . លក្ខណៈបក្ស

ជាការស្តែងចេញពិសេសមួយរបស់វណ្ណៈក្នុងស្ថានភាពមួយ ដែលមានការតស៊ូតឹងតែង លក្ខណៈបក្សផ្តើមចេញពីលក្ខណៈវណ្ណៈ ដែលជាសារជាតិ ជាក្រិតក្រមរបស់សង្គម និងជនជាតិចាប់តាំងពីពេលដែលមនុស្សមានការបែងចែកជាពួក ជាក្រុមទៅតាមទស្សនៈ គោលការណ៍ លទ្ធិឬ មនោគមវិជ្ជា ...តែក្រុមពួកនីមួយៗ ។ ចំណុចពិសេសៗនៃលក្ខណៈបក្សមាន :

- បំផុសស្មារតី ឧត្តមគតិស្នេហាជាតិ មាតុភូមិរបស់ប្រជាពលករ
- បំផុសស្មារតី បញ្ចុះបញ្ចូលអ្នកអាន អ្នកស្តាប់ អ្នកទស្សនាឱ្យលង់ជំនឿទៅលើបក្សណាមួយ
- ផ្សព្វផ្សាយឥទ្ធិពលដឹកនាំនិងសកម្មភាពរបស់បក្សក្នុងការកសាងមាតុភូមិ
- ជាស្នាដៃបម្រើនយោបាយនិងបម្រើគោលមាគ៌ារបស់បក្ស ការពារផលប្រយោជន៍របស់បក្ស ដោយផ្សារភ្ជាប់ទៅនឹងផលប្រយោជន៍ជាតិ ។

លក្ខណៈទាំងអស់នេះមានន័យថា គំនិតរបស់អ្នកនិពន្ធ កវី សិល្បករ ផ្តើមឡើងដោយខ្លួនឯង ជាអ្នកយល់ជ្រួតជ្រាបយ៉ាងជ្រាលជ្រៅលើគោលការណ៍បក្សដែលខ្លួនប្រកាន់យក ។ ជាក់ស្តែងដូចជា វាគ្មិន ប្រព័ន្ធឃោសនាដែលប្រកាន់យកនិន្នាការគណបក្សនយោបាយជានិច្ច គឺនិយាយដើម្បីអូសទាញ ប្រជាជនឱ្យមានជំនឿមកលើបក្សរបស់គេ ហើយការនិយាយក៏ជាការលើកសរសើរបក្ស បម្រើឧត្តម គតិនិងផលប្រយោជន៍របស់បក្ស ។

៦ . លក្ខណៈប្រវត្តិ

ជាលក្ខណៈមួយដែលស្នាដៃអក្សរសិល្ប៍ទាក់ទងទៅនឹងសម័យកាល ឬព្រឹត្តិការណ៍ខ្លះៗដែលកើតមានឡើងនៅក្នុងប្រវត្តិសាស្ត្រ ។ ប៉ុន្តែយើងត្រូវយល់ថា អក្សរសិល្ប៍ពុំដូចគ្នានឹងប្រវត្តិសាស្ត្រ ដែលមានទាំងកត់ត្រានូវរឿងរ៉ាវ ឬព្រឹត្តិការណ៍ផ្សេងៗបានកើតមានឡើងក្នុងសង្គមនីមួយៗនោះឡើយ ។

៧ . លក្ខណៈជាតិ

អក្សរសិល្ប៍មានដែលលក្ខណៈជាតិជាស្នាដៃ ដែលបានបង្ហាញនូវតម្លៃពិសេសរបស់ជាតិមួយ ដែលខុសប្លែកពីបរទេសតាំងពីជំនឿ ទំនៀមទម្លាប់ ប្រពៃណី ទស្សនៈ ចិត្តគំនិត និងអាកប្បកិរិយាផ្សេងៗ ។ គេចាត់ទុកអក្សរសិល្ប៍មានលក្ខណៈជាតិ គឺជាស្នាដៃអក្សរសិល្ប៍ដែលទ្រទ្រង់ព្រលឹងរបស់ជាតិឱ្យមានភាពស្ថិតស្ថេរជាអមតៈ ។ លក្ខណៈជាតិក្នុងអក្សរសិល្ប៍នេះ ស្តែងឡើងតាមអត្ថន័យនិង

អត្តរូប ដែលស្នាដៃបានលើកពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ភាសា វប្បធម៌ ទិដ្ឋភាព ធម្មជាតិ សោភ័ណភាពរបស់ប្រទេសជាតិមកធ្វើជាកម្មវត្ថុ ឆ្លុះបញ្ចាំងក្នុងក្របខណ្ឌប្រធានបទនៃលក្ខណៈជាតិ ទោះជាតាមរយៈបទចម្រៀង កំណាព្យ ឬសិល្បៈផ្សេងៗ។ ការចោទនិងការដោះស្រាយបញ្ហាស្នាដៃនីមួយៗសុទ្ធតែបំផុសទឹកចិត្តស្នេហាជាតិមោទនភាពជាតិ មនសិការ ឯករាជ្យ សេរីភាព។ ពិសេសស្នាដៃនេះមិនត្រឹមតែបង្ហាញពីគោលបំណងដណ្តើមសិទ្ធិអំណាចជូនមាតុភូមិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញនូវយុទ្ធសាស្ត្រ យុទ្ធវិធី និងវិធានការតស៊ូដោយខ្លួនឯងផ្ទាល់ទៀតផង។ លក្ខណៈជាតិកាន់តែចូលជ្រៅថែមទៀតទៅក្នុងការបង្ហាញរូបារម្មណ៍ កាបង្ហាញតួអង្គ និយាយដោយឡែកជាមួយនឹងស្មារតីព្រលឹង និងលក្ខណៈជាតិនីមួយៗផ្ទាល់។ វិធីតែងនិពន្ធ គឺជាភាពបន្សំដ៏ប៉ិនប្រសប់រវាងអត្ថន័យនិងអត្តរូប ដែលមានការសម្រិតសម្រាំងយ៉ាងល្អនៅក្នុងតថភាពអក្សរសិល្ប៍និងក្នុងប្រព័ន្ធគំនិតក៏នាំមកនូវលក្ខណៈជាតិនេះផងដែរ។ លក្ខណៈវិនិច្ឆ័យនៃស្នាដៃដែលមានលក្ខណៈជាតិរួមមាន ៖

- បង្ហាញនិងបំផុសនូវសេចក្តីស្នេហាចំពោះមាតុភូមិ ស្មារតីតស៊ូប្រកបដោយថាមពលល្អប្រពៃដែលពុំអាចបង្ក្រាបបាន
- បណ្តុះស្មារតីគ្រឹះនិងការពារប្រទេសក្នុងឆន្ទៈឯករាជ្យ
- បង្ហាញតួអង្គដែលពោរពេញទៅដោយចិត្តសាស្ត្រនិងលក្ខណៈជាតិ
- អ្នកនិពន្ធចេះប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវឃ្លាប្រយោគ ពាក្យពេចន៍របស់ជាតិច្បាស់លាស់
- អ្នកនិពន្ធចេះប្រើយ៉ាងស្ទាត់ជំនាញនិងទូលាយនូវសិល្បៈរូបារម្មណ៍ស្របតាមសោភ័ណរស

រីឯស្នាដៃដែលមានប្រភពមកពីបរទេស ក៏អាចមានលក្ខណៈជាតិបានដែរ ប៉ុន្តែលុះត្រាតែអ្នកនិពន្ធចេះកែច្នៃបូកផ្សំធាតុចាស់និងធាតុថ្មីធ្វើយ៉ាងណាឱ្យបានធាតុថ្មីមួយទៀត ដែលមានលក្ខណៈស្របទៅនឹងទស្សនៈចំណង់ចំណូលចិត្តជាតិរបស់ខ្លួន ធ្វើឱ្យស្នាដៃក្លាយទៅជានិមិត្តរូបជាតិ ដោយមានអត្ថន័យ អត្តរូប និងអត្ថរសល្អ។ តាមធម្មតាជនជាតិនីមួយៗមានលក្ខណៈតម្លៃ ពិសេសក្នុងការឆ្លុះបញ្ចាំងចិត្តគំនិតគេ។ ដូច្នេះ អ្នកនិពន្ធត្រូវបំផុសបង្ហាញយ៉ាងណាឱ្យឃើញទំនៀមទម្លាប់ ប្រពៃណីល្អរបស់ជាតិ រួចការពារដួងព្រលឹង និងនិមិត្តរូបរបស់ជាតិឱ្យស្ថិតស្ថេរគង់វង្ស និងចេះច្នៃឥទ្ធិពលបរទេសឱ្យស្របនឹងវប្បធម៌ជាតិ។ ក្រៅពីនេះ លក្ខណៈជាតិក៏តម្រូវឱ្យមានការទទួលយកវប្បធម៌បរទេសជឿនលឿនមកបំពេញបន្ថែមលើវប្បធម៌ជាតិខ្លួនឱ្យកាន់តែមានភាពប្រសើរឡើងដែរ ប៉ុន្តែត្រូវស្ថិតក្នុងលក្ខខណ្ឌរក្សាលក្ខណៈជាតិជានិច្ច។

៨ . លក្ខណៈអន្តរជាតិ

មនុស្សយើងក្រៅពីរួមផ្តុំជនជាតិ នៅមានការរួមផ្តុំអន្តរជាតិផងដែរ។ មានន័យថា អក្សរសិល្ប៍បានជះឥទ្ធិពលទាំងផ្នែកអត្ថន័យ អត្ថរូបទៅលើឆាកអន្តរជាតិទទួលយកមកសិក្សាដូចស្មាដៃជាតិរបស់ខ្លួនដែរ។ លក្ខណៈអន្តរជាតិ គឺជាលក្ខណៈមួយរបស់អក្សរសិល្ប៍ បន្ទាប់ពីស្មាដៃមានលក្ខណៈជាតិរួចហើយ។ បានន័យថា នៅពេលដែលជាតិទទួលស្គាល់ថា រឿងនេះមានតម្លៃទ្រង់ទ្រាយ វប្បធម៌ជាតិហើយបរទេសក៏បានមករៀនសូត្រផ្សព្វផ្សាយនៅក្នុងអន្តរជាតិរបស់គេ។ ពេលនោះហើយ ដែលអក្សរសិល្ប៍មានលក្ខណៈអន្តរជាតិ។ លក្ខណៈវិនិច្ឆ័យនៃលក្ខណៈអន្តរជាតិរបស់អក្សរសិល្ប៍រួមមាន ៖

- ជាស្មាដៃដែលបម្រើនូវឧត្តមគតិ ផលប្រយោជន៍របស់មនុស្សជាតិទូទៅ
- ខ្លឹមសារនៃស្មាដៃបានបម្រើផលប្រយោជន៍សង្គម សមូហភាព អន្តរជាតិ
- ជាស្មាដៃដែលសិក្សាស្រាវជ្រាវស៊ីជម្រៅលើផ្នែកសង្គមសាស្ត្រ មនោគមវិជ្ជា នយោបាយ សង្គមស្រាវជ្រាវផ្សព្វផ្សាយពីការរីកចម្រើនបច្ចេកទេសវិទ្យាសាស្ត្រ ដើម្បីធ្វើឱ្យជីវិតមនុស្សជាតិទាំងមូលរស់នៅប្រកបដោយសុខមាលភាពសុភមង្គល។
- ស្មាដៃបានបង្កើតនូវតួតាងខ្លះដែលមានឧត្តមគតិ ហើយតាមរយៈឧត្តមគតិនេះ គេបានបញ្ចេញនូវសកម្មភាព ដែលគួរដកស្រង់ធ្វើជាមេរៀនជាគំរូនៃបទពិសោធក្នុងការត្រិះរិះពិចារណានិងយកទៅអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សជាទូទៅ។



ការសិក្សាអំពីលិខិតផ្លូវការរដ្ឋបាល

លិខិតរដ្ឋបាលធ្វើឡើងសម្រាប់ទាក់ទងគ្នាជាផ្លូវការពីស្ថាប័នខ្ពស់មកស្ថាប័នទាប ឬពីស្ថាប័នទាបទៅស្ថាប័នខ្ពស់ ឬស្ថាប័នដែលមានឋានៈស្មើនិងប្រហាក់ប្រហែលគ្នា។ ទម្រង់លិខិតរដ្ឋបាលនីមួយៗចែកចេញជាបីផ្នែក គឺផ្នែកក្បាល(ដើម) ផ្នែកអត្ថបទ(កណ្តាល) និងផ្នែកបញ្ចប់(បញ្ចប់)។ ចូរអានទម្រង់គំរូលិខិតរដ្ឋបាលខាងក្រោម ៖

- **លិខិតពីស្ថាប័នខ្ពស់ទៅស្ថាប័នទាប**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលារាជធានីភ្នំពេញ

លេខ ..... រាជធានីភ្នំពេញ , ថ្ងៃទី .....ខែ .....ឆ្នាំ ២០ ...

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ
គោរពមក
លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ

កម្មវត្ថុ : ការធ្វើបដិសណ្ឋារកិច្ច

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំសូមជម្រាបលោកថា នៅសាលារាជធានីភ្នំពេញត្រូវរៀបចំធ្វើបដិសណ្ឋារកិច្ចក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ..... ប្រធានរដ្ឋសភា ប្រទេស .....នៅថ្ងៃទី .....ខែ .....ឆ្នាំ ២០.... វេលាម៉ោង ៩ : ៣០នាទីព្រឹក។

អាស្រ័យហេតុនេះ សូមលោកមេត្តាជួយផ្សព្វផ្សាយនិងរៀបចំចាត់ចែងបុគ្គលិកសិក្សានិងសិស្សានុសិស្សទាំងអស់របស់លោកចូលរួមក្នុងពិធីនេះឱ្យបានច្រើនកុះករ។

សូមលោកទទួកនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ
ហត្ថលេខា ឈ្មោះ និងត្រា

ចម្លងជូន
-គ្រប់មន្ទីរជុំវិញរាជធានី
"ដើម្បីចូលរួម"
-ឯកសារកាលប្បវត្តិ

• **លិខិតពីស្ថាប័នទាបទៅស្ថាប័នខ្ពស់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខណ្ឌ (ដ.ក)

លេខ .....

អភិបាលខណ្ឌ (ដ.ក)

គោរពមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ

កម្មវត្ថុ : សំណើសុំជ្រើសរើសបុគ្គលិក

សេចក្តីដូចបានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំបាទមានកិត្តិយសសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា សព្វថ្ងៃនេះនៅការិយាល័យរដ្ឋបាលខណ្ឌ(ដ.ក) មានការខ្វះខាតបុគ្គលិកបម្រើការចំនួន ០១នាក់ ។

អាស្រ័យហេតុនេះសូមឯកឧត្តម មេត្តាអនុញ្ញាតឱ្យសាលាខណ្ឌជ្រើសរើសបុគ្គលិកតាមចំនួនត្រូវការដោយអនុគ្រោះ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ភ្នំពេញ , ថ្ងៃទី ..... ខែ .....ឆ្នាំ ២០១១

អភិបាលខណ្ឌ

ហត្ថលេខា ឈ្មោះ និងត្រា

ចម្លងជូន
-ឯកសារកាលប្បវត្តិ

លំហាត់

ចូររៀបគ្នាជាក្រុមតូចៗ រួចពិភាក្សាសរសេរលិខិតផ្លូវការរដ្ឋបាលតាមទម្រង់ខាងលើ ។

១. សរសេរលិខិតពីអង្គភាពអ្នកជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាមរយៈការិយាល័យអប់រំស្រុក ។


២. សរសេរលិខិតអញ្ជើញមាតាបិតា សហគមន៍ អាជ្ញធរឱ្យចូលរួមក្នុងពិធីមួយក្នុងសាលារបស់អ្នក ។

៣. សរសេរលិខិតពីស្ថាប័នទាបទៅស្ថាប័នខ្ពស់និងពីស្ថាប័នខ្ពស់ទៅស្ថាប័នទាប ។

មេរៀនទី



អក្សរសិល្ប៍ពុទ្ធនិយម



អក្សរសិល្ប៍ពុទ្ធនិយម គឺជាអក្សរសិល្ប៍ដែលទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា។ រឿងក្នុងគោលពុទ្ធនិយមមានលក្ខណៈខុសប្លែកពីរឿងក្នុងគោលព្រាហ្មណ៍និយម ដោយគោលគំនិតធំ ឬមូលបញ្ហានៃរឿងពុទ្ធនិយម គឺការសាងបារមីរបស់ព្រះពោធិសត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធ។ ដំណោះស្រាយបញ្ហាក្នុងរឿងពុទ្ធនិយម គឺអហិង្សា ឬសន្តិវិធី។ រឹងតួអង្គឯកប្រុសជាព្រះពោធិសត្វនិងតួអង្គឯកស្រីជាកន្សែសពើជ្ឈ។ ចុងបញ្ចប់នៃរឿង គឺការសរជាតិ។ រឿងក្នុងអក្សរសិល្ប៍ពុទ្ធនិយម មានពីរបែប គឺរឿងពុទ្ធនិយមសុទ្ធសាធនិងរឿងបែបពុទ្ធនិយមក្លាយ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីគោលគំនិតសំខាន់ៗរបស់ពុទ្ធសាសនា លក្ខណៈសម្គាល់រឿងបែបពុទ្ធនិយម អត្ថបទដកស្រង់រឿងព្រះវេស្សន្តរ ខ្លឹមសារអត្ថបទ វិធីតែងនិពន្ធមួយចំនួននិងអត្ថបទរឿងបែបពុទ្ធនិយមមួយចំនួនទៀត។ អ្នកនឹងបានសិក្សាបន្ថែមទៀតអំពីការវិវត្តនៃអក្សរសិល្ប៍ខ្មែរ លក្ខណៈអ្នកនិពន្ធនិងស្នាដៃមួយចំនួន រៀបរាប់ឡើងវិញពីគោលគំនិតសំខាន់ៗមួយចំនួនក្នុងទ្រឹស្តីព្រះពុទ្ធសាសនា បន្ទាប់ពីបានស្តាប់ ព្រមទាំងសំណេរបំពេញលិខិតរដ្ឋបាលផ្លូវការមួយចំនួន។



ពុទ្ធសាសនា

ពុទ្ធសាសនាមានដើមកំណើតនៅប្រទេសឥណ្ឌាក្នុងសតវត្សទី ៦មុនគ្រិស្តសករាជ ប្រហែលគ្នានឹងកំណើតព្រាហ្មណ៍និយមដែរ។ នៅសតវត្សទី ៣មុនគ្រិស្តសករាជ ក្នុងរជ្ជកាលព្រះបាទអសោក ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញទាំងក្នុងប្រទេសឥណ្ឌាទាំងក្រៅប្រទេស។ តាមប្រវត្តិសាស្ត្រ គេបានដឹងថានៅពុទ្ធសតវត្សទី ៣(ព.ស. ២៣៤)គឺមុនគ.ស. ៣០០ឆ្នាំម្ល៉េះ ព្រះបាទអសោកពុទ្ធសាសនិកដ៏ឆ្នើមក្នុងប្រទេសឥណ្ឌាបានបញ្ជូនសមណទូតពីរអង្គគឺព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរឱ្យនាំយកពុទ្ធសាសនាថេរវាទមកផ្សាយនៅសុវណ្ណភូមិ (អាស៊ីអាគ្នេយ៍)។ តាមសិលាចារឹកវ៉ូកាញ់ (វៀតណាមខាងត្បូង)ទំនងជាពុទ្ធសាសនាចូលមកប្រតិស្ថានក្នុងប្រទេសខ្មែរនៅសតវត្សទី ២នៃគ្រិស្តសករាជក្នុងរជ្ជកាលព្រះបាទស្រីមារៈឬហ្វាន់ចេរម័ន។

ស្ថាបនិកនៃពុទ្ធសាសនា គឺព្រះពុទ្ធគោតម (៥៦៤-៤៨៣មុនគ.ស.)។ ព្រះអង្គមានព្រះជន្មគង់នៅ បានប្រៀនប្រដៅ និងបានចូលបរិនិព្វាននៅប្រទេសឥណ្ឌាភាគឦសាននៅពេលដែលទស្សនៈឥណ្ឌាបុរាណកំពុងចោទជាបញ្ហាអំពីសុពលភាពនៃសម្មតិកម្មខ្លះៗជាគ្រឹះផ្ដាល់របស់ខ្លួន។ ប៉ុន្តែព្រះធម៌ជាពាក្យប្រៀនប្រដៅទាំងឡាយ និងឥទ្ធិពលរបស់ព្រះអង្គបានផ្សព្វផ្សាយទៅទូទាំងទ្វីបអាស៊ីភាគកណ្ដាល ខាងត្បូង និងខាងជើងដែលនៅទីនោះៗបានបន្តផ្តល់ឱ្យមានចំណងវប្បធម៌រួមគ្នាមួយ ហើយព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គក៏ត្រូវបានគេស្គាល់នាពេលសព្វថ្ងៃនេះ នៅក្នុងអឌ្ឍគោលខាងលិចផងដែរ។ នៅពេលខាងក្រោយមក ពុទ្ធសាសនាត្រូវបែកចេញជានិកាយផ្សេងៗ។ និកាយទាំងឡាយនោះ នៅតែបានរក្សាប្រពៃណីនៃជីវភាពរបស់ព្រះអង្គ។ ប្រពៃណីទាំងនោះភាគច្រើនឃើញមាននៅក្នុងភាសាបាលី ភាសាសំស្ក្រឹត ភាសាចិន និងភាសាទីបេ។ ចេញពីភាសាទាំងនោះការសិក្សាប្រវត្តិសាស្ត្រសម័យថ្មី ស្វែងរកឃើញក្របខណ្ឌព្រឹត្តិការណ៍សំខាន់ៗ មានស្ថិរភាពបង្ហួរនៅក្នុងចរិតមួយ ដែលគេនៅតែធ្វើបុណ្យអបអរសាទរនៅឡើយក្រោយពេល ២ ៥០០ឆ្នាំបានកន្លងទៅ។ ពុទ្ធសាសនា គឺជាសាសនាផង និងជាទស្សនវិជ្ជាផង។ វាហាក់ដូចជាព្រះពុទ្ធ និងគ្រូអាចារ្យប្រដៅសាសនាសហសម័យដទៃទៀតផង ហើយព្រះធម៌ជា "វាទៈ និងវិន័យ"មួយ។ នេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា យោងតាមទស្សនៈឥណ្ឌាបុរាណវាទៈឬទស្សនវិជ្ជាមួយមិនអាចប្រតិបត្តិកើតដោយគ្មានវិន័យសមស្របទេ។ តាមការពិតព្រះពុទ្ធបានបញ្ញត្តិក្រមចរិយាធម៌មួយយ៉ាងល្អសម្រាប់ភិក្ខុ និងភិក្ខុនី ហើយទ្រង់ក៏បានទូន្មានពុទ្ធសាសនិកជនជាគ្រហស្ថឱ្យចេះប្រព្រឹត្តធ្វើខ្លួនយ៉ាងណាផងដែរ។

ពុទ្ធសាសនា គឺជាសាសនាមនុស្សនិយម។ រូបមន្តដំបូងបំផុតរបស់ព្រះពុទ្ធសាសនា ត្រូវបានគេរកឃើញនៅក្នុងអ្វីដែលគេស្គាល់ថាជា "ចតុរារិយសច្ចៈ" ដែលត្រូវតែជាការយកចិត្តទុកដាក់របស់

មនុស្ស ប្រកបដោយប្រាជ្ញាគ្រប់រូប និងជាសេចក្តីប្រកាសត្រឹមត្រូវ ស្តីពីធម្មជាតិនៃលោកនិងធម្មជាតិនៃមនុស្ស ។

ចតុរារិយសច្ច: (អរិយសច្ច:បួន)គឺ :

១. ទុក្ខអរិយសច្ច: ទាក់ទងនឹងធម្មជាតិពិតនៃជីវិត សេចក្តីសោកសៅ និងសេចក្តីសប្បាយតែខាងក្រៅនៃជីវិតការខកចិត្ត និងទោមនស្សនៃជីវិតអនិច្ចតានិងអនត្តានៃជីវិត ។ បុគ្គលគប្បីយល់ប្រការនេះជាការណ៍ពិតដោយច្បាស់លាស់និងដោយពេញលេញ ។

២. សមុទយអរិយសច្ច: (ហេតុនៃទុក្ខ) សម្តែងថាទុក្ខបណ្តាលមកពីប្រភេទនៃរាគៈ ឬតម្រេកដែលជិតដាមដោយកាមតណ្ហា កិលេស និងសេចក្តីសៅហ្មងដទៃទៀត ។ បុគ្គលមិនគ្រាន់តែយល់ដឹងនូវការពិតនេះដោយច្បាស់លាស់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានសេចក្តីព្យាយាមលុបបំបាត់បំផ្លាញចោលនិងរំលើងឫសគល់រាគៈទាំងនោះថែមទៀត ។

៣. និរោធទុក្ខអរិយសច្ច: (ការរំលត់ទុក្ខ) អះអាងពីលទ្ធភាពជំនះទុក្ខបាន ដោយនិយាយយោងទៅរកគុណធម៌ដ៏ខ្ពស់បំផុតនៃពុទ្ធសាសនាគឺនិព្វាន ដែលគេត្រូវសម្រេចបានក្នុងជាតិនេះនៅក្នុងជីវិតផ្ទាល់របស់គេ ហើយក៏មិនមែនជាតថភាពបរមត្ថដូចនៅក្នុងវេទាន្តៈទេ ។ បុគ្គលត្រូវខិតខំព្យាយាមសម្រេចឱ្យបានយ៉ាងឆាប់ ។

៤. មគ្គអរិយសច្ច: មាគ៌ានាំទៅកាន់ការរំលត់ទុក្ខពិតប្រាកដ ការយល់ដឹងនូវមគ្គៈតែប៉ុណ្ណោះមិនគ្រប់គ្រាន់ទេ គេត្រូវខិតខំដើរតាមមាគ៌ានេះ និងប្រតិបត្តិតាមដោយទៀតទាត់ទៀត ។

(រៀបរៀងនិងកែសម្រួលពីសៀវភៅអរិយធម៌ខ្មែររបស់អ្នកស្រី ត្រិង-ងា ទំព័រ ២៥-៣៣)

សំណួរ

១. តើពុទ្ធសាសនាមានកំណើតពីពេលណា ? នៅឯណា ?

២. តើពុទ្ធសាសនាមានការីកចម្រើនក្នុងសម័យណា ? ហើយចូលមកផែនដីសុវណ្ណភូមិតាមរយៈនរណា ? មានអ្វីជាភស្តុតាង ?

៣. តើនរណាជាអ្នកបង្កើតពុទ្ធសាសនា ? ព្រះអង្គជាជនជាតិអ្វី ?

៤. ចូរអ្នករាប់និកាយផ្សេងៗនៃពុទ្ធសាសនាឱ្យបានពីរ ។

៥. ចូរបង្ហាញថាពុទ្ធសាសនាជាសាសនាមនុស្សនិយម ។

៦. តើអ្នកយល់ដូចម្តេចចំពោះពុទ្ធសាសនា ?



ក. សិក្សាពាក្យគន្លឹះ

- ត្រៃវេទ (ន) : គម្ពីរសម្តែងបែបរបៀបផ្សេងៗខាងសាសនាព្រាហ្មណ៍ក្នុងសម័យដើម មានត្រឹមតែបីយ៉ាង ដែលពួកព្រាហ្មណ៍ក៏ប្រកាន់ជឿស៊ប់ថា មហាព្រហ្ម ប្រសិទ្ធិឱ្យកើតឡើង ... ។
- វិបរិត (គុ) : ដែលប្រែប្រួល ផ្លាស់ប្រែ ដែលមិនពិត ដែលជាទំនាស់នឹងគ្នា ដែលផ្ទុយគ្នា ទីទៃពីគ្នា ។
- វិវត្តន៍ (ន) : ការប្រែចម្រើនឡើង ការស្ទុះទៅមុខ ។
- វិបត្តិ (ន) : សេចក្តីប្រែប្រួល ដំណើរផ្តោះធ្លាក់ សេចក្តីវិនាស អន្តរាយ ដំណើរទទួលគ្រោះថ្នាក់ ដំណើរហិនហោច ... ។
- សាស្ត្រ (ន) : សត្រា គម្ពីរក្បួន ។
- និន្នាការ (ន) : អាការដែលទ្រេតទេរទៅ ឬដែលលម្អៀងទៅម្ខាងៗ ។
- ជាតិនិយម (ន) : សេចក្តីកំណត់តាមកំណើត ការនិយមតែជាតិរបស់ខ្លួន ។
- ចរន្ត (ន) : ចលនាឬដំណើរប្រព្រឹត្តទៅដោយកម្លាំងនៃធាតុទឹកនិងធាតុភ្លើងជាដើម ។

- បដិវត្តន៍ (ន) : ការប្រែប្រួល ការវិលត្រឡប់ ការកែប្រែ ឬផ្លាស់ប្តូរ ។ ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវរបបគ្រប់គ្រងចាស់ ដែលមិនចម្រើនឱ្យបានចម្រើនលូតលាស់ទាន់កាលសម័យជាដើមការប្រព្រឹត្តប្រឆាំងដោយកម្លាំងអាវុធចំពោះអំពើរំលោភ ។
- បញ្ញវន្ត (ន) : អ្នកមានប្រាជ្ញា អ្នកប្រាជ្ញ អ្នកយកចិត្តទុកដាក់ប្រើគំនិតត្រិះរិះក្នុងកិច្ចការគ្រប់ជំពូក ។
- ប្រលោមលោក (ន) : រឿងប្រលោមចិត្តមនុស្សលោក គឺរឿងដែលអ្នកតែងប្រតិដ្ឋដួចឡើងដោយឥតមានច្បាប់ដើមជាការណ៍ពិតប្រាកដជាគោលចារឹកឡើយ ។
- សង្គមរាស្ត្រនិយម(ន) : ជារបបនយោបាយមួយនៅកម្ពុជានាទសវត្សទី ៦០ ។
- ប្រជាធិបតេយ្យ (ន) : ភាពនៃប្រទេសដែលមានប្រជារាស្ត្រជាអធិបតី គឺប្រទេសឬរដ្ឋបាលដែលមានប្រជាជនជាធំក្នុងការរើសតំណាងរបស់ខ្លួនឱ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស ... ។
- ប្រជាប្រិយ (គុ) : ដែលជាទីស្រឡាញ់របស់ពួករាស្ត្រ(ប្រជាជន) ។
- ផលិតកម្ម (ន) : ការបង្កើនផល ការធ្វើឱ្យបានផល ការបង្ហាញឬបញ្ចេញផលឱ្យឃើញជាក់ស្តែង អំពើដែលនាំឱ្យបានសម្រេចផល ។
- សមាគម (ន) : ការមកជួបជុំ ការប្រជុំ ការរួមគំនិតគ្នា ដំណើររួបរួម កិច្ចការជាមួយគ្នា ។
- រណសិរ្ស (ន) : ក្បាលទ័ព ខាងមុខនៃកងទ័ព ជួរនៃកងទ័ពដែលរៀបចំត្រៀមខ្លួនចាំឈមមុខបម្រុងប្រយុទ្ធនឹងបច្ចាមិត្ត ។
- សាធារណរដ្ឋ (ន) : រដ្ឋដែលបណ្តារាស្ត្រជ្រើសរើសតំណាងរបស់ខ្លួន ហើយចាត់តាំងឱ្យកាន់កាប់ផែនដី ។ រដ្ឋដែលគ្មានស្តេចគង់រាជ្យ ។

២. អភិវឌ្ឍន៍បំណិន

អ្នកធ្លាប់បានសិក្សាអំពីការវិវត្តនៃអក្សរសិល្ប៍ខ្មែរនៅមេរៀនមុខខ្លះហើយ ។ ឥឡូវអ្នកសិក្សាអំពីប្រវត្តិអក្សរសិល្ប៍តាមដំណាក់កាលសង្គមប្រវត្តិសាស្ត្រ អំពីអ្នកកវី អ្នកនិពន្ធ និងស្នាដៃរបស់លោកនៅដំណាក់កាលនីមួយៗតាមខ្លឹមសារអត្ថបទ ។

គ. អត្ថបទ

អក្សរសិល្ប៍ ជាកញ្ចក់ឆ្លុះបញ្ចាំងតថភាពសង្គម។ តាមស្នាដៃអក្សរសិល្ប៍ យើងអាចឆ្លុះឃើញការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗ ហើយអាចឱ្យយើងធ្វើការវិភាគវាយតម្លៃពីចរិតអ្នកកវីនិពន្ធនិងបំណងរបស់អ្នកនិពន្ធ ដែលបង្កប់នៅក្នុងស្នាដៃនោះ។

បើយោងតាមប្រវត្តិសាស្ត្រ គេចែកសង្គមខ្មែរជាបីដំណាក់កាលធំៗ គឺសម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរ។ ចំណែកស្នាដៃអក្សរសិល្ប៍ក៏ត្រូវបានបែងចែកជាបីដំណាក់កាលធំៗ គឺអក្សរសិល្ប៍សម័យបុរាណ អក្សរសិល្ប៍កណ្តាល និងអក្សរសិល្ប៍សម័យទំនើប។

១. អក្សរសិល្ប៍សម័យបុរាណ

អ្នកស្រាវជ្រាវប្រវត្តិអក្សរសិល្ប៍ បានកំណត់ថា សម័យមុនអង្គរនិងសម័យអង្គរ គេឃើញមានសេសសល់តែសិលាចារឹក ដែលភាគច្រើនសរសេរជាភាសាសំស្ក្រឹត ហើយខ្លះទៀតសរសេរជាអក្សរខ្មែរបុរាណដែលពិបាកយល់។ នៅសម័យអង្គរដ៏រុងរឿង គេឃើញមានសិលាចារឹកខ្លះបានប្រាប់ឈ្មោះអ្នកកវីដូចជា ៖

- បណ្ឌិតសិវសោម មានចំណេះខាងក្បួនច្បាប់ផ្សេងៗក្នុងអក្សរសាស្ត្រនិងមន្តវិជ្ជាគាថាខាងព្រាហ្មណ៍សាសនា។ លោកបានបកប្រែរឿងមហាភារតៈនិងក្បួនវេយ្យាករណ៍។ ស្នាដៃសិលាចារឹកប្រាសាទកណ្តាលដើម នៅចម្ងាយ ៣០០ម ខាងលិចកំពែងប្រាសាទព្រះគោ។
- បណ្ឌិតយតិអមរភាវៈ ឋានៈសង្ឃរាជនៅវត្តឥន្ទ្រស្រម (ផ្នែកសាសនាព្រាហ្មណ៍)។ ស្នាដៃសិលាចារឹកភ្នំបាយ័ង្គ នៅស្រុកទ្រាំង ខេត្តតាកែវ។
- បណ្ឌិតទិវាករ មានចំណេះចារត្រៃវេទស្ទាត់ជំនាញ។ ស្នាដៃសិលាចារឹកប្រាសាទកំភីស នៅឃុំយាង(ម្ហូព្រៃ) ចម្ងាយ ២៥គ.ម ពីកោះកែវ។
- បណ្ឌិតកវិន្ទ្រៈ មានឋានៈជាទីប្រឹក្សានៃមហាក្សត្រជ្រាល់។ ស្នាដៃសិលាចារឹកប្រាសាទខ្នាស្ថិតនៅក្នុងខេត្តម្ហូព្រៃ។
- បណ្ឌិតភូបេន្ទ្រៈ ជាអធិបតីលើអ្នកប្រាជ្ញនិងចៅក្រម(នីតិសាស្ត្រ)។ ស្នាដៃសិលាចារឹកប្រាសាទទរ ស្ថិតនៅតំបន់វត្តភូ (ប្រទេសឡាវ)។
- ព្រះនាងឥន្ទ្រទេវី ជាព្រះអគ្គមហេសីទី ២ នៃព្រះបាទជ័យវរ្ម័នទី ៧និងជាអគ្គសានូបត្ថម្ភខាងព្រះពុទ្ធសាសនា។ ស្នាដៃសិលាចារឹកប្រាសាទភិមានអាកាស (ខេត្តសៀមរាប)។

- បណ្ឌិតសិរីវាចារ្យ ជាអធិការត្រួតត្រាខាងសីលធម៌ ។ ស្នាដៃសិលាចារឹកប្រាសាទតាកែវ (ខេត្តសៀមរាម) ។

ក្រៅពីនេះមានសិលាចារឹក រាប់រយទៀត ដែលគេពុំបានស្គាល់ឈ្មោះអ្នកនិពន្ធឡើយ ។

២ . អក្សរសិល្ប៍សម័យកណ្តាល (សម័យក្រោយអង្គរ)

នៅសម័យក្រោយអង្គរ ប្រទេសខ្មែរមានវិបរិតដោយសារតែសង្គ្រាម ។ គ្រោះមហន្តរាយទាំងអស់នេះធ្វើឱ្យការសិក្សា តែងនិពន្ធ ក្បួនខ្នាត ឬការចងក្រងកត់ត្រានូវព្រឹត្តិការណ៍ផ្សេងៗថយចុះជាលំដាប់ ។ ទោះជាយ៉ាងនេះក៏ដោយ អ្នកនិពន្ធ កវីបណ្ឌិតខ្មែរពុំលះបង់សេចក្តីព្យាយាមចងក្រងអត្ថបទរឿងរ៉ាវកត់ត្រាលើថ្មនិងចារលើក្រាំង ឬស្លឹករឹត ដើម្បីលាតត្រដាងនូវទឹកចិត្តរបស់ខ្លួនសម្រាប់ទុកជាកេរមរតកនិងជាវិភាគទានយ៉ាងធំក្នុងវិស័យវប្បធម៌ អរិយធម៌ជាតិដែរ ។ អត្ថន័យនៃអត្ថបទមានលក្ខណៈរឿងប្រឌិតតាមបែបមនោសញ្ចេតនា ។ រឿងក្នុងជាតកបែបបាលី បានច្នៃតែងផ្សំប្រមុំតាមចិត្តគំនិតរបស់ខ្លួន ដើម្បីសម្របទៅតាមជំនឿ បញ្ហាជីវភាពរស់នៅនាសម័យនោះ ។ អត្ថបទភាគច្រើនសរសេរជាពាក្យកាព្យមានបទកាកគតិ ពំនោល ព្រហ្មគតិ បទភុជង្គលីលាជាដើម ។

កវីនិពន្ធនិងស្នាដៃនាសម័យនោះមានដូចជា ៖

- អ្នកឧញ៉ាចក្រីកែវ និពន្ធសាស្ត្រា "ជាវរឿង" ជាពាក្យកាព្យ ។
- បណ្ឌិតកោ និពន្ធសាស្ត្រា "ជ័យទត្ត" ជាពាក្យកាព្យ ។
- បណ្ឌិតស្ពឹតឬសំអាត និពន្ធសាស្ត្រា "មុច្ចលិន" ជាពាក្យកាព្យ ។
- ព្រះអារិយគាមុនីហ៊ីង មានឋានៈជារាជាគណៈសម័យក្រុងឧដុង្គមានជ័យ និពន្ធសាស្ត្រា "ជិនវង្ស" ជាពាក្យកាព្យ ។
- កវីយ៉ែម និពន្ធសាស្ត្រា "វិមានចន្ទ" ជាពាក្យកាព្យនិងមានកវីនិពន្ធនិងស្នាដៃច្រើនទៀតដែលខ្លះស្គាល់ឈ្មោះអ្នកតែងដឹងកាលបរិច្ឆេទ ខ្លះទៀតពុំស្គាល់ឈ្មោះនិពន្ធទេ ។

ក្នុងសម័យនោះ គេហៅថា "សាស្ត្រា" ជំនួសពាក្យ "រឿង" ដូចជា សាស្ត្រាជ័យទត្ត សាស្ត្រាជាវរឿង ... គេហៅដូចនេះប្រហែលជាគេសំអាងថា រឿងរ៉ាវទាំងនោះគឺចារលើសាស្ត្រាស្លឹករឹត ។

៣ . អក្សរសិល្ប៍សម័យទំនើប

ជំណាក់កាលនេះ អក្សរសិល្ប៍មានការវិវត្តខ្លាំងក្លា ដែលយើងអាចចែកជា ៥ សម័យសំខាន់ៗ ៖

- **សម័យអាណាព្យាបាលបារាំង (១៨៦៣-១៩៥៤)**

សម័យនេះខ្មែរ មានវិបត្តិភាសាជាតិយ៉ាងធ្ងន់ធ្ងរ។ កូនចៅខ្មែរត្រូវពួកអាណាព្យាបាលចាប់បង្ខំឱ្យរៀនភាសាបារាំងតាំងពីថ្នាក់ដំបូងឡើងទៅ។ អក្សរខ្មែរបានទៅជ្រកកោនក្នុងទីវត្តអារាមព្រះពុទ្ធសាសនា ហើយក៏មានកូនខ្មែរមួយចំនួនធំទៅសិក្សារៀនសូត្រនៅទីនោះ។ ការតាក់តែងនិពន្ធស្នាដៃគ្រប់យ៉ាងត្រូវឆ្លងកាត់ត្រួតពិនិត្យពីពួកបារាំងដែរ។ ទោះបីជាមានគំនាបដ៏ខ្លាំងរបស់ពួកអាណាព្យាបាលបែបនេះក៏ដោយ ក៏គេសង្កេតឃើញមានស្នាដៃមួយចំនួនបានបង្កប់ខ្លឹមសារនិះគន់របបគ្រប់គ្រងបែបនេះដែរ។ រឿង "កូនចៀមនិងចចក" ក្នុងគតិលោកដែលជាស្នាដៃកវីនិពន្ធសុតន្តប្រឹជាឥន្ទ ច្បាប់ល្បីកថ្មី របស់លោកតាក្រម ង៉ុយ និងស្នាដៃផ្សេងទៀតក៏សុទ្ធតែបានបង្កប់គំនិតរិះគន់ដ៏ខ្លាំងក្លាចំពោះអាណាព្យាបាលបារាំង។ ក្រៅពីនេះ ការតាក់តែងស្នាដៃអក្សរសិល្ប៍គ្រានោះ មួយចំនួនបានទទួលឥទ្ធិពលពីបរទេស ដោយមានស្នាដៃខ្លះ សរសេរជាពាក្យរាយ ហើយគេឱ្យឈ្មោះថា **ប្រលោមលោក**។ ចូរចងចាំថាសម័យនេះបានបង្កើតពុម្ពអក្សរខ្មែរ មានបោះពុម្ពសៀវភៅជាលើកដំបូង រៀបចំវចនានុក្រមខ្មែរ បង្កើតទស្សនាវដ្តីកម្ពុជសុរិយា ហើយក៏មានការប្រឡងប្រជែងអក្សរសាស្ត្រ ហើយនិងបង្កើតក្រុមពុទ្ធសាសនាបណ្ឌិត្យផងដែរ។

- **សម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)**

សម័យឯករាជ្យ អ្នកនិពន្ធមានសេរីភាពក្នុងការនិពន្ធមាននិន្នាការជាតិនិយម សង្គមនិយមប្រជាធិបតេយ្យ និងប្រជាប្រិយ។ ផលិតកម្មអក្សរសិល្ប៍ប្រកបដោយវឌ្ឍនភាពខ្លាំងក្លា ជាពិសេសនៅរវាងឆ្នាំ ១៩៦៥និង ១៩៦៦ គឺប្រទេសទទួលការរីកចម្រើនដ៏ខ្ពង់ខ្ពស់បំផុតក្នុងវិស័យវប្បធម៌ ដោយមានសកលវិទ្យាល័យរីកដុះដាលក្នុងព្រះរាជាណាចក្រ។ ស្នាដៃអក្សរសិល្ប៍មានច្រើនប្រភេទដូចជា ប្រលោមលោក កំណាព្យ រឿងល្ខោន សៀវភៅបច្ចេកទេស សៀវភៅសិក្សាអប់រំ សៀវភៅទាក់ទងនឹងទស្សនវិជ្ជា។ល។ នៅសម័យនោះអ្នកនិពន្ធខ្មែរបានបង្កើតសមាគម ដើម្បីពង្រឹងនិងផ្សព្វផ្សាយអក្សរសិល្ប៍ជាតិ ព្រមទាំងមានការប្រលងប្រជែងយកពានរង្វាន់ឥន្ទ្រទេវីរវាង ៥ឆ្នាំម្តង។ អ្នកនិពន្ធនិងស្នាដៃសម័យនោះមានច្រើនណាស់ដូចជា ៖

- លោក អឹម ឆោម សមាជិកសមាគមអ្នកនិពន្ធខ្មែរ បានទទួលជ័យលាភីអក្សរសិល្ប៍ឥន្ទ្រទេវីនៅឆ្នាំ ១៩៦៥ ចំពោះប្រលោមលោករឿង **នាងរ៉ែនណែត** និងស្នាដៃផ្សេងទៀត គឺរឿងព្រេងខ្មែរជាកំណាព្យ រឿង ក្រឡាហោមគង់ជាដើម។

- លោកទ្រិញ វ៉ាញ ជាសមាជិកអ្នកនិពន្ធខ្មែរ។ ស្នាដៃរបស់លោក គឺរឿង **ខ្ញុំមានព្រោះអ្វី ?**
- លោក ហ៊ែល សុំផា ជាប្រធានសមាគមអ្នកនិពន្ធខ្មែរក្នុងចន្លោះឆ្នាំ ១៩៥៧-១៩៧៤។ ស្នាដៃរបស់លោកមានរឿង ចោរបិទមុខ រឿងចោរលួចប្រាក់ រឿងចោរភ្នំតែ្បង រឿងចិត្តឪពុក និងសិក្សាកថា វចនានុក្រមច្បាប់ជាដើម។
- លោកកេង វ៉ាន់សាក់ ជានិស្សិតមកពីប្រទេសបារាំង។ លោកបាននិពន្ធរឿងល្ខោន កំណាព្យ និងសិក្សាកថាជាច្រើន។ រឿងល្ខោនសាច់ពុំបានស៊ីយកឆ្អឹងព្សរក កំណាព្យចិត្តក្រមុំ កុកកាម កិលេសជាដើម។

នៅសម័យនោះមានកវីនិពន្ធជាច្រើនទៀត ហើយមានខ្លះបានបន្តការតែងនិពន្ធមកដល់សម័យសាធារណរដ្ឋខ្មែរ។

- **អក្សរសិល្ប៍សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)**

ប្រទេសកម្ពុជានាសម័យនោះ ស្ថិតក្នុងភ្លើងសង្គ្រាមយ៉ាងសន្ធោសន្ធៅ។ អក្សរសិល្ប៍ខ្មែរនៅសម័យនេះបានចាប់ផ្តើមបែររកទិសដៅថ្មី ហើយមានសន្ទុះរីកចម្រើនខ្លាំងក្លាណាស់ ព្រមទាំងមានចលនារស់រវើក។ ជាតិកតាងគេឃើញស្នាដៃរបស់អ្នកនិពន្ធជាច្រើនបានរីកដុះដាលឡើង ហើយថែមបានទទួលជោគជ័យនិងមានឈ្មោះបោះសំឡេងគួរឱ្យកត់សម្គាល់ថែមទៀត។ អាជីពអ្នកនិពន្ធបានទទួលបានជីវភាពសមល្មមនឹងរស់នៅស្រួលក្នុងសង្គមតាមរយៈការបោះពុម្ពនិងការលក់ស្នាដៃរបស់ខ្លួននេះ បើប្រៀបធៀបទៅនឹងអាជីពដទៃទៀតផ្សេងទៀត។ អត្ថន័យអក្សរសិល្ប៍សម័យនេះមានចរន្តពីរ គឺមួយទ្រទ្រង់នយោបាយថ្មីបែបសាធារណរដ្ឋនិងមួយទៀតទិតៀនរិះគន់របបថ្មីនេះ។ ជាមួយគ្នានោះប្រធានបទនៃស្នាដៃមួយចំនួននិយាយពីបញ្ហាទឹកដី ប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍សំខាន់ៗនៃសង្គមខ្មែរ ពីចលនាតស៊ូ ពីបញ្ហាវត្តទាមទារសិទ្ធិសេរីភាព។ល។ ទោះជាយ៉ាងនេះក៏ដោយភាពថ្មីនៃរបបដែលប្រជាជាតិទាំងមូលមិនដែលស្គាល់និងភ្លក់រសជាតិពីមុនមកនោះ ហាក់ដូចជាកាន់តែនាំឱ្យប្រជាជាតិទាំងមូលទទួលរងនូវវិបត្តិនិងបញ្ហាកាន់តែធ្ងន់ធ្ងរទ្វេឡើងថែមទៅវិញ។ ភាពទំនើបនិងការចម្លងអារ្យធម៌បរទេសដ៏ស៊ីវិល័យនាសម័យនោះ គឺជាឧបសគ្គធំចំពោះប្រជាជនក្នុងប្រទេស ហើយក៏ជាគ្រោះថ្នាក់មួយចំពោះវិស័យវប្បធម៌និងអារ្យធម៌របស់ជាតិសាសន៍ខ្លួនដែលធ្លាប់មានភាពទន់ភ្លន់ស្លប់ស្លៀម និងថ្លៃថ្នូរ តាំងពីយូរយារមកហើយនោះ។

អក្សរសិល្ប៍សម័យនេះមានប្រភេទប្រលោមលោក កំណាព្យ ល្ខោននិយាយឬភាគនិទានរឿង ប្រលោមលោក ចម្រៀង និងល្ខោនបាសាក់ជាដើម។

អ្នកកវីនិពន្ធនិងស្នាដៃមាន ៖

- លោក គង្គ ប៊ុនឈឿន ស្នាដៃរឿង ពលទោអភ័ព្វនិងប្រលោមលោកជាច្រើន ។
- លោក ឡាំង ម៉េងសៀក ស្នាដៃរឿង ព្រលឹងម៉ែ ទោសពានវាំង ខ្សល់កំបុតត្បូង ... ។
- លោក ឃុន ស្រ៊ុន ស្នាដៃ លំនៅចុងក្រោយ ជាកម្រងរឿងនិទាននិងកំណាព្យមួយចំនួន ។
- លោក តាំង វស្សា ស្នាដៃរឿង នាងខៀប-វណ្ណដារ៉ា រឿង អន្ទាក់កាមទេព ... ។
- លោក ប៊ុណ្ណ ចន្ទម៉ុល ស្នាដៃអត្ថបទ ចរិតខ្មែរ គុកនយោបាយ ... ។
- លោក គយ សារុន ស្នាដៃ កើតជាមនុស្សនេះ សរសេរជាកំណាព្យ បុប្ផាខ្មៅ ។
- លោក ជិត ខៀ ស្នាដៃ រឿង ខ្មោចព្រាយអសុរកាយ មេម៉ាយប្តី ៥ និងមានស្នាដៃបកប្រែពីភាសាបរទេសមួយចំនួនដូចជា បុត្រឆ្នើមនៃសង្គ្រាម ជញ្ជាំង ... ។
- លោក ស៊ូ ចំរើន ស្នាដៃរឿង ជនសង្គ្រាមជ័យ អាម៉ៅឆ្កែខ្ញុំ ពោធិ៍កំបោរ ... ។ មានអ្នកនិពន្ធល្បីៗជាច្រើនទៀតដូចជា សុទ្ធ ប៉ូលីន ,មិត្ត សាខុន , ឌឹក គាម , ទី ជីហួត ... ។

- **អក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)**

ខ្មែរក្រហម បានចាប់ផ្តើមកាន់កាប់អំណាចនាថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ។ ការធ្វើបដិវត្តផ្តាច់ការដ៏ខ្លាំងក្លា បានធ្វើឱ្យប្រជាជនស្លាប់ជាច្រើនលាននាក់ ។ កវីនិពន្ធស្លាប់ស្ទើរតែទាំងអស់ អក្សរសិល្ប៍ស្ទើរតែវិនាសមហាន្តរាយអស់ ។ ផលិតកម្មក្រោមរបបកម្ពុជាប្រជាធិបតេយ្យមានតិចតួចបំផុត ។

យើងអាចចែកអក្សរសិល្ប៍សម័យកម្ពុជាប្រជាធិបតេយ្យ ជាដំណាក់កាល ៖

ដំណាក់កាលរណសិរ្ស : ១៩៧០-១៩៧៦ ស្នាដៃអក្សរសិល្ប៍មានលក្ខណៈបង្រួបបង្រួមកម្លាំងគ្រប់ស្រទាប់ គ្រប់សមាសភាពបទចម្រៀងនាពេលនោះមាន បទមិត្តដើរព្រៃលើ អាគិញចង្រៃ ។ល។ រឿងខ្លីៗមានពលីកម្មម៉ែៗ រឿងគំនុំវណ្ណៈ ... ។

ដំណាក់កាលបដិវត្តប្រជាជាតិ ប្រជាធិបតេយ្យ : ១៩៧៦-១៩៧៧ អក្សរសិល្ប៍មានភារកិច្ចនិងប្រធានបទជុំវិញស្មារតីកសាងប្រទេសនិងលុបបំបាត់កាកសំណល់សង្គមចាស់ ។ ប៉ុល ពតបាននិពន្ធបទ "១៧ មេសា មហាជោគជ័យ" ក្រៅពីនេះមានបទ "នៅគ្រប់ការដ្ឋានថ្ងៃណាក៏បុណ្យ" ។

ដំណាក់កាលបដិវត្តសង្គមនិយម : ១៩៧៧-១៩៧៩ អក្សរសិល្ប៍មានភារកិច្ចរួមចំណែកបម្រើឱ្យមាគ៌ាសង្គមនិយមឆ្ពិនឆ្ពោរបស់បក្សកុម្មុយនីស្តកម្ពុជា ជារណសិរ្សសតិអារម្មណ៍ ជាឧបករណ៍នយោបាយក្នុងការអនុវត្តមាគ៌ា "មហាលោតផ្លោះ មហាអស្ចារ្យ" និងប្រឆាំងវាយកំទេចរាល់ខ្មាំង

របស់បដិវត្តទាំងក្នុងទាំងក្រៅប្រទេស"[1] ។ ក្រៅពីអ្នកនិពន្ធបម្រើឱ្យបក្សកុម្មុយនីស្តជាផ្លូវការ គេក៏រកឃើញថាមានអ្នកនិពន្ធ ជាប្រជាជនដែលមានការឈឺចាប់ក្នុងរបបនេះបានលួចតាក់តែងបញ្ចេញគំនិតរបស់ខ្លួនរិះគន់ ដែលជាស្នាដៃមានលក្ខណៈជាប្រវត្តិសាស្ត្រមានដូចជា ៖

- លោកជួន ម៉ែន កំណាព្យ "មើលផែនដីខ្មែរសម័យប៉ុល ពត អៀងសារី" និពន្ធឆ្នាំ ១៩៧៦-១៩៧៧ ។
- លោកស្រី អ៊ុន ស៊ីណន កំណាព្យ "សោកនាដកម្មស្រុកមោងឫស្សី" និពន្ធឆ្នាំ ១៩៧៨ ។
- លោក កែវ ចិន្តា កំណាព្យ "ចុកណែនឱរា" និពន្ធឆ្នាំ ១៩៧៦ ។

- **អក្សរសិល្ប៍សម័យក្រោយថ្ងៃ ៧មករា ១៩៧៩-បច្ចុប្បន្ន**

សម័យសាធារណរដ្ឋប្រមានិតកម្ពុជា-រដ្ឋកម្ពុជា : នៅខែមករា ១៩៧៩ មានអ្នកនិពន្ធខ្មែរមួយចំនួនបានរស់រានមានភ័ព្វបានរួចផុតពីរណ្តៅមរណៈនៃរបបខ្មែរក្រហម ។ ស្នាដៃមួយចំនួនបានផ្តើមគំនិតក្នុងទិសដៅថ្មីស្របទៅនឹងបន្ទាត់នយោបាយថ្មីនៃកម្ពុជា ជាពិសេសគឺសរសេរពីទុក្ខសោកនិងភាពយោរយៅនានានៃរបបប្រល័យពូជសាសន៍របស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម) ។

នៅឆ្នាំ ១៩៨៥ លោក ហ៊ឺ សុខៃ បានផ្សាយដំបូងជាលើកនិយាយតាមវិទ្យុជាតិនូវរឿង "ក្រញាំមួលធន" ឆ្នាំ១៩៨៧-១៩៨៨ យើងឃើញមានលេចចេញស្នាដៃប្រលោមលោកខ្លីៗ ដែលចាប់ផ្តើមសរសេរពីប្រធានបទមនោសញ្ចេតនាសុទ្ធសាធ បរិយាយនិងឆ្លុះបញ្ចាំងជ្រុងនៃជីវិតក្នុងសង្គមជាបន្តបន្ទាប់ដូចជារឿង "យប់កណ្តាលថ្ងៃ" របស់អ្នកនិពន្ធប៉ុក បុណ្ណសមាជ បានរៀបរាប់អំពីជីវិតមនោសញ្ចេតនាពិតៗក្នុងគ្រួសារតូចមួយ ដែលតថភាពសង្គមបានរុញច្រានទៅដល់ភាពជូរចត់នៃជីវភាពគ្រួសារ ។

សម័យព្រះរាជាណាចក្រកម្ពុជាទី ២ : យើងឃើញថាអក្សរសិល្ប៍ក៏ចាប់ផ្តើមរីកចម្រើនបែបសេរីឡើងវិញ ។ ប៉ុន្តែវិស័យអក្សរសិល្ប៍ដែលទើបនឹងទទួលសេរីភាពពេញលេញនេះក៏ចាប់ផ្តើមជួបនឹងការប៉ះទង្គិចយ៉ាងខ្លាំងនោះ គឺការរីកចម្រើននូវបច្ចេកវិទ្យាវីដេអូ ព្រមទាំងការហូរចូលយ៉ាងគំហុក ដោយខ្វះការត្រួតពិនិត្យឱ្យបានត្រឹមត្រូវនៃវប្បធម៌និងខ្សែវីដេអូបរទេសចូលលុកលុយសង្គមកម្ពុជាយើង ហើយសង្កត់វិស័យវប្បធម៌ខ្មែរ វិស័យអក្សរសិល្ប៍ខ្មែរ ដែលទើបតែងើបពីសង្គ្រាមជាងពីរទសវត្សកន្លងមក ។

សរុបសេចក្តីមក អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះមើលការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ គឺជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់ផ្សាយវប្បធម៌ជាតិថែមទៀត។ ដូច្នេះអ្នកនិពន្ធដែលមានឋានៈជាអ្នកផ្សាយវប្បធម៌ គប្បីជ្រើសរើសយកគំនិតទស្សនៈយោបល់ល្អៗ ហើយសំខាន់ៗទៅតាក់តែងអត្ថបទរបស់ខ្លួនឱ្យបានជាទីគាប់ចិត្ត ចាប់អារម្មណ៍ហើយជាគុណប្រយោជន៍ដល់អ្នកអានថែមទៀត។

ដកស្រង់និងសំរួលពី ៖

- *សៀវភៅប្រវត្តិអក្សរសិល្ប៍ខ្មែរភាគ ១ របស់លោក លាង ហាប់អាន*
- *សៀវភៅ "អក្សរសិល្ប៍ខ្មែរឆ្នាំ ១៩៧០-១៩៧៥" របស់លោក ហាក់ វ៉ាន់ដារា ទំព័រ ២៣១-២៣២*
- *សៀវភៅ "អក្សរសិល្ប៍ខ្មែរឆ្នាំ ១៩៧០-១៩៧៥" របស់លោក ហាក់ វ៉ាន់ដារានិងសៀវភៅអក្សរសិល្ប៍ខ្មែរសតវត្សទី ២០ របស់លោក ឃឹង ហុកឌី*
- *សៀវភៅកំណាព្យចម្រៀងសម័យកម្ពុជាប្រជាធិបតេយ្យទំព័រ ៣៥ របស់លោក ណុន សុខា រាជបណ្ឌិត្យសភាកម្ពុជា*

សំណួរ

១. តាមរយៈអត្ថបទនេះ តើគេអាចចែកអក្សរសិល្ប៍ខ្មែរប៉ុន្មានដំណាក់កាល ? គឺអ្វីខ្លះ ?

២. តើអក្សរសិល្ប៍សម័យទំនើបមានប៉ុន្មានផ្នែក ? ចូររៀបរាប់។

៣. ចូររាប់ឈ្មោះរឿងប្រលោមលោកល្បីៗក្នុងសម័យអាណាព្យាបាលបារាំង ហើយកំពុងបញ្ចូលក្នុងកម្មវិធីសិក្សានាពេលបច្ចុប្បន្ននេះ។

៤. តើអ្នកយល់ដូចម្តេច ចំពោះអក្សរសិល្ប៍ខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរ ?

៥. ចូរនិយាយអំពីអក្សរសិល្ប៍ខ្មែរក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ហើយពន្យល់ចំណងជើងចម្រៀង "នៅគ្រប់ការដ្ឋានថ្ងៃណាក៏បុណ្យ"។

៦. តើអ្នកមានវិធីណាខ្លះដើម្បីទប់ស្កាត់ការហូរចូលនៃអក្សរសិល្ប៍បរទេស ដែលបង្ហាញពីចំណុចអសកម្ម (អវិជ្ជមាន) ដល់អក្សរសិល្ប៍ខ្មែរ (ផ្នែកខ្សែភាពយន្តនិងវីដេអូ) ?

រឿងព្រះវេស្សន្តរ



ក. សិក្សាពាក្យគន្លឹះ

- រលាក់រលើ (កិ) : រលើដោយភ័ន្តស្មារតី ភ័ន្តផ្លូវ ពភ្លាក់ពព្លើ។
- សសៀរមមៀរ (កិ) : ដើរសសៀរសំរៀមៗ ក្បែរខាង។
- ភគវតី (ន) : ពាក្យជាឥត្ថីលិង្គរបស់ពាក្យភគវត ឬភគវន្ត តាមរូបសព្ទសម្រាប់ហៅស្ត្រីអ្នកមានបុណ្យ មានសក្តិទាំងពួង តាមលទ្ធិព្រាហ្មណ៍ច្រើនហៅព្រះឧមារ ឬព្រះលក្ស្មីថា ព្រះភគវតីតាមសណ្តាប់ប្រទេសហៅថា ស្ត្រីជាព្រះអគ្គមហេសីនៃក្សត្រទ្រង់រាជ្យក៏បាន។
- សុបិននិមិត្ត (ន) : ការយល់សប្តិឃើញមានទំនងជាគ្រឿងសង្កេតបាន (ថានឹងមានហេតុអាក្រក់ឬល្អ)។
- ឆ្កៀល (កិ) : ខ្ទេះកកាយគាស់អ្វីៗ ដោយម្រាមដៃ ចុងកាំបិត ឬដែកស្រួច។
- ព្រះអង្ឃា (ន) : ស្មាក្សត្រិយ៍ (រាជសព្ទ)
- តើន (កិ) : ភ្ញាក់ពីដេក (រាជសព្ទ សង្ឃសព្ទ)
- ភិតភ័យ (គុ) : សេចក្តីខ្លាច ហេតុឬដំណើរដែលគួរឱ្យខ្លាច។

- អារ្យមគ្គ (ន) : កន្លែងនៅសម្រាប់ធ្វើចិត្តឱ្យស្ងប់រម្ងាប់ លំនៅសម្រាប់រម្ងាប់រាគាទិក្កិលេស គឺខ្ទមឬកុដិលំនៅរបស់តាបស ឥសី យោគី ។
- ព្ពីរ (គុ) : ដែលតឹងឬណែនខ្លាំង ដែលចង្អៀតចិត្តខ្លាំង ។
- ទង្គិរ (កិ) : ផ្ទួកនឹកមមៃដោយអាការតានតឹងចិត្ត ។
- តក្កមា (កិ) : តក់ប្រាជ្ញា គឺតក់ស្លុត ស្លន់ញ៉ូរទទ្រាក់ទទ្រើកស្មើរភ័ន្តបាត់ប្រាជ្ញាស្មារតី
- ស្ងៃពន្លះ (កិ) : លះកិច្ចការឯទៀតហើយខំប្រឹងសង្វាតស្វែងរកអ្វីមួយដែលត្រូវការមិនគិតដល់ទីឆ្ងាយ ។
- បារមី (ន) : គុណជាតិដ៏ល្អដែលបុគ្គលគួរបំពេញ ។
- ញ៉ូរចំប្រប់ (កិ) : កក្រើកទទាក់ខ្លាំង កម្រើករន្ធាន់ ភ័យខ្លាំង ។
- ព្រាហ្មណ៍ (ន) : មនុស្សដែលកំណត់តាមលទ្ធិបុរាណពីព្រេងនាយ ថាមានពូជដើមកើតអំពីព្រះឱស្ឋព្រហ្ម ។
- អយ្យកោ (ន) :ជីតា តា ។
- ទន្ទរ (កិ.វិ) : ដែលមានអាការឱនៗ លបៗ ។
- កញ្ឆក់ (កិ) : ចាប់យកដោយប្រញាប់ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកត្រូវអានដោយយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងទៅនឹងគោលសំខាន់ៗក្នុងព្រះពុទ្ធសាសនា វិធីតែងនិពន្ធមួយចំនួននិងខ្លឹមសារសំខាន់ៗក្នុងអក្សរសិល្ប៍ពុទ្ធនិយម ។

គ. សង្ខេបរឿង

កាលព្រះសាស្ត្តាចារ្យគង់នៅនគរាជគ្រឹះ ឧទាយិត្ថេរ បាននិមន្តព្រះសង្ឃឱ្យនិវត្តមកកាន់នគរកបិលព័ស្តុ តាមសេចក្តីអារាធនារបស់ព្រះបាទស្រីសុទ្ធោទន៍ ពុទ្ធបិតា ។ កាលព្រះពុទ្ធយាងមកដល់និងក្រោយពេលដែលពុទ្ធបិតាទ្រង់ផ្គងអញ្ជលីគោរពថ្វាយបង្គំព្រះដ៏មានបុណ្យ ស្រាប់តែមហាមេឃបង្អុរភ្លៀងបោក្ខរព័សដ៏អស្ចារ្យ គឺនរណាចង់ទទឹកទើបទទឹក នរណាពុំចង់ទទឹកក៏ឥតទទឹកឡើយ ។ ដោយហេតុដ៏អស្ចារ្យនៃភ្លៀងសួគ៌នេះ ដែលព្រះពុទ្ធទ្រង់សម្តែងធម្មទេសនារឿងព្រះវេស្សន្តរថា ៖

កាលនោះព្រះបាទសិរិមហារាជ សោយរាជ្យនៅនគរជេតុត្តរសិរិរដ្ឋ ទ្រង់មានព្រះរាជបុត្រនាមសញ្ជ័យ ។ ព្រះរាជាទ្រង់អភិសេកព្រះសញ្ជ័យជាមួយ ផុស្សតី ជារាជបុត្រីនៃព្រះបាទ មទ្ទរាជ នៃនគរមទរដ្ឋ ។

បុព្វប្រវត្តិនៃនាងផុស្សតីនោះ គឺថានៅចុងកប្បទី ៩១ នាងនេះជារាជបុត្រីនៃព្រះបាទ មទ្ទរាជ នៃនគរមទរដ្ឋ។ នាងបានបូជាលំអិតខ្លឹមចន្ទន៍ចំពោះព្រះពុទ្ធ វិបស្សី។ ដោយផលានិសង្សនេះ នាងមានក្លិនក្រអូប។ ទីបំផុតនាងបានទៅជាអគ្គមហេសីនៃព្រះឥន្ទ្រាធិរាជ។ កាលដល់កំណត់ជន្មាយុ ព្រះឥន្ទ្រជ្រាបថា នាងនឹងច្យុតចាកទេវលោក ព្រះអង្គក៏ប្រទានពរ ១០ប្រការ ចំពោះនាងតាមសេចក្តីប្រាថ្នាគឺ :

១. ឱ្យបានជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យ នានគរជេតុត្តរ

២. ឱ្យមានភ្នែកល្អ មានភ្លុមោកោងទ្រទេសទ្រទួយដូចចង្កួយកៅទណ្ឌ

៣. ឱ្យមានឈ្មោះថា ផុស្សតីដដែល

៤. ឱ្យមានកូនប្រុសមួយ មានកិត្តិនាមល្បីល្បាញ

៥. ពេលមានគតិសូមឱ្យមានផ្ទៃពោះរាបស្មើល្អដូចប្រក្រតី

៦. កុំឱ្យមានដោះសណ្តាយ

៧. កុំឱ្យមានសក់ស្ពូវ

៨. ត្រូវមានសាច់សម្បុរស្បែកម៉ដ្ឋខៃល្អ ដូចសាច់ពពិលមាស

៩. ឱ្យមានអំណាចអាចដោះទុក្ខទោសរបស់មនុស្ស សត្វទាំងឡាយ

១០. ត្រូវមានបក្សី គឺហង្ស ក្រៀល ក្ងាន ក្ងោក បន្តឺនូវសំឡេងល្វើយនាព្រះរាជមន្ទីរ។

ព្រះនាងផុស្សតី ច្យុតចាកទេវលោកមកកើតក្នុងផ្ទៃនៃព្រះអគ្គមហេសីរបស់ព្រះបាទមទ្ទរាជ។ នាងមានក្លិនកាយក្រអូបដូចខ្លឹមចន្ទន៍ ទើបគេថ្វាយព្រះនាមថា ផុស្សតី។ ព្រះបាទ សិរិមហារាជទ្រង់ប្រោសអភិសេកនាងឱ្យជាអគ្គមហេសីនៃព្រះស្រីសញ្ជ័យរាជបុត្ររបស់ព្រះអង្គ។ កាលនោះព្រះពោធិសត្វយាងចុះពីឋានតៃត្រឹង្សមកចាប់បដិសន្ធិក្នុងផ្ទៃនាងផុស្សតី។ តាំងពីមានគតិកាលណា ព្រះនាងផុស្សតីចំណាយព្រះរាជទ្រព្យ ៦ម៉ឺនគហាបណៈរាល់ៗថ្ងៃ ដើម្បីព្រះរាជទានក្នុងសាលាទានទាំង ៦។ នៅពេលគ្រប់ទសមាស ព្រះនាងយាងប្រទក្សិណនគរ ក៏ស្រាប់តែប្រសូតព្រះពោធិសត្វនៅចំចន្លោះផ្លូវនៃឈ្នួញ ទើបគេថ្វាយនាមរាជទារកថា ព្រះវេស្សន្តរ។ ក្នុងថ្ងៃព្រះពោធិសត្វប្រសូតមក មេដំរីមួយបាននាំកូនដំរីសសុទ្ធមកថ្វាយក្នុងកន្លែងដំរីមង្គល។ គេដាក់នាមដំរីនេះ បច្ចយនាគ។ នៅពេលព្រះជន្មបានប្រាំឆ្នាំ ព្រះពោធិសត្វប្រទានទ្រព្យគ្រឿងប្រដាប់កុមារមានតម្លៃ ១សែនកហាបណៈដល់មេនំ គំរប់ ៩ដង។ កាលព្រះជន្មបាន ៨ឆ្នាំទ្រង់ប្រាថ្នាឱ្យបេះដូង ភ្នែក សាច់ ឈាម ជាទានហៅថា អជ្ឈត្តិកទាន។

ព្រះជន្មបាន ១៦ឆ្នាំ ព្រះបិតាទ្រង់ផ្សំផ្គុំនាង មទ្រី ជារាជបុត្រីនៃស្តេច មាតុលនគរ នៃដែលមទ្ទរដ្ឋឱ្យជាអគ្គមហេសី ហើយទ្រង់ដាក់រាជ្យថ្វាយឱ្យគ្រប់គ្រងនគរវៀងមក។ ចំណេរកាលមក នាងមទ្រីប្រសូតព្រះរាជបុត្រមួយដាក់នាមថា ជាលី រួចប្រសូត្របានរាជបុត្រីមួយដាក់នាមថា កណ្ហាជិនា។[៥]

គ្រាមួយដែន ក្លិងរាស្ត្រ កើតទុរ្ភិក្ស រាំងភ្លៀងអត់បាយ។ អ្នកនគរចាត់ឱ្យព្រាហ្មណ៍ ៨នាក់ទៅសុំដំរីមង្គលពីព្រះវេស្សន្តរ។ ព្រះពោធិសត្វក៏សព្វព្រះទ័យប្រោសប្រទានដំរី ព្រមទាំងគ្រឿងប្រដាប់ស្នូម។ ពេលនោះអ្នកស្រុកពិរាស្ត្រនាំគ្នាខឹង សុំព្រះរាជាឱ្យបំបរបង់ព្រះវេស្សន្តរចេញពីនគរ។ ព្រះបាទស្រីសញ្ជ័យពុំយល់ព្រមតាម តែអ្នកស្រុកពុំសុខចិត្ត។ ទីបំផុត ព្រះវេស្សន្តរសម្រេចព្រះទ័យថានឹងចេញពីនគរទៅបួសនៅក្នុងព្រៃភ្នំគីរីវង្កត។ ព្រះអង្គហៅនាងមទ្រី មកផ្តែផ្តាំ ប៉ុន្តែព្រះនាងទទូចសុំទៅតាមបម្រើព្រះស្វាមីតែមួយមុខ។

ព្រះនាង ផុស្សតី អាឡោះអាល័យបុត្រ។ នាងយាងទៅអង្វរសុំទោសព្រះស្វាមីឱ្យព្រះរាជទានលើកលែងទោសព្រះវេស្សន្តរ តែពុំបានសម្រេច។ តមកព្រះវេស្សន្តរប្រារព្ធធ្វើសត្តកមហាទាន គឺទានវត្ថុចំនួន ៧រយៗ គម្រប់ ៧មុខ មានដំរី សេះ រទេះ កញ្ញា មេគោផ្នាត់ គោបា ខ្ញុំប្រុសខ្ញុំស្រី ៧រយៗ មួយមុខៗ។

ព្រះនាងផុស្សតី សុំឃាត់នាងមទ្រីជារាជសុណិសាឱ្យនៅក្នុងនគរ នាងមទ្រីពុំព្រម។

តមកព្រះវេស្សន្តរនិងនាងមទ្រី នាំបុត្រទាំងពីរថ្វាយបង្គំព្រះមាតាបិតាយាងចេញទៅ។ ព្រះពោធិសត្វទ្រង់ប្រទានសេះទាំង៤ទៅព្រាហ្មណ៍ ៤នាក់និងរាជរថទៅព្រាហ្មណ៍ម្នាក់ទៀតតាមផ្លូវ។ ទីបញ្ចប់ទ្រង់ពបាជាលី នាងមទ្រីពទៅក្រីស្នា[៦] យាងផ្ទាល់ព្រះបាទាបន្តដួរទៅមុខទៀត។

ព្រះវេស្សន្តរមហេសីនិងបុត្រយាងដល់មាតុលនគរ។ ពួកអ្នកចេត្ររាស្ត្រចេញមកទទួល ហើយព្រមព្រៀងថ្វាយរាជសម្បត្តិចំពោះព្រះវេស្សន្តរ ប៉ុន្តែព្រះអង្គពុំទទួល។ ស្តេចចេត្ររាស្ត្រនាំគ្នារៀបជួនជំណើរព្រះពោធិសត្វទៅដល់ទ្វារភ្នំគីរីវង្កត ហើយលើសកូនប្រុសអ្នកស្រុកម្នាក់ឈ្មោះ ចេតបុត្រឱ្យចាំនាំច្រកភ្នំ ដើម្បីការពារសេចក្តីសុខចំពោះព្រះវេស្សន្តរ។ ក្សត្រទាំង ៤ យាងដល់ឆ្នេរស្រះបោក្ខរណីបានឃើញអាស្រមបទដែលសក្កទេវរាជនិម្មិតថ្វាយ ក៏នាំគ្នាចូលគង់នៅបួសជាឥសីក្នុងទីនោះទៅ។

គេនិយាយពីព្រាហ្មណ៍ម្នាក់ឈ្មោះ ជូជក នៅស្រុកទុន្ទវិដ្ឋព្រាហ្មណ៍គ្រាម សន្សំប្រាក់បាន ១រយគហាបណៈយកទៅផ្ញើនឹងត្រកូលព្រាហ្មណ៍មួយ។ ត្រកូលព្រាហ្មណ៍ចាយប្រាក់ជូជកអស់ ក៏សុខចិត្តលើកកូនស្រីឈ្មោះនាងអមិត្តតាបនា ឱ្យធ្វើជាប្រពន្ធតាជូជក។ ថ្ងៃមួយពួកព្រាហ្មណ៍ក្មេងៗបានចោមរោមវាយនាងអមិត្តតាបនា ដោយក្តីច្រណែន។ នាងនេះបានលេសក៏លែងបម្រើប្តីចាស់ ហើយក៏បង្ខំតាជូជកឱ្យទៅរកសុំកូនព្រះវេស្សន្តរមកបម្រើនាង។ ជូជក ធ្វើដំណើរទៅកាន់ភ្នំគីរីវង្កត។ ចេតបុត្រ

ឃើញព្រាហ្មណ៍ចាស់ត្រូវឆ្កែដេញខាំរត់ឡើងចុងឈើ ក៏គិតបាញ់ប្រហារ។ ជូជក កុហកថាខ្លួនជារាជទូតព្រះបាទស្រីសញ្ជ័យ។ ចេតបុត្រជឿក៏អញ្ជើញជូជកមកជប់លៀង។

ក្រោយការជប់លៀង ចេតបុត្ររៀបរាប់ដំណើរទៅកាន់ភ្នំគិរីវង្គតឱ្យជូជកស្លាប់។ តមកជូជកលាចេតបុត្រធ្វើដំណើរទៅដល់អាស្រមនៃអច្ចុតមហាឫសី។

អច្ចុតមហាឫសីទទួលជូជក រួចក៏រៀបរាប់ពីផ្លូវទៅកាន់អាស្រមព្រះវេស្សន្តរ។

ជូជក ទៅដល់ជិតអាស្រមនៅពេលរសៀល។ តាជីនៅសំណាក់ជើងភ្នំមួយយប់ រង់ចាំព្រឹកស្អែកនិងចូលទៅសុំបុត្រអំពីព្រះវេស្សន្តរ។

រាត្រីនោះនាងមទ្រីយល់សប្តិឃើញបុរសម្នាក់ទាបខ្មៅ ស្លៀកសំពត់អម្ចត់ សៀតផ្កាចារនៅត្រចៀកចូលមកផ្តួលនាង ឆ្កៀលយកភ្នែកទាំងពីរ កាត់ស្មានាងទាំងសងខាង ពុះទ្រូងរួងយកថ្លើមនិងបេះដូងទៅ។ ភ្ញាក់ទាំងរាត្រីទូលព្រះវេស្សន្តរ។ ព្រះពោធិសត្វកាត់សុបិនថា ល្អណាស់។

ស្អែកឡើងនាងមទ្រីចេញទៅបេះផលា។ តាជូជកចូលមកសុំថៅក្រីស្នានិងជាលី។ រាជកុមារទាំងពីរភិតភ័យ ក៏នាំគ្នារត់ទៅពួននៅឯស្រះឈូក។ ជូជក ចាប់រាជកុមារទាំងពីរចងវាយវាត់នៅចំពោះមុខព្រះភ័ក្ត្រព្រះវេស្សន្តរ។ ព្រះពោធិសត្វទប់ព្រះទ័យពុំបាន ទ្រង់ចាប់ធ្នូសរបម្រុងនឹងប្រហារព្រាហ្មណ៍ចោល តែទ្រង់ទប់បានវិញ។ ជូជកនាំកុមារចេញទៅ។

និយាយពីនាងមទ្រីទៅបេះផ្លែឈើពុំបានសោះ។ នាងបានជួបប្រទះនូវខ្យល់ព្យុះ ភ្លៀង ផ្គរ ហើយចេះតែជួបហេតុភេទស្លែកៗដូចជា រកាំភ្នែកឆ្វេង កម្រើកភ្នែកស្តាំ ធ្លាក់សង្រែកពីស្មា ធ្លាក់ទំពក់ពីដៃ។ នាងពុំអាចវិលមកអាស្រមបាន ព្រោះទេវបុត្រនិម្មិតកាយជារាជសីហ៍១ ខ្លាធំ១ ខ្លាដំបង១ រាំងផ្លូវនាង។ លុះព្រលប់ទើបទេវបុត្រកាឡាចេញអស់ទៅ នាងវិលមកកាន់អាស្រម។ នាងមទ្រីបាត់ពុំឃើញបុត្ររត់មកទទួលដូចប្រក្រតី។ នាងភិតភ័យខំស្រែកហៅក៏ពុំឃើញ។ នាងសួរព្រះស្វាមីក៏ព្រះអង្គពុំឆ្លើយតប។ នាងមទ្រីសោយសោកលុះដួលសន្លប់បាត់ស្មារតី។ ព្រះវេស្សន្តរស្ទុះមកត្រកងបីយកទឹកស្រពាក្ត្រឱ្យនាងដឹងខ្លួនវិញ ទើបទ្រង់លួងលោមប្រាប់ថា ព្រះអង្គបានប្រទានបុត្រទៅជូជកហើយ។ នាងមទ្រីអនុមោទនាបុត្តទានក្នុងខណៈនោះ។

និយាយពីព្រះឥន្ទ្រាធិរាជ ទ្រង់ចុះមកកាឡាជាព្រាហ្មណ៍ម្នាក់ដើរចូលមកអាស្រមព្រះវេស្សន្តរ ដើម្បីបំពេញភរិយាទានរបស់ព្រះពោធិសត្វ។ ព្រះនាងមទ្រីយល់អធ្យាស្រ័យស្វាមី ក៏ព្រមឱ្យព្រះវេស្សន្តរដាក់ប្រទាននាងទៅឥន្ទ្រព្រាហ្មណ៍។ ព្រះឥន្ទ្រទ្រង់សរសើរព្រះហឫទ័យសប្បុរសរបស់ព្រះពោធិសត្វ ហើយទ្រង់បានប្រគល់នាងមទ្រីថ្វាយទៅព្រះវេស្សន្តរវិញ។ ខណៈនោះព្រះវេស្សន្តរបានសុំពរពីព្រះឥន្ទ្រ ៨ប្រការ :

១. សូមឱ្យព្រះវរាជបិតាស្តេចមកនាំយើងខ្ញុំត្រឡប់ទៅនគរវិញ

២. សូមឱ្យមានអំណាចអាចដោះទុក្ខទោសរបស់សត្វទាំងឡាយឱ្យផុតពីសេចក្តីស្លាប់

៣. សូមឱ្យបានជួយសង្គ្រោះដល់ជនកំសត់ទុគ៌តផុតពីក្តីក្រលំបាក

៤. សូមកុំឱ្យមានចិត្តត្រេកត្រអាលខាងផ្លូវកាមគុណជាអកុសល

៥. សូមឱ្យចៅជាលីនិងកណ្ហាជិនា បានគ្រប់គ្រងបុរីពិជ័យជេតុត្តរ

៦. សូមឱ្យមានអាហារទិព្វកើតឡើងរាល់ថ្ងៃ

៧. សូមឱ្យការបរិច្ចាគទានកុំបីមានការខ្វះខាតឡើយ

៨. សូមឱ្យរំលងខន្ធទៅបានកើតឋានតុសិតទេវលោក កុំបីខានឡើយ ។

ជូជក បានដើរអស់ ១៥ថ្ងៃ ហើយទីបំផុតក៏វង្វេងផ្លូវទៅកាន់ក្រុងជេតុត្តរ ។ ព្រះបាទស្រីសញ្ជ័យទតឃើញព្រាហ្មណ៍ចាប់បណ្តើរក្មេងតូចៗទ្រង់បញ្ជាឱ្យហៅមកគាល់ ។ ពួកអាមាត្យមុខមន្ត្រីបានស្តាប់ជូជកប្រាប់ ក៏ចោទប្រកាន់ថ្កោលទោសព្រះវេស្សន្តរថា "មិនគួរលើកកូនឱ្យទានសោះ" ។ ចៅជាលីបានដោះសារការពារព្រះបិតា ។ ព្រះបាទស្រីសញ្ជ័យត្រាស់ឱ្យលោះព្រះរាជនត្តោអំពីជូជក ហើយទ្រង់ឱ្យរៀបពិធីទទួលព្រលឹងចៅ ។ ជាលីបានក្រាបទូលអំពីទុក្ខលំបាករបស់មាតាបិតានៅក្នុងព្រៃ ។ ព្រះស្រីសញ្ជ័យសម្រេចនាំរេហ៍ពលទៅតាមរាជបុត្រវិលមកនគរវិញ ។ ជូជកឃ្លានអាហារពេកស៊ីហួសប្រមាណទាល់តែរលត់សង្ខារទៅ ។ ព្រះបាទស្រីសញ្ជ័យ នាងផុស្សតី រាជវង្សានុវង្ស និងអស់មន្ត្រីព្រមទាំងកុមារទាំងពីរបានចេញដំណើរទៅកាន់ភ្នំគីរីវង្គត ។ ក្សត្រទាំង៦អង្គក៏បានជួបជុំគ្នាដូចប្រាថ្នា ហើយសំណោះសំណាលយំសោកត្រាតែសន្លប់អស់ ។ ខណៈនោះមហាមេឃបង្អុរភ្លៀងបោកព័ស៌ចុះមក ធ្វើឱ្យក្សត្រទាំង៦និងសេនាអាមាត្យមុខមន្ត្រីដឹងស្មារតីវិញ ។ អស់មុខមន្ត្រីក្រាបថ្វាយបង្គំព្រះវេស្សន្តរនិងនាងមទ្រីសូមឱ្យស្តេចត្រឡប់ថ្កានព្រះនគរសោយរាជសម្បត្តិវិញ ។ ក្រោយនោះព្រះវេស្សន្តរនិងនាងមទ្រីលាព្រះផ្នួស ។ ព្រះស្រីសញ្ជ័យបានសុំទោសបុត្រ ហើយទ្រង់លួងលោមបុត្រដោយប្រការផ្សេងៗ ។ តមកចតុរង្គសេនា ក៏ដង្ហែព្រះពោធិសត្វ រាជវង្សានុវង្សចូលមកនគរវិញដោយសុវត្ថិភាព ។ ព្រះវេស្សន្តរសោយរាជ្យជាសុខរហូតសោយទីវង្គតបានទៅកើតឋានតុសិត មាននាមថាសន្តុសិតទេវបុត្រ ។ ព្រះរាជវង្សានុវង្សនិងនាម៉ឺនសព្វមុខមន្ត្រី បានចាត់ការធ្វើរាជាភិសេកព្រះជាលីនិងនាងកណ្ហាជិនាជាព្រះមហាក្សត្រៀងមក ។

គ. អត្ថបទដកស្រង់ : កណ្ឌទី ៨ កុមារបាព៌

ជូជកោ ឬជូជកចាស់ជរា ដើរតាមមាគ៌ាអស់រយៈពេលមួយថ្ងៃគត់បានដល់ទីជិតអាស្រមបទ ជួនជារយៈសាយណ្ហសម័យថ្ងៃទន់ទាបរហៀបអស្តង្គតរលត់ព្រះសូរ្យសែង ដោយអំណាចខំដើរតាមផ្លូវដាច់

សង្វែង ក៏មានក្តីលំបាកយ៉ាងខ្លាំង ជួជកចុកចង្កេះរឹងគាំង ទើបយកដៃគក់បណ្តើរ គិតបណ្តើរថា "ថ្មារនេះ នាងមទ្រីមកពីព្រៃវិញហើយ មុខជាពុំព្រមឱ្យកូនដល់អញទេ អញដេកនៅទីនេះសិនចុះ ព្រឹកឡើងនាងមទ្រីទៅព្រៃបាត់ សឹមអញសុំកូននឹងព្រះវេស្សន្តរ" គិតដូច្នោះហើយ ក៏ដើរសសៀរមម្យៀរតាមជំនៀរភ្នំ ឃើញថ្លុកជង្អុកណ្តាងថ្ម គាត់ក៏យកខ្នងទៅលេ យល់ជាត្រូវល្អ ទើបប្រែខ្លួនដេកលក់ជាសុខនៅទីនោះ ។

ថ្លែងពីសម្តេចព្រះភគវតីស្រីមទ្រី ក្នុងវេលារាត្រីនោះព្រះនាងទ្រង់ឃើញសុបិននិមិត្តថា "បុរសម្នាក់ទាបខ្មៅ ស្លៀកសំពត់អម្ចត់ត្រីមជង្គង់ សៀតផ្កាចារព្ធដ៏ត្រចៀក កាន់អាវុធមុតថ្លារត់ចូលមកក្នុងបរមសាលា ចាប់ព្រះនាងផ្តួលចុះ ឆ្កៀលយកព្រះនេត្រទាំងពីរ កាត់យកព្រះអង្សាទាំងសងខាង ពុះទ្រូងរួងយកថ្លើមបេះដួងទៅ ។ ព្រះនាងតើនឡើងភិតភ័យតក្កមា ទើបព្រះនាងយាងយាត្រាចូលទៅរកស្វាមី គោះទ្វារអាស្រមបរមកុដទាំងរាត្រីនោះឯង ។

- ព្រះវេស្សន្តរសួថា កោងសោ នរណាអ្ហ៊ឺះ ! នរណាហ្នឹង ?
- ព្រះនាងមទ្រីទូលថា ខ្ញុំម្ចាស់ព្រះអង្គ សូមទ្រង់មេត្តាប្រោស !
- ព្រះវេស្សន្តរ នែ ! ម្តេចក៏នាងមកក្នុងពេលពុំជួរកាលដូច្នេះ ក្រែងយើងបានប្តេជ្ញាគ្នាហើយឬ ! ថាកុំឱ្យមករកគ្នាក្នុងវេលាយប់ស្ងាត់ ។
- ព្រះនាងមទ្រីថា ពិតដូច្នោះមែនហើយព្រះអង្គ ប៉ុន្តែសូមទ្រង់ព្រះសណ្តាប់ ខ្ញុំម្ចាស់នឹងសារស័ព្ទឱ្យសព្វសេចក្តី ព្រោះអម្បាញ់មិញនេះខ្ញុំម្ចាស់យល់សប្តិឃើញអាក្រក់ណាស់ព្រះអង្គ ។ ព្រះនាងថ្លែងសេចក្តីនៃសុបិននិមិត្តថ្វាយសព្វគ្រប់ ។
- ព្រះវេស្សន្តរថា អើ ! នាងនៅខាងក្រៅទ្វារនេះចុះ សុបិននិមិត្តនៃនាងនោះ មិនអាក្រក់ទេ ! កុំភ័យអី ! ទៅវិញចុះនាងក្រែងកូនភ្ញាក់ឡើងវាខ្លាច ។

ព្រឹកឡើងព្រះនាងមទ្រីនាំព្រះរាជបុត្រទាំងពីរទៅផ្ញើនឹងព្រះស្វាមី ផ្តែផ្តាំសព្វសេចក្តីហើយ ក្សត្រីយ៍ទ្រង់យកសង្រែកដងវែក ជ្រនឹក ទំពក់ចូលទៅក្នុងព្រៃ ដើម្បីប្រមូលផលាផល ព្រះជលនេត្រហូររហាមតាមព្រះនេត្រា ព្រះឱរាតឹងពួនទង្គឹះក្នុងព្រះរាជហឫទ័យ ព្រះនាងនឹកមមៃមករកព្រះរាជបុត្រនិងព្រះរាជស្វាមី ដោយក្តីពិភាល់យ៉ាងខ្លាំងចំពោះសុបិននិមិត្តនោះ ។

រីឯជួជក ភ្ញាក់ឡើងគិតថា "ថ្មារនេះប្រហែលជានាងមទ្រីទៅព្រៃហើយ" គិតហើយក៏ដើរឆ្ពោះសំដៅទៅអាស្រមបទ ។

ព្រះវេស្សន្តរទ្រង់ជ្រាបតាំងពីល្ងាចថា "ព្រឹកនេះនឹងមានស្នូមមកសូមព្រះរាជបុត្រ" ទើបព្រឹកឡើងទ្រង់ចេញមកគង់ខាងក្រៅអាស្រមបទ ទន្ទឹងផ្លូវស្នូមដូចជា មនុស្សប្រមឹកទន្ទឹងផ្លូវប្រពន្ធទៅផ្សារ ដើម្បីទិញស្រាមកផ្ទើ លុះទ្រង់ទតឃើញជូជកដើរលាក់លើ ទ្រង់ហៅកុមារជាលីថា កូនអើយកូន អ្នកណាឈរឡើង! មើលនុះន៏ នរណាមកពីចម្ងាយ ?

- ជាលីក្រាបបង្គំទូលថា បពិត្រព្រះបិតា ទូលព្រះបង្គំមើលទៅឃើញប្រាកដដូចជាព្រាហ្មណ៍ ព្រាហ្មណ៍នោះមកជាភ្ញៀវយើងហើយព្រះអង្គ។ ព្រះកុមារទូលហើយ ក៏ស្ទុះតម្រង់ទៅទទួលដំណើរព្រាហ្មណ៍ត្រូវជូជកគំរាម។
- ជូជកទន្ទបលបចូលទៅសួរសុខទុក្ខព្រះវេស្សន្តរ។
- ព្រះវេស្សន្តរថា យើងសុខសប្បាយទេព្រាហ្មណ៍ទាំងមូលផលាផលក៏គ្រប់គ្រាន់ ពួកសត្វល្ពិតសត្វទ្វេបាត ចតុប្បាទ ឥតយាយីយើងទេ តែតាំងពីយើងមកនៅព្រៃ ៧ខែហើយឥតមានមនុស្សណាមួយមកជាភ្ញៀវយើងឡើយ ទើបតែនឹងបានឃើញព្រាហ្មណ៍ឯងជាដំបូង ចូរអ្នកលាងជើង ចូរអ្នកបរិភោគផ្លែឈើបើអ្នកចង់ផឹកចូរដងយកអំពីរោងទឹកខាងណោះ អ្នកស្ងួនពន្លះមកដល់ទីនេះ តើដើម្បីអ្វី ?
- ជូជកទូលថា ខ្ញុំព្រះអង្គឮថា ព្រះរាជហឫទ័យរបស់ព្រះអង្គពេញព្រៀបដោយបរិច្ចាគចេតនាដូចជា ទន្លេពេញព្រៀបដោយទឹក មិនចេះអស់សព្វកាយ កាលពេលមុន ខ្ញុំព្រះអង្គមកទទួលព្រះរាជទានពុំទាន់នឹងគេ ទើបតែឥឡូវនេះបានតាមមកថ្វាយបង្គំដើម្បីសុំព្រះរាជបុត្រាបុត្រី។
- ព្រះវេស្សន្តរថា យើងឱ្យ! យើងឥតរុញរាទេ ប៉ុន្តែមាតានៃបុត្រទាំងពីរនុ៎ះ ចេញទៅរកផលាតាំងពីព្រឹកម្ល៉េះ ដូច្នេះព្រាហ្មណ៍រង់ចាំនៅទីនេះមួយយប់សិន លុះព្រឹកឡើងសឹមនាំយកកុមារទាំងពីរ ដែលមាតាស្ងួតស្ងាងហើយនោះទៅចុះ។
- ជូជកថា ទូលព្រះបង្គំមិនគាប់ចិត្តនឹងការនៅទេ ក្រែងមានអន្តរាយ ទូលព្រះបង្គំនឹងទៅឥឡូវនេះខានពុំបាន។
- ព្រះវេស្សន្តរថា បើអ្នកមិនចង់ជួបនឹងភរិយាយើងទេ ចូរអ្នកនាំកុមារទាំងពីរនេះទៅថ្វាយចំពោះព្រះអយ្យកោចុះ មុខជាទ្រង់រីករាយនឹងព្រះរាជទានទ្រព្យច្រើនដល់អ្នក។
- ជូជកប្រកែកថា ទេ! ទេ! ពុំហ៊ានទៅទេព្រះអង្គ ខ្លាចក្រែងព្រះអយ្យកោដណ្តើមយកព្រះរាជកុមារ ហើយពួកអាមាត្រធ្វើរាជទណ្ឌចំពោះខ្ញុំព្រះអង្គ។

- ព្រះវេស្សន្តរថា ម្ចៅកូនទាំងពីរជាទីស្រឡាញ់របស់បិតា ចូរកូនមកអាយ ចូរបំពេញបារមីរបស់បិតា ចូរស្រោចស្រពហឫទ័យរបស់បិតា ចូរកូនតាំងខ្លួនជាយានានាវាឱ្យបិតានាំសត្វជិះឆ្លងចាក ជាតិ ជរា ព្យាធិ មរណៈ ទៅកាន់ត្រើយនាយ គឺព្រះនិព្វានណ៎កូន ។

គ្រាដែលព្រះពោធិសត្វប្រទានព្រះរាជបុត្រដល់ព្រាហ្មណ៍នេះ ផែនដីក៏កក្រើករំពើកញាប់ញ័រជាលើកទី ៥ ។ កុមារទាំងពីរឮសំដីព្រាហ្មណ៍រឹងរូសដូច្នោះភ័យណាស់នាំគ្នារត់ទៅពួនឯស្រះ យកស្លឹកឈូកបាំងព្រះភ័ក្ត្រ ។ ជូជកបោចវល្លិចងព្រះហស្តនៃព្រះកុមារទាំងពីរព្រះអង្គ វាយនាំបណ្តើរទៅអំពីទីចំពោះព្រះភ័ក្ត្រនៃព្រះរាជា គ្រាន់តែផុតអំពីព្រះនេត្រា ជូជកជំពប់ដួលខ្ពោក ។ កុមារទាំងពីរ កំពុងមានទឹកនេត្រាហូរសស្រាក់ ក៏របូតអំពីចំណងរត់ត្រសងមករកបិតា មានព្រះកាយញ័រចំប្រប់ដូចស្លឹកពោធិ៍ត្រូវខ្យល់ ឱបងើបទតព្រះភ័ក្ត្រព្រះបិតា ។

- ជាលីទូលអង្វរថា ព្រះមាតាចេញទៅព្រៃហើយ ម្តេចក៏ព្រះបិតាពុំបង្ហង់ឱ្យយើងខ្ញុំជួបនឹងព្រះមាតាសិន សឹមទ្រង់ព្រះរាជទានយើងខ្ញុំ ! មួយទៀត សូមព្រះអង្គព្រះរាជទានតែខ្ញុំជាលីទៅចុះ កុំព្រះរាជទានកណ្ហាជិនាឡើយ ព្រោះនាងនៅតូចណាស់ ។

ជូជកតាមមកចាប់កញ្ឆក់ទាញយកទៅទៀត វាយវាត់ឥតត្រាប្រណី ។ ព្រះមហាឥសីទប់ព្រះហឫទ័យពុំបាន ទ្រង់ចាប់ធ្នូសរផ្គងតម្រង់ឆ្ពោះទៅជូជកបម្រុងនឹងប្រហារជីវិតបង់ តែទ្រង់ទប់បានដោយមានព្រះតម្រិះថា ប្រពៃណីនៃពោធិសត្វអំពីបុរាណ មិនដែលខានធ្វើនូវបញ្ចមហាបរិច្ចាគ គឺធនបរិច្ចាគ អង្គបរិច្ចាគ ជីវិតបរិច្ចាគ បុត្របរិច្ចាគ និងភរិយាបរិច្ចាគទេ ។ [...]

សំណួរ

១. ចូរសង្ខេបអត្ថបទខាងលើឱ្យខ្លីល្មមស្តាប់បាន ។

២. ចូរបង្ហាញសិល្បវិធីនិពន្ធ (ឯកវាទវិធី សំវាទវិធី សន្ទេហវិធី រចនាវិធី ឧបមានវិធី ...) ពីអត្ថបទខាងលើនេះ ។

៣. តើប្រផ្នូលអ្វីដែលធ្វើឱ្យព្រះនាងមទ្រីព្រួយបារម្ភ មុនពេលចេញទៅបេះផលា ?

៤. ប្រសិនបើតាជូជកជួបនឹងព្រះនាងមទ្រី តើអាចសុំព្រះរាជបុត្រទាំងពីរ ពីព្រះវេស្សន្តរបានឬទេ ? ព្រោះអ្វី ?

៥. ចូររកមូលន័យក្នុងអត្ថបទដកស្រង់ខាងលើ ដោយភ្ជាប់ឧទាហរណ៍ផង ។

៦. ដូចម្តេចដែលហៅថាអជ្ឈត្តិកទាន ? ពាហិរទាន ? ចូររកឧទាហរណ៍ពីក្នុងអត្ថបទខាងលើមកបញ្ជាក់ ។

៧. តាមរយៈអត្ថបទនេះ តើអក្សរសិល្បពុទ្ធនិយមបានផ្តល់ការអប់រំដូចម្តេចខ្លះ ?



ការរៀបរាប់ឡើងវិញពីទស្សនៈមួយចំនួនក្នុងព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា គឺជាព្រះធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ ។ ព្រះធម៌ ជាពាក្យប្រៀនប្រដៅសំខាន់ៗមួយចំនួនមានដូចខាងក្រោម ៖

១ . អរិយសច្ចៈ ៤ យ៉ាង

- ទុក្ខអរិយសច្ចៈ ទុក្ខដែលជាសភាពពិត មាន ជាតិទុក្ខ គឺទុក្ខព្រោះកំណើត ។ ជរាទុក្ខ គឺជាទុក្ខព្រោះចាស់ ។ ព្យាធិទុក្ខ គឺទុក្ខព្រោះឈឺ ។ មរណទុក្ខ គឺទុក្ខព្រោះស្លាប់ ។
- សមុទយអរិយសច្ចៈ ហេតុដែលនាំឱ្យកើតទុក្ខ ព្រោះវិជ្ជានិងតណ្ហា ។ អវិជ្ជា គឺមកពីមិនដឹង មិនយល់ហេតុនៃទុក្ខ ។ តណ្ហា គឺចំណង់ចង់បាននូវអ្វីៗគ្រប់យ៉ាងមានកាមតណ្ហា ចំណង់ជាដើម ។
- និរោធអរិយសច្ចៈ សភាពពិតក្នុងការរំលត់ទុក្ខ ដោយបំបាត់អវិជ្ជាជាប្រភពដើមនៃទុក្ខ ។
- មគ្គអរិយសច្ចៈ វិធីរំលត់ទុក្ខប្រកបដោយមគ្គ (ត្រូវ) មាន ៨ យ៉ាងគឺ (ហៅថា អដ្ឋង្គិកមគ្គ)
  - សម្មាទិដ្ឋិ : យល់ឃើញត្រូវ
  - សម្មាសង្កប្ប : ត្រិះរិះត្រូវ
  - សម្មាវាចា : សម្តីត្រូវ
  - សម្មាកម្មន្ត : ការងារត្រូវ
  - សម្មាអាជីវៈ : ការចិញ្ចឹមជីវិតត្រូវ
  - សម្មាវាយាម : ព្យាយាមត្រូវ
  - សម្មាសតិ : រឭកត្រូវ
  - សម្មាសមាធិ : តាំងចិត្តត្រូវ

២ . លក្ខណៈនៃភាវៈ (ត្រៃលក្ខណ៍)

លក្ខណៈសកលបីយ៉ាងនៃជីវិតគឺ :

- អនិច្ចំ : ភាវៈទាំងអស់សុទ្ធតែមិនទៀងទាត់ ក្នុងការកើតស្លាប់ចម្រើនវិនាស មិនទៀងទាត់ ។
- ទុក្ខំ : ភាវៈទាំងអស់ឱ្យតែមាននាមនិងរូប សុទ្ធតែមានទុក្ខដូចគ្នា ។
- អនត្តា : ភាវៈទាំងអស់សុទ្ធតែមិនមែនជារបស់ខ្លួន ។

សរុបមក ភាវៈទាំងពួងក្នុងធម្មជាតិត្រូវតែមានការប្រែប្រួលដោយភ្ជាប់ហេតុនិងផល ។

៣ . បញ្ហាកម្មផល

- កម្មផល : ទ្រឹស្តីកម្មផល ដែលបង្ហាញពីចំណងនៃអំពើនិងផលដែលបុគ្គលបានសាងឡើង ។

មនុស្សមានការចេះដឹង លូងំខ្លៅ ល្អ អាក្រក់ ស្រេចទៅលើខ្លួនឯង អំពើរបស់ខ្លួននិងមានវិជ្ជាចេះដឹងបានសម្រេចមគ្គផលក៏ដោយសារខ្លួនឯង បានសិក្សាសន្សំ ប្រឹងស្ទឹងស្មាធ៍ បើលូងំខ្លៅអប្បប្រាជ្ញាក៏ដោយសារកម្មនិងផល ២យ៉ាង :

- កល្យាណកម្ម : អំពើល្អឱ្យផលល្អ (ធ្វើបុណ្យបានបុណ្យ)
- បាបកម្ម : អំពើអាក្រក់ឱ្យផលអាក្រក់ (ធ្វើបាបបានបាប) ។

ពុទ្ធភាសិត "អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ" ។

- កម្មពៀរ : ផលអាក្រក់ដែលបុគ្គលបានទទួលដោយសារអំពើអាក្រក់ ដែលបុគ្គលនោះបានប្រព្រឹត្តពីអតីតជាតិ ។

៤ . បញ្ហាសុខ

ដើម្បីបានសេចក្តីសុខ គឺលះបង់តណ្ហា កំចាត់អវិជ្ជា មិនប្រមាថធ្វេសប្រហែស តម្កល់ចិត្តក្នុងសីល សមាធិ បញ្ញា និងលះបង់អត្ត: (កុំប្រកាន់ថាខ្លួន ជារបស់ខ្លួន)

សម្បត្តិ ៣ប្រការ

- សម្បត្តិមនុស្ស ឬមនុស្សសម្បត្តិ គឺសម្បត្តិដែលប្រសើរជាងសត្វតិរច្ឆាន ។
- សម្បត្តិសួគ៌ ឬសគ្គសម្បត្តិ គឺសម្បត្តិដែលកើតឡើងដោយចំណងនិស្ស័យនៃបុញ្ញកម្ម ។
- សម្បត្តិនិព្វាន ឬនិព្វានសម្បត្តិ គឺសម្បត្តិខ្ពស់បំផុតឥតមានភ័យណាមួយក្នុងលោកចូលមកបៀតបៀនបានឡើយ ។

លំហាត់

ចូរអ្នករៀបរាប់ឡើងវិញ ប្រាប់មិត្តភក្តិរបស់អ្នកស្តីអំពីធម្មទេសនារបស់ព្រះសង្ឃនៅក្នុងពិធីណាមួយដែលអ្នកបានស្តាប់ ដែលមានខ្លឹមសារទាក់ទងនឹងបញ្ហាសំខាន់ៗក្នុងព្រះពុទ្ធសាសនាខាងលើ ។

នៅពេលអ្នករៀបរាប់នេះ អ្នកគប្បីបង្ហាញអំពី ៖

- ពេលវេលា ទីកន្លែង ប្រភព ... នៃព្រះធម្មទេសនា ឬពុទ្ធឱវាទផ្សេងៗទៀត
- ខ្លឹមសារនៃធម្មទេសនាឬពុទ្ធឱវាទ
- ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ។



សំណេរបំពេញលិខិតផ្សេងៗ

អ្នកធ្លាប់បានរៀនសរសេរបំពេញលិខិតផ្សេងៗច្រើនមកហើយ។ ពេលនេះ ចូរអ្នកបំពេញលិខិតខាងក្រោមនេះ ៖

១ . លិខិតបញ្ជាក់ទីលំនៅ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខណ្ឌ .....

សង្កាត់ .....

លេខ .....

លិខិតបញ្ជាក់ទីលំនៅ

យើងចៅសង្កាត់ / ឃុំ .....

បានបញ្ជាក់ថា ឈ្មោះ ..... សញ្ជាតិ ..... អាយុ ..... ភេទ .....
របររកស៊ី ..... សព្វថ្ងៃរស់នៅក្នុងភូមិ ..... ឃុំ / សង្កាត់ .....
ស្រុក / ខណ្ឌ ..... ខេត្ត / ក្រុង ..... ពិតប្រាកដមែន។

យើងចេញលិខិតបញ្ជាក់នេះ ឱ្យសាមីជនសម្រាប់យកទៅប្រើប្រាស់ក្នុងករណីដែលច្បាប់អនុញ្ញាត។

..... ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

ចៅសង្កាត់-មេឃុំ

ហត្ថលេខា ត្រា និងឈ្មោះ

២ . ពាក្យសុំប្រកបមុខរបរអាជីវកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំប្រកបមុខរបរអាជីវកម្ម

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ..... សញ្ជាតិ ..... អាយុ ..... ភេទ .....
កើតថ្ងៃទី ..... ខែ ..... ឆ្នាំ ..... ទីលំនៅផ្ទះលេខ ..... ផ្លូវលេខ ..... ក្រុមទី .....
ឃុំ/សង្កាត់ ..... ស្រុក/ខណ្ឌ ..... ខេត្ត/ក្រុង ..... ។

សូមគោរពជូន

លោកអភិបាល .....

កម្មវត្ថុ : សំណើសុំប្រកបមុខរបរអាជីវកម្ម .....

ដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមលោក .....
មេត្តាពិនិត្យនិងអនុញ្ញាតច្បាប់ប្រកបរបរអាជីវកម្ម ..... ដល់ខ្ញុំបាទ-នាងខ្ញុំដែល
មានទីតាំងអាជីវកម្មនៅដីឡូត៍លេខ ..... ទីលំនៅផ្ទះលេខ ..... ផ្លូវលេខ .....
ក្រុមទី ..... ឃុំ/សង្កាត់ ..... ស្រុក/ខណ្ឌ ..... ខេត្ត/ក្រុង .....ដោយអនុគ្រោះ ។

សូមលោកទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ ។

..... ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

ហត្ថលេខា និងឈ្មោះ

សូមភ្ជាប់ជាមួយនូវ :

-រូបថត ៤ x ៦ ២សន្លឹក

-ប្រវត្តិរូបសង្ខេបចិទរូបថត ១សន្លឹក

-ប័ណ្ណសម្គាល់គ្រួសារឬអត្តសញ្ញាណប័ណ្ណ ១សន្លឹក

-កិច្ចសន្យា ១សន្លឹក

៣ . ពាក្យសុំបើកទីតាំងអាជីវកម្ម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យសុំបើកទីតាំងអាជីវកម្ម

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ..... សញ្ជាតិ ..... អាយុ ..... ភេទ .....
កើតថ្ងៃទី ..... ខែ ..... ឆ្នាំ ..... ទីលំនៅផ្ទះលេខ ..... ផ្លូវលេខ ..... ក្រុមទី .....
ឃុំ/សង្កាត់ ..... ស្រុក/ខណ្ឌ ..... ខេត្ត/ក្រុង ..... ។

សូមគោរពជូន

.....

តាមរយៈ - លោកប្រធានគណៈកម្មការផ្សារ

- .....

កម្មវត្ថុ : សំណើសុំបើកទីតាំងអាជីវកម្ម .....

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើនេះ ខ្ញុំបាទ-នាងខ្ញុំមានកិត្តិយសសូមជម្រាបជូន ..... ឱ្យបានជ្រាបថា ខ្ញុំបាទ-នាងខ្ញុំទើបតែចេញលក់ពុំទាន់មានច្បាប់អនុញ្ញាតពីរដ្ឋអំណាចមានសមត្ថកិច្ចនៅឡើយ។ ខ្ញុំបាទ-នាងខ្ញុំសុំអនុញ្ញាតបញ្ជាក់នូវទីតាំងតូបលេខ ..... ។

អាស្រ័យហេតុនេះ ដើម្បីសម្រួលក្នុងការសុំច្បាប់ធ្វើអាជីវកម្មថ្មីពីក្រសួងពាណិជ្ជកម្ម ខ្ញុំបាទ-នាងខ្ញុំសូម ..... មេត្តាពិនិត្យនិងសម្រេចជួយផ្តល់នូវលិខិតបញ្ជាក់លើទីតាំងអាជីវកម្មដល់ខ្ញុំបាទ-នាងខ្ញុំដោយអនុគ្រោះ។

សូមលោកទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។


..... ថ្ងៃទី ..... ខែ ..... ឆ្នាំ .....

ហត្ថលេខានិងស្នាមមេដៃ

លេខ .....ប.ជ
បានឃើញនិងបញ្ជូនមក
.....
មេត្តាពិនិត្យនិងសម្រេចដោយអនុគ្រោះ។
.....ថ្ងៃទី .....ខែ .....ឆ្នាំ .....
.....

លេខ .....ប.ជ
បានឃើញនិងបញ្ជូនមក
លោក .....
មេត្តាពិនិត្យនិងសម្រេចដោយអនុគ្រោះ។
ភ្នំពេញ ថ្ងៃទី .....ខែ .....ឆ្នាំ .....
ប្រធានគណៈកម្មការផ្សារ .....

សិល្បៈ



សិល្បៈជាមែកធាងមួយរបស់វប្បធម៌ ។ សិល្បៈក៏ជាអត្តសញ្ញាណជាតិមួយក្នុងចំណោមអត្តសញ្ញាណជាតិជាច្រើនទៀត ។ សិល្បៈមានន័យទូលំទូលាយណាស់ ។ តាមន័យមួយសិល្បៈសំដៅយកការងារផ្សេងៗផ្នែកជំនាងហត្ថកម្មគ្រប់បែបយ៉ាងប្រកបទៅដោយសិល្ប៍ ដែលអាចខាបអន្ទង ធ្វើឱ្យជក់ចិត្ត ជក់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្តាប់ ។ សិល្បៈមានច្រើនប្រភេទណាស់ទាំងបុរាណនិងសម័យដូចជា· ភ្លេង ចម្រៀង របាំ ល្ខោន ភាពយន្តខ្នាតធំ វីដេអូ សំណង់ស្ថាបត្យកម្ម គំនូរ ចម្លាក់ សួនរូប ។ល ។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាប្រភេទសិល្បៈរបស់ខ្មែរយើងមួយចំនួន ខ្លឹមសារសំខាន់ៗនិងលក្ខណៈពិសេសខ្លះៗរបស់សិល្បៈខ្មែរ ។ ទន្ទឹមនឹងនេះ អ្នកនឹងសិក្សាបន្ថែមទៀតអំពីអត្ថបទអក្សរសិល្ប៍ទំនើប គឺរឿងព្រះអាទិត្យថ្មីរះលើផែនដីថាស់ ដោយបង្ហាញពីអត្ថរូប អត្ថន័យ អត្ថរស និងការតាក់តែងរឿងប្រលោមលោកខ្នាតខ្លីដែលមានលក្ខណៈរៀបរយល្អ ។



អត្ថរស

ស្នាដៃអក្សរសិល្ប៍ដែលល្អ គឺអាស្រ័យលើគោលធំៗបី គឺអត្ថន័យ អត្ថរូប និងអត្ថរស។ យើងអាចចែកអត្ថរសនៅអត្ថបទអក្សរសិល្ប៍ជាបី គឺបច្ចេករស វិសេសរស និងសព្វរស។

ក. បច្ចេករស

ជាតម្លៃដែលអ្នកនិពន្ធបានបង្កើតឡើង ពិសេសសម្រាប់តាក់តែងនិពន្ធរឿងរ៉ាវផ្សេងៗក្នុងអក្សរសិល្ប៍។ គេអាចឱ្យឈ្មោះតម្លៃសិល្បៈកែច្នៃនូវអត្ថបទផ្សេងៗគ្នានៃអក្សរសិល្ប៍នោះថា បច្ចេករស បច្ចេកសិល្បារម្មណ៍រសដែលមាន ៖

កាព្យរស : តម្លៃដែលកវីបានរចនាអត្ថបទជាពាក្យកាព្យឱ្យមានសម្ផស្សស្អាតសំឡេងចួនរណ្តំណែងណង ក្នុងការពិពណ៌នារៀបរាប់អ្វីមួយធ្វើឱ្យអ្នកអាន អ្នកស្តាប់រំភើបតាមដំណើររឿងដែរ។ ដូចជាកំណាព្យរៀបរាប់ពីអរុណោទ័យអស្តង្គតកាលនៃព្រះអាទិត្យ រៀបរាប់ពីធម្មជាតិព្រៃព្រឹក្សា ទេសភាពម្រីគីម្រីគា ដោយប្រើពាក្យពេចន៍ចួនរណ្តំពីរោះដល់ត្រចៀក រំភើបដល់ចិត្តទៀតផង។

ប្រលោមរស : តម្លៃដែលអ្នកនិពន្ធបង្កើតជាដំណើររឿងក្តី ជាសកម្មភាពតួអង្គក្តីធ្វើឱ្យមានភាពអណ្តែតអណ្តូង ស្នេហាក្រោមពន្លឺព្រះចន្ទ កំសត់លើផ្ទុកខ្សាច់ លើកោះ លើវាលស្មៅ។ល។ ដូចជារឿងផ្កាស្រពោន និយាយពីដំណើរតាមរថភ្លើងរបស់ប៊ុនធឿនទៅស្រុកកំណើតទាំងកណ្តោចកណ្តែងក្នុងចំណោមមិត្តភក្តិទាំងឡាយ ដែលសប្បាយរីករាយ ព្រោះតែនឹកសង្សារ ផ្ទះសម្បែង និង ឪពុកម្តាយ។ លក្ខណៈនេះធ្វើឱ្យអ្នកអានរំភើប កើតនូវការកំសត់ សប្បាយ ព្រួយជាមួយតួអង្គក្នុងរឿងដែរ។

នាដករស : តម្លៃដែលអ្នកនិពន្ធប្រើនៅក្នុងការសរសេររឿងល្ខោន ដោយមានការរៀបរាប់ដំណើររឿងក្នុងអត្ថបទល្ខោនឱ្យមានលក្ខណៈឯកភាព ទាំងក្នុងសកម្មភាព ទីកន្លែង និងពេលវេលា។

ខ. វិសេសរស

ជាតម្លៃដែលអ្នកនិពន្ធបានបង្កើតឡើងពិសេសៗ នៅក្នុងការតាក់តែងនិពន្ធល្ខោន កំណាព្យ រឿងព្រេង រឿងល្បើក ឬអត្ថបទផ្សេងៗក្តី។ វិសេសរសមានច្រើនប្រភេទដូចជា ៖

សុន្ទរីរស (តម្លៃល្អ) : តម្លៃមួយល្អដែលធ្វើឱ្យអ្នកអាន អ្នកទស្សនាឱ្យទៅលើរឿងដែលខ្លួនពេញចិត្ត ទោះបីរឿងអាក្រក់ក៏ដោយ។ ល្អម្យ៉ាងទៀត គឺល្អដោយសារអ្នកនិពន្ធបង្ហាញលក្ខណៈតួអង្គត្រឹមត្រូវ តាមការពិត សេចក្តីពិត ឬរូបលក្ខណៈពិត។ ល្អម្យ៉ាងទៀត ដោយសារអ្នកនិពន្ធចេះពណ៌នារូបភាព លក្ខណៈសកម្មភាពរបស់តួអង្គ ដំណើររឿងធម្មជាតិ ទេសភាពច្បាស់លាស់នៅក្នុងរឿងនីមួយៗ។ ដូចជារឿងកាកី អ្នកនិពន្ធបង្ហាញថាល្អទាំងរូប ល្អទាំងកាយ ពាក្យសំដី ឃ្លារៀបរាប់ អំពីសម្រស់របស់នាងកាកី។

វិហាសរូបរស (តម្លៃអាក្រក់) : តម្លៃដែលអ្នកនិពន្ធបង្ហាញទៅលើលក្ខណៈអាក្រក់របស់តួអង្គ ក្តី លក្ខណៈសកម្មភាពក្តី តាមរយៈការពណ៌នានេះធ្វើឱ្យមានភាពប្រត្យក្សអំពីរឿងរបស់តួអង្គ ដើម្បីបង្កើតនូវសោភ័ណភាពនៃរឿង។ ដូចជារឿងរាមកេរ្តិ៍ វិហាសរូបរស ត្រង់កន្លែងដែលអ្នកនិពន្ធបង្ហាញនូវរូបលក្ខណៈរបស់តួអង្គ កូខ័នជាថ្មើរព្រៃមានរូបរាងអាក្រក់ តែមានទឹកចិត្តល្អបរិសុទ្ធ ស្គាល់គុណទោស។ រីឯការពណ៌នាពីតាជូជក់នៅក្នុងរឿងព្រះវេស្សន្តរ គឺអាក្រក់ទាំងរូប សម្បុរ ទាំងកាយ និងចិត្ត។

វិសិដ្ឋរស : តម្លៃដែលស្តែងឡើងដោយអ្នកនិពន្ធបង្ហាញនូវសកម្មភាពអស្ចារ្យរបស់តួអង្គក្នុងការធ្វើពលិកម្មអ្វីមួយ ដែលសកម្មភាពខ្លះជាការលះបង់ខ្ពស់រហូតដល់មនុស្សធម្មតាធ្វើពុំដូចទៀតផង។ ដូចជាតួអង្គព្រះពោធិសត្វក្នុងរឿងព្រះវេស្សន្តរជាតក តួអង្គព្រះវេស្សន្តរដាក់ទានតាំងពីទ្រព្យសម្បត្តិរហូតដល់ប្រពន្ធកូននិងខ្លួនឯងថែមទៀតផង។

វីររស : តម្លៃដែលអ្នកនិពន្ធបង្ហាញនូវលក្ខណៈអាកប្បកិរិយា ចិត្តគ្លាហានមោះមុតរបស់តួអង្គក្នុងការប្រយុទ្ធដោយកាយ វាចា ចិត្ត ឬក្នុងអំពើណាមួយ ដើម្បីទប់ទល់តាំងនឹងអំពើអ្វីមួយដែលមានលក្ខណៈមិនល្អ។ ដូចជាក្នុងរឿងកុលាបប៉ៃលិន ថៅចិត្រមានសេចក្តីក្លាហានចេញមុខប្រយុទ្ធតតាំងជាមួយក្រុមចោរ ដែលស្នាក់ប្លន់ដំណើរក្រុមគ្រួសារលោកហ្លួងរតនសម្បត្តិ។ រឿងរាមកេរ្តិ៍ ហនុមានតតាំងនឹងទ័ពយក្សក្នុងសង្គ្រាមដណ្តើមនាងសីតា។

ទារុណរស : តម្លៃដែលអ្នកនិពន្ធរៀបរៀងរឿងឡើងធ្វើឱ្យឃើញនូវសកម្មភាពប្រយុទ្ធ ការព្យាបាទសងសឹក ជិះជាន់រំលោភ ធ្វើទុក្ខទោសទណ្ឌកម្មយ៉ាងឃោរឃៅអស្ចារ្យរហូតដល់បាត់បង់ជីវិត តួអង្គទន់ខ្សោយ ដែលគ្មានសមត្ថភាព។ ដូចជាប្រជាជនភូមិក្រាំងលាវ ក្រោយពីបានបង្កើតចលនាតស៊ូសម្លាប់បារាំងឈ្មោះ បាដេសរួចមក ប្រជាជនក្នុងភូមិទាំងមូលត្រូវអាណានិគមបារាំងដាក់ទណ្ឌកម្មសងសឹកវិញយ៉ាងធ្ងន់ធ្ងរ។

នាដ្យរស : តម្លៃដែលចេញមកពីការកំសត់នៅក្នុងរឿងវិបត្តិទំនាស់ ប្រឆាំងរវាងតួអង្គបដិបក្ខដ៏មានកម្លាំង សមត្ថភាព មធ្យោបាយគ្រឿងការពារប៉ុនគ្នា ស្មើគ្នា។ ដូចជាសង្គ្រាមរវាងព្រះរាមនិងក្រុងរាពណ៍ក្នុងរឿងរាមកេរ្តិ៍បានបន្សល់ទុកនូវការបែកបាក់ព្រាត់ប្រាសបងប្អូន សាច់ញាតិ ក្រុមគ្រួសាររបស់ជាតិយក្សក៏ដូចជា ពួកស្វាសុទ្ធតែទទួលរងនូវសោកនាដ្យកម្ម។

ហាសរស : តម្លៃដែលកើតឡើងមកពីលក្ខណៈសកម្មភាព ឬចលនានៃរឿងក្តី នៃតួអង្គក្តីក្នុងការបង្កើតភាពកំប្លែង ធ្វើឱ្យអ្នកអាន អ្នកស្តាប់សប្បាយរីករាយសើចអបអរសាទរ ជ្រះថ្លា ថ្លាចិត្ត។ ដូចជារឿងធនញ្ជ័យ ត្រង់សកម្មភាពរបស់ធនញ្ជ័យរើសអាចម៍សេះដាក់ក្នុងថង់យាមជូនសេដ្ឋីហួបធនញ្ជ័យជិះសេះចត្រង្គ ជិះដីរីដោលនឹងថ្នោលបើកក្តោងតាមស្តេច។

សោភណរស (ល្អ) : តម្លៃដែលធ្វើឱ្យស្នាដៃអក្សរសិល្ប៍មានលក្ខណៈប្រសើរ គឺល្អក្នុងផ្នែកអត្ថន័យ ប៉ិនចោទ ប៉ិនស្រាយ។ ល្អក្នុងផ្នែកអត្ថរូប គឺអត្ថបទមានភាពទាក់ទាញអារម្មណ៍អ្នកអានឱ្យចូលចិត្ត ពីរោះស្តាប់និយាយខ្លីងាយយល់។

ទស្សនីយរស : តម្លៃដែលកើតឡើងតាមរយៈការរៀបរាប់ទេសភាព ធម្មជាតិ ព្រៃព្រឹក្សា មច្ឆា បក្សាបក្សីប្រកបដោយសូរស័ព្ទសំឡេងពីរោះរណ្តំគ្នានៃស្រៈនិងព្យញ្ជនៈបង្កើតជាបរិយាកាសមួយ។

ឧទាហរណ៍ : ក្នុងរឿងទុំទាវ ការរៀបរាប់ទេសភាពធម្មជាតិតាមដងទន្លេមេគង្គពីក្រុងលង្វែកមកស្រុកត្បូងឃ្មុំក្នុងពេលដែលព្រះរាមាទ្រង់យាងមកជំនុំជំរះក្តីអរជួននិងក្រុមបក្សពួក។

គ. សព្ទរស

ជាតម្លៃទូទៅនៃរឿងដែលកវីនិពន្ធតែងលើកយកមកប្រើក្នុងអត្ថបទឬស្នាដៃរបស់ខ្លួនតម្លៃមាន :

តថរស : តម្លៃដែលអ្នកនិពន្ធយកតួអង្គជាក់ស្តែងមានមនុស្សគ្រប់វ័យនិងយកបញ្ហាជីវភាពប្រចាំថ្ងៃរបស់មនុស្សមានដូចជា ទំនាស់វិបត្តិផ្សេងៗទាក់ទងនឹងការគ្រប់គ្រងសង្គម ជំនឿ ប្រពៃណី សាសនាមកធ្វើការតាក់តែងនិពន្ធឱ្យឃើញជាក់ច្បាស់នឹងភ្នែក ងាយយល់ ងាយស្តាប់ ងាយចាប់សេចក្តីបាន។ ដូចជារឿងទុំទាវ បានបង្ហាញយ៉ាងជាក់ច្បាស់អំពីតថភាពសង្គមខ្មែរសម័យលង្វែកដែលពេលនោះប្រជាជនខ្មែរប្រកាន់ខ្ជាប់នូវប្រពៃណី "នំមិនធំជាងនាឡិ" ក្នុងការទុកដាក់កូនចៅឱ្យមានគូស្រករ។

អច្ឆរិយរស : តម្លៃស្តែងចេញតាមរយៈការលើកឡើងរបស់អ្នកនិពន្ធក្នុងការយកតួអង្គអរូបី ឬតួអង្គសត្វចេះនិយាយ តួអង្គទេវៈ ឬសកម្មភាពអស្ចារ្យ ចេះហោះហើរ ដើរលើអាកាសប្រែកាលបែងភាគ ។ល។ លក្ខណៈអស្ចារ្យទាំងនេះជាតម្លៃអច្ឆរិយ។

កុសលរស : តម្លៃដែលស្ថិតនៅលើការអប់រំទូន្មានប្រៀនប្រដៅ (ពិសេសកុសលនៅក្នុងរឿងផ្នែកមនោគតិនិយម) នៅក្នុងកម្ពុជច្បាប់ផ្សេងៗហៅថា ច្បាប់ឧបទេសដែលកុសលរសមាននៅក្នុងពាក្យសុភាសិត ពាក្យទំនីមទំនៀម ពាក្យទូន្មាន ពុទ្ធសុភាសិតនៅក្នុងរឿងព្រេងរឿងល្បើក ដែលស្តែងឡើងតាមរយៈអត្ថន័យរបស់អត្ថបទ ឬសកម្មភាពរបស់តួអង្គជាដើម។

> ***រស មានន័យថាតម្លៃមានដូចជា ល្អ អាក្រក់ ពីរោះ មិនពីរោះជាដើម។ ដូច្នេះ អត្ថរស គឺជាតម្លៃរបស់អត្ថបទអក្សរសិល្ប៍ដូចជា តម្លៃល្អ អាក្រក់ ពីរោះ មិនពីរោះរបស់ស្នាដៃអក្សរសិល្ប៍នីមួយៗ។***

លំហាត់

ចូរបង្ហាញពីអត្ថរសនីមួយៗនៅក្នុងរឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់ដោយលើកឧទាហរណ៍មកបញ្ជាក់។



ចលនាអក្សរសិល្ប៍

អក្សរសិល្ប៍ខ្មែរយើង មានដើមកំណើតតាំងពីយូរយាណាស់មកហើយ ហើយវាបានវិវត្តន៍ឥតឈប់ឈរពីសម័យកាលមួយទៅសម័យកាលមួយ។ ស្នាដៃអក្សរសិល្ប៍ទាំងនោះ តែងផ្តោតទៅតាមគំនិតទស្សនៈការនិយមរបស់ក្រុមមនុស្សផ្សេងៗគ្នា។ ដូច្នេះហើយទើបគេចែកស្នាដៃអក្សរសិល្ប៍ទាំងនោះជាចលនាផ្សេងៗ ដើម្បីងាយស្រួលកត់សម្គាល់។

១ . ចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម

ស្នាដៃអក្សរសិល្ប៍ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងបែបបទលិទ្ធិសាសនាព្រាហ្មណ៍។ អក្សរសិល្ប៍បែបនេះគេតែងជឿលើអាទិទេពបីអង្គ គឺព្រះព្រហ្ម ព្រះឥសូរ និងព្រះវិស្ណុ ឬព្រះនារាយណ៍។ ជួនកាលគេគោរពអាទិទេពទាំងបីចម្រុះគ្នាមានឈ្មោះ ត្រៃម៉ូតិ។ ជួនកាលគេគោរពដោយមានការបង្រួបបង្រួមគ្នារវាងអាទិទេពពីរ គឺព្រះវិស្ណុនិងព្រះឥសូរ រួមបញ្ចូលគ្នាឱ្យឈ្មោះថា ហរិហរ៍។ ម៉្យាងទៀត គេជឿលើពុទ្ធិទាំងឡាយស្ថិតក្នុងគម្ពីរវេទ ហើយតួអង្គសំខាន់ៗជាតួអង្គអាទិទេព ឬអវតារជាដើម។

ក. ផ្តើមរឿង

ការផ្តើមរឿងនៃស្នាដៃអក្សរសិល្ប៍ប្រភេទនេះ គឺចាប់ផ្តើមឡើងដោយការបង្ហាញឈ្មោះរបស់អាទិទេពធំទាំងបីដូចជា ព្រះព្រហ្ម ព្រះវិស្ណុ ព្រះឥសូរ។

ខ. តួអង្គ

- តួអង្គ : ជាអាទិទេព ឬអវតារនៃព្រះវិស្ណុមកយកកំណើតជាមនុស្សបុរសអស្ចារ្យនិងនារីអស្ចារ្យ ឯតួអង្គផ្សេងទៀតមានឥសី ទេវតា យក្ស គ្រុឌ ...។
- ដំណើររឿង : ច្បាំងមិនចេះចប់ ប្រកបដោយសិល្ប៍សាស្ត្រអស្ចារ្យ។
- ទីកន្លែង : ព្រៃហោមពាន្ត ស្ថានសួគ៌ ស្ថានសិម្ពលី ...។
- បញ្ហាចោទ : ដោយមានទំនាស់វិបត្តិរវាងសភាវៈល្អនិងសភាវៈអាក្រក់។
- ដំណោះស្រាយ : ដោយសិល្ប៍មន្ត ឫទ្ធិអំណាច សង្គ្រាម ធ្វើចម្បាំងនឹងគ្នា ដោះស្រាយដោយយុទ្ធវិធី។
- ស្នេហា : មកពីឥទ្ធិពលអាទិទេព ហើយអ្នកឈ្នះ គឺបានទទួលស្នេហា។
- កំសត់ : កើតឡើងដោយវិបត្តិទំនាស់រវាងសភាវៈល្អនិងអាក្រក់ច្បាំងទាស់ទែងគ្នា មានទារុណកម្មខាងផ្លូវចិត្តនិងផ្លូវកាយ។

- ឧត្តមគតិរឿង : អប់រំមនុស្សឱ្យជឿលើអាទិទេពនិងមានជំនឿថា ទុក្ខសោក ល្អ អាក្រក់ របស់ខ្លួនបានមកពីអាទិទេពទាំងនេះធ្វើឱ្យមនុស្សខ្វះការជឿជាក់លើខ្លួនឯង ។

គ. បញ្ចប់រឿង

ការបញ្ចប់រឿងបែបព្រាហ្មណ៍និយម គឺតួអង្គតំណាងអាទិទេព (សភាវៈល្អ) មានជ័យជំនះលើសភាវៈអាក្រក់ យក្ស គ្រុឌ អសុរៈ ... ។

២ . ចលនាអក្សរសិល្ប៍ពុទ្ធនិយម

អត្ថបទរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងការលើកយកទ្រឹស្តីពុទ្ធសាសនាធ្វើជាគោល ហើយទ្រឹស្តីតាំងនោះស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិតក ដែលអ្នកនិពន្ធលើកយកបញ្ហាបុណ្យ បាប ផលល្អ ផលអាក្រក់របស់តួអង្គមកចោទនិងដោះស្រាយ។ អក្សរសិល្ប៍បែបពុទ្ធនិយមនេះមានអក្សរសិល្ប៍ ពុទ្ធនិយមសុទ្ធសាធ ពុទ្ធិនិយមក្លាយ និងពុទ្ធនិយមក្លាយហួសហេតុ ។

ក. ផ្តើមរឿង

ផ្តើមរឿងឡើងដោយបទនមស្កាមានតំណាលថា ព្រះពុទ្ធគង់ក្នុងអារាមណាមួយទ្រង់សំដែងឡើងនូវរឿងអតីតជាតិរបស់ព្រះអង្គទៅកាន់ពុទ្ធបរិស័ទ ។

ខ. តួរឿង

- តួអង្គ : តួអង្គប្រុសជាព្រះពោធិសត្វ ឯតួអង្គស្រីជាកន្សែសារពេជ្ជ ។ តួអង្គមានមនុស្ស ទេវៈ អសុរៈ ... ។
- ទីកន្លែង : ដំណើររឿងប្រព្រឹត្តិទៅនៅនគរពារាណសី តក្កសិលា ព្រៃហេមពាន្ត ... ។
- បញ្ហាចោទ : ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស ទំនៀមទម្លាប់ កម្មពៀរ ... ។
- ដំណោះស្រាយ : ព្យាយាមតស៊ូប្រឹងប្រែងដោយយកសីលធម៌ទៅអប់រំដោយសន្តិវិធី ខន្តី មិនប្រើហិង្សា ដើម្បីដោះស្រាយបញ្ហាជានិច្ច ។
- ស្នេហា : គឺស្នេហារវាងព្រះពោធិសត្វនិងកន្សែសារពេជ្ជជាស្នេហាបរិសុទ្ធ ។
- កំសត់ : កើតឡើងដោយសារការព្រាត់ប្រាស ទំនៀមទម្លាប់ និងកម្មពៀរ ... ។
- ឧត្តមគតិរឿង : អប់រំមនុស្សឱ្យស្គាល់បុណ្យ បាប ខំប្រឹងតស៊ូ និងជឿជាក់លើខ្លួនឯង ។

គ. បញ្ចប់រឿង

ការបញ្ចប់រឿងដោយមានការសរជាតិរបស់តួអង្គព្រះពោធិសត្វនិងកន្សែសារពេជ្ជ ។

កំណត់សម្គាល់ : រឿងក្នុងជាតក គឺជារឿងរបស់ព្រះពុទ្ធអង្គ កាលកំពុងវិលអន្ទោលយកកំណើតក្នុងបុព្វជាតិ ដើម្បីត្រាស់ដឹង ដើម្បីស្រង់សត្វលោកដែលស្ថិតក្នុងវាលវដ្តសង្សារ។ អក្សរសិល្ប៍ពុទ្ធនិយមមាន ៖

រឿងពុទ្ធនិយមសុទ្ធសាធ : សំដៅលើរឿងទសជាតក ឬរឿងនានាជាតកដែលដំណើររឿងទាក់ទងនឹងទស្សនៈគោលសំខាន់ៗក្នុងព្រះពុទ្ធសាសនា ដោយអ្នកនិពន្ធលើកយករឿងបុណ្យ បាប កម្ម ផលល្អអាក្រក់របស់តួអង្គមកចោទនិងដោះស្រាយ។ រឿងទាំងឡាយត្រូវបានរៀបរៀងឡើងជាភាសាបាលី តែក្រោយមកមានសម្រាយជាខេមរភាសា មានសរសេរជាពាក្យកាព្យ។ ចំពោះអត្ថបទសរសេរជាពាក្យរាយគេច្រើនសរសេរឱ្យឈ្មោះថា រឿងជាតកឬគម្ពីរជាតក គម្ពីរទសជាតក គម្ពីរបញ្ញាសជាតក គម្ពីរនានាជាតកជាដើម។ រឿងក្នុងទសជាតកជារឿងដែលព្រះពោធិសត្វកសាងបារមីដូចជា ៖

១. រឿង តេមិយ	២. រឿង មហាជនក
៣. រឿង សុវណ្ណសាម	៤. រឿង នេមិរាជ
៥. រឿង មហោសថ	៦. រឿង ភូរិទត្ត
៧. រឿង ចន្ទកុមារ	៨. រឿង នារទៈ
៩. រឿង វិធុរ	១០. រឿង ព្រះវេស្សន្តរ

រឿងពុទ្ធនិយមក្លាយ : អត្ថបទអក្សរពុទ្ធនិយមក្លាយចែកជាពីរ ៖

- រឿងពុទ្ធនិយមក្លាយធម្មតា : ជាអត្ថបទដែលទាក់ទងនឹងទស្សនៈក្នុងព្រះពុទ្ធសាសនាតិចតួច ហើយរឿងទៀតសោតពុំស្ថិតក្នុងគម្ពីរត្រឹមត្រូវជាពុទ្ធវចនៈ (ក្នុងគម្ពីរព្រះត្រៃបិតក)ដូចជារឿងទសជាតកឡើយ។ អត្ថបទរឿងបែបពុទ្ធនិយមក្លាយច្រើនស្ថិតក្នុងគម្ពីរបញ្ញាសជាតក (៥០ជាតិ) មាន៥០រឿង។
- រឿងពុទ្ធនិយមក្លាយហួសហេតុ : ស្នាដៃប្រភេទនេះពុំមាននៅក្នុងគម្ពីរក្បួនខ្នាតពីបុរាណណាមួយឱ្យបានច្បាស់លាស់ទេ ប្រសិនបើមានបញ្ជាក់ក្បួនខ្នាតដើម គម្ពីរដើម គឺអ្នកនិពន្ធគ្រាន់តែថាប៉ុណ្ណោះ ពុំមានដំណើររឿងដូចគ្នាបេះបិទឡើយ។ ដំណើររឿងមានគោលគំនិតទាក់ទងនឹងពុទ្ធទស្សនៈតែបន្តិចបន្តួច ចំណែកឯតួអង្គនៃរឿងច្រើនមានសកម្មភាពប្រកបដោយគុណវិបត្តិហួសហេតុ រហូតដល់មនុស្សធម្មតាធ្វើមិនកើត ហើយរឿងពុំមានការកសាងបារមីអ្វីមួយច្បាស់លាស់ឡើយ តែទោះជាតួអង្គធ្វើអំពើខុសយ៉ាងណាក្តី លុះដល់ចប់រឿងមានការសជាតិ អ្នកនិពន្ធប្រារព្ធថា តួអង្គនោះជាព្រះពោធិសត្វ។ ***ឧទាហរណ៍ :*** រឿង កាកី។

៣ . ចលនាអក្សរសិល្ប៍ខេមរនិយម

ក. អត្ថន័យ

គោលបំណងសំខាន់បំផុតនៃអក្សរសិល្ប៍ខេមរនិយម គឺបង្ហាញបញ្ហាជីវភាពជាក់ស្តែងរបស់មនុស្សក្នុងសង្គមស្របទៅតាមវប្បធម៌ អរិយធម៌យើង។ ពិសេសខ្លឹមសារនៃស្នាដៃប្រភេទនេះ មានការទាក់ទងទៅនឹងសង្គមបរិយាកាសរបស់ខ្មែរ។ ដំណើររឿងកើតឡើងនៅក្នុងភូមិស្រុក ឬទីកន្លែងណាមួយដែលមានទំនាក់ទំនងទៅនឹងការប្រកបអាជីវកម្មរបស់ខ្មែរពិត "ច្រើនតែជារឿងតថ"។

មូលហេតុដែលនាំឱ្យមានទំនាស់វិបត្តិក្នុងអក្សរសិល្ប៍បែបខ្មែរនិយម គឺជាទំនាស់ដែលកើតមានក្នុងជីវភាពរស់នៅរបស់ជនសាមញ្ញ ដែលតែងតែប្រទះដូចជា ទំនាស់រវាងខ្លួនឯងនិងអ្នកដទៃ ទំនាស់រវាងខ្លួនឯងនិងគ្រួសារ ទំនាស់រវាងអ្នកដទៃនិងគ្រួសារខ្លួន ទំនាស់រវាងខ្លួនឯងនិងសង្គម។

ជាទូទៅដំណោះស្រាយបញ្ហានៅក្នុងអក្សរសិល្ប៍ខេមនិយម គឺតួអង្គពឹងលើសមត្ថភាពផ្ទាល់ខ្លួនជំនះលើផ្លូវកាយ ផ្លូវចិត្ត ដើម្បីផ្តាញ់ឧបសគ្គក្នុងសង្គមនិងធម្មជាតិ។ ជម្រៅនៃរឿង (រឿងព្រេង) មានបញ្ហាចោទចំពោះមនុស្សលោកបច្ចុប្បន្នដោយអប់រំឱ្យចិតខំត្រិះរិះដោះស្រាយបញ្ហាក្នុងសង្គមមនុស្ស។ គេយករឿងរបស់មនុស្ស គឺរឿងរបស់ខ្មែរគ្រប់បែបយ៉ាងមកចោទហើយដោះស្រាយតាមលក្ខណៈស្របទៅនឹងរឿងបច្ចុប្បន្ន រឿងពិតរបស់មនុស្ស។ ដូចជារឿង ពស់កេងកង មាយាស្ត្រី។

តួអង្គមនុស្សធម្មតា ចាប់ពីអ្នកបម្រើគេរហូតដល់វណ្ណៈអភិជន ក្រៅពីនេះមានតួអង្គដែលមានលក្ខណៈអច្ឆរិយៈដូចជា យក្ស ខ្មោច បិសាច អ្នកតា ទេវតា និងមានតួអង្គជាសត្វដូចជា ចចក ទន្សាយ ... ប៉ុន្តែតួអង្គទាំងនោះសុទ្ធតែតំណាងឱ្យមនុស្ស ឬជីវភាពរបស់សង្គមមនុស្ស។

ខ. អត្ថរូប

អត្ថបទអក្សរសិល្ប៍ខេមរនិយម ច្រើនតែអត្ថបទប្រលោមលោក ពាក្យកាព្យ រាយពាក្យជារឿង សម្រាប់អានកំសាន្តតែអផ្សុក តែមានគតិក្នុងការអប់រំទូន្មានប្រៀនប្រដៅផង។ អត្ថបទខ្លះ ត្រូវបានបោះពុម្ពជាសៀវភៅ។ រឿងទាំងនោះមានប្រើពាក្យសំដីរបស់ជនសាមញ្ញ ពាក្យអ្នកស្រុកជាន់កណ្តាលជាន់ទាប ពុំមានភាសាបាលីសំស្ក្រឹតច្រើនគួរឱ្យពិបាកអាននោះឡើយ។

- ផ្តើមរឿង : ការផ្តើមរឿងក្នុងស្នាដៃអក្សរសិល្ប៍បែបខេមរនិយមមិនមានការឯកភាពគ្នាទេ អាស្រ័យលើទេពកោសល្យរបស់អ្នកនិពន្ធម្នាក់ៗ។
- ដំណើររឿង : វណ្ណនារូប អ្នកនិពន្ធច្រើនតែនិទានខ្លួនឯង
- ការបញ្ចប់រឿង : គឺបង្ហាញពីឧត្តមគតិអប់រំទូន្មានដល់អ្នកអាន អ្នកសិក្សាតាមរយៈសុភាសិត។ ប៉ុន្តែចំពោះស្នាដៃប្រលោមលោកវិញ ការបញ្ចប់រឿងមានឈ្នះ មានចាញ់ទៅតាមការពិតជាក់ស្តែងនៃបញ្ហា ដែលអ្នកនិពន្ធឆ្លុះបញ្ចាំងជាទូទៅអំពើល្អឈ្នះអំពើអាក្រក់។

គ. អត្ថរស

តម្លៃរបស់អក្សរសិល្ប៍ខេមរនិយមស្តែងចេញពីការឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង ការអប់រំសីលធម៌ និងស្មារតីជាតិនិយមពិតៗ ។

យោបល់រួម : អក្សរសិល្ប៍បែបខេមរនិយម ជារឿងបែបមនុស្សលោកិយ ជារឿងរបស់ជាតិខ្មែរដែលយកសង្គមារម្មណ៍មកចោទនិងដោះស្រាយទៅតាមប្រយោជន៍នៃសង្គមជាតិក្នុងគោលបំណងណែនាំ ខេមរជនឱ្យស្រឡាញ់អំពើល្អ ស្អប់ និងចៀសវាងអំពើអាក្រក់ ។

ឧទាហរណ៍ : រឿង ផ្កាស្រពោន រឿង កុលាបម៉ែលិន ... ។

៥ . ចលនាអក្សរសិល្ប៍បរទេសនិយម

ចលនានេះ ពុំមាននៅក្នុងអក្សរសិល្ប៍បុរាណទេ ទើបតែសម័យដែលប្រទេសធ្លាក់ក្រោមឱវាទពួកបស្ចឹមប្រទេស (អាណានិគមបារាំង) អស់រយៈពេលមួយសតវត្ស ចលនានេះក៏កើតមានឡើង ។ ចលនានេះ មានឥទ្ធិពលខ្លាំងក្លាណាស់ក្នុងពេលបច្ចុប្បន្ន មានមនុស្សទូទៅក្នុងសកលលោក ច្រើនចូលចិត្តការនិយមបែបនេះ ។ សព្វថ្ងៃគេឃើញមាននៅសល់ការនិយមពាសពេញដូចជា សុជីវធម៌ សម្លៀកបំពាក់ សិល្បៈ ការរាំរែក ... ។

ចលនាអក្សរសិល្ប៍ គឺជាការប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមលើទស្សនៈ ទ្រឹស្តី គោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ។ តាមការសិក្សាគេចែកអក្សរសិល្ប៍ខ្មែរជា ៤ចលនា គឺចលនាអក្សរសិល្ប៍ព្រាហ្មណ៍និយម ចលនាអក្សរសិល្ប៍ពុទ្ធនិយម ចលនាអក្សរសិល្ប៍ខេមរនិយម និងចលនាអក្សរសិល្ប៍បរទេសនិយម ។


លំហាត់

១. តើគេចែកអក្សរសិល្ប៍ខ្មែរជាប៉ុន្មានចលនា ? ចលនាអ្វីខ្លះ ?

២. ដូចម្តេចហៅថា ចលនាព្រាហ្មណ៍និយម ពុទ្ធនិយម ខេមរនិយម និងបរទេសនិយម ?

៣. ចូរធ្វើចំណែកថ្នាក់រឿងទាំងនេះតាមចលនាអក្សរសិល្ប៍ ដោយផ្តល់អំណះអំណាងក្នុងរឿងនីមួយៗឱ្យបានសមស្រប ។ រឿងព្រះវេស្សន្តរ រាមកេរ្តិ៍ ព្រះអាទិត្យថ្មីរះលើផែនដីចាស់ តេជោយ៉ត ចៅកែចិត្តចោរ ទុំទាវ មាយើង ចៅស្រទបចេក សព្វសិទ្ធិ ក្រពើនិងអ្នកបរទេះ ចាបស្រុកនិងចាបព្រៃ អារក្សនិងអ្នកស្រែ ។

រឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់



ក. សិក្សាពាក្យគន្លឹះ

- ករណីយកិច្ច (ន) : កិច្ចការដែលត្រូវធ្វើ ។
- កូដកម្ម (កិ) : សម្តែងអាកប្បកិរិយាប្រឆាំងជំទាស់ ។
- ទិដ្ឋិមាន៖ (ន) : ការរឹងរូស ។
- ទុក្ករកិរិយាកម្ម (ន) : អំពើយ៉ាងកម្រ អំពើដែលព្រះពុទ្ធធ្វើ ដើម្បីសម្រេចពោធិញ្ញាណ ។
- នក្ខត្តឫក្ស (ន) : ពេលវេលាដែលហោរាគន់រក ដើម្បីឱ្យដឹងថាគ្រោះកាចឬគ្រោះជា ។
- នយោបាយទឹក (ន) : ការរៀបចំអភិវឌ្ឍន៍ប្រព័ន្ធទឹក ។
- យថាកម្ម (កិ) : តាមកម្ម តាមអំពើ ។
- សហជីវិន (ន) : អ្នកចូលរួមសមាគមជាមួយគ្នា ។
- ស្នូមយាចក (ន) : អ្នកដើរសុំទាន ។
- ហត្ថកម្ម (ន) : ការធ្វើដោយដៃ ។
- អាណានិគម (ន) : លទ្ធិនៃជនខ្លះដែលចូលចិត្តតែខាងជ្រៀតជ្រែក រាយដណ្តើមយកប្រទេសដទៃមកធ្វើជាស្រុកចំណុះរបស់ខ្លួន ។

- ឥស្សរយស (ន) : គ្រឿងតម្កើងយស មេដាយ ... ។
- ឥស្សរភាព (ន) : ភាពនៃអ្នកធំ។
- ឱសថាល័យ (ន) : មន្ទីរពេទ្យសាធារណៈ (ពេទ្យរដ្ឋ) កន្លែងផ្តល់ថ្នាំព្យាបាលជំងឺ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលសិក្សាអត្ថបទរឿង ព្រះអាទិត្យថ្មីរះលើផែនដីចាស់ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងចលនាអក្សរសិល្ប៍ អត្ថន័យ អត្ថរូប និងអត្ថរស ។

គ. សង្ខេបរឿង

សួនសមជាកូនរបស់ នាយសួនសុខនិងនាងសន រស់នៅឃុំបរវិល ស្រុកសង្កែ ខេត្តបាត់ដំបង ។ ឪពុកត្រូវបារាំងធ្វើទណ្ឌកម្មរហូតដល់ស្លាប់ ដោយចោទថាចូលដៃជាមួយឥស្សរៈ។ ម្តាយស្លាប់ដោយជំងឺ ។ សម ត្រូវពួកឥស្សរៈសង្ស័យថា ចូលដៃជាមួយបារាំងក៏បានធ្វើដំណើរមកភ្នំពេញ ហើយបានធ្វើជាកម្មករ ស្នាក់នៅវត្តមហាមន្ត្រីជាមួយភិក្ខុសៅ ។ សម ផ្លាស់ប្តូរកន្លែងធ្វើការជាញឹកញាប់ ព្រោះទ្រាំមិនបាននឹងពាក្យមើលងាយមើលថោក ។ ក្រោយមកសមមានប្រពន្ធឈ្មោះនាងសយ ។ សមបានទៅនៅផ្ទះជួលទាំងជីវភាពលំបាកលំបិន ។ សម ជាកម្មករត្រីចក្រយាន ។ ទាំងពីរនាក់ប្តីប្រពន្ធរស់នៅយ៉ាងកំសត់ ណាមួយប៉ូលីសជាកពិន័យ ណាមួយរកប្រាក់បង់ថ្លៃស៊ីភ្លូមិនគ្រប់ ធ្វើឱ្យម្ចាស់ស៊ីភ្លូរឹបអូសយកស៊ីភ្លូទៅវិញ ។ ក្នុងភាពទំនេរគ្មានការងារធ្វើ សមត្រូវជួបនឹងការលំបាកកាន់តែខ្លាំង ។ ឆ្លៀតពេលនេះសៅរកស៊ីដើរលួចឆក់បានបញ្ចុះបញ្ចូលសមឱ្យទៅជាមួយ តែសមបដិសេធ ។ ដោយខ្វះប្រាក់បង់ថ្លៃផ្ទះសមនិងប្រពន្ធត្រូវគាសានបណ្តេញចេញពីផ្ទះ ។ ទាំងពីរនាក់បានទៅនៅនឹងសំយាបព្រះវិហារលោកសង្ឃយួនទួលប្រសី ។ ក្រោយមកនាងសយបានទៅធ្វើជាអ្នកបម្រើនៅផ្ទះថៅកែហុក ។ សមនិងប្រពន្ធត្រូវរស់បែកគ្នា ។

ថៅកែហុក ជាមនុស្សខិលខូចនឹងស្រីញីណាស់ ។ ស្រីបម្រើនៅផ្ទះគាត់ ច្រើនធ្លាក់ខ្លួនជាចំណីនៃសេចក្តីសប្បាយស្ទើរតែទាំងអស់ ។ វាសនារបស់នាងសយក៏មិនខុសពីអ្នកទាំងនោះដែរ ត្រូវថៅកែហុករំលោភយ៉ាងព្រៃផ្សៃ ។ តាំងពីពេលនោះមក នាងសយក៏ចាកចេញពីផ្ទះថៅកែហុក ហើយបានទៅរស់នៅជាមួយនាយម៉ឺនិងនាងម៉ុម ដែលជាកម្មករត្រីចក្រយាននិងត្រូវជាមិត្តភ័ក្តិប្តីនាង ដើម្បីរង់ចាំប្តីត្រឡប់មកពីបាត់ដំបងវិញ ។ សម ត្រឡប់ពីបាត់ដំបងវិញដឹងរឿងនេះ មានការឈឺចាប់ជាខ្លាំងនិងមានបំណងសងសឹកស្លាមតែត្រូវ ម៉ឺឃាត់ ។ ដោយទប់កំហឹងមិនបាន សម បានទៅផ្ទះថៅកែហុកក្នុងបំណងសម្លាប់ថៅកែនោះ ដើម្បីសងសឹក ។ តែសមត្រូវចាញ់កលថៅកែហុកក៏ត្រូវបានប៉ូលិសចាប់

ដាក់គុក។ សមត្រូវជាប់គុកបីខែ។ នៅក្នុងគុក សមត្រូវអ្នកទោសនៅបន្ទប់ជាមួយនិងភ្នាក់ងារអនុរក្ស វាយធ្វើបាបស្ទើរស្លាប់ស្ទើររស់។ ពេលចេញពីគុក សមប្រកបរបរធាក់ស៊ីក្លូដូចពីមុន។ ចៃដន្យ ថ្ងៃមួយសមត្រូវរងគ្រោះថ្នាក់ចរាចរយ៉ាងធ្ងន់ធ្ងរ។ រថយន្ត ដែលបើកបុកសមនោះបានបើកគេចបាត់។ សមត្រូវសំរាកនៅមន្ទីរពេទ្យព្រះកេតុមាលាយ៉ាងយូរ។ ពេលបានជាសះស្បើយ សមសម្រេចចិត្តឈប់ធាក់ស៊ីក្លូ ហើយរកការងារថ្មីធ្វើវិញ។ សមបានទៅធ្វើការនៅរោងចក្រសាប៊ូ ដែលមានថៅកែជាជនជាតិចិន ដោយសមបានធ្វើជាកាបូរ៉ាល់។ មិនយូរប៉ុន្មានថ្ងៃមួយ នៅពេលរោងចក្រត្រូវប្តូរអ្នកចាត់ការថ្មី។ អ្នកចាត់ការថ្មីត្រូវការកាត់បន្ថយចំនួនកម្មករ ធ្វើឱ្យមានទំនាស់ជាមួយសម។ ដោយហេតុនេះ សមក៏លាឈប់ពីការងារ។ សមបានទៅធ្វើការនៅរោងចក្រឧស្សាហកម្មមួយទៀតក្នុងតំណែងជាកាបូរ៉ាល់ដដែល។ ទីបំផុតសមត្រូវបណ្តេញពីតំណែង ដោយសារសមបានកាន់ជើងកម្មករ។ បន្តពីនេះ សមបានទៅធ្វើកម្មករលីសែងនៅកំពង់ផែក្នុងតំណែងជាកាបូរ៉ាល់ទៀត ហើយត្រូវបណ្តេញចេញពីតំណែងដោយសាររឿងការពារកម្មករដដែល។ សមបានត្រឡប់ទៅប្រកបរបរធាក់ស៊ីក្លូវិញ។ ដោយស្តប់ខ្ពើមការជិះជាន់របស់នាយទុន សមបានបង្កើតសមាគមកម្មករឡើង។ ក្រោយមកមានអ្នកនយោបាយជ្រៀតចូល ដោយចំណាយប្រាក់កាសខ្លះៗ ដើម្បីទាក់ទាញពួកកម្មករឱ្យស្ថិតក្រោមការក្តោបក្តាប់របស់ពួកគេ ដើម្បីបានសន្លឹកឆ្នោត។

ក្រោយពេលជាប់ឆ្នោត អ្នកនយោបាយទាំងនោះមិនបានយកចិត្តទុកដាក់នឹងសមាគមរបស់សមទៀតឡើយ។ ក្រោយមកសមាគមនេះ ត្រូវរំលាយព្រោះគ្មានអ្នកឧបត្ថម្ភ។ សមបានទាំប្រពន្ធទៅជួលខ្មមនៅឆ្ងាយពីក្រុង ដោយប្រកបរបរជាកម្មករត្រីចក្រយានដដែល។ ពេលនេះសមមិនអាចធាក់ស៊ីក្លូពេញៗមួយថ្ងៃបានឡើយ ព្រោះបញ្ហាសុខភាព។ ប៉ុន្តែបន្ទុកក្នុងគ្រួសារកាន់តែធ្ងន់ធ្ងរ ព្រោះប្រពន្ធមានផ្ទៃពោះគ្រប់ខែ។ ថ្ងៃមួយពួកអ្នកលេងបានបន្ទំជិះស៊ីក្លូសមដោយឱ្យសមជីកទៅផ្លូវឆ្ងាយ រួចគំរាមទារប្រាក់ តែសមគ្មានប្រាក់មួយរៀលសោះ ពួកគេក៏គេចបាត់ទៅ។ ថ្ងៃប្រពន្ធឆ្លងទន្លេបានមកដល់ប្រពន្ធសមបានឈឺពោះខ្លាំងទាំងយប់ សមបានទៅអញ្ជើញគ្រូពេទ្យដ៏ល្បីល្បាញឈ្មោះ នរា តែត្រូវគ្រូពេទ្យនោះបដិសេធ ព្រោះសមមិនមានប្រាក់គ្រប់គ្រាន់។ នាងសយត្រូវស្លាប់នៅពេលឆ្លងទន្លេ ព្រោះគ្មានឆ្មបមានជំនាញត្រឹមត្រូវជួយ។ តាំងពីប្រពន្ធស្លាប់ទៅសមនៅតែលតោលឥតការងារធ្វើ ឯម៉ីក៏មានជំងឺនិងថែមទាំងឥតស៊ីក្លូធាក់ទៀតផង។ សមក៏បានទៅផ្ទះលោកយ៉ង តំណាងរាស្ត្រ ដែលសមធ្លាប់ជួយគាំទ្រដើម្បីរកជួលស៊ីក្លូ តែត្រូវលោកយ៉ងបដិសេធ ព្រោះសមគ្មានប្រាក់កក់។ សមចេះតែដើរអានាថាម្ចាក់ឯងរហូតត្រូវប៉ូលិសចាប់ឃុំអស់ពីរថ្ងៃ ព្រោះសង្ស័យថាជាអ្នកទោសរត់ចេញពីគុក។ ចេញពីប៉ុស្តិ៍ប៉ូលិស សមដើរដោយគ្មានគោលដៅ។ ដោយសេចក្តីស្រេកឃ្លាន សមដាច់ចិត្តទៅឆក់កាបូបគេ ដើម្បី

យកប្រាក់ទិញអាហារ ។ តែឃើញប្រាក់និងទ្រព្យច្រើនពេកសមបានយករបស់ទាំងនោះឱ្យម្ចាស់គេវិញ និងមានបំណងសុំការអត់ឱនទោសពីម្ចាស់ទ្រព្យ ។ តែរឿងនេះមិនដូចបំណងទេ សមត្រូវម្ចាស់ទ្រព្យប្តឹងដាក់គុក ៦ខែ ។

ចេញពីគុក សម ត្រាច់ចរករកការងារធ្វើចែជន្យពេលឆ្លងកាត់ផ្លូវ ត្រូវឡានលោករដ្ឋមន្ត្រីបុក ។ គ្រោះអាក្រក់ក្លាយជាលាភ លោករដ្ឋមន្ត្រីកំលោះនោះទើបតែមកពីស្រុកបារាំង ។ លោកជាមនុស្សមេត្តា ដោយបានឱ្យសមទៅធ្វើការមើលថែផ្ទះរបស់គាត់ ។ មិនយូរប៉ុន្មានសមបានផ្លាស់ប្តូរគំនិតដោយឈប់ធ្វើកម្មករ ត្រលប់មកធ្វើស្រែចំការវិញ ។ ដំបូងឡើយការធ្វើកសិកម្មមិនសូវបានផលល្អឡើយ ព្រោះធ្វើស្រែប្រវាស់មេឃ តែក្រោយមក ប្រទេសក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ព្រះបាទនរោត្តម សីហនុ ធ្វើឱ្យកសិករមានសង្ឃឹមដោយការធ្វើនយោបាយទឹក ។ថ្ងៃមួយ សមបានមកលេងភ្នំពេញ ។ សម ដើរមើលឃើញរាជធានីភ្នំពេញស្អែកជាខ្លាំងមាន អគារធំៗ សាលារៀន មន្ទីរពេទ្យ ហេដ្ឋារចនាសម្ព័ន្ធយ៉ាងល្អ នេះជាជោគជ័យនៃសង្គមរាស្ត្រនិយម ។ រង្គសាលដែលធ្លាប់មានជាច្រើននៅសម័យមុនត្រូវបិទទ្វារ ព្រោះរាជការរឹតបណ្តឹងមិនឱ្យមានមន្ត្រីខិលខូចប្រព្រឹត្តិអំពើទុច្ចរិតយកប្រាក់ទៅស៊ីចាយសប្បាយហ៊ីហា ហើយរាជការផ្តល់ប្រាក់ខែត្រឹមតែគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារប៉ុណ្ណោះ ហើយរាជការតែងរៀបចំធ្វើសមាជជាតិ ដែលមានប្រជារាស្ត្រចូលរួមយ៉ាងច្រើនទៀតផង ។

ឃ. អត្ថបទដកស្រង់

វគ្គ : ទីពឹងថ្មី

[...]សមបានត្រឡប់មកពីកន្លែងនោះវិញ ហើយចេះតែដើរអស់រសាត់អណ្តែតតទៅទៀត ក្នុងឋានៈជាកម្មកររកការងារធ្វើមិនបានម្នាក់ ។ ទីបំផុតការម្យ៉ាង ដែលជាការពិតនោះ គឺសមត្រូវបានចាប់ផ្តើមអត់អាហារទៀតផង ហើយសមមិនមែនអត់អាហារដើម្បីទុក្ករកិរិយាកម្ម កូដកម្ម ដើម្បីទាមទារសិទ្ធិសេរីភាពអ្វីឡើយ តែសមអត់ព្រោះគ្មានអាហារបរិភោគ ។ ដូចជាសាកសពដែលអាចកម្រើកខ្លួនបានសមចេះតែដើរអស់រសាត់អណ្តែតទៅដោយគ្មានគោលបំណង ឬទីដៅអ្វីឡើយ ... សមមានទឹកមុខខ្មៅជាំខុសធម្មតាមានប្រសីភ្នែក ដែលគ្មានរស្មីនៃសេចក្តីរីករាយ ហើយមានសម្លៀកបំពាក់និងខ្លួនប្រាណមិនខុសពីស្នួមយាចក ... តាំងពីថ្ងៃដល់រសៀល រហូតដល់ពេលល្ងាច សេចក្តីស្រេកឃ្លានបានធ្វើទុក្ខបុកម្នេញសមជាខ្លាំង ។ សមបានផឹកត្រឹមតែទឹកម៉ាស៊ីននៅតាមចិញ្ចើមថ្នល់ ដើម្បីផ្សើមបំពង់កប៉ុណ្ណោះ ។ សមដូចជាស្រយុតស្រយុងរោយស្រពន់អស់ទាំងរាងកាយ ។ ហើយក្នុងវេលាប្រហែលម៉ោង ១៧កន្លះ សមក៏បានជួបប្រទះនឹងឧប្បទ្វវហេតុ ដែលគួរឱ្យព្រឺខ្លួនក្នុងខណៈ ដែលបានឆ្លងកាត់វិថីដោយអារម្មណ៍អណ្តែតអណ្តូង ហើយមិនឃើញរថយន្តមួយ ដែលលូនចូលមកក្នុងរយៈដ៏ជិត អ្នក

លើកបរខំទប់ប្រាំងបញ្ឈប់ រថយន្តនោះក៏បុកកម្មករពោះម៉ាយ ដែលគួរឱ្យអាណិតនោះដួលដេក នៅលើវិថីនាកណ្តាលសំឡេងស្រែកភ្ជាត់មាត់ភ្ជាត់ករបស់ស្រីៗ ២-៣នាក់ ដែលបានឃើញហេតុការណ៍ដែលគួរឱ្យខ្លាចនោះ។ គ្រោះបែបនេះ រាប់ថាជាគ្រោះអាក្រក់សម្រាប់អ្នកមាន តែថាវាជាគ្រោះល្អសម្រាប់អ្នកក្រដូចរូបសម ព្រោះគ្រោះថ្នាក់នេះ ជាហេតុធ្វើឱ្យសមមានការងារធ្វើ។ សុភាពបុរសកំលោះម្នាក់ដែលអង្គុយលើរថយន្តខាងក្រោយនោះ ជារដ្ឋមន្ត្រីនៃក្រសួងមួយ ដែលលោកទើបនឹងត្រឡប់មកពីប្រទេសបារាំងកាលពីឆ្នាំទៅ ហើយលោកទើបនឹងជ្រើសតាំងជារដ្ឋមន្ត្រីកាលពីប៉ុន្មានខែមុននេះ។ ដោយសារការភ័យនឹកអាណិតអាសូរ លោករដ្ឋមន្ត្រីកំលោះនោះក៏បើកទ្វាររថយន្តចុះទៅមើលភ្លាម។ ខណៈនោះអ្នកបើកបររថយន្តស្ទុះចូលទៅត្រកងលើក សម ឡើង។ តែគ្រោះថ្នាក់នោះក៏មិនជាធ្ងន់ធ្ងរអ្វីប៉ុន្មានទេ គឺគ្រាន់តែបែកក្បាលជង្គង់និងត្រគៀកជើងខាងស្តាំប៉ុណ្ណោះ។ លោករដ្ឋមន្ត្រីជួយលើកសម ហើយពិនិត្យមើលដោយក្រសែភ្នែកដែលសម្តែងនូវសេចក្តីអាណិតអាសូរ។ លើកដាក់លើឡានទៅ លោករដ្ឋមន្ត្រីបង្គាប់អ្នកបើកបររថយន្ត នាំគាត់យកទៅពេទ្យ ហើយលោកក៏ឱនសួរសមដោយសេចក្តីមេត្តាថា "ម្តេចទៅបងត្រូវត្រង់ណាខ្លះ ?" មិនអីទេទានប្រោស! សមឆ្លើយឡើងតិចៗត្រូវបន្តិចបន្តួចប៉ុណ្ណោះ ហើយការនេះវាជាកំហុសរបស់ខ្ញុំបាទ ដែលដើរឆ្លងកាត់ផ្លូវដោយការធ្វេសប្រហែសពេកមិនងាកមើលឆ្វេងស្តាំជាមុន សុំព្រះគេជគុណមេត្តាជាក់ខ្ញុំទៅវិញចុះរបួសបន្តិចបន្តួចប៉ុណ្ណោះមិនបាច់ទៅពេទ្យទេទានប្រោស"។ បើអញ្ចឹងខ្ញុំនឹងជូនបងទៅដល់ផ្ទះ "លោករដ្ឋមន្ត្រីនិយាយឡើងទឹកមុខញញឹម" ចុះផ្ទះបងនៅដល់ណាទៅ ? ខ្ញុំគ្មានផ្ទះសម្បែងទេទានប្រោស សមឆ្លើយដោយទឹកមុខក្រៀមក្រំ តែខំសម្តែងនូវសេចក្តីគោរព "ខ្ញុំបាទជាមនុស្សកំព្រាអានាថា ជាកម្មករដែលគ្មានការងារធ្វើទេទានប្រោស"។ លោករដ្ឋមន្ត្រីក្មេងងក់ក្បាលទទួលស្តាប់ពាក្យសម្តីរបស់សម ដោយការអាណិតអាសូរ។ លោកពេញចិត្តចំពោះសុភាពរាបសារបស់សមជាខ្លាំង ថ្វីបើសមជាក្រមានសម្លៀកបំពាក់មិនសមរម្យក៏ដោយ តែសមក៏ឫកពានិងពាក្យសម្តីគួរឱ្យអាណិតដែរ។ បង! លោករដ្ឋមន្ត្រីនិយាយឡើងដោយពាក្យផ្អែមល្ហែម "អាណិតបងឯងណាស់ក្នុងការដែលបងត្រូវទទួលគ្រោះថ្នាក់ ដោយសារឡានរបស់ខ្ញុំនេះ ខ្ញុំសូមជូនបង ៥០០រៀល ជាសាហ៊ុយខូចខាត ហើយបងមានការអីសូមអញ្ជើញទៅរកខ្ញុំចុះ" ហើយលោករដ្ឋមន្ត្រីហុចប្រាក់ ព្រមទាំងនាមប័ណ្ណមួយសន្លឹកទៅឱ្យសម "សុំបងទៅរកខ្ញុំកុំខានណា"។ ពាក្យសំដីពោរពេញទៅដោយសេចក្តីមេត្តាករុណារបស់លោករដ្ឋមន្ត្រីនេះធ្វើឱ្យសមកោតសរសើរនឹងគោរពលោកជាខ្លាំង។ សមលើកដៃសំពះលោករដ្ឋមន្ត្រីដោយសេចក្តីគោរព ហើយនិយាយតិចថា "ព្រះគេជគុណមេត្តាខ្ញុំបាទ សុំព្រះគេជគុណកុំឱ្យប្រាក់ខ្ញុំបាទធ្វើអីទានប្រោស សុំព្រះគេជគុណជួយរកការងារឱ្យខ្ញុំបាទធ្វើវិញទៅល្អជាជាង ព្រោះខ្ញុំបាទកំពុងតែដើរស្វែងរកការងារធ្វើអីក៏បានដែរទានប្រោស ឱ្យតែការងារសុចរិតខ្ញុំធ្វើបានទាំងអស់ ដោយមិនរើសថាការធ្ងន់

ឬស្រាលឡើយ" ។ ខ្ញុំជាអ្នករាជការ មិនមែនជាអ្នកជំនួញទេ តែខ្ញុំពេញចិត្តនឹងជួយបងតាមសមត្ថភាព ខ្ញុំត្រូវនាំបងទៅពេទ្យសិន ហើយសឹមនាំបងឯងទៅផ្ទះខ្ញុំ បងឯងមិនរើសការងារមែនឬទេ ។ សម ខំប្រឹងញញឹមឡើងទាំងដែលមានរាងកាយកំពុងឈឺចាប់ ព្រោះការត្រេតអរលើសលន់ពន់ប្រមាណ ។ ខ្ញុំបាទមិនរើសទេទានប្រាសឱ្យតែឈ្មោះថា ការងារខ្ញុំបាទធ្វើបានទាំងអស់សុំឱ្យតែការងារនោះ ជាការងារសុចរិត ។ រថយន្តបានលូនចេញពីកន្លែងឧប្បទហេតុនោះសន្សឹមៗ ។ សមបានអង្គុយជិត លោករដ្ឋមន្ត្រីត្រង់បាំងខាងក្រោយ ។ លោករដ្ឋមន្ត្រីបានសម្លឹងពិនិត្យមើលសមដោយការគិតវែង ឆ្ងាយ ។ រថយន្តបានបើកសំដៅទៅឱសថាល័យព្រះអង្គឌួង ។ បង ! លោករដ្ឋមន្ត្រីនិយាយប្រាប់សម តាមផ្លូវដោយការអាណិតអាសូរ "ខ្ញុំនឹងឱ្យបងមើលថែផ្ទះសម្បែងខ្ញុំ ដើម្បីឱ្យមានការងារធ្វើ ហើយ មិនពិបាកតទៅទៀត" ។ សូមអរគុណព្រះតេជគុណណាស់ហើយទានប្រាស ។ មនុស្សយើងត្រូវតែ ពឹងពាក់អាស្រ័យគ្នាទៅមកណាបង លោករដ្ឋមន្ត្រីសម្លឹងមើលមុខ សម ហើយនិយាយឡើងយឺតៗ មនុស្សយើងត្រូវមានសិទ្ធិសេរីភាពស្មើគ្នា តែសិទ្ធិសេរីភាពនោះត្រូវតែមានព្រំដែន ខ្ញុំរីករាយណាស់ ក្នុងការដែលបានជួយជ្រោមជ្រែងមនុស្សដែលមានទុក្ខលំបាក សុំទោសចុះបង បងឈ្មោះអី ? ខ្ញុំបាទ ឈ្មោះសមទានប្រាស ... ។ បើអញ្ចឹងក៏ស្រួលដែរ ខ្ញុំនឹងជួយបងឯងឱ្យបានស្រួល ខ្ញុំមិនត្រូវការអី ក្រៅពីសេចក្តីស្មោះត្រង់សុចរិតរបស់បងឯងទេបង ។ បាទទានប្រាស ! ខ្ញុំបាទនឹងធ្វើជាអ្នកបម្រើ ព្រះតេជគុណដោយសេចក្តីស្មោះត្រង់តរៀងទៅ ។

ជីវិតរបស់សមបានវិលវល់ផ្លាស់ប្តូរទៅតាមយថាកម្ម ... ។ សមបានទទួលនូវសេចក្តីសុខកាយ សប្បាយចិត្តគ្រាន់បើបន្តិចនៅក្រោមម្លប់ដំបូលផ្ទះរបស់លោករដ្ឋមន្ត្រីកំលោះ ដែលមានចិត្តទូលាយ ចំពោះជនរួមជាតិទូទៅ ។

វគ្គ : កសិករថ្មី

ដោយសារកិរិយាមារយាទដ៏សុភាពរាបសារបស់សម លោករដ្ឋមន្ត្រីអាណិតអាសូរស្រឡាញ់ សមជាខ្លាំង ។ សមបានជ្រកកោននៅក្រោមម្លប់នៃដំបូលផ្ទះលោករដ្ឋមន្ត្រីដោយសេចក្តីសុខសាន្ត ។ ប៉ុន្តែសមសម្លឹងមើលទៅឃើញថា ការរស់នៅក្នុងឋានៈជាកម្មករនៅរាជធានីមិនជាការសុខកាយ សប្បាយចិត្តរស់នៅដោយមានកិត្តិយសថ្កុំថ្កើងរស់នៅដោយមានចម្រើនលូតលាស់ឡើយ ។ ការរស់នៅ ក្នុងក្រុងចំនួនប៉ុន្មានឆ្នាំមកនេះ ជីវិតរបស់សមត្រូវរិចរិលបន្តិចម្តងៗដូចជា បុប្ផាដែលគេយកទៅដាំ ក្នុងដើងគ្មានជីរជាតិកាន់តែស្វិតស្រពោនទៅមួយថ្ងៃបន្តិចៗ ... ។

ក្នុងកាលដែលប្រទេសកម្ពុជាបានឯករាជ្យបរិបូរហើយ ដោយស្នាព្រះហស្តរបស់ព្រះបាទសម្តេច ព្រះនរោត្តម សីហនុជាព្រះមហាប្រមុខរដ្ឋនៃព្រះរាជាណាចក្រទាំងមូលដែលធ្លាប់ជួបប្រទះនូវអសន្តិ សុខ ដែលជួបប្រទះគ្រោះមហន្តរាយយ៉ាងសម្បើមដោយសារពួកឧទ្ទាមនោះ ឥឡូវក៏បានប្រែក្លាយទៅ

ជាមានសន្តិសុខយ៉ាងពិតប្រាកដ។ ប្រជារាស្ត្រខ្មែរគ្រប់ជាន់ថ្នាក់ ទោះបីនៅក្នុងទីក្រុងក្តី ស្រុកស្រែចំការក្តីក៏បានទទួលនូវសេចក្តីសុខក្សេមក្សាន្តឥតមានភ័យបារម្ភចំពោះសន្តិសុខទៀតឡើយ។ សមបានសម្លឹង មើលទៅឃើញនូវការដ៏សំខាន់ ម្យ៉ាងដែលអាចនាំឱ្យជីវិតគេឱ្យមានជំហានឈានឆ្ពោះទៅកាន់សេចក្តីចម្រើនរុងរឿងទៅអនាគត។ លុះបាននឹកដល់វាលស្រែដ៏ធំធេង តែគ្មានអ្នកភ្ជួររាស់។ វាលស្រែស្រុកសមអាចនឹងក្លាយទៅជាគំនរទ្រព្យសម្បត្តិយ៉ាងពិសេសបាន ប្រសិនបើមានកសិករខិតខំកាប់គាស់សម្រុកភ្ជួររាស់សារជាថ្មី។ គួរឱ្យស្តាយណាស់ ! ស្តាយស្រែភ្លឺដែលជាកេរមត៌កពីបុព្វបុរសបានសាងទុកឱ្យមក ហើយសមបានបោះបង់ចោលនូវមត៌តដ៏មានតម្លៃនោះអស់ចំនួនច្រើនឆ្នាំណាស់មកហើយ... តែការបោះបង់នេះក៏មិនមែនប្រែសេចក្តីថា សមខ្ជីខ្ជួរអើមចំពោះការរកស៊ីដោយកម្លាំងកាយដ៏សុចរិតនោះឡើយ។ ការដែលសមបោះបង់ស្រែចំការចោល ហើយមកនៅទីក្រុងនេះ សមក៏ត្រូវធ្វើការបែកញើសហូរញើសដូចគ្នាដែរ ហើយការរកស៊ីដោយកម្លាំងកាយនៅទីក្រុងនេះ វារឹតតែធ្វើឱ្យសមមានសភាពដុនជាបជាងនៅស្រុកស្រែចំការទៅទៀត។ សមបោះបង់ស្រែចំការក៏ព្រោះតែអសន្តិសុខ។

ឥឡូវនេះ ព្រះអាទិត្យថ្មីបានរះនៅលើផែនដីចាស់ ហើយរះនៅលើផែនដីនៃអាណានិគមបារាំងនិងផែនដីនៃអ្នកនយោបាយបោកប្រាស់។ ព្រះអាទិត្យថ្មីបានយកនូវរស្មីនៃសន្តិភាពមកបាចជះនៅលើផែនដីចាស់។ សមបានតាំងចិត្តយ៉ាងមាំថា ត្រូវតែត្រឡប់ទៅលើកចប នង្គ័ល រនាស់នៅស្រុកកំណើតដូចជាពេលមុនវិញ...។ សមសប្បាយរីករាយណាស់ក្នុងការដែលនឹកឃើញដល់ជីវភាពនៃកសិកររបស់ខ្លួនពីអតីត ដែលពោរពេញទៅដោយឥស្សរភាពនិងសុខដុមរមួនា សមក៏កាត់ចិត្តថាត្រូវតែត្រឡប់ទៅកាន់ជីវភាពចាស់វិញ។ សមនៅចាំបានទៀតថា ក្នុងថ្ងៃនក្ខត្តឫក្សមួយនោះ ព្រះមហាវីរក្សត្រព្រះបិតាឯករាជ្យជាតិទ្រង់បានថ្លែងព្រះរាជសុន្ទរកថាទៅកាន់ជនរួមជាតិ ដើម្បីដាស់តឿនប្រជាពលរដ្ឋឱ្យនឹករលឹកដល់វាលស្រែយើង ព្រោះវាលស្រែនេះហើយជាឫសគល់ ឬជាមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ...។ សមពេញចិត្តនឹងព្រះរាជសុន្ទរកថានោះណាស់ ព្រោះសមយល់ថា វាលស្រែស្រុកខ្មែរ គឺជាជង្រុកមាសពេជ្រ សេដ្ឋកិច្ចក៏បានលូតលាស់។ ហេតុនេះក្នុងឋានៈជាពលរដ្ឋខ្មែរស្នេហាជាតិម្នាក់ សមក៏បានប្តេជ្ញាចិត្តថា ត្រូវតែត្រឡប់ទៅកាន់ស្រុកកំណើតវិញ ដើម្បីពួតដៃជាមួយកសិករខ្មែរទាំងឡាយកសាងខឿនសេដ្ឋកិច្ច ដែលទ្រុឌទ្រោមរិចរិលក្នុងសម័យអាណានិគមនិយមឱ្យបានខ្ពស់ត្រដែតឡើងវិញ...។ សមគិតថា ត្រូវយកនង្គ័ល រនាស់ ចបជីក កណ្តៀវមកធ្វើជាឧបករណ៍នៃអាជីវកម្មដោយត្រូវត្រឡប់ទៅកសាងជីវភាព "កសិករថ្មី" ដោយរួសរាន់...។ ពិតដូចគំនិតមែន សមបានត្រឡប់ទៅប្រកបការកសិកម្មវិញ ដោយពេញចិត្ត តែអស់ពេលបីឆ្នាំមកហើយការធ្វើស្រែនោះ

ពុំទាន់បានផលល្អមកឱ្យសមនៅឡើយ ព្រោះសមត្រូវធ្វើស្រែប្រវាស់និងមេឃ លើមេឃបង្អុរភ្លៀងចុះមក កសិករទាំងឡាយមានសមជាដើម ក៏មានសង្ឃឹមតែលើមេឃបែរជារាំងទៅវិញ ជីវិតកសិករត្រូវស្រពោនក្រៀមក្រំតាមមេឃដែរ ព្រោះសេចក្តីសង្ឃឹម សមនិងកសិករខ្មែរភាគច្រើនធ្វើស្រែមិនសូវបានចម្រើនសោះ។ សមនិងកសិករឯទៀតៗត្រូវធ្លាក់ចុះក្នុងសេចក្តីអស់សង្ឃឹម។ ប៉ុន្តែការអស់សង្ឃឹមរបស់កសិករមានសមជាដើមនោះ ពុំមែនស្ថិតនៅអស់មួយជីវិតទេ ... នុ៎ះហ្ន! កសិករទាំងនោះត្រូវបានរីករាយឡើងវិញ ហើយជីវភាពកសិកររដែលកំពុងតែក្រៀមក្រំស្ងិតស្រពោននោះ ឥឡូវក៏ប្រែទៅជាស្រស់បស់ប្រកបដោយសេចក្តីសង្ឃឹមយ៉ាងធំទូលាយឡើងវិញ។ សមសង្ឃឹមអ្វី ? សង្ឃឹមលើការធ្វើស្រែចំការប្រវាស់មេឃនោះឬ ? មិនមែនទេ ! សមឈប់សង្ឃឹមលើមេឃទៀតហើយ តែសមបែរជាមានសង្ឃឹមទៅលើ "នយោបាយទឹក" ទៅវិញ។ ចាប់តាំងពីសម័យដែលសង្គមរាស្ត្រនិយមកើតឡើងហើយកាន់ការប្រទេសក្រោមការដឹកនាំក៏ភ្លឺស្វាងរបស់សម្តេចព្រះនរោត្តម សីហនុ មកប្រទេសបានឈានមួយជំហានយ៉ាងវែងទៅកាន់សម័យថ្មី គឺ "សម័យកសាង" រាជរដ្ឋាភិបាលបានជួយយឺតយោងលើកតម្កើងកម្រិតជីវភាពប្រជារាស្ត្រដោយគ្រប់វិធី ហើយជាពិសេស គឺផែនការប្រចាំឆ្នាំ ដែលនៅក្នុងនោះមាន "ហត្ថកម្ម" ដែលជាជួងព្រលឹងរបស់កសិករ ... ។ សព្វថ្ងៃនេះ សមលែងសង្ឃឹមលើមេឃទៀតហើយ ព្រោះសមមានទំនប់ទឹក មានស្រះ មានអណ្តូងប្រើប្រាស់គ្រប់គ្រាន់ កាលពេលមុនសមត្រូវអុចធូបបន់ព្រះ សំពះទេវតាសុំទឹកភ្លៀង ... តែឥឡូវទោះបីគ្មានភ្លៀង សមក៏មិនអស់សង្ឃឹមដែរ ព្រោះក្នុងស្រុករបស់សម ដែលកាលពីដើមគ្មានទំនប់ទឹក គ្មានស្រះ គ្មានអណ្តូងឥឡូវក៏បានប្រែក្លាយទៅជាសំបុកទឹកឥតខ្វះខាត។

រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម បានដឹកនាំប្រជារាស្ត្រស្ថាបនាទំនប់ទឹកឱ្យជីកស្រះ ជីកអណ្តូងជាច្រើននៅក្នុងស្រុករបស់សម។ កសិករទាំងឡាយមានសមជាដើម ក៏បានខិតខំកសាងដោយសេចក្តីរីករាយ។ កសិករទាំងឡាយមានសមជាដើម លែងមានសេចក្តីព្រួយបារម្ភពីរឿងទឹកសម្រាប់ប្រើប្រាស់និងធ្វើស្រែចំការទៀតហើយ ជាពិសេសដីស្រែចំការរបស់សម ដែលកាលពីមុនមកបានផ្តល់យ៉ាងតិចតួចស្តួចស្តើងនោះ ឥឡូវក៏បានហូរផលយ៉ាងសម្បើមដល់កសិកររថ្មីនេះ។ សមនិកពេញចិត្តចំពោះនយោបាយទឹក គឺហត្ថកម្មលើកទំនប់ទឹករកអ្វីប្រៀបគ្មាន។ ស្រែសមបានចម្រើន ស្រែរបស់កសិករឯទៀតក៏បានរីកចម្រើន ហើយវាលស្រែគ្រប់ជនបទក្នុងព្រះរាជាណាចក្រទាំងមូលក៏បានចម្រើនដែលកាលបើកសិកម្មបានចម្រើន ដូច្នេះសេដ្ឋកិច្ចជាតិក៏បានល្អលូតលាស់យ៉ាងពិតប្រាកដ។ ក្រៅពីនេះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមបានជួយយឺតយោងកសិករច្រើនផ្លូវទៀត គឺជួយលើកតម្កើងផលិតផលដែលកើតឡើងក្នុងប្រទេសយើង អាស្រ័យហេតុនេះ ផលិតផលខ្មែរក៏ត្រូវមានជំហរឯ្ងប៉ឹងនិង

ថ្លៃថ្នូរលើផ្សារក្នុងប្រទេសនិងបរទេស។ មិនមែនមិនបាច់ព្រួយតែអំពីរឿងខ្វះទឹកធ្វើស្រែទេ សមត្រូវ
មិនបាច់ព្រួយបារម្ភអំពីការខ្វះពូជដំណាំ ការបំផ្លាញនៃសត្វចង្រៃ ដែលតែងតែស៊ីបំផ្លាញនូវដំណាំ
ផ្សេងៗទៀតផង។ សព្វថ្ងៃនេះនៅក្នុងស្រុករបស់សម ក៏ដូចជាគ្រប់តំបន់នៃព្រះរាជាណាចក្រដែរ
គឺរាជរដ្ឋាភិបាលបានបង្កើតក្រសួងកសិកម្មសម្រាប់ធ្វើជាគំរូដល់កសិករក្នុងការបណ្តុះបណ្តាលពូជ ព្រម
ទាំងសម្រាប់ការពារផលដំណាំរបស់កសិករទៀតផង។ សមបានទទួលនូវការពន្យល់ហ្វឹកហាត់គ្រប់
ផ្នែក មានការធ្វើដីឱ្យមានជីរជាតិ ការបណ្តុះពូជធារ ពីភ្នាក់ងារនៃក្រសួងកសិកម្ម។ សមរីតតែ
សប្បាយចិត្តចំពោះកិច្ចការខ្លួនណាស់ទៅទៀត។ ពេលមួយនោះ សត្វចង្រៃបានស៊ីបំផ្លាញស្រូវសមនិង
អ្នកស្រុកឯទៀត។ សមបានទៅប្តឹងក្រសួងកសិកម្ម ដើម្បីឱ្យប្រយុទ្ធនឹងសត្វចង្រៃ។ ក្រសួងនេះក៏បាន
ចាត់ភ្នាក់ងារឱ្យចេញទៅប្រតិបត្តិការណ៍បាចថ្នាំកំចាត់សត្វចង្រៃតាមពាក្យសុំរបស់សម។ សមបាន
ឃើញច្បាស់នឹងភ្នែកថា ក្នុងសម័យបច្ចុប្បន្ន គឺសម័យកសាងរបស់សង្គមរាស្ត្រនិយមមិនដូចសម័យ
អាណានិគមបារាំង ឬក្នុងសម័យឯករាជ្យក្លែងក្លាយនោះឡើយ។ សម័យសង្គមរាស្ត្រនិយម គឺជា
សម័យដែលរាជរដ្ឋាភិបាលបានជួយជ្រោមជ្រែងកសិករក្នុងការធ្វើស្រែចំការ ហើយថែមទាំងលើក
តម្កើងកសិករឱ្យក្លាយទៅជាពលរដ្ឋដ៏មានតម្លៃក្នុងសង្គមជាតិផង ... ។ កសិករសម័យព្រះសីហនុមិន
មែនអាប់ឱន ឬថោកទាបដូចសម័យមុនៗឡើយ។ សមស្រឡាញ់សង្គមរាស្ត្រនិយមស្មើជីវិត សព្វថ្ងៃ
នេះសេចក្តីស្មោះត្រង់ ដែលហូរចេញពីដួងចិត្តដ៏បរិសុទ្ធនោះ សមបានបូជាចំពោះសង្គមរាស្ត្រនិយម
ដោយសេចក្តីគោរព។ សមបានឃើញច្បាស់នឹងភ្នែកថា ព្រះបិតាឯករាជ្យជាតិព្រះអង្គទ្រង់មិនប្រកាន់
ព្រះរាជឋានៈឡើយ។ ព្រះអង្គតែងយាងទៅប្រតិបត្តិការណ៍ហត្ថកម្មដោយផ្ទាល់ព្រះហស្ត ហើយចេះ
អាណិតអាសូរនិងស្រឡាញ់រាស្ត្រ។ សម័យសង្គមរាស្ត្រនិយម មន្ត្រីរាជការគ្រប់រូបត្រូវបោះបង់ទួង
ដងប៉ាកកាចោលមួយពេលមួយគ្រា ដើម្បីទៅចាប់នង្គ័ល រនាស់ ចប បង្គីជួយធ្វើស្រែរាស្ត្រនិងដើម្បី
បង្ហាត់ចិត្តគំនិតរបស់មន្ត្រីរាជការទាំងនោះឱ្យដឹងសុខទុក្ខនិងជីវភាពរបស់ប្រជារាស្ត្រ។ សមហ៊ាន
និយាយថា ក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរគ្មានព្រះមហាក្សត្រអង្គណា ឬវរជនរូបណាដែលចេញទៅធ្វើ
ហត្ថកម្មដោយព្រះហស្ត ឬដោយដៃដូចសម្តេចព្រះនរោត្តមសីហនុឡើយ។ ក្នុងពេលថ្មីៗនេះ សម្តេច
ឧបយុវរាជទ្រង់បានយាងទៅប្រតិបត្តិការហត្ថកម្មដោយផ្ទាល់ព្រះហស្តរបស់ព្រះអង្គនៅជិតស្រុករបស់
សម។ ដោយសារការស្រឡាញ់ពេញចិត្ត ព្រោះឃើញច្បាស់ថា សង្គមរាស្ត្រនិយមក្រោមការដឹកនាំ
ដ៏ភ្លឺស្វាងរបស់សម្តេចព្រះឧបយុវរាជ សីហនុ ពិតជាធ្វើផលប្រយោជន៍ឱ្យរាស្ត្រ ដោយជាក់ស្តែងនោះ
សមបានខិតខំប្រឹងប្រែងដើរបញ្ចុះបញ្ចូលអ្នកស្រុក អ្នកភូមិឱ្យយល់ដល់តម្លៃនៃការហត្ថកម្ម ស្រឡាញ់
ការហត្ថកម្ម ហើយនាំគ្នាស្ម័គ្រចិត្តចូលទៅជួយរួបរួមក្នុងហត្ថកម្មនោះ ការហត្ថកម្មនោះក៏បានសម្រេច

ផលជាទីពេញចិត្ត។ សមបានយកកម្លាំងកាយនិងកម្លាំងចិត្តបូជាចំពោះសង្គមរាស្ត្រនិយម ដោយឥតខ្លាចនឿយហត់សោះឡើយ។ មិនយូរប៉ុន្មានប្រជារាស្ត្រក្នុងស្រុកភូមិក៏ស្រឡាញ់រាប់អានគោរពសមហើយទុកសមដូចជាមេគោយរបស់ខ្លួន។ ដោយសេចក្តីស្មោះត្រង់ចំពោះជាតិ សាសនា ព្រះមហាក្សត្រ និងសេចក្តីប្រឹងប្រែងចំពោះការងារគ្រប់បែបមានដឹកនាំប្រជារាស្ត្រឱ្យធ្វើហត្ថកម្មជាដើម ដែលជាការជួយឱ្យបានសម្រេចនូវគោលបំណងសង្គមរាស្ត្រនិយម នោះរាជរដ្ឋាភិបាលក៏ពេញចិត្តនឹងអាកប្បកិរិយារបស់សមជាខ្លាំង ហើយបានសរសើរសមដោយរង្វាន់និងឥស្សរិយសជ្រុងៗដ៏គួរពេញចិត្ត។ មិនយូរប៉ុន្មាន សមត្រូវប្រជារាស្ត្រក្នុងស្រុកភូមិបោះឆ្នោតជ្រើសតាំងឱ្យធ្វើជាប្រធានគណៈកម្មការក្នុងឃុំនៃសង្គមរាស្ត្រនិយម។ ការដែលបានធ្វើជាប្រធានហើយ សមក៏រឹងរឹតតែខំប្រឹងប្រែងធ្វើការណាស់ទៅទៀត។ សមបានដឹកនាំអ្នកស្រុកឱ្យដើរតាមក្រោយនយោបាយរបស់សម្តេច សហជីវិន គឺដឹកនាំឱ្យចេះស្រឡាញ់ការងារ ពួតដៃគ្នាជីកស្រះ អណ្តូង លើកថ្នល់ សង់ស្ពាន សាលារៀន។ល។ ក្រៅពីនោះ សមដឹកនាំអ្នកស្រុកឱ្យចេះស្រឡាញ់ករណីយកិច្ចនៃពលរដ្ឋដ៏ល្អមានការកំចាត់ជនទុច្ចរិតជាដើម។

ជាទីបំផុត សមបានដឹកនាំអ្នកស្រុកឱ្យស្គាល់តម្លៃនៃសមាជជាតិ ពេលសមាជម្តងៗអ្នកស្រុកសមតែងតែនាំគ្នាមកចូលរួមប្រជុំជាច្រើន។ អ្នកស្រុកសមកាលពីដើមល្ងង់ខ្លៅ ឥឡូវបានប្រែទៅជាមនុស្សចេះដឹង និយាយ និងយល់ការណ៍។ ស្រុកសមដែលធ្លាប់ជួបប្រទះនូវទុរ្ភិក្សកាលពីដើម ឥឡូវបានប្រែក្លាយទៅជាស្រុកសម្បូរសប្បាយ។ អ្នកស្រុកសមកាលពីដើមមានសភាពដុនដាបនោះ ឥឡូវក៏បានប្រែក្លាយទៅជាមានជីវភាពធូរធាជាងមុនច្រើន ... ។

(ជកស្រង់ពីរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ របស់លោក សួន សុវិន្ទ)

សំណួរ

១. តើរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ស្ថិតនៅក្នុងចលនាអក្សរសិល្ប៍អ្វី ? ចូរផ្តល់អំណះអំណាង ?

២. តើសមមានលក្ខណៈពិសេសអ្វីខ្លះ ដែលនាំឱ្យជីវិតសមបានទទួលលទ្ធផលវិជ្ជមានបែបនេះ ? ចូរបង្ហាញពីលក្ខណៈវិជ្ជមានទាំងនោះ។

៣. ចូរអ្នកបកស្រាយឃ្លា "ព្រះអាទិត្យថ្មីបានរះនៅលើផែនដីចាស់ ហើយរះនៅលើផែនដីនៃអាណានិគមនិយមបារាំង" រកអំណះអំណាងក្នុងអត្ថបទខាងលើមកបញ្ជាក់។

សិល្បៈខ្មែរ



ក. សិក្សាពាក្យគន្លឹះ

- កេតនភណ (ន) : របស់ទុកដូចជាទង់សម្រាប់ជាតិ វត្ថុដ៏ឧត្តុង្គឧត្តមសម្រាប់ជានិមិត្តរូប ។
- កំពែង (ន) : របងធ្វើដោយឥដ្ឋឬថ្ម ។
- ងោះ (ន) : ឈ្មោះរូបមួយក្នុងខ្យងស័ង្ខ ជារូបអាក្រក់ ។
- ថ្មភក់ (ន) : ឈ្មោះថ្មមួយប្រភេទដែលគេយកមកធ្វើប្រាសាទ (សសរពេជ្រ) ។
- ប្រាង្គ (ន) : កំពូលប្រាសាទ ។
- ព្រះពោធិសត្វ (ន) : អ្នកដែលខំបំពេញបារមីបម្រុងនឹងបានបំពេញជាព្រះសម្មាសម្ពុទ្ធ ។
- រចនាបថ (ន) : បែបបទ ម៉ូតដែលគេរចនា ។

ខ. អភិវឌ្ឍន៍បំណិន

នៅក្នុងការសិក្សាអត្ថបទនេះ ចូរអ្នកយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងប្រភេទសិល្បៈខ្មែរ ចម្លាក់ ភ្លេង របាំជាដើម ។

សិល្បៈសំដៅយកការងារផ្សេងៗផ្នែកជំនាងហត្ថកម្មគ្រប់បែបយ៉ាង ដែលមានសិល្ប៍ ពោលគឺធ្វើមនុស្សចិត្តចាប់អារម្មណ៍ ចង់មើល ចង់ស្តាប់។ សិល្បៈមានច្រើនប្រភេទណាស់ដូចជា សិល្បៈរបាំ ភ្លេងចម្រៀង ល្ខោន គំនូរ សំណង់ សូនរូប។ល។ ក្នុងចំណោមសិល្បៈរបស់ខ្មែរយ៉ាងច្រើនសន្ធឹកសន្ធាប់ភ្លេងនិងរបាំក៏មានច្រើនបែបយ៉ាងដែរ។

១ . ភ្លេង

ភ្លេងជាសិល្បៈមួយប្រភេទ សម្រាប់ប្រគុំញ៉ាំងបរិយាកាសក្នុងពិធីបុណ្យទាននិងពិធីជាទំនៀមផ្សេងៗឱ្យមានភាពលន្លង់លន្លោចរីករាយរុងរឿង ឬអឺកធឹកឡើង។ ភ្លេងដែលខ្មែរនិយមប្រើតាំងពីសម័យបុរាណមានច្រើនប្រភេទដូចជា ៖

ក. ភ្លេងពិណពាទ្យ

គេឱ្យឈ្មោះថា ភ្លេងពិណពាទ្យ ព្រោះក្នុងក្រុមភ្លេងនោះកាលដើមឡើយគេនិយមប្រើពិណចេញផ្តើមមុនគេ។ អ្នកខ្លះហៅភ្លេងពិណពាទ្យនេះដោយភ័ន្តច្រឡំថា ភ្លេងសៀម។ ការពិតសៀមយកពីខ្មែរយើងទៅវិញទេ។ សៀមហៅវង់ភ្លេងនេះថា ប៊ីពាទ្យ (ពិជាត) ព្រោះក្នុងការចាប់ផ្តើមគេប្រើប៊ីឬស្រឡៃនាំមុខគេ។ លោក ឈឹម ក្រសេម បានលើកឡើងថា ភ្លេងពិណពាទ្យមានកំណើតមកពីឥណ្ឌាតាំងពីសម័យព្រេងនាយ លុះដល់ក្រោយមកខ្មែរក៏បានកែប្រែផ្លាស់ប្តូរនិងថែមថយគ្រឿងភ្លេងឱ្យក្លាយជាភ្លេងរបស់ខ្មែរ។ សព្វថ្ងៃនេះគេបានរៀបចំភ្លេងពិណពាទ្យជាពីរវង់ គឺពិណពាទ្យវង់តូច (មានប្រដាប់ ៥គ្រឿង) និងពិណពាទ្យវង់ធំ (មានប្រដាប់ ១០គ្រឿង)។ នៅក្នុងព្រះរាជវាំងមានគ្រឿងភ្លេងពិណពាទ្យពិសេសមួយបែបហៅថា ក្រុមមហោរីព្រះរាជទ្រព្យ (មានគ្រឿងចម្រុះច្រើនយ៉ាងដល់ទៅ ១៦គ្រឿង)។ ខ្មែរប្រើវង់ភ្លេងពិណពាទ្យក្នុងការកំដររបាំបុរាណក្នុងពិធីបួងសួង (បន់ស្រន់លាបំណន់)ក្នុងពិធីសាសនា (បុណ្យលបិន បំបួសនាគ ពុទ្ធភិសេក...) ជួនកាលក្នុងពិធីបុណ្យសព។

ខ. ភ្លេងអារក្ខ

ភ្លេងដែលគេប្រគំឡើងក្នុងពិធីបញ្ជូលខ្មោច បិសាច អារក្ខ អ្នកតា។ នៅពេលមានមនុស្សឈឺហើយបើចង់សាកសួរខ្មោចអំពីបុព្វហេតុនៃជំងឺ គេលេងភ្លេងអារក្ខនេះ ដើម្បីបញ្ជូលខ្មោចលៀងខ្មោច។ ក្រោយពីបានសាកសួរដឹងបុព្វហេតុ ដែលនាំឱ្យមានជំងឺគេអង្វរខ្មោចសុំឱ្យជាសះស្បើយ

ហើយគេរៀបចំតង្វាយផ្សេងៗថ្វាយខ្មោចនោះទៅ ក្រៅពីលេងក្នុងពិធីបញ្ចូលនិងលៀងអារក្ខ ភ្លេងអារក្ខប្រើក្នុងពិធីឡើងអ្នកតាដែរ។ តាមការស្រាវជ្រាវរបស់លោក ជឹម ឈុំ សមាជិកនៃក្រុមទំនៀមទម្លាប់ភ្លេងអារក្ខនេះ មានកំណើតឡើងអំពីកូនក្មេងលេង "បាយឡុកបាយឡ"។ គេតែនិយាយរឿងនេះតៗគ្នាមកថា កាលនោះនៅក្នុងភូមិមួយមានក្មេងស្រីប្រុសប្រជុំគ្នាលេង អ្នកខ្លះធ្វើភ្ញៀវ ខ្លះធ្វើអ្នកផ្ទះ ខ្លះធ្វើប្តី ខ្លះធ្វើប្រពន្ធ ខ្លះទៀតធ្វើកូន ហើយនាំគ្នាជប់លៀងស៊ីផឹកស្រវឹងដួលដេក សើចហ៊ាកញ្ជ្រៀវយ៉ាងសប្បាយរាល់ៗថ្ងៃរៀងខ្លួន។ ដំបូងលេងតែពេលថ្ងៃទេ លុះយូរទៅក៏វក់លេងទាំងថ្ងៃទាំងយប់ រហូតដល់ពេលភ្លេចបាយទឹកភ្លេចដេកពួន។ ឪពុកម្តាយ ហាមឃាត់យ៉ាងណាក៏ពុំស្តាប់។ ឃើញហេតុខុសពីធម្មតាបែបនេះ ចាស់ៗក៏នឹងថាប្រហែលមានព្រាយបិសាចចូលមកពង្វក់ចិត្តក្មេងទាំងនោះ ហើយទើបនាំគ្នាបន់ស្រន់ឡើង។ ឯពួកបិសាចកាលបើគេនឹងហៅរកខ្លួន ក៏ឆ្លៀតឱកាសនេះចូលទៅសណ្ឋិតក្នុងរូបក្មេងម្នាក់ភ្លាម ហើយក៏និយាយបញ្ជាឱ្យចាស់ទាំងនោះរៀបសំណែន ដោយមានលេងភ្លេងថ្វាយពួកគេផង ទើបពួកគេជួយរក្សាឱ្យបានសុខសប្បាយតរៀងទៅ។ បន្ទាប់មក បិសាចក៏នាំគ្នាឱ្យក្មេងធ្វើបទភ្លេងដោយមាត់តាមចិត្តវា។ ក្រោយដែលបានស៊ីសំណែនឆ្អែតស្កប់ស្កល់ហើយ ពួកបិសាចក៏ចាកចេញទៅ ឯពួកក្មេងក៏ឈប់វក់លេងដូចមុនទៀត ហើយរស់នៅជាសុខសប្បាយរហូតមក។ ចាប់តាំងពីពេលនោះមក អ្នកស្រុកក៏ប្រកាន់ជឿខ្មោចអារក្ខ ព្រាយបិសាច ព្រមទាំងយកទីគោរពទីពឹងក្នុងគ្រាមានអាសន្ន។

គ. ភ្លេងខ្មែរ

គេចាត់ទុកភ្លេងខ្មែរជាភ្លេងមង្គល។ ដូច្នេះហើយបានជាគេត្រូវប្រគំតែក្នុងពិធីមង្គលតាមប្រពៃណីខ្មែរដូចជា ពិធីបញ្ចេញម្លប់កូនស្រី ពិធីមង្គលការជាដើម។ ភ្លេងខ្មែរសម្រាប់ពិធីមង្គលការមានច្រើនប្រភេទណាស់ដូចជា បទបែកូនកំលោះចូលរោង បែកំណត់ស៊ីស្លា កាត់សក់ សែនក្រុងពាលី កូនប្រុសសំពះពេលាកូនស្រីចេញថ្មីមចងដៃ បង្ហិលពពិល។ល។ បទភ្លេងខ្មែរមានទំនាក់ទំនងទៅនឹងរឿងព្រេងខ្មែរ។ បទខ្មែរ ខ្លងភ្នំ របងមាស បន្ទាយប្រាសាទ ស្រងាត់ ដោះក្រាល កន្ត្រែនទ្រាំង លេងនៅពេលលៀងភោជនាហារថ្ងៃត្រង់ (ក្រោយពេលស៊ីស្លាកំណត់) មានកំណើតដោយយកតម្រាប់តាមតាជុងយាយជ័យ ដែលឱ្យអ្នកភ្លេងលេងបទទាំងនេះថ្វាយអ្នកតាព្រៃ ដើម្បីលាមាត់លាកដែលគាត់បានបន់ស្រន់នៅពេលធ្វើដំណើរកាត់ព្រៃទៅរៀបការកូនស្រីឈ្មោះនាងត្រចើលដោះក្រាលនិងចៅប្រមាញ់ រឹងស៊ុង។ ចំណែកបទព្រះថោង ដែលគេប្រើលេងនៅពេលសំពះផ្ចឹមនោះ មានកំណើតឡើងក្នុងរជ្ជកាលព្រះថោង (ហ៊ុនទៀន) បបមក្សត្រខ្មែរ។ ព្រះអង្គទ្រង់រៀបអភិសេក

ជាមួយនាងទាវតី (លីវយី) បុត្រីស្តេចភុជង្គនាគ។ លុះរៀបមង្គលការនៅស្ថានមនុស្សរួចហើយ ស្តេចភុជង្គនាគបាននាំព្រះថោងទៅជប់លៀងម្តងទៀតនៅស្ថានបាតាល។ ដោយព្រះថោងពុំចេះវិជ្ជាខាងជ្រែកទឹកក៏តោងកន្ទុយនាងនាគទើបចុះទៅបាន។ អាស្រ័យដោយមានរឿងខាងលើនេះ ហើយបានជាគេសន្មតឈ្មោះបទភ្លេងថា បទព្រះថោង ដែលខ្មែរនិយមប្រើលេងជាប់រហូតមកដល់សព្វថ្ងៃនេះ ព្រមទាំងមានទំនៀមទម្លាប់ឱ្យប្រុសតោងជាយស្បៃកូនស្រីចូលបន្ទប់ទៀតផង។

ឃ. ភ្លេងឆៃយ៉ាំ

គេលេងភ្លេងឆៃយ៉ាំតែក្នុងពិធីបុណ្យ ដែលជាទីរីករាយដូចជា លេងកំដបុណ្យ កឋិន បុណ្យផ្កាបុណ្យបំបួសនាគជាដើម។ ភ្លេងឆៃយ៉ាំជាភ្លេងដែលរំភើបសប្បាយ ហើយរស់រវើកប្លែកពីភ្លេងឯទៀត។ គេពុំទាន់ដឹងច្បាស់នៅឡើយទេអំពីប្រភពភ្លេងឆៃយ៉ាំនេះ។ ដោយចង្វាក់ភ្លេងមានលោតៗភ្ញាក់ៗ អ្នកខ្លះឱ្យយោបល់ថា ភ្លេងឆៃយ៉ាំទំនងមានកំណើតចេញពីមនុស្សជំនាន់ដើម ដែលតែមានសភាពភ្ញាក់ផ្អើលខ្លាចរអាប្រៀបបានទៅនឹងសត្វព្រៃផ្អើលនៅពេលឃើញមនុស្ស។ អ្នកខ្លះទៀតថា នៅពេលមនុស្សបានទទួលជោគជ័យក្នុងកិច្ចការរបស់ខ្លួនតែងតែសប្បាយរីករាយយ៉ាងខ្លាំង ហើយក៏បង្កើតភ្លេងឆៃយ៉ាំនេះឡើង ដើម្បីរំលឹកនូវជ័យជំនះនោះ។

ង. ភ្លេងមហោរី

ពាក្យមហោរី សម្គាល់ឈ្មោះភ្លេងផង សម្គាល់សភាពនៃវង់ភ្លេងផង។ បទភ្លេងមហោរីមានលក្ខណៈប្រជាប្រិយ ហើយស្រាលជាងភ្លេងពិណពាទ្យ។ វង់ភ្លេងមហោរីនិយមលេងក្នុងពិធីបុណ្យទានផ្ទាល់ទេ ប៉ុន្តែអាចប្រើកំដបរិយាកាសបានដែរ។ ជាទូទៅ គេលេងភ្លេងមហោរីកំដរល្ខោនមហោរី។

ច. ភ្លេងក្លងឆ្នាក់

ដើម្បីឱ្យបរិយាកាសស្រងេះស្រងោចលន្លង់លន្លោច គេលេងភ្លេងក្លងឆ្នាក់ក្នុងពិធីតម្កល់សពហែសពបូជា។ អ្នកខ្លះហៅភ្លេងក្លងឆ្នាក់នេះតាមភាសាសៀមថា **ភ្លេងក្លងខែក** ដែលមានន័យថាភ្លេងស្គរជ្វា។ តាមសេចក្តីរាយការណ៍របស់លោក **ឌួង អ៊ូច** ថាកាលពីយូរណាស់មកហើយនៅវត្តពោធិរាមា ស្រុកកោះធំ ខេត្តកណ្តាល ព្រះគ្រូសីរវង្សាជាមេគណក្នុងស្រុកនោះបង្កើតឱ្យមានភ្លេងខ្មែរមួយវង់សម្រាប់លេងទទួលកឋិននិងកំដរបុណ្យទានដែលលោកតែងតែហៅថា ភ្លេងខែក លោកគ្រូអង្គនោះតែងមានពុទ្ធដិកាប្រាប់អ្នកស្និទ្ធស្នាលនឹងលោកថា នេះហើយជាភ្លេងខ្មែរបុរាណយូរយារណាស់មកហើយ។

ឆ. ភ្លេងគងស្គរ

អ្នកខ្លះហៅថាភ្លេងគងស្គរថា ភ្លេងទាំមួនឬកន្ទ្រាំមួន។ ភ្លេងនេះ មានសូរសព្ទគួរឱ្យស្រងេះស្រងោចណាស់ ហេតុនេះហើយបានជាគេលេងភ្លេងនេះនៅពេលដែលមានមនុស្សស្លាប់និងនៅពេលធ្វើបុណ្យលើកខ្មោច។ តាមការស្រាវជ្រាវរបស់សមាជិកក្រុមជំនុំទំនៀមទំលាប់ថា ភ្លេងគងស្គរមានកំណើតឡើងក្នុងរជ្ជកាល ព្រះបាទត្រសក់ផ្អែម។ កាលព្រះអង្គបានឡើងសោយរាជ្យសម្បត្តិ ព្រះអង្គតែងនិងស្រណោះសំឡេងសត្វគ្រប់បែបយ៉ាងលាយឡំនឹងស្នូរខ្យល់ ភ្លៀង ផ្គរ រន្ទះ ដែលព្រះអង្គធ្លាប់បានស្តាប់ទាំងយប់ទាំងថ្ងៃ កាលព្រះអង្គនៅជាម្ចាស់ចំការត្រសក់ផ្អែម។ ដើម្បីតាងភ្លេងធម្មជាតិដ៏កំសត់បែបនេះ ព្រះអង្គទ្រង់ចាត់ឱ្យអ្នកប្រាជ្ញរាជបណ្ឌិតបង្កើតក្រុមភ្លេងគងស្គរនេះឡើង។

ជ. ភ្លេងយោល

នៅសម័យដើមគេប្រើវង់ភ្លេងស្គរយោលជាវង់ភ្លេងកងទ័ព ដែលគេព្យួរនៅលើខ្នងដំរី លុះមកដល់សម័យបច្ចុប្បន្ន គេយកមកប្រើសម្រាប់កំដរពិធីបុណ្យខ្មោចនិងកំដរល្បែងប្រជាល់សេរី។

ឈ. ភ្លេងប៊ីកែវ

ភ្លេងប៊ីកែវ គឺជាភ្លេងមួយបែបស្ថិតនៅក្នុងវង់ភ្លេងព្រះរាជទ្រព្យ។ តាមលោក បាន តេង គ្រូនៃក្រុមភ្លេងព្រះរាជទ្រព្យថា ភ្លេងប៊ីកែវលេងនៅពេលចាក់ទឹកដួងថ្វាយព្រះបិដក (សែនដួនតា) នៅក្នុងព្រះរាជវាំង។

យោបល់រួម : ការអធិប្បាយរៀបរាប់មកហើយនេះបង្ហាញឱ្យឃើញថា ភ្លេងខ្មែរបុរាណមានច្រើនប្រភេទ ច្រើនវង់ ហើយវង់នីមួយៗពុំមែនចេះតែយកទៅប្រគំលេងបានគ្រប់ពេលវេលាទេ គឺមានលក្ខណៈពិសេសរបស់ខ្លួនស្របទៅតាមតម្រូវការនៃពិធីបុណ្យទាន ឬពិធីផ្សេងៗថែមទៀត។ បើនិយាយពីតម្លៃវិញ បទភ្លេងខ្មែរបុរាណមានចង្វាក់ស្របទៅនឹងកិច្ចការរបស់មនុស្សខ្មែរ ដែលតែងប្រព្រឹត្តទៅតាមសម្រួលមិនលឿនពេកមិនយឺតពេកក្នុងបរិយាកាសធម្មតា ទុក្ខសោក ស្រងេះស្រងោចលន្លង់លន្លោចសប្បាយរីករាយ។ល។ បទភ្លេងខ្លះមានសូរសព្ទរងំស្តាប់យូរទៅរីតតែពិរោះឡើងៗមិនងាយសាបរលាបទៅវិញភ្លាមៗបានឡើយ។ ទាំងនេះសុទ្ធតែផុសចេញមកពីគំនិតសញ្ចេតនារបស់ខ្មែរព្រលឹងខ្មែរនេះឯង ពោលគឺបទភ្លេងនីមួយៗពុំមែនបង្កើតឡើងដើម្បីគ្រាន់តែពិរោះស្តាប់ ឬបញ្ចើចបញ្ចើឥតន័យនោះឡើយ។

២ . រាំវង់ប្រពៃណី

ការស្តាប់ភ្លេងជាតិ ជាការពិរោះម្យ៉ាងហើយ ប៉ុន្តែបើគេធ្វើកាយវិការទៅតាមចង្វាក់ភ្លេង នោះគេនឹងបានល្អមើលផង ហើយពីរោះស្តាប់ផង ដោយហេតុនេះហើយទើបគេបង្កើតឱ្យមានរបាំឡើង។

ក. របាំប្រជាប្រិយ

របាំប្រជាប្រិយ គឺជារបាំដែលប្រជារាស្ត្រស្រឡាញ់រាប់អាន ។

របាំត្រុដិ : ពាក្យសំស្ក្រឹត ត្រុដិ បានន័យថាផ្តាច់ ។ របាំត្រុដិប្រជាប្រិយមួយបែប ដែលគេនិយមលេងតែក្នុងពេលចូលឆ្នាំខ្មែរ ដើម្បីផ្តាច់ចាស់ចូលឆ្នាំថ្មី ដើម្បីប្រសិទ្ធិសព្ទសាធុការជូនពរដល់អ្នកស្រុកឱកាសចូលឆ្នាំនោះផង ។ ប៉ុន្តែតាមទម្លាប់របស់អ្នកស្រុកជួនកាលគេលេងរបាំនេះម្តងៗដែរ នៅពេលបន់ស្រន់សុំទឹកភ្លៀង ដោយនៅពេលនោះមានការរាំងស្ងួតជាយូរមកហើយ ។ សព្វថ្ងៃនេះ គេប្រទះឃើញមានលេងរបាំត្រុដិតែនៅខេត្តសៀមរាបនិងខេត្តបាត់ដំបងប៉ុណ្ណោះ ។ តាមសេចក្តីរាយការណ៍ពី លោកមាស ហាំម កាលធ្វើចៅហ្វាយស្រុកសូទ្រនិគម ថាត្រុដិជារបាំរបស់សាសន៍សំរែ ដែលជាជនជាតិដើមមួយ រស់នៅលើទឹកដីយើងតាំងពីបុរាណមក (សព្វថ្ងៃរស់នៅត្រង់ភូមិភាគខាងជើងនៃទន្លេសាប) ។ ជនជាតិសំរែនេះធ្លាប់នាំយករបាំត្រុដិលេងថ្វាយព្រះពរព្រះរាជាខ្មែរ កាលព្រះអង្គគង់នៅនគរវត្តរាល់ពេលចូលឆ្នាំ ។ អាស្រ័យហេតុនេះហើយ ទើបបានជារបៀបរាំត្រុដិនេះនៅសេសសល់ នៅខេត្តសៀមរាប ហើយគេនិយមលេងនៅពេលចូលឆ្នាំរហូតដល់សព្វថ្ងៃនេះ ។ តាមសេចក្តីរាយការណ៍ពីលោក ឡុង សាន់ នៅខេត្តបាត់ដំបងថា នៅតាមស្រុកជិតឆ្ងាយយូរៗម្តងរមែងមានសត្វព្រៃចូលមកក្នុងស្រុក ។ អ្នកស្រុកមានជំនឿថា ប្រសិនបើមានសត្វព្រៃណាមួយចូលក្នុងស្រុកហើយនឹងកើតឧបទ្រុបចង្រៃបែបណាមួយមិនខាន ។ គេក៏នាំប្រោះព្រំប្រេងម្សៅឱ្យសត្វនោះហើយ សុំពរជ័យពីសត្វនោះវិញ ។ ដោយមានជំនឿបែបនេះ អ្នកស្រុកក៏បង្កើតឱ្យមានរបាំត្រុដិនេះឡើង ដែលមានសត្វប្រឹស ទន្សោង ក្ងោកសុទ្ធសឹងតែជាសត្វព្រៃមកបង្ហាញឱ្យអ្នកស្រុកភូមិប្រោះព្រំប្រេងម្សៅ ចងដៃអំបោះ កម្រងផ្កា ឱ្យទានជាលុយកាក់ទៅធ្វើបុណ្យរំដោះគ្រោះឱ្យស្រេចតែម្តងទៅ ប្រសិនបើមានសត្វព្រៃចូលមកក្រោយទៀតក៏ចង្រៃឧបទ្រពពុំអាចកើតទៀតឡើយ ។ តាមឯកសារលោក សុក មេភូមិក្រសាំង(សៀមរាប) ថារបាំត្រុដិនេះមានប្រភពទាក់ទងនឹងបុរាណមួយដែលតំណាលថា កាលព្រះពុទ្ធនៅជាព្រះពោធិសត្វមុនត្រាស់ដឹង ទ្រង់យាងចេញទៅសាងផ្នួសស្រាប់តែមារតំណែងខ្លួនជាសត្វប្រឹសមករាំងស្ទាក់ផ្លូវព្រះអង្គកុំឱ្យយាងទៅមុខបាន ។ ពេលនោះ ព្រះពោធិសត្វក៏អធិដ្ឋានឡើងធ្វើឱ្យក្តៅដល់ទេវលោក ។ ទេវតាទាំងឡាយក៏ចុះតំណែងខ្លួនជាដោះ លបបាញ់ប្រើសក្តែងភេទនោះស្លាប់ទៅ ហើយក៏ដង្ហែព្រះពោធិសត្វទៅសាងផ្នួសបានសម្រេចដូចបំណង ។ ដោយមានរឿងបែបនេះហើយបានជាគេសាងរបាំត្រុដិដែលមាន "ដាក់កញ្ឆារតំណាងឆ័ត្រ ឬក្តស់បាំងព្រះពោធិសត្វ ពួកភ្លេងតំណាងទេវតា នាងរាំតំណាងទេពអប្សរហែរហម ប្រើស ទន្សោងតំណាងមារ ព្រាន មនុស្សព្រៃតំណាងដោះ(ទេវតាកាឡាខ្លួន)" ។

តាមមតិរបស់អ្នកស្រី ហ្គ បូរ៉ែ របាំត្រុដិដែលគេនិយមកន្ទុយក្ងោក ដោយហេតុថាជនជាតិអាស៊ី យើងនិយមទុកសត្វនេះជាតំណាងព្រះអាទិត្យ ដែលជំនឿជំនាន់ដើមទុកជាអាទិទេពមួយដែរ។ មនុស្ស យើងត្រូវការបន់ស្រន់ចំពោះអាទិទេពឱ្យធ្វើអំណោយទឹកភ្លៀងគ្រប់គ្រាន់សម្រាប់ធ្វើស្រែចំការ។ ហេតុនេះបានជាកាលណាគ្មានភ្លៀង គេលេងត្រុដិសុំទឹកភ្លៀង។ នៅពេលចូលឆ្នាំគេនិយមលេងត្រុដិ កំចាត់ឧបទ្រពផង ថ្វាយព្រះអាទិត្យផង ដើម្បីអង្វរករសុំទឹកភ្លៀងឱ្យស្រេចតាំងពីដើមឆ្នាំទៅដូចគ្នានឹង ទម្លាប់ជនជាតិចិនហែក្បាលតោ ហែនាគនៅរាល់ពេលចូលឆ្នាំនោះដែរ។

របាំស្នែងទន្សោង : ហេតុបានជាគេឱ្យឈ្មោះបែបនេះ ព្រោះនៅពេលរាំគេពាក់ស្នែងទន្សោង នៅលើក្បាល ហើយគេធ្វើកាយវិការត្រាប់តាមសត្វទន្សោង។ អ្នកភូមិអញ្ចាងរួង ស្រុកបរិបូណ៌ ខេត្ត កំពង់ឆ្នាំងបានចេះចាំរឿងនិទានមួយដែលទាក់ទងនឹងរបាំស្នែងទន្សោង។ ឯរឿងព្រេងនោះ មាន សេចក្តីអាទិ៍ថា កាលនោះមានព្រានព្រៃម្នាក់ឈ្មោះព្រានពរបានទទួលព្រះរាជបញ្ជាពីព្រះរាជាឱ្យទៅ រកបាញ់ទន្សោង។ នៅទីបំផុតព្រាននោះត្រឡប់មកគាល់ព្រះរាជាវិញដោយដៃទទេ ហើយរៀបរាប់ ទូលព្រះរាជាថាខ្លួនបានជួបប្រទះទន្សោងមួយគូ ញីឈ្មោលចេះរាំយ៉ាងល្អប្លែកនាំឱ្យខ្លួនជក់មើលពុំអាច បាញ់វាកើតឡើយ។ ម្យ៉ាងវិញទៀតមានខ្លាធំមួយដែលបំរុងនឹងចាប់ទន្សោងដែរនោះក៏ចាប់មិនកើត បែរជាជួយគោះជើងជាចង្វាក់ឱ្យសត្វនោះវិញ ហើយនៅជុំវិញទន្សោងនេះមានកន្លង់មួយហ្វូង ហើរ ប្រទក្សិណដោយបញ្ចេញសូរសៀងជួយធ្វើជាភ្លេងកំដរយ៉ាងពីរោះថែមទៀតផង។ ព្រះរាជាលុះទ្រង់ សណ្តាប់សព្វគ្រប់ ហើយត្រាស់ប្រើឱ្យព្រានពរធ្វើត្រាប់តាមទស្សនីយភាពនោះ ថ្វាយព្រះអង្គទត។ ការសម្តែងកាយវិការរបស់ព្រានពរនេះហើយ ដែលនាំឱ្យកើតរបាំស្នែងទន្សោងនេះឡើងដែលមាន អ្នកពាក់ស្នែងពីរនាក់តំណាងទន្សោងញីឈ្មោល សំឡេងផ្គរតំណាងសន្ធឹកខ្លា សំឡេងខ្លួយ(ប្រជាប់ផ្លុំ ពីរោះដូចខ្លុយដែរ)តំណាងសូរសព្ទកន្លង់។ ការស្រាវជ្រាវរបស់លោក **រ.បារាដាត** (R.Baradat) ជាតិបារាំង បានឱ្យដឹងថា របាំស្នែងទន្សោងមានដើមកំណើតឡើងពីជនជាតិមួយហៅថា ព័រ ដែល ច្រើនរស់នៅតាមជួរភ្នំក្រវាញ ស្រុកភ្នំក្រវាញ (ខេត្តពោធិ៍សាត់) ស្រុកភ្នំស្រួច(ខេត្តកំពង់ស្ពឺ) ស្រុក ទឹកផុស(ខេត្តកំពង់ឆ្នាំង) និងស្រុកកំពង់សោម(ខេត្តព្រះសីហនុ)។ ដោយព្រានពរជាសាសន៍ព័រ គេក៏ សន្និដ្ឋានថា របាំស្នែងទន្សោងប្រាកដជាកេរតំណែរពីជនជាតិព័រសម្រាប់លេងនៅពេលប្រកបពិធីមួយ យកលំនាំតាមរបរគ្នាគេជាអ្នកប្រមាញ់។ ប៉ុន្តែតាមមតិខ្មែរយើងខ្លះថាំថា គេលេងរបាំនេះនៅក្នុងវាំង តែក្នុងព្រះរាជពិធីបុណ្យចូលឆ្នាំ។

របាំគោះអង្រែ : កាលពីសម័យដើម គេនិយមលេងរបាំគោះអង្រែសឹងតែគ្រប់ភូមិស្រុក ប៉ុន្តែ មកដល់សព្វថ្ងៃរបាំនេះនៅសេសសល់បន្តិចបន្តួចតែក្នុងកន្លែងណាដែលមានអ្នកចង់ថែរក្សាទុកនូវ ប្រពៃណីនេះ ឬកន្លែងណាដែលឆ្ងាយពីទំនាក់ទំនងជាមួយអរិយធម៌បរទេសដូចជា សំរោងចុងកាល់ ជាំក្សាន្តជាដើម។ លោក **គុយ ហួត** បានរាយការណ៍ថា អ្នកស្រុកសូទ្រនិគមហៅរបាំគោះអង្រែថា **របាំក្ងួយនិងរាំក្ងួយ** ឃើញថាមានជាប់ឈ្មោះកុលសម្ព័ន្ធខ្មែរដើមមួយហៅថា ក្ងួយ ដែលជាហេតុនាំឱ្យ

គេសន្និដ្ឋានថា របាំគោះអង្រែមានដើមកំណើតមកពីសាសន៍កួយនេះឯង។ ឯកសារឆ្លើយឆ្លងពីសមាជិកនៃក្រុមជំនុំទំនៀមទម្លាប់បានឱ្យដឹងថា របាំនេះចម្លងមកពីប្រទេសហ្វីលីពីនតាំងពីរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម កាលដែលព្រះអង្គទ្រង់យាងទៅក្រុងម៉ានីល ហើយពួកបរិពារព្រះអង្គក៏បានរៀបចំរបាំនេះយកមកលេងនៅប្រទេសខ្មែរយើង។ ប៉ុន្តែនៅមានមតិមួយទៀតយល់ឃើញថា ជនជាតិកួយក្តី ហ្វីលីពីនក្តី សុទ្ធតែជាអ្នកមានកំណើតដើមបង្កើតអរិយធម៌អូស្ត្រូអាស៊ីដូចគ្នា។ ដូច្នេះរបាំគោះអង្រែនេះមានដើមកំណើតមកពីមនុស្សជាន់ដើមទាំងនោះ មិនប្រាកដថាជារបស់ជនជាតិណាតែម្នាក់ឯងឡើយ។

របាំយីកេ : ខ្មែរយើងនិយមលេងរបាំយីកេនេះតាំងពីយូរយារណាស់មកហើយ។ គេច្រើនលេងរបាំយីកេនៅពេលបុណ្យទាន ឬនៅពេលលំហែពីកិច្ចការស្រែចំការ។ គេតែងបង្កើតវង់របាំយីកេប្រចាំភូមិស្រុករបស់គេ ហើយដែលមានអ្នកស្រុកស្រីប្រុសក្មេងចាស់ចូលរួមក្នុងវង់របាំនេះដែរ។ ម្ល៉ោះហើយរបាំនេះក៏មានការរីកចម្រើនលូតលាស់ ដោយសារការនិយមរាប់អានយ៉ាងខ្លាំងអំពីសំណាក់អ្នកស្រុកនេះឯង។ ប៉ុន្តែ របាំនេះខ្សត់ខ្សោយទៅវិញ នៅគ្រាដែលប្រទេសយើងមានការកើតចលាចលក្នុងរវាងដើមសតវត្សទី ១៩ រហូតដល់សម័យអាណាព្យាបាលបារាំង។ ចាប់ពីក្រោយពេលនោះមករបាំយីកេក៏មានជីវិតឡើងវិញ។ ចំពោះប្រភពនៃរបាំយីកេអ្នកស្រាវជ្រាវខ្លះបានឱ្យដឹងថារបាំនេះមានកំណើតមកពីជ្វា ឬម៉ាលយូរហើយទំនងចូលមកស្រុកខ្មែរតាមរយៈព្រះបាទជ័យវរ្មនទី ២ដែលយាងទៅគង់នៅប្រទេសជ្វាអស់ពេលយ៉ាងយូរ ឬតាមរយៈចាម។

របាំឆៃយ៉ាំ : គេនិយមលេងរបាំនេះជាញឹកញាប់ក្នុងពិធីបុណ្យទានដូចជា បុណ្យផ្កា កឋិន បំបួសនាគជាដើម។ របាំឆៃយ៉ាំធ្វើឱ្យបរិយាកាសមានសភាពអឺកធឺកណាស់ ព្រោះចង្វាក់ភ្លេងមានសន្ទុះហឹកហ៊ាក់ស្របតាមកាយវិការលោតចុះឡើង ញាក់មុខ ញាក់ខ្លួន ក្រមាច់ក្រមើមគួរឱ្យអ្នកស្តាប់ឬអ្នកមើលរីករាយជាខ្លាំង។ ការស្រាវជ្រាវប្រវត្តិនៃរបាំនេះ ពុំទាន់បានលទ្ធផលច្បាស់លាស់នៅឡើយទេ ប៉ុន្តែគេអាចសន្និដ្ឋានបានខ្លះថា របាំនេះប្រាកដជាមានសំណល់ពីអរិយធម៌មនុស្សជាន់ដើមលើទឹកដីខ្មែរនេះឯង។

របាំរាំវង់ : បានជារបាំនេះមានឈ្មោះថា **រាំវង់** ព្រោះរបាំនេះប្រព្រឹត្តទៅជុំវិញតុផ្កា មានគូប្រុសស្រីដើររាំបន្តបន្ទាប់គ្នាជាវង់មូល។ លាវហៅរបាំនេះថា ឡាំលាវឬឡាំកេន ឯសៀមហៅថា ឡាំថួន។តាមពិតរបាំរាំវង់ជាសិល្បៈចាស់បុរាណ ដែលប្រភពដើមនៅប្រទេសខ្មែរយើងនេះឯង។ ប៉ុន្តែរបាំនេះក្រោយមកជនជាតិជិតខាងយកទៅពត់បត់បែនតាមរបៀបគេរួចហើយ ទើបចូលមកប្រទេសខ្មែរវិញ។សព្វថ្ងៃរបាំនេះក្លាយជារបាំប្រជាប្រិយទៅហើយ។ គេតែងតែសង្កេតឃើញនៅគ្រប់ខេត្តមានការនិយមរាំវង់ ជាពិសេសនៅពេលបុណ្យចូលឆ្នាំ។ ជួនកាល គេរាំនៅពេលទំនេរពីការងារ ឬនៅក្នុងពិធីជប់លៀង ក្នុងឱកាសពិធីអាពាហ៍ពិពាហ៍ និងក្នុងពិធីបុណ្យទានក្នុងគ្រួសារដែរ។

របាំក្ងោក : ជារបាំដែលគេប្រទះឃើញជាពិសេសនៅតំបន់ប៉ៃលិន ។ បណ្តាជនបរប៉ៃលិនច្រើនជាជនជាតិកុឡា ដែលចូលសញ្ជាតិខ្មែរ ។ ពេលចូលឆ្នាំ គេនិយមរាំក្ងោកឱ្យបណ្តាជនមើលកំសាន្ត ។ តាមមតិរបស់អ្នកស្រុកបរប៉ៃលិនថា របាំក្ងោកមានប្រវត្តិទាក់ទងនឹងរឿងព្រេង ។ ប៉ុន្តែ បើតាមការស្រាវជ្រាវ របាំក្ងោកនេះសេសសល់ពីអរិយធម៌អូស្ត្រូអាស៊ីដូចរបាំប្រជាប្រិយដទៃទៀតដែរ ។ រីឯទំនុកច្រៀងនៃរបាំនេះនៅជាពាក្យកុឡានៅឡើយ ដែលមានន័យថាជាសេចក្តីបួងសួងប្រសិទ្ធពរជ័យដល់អ្នកស្រុកឱ្យបានសុខចម្រើនឱ្យមានទឹកភ្លៀងគ្រប់គ្រាន់ឱ្យដីកដីរកស្រូងបានផលល្អ ។ល ។

ក្រៅពីរបាំប្រជាប្រិយដែលរៀបរាប់រួចមកហើយនៅមានរបាំប្រជាប្រិយខ្លះទៀតដែរ ដែលសព្វថ្ងៃមិនសូវនិយមយកមកលេងកំសាន្តដូចជា របាំបុកអង្រែ របាំកន្តែរ៉ែ របាំសួព្រ័ត្រ របាំគោះត្រឡោក របាំវាយក្រាប់ របាំវាយកួយជាដើម ។

ខ. របាំតន្ត្រី

កាលពីសម័យមុនគេហៅរបាំតន្ត្រីនេះថា របាំព្រះរាជទ្រព្យ ព្រោះជារបាំរបស់ស្តេច ហើយគេនិយមលេងតែក្នុងវាំងស្តេច ដូចជាលេងនៅពេលបួងសួង លេងថ្វាយអាទិទេព និងថ្វាយវិញ្ញាណខ័ន្ធស្តេចដែលបានចូលទិវង្គតទៅហើយ ។ របាំនេះមានកំណើតយូរយារណាស់មកហើយ ។ លុះដល់សម័យអង្គរគេបានឆ្លាក់រូបទេពអប្សរដែលជាស្ត្រីរបាំចុះពីលើស្ថានសួគ៌មករេរាំនៅតាមជញ្ជាំងប្រាសាទ ។ ផ្នែកខ្លះនៃរបាំនេះបានដកស្រង់អំពីរឿងរាមកេរ្តិ៍ រឿងមហាភារតៈ និងរឿងព្រេងខ្មែរ ។ ក្រៅពីរបាំដែលទាក់ទងនឹងរឿងរ៉ាវទាំងនេះមានរបាំថ្វាយពរ របាំទេពមនោរម្យ របាំមេអំបៅ របាំស្វា របាំដាវ ។ល ។ ឯការដែលគួរឱ្យចាប់អារម្មណ៍ចំពោះរបាំតន្ត្រី ឬរបាំក្បាច់បុរាណនេះ គឺកាយវិការនីមួយៗមានន័យមួយ ហើយសភាពទន់ភ្លន់សុភាពសមតាមចិត្តគំនិតខ្មែរ ដែលជាអ្នកនិយមសុខសន្តិភាព ។ សម័យបច្ចុប្បន្នរបាំក្បាច់បុរាណនេះ ត្រូវបាននាំទៅលេងឯបរទេសជាញឹកញាប់ ។

(ដកស្រង់និងកែសំរួលចេញពីឯកសារអរិយធម៌ខ្មែររបស់អ្នកស្រី ត្រឹង ងារ)

សំណួរ

១. តើភ្លេងខ្មែរមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ? ចូររៀបរាប់ ។

២. ដូចម្តេចហៅថារបាំប្រជាប្រិយ ? តើខ្មែរយើងមានរបាំប្រជាប្រិយអ្វីខ្លះ ? ចូររៀបរាប់អំពីរបាំទាំងនោះ ។

៣. តើ "របាំតន្ត្រី" មានន័យយ៉ាងដូចម្តេច ? តើរបាំតន្ត្រីមានប្រភពមកពីណា ? មានអ្វីជាភស្តុតាងបញ្ជាក់ពីប្រវត្តិនិងអត្ថន័យនៃរបាំនេះ ?

៤. ចូរអ្នកបង្ហាញពីលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នានៃរបាំគោះអង្រែ របាំយីកេ របាំឆៃយ៉ាំ និងរបាំរាំវង់ ។ តើរបាំខាងលើនេះបានបង្កប់នូវអត្ថសញ្ញាណជាតិយ៉ាងណាខ្លះ ?



វិធីតែងនិពន្ធ

ស្នាដៃនិពន្ធ គឺជាការប្រមូលផ្តុំនូវសកម្មភាពអក្សរសិល្ប៍ សិល្បៈ(និយាមសិល្បៈ) ដោយមានកត្តាវត្ថុ វិស័យកត្តាប្រធានវិស័យ មានកាលអាកាសពិតប្រាកដ។ ការនិពន្ធស្នាដៃអក្សរសិល្ប៍មិនមែនសរសេរជារបៀបរបាយការណ៍ដូចសារព័ត៌មានទេ តែជាការធ្វើទូទៅកម្មទៅលើតថភាព (វត្ថុវិស័យនិងប្រធានវិស័យ) ដោយបញ្ចូលធាតុសិល្បៈ ចេះលើកយករឿងរ៉ាវមួយមក ធ្វើជារឿងរ៉ាវរបស់មនុស្សទូទៅនិងធ្វើឱ្យយើងមើលឃើញនូវអ្វីធម្មតាក្នុងភាពមិនធម្មតានិងមើលឃើញនូវអ្វីមិនធម្មតាក្នុងភាពមិនធម្មតា។ អ្នកនិពន្ធមិនត្រឹមតែសរសេរឆ្លុះបញ្ចាំងឱ្យឃើញតថភាពទេ តែត្រូវសរសេរមានលក្ខណៈធំជាងនិងមានលក្ខណៈពិសេសជាងរបាយការណ៍។

ក. រូបារម្មណ៍

ចំពោះបញ្ហារូបារម្មណ៍ត្រូវ ៖

- ចេះបង្កើតតួអង្គដែលតំណាងឱ្យចិត្តគំនិត ទស្សនៈ ឧត្តមគតិផ្ទាល់របស់ខ្លួន(មានន័យថាត្រូវមានតួអង្គច្បាស់លាស់ តួអង្គណាទំនាស់ជាមួយតួអង្គណា)។
- ចេះបង្កើតប្រព័ន្ធហេតុការណ៍ ប្រព័ន្ធហេតុការណ៍មានសារៈសំខាន់ណាស់ ព្រោះវាជាកត្តាបង្កើតតួអង្គ ហើយត្រូវរៀបចំព្រឹត្តិការណ៍ណាខ្លះ ? តួអង្គចេញនៅទីណា ? ជួបហេតុការណ៍អ្វីខ្លះ? តួអង្គមានទំនាក់ទំនងគ្នាបែបណា ? មានបញ្ហាអ្វីកើតឡើង ? ជាមួយនឹងការតែងនិពន្ធនេះដែរ អ្នកនិពន្ធក៏មានការពាក់ព័ន្ធជាមួយនឹង ៖
  - សមត្ថភាពលំនឹក (ការនឹកឡើងវិញអំពីដំណើររឿង) សមត្ថភាពលំនឹកពុំមែនអាចមាននៅគ្រប់អ្នកនិពន្ធនោះទេ។ អ្នកនិពន្ធត្រូវការសកម្មភាព ឬសមត្ថភាពខាងលំនឹក ដើម្បីកុំឱ្យការតែងនិពន្ធមានភាពច្របូកច្របល់។ *ឧទាហរណ៍ :* អ្នកនិពន្ធ **ហ្គឺត** មានសមត្ថភាពលំនឹកខ្ពស់នៅក្នុងរឿងខ្លះ គាត់សរសេរមិនទាន់ចប់ដោយទុកចោល ៣០ឆ្នាំ ប៉ុន្តែគាត់នៅតែចងចាំដំណើររឿងបានល្អ។
  - បុគ្គលិកលក្ខណៈរបស់អ្នកនិពន្ធ អ្នកនិពន្ធម្នាក់ៗតែងមានស្រាប់នូវទឹកចិត្ត សញ្ចេតនា ឧត្តមគតិ ទំនោរអត្តចរិត។ ចំណែកឯតថភាពខាងក្រៅ ដែលអ្នកនិពន្ធត្រូវលើកយកមកបង្ហាញត្រូវឆ្លងកាត់ចិត្តគំនិត ឧត្តមគតិ សញ្ចេតនា ទំនោរទាំងនោះយ៉ាងជោគជាំ មានន័យថា អ្នកនិពន្ធមិនមែនជាម៉ាស៊ីនស្ងួយប្រវត្តិ មានលក្ខណៈបែបមនុស្សយន្តទេ។ ការរចនា គឺជាអត្តចរិត ហើយអត្តចរិតនេះកើតឡើងដោយសារស្ថានភាពសង្គម(គ្រួសារ សាលារៀន

មជ្ឈដ្ឋានជុំវិញ) សញ្ចេតនា > ចិត្តវិភេទ > មានឧត្តមគតិ។ គេមិនអាចបង្ខំសិល្បៈកវឱ្យមានសកម្មភាពស្មោះត្រង់ដូចរូបថត ឬម៉ាស៊ីននោះទេ ប៉ុន្តែត្រូវមានអ្វីមួយទៀតដែលជ្រាលជ្រៅនិងធំធេងជាងនេះ គឺអ្នកនិពន្ធត្រូវមានឧត្តមគតិដោយឡែក។ នៅពេលមានស្នាដៃណាមួយ អ្នកនិពន្ធត្រូវប្រឈមនឹងសំណួរថា តើអ្នកជាមនុស្សប្រភេទណា ? តើអ្វីដែលអ្នកខុសប្លែកពីអ្នកនិពន្ធដទៃ ? តើអ្នកអាចនិយាយប្រាប់ខ្ញុំនូវអ្វីដែលថ្មីបានទេ ?ល។ មនុស្សម្នាក់ៗមានគ្រប់គ្រាន់នូវធនធានរបស់ខ្លួន ដូច្នេះគេត្រូវតែចម្រាញ់ ឬរៀបចំធនធានទាំងនោះប្រើឱ្យបានមានន័យថា អ្នកនិពន្ធត្រូវយកអ្វីដែលជាទេពកោសល្យរបស់ខ្លួនមកប្រើប្រាស់ ដើម្បីបង្កើតស្នាដៃអក្សរសិល្ប៍។ មនុស្សទាំងអស់តែងមានចំណង់ គឺអាចធ្វើជាអ្នកនិពន្ធបាន ព្រោះស្នាដៃអក្សរសិល្បៈនោះកើតចេញពីស្រមោលនៃស្មារតីរបស់មនុស្សក្រោមឥទ្ធិពលដ៏ស្មុគស្មាញនៃចំណង់របស់អ្នកនិពន្ធ។ អ្នកនិពន្ធត្រូវមានទំនាក់ទំនងជាមួយសង្គម មិនឯកកោគឺត្រូវមានចំណេះដឹងខាងប្រវត្តិសាស្ត្រ ភូមិសាស្ត្រ សីលធម៌ថែមទៀតផង។ អ្នកនិពន្ធត្រូវឆ្លុះបញ្ចាំងឱ្យឃើញនូវទស្សនៈពិភពខាងក្នុង ឬទស្សនៈពិភពខាងក្រៅ ដែលជាតថភាពរបស់សង្គម។

ខ. មាគ៌ាឆ្ពោះទៅរកទេពកោសល្យ

នៅក្នុងទស្សនវិជ្ជា បើយើងមិនទៅមុខមិនមែនមានន័យថា យើងនៅមួយកន្លែងទេ ប៉ុន្តែយើងដើរថយក្រោយ។ ដូច្នេះយើងត្រូវយកលក្ខណសម្បត្តិទៅអនុវត្ត ដើម្បីជាកម្លាំងចលករឆ្ពោះទៅរកទេពកោសល្យ ពោលគឺត្រូវតែខំហាត់ពត់ខ្លួន ដើម្បីឈានទៅរកភាពល្បីល្បាញបាន។ ឧត្តមគតិ គឺជាផ្កាយឬព្រះចន្ទ សម្រាប់នាំផ្លូវ ប្រសិនបើយើងមិនអាចក្លាយជាព្រះចន្ទបំភ្លឺលោកបានទេ គួរតែយើងជាចង្កៀងតូចមួយសម្រាប់បំភ្លឺអ្នកជិតខាង។ ដូច្នេះសមត្ថភាពចាំបាច់ដំបូង គឺការគួបផ្សំទេពកោសល្យដែលមានតាំងពីកំណើត រួមបញ្ចូលជាមួយនៃទុននៃជីវិតដែលប្រមូលផ្តុំបទពិសោធក្នុងជីវិតមកសម្តែងក្នុងអក្សរសិល្ប៍។ ក្រៅពីទេពកោសល្យនិងទុនជីវិត អ្នកនិពន្ធត្រូវមានទុនវប្បធម៌ ទុនវិជ្ជាជីវៈថែមទៀត គឺត្រូវចេះសរសេរ ចេះរៀបតាក់តែង និងរបៀបរបបរបស់អ្នកនិពន្ធ ជាពិសេសអ្នកនិពន្ធត្រូវមានឆន្ទៈថែមទៀតផង។

គ. ដំណួចគំនិត

ដំណួចគំនិត : មានន័យថា ការប្រមូលគំនិត ប្រមូលអារម្មណ៍ ឬការផ្តោតគំនិតឱ្យមូលដើម្បីសរសេរ។ ក្នុងដំណើរការតែងនិពន្ធយើងសង្កេតឃើញថា មានទស្សនៈជាច្រើនដែលយល់ដឹងនិងមាន

បទពិសោធខុសៗគ្នា។ អ្នកនិពន្ធខ្លះ គិតគួរអំពីប្លង់ មុនពេលចាប់ផ្តើមតែងនិពន្ធ ប៉ុន្តែអ្នកនិពន្ធខ្លះទៀតពុំត្រូវការប្លង់ឡើយ គឺគេអាចចាប់ផ្តើមសរសេររឿងតែយកតែម្តង។ ឥឡូវនេះ យើងចាប់ផ្តើមមើលដំណាក់ដំបូង(ដំណាក់កាលទី ១) គឺដំណួចគំនិតរបស់យើង។ ដំណួចគំនិត គឺជាបញ្ហាលេចធ្លោបំផុត មានលក្ខណៈប្រមូលផ្តុំបំផុត ដែលផុសឡើងក្នុងអារម្មណ៍កវីអ្នកនិពន្ធ ក្នុងកាលៈទេសៈណាមួយ មុនពេលចាប់ផ្តើមសរសេររឿង។ ដំណួចគំនិតអាចកើតឡើងក្នុងអារម្មណ៍មនុស្សគ្រប់ស្រទាប់ពលករ សិប្បករ ... កវីនិពន្ធតែងមានពន្លក ឬការនឹកស្រមៃ។ ដំណួចគំនិត គឺជាកត្តាប្រធានវិស័យរបស់អ្នកនិពន្ធ។ អ្នកនិពន្ធដែលមានទេពកោសល្យខ្ពស់ គេមិនសូវគិតអំពីបញ្ហាដំណួចគំនិតនោះទេ ប៉ុន្តែគេខិតខំពិចារណារកកម្មវត្ថុឬបញ្ហាដែលត្រូវសរសេរឱ្យបានច្បាស់លាស់។ អ្នកនិពន្ធស្តង់ដាល (Standal) បានខកចិត្តក្នុងការរង់ចាំដំណួចគំនិតអស់រយៈពេល ១០ឆ្នាំអត់បានផលប្រយោជន៍អ្វីទាំងអស់។ អ្នកនិពន្ធហ្សូឡា (Zola) គាត់តែងអង្គុយរង់ចាំដំណួចគំនិត ដូចអ្នកលក់ដូរអង្គុយចាំអ្នកទិញ។ អ្នកនិពន្ធហ្សកសង់ (J.Sand) តែងប្រើប្រាស់ពេលវេលាសរសេរយ៉ាងទៀងទាត់បំផុត។ គាត់បាននិយាយថា "**បើគ្មានដំណួចគំនិតទេ គាត់មិនអាចសរសេរបានមួយថ្ងៃពីរសន្លឹកទេ**"។ លោកប៊ែរ ស៊ុន (Berg Son) បានពោលថា ដំណួចគំនិត គឺជអព្ភូតរញ្ជាណមួយនៅក្នុងខួរក្បាលអ្នកនិពន្ធ ឬសហជញ្ញាណ(ញាណដែលកើតឡើងឯងៗ) វាជាជំនួយយ៉ាងពិសេស។ អ្នកដែលនិយាយបានល្អមិនចេះចប់ គឺអ្នកដែលមានសហជញ្ញាណនេះឯង។

ឃ. ដំណាក់កាលតែងនិពន្ធ

ក្នុងតែងនិពន្ធមាន ៥ដំណាក់កាល ៖

១. ភ្នកគំនិត ជាដំណាក់កាលតែងនិពន្ធស្មាដៃអក្សរសិល្ប៍។ ភ្នកគំនិតកំណត់ទៅលើគំនិតតែងនិពន្ធជាប្រធានរឿង ឬកំណត់ប្រធានបទ។ គឺជាដំណាក់ដំបូង ព្រោះវាប្រមូលផ្តុំឆន្ទៈសំដៅទៅរកអ្វីដែលជាក់លាក់។ អ្នកខ្លះភ្នកចង់សរសេរពីសាសនា ខ្លះភ្នកចង់សរសេរពីនយោបាយ និងខ្លះទៀតចង់សរសេរពីស្នេហា ... ។ ចំពោះបញ្ហាភ្នកគំនិតរបស់មនុស្សម្នាក់ៗ តែងតែខុសៗគ្នានៅចំពោះមុខកម្មវត្ថុតែមួយ។ *ឧទាហរណ៍ :* នៅពេលឃើញមរណភាព ឬអត្តឃាតនារីណាម្នាក់ អ្នកនិពន្ធម្នាក់ៗតែងមានការភ្នកគំនិតខុសៗគ្នា។ ខ្លះយល់ថា មកពីបញ្ហាសង្គម ខ្លះថាមកពីបញ្ហាគ្រួសារ ហើយខ្លះទៀតថាមកពីបញ្ហាស្នេហា ... ។

២. ការប្រមូលផ្តុំឯកសារ ដើម្បីចៀសវាងការសសេរឃ្លាតឆ្ងាយពីតថភាព អ្នកនិពន្ធត្រូវមានឯកសារជាកំណត់។ *ឧទាហរណ៍ :* រឿងភូមិតិរច្ឆាន អ្នកនិពន្ធប្រមូលផ្តុំឯកសារជាច្រើនដែលទាក់ទងទៅនឹងដំណើររឿង។

អ្នកនិពន្ធត្រូវស្គាល់ឱ្យបានច្បាស់លាស់ពីទីតាំងភូមិសាស្ត្រ ស្រុក ខេត្ត ... ពោលគឺទាមទារឱ្យអ្នកនិពន្ធចូលឱ្យជិតនឹងព្រឹត្តិការណ៍។ *ឧទាហរណ៍ :* បើចង់សរសេរពីសង្គ្រាម អ្នកនិពន្ធត្រូវដឹងពីព្រឹត្តិការណ៍នៃសង្គ្រាម ព្រមទាំងត្រូវដឹងពីឯកសារសំងាត់ខ្លះៗទៀតផង។

៣. ការកសាងទម្រង់ ការកសាងទម្រង់ ឬគំរោងរឿងមានលក្ខណៈសំខាន់ក្នុងការតែងនិពន្ធ។ អ្នកនិពន្ធជាទូទៅត្រូវធ្វើគំរោង ប៉ុន្តែក៏មានអ្នកនិពន្ធខ្លះសរសេររឿងដោយមិនត្រូវការគំរោងដែរ ដូចជា អ្នកនិពន្ធ ពុស្តឹន តុលស្តយ ជាអ្នករៀបចំគំរោងយ៉ាងសម្រិតសម្រាំងមុនពេលសរសេររឿង។ ប៉ុន្តែអ្នកនិពន្ធ ស្តង់ដាល ចាប់ផ្តើមសរសេរដោយពុំចាំបាច់គិតពីគំរោងឡើយ គំនិតផុសឡើងឯងៗក្នុងពេលសរសេរ។

៤. ដំណាក់សរសេររឿង ក្នុងដំណាក់កាលនេះ អ្នកនិពន្ធអាចធ្វើការផ្លាស់ប្តូរគំរោង។ ក្នុងពេលសរសេរ អ្នកនិពន្ធត្រូវផ្តាច់ខ្លួនចេញពីមជ្ឈដ្ឋានខាងក្រៅ ហើយចូលខ្លួនទៅក្នុងពិភពប្រលោមលោក។ ដំណាក់កាលសរសេរជាដំណាក់កាលពិបាកបំផុត។ អ្នកនិពន្ធចែកចេញជាពីរប្រភេទ គឺអ្នកនិពន្ធដែលសរសេរលឿននិងអ្នកនិពន្ធដែលសរសេរយឺត។

៥. ដំណាក់ជួសជុល រឿងដែលសរសេររួចត្រូវមានការជួសជុលឡើងវិញ។ ប៉ុន្តែមានអ្នកនិពន្ធមួយចំនួនមិនត្រូវការជួសជុលទេ ពីព្រោះគាត់យល់ថា "តួអង្គពេលសរសេរទេដែលជាអ្នកសរសេរ" ចំណែកអ្នកនិពន្ធខ្លួនគាត់មិនអាចកែប្រែបានឡើយ។ *ឧទាហរណ៍ :* ឡាម៉ាទីន (Lamatin) ជាកវីអណ្តែតអណ្តូងជាតិបារាំង បានចាត់ទុកស្នាដៃកំណាព្យរបស់គាត់ជាស្នាដៃគ្មានម្ចាស់ គ្មាននរណាមកប៉ះពាល់ ឬកែបានឡើយ។

ង. សិល្បវិធីក្នុងការតែងនិពន្ធ

ជាទូទៅអ្នកនិពន្ធតែងប្រើប្រាស់សិល្បវិធីមួយចំនួនដូចខាងក្រោម ៖

- វចនវិធី គឺការប្រើប្រាស់ពាក្យពេចន៍នៅក្នុងអត្ថបទ។ ពាក្យពេចន៍ត្រូវឱ្យស្របតាមស្ថានភាពសង្គម បរិយាកាស តួនាទី ឋានៈ មុខរបរ និងតាមប្រភេទនៃរឿងផងដែរដូចជា ពាក្យពេចន៍របស់កសិករ អាជីវករ មន្ត្រីរាជការ រាជស័ព្ទ សង្ឃស័ព្ទជាដើម។
- រចនាវិធី គឺការប្រើប្រាស់ឃ្លាល្អ ដើម្បីឱ្យស្នាដៃ ឬអត្ថបទរឿងមានសម្រស់ទាក់ទាញ អារម្មណ៍បង្កើតបាននូវបរិយាកាសអណ្តែងអណ្តូង រំភើបរីករាយ កើតទុក្ខ ព្រួយបារម្ភ ... ។
- សន្ទេហវិធី គឺជាវិធីដែលអ្នកនិពន្ធធ្វើឱ្យអ្នកអាន អ្នកទស្សនាងឿងឆ្ងល់ចង់តាមដាន ចង់ដឹងហើយចង់ដឹងទៀតអំពីបញ្ហាដែលកំពុងចោទនៅក្នុងដំណើររឿង។ ស្នាដៃអក្សរសិល្ប៍ សិល្បៈដែលគេចូលចិត្តអានតាមដានទស្សនា គឺអាស្រ័យលើអ្នកនិពន្ធមានទេពកោសល្យក្នុងការ

បញ្ចូលសន្ទេហាវិធីនេះឯងដូចជា ក្នុងរឿងទុំទាវ ពេលព្រះរាជាជ្រើសទាវទៅធ្វើស្នំ តើស្នេហាទុំទាវនឹងទៅជាយ៉ាងណា ? ពេលម្តាយទាវ កុហកទាវឱ្យមករៀបការជាមួយម៉ឺនងួន តើស្នេហាទុំទាវទៅជាយ៉ាងណា ?

- បដិវិធីឬវិធីផ្ទុយ គឺជាវិធីដែលអ្នកនិពន្ធប្រើសម្រាប់ធ្វើឱ្យតួអង្គមានទំនាស់វិបត្តិគ្នាខាងពាក្យសំដី កាយវិការ វាចា ចិត្ត។
- វណ្ណនាវិធី គឺជាវិធីដែលអ្នកនិពន្ធលើកយកតួអង្គ ព្រឹត្តិការណ៍ ធម្មជាតិ ទេសភាព សកម្មភាព មកពណ៌នារៀបរាប់ឱ្យឃើញច្បាស់ហាក់នៅនឹងភ្នែកស្រស់ៗ។
- ឧបមានវិធី គឺជាវិធីដែលអ្នកនិពន្ធធ្វើការប្រៀបធៀបតួអង្គ ឬសកម្មភាពនៅក្នុងដំណើររឿង ដើម្បីរំលេចនូវជីវរូបារម្មណ៍ ឬមនោរម្មណ៍។

ឧទាហរណ៍ : រឿងទុំទាវ មានវគ្គមួយលើកឡើងថា "ខ្លួនឯងសព្វថ្ងៃប្រៀបដូចផ្កា ខ្លួនអ្នកឧបមាដូចកន្លង់ ហើរកឃើញផ្កាចូលត្របត្រង់ រួចមិនបង្អង់ត្រាច់លីលា"។

- សំវាទវិធី គឺជាវិធីដែលអ្នកនិពន្ធធ្វើឱ្យតួអង្គពីរនាក់ឡើងសន្ទនាឆ្លើយឆ្លងគ្នាអំពីបញ្ហាអ្វីមួយ។
- វេសមវិធី គឺជាវិធីដែលអ្នកនិពន្ធបង្ហាញភាពផ្ទុយគ្នានៅក្នុងហេតុការណ៍ គំនិត រូបលក្ខណៈ ដើម្បីធ្វើឱ្យឃើញឬយល់កាន់តែច្បាស់ថែមទៀត។

ឧទាហរណ៍ : ក្នុងរឿងរាមកេរ្តិ៍ខ្សែទី ១ ពណ៌នារាងកាយកូនខ័ន "សត្តិសួនជាអ្នកថ្មើរព្រៃ ខ្លួនខ្មៅក្រៅវិស័យ នូវធ្មេញសស្តឹមភ្នែកច្រាល"។

- ឯកវាទវិធី គឺជាវិធីដែលគេធ្វើឱ្យតួអង្គរងទុក្ខទោសមានការឈឺចាប់ក្នុងខ្លួន ឬមានវិប្បដិសារីអំពីរឿងអ្វីមួយ ដោយមានការនិយាយរំលឹកអំពីហេតុភេទ ឬរឿងរបស់ខ្លួនតែម្នាក់ឯង។

ឧទាហរណ៍ : ក្នុងរឿងកុលាបប៉ៃលិន ចៅចិត្របាននិយាយម្នាក់ឯងថា "ឱ! ខ្លួនអញអើយ កណ្តោចកណ្តែងខ្លោចផ្សារតែម្នាក់ឯង ហើយបើងាកទៅពឹងបងប្អូនញាតិសាច់សារលោហិតជិតខាងឯណាក៏គ្មាន ..."។

- វឌ្ឍមានវិធី គឺជាវិធីដែលអ្នកនិពន្ធប្រើដើម្បីធ្វើឱ្យដំណើររឿងកាន់តែតឹងតែងឡើងៗតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់។
- ឧបកថាវិធី គឺជាវិធីដែលអ្នកនិពន្ធចែកដំណើររឿងជាដំណាក់ៗ។ មានន័យថា កំពុងតែនិយាយអំពីហេតុការណ៍ត្រង់នេះ ស្រាប់ដំណើររឿងត្រូវផ្អាក ហើយចាប់រឿងផ្សេងមកនិយាយវិញម្តង។

- សមន្តវិធី គឺជាវិធីដែលអ្នកនិពន្ធលើកយកតួអង្គដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នាធ្វើជាគូទំនាស់។ ដូច្នេះនៅក្នុងទំនាស់ មិនមានតួអង្គណាឈ្នះរហូតឡើយ ពោលគឺទោះបីតួអង្គល្អក្តី អាក្រក់ក្តី មានចាញ់មានឈ្នះគ្នាទៅវិញទៅមក។
- អបេក្ខណវិធី គឺជាវិធីពណ៌នាបង្ហាញតួអង្គឱ្យស្របទៅតាម កាយវិការ ចរិយា និងសកម្មភាព។
- បុនរុត្តិវិធី គឺជាវិធីតែងកាព្យ ដែលធ្វើឱ្យផ្ចួនពាក្យសំដីដែលអ្នកនិពន្ធប្រើដើម្បីបញ្ជាក់សម្មភាពរបស់តួអង្គឱ្យកាន់តែជាក់ស្តែងថែមទៀត។

  ឧទាហរណ៍ : នីកៗថាអេះ នាងនេះល្អម្ល៉េះ នេះហៅល្អល្អន់
  ត្រកាលឃើញម្តង នេះហោងហៅបុណ្យ គ្មានស្រីណាប៉ុន
  ល្អពន់ប្រមាណ។
  អេះនេះហៅល្អ ល្អចេះរកក្រ ក្រែកទៀតគ្មាន
  អញធ្លាប់ឃើញសព្វ នីករាប់ពុំបាន ពុំដែលឃើញមាន
  ឱ្យល្អដូច្នេះ។
- ហាសវិធី គឺជាវិធីដែលអ្នកនិពន្ធប្រើក្នុងដំណើររឿង ធ្វើឱ្យអ្នកអាន អ្នកស្តាប់ផ្ទុះសំណើចមិនដឹងខ្លួន។
- ប្រលោមវិធី គឺជាវិធីដែលអ្នកនិពន្ធចេះលួងលោម បញ្ចោសអង្អែលធ្វើឱ្យអ្នកអាន អ្នកស្តាប់រីករាយរំភើបតាមដំណើររឿង។
- ទារុណវិធី គឺជាវិធីដែលអ្នកនិពន្ធធ្វើឱ្យដំណើររឿងមានភាពកំសត់ព្រាត់ប្រាសនិងការធ្វើទុក្ខទោសតួអង្គ។ ចលនាអក្សរសិល្ប៍និងស្របទៅតាមសិល្ប៍វិធីរៀងៗខ្លួន។
  - ចលនាពុទ្ធិនិយម អ្នកនិពន្ធបានបញ្ចប់រឿងដោយការបានសម្រេចជោគជ័យក្នុងការកសាងបារមីរបស់តួអង្គពោធិសត្វ "ទសបារមី" ដោយមានការជួបជុំវង្សត្រកូលប្រពន្ធកូននិងដោយសរជាតិ។
  - ចលនាព្រហ្មនិយម អ្នកនិពន្ធបញ្ចប់ដោយធ្វើឱ្យសភាវៈល្អ តំណាងឱ្យទេវៈឈ្នះលើភាវៈអាក្រក់មានពួកយក្ស អាសុរ ...។
  - ចលនាខេមរនិយម អ្នកនិពន្ធបញ្ចប់ដោយពុំមានលក្ខណៈឯកភាពគ្នាទូទៅទេ គឺវាអាស្រ័យទៅតាមដំណើររឿងដែលមានឈ្នះ មានចាញ់ បានជួបជុំគ្នា ឬពុំបានជួបជុំបានសម្រេចបំណងឬពុំបានសម្រេចបំណង។

ការតែងរឿងប្រលោមលោក

អ្នកបានសិក្សារួចមកហើយអំពីប្រភេទអក្សរសិល្ប៍ លក្ខណៈអក្សរសិល្ប៍ ចលនាអក្សរសិល្ប៍ និងសិល្ប៍វិធីក្នុងការតែងនិពន្ធអក្សរសិល្ប៍។ នៅពេលនេះ អ្នកនឹងត្រូវតាក់តែងរឿងប្រលោមលោក ដែលមានកាលអាកាសច្រើន ព្រឹត្តិការណ៍ច្រើន និងស្មុគស្មាញ។ ដូច្នេះអ្នកត្រូវស្គាល់ចំណុចសំខាន់ៗមួយចំនួនរបស់រឿងប្រលោមលោក។ ក្នុងការតាក់តែងប្រលោមលោក អ្នកត្រូវយកចិត្តទុកដាក់លើចំណុចសំខាន់ៗបីធំៗ គឺអត្ថន័យ អត្តរូប និងអត្តរស។

ក. អត្ថន័យ

បង្ហាញពីបញ្ហាជីវភាពជាក់ស្តែងរបស់មនុស្សក្នុងសង្គមស្របទៅតាមវប្បធម៌ អរិយធម៌។ ពិសេសខ្លឹមសារនៃស្នាដៃប្រភេទនេះមានការទាក់ទងទៅនឹងសង្គមបរិយាកាសរបស់ខ្មែរ។ ដំណើររឿងកើតឡើងនៅក្នុងភូមិស្រុក ឬទីកន្លែងណាមួយដែលមានទំនាក់ទំនងនឹងការប្រកបអាជីវកម្មរបស់ខ្មែរពិត "ច្រើនតែជារឿងតថ"។ ដំណើររឿងមានលក្ខណៈតឹងតែង ធូរស្រាលប្រកបដោយជ័យជំនះបរាជ័យ មានស្លាប់ មានរស់ មានកំសត់ មានកំប្លែងលាយឡំគ្នា។

- មូលហេតុដែលនាំឱ្យមានទំនាស់វិបត្តិ គឺជាទំនាស់ដែលកើតមានក្នុងជីវភាពរស់នៅជាក់ស្តែងរបស់មនុស្សដូចជា ទំនាស់រវាងខ្លួនឯងនិងអ្នកដទៃ ទំនាស់រវាងខ្លួនឯងនិងគ្រួសារ ទំនាស់រវាងអ្នកដទៃនិងគ្រួសារ ទំនាស់រវាងខ្លួនឯងនិងសង្គម
- ជម្រៅនៃរឿង មានបញ្ហាចោទចំពោះមនុស្សលោកិយបច្ចុប្បន្ន ដោយអប់រំឱ្យខិតខំត្រិះរិះដោះស្រាយបញ្ហាក្នុងសង្គមមនុស្ស។ គេយករឿងរបស់មនុស្សមកចោទ ហើយដោះស្រាយតាមលក្ខណៈស្របទៅនឹងរឿងបច្ចុប្បន្ន រឿងពិតរបស់មនុស្ស។
- ដំណោះស្រាយបញ្ហា គឺតួអង្គពឹងលើសមត្ថភាពផ្ទាល់ខ្លួន ជំនះផ្លូវកាយ ផ្លូវចិត្ត ដើម្បីផ្គាញ់ឧបសគ្គក្នុងសង្គមនិងធម្មជាតិ។
- តួអង្គជាមនុស្សធម្មតា ចាប់ពីអ្នកបម្រើគេរហូតដល់វណ្ណៈអភិជន។ រវាងតួអង្គត្រូវមានលក្ខណៈសម្បត្តិ សមត្ថភាពប្រហាក់ប្រហែលគ្នា។

ខ. អត្ថរូប

អ្នកនិពន្ធប្រើប្រាស់សិល្បវិធីផ្សេងៗក្នុងការតែងនិពន្ធដូចជា សំវាទវិធី សន្ទេហាវិធី ឯកវាទវិធី វចនវិធី វណ្ណវិធី បដិវិធី វណ្ណនាវិធី រចនាវិធី ... ។

គ. អត្ថរស

តម្លៃរបស់អក្សរសិល្បស្តែងចេញពីការឆ្លុះបញ្ចាំងនូវតថភាពជាក់ស្តែង ការអប់រំ សីលធម៌ និង ស្នារតីជាតិនិយមពិតៗ។ អ្នកនិពន្ធបញ្ចូលនូវគំនិត យោបល់ ទស្សនៈ ដំបូន្មានរបស់ខ្លួនទៅក្នុងសកម្ម ភាពនៃរឿង។ ពាក្យពេចន៍ចរចាដើម្បីជាការិះគន់ ប្រដៅណែនាំ ទូន្មានអ្នកអាន អ្នកទស្សនា។ ដូច្នេះគេតែងប្រលោមលោកដោយប្រត្យក្សភាព ដើម្បីបង្កើតប្រត្យក្សរស ពោលគឺគេយកកំហុស គុណវិបត្តិ អំពើឆ្គាំឆ្គងរបស់មនុស្សដែលត្រូវគេរិះគន់សម្រាប់ណែនាំអប់រំមកបញ្ចូលក្នុងពាក្យសំដី សកម្មភាព កាយវិការរបស់តួអង្គយកទៅសម្តែងបង្ហាញទស្សនិកជនបានឃើញនឹងភ្នែក។ លក្ខណៈជា តម្លៃឃើញប្រត្យក្សនឹងភ្នែកនេះហើយ ដែលរឿងប្រលោមលោកផ្តល់នូវកុសលនិងការអប់រំសម្រាប់ ណែនាំទូន្មានប្រជាជន។

លំហាត់

ចូរវៀបគ្នាជាក្រុម រួចពិភាក្សាតែងរឿងប្រលោមលោក ដែលមានកាលអាកាសច្រើន ព្រឹត្តិ ការណ៍ច្រើន និងស្មុគស្មាញ។ ក្នុងការតាក់តែងអ្នកត្រូវផ្អែកទៅលើអត្ថន័យ អត្ថរូប អត្ថរស។

ល្ខោន



គ្រប់ជាតិសាសន៍ទាំងអស់ សុទ្ធតែមានសិល្បៈជាច្រើនប្រភេទទៅតាមការច្នៃប្រឌិតនិងការនិយមចូលចិត្តរបស់ពួកគេ។ ល្ខោន ជាសិល្បៈមួយប្រភេទដែលបញ្ជាក់ពីអត្តសញ្ញាណជាតិនីមួយៗ។ ខ្មែរយើងមានល្ខោនជាច្រើនប្រភេទដូចជា ល្ខោនបាសាក់ ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល (ស្បែកធំ ស្បែកតូច)។ល។ នៅសម័យមុនល្ខោនជាសិល្បៈដ៏មានប្រជាប្រិយភាព។ គេនិយមសម្តែងល្ខោនក្នុងពិធីផ្សេងៗមាន បុណ្យប្រពៃណីជាតិ បុណ្យជាលក្ខណៈគ្រួសារ បុណ្យជាតិ រាជពិធីបុណ្យ និងពិធីមហោស្រពសិល្បៈជាដើម។ បច្ចុប្បន្ន សិល្បៈល្ខោននៅតែជាទីនិយមចូលចិត្តរបស់ប្រជាជនយើង ពិសេសអ្នកមានវ័យចំណាស់។ ក្នុងនាមយើងជាពលរដ្ឋកម្ពុជា ត្រូវចូលរួមអភិរក្សនិងអភិវឌ្ឍអត្តសញ្ញាណជាតិនេះឱ្យបានគង់វង្សនិងរីកចម្រើន។

មេរៀននេះ អ្នកនឹងបានសិក្សាអំពីបំណិនមួយចំនួនទាក់ទងនឹងរឿងល្ខោនដូចជា ឈុត ឆាក វិធីបង្ហាញតួអង្គ លក្ខណៈសម្បត្តិតួអង្គ (ការវិភាគតួអង្គ) លក្ខណៈពិសេសរបស់ល្ខោន អត្ថន័យ អត្ថរូប អត្ថរស ខ្លឹមសារសំខាន់ៗ សង្ខេបរឿងឡើងវិញ និងតែងរឿងល្ខោនខ្នាតខ្លី។



វិធីបង្ហាញតួអង្គក្នុងរឿងល្ខោន

ល្ខោន គឺជាសិល្បៈមួយប្រភេទដែលអ្នកនិពន្ធចងក្រងឡើងសម្រាប់យកទៅសម្តែងលើឆាក ។ រឿងល្ខោនមានទាំងអត្ថបទសំណេរនិងការសម្តែង ។ វិធីបង្ហាញតួអង្គក្នុងរឿងល្ខោនស្រដៀងគ្នានឹងប្រភេទរឿងផ្សេងៗទៀតដែរ ។ គេសង្កេតឃើញថា រឿងល្ខោនមានវិធីបង្ហាញតួអង្គបួនបែប គឺការបង្ហាញដោយអ្នកនិពន្ធ ការបង្ហាញដោយតួអង្គខ្លួនឯង ការបង្ហាញដោយតួអង្គដទៃ និងការបង្ហាញតាមរយៈដំណើររឿង ឬសកម្មភាពតួអង្គ ។ ចូរអានរឿងខាងក្រោម រួចសង្កេតមើលវិធីបង្ហាញតួអង្គ ៖

តួអង្គនិងមុខងារ

- តេជោមាស : ជាស្វាមីជំទាវស្រែន មានងារជាតេជោបរមរាជត្រួតខេត្ត កំពង់ស្វាយ ។
- តេជោយ៉ត : ជាសិស្សតេជោមាស មានងារជាតេជោត្រួតខេត្ត កំពង់ស្វាយ ពេលតេជោមាសស្លាប់ទៅ ។
- ជំទាវស្រែន : ជាភរិយារបស់តេជោមាស ជាស្ត្រីដែលមានល្បិចឆ្មើមអាចចាប់ស្តេចសម្រែកត្បាត់ជាតិយកទៅកាត់ទោស ។
- ព្រះចៅជ័យចេស្តា : មហាក្សត្រខ្មែរគង់នៅក្រុងឧដុង្គមានជ័យ ។
- អ្នកម្នាងនួ : បងស្រីមុឺនចៃចុងរ៉ាក់និងជាអ្នកម្នាងរបស់ព្រះចៅជ័យចេស្តា ។
- ស្តេចសំរែ : មេបះបោរបម្រុងដណ្តើមរាជពីព្រះចៅជ័យចេស្តា ។
- ឧកញ៉ាពិភា : មន្ត្រីជំនិតរបស់ស្តេចសំរែ ។
- ឧកញ៉ាព្រះស្រី ទ្វារប្រាសាទដប់ : បម្រើការងារជាមួយតេជោមាសនិងតេជោយ៉ត ។
- នាងម៉ៃ : បុត្រីឧកញ៉ាស្រីទ្វារប្រាសាទដប់និងជាអ្នកស្រឡាញ់តេជោយ៉ត តែមិនបានសម្រេចក្លាយទៅជាប្ពន្ធធម៌របស់តេជោយ៉តទៅវិញ ។
- នាយឈិត : ឈ្លើយសឹកសៀមនិងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ ។
- មុឺនចៃចុងរ៉ាក់ : ប្អូនអ្នកម្នាងនួប្រឆាំងតេជោយ៉ត ហើយតេជោយ៉តចាប់ទៅសម្លាប់ចោលនិងមានតួអង្គរំលឹកជាច្រើន ។

ឆាកទី ១

តេជោមាស : ខ្ញុំឈ្មោះ "មាស" មានគោរម្យងារជាឧកញ៉ាតេជោបរមរាជ ...(ច្រៀង) តាំងចិត្តប្តេជ្ញាការពារទឹកដី ដូចជាប្រសើរក្នុងកែវនេត្រា(២ដង) ទោះត្រូវលះបង់អាយុសង្ខារ ក៏ចិត្តស្នេហាជាតិ មិនរសាយ ។ (និយាយ) ជិតដល់ពេលចេញដំណើរហើយតើ ! ឯណាយ៉ត ?

យ៉ត : បាទលោកគ្រូ !

តេជោមាស : កងទ័ពរបស់យើងបានរៀបចំរួចរាល់ហើយឬនៅ ?

យ៉ត : បាទ ! ខ្ញុំបាទត្រៀមរួចអស់ហើយ គឺយើងយកតែទ័ពសេះប៉ុណ្ណោះតាមការគ្រោងទុកណាលោកគ្រូ ។

តេជោមាស : អឺ ! ល្អហើយ(សូរសំឡេងសេះកញ្ជ្រៀវខ្ញៀវខ្ញារ ...) ។

ជំទាវស្រែន : បងគិតចេញដំណើរឥឡូវនេះឬ ?

តេជោមាស : ហ្នឹងហើយអូន ! ដល់ពេលវេលាបងហើយណា !

ជំទាវស្រែន : នេះថ្នាំព្យាបាលរបួសដែលបងតែងដាក់តាមខ្លួន អូនបានរៀបចំជូនបងសព្វគ្រប់អស់ហើយ ។

តេជោមាស : អឺ ល្អហើយ !

ជំទាវស្រែន : ហ៊ឺ ! រាល់ពេលមានកលយុគក្នុងនគរ បងតែងមានភារកិច្ចចេញធ្វើសឹកសង្គ្រាមជានិច្ច ។

តេជោមាស : ស្រែនអូន !

ជំទាវស្រែន : ថ៎សបង !

តេជោមាស : បានធ្វើពលិកម្មបម្រើជាតិយ៉ាងនេះ គឺជាកិត្តិយសមួយធំធេងណាស់អូន ។

ជំទាវស្រែន : ថ៎ស ! សូមបងប្រយ័ត្នប្រយែងណ៎ា ព្រោះអូនឮគេថា ស្តេចសំរែនោះខ្លាំងពូកែណាស់បង !

តេជោមាស : មិនអីទេអូន ! មិនអីទេ !

ជំទាវស្រែន : (ច្រៀង) អូនសូមជូនពរជោគជ័យ អឺ អឺង អឺយ (២ដង) ដល់រូបអ្នកប្តី អឺ អឺង អឺយ (២ដង) គូគាប់វាសនា សូមបងបានឈ្នះ លើពួកបច្ចា អឺ អឺង អឺយ ... ។

តេជោមាស : ស្រែនអូន ! នៅផ្ទះចូរថែរក្សាខ្លួនឱ្យបានសុខចុះណាកុំព្រួយបារម្ភដល់បង អឺ ! ណាអូន ។

ជំទាវស្រែន : ចាស ! បងជាមេទ័ពខ្លាំងពូកែធ្លាប់មានស្នាដៃក្នុងសឹកអូនតែងគិតដល់សុខទុក្ខរបស់បងជានិច្ចណ៎ា !

តេជោមាស : អឺ ! មែនហើយអូនកុំគិតច្រើនពេកណ៎ាអូនស្រែន ស្លាប់ក្នុងបុព្វហេតុការពារប្រទេសជាតិមាតុភូមិ ជាមហាកិត្តិយសដ៏ធំមែនទេអូន !

ជំទាវស្រែន : ថ៎ ឯណាយ៉ត ?

យ៉ត : បាទ !

ជំទាវស្រែន : បម្រើគ្រូឯងឱ្យដិតដល់មែនទែនណា៎ !

យ៉ត : បាទ ! សូមលោកជំទាវកុំបារម្ភឱ្យសោះ ។

តេជោមាស : ប្រពន្ធសំលាញ់ បងលាហើយណា៎ !

ជំទាវស្រែន : សូមបង ! ប្រកបតែជោគជ័យនិងសេចក្តីសុខណាបង !

តេជោមាស : សូមនៅឱ្យបានសេចក្តីសុខណាអូន បងលាសិនហើយ !

ជំទាវស្រែន : ចា៎ស ! ចា៎ស ! (ស្នូរជើងសេះចេញដំណើរ) ។

តាមរយៈសាច់រឿងខាងលើ យើងអាចសិក្សាពីវិធីបង្ហាញតួអង្គដូចតទៅ ៖

- វិធីបង្ហាញតួអង្គដោយអ្នកនិពន្ធ : សរសេររាយនាមតួអង្គ មុខងារ ប្រភពកំណើតរបស់តួអង្គនីមួយៗនៅខាងដើមអត្ថបទ ។ ចំពោះនៅក្នុងការសម្តែងវិញ វិធីបង្ហាញតួអង្គរបស់គេ គឺការប្រកាសឈ្មោះតួអង្គនៅក្នុងរឿងនិងឈ្មោះតួសម្តែងតំណាងនៅពេលចាប់ផ្តើមសម្តែងល្ខោន ។
- វិធីបង្ហាញតួអង្គដោយតួអង្គខ្លួនឯង : តួអង្គតេជោមាសបង្ហាញឈ្មោះនិងមុខងារដោយខ្លួនឯង ខ្ញុំឈ្មោះ "មាស" មានគោរម្យងារជាឧកញ៉ាតេជោបរមរាជ ។
- វិធីបង្ហាញតួអង្គដោយតួអង្គដទៃ : តួអង្គតេជោមាសបង្ហាញឈ្មោះតួអង្គយ៉ត : តេជោមាស ... (និយាយ) ជិតដល់ពេលចេញដំណើរហើយតើ ! ឯណាយ៉ត ? យ៉ត : បាទលោកគ្រូ !
- វិធីបង្ហាញតួអង្គតាមរយៈដំណើររឿង ឬសកម្មភាពតួអង្គ : តួអង្គជំទាវស្រែន លេចចេញមកដោយគ្មានអ្នកហៅនិងមិនបង្ហាញឈ្មោះខ្លួនឯងឡើយ គឺបង្ហាញខ្លួនតាមដំណើររឿងតែម្តង យ៉ត : បាទ ! ខ្ញុំបាទ ត្រៀម ... លោកគ្រូ ! តេជោមាស : អឺ ! ល្អហើយ (សូរសំឡេងសេះកញ្ជ្រៀវខ្ញៀវខ្ញារ ...) ។ ជំទាវស្រែន : បងគិតចេញដំណើរឥឡូវនេះឬ ? តេជោមាស : ហ្នឹងហើយអូន ... ។

> ***វិធីបង្ហាញតួអង្គ គឺជាការប្រាប់ពីឈ្មោះ អាយុ ឋានៈ ប្រភពកំណើតរបស់តួអង្គនីមួយៗនៅក្នុងរឿង ដើម្បីឱ្យអ្នកអាន ឬអ្នកទស្សនាបានស្គាល់ ។ វិធីបង្ហាញតួអង្គក្នុងរឿងល្ខោនមានបង្ហាញតួអង្គដោយ ៖ អ្នកនិពន្ធ តួអង្គខ្លួនឯង តួអង្គផ្សេងទៀត ដំណើររឿង ។***

លំហាត់

ចូរអ្នកអានអត្ថបទល្ខោននិយាយរឿង "ថៅកែចិត្តចោរ" របស់អ្នកនិពន្ធ ពៅ យូឡេងនិងអ្នកនិពន្ធ អ៊ុំ ឈឿន រួចប្រាប់ពីវិធីបង្ហាញតួអង្គក្នុងរឿង ។

រឿងតេជោយ័ត



ក. សិក្សាពាក្យគន្លឹះ

- កេណ្ឌ (កិ) : ប្រមូលហៅដោយអាជ្ញា កេណ្ឌពល ។
- ឃ្នាង (ន) : គ្រឿងមានកាំម្យ៉ាងសម្រាប់ដាក់កមនុស្សមានទោស ។
- ជំទាវ (ន) : បណ្ដាស័ក្តិសម្រាប់ស្ត្រីជាភរិយា ដោយព្រះករុណាជាម្ចាស់ជីវិត ទ្រង់ប្រោសព្រះរាជទានតាំងលោកជំទាវ (លោកស្រី) ។ បណ្ដាស័ក្តិនេះ ទោះបីភរិយារបស់មន្ត្រីស័ក្តិ ១០ហ៊ូពាន់ឯទៀតៗក្រៅពីសេនាបតីក៏ដោយ ស្រេចតែនឹងព្រះករុណាជាម្ចាស់ជីវិត បើទ្រង់ព្រះមេត្តាប្រោសព្រះរាជទានតាំងក៏បាន ។ បច្ចុប្បន្នងារនេះ ត្រូវបានគេប្រើសម្រាប់ភរិយារបស់ស្វាមីដែលមានងារជាឯកឧត្តមនិងសម្រាប់ស្ត្រីដែលមានឋានៈចាប់ពីអគ្គនាយក អនុរដ្ឋលេខាធិការឡើងទៅ ។
- ឧកញ៉ា (ន) : ពាក្យប្រើជាឋានន្តរស័ក្តិនៃមន្ត្រីថ្នាក់ខ្ពស់សំដៅលើអ្នកចេះត្រួតត្រាមុខការក្នុងក្រសួង ឬនាទីរបស់ខ្លួន ។ ប្រើតាមលំដាប់ធំតូច គឺលោកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ។

- តេជោ (ន) : អំណាច អានុភាពកម្លាំង ។
- អាសនៈ (ន) : កន្លែងអង្គុយ ។
- វិបុលសុខ (ន) : សេចក្តីសុខក្រៃលែង ។
- និន្ទា (ន) : ការរិះគន់ ការតិះដៀល ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលសិក្សាអត្ថបទរឿងល្ខោននេះ ចូរអ្នកយកចិត្តទុកដាក់ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងឈុត ឆាក សង្ខេបរឿងឡើងវិញ វិធីបង្ហាញតួអង្គ វិភាគតួអង្គ អត្ថន័យ អត្ថរូប និងអត្ថរស ។

គ. សង្ខេបរឿង

នៅដែនកំពង់ស្វាយមានបុរសម្នាក់ឈ្មោះ **មាស** មានងារជាឧកញ៉ាតេជោបរមរាជ ដែលគេហៅថា **តេជោមាស** ។ លោកមានភរិយាឈ្មោះ **ស្រែន** មានងារជាជំទាវនិងមានសិស្សម្នាក់ឈ្មោះ **យ៉ត** ដែលតែងតែទៅសមរភូមិប្រយុទ្ធជាមួយនឹងលោកគ្រប់ទីកន្លែង ។ ស្វាមីភរិយាទាំងពីរនេះ មានទឹកចិត្តស្រឡាញ់រាប់អាន យ៉តជាពន់ពេក ។ ស្តេចសម្រែបានតាំងខ្លួនឯងថា **ស្តេចសម្រែរាជាធិរាជ** បានតាំងទីកងទ័ពនៅកំពង់ហៅ (កំពង់ឆ្នាំង) ដោយបានរៀបចំបន្ទាយមួយឈ្មោះថា **បន្ទាយនគរ** ។ ស្តេចសម្រែជាមេបះបោរប្រឆាំងនឹងព្រះជ័យចេស្តា ដើម្បីដណ្តើមអំណាចគ្រប់គ្រងផែនដី ។ តេជោមាសនិងយ៉តបានព្យាយាមលើកទ័ពទៅបង្ក្រាបក្រុមបះបោរនេះខ្លាំងណាស់ដែរ តែត្រូវបរាជ័យ ។ ជំទាវស្រែនបានរៀបចំលិច្ឆបញ្ឆោតឱ្យស្តេចសម្រែធ្លាក់ក្នុងអន្ទង់ស្នេហា ហើយបង្អកស្រារហូតដល់ស្រវឹង ។ ស្តេចសម្រែនិងបក្សពួកត្រូវតេជោមាស យ៉ត និងកងទ័ពចាប់ទៅថ្វាយព្រះចៅជ័យចេស្តាកាត់ទោសតាមច្បាប់នគរ ។

ក្រោយពីបានទទួលជោគជ័យលើស្តេចសម្រែមក តេជោមាសបានទទួលអនិច្ចកម្មទៅ ។ ព្រះរាជាក៏ប្រទានងារឱ្យទៅ**តេជោយ៉ត** បំពេញនាទីដឹកនាំទ័ពជំនួស ។ តេជោយ៉តបានទទួលរាជបញ្ជានិងដាវអាជ្ញាសឹកទៅបង្ក្រាបពួកឈ្លើយសឹកបះបោរនៅខេត្តពោធិ៍សាត់ ។ ឆ្លងតាមបទពិសោធរបស់ឧកញ៉ាចក្រីនិងក្រឡាហោមដែលទទួលបរាជ័យក្នុងការបង្ក្រាបឈ្លើយសឹកនៅទីនោះ តេជោយ៉តបានបញ្ជាកេណ្ឌទ័ពនៅលង្វែក កំពង់ស្វាយក្នុងនោះមាន **ម៉ឹងចៃចុងវ៉ាក់** ដែលជាប្អូនថ្លៃមហាក្សត្រផងដែរ ។ ដើម្បីរកសត្រូវក្រោយខ្នង តេជោយ៉តបានបញ្ជាឱ្យកងទ័ពកំណែនទាំងអស់អូសបូស្សីបញ្ជ្រាសចុងដើម្បីកសាងបន្ទាយ លើនរណាប្រឆាំងត្រូវសម្លាប់ចោល ។ បក្សពួកម៉ឺនចៃចុងវ៉ាក់មិនធ្វើតាមបញ្ជានេះឡើយ ហើយថែមទាំងធ្វើការតាមទំនើងចិត្តរបស់ខ្លួន ព្រោះសំអាងទៅលើបងស្រីដែលធ្លាប់ទទួលសំណូកនិងជាអ្នកម្នាងរបស់ព្រះមហាក្សត្រនឹងជួយឱ្យរួចពីកំណែននេះ ។ ទង្វើនេះត្រូវបានតេជោយ៉ត

រកឃើញហើយសម្លាប់ម៉ឺនចៃចុងរ៉ាក់ចោលទៅ។ ដឹងដំណឹងនេះភ្លាម អ្នកម្នាងនួបានទូលថ្វាយព្រះរាជាឱ្យចាប់តេជោយ៉តទៅកាត់ទោសប្រហារជីវិត។ ព្រះរាជាបានធ្វើតាមអ្នកម្នាង តែតេជោយ៉តមិនបានមកតាមបញ្ជានេះឡើយ ដោយសំអាងថា ខ្លួនជាប់ដៃបង្ក្រាបសត្រូវបះបោរ ចាំរួចការនេះនឹងចូលទៅទទួលទោសដោយខ្លួនឯង។ ដោយការទទូចសុំពីអ្នកម្នាងខ្លាំងពេក ព្រះរាជាបានបង្ខំឱ្យតេជោយ៉តមកជួបទល់មុខជាមួយអ្នកម្នាងនួ។ ពេលកំពុងជជែកគ្នាតេជោយ៉តបានចោទប្រកាន់ថា អ្នកម្នាងនួជាសត្រូវពីក្រោយខ្នង ព្រោះបានរំខានខ្លួនធ្វើសឹកបើកឱកាសឱ្យសត្រូវវាយលុកនិងទទួលសំណូកដើម្បីការពារបក្សពួកម៉ឺនចៃចុងរ៉ាក់ធ្វើកងទ័ពបាក់ស្មារតី ហើយក៏គប់កូនដាវសម្លាប់អ្នកម្នាងនួនាពេលនោះទៅ។ តេជោយ៉តប្រកាសជំរាបមន្ត្រីទាំងនោះថា ចាំបង្ក្រាបសត្រូវរួចនឹងចូលមកទទួលទោសដោយខ្លួនឯង។

ការបង្ក្រាបឈ្លើយសឹកសៀមបះបោរបានទទួលជោគជ័យ តេជោយ៉តឱ្យគេធ្វើឃ្នាងដាក់ខ្លួនឯងដើរចូលទៅទទួលទោសពីព្រះរាជា ពីបទដែលខ្លួនបានសម្លាប់អ្នកម្នាងនួ។ ព្រះរាជាមិនឱ្យចូលជួបហើយបញ្ជាឱ្យមន្ត្រីដោះលែងនិងឱ្យទៅត្រួតការងកំពង់ស្វាយវិញ។ តេជោយ៉ត បានគួចចិត្តប៉ងយកជំទាវស្រែនធ្វើជាភរិយាតែមិនបានសម្រេច ព្រោះជំទាវគិតថាយ៉តជាជនជាតិភាគតិច ហើយជាសិស្សប្តីនាងពីមុនផងដែរ។ ដោយឃើញថា ជំទាវរើសអើងប្រកាន់វណ្ណៈបែបនេះ យ៉តប្រើល្បិចលួចយកកាំជណ្តើរផ្ទះជំទាវស្រែនមកឱ្យជាងឆ្លាក់ព្រះពុទ្ធបដិមានិងរូបសំណាកតេជោមាស ហើយប្រកាសធ្វើបុណ្យយ៉ាងធំបញ្ជូនកុសលទៅគ្រូរបស់ខ្លួន។ ជំទាវស្រែនបានទៅចូលរួមពិធីនេះ ហើយថ្វាយបង្គំព្រះពុទ្ធបដិមានិងរូបសំណាកតេជោមាសនោះ តែត្រូវបានតេជោយ៉តប្រាប់ការពិតថា ថ្វាយបង្គំកាំជណ្តើរផ្ទះរបស់ខ្លួនឯង។ ពេលនោះជំទាវស្រែន យល់ន័យនៃទង្វើរបស់តេជោយ៉ត ហើយក៏ព្រមព្រៀងរៀបការជាមួយតេជោយ៉តនាពេលនោះទៅ។

ឃ. អត្ថបទដកស្រង់

ឆាកទី ១៥ : ជំទាវស្រែន-តេជោយ៉ត

ជំទាវស្រែន : យ៉ត! ខ្ញុំជួយអបអរសាទរចំពោះជ័យជំនះក្នុងការធ្វើសង្គ្រាមរបស់យ៉តណា!

តេជោយ៉ត : អូ! លោកជំទាវជំរាបសួរ!

ជំទាវស្រែន : ចាស! យ៉តខ្ញុំគ្រាន់តែទទួលដំណឹងថាយ៉តមកដល់ខ្ញុំក៏ជួបភ្លាមដែរ ព្រោះយ៉តយ៉តធ្លាប់ទៅច្បាំងជាមួយប្តីខ្ញុំជាច្រើនលើកជាច្រើនសារ។ ខ្ញុំហាក់ស្រមៃថាគាត់នៅរស់ ហើយទៅធ្វើសឹកសង្គ្រាមដូចមុនអញ្ចឹងធ្វើឱ្យខ្ញុំទន្ទឹងផ្លូវគ្រប់ពេលវេលា ឃើញយ៉តត្រឡប់មកវិញ!

តេជោយ៉ត : ដោយក្តីរំភើបចំពោះទឹកចិត្តប្រកបដោយសប្បុរសធម៌របស់លោកជំទាវ ដែលធ្លាប់មានចំពោះរូបខ្ញុំតាំងពីដើមរហូតមកទល់សព្វថ្ងៃនេះ ឥតមានប្រែប្រួលបន្តិចទេ ។

ជំទាវស្រែន : នេះជាវត្ថុដែលខ្ញុំរៀបចំផ្តាល់ដៃយ៉ាងសម្រិតសម្រាំងទុកជាក់ឱ្យយ៉តជារង្វាន់ណា ! មានតាំងពីក្រមាជរជាយស្រោមខ្ចីយប៉ាក់ឱនជាដើម ។ ប៉ុន្តែនៅរង្វាន់មួយបែបទៀតដែលខ្ញុំរកឱ្យយ៉ត ពុំទាន់បានណា !

តេជោយ៉ត : រង្វាន់អីទៅ ? ដែលលោកជំទាវរកពុំទាន់បាននោះ !

ជំទាវស្រែន : រង្វាន់សុភមង្គលប្រចាំជីវិតរបស់យ៉តណា ! (ច្រៀង) ធម្មជាតិជាមនុស្ស អឺ... រស់លើផែនដីទាំងប្រុសទាំងស្រីត្រូវមានស្នេហា (២ដង) ប៉ុន្តែជ្រើសរើសទៅតាមកំណត់វាសនាត្រូវត្រិះរិះពិចារណាឱ្យបានអើយ ... ។

តេជោយ៉ត : រង្វាន់សុភមង្គល គឺអ្វីទៅ ?

ជំទាវស្រែន : គឺស្នេហា !

តេជោយ៉ត : អ៎ុំ ! លោកជំទាវប្រាថ្នារកភរិយាឱ្យខ្ញុំ !

ជំទាវស្រែន : ត្រូវហើយ ខ្ញុំមានបំណងបែបនេះ តាំងពីលោកគ្រូរបស់យ៉តឯងនៅរស់ជីវិតម្ល៉ះណា !

តេជោយ៉ត : ខ្ញុំលួចស្រឡាញ់ស្រីម្នាក់ឃ្លាខែហើយ តែក្រែងពេលបានស្គាល់ឈ្មោះទៅលោកជំទាវពុំព្រមដណ្តឹងឱ្យណ៎ !

ជំទាវស្រែន : ម៉េចថាអញ្ចឹងយ៉ត ! ឱ្យតែយ៉តពេញចិត្ត ខ្ញុំក៏ប្រហែលជាពុំទាស់ចិត្តដែរណាយ៉ត !

តេជោយ៉ត : ប៉ុន្តែកុំអាលសិន ! ចាំថ្ងៃក្រោយខ្ញុំនឹងជំរាបលោកជំទាវ ។

ជំទាវស្រែន : អីបើអញ្ចឹងក៏មិនអីដែរ តែល្ងាចនេះសូមយ៉តអញ្ជើញអស់លោកដែលទើបនឹងមកពីធ្វើសង្គ្រាមទាំងអស់គ្នាទៅផ្ទះខ្ញុំ ព្រោះខ្ញុំធ្វើពិធីជប់លៀងមួយដើម្បីទទួលយ៉តណ៎ !

តេជោយ៉ត : បាទ ! បាទ ! សូមអរគុណ !

ឆាកទី ១៦ : តេជោយ៉ត-នាងម៉ៃ-នាយតយ

នាងតយ : អូ ! នាងម៉ៃអញ្ជើញទៅណា ! បានជាទឹកមុខពុំសូវស្អាតសោះ !

នាងម៉ៃ : នាយតយ ! តើបងយ៉តនៅឯណា ?

នាយតយ : បាទ ! បាទ ! គាត់កំពុងបង្ហាត់សេះនៅខាងក្រោយផ្ទះឯណោះបាទ ! បើអ្នកនាងរកលោកតេជោ ចាំខ្ញុំទៅជំរាបជូន !

នាងម៉ែ : ចាស៎ ! មិនអីទេ ចាំខ្ញុំទៅជួបនឹងគាត់បានហើយ ! (ពេលនោះតេជោយ៉ឹតកំពុងបង្ក្រាបសេះនៅឯទីវាល)

តេជោយ៉ឹត : អូនម៉ែឈប់ៗកុំអាលចូល ។ សេះនេះកាចណាស់ចាំបងយកវាចងសិន ។ តោះយើងទៅអង្គុយលើគ្រែក្រោមដើមស្វាយឯនោះណ៎ា ! អូនកើតអីហ្នឹង ?

នាងម៉ែ : បងយ៉ឹត !

តេជោយ៉ឹត : ហេតុអ្វីបានជាយំ !

នាងម៉ែ : មកពីបង ! ខ្ញុំចង់លាបងទៅបួសហើយ ។

តេជោយ៉ឹត : អ៎ា ! ទៅបួស ! បងឆ្ងល់ណាស់ហេតុអីបានជាម៉ែចេះតែយំ ? យំមិនឈប់អញ្ចឹង !

នាងម៉ែ : ព្រោះបងធ្វើបាបចិត្តខ្ញុំណាស់ !

តេជោយ៉ឹត : បងមិនដែលធ្វើបាបម៉ែសោះ ហេតុអីបានជាអូនម៉ែចោទថា បងជាអ្នកធ្វើបាបចិត្តអូន ? ម៉ែអូន ! អូនយល់ច្រឡំហើយ !

នាងម៉ែ : ខ្ញុំតូចចិត្តណាស់ ! (ច្រៀង) បងជាបុរសមានកេរ្តិ៍ឈ្មោះល្បីការពារទឹកដី បុរីសីមា តែមានចិត្តហោរហៅមិនយល់ជម្រៅស្នេហា (តេជោយ៉ឹតច្រៀងបន្ត) អូនជាបុប្ផាក្រពុំពេញវ័យអ្នកផង ស្រម៉ែចង់បានស្នេហា អឺយ ... ។

តេជោយ៉ឹត : អូនម៉ែយល់ច្រឡំទេដឹងអូន !

នាងម៉ែ : ខ្ញុំខ្មាសខ្លួនឯងណាស់ ខ្ញុំមិនចង់ឃើញមុខបងឯងទេ !

តេជោយ៉ឹត : ឈប់យំទៅអូន ។ អូនស្តាប់បងសិន ។

នាងម៉ែ : ខ្ញុំឈប់ស្តាប់បងហើយ បងឯងជាអ្នកច្រានខ្ញុំទម្លាប់ទៅក្នុងរណ្តៅទឹកភ្នែក

តេជោយ៉ឹត : មិនមែនអញ្ចឹងទេ អូនយល់ខុសហើយ ។

នាងម៉ែ : ម៉េចក៏ខ្ញុំយល់ខុសតាំងពីបងមកពីបង្ក្រាបឈ្លើសសឹកសៀមប៉ុន្មានខែនេះ យើងទាំងពីរនាក់កាន់តែស្និទ្ធស្នាលនឹងគ្នាណាស់ ដូច្នេះបងមិនមែនមិនដឹងចិត្តខ្ញុំទេ ។

តេជោយ៉ឹត : បងដឹងច្បាស់ណាស់ !

នាងម៉ៃ : បើដឹង ហេតុអ្វីបងធ្វើបាបខ្ញុំ ខ្ញុំទើបឮពុកខ្ញុំប្រាប់ពីយប់មិញនេះ ថាបងពីងគាត់ និងចាស់ទុំទៀតឱ្យចូលស្តីដណ្តឹងជំទាវស្រែនឱ្យបង ! ហេតុអ្វីបងធ្វើអ៊ីចឹង !

តេជោយ៉ត : ព្រោះបងស្រឡាញ់ជំទាវស្រែន !

នាងម៉ៃ : ស្តាប់ពាក្យសំដីនេះ ធ្វើឱ្យខ្ញុំឈឺចិត្តណាស់ !

តេជោយ៉ត : ម៉ៃសេចក្តីស្នេហាពិតប្រាកដ គេមិនអាចបង្ខំបានទេ គឺស្នេហានោះវាផុសចេញពីមនោសញ្ចេតនាយើងសុទ្ធសាធ។ បងស្រឡាញ់រាប់អានម៉ៃដោយស្មោះ ទើបបងមិនយកសេចក្តីស្នេហាក្លែងបន្លំទៅបោកប្រាសអូនណា៎ !

នាងម៉ៃ : អញ្ចឹងបងគ្រាន់តែស្រឡាញ់ខ្ញុំ រាប់អានប៉ុណ្ណោះទេអឺ ?

តេជោយ៉ត : ស្នេហានិងការស្រឡាញ់រាប់អានវាចែកដាច់ពីគ្នាស្រលះណាម៉ៃ។

នាងម៉ៃ : អូនសូមជូនពរឱ្យបានរស់ក្នុងសុភមង្គលជាមួយជំទាវស្រែនទៅចុះ។ ខ្ញុំសូមលាហើយ !

តេជោយ៉ត : ឈប់សិន ! ឈប់សិនម៉ៃ ! ន៎ែ បើអូនមានចិត្តជ្រះថ្លាក្នុងសាសនាដោយស្មោះស្ម័គ្រមែនបងមិនហ៊ានឃាត់ទេ។ ប៉ុន្តែបើអូនទៅបួស ព្រោះឈឺចាប់នឹងរឿងនេះ គឺជាការខុសឆ្គងទៅវិញ។

នាងម៉ៃ : ម៉េចក៏ខុសឆ្គង ?

តេជោយ៉ត : ព្រោះអូនជំនះឧបសគ្គក្នុងជីវិតពុំបាន ទើបរត់ទៅបួស។

នាងម៉ៃ : ទេ ! ទេ ! ខ្ញុំកាត់ចិត្តពីបងហើយ។

តេជោយ៉ត : បើពិតជាកាត់ចិត្តមែនចាំបាច់អីអូនទៅបួសទៀត គួរតែអូនរក្សាយុវវ័យរបស់អូនឱ្យរឹងប៉ឹងភ្លឺស្វាង ដើម្បីកសាងប្រទេសណា៎ !

នាងម៉ៃ : អា៎ ! នេះពិតជាគំនិតវីរបុរសមែន។ បងយ៉ត ខ្ញុំសូមសំពះបងធ្វើជាបងធម៌រហូតអស់មួយជីវិតណាបងណា៎ !

តេជោយ៉ត : អូនម៉ៃ បងសប្បាយចិត្តណាស់ក្រោកឡើងអូន។

ឆាកទី ១៧ : តេជោយ៉ត-ឧកញ៉ាព្រហ្មស្រី

ឧកញ៉ាព្រហ្មស្រី : លោកតេជោរឿងនោះ មិនកើតទេណា !

តេជោយ៉ត : យ៉ាងម៉េចទៀតហើយ លោកព្រហ្មស្រី

ឧកញ៉ាព្រហ្មស្រី : បាទ ! នេះជាលើកទីបីហើយ តែឥរិយាបថរបស់ជំទាវស្រែននៅតែរឹងរូសដដែលឥតមានទន់ជ្រាយបន្តិចសោះទាន !

តេជោយ៉ត : ស្រែន ! ប្រកែកទៀតអី !

ឧកញ៉ាព្រហ្មស្រី : បាទ ! ដូចតែលើកមុនៗអញ្ចឹង ពេលពួកខ្ញុំជាថៅមហាជាចាស់ទុំទៅដល់លោកជំទាវរៀបចំទទួលយ៉ាងរាក់ទាក់ស្និទ្ធស្នាល ឥតមានរង្គៀសសោះ ។ តែដល់ពេលនិយាយដល់ការស្តីដណ្តឹងរូបគាត់ជូនលោកតេជោ ជំទាវតបយ៉ាងញញឹមពព្រាយថា គាត់មិនអាចទទួលយកតេជោជាស្វាមីបានទេ ព្រោះលោកជាអតីតបាវបំរើរបស់គាត់ ហើយមានដើមកំណើតជាជនជាតិភាគតិចផងបាទ !(ឧកញ៉ាព្រហ្មស្រីនិយាយទាំងញញើតញញើម)

តេជោយ៉ត : ហ៊ឺ ! ជំទាវស្រែនជានារីបញ្ចពិធកល្យាណីស្រីគ្រប់លក្ខណ តែនៅមានគំនិតប្រកាប់វណ្ណៈប្រកាន់ពូជសាសន៍ដែលបណ្តាលមកពីបរិយាកាសសង្គម ។

ឧកញ៉ាព្រហ្មស្រី : បាទ ! ពិតជាអញ្ចឹងហើយលោកតេជោ !

តេជោយ៉ត : មិនអីទេ ! ខ្ញុំនឹងព្យាយាមធ្វើឱ្យនាងភ្ញាក់រលឹក ។ លោកត្រូវចាត់ចែងសង់រោងឱ្យធំ ដើម្បីប្រារព្ធធ្វើបុណ្យរំលឹកដល់វិញ្ញាណក្ខន្ធរបស់លោកតេជោ ។

ឧកញ៉ាព្រហ្មស្រី : អ៊ុំ ! បាទមិនអីទេ ។

តេជោយ៉ត : ឯរូបសំណាកលោកគ្រូនិងព្រះពុទ្ធរូបដែលខ្ញុំឱ្យជាងឆ្លាក់ពីថ្ងៃមុននោះ ត្រូវយកទៅតម្កល់លើអាសនៈកណ្តាលរោងបុណ្យណា៎ ! ដើម្បីធ្វើសក្ការៈបូជា ។ សូមលោកជួយចាត់ចែងឱ្យអធិកអធមណា ។

ឧកញ៉ាព្រហ្មស្រី : បាទ !

ឆាកទី ១៨ : ជំទាវស្រែន-តេជោយ៉ត-អ្នកបំរើ-ទាយទិន

ជំទាវស្រែន : ហ៊ឺ ! ពិបាកចិត្តណាស់ ! យ៉តពឹងពាក់ចាស់ទុំឱ្យចូលស្តីដណ្តឹងខ្ញុំពីរបីសាទៅហើយ ។ យី ! គិតយ៉ាងម៉េចអ៊ីចេះ ! ខ្ញុំដូចជាពុំយល់សោះ ។ គិតមិនលេចសោះ ។ (ច្រៀង) អាណិត ស្រឡាញ់ អឺយ ពេញក្នុងចិន្តា អឺយ ពេញចិត្តប៉ុន្តែ អឺយ ចាប់ស្រវាអឺយពុំបាន អឺយពីព្រោះ ខ្ញុំៗខ្មាស អៀន អឺយខ្មាសអៀនញាតិសន្តាន អឺយ យើងទាំងពីរប្រាណៗ អឺយ វណ្ណៈខុសគ្នា អឺយ ឱ ណាថ្លៃអឺយ វណ្ណៈខុសគ្នា ខ្លួនអឺយចំបែងថ្លៃអឺយខ្ញុំវែងថ្លែងប្រាប់នរណា បើខ្ញុំអឺយ ក្លាហាន អ្នកផងសើចនិន្ទា អឺយទុក្ខញាំញីអឺយ ប្រកែករែកទុក្ខគ្រាំគ្រា អួយ ម្តេចក៏ពុំងា ពារចាប់ស្រវា ឱប្រុសជីវាស្នេហាខ្ញុំអឺយ ... ។ (និយាយ) ហ៊ឺ ! យ៉តជាបុរសមានឧត្តមគតិ

ស្នេហាជាតិនិងលក្ខណៈសម្បត្តិថ្លៃថ្នូរដូចស្វាមីខ្ញុំគ្រប់បែបយ៉ាងទាំងអស់ ប៉ុន្តែគេជាអតីតបាវបម្រើ ដូច្នេះបើរៀបការជាមួយយ៉ត ច្បាស់ជាអ្នកផង សើចនិន្ទាខ្ទរខ្ទារពេញនគរមិនខាន ។

អ្នកបម្រើ : លោកជំទាវ តេជោយ៉ត តេជោយ៉តបានរៀបចំពិធីបុណ្យអធិកអធម ណាស់ ។ ហើយមានតាំងរូបសំណាក់លោកតេជោមាសជាទីសក្ការៈបូជា ផង ។

ជំទាវស្រែន : អូ ! អ៊ីចឹងផង មានរូបសំណាក់ប្តីខ្ញុំផងអី ! អ៎ ! ខ្ញុំចង់ឃើញរូបបងមាស ណាស់ ។ ន៏ែ ! នាងៗទាំងអស់គ្នារៀបចំរណ្តាប់ទៅ ដើម្បីទៅចូលរួម បុណ្យតេជោយ៉តណា ។ ចំណែកខ្ញុំទៅរៀបចំខ្លួនសិនណា៎ !

អ្នកបម្រើ : ចា៎ស !

ជំទាវស្រែន : ឃី ! បុណ្យគេអធិកអធមណាស់ហ្ន៎ ។ មនុស្សច្រើនអ៊ូអរសប្បាយមែន ។ ន៏ែ ! ឯងមើលជាងណានេះ ចេះឆ្លាក់រូបសំណាក់ដូចប្តីខ្ញុំបេះបិទហ្ន៎ !

អ្នកបម្រើ : ចា៎ស ! ព្រះពុទ្ធក្បែរនោះក៏ល្អដែរ លោកជំទាវ !

ជំទាវស្រែន : ហ្នឹងហើយ ! ខ្ញុំទៅដុតធូបថ្វាយបង្គំសិនទើបយករណ្តាប់ទៅចូលបុណ្យ ជាក្រោយណា !

អ្នកបម្រើ : ចាស៎ !

ជំទាវស្រែន : បងមាសៗ សូមបងទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

តេជោយ៉ត : ជំរាបសួរ លោកជំទាវ !

ជំទាវស្រែន : ចា៎ស ! ឃី ! យ៉តរៀបចំពិធីអធិកអធមណាស់ហ្ន៎ !

តេជោយ៉ត : លោកជំទាវ បត់ជើងសំពះអីហ្នឹង !

ជំទាវស្រែន : អា៎ ! ម៉េចយ៉តសួរអ៊ីចឹង ខ្ញុំសំពះព្រះពុទ្ធរូបនិងរូបសំណាកប្តីខ្ញុំណា !

តេជោយ៉ត : ត្រូវហើយ លោកជំទាវ ! វត្ថុទាំងនេះជាទីសក្ការៈក្នុងពិធីបុណ្យ ។ លោក ជំទាវត្រូវតែសំពះអ៊ីចឹងហើយ ។ ប៉ុន្តែលោកជំទាវដឹងទេថា រូបសំណាក ទាំងពីហ្នឹង សាងពីអ្វីទេ ?

ជំទាវស្រែន : ហ៊ឹ ! យ៉តកំប្លែងណាស់ ស្មានថាលាភពណ៌ល្អស្អាតនិងតុបតែងវិចិត្រ ប៉ុណ្ណឹង ខ្ញុំមើលមិនដឹងឬ ? រូបសំណាកនិងរូបព្រះពុទ្ធនោះឆ្លាក់អំពីឈើ មិនមែនថ្មទេណាយ៉ត !

តេជោយ៉ត : ត្រូវហើយ ! ប៉ុន្តែលោកជំទាវដឹងទេថា ខ្ញុំយកឈើអ្វីមកឱ្យគេឆ្លាក់ ?

ជំទាវស្រែន : យី ! ធ្វើម៉េចខ្ញុំនឹងដឹងបាន !

តេជោយ៉ត : រូបសំណាកលោកគ្រូនិងព្រះពុទ្ធរូបនេះ ខ្ញុំបានទៅលួចយកកាំជណ្តើរទីមួយពីផ្ទះលោកជំទាវមកឱ្យគេឆ្លាក់ណា !

ជំទាវស្រែន : អ៎ ! អ៊ីចឹងបានពីថ្ងៃមុនខ្ញុំបាត់កាំជណ្តើរមួយ ។ យី ! យ៉ត !

តេជោយ៉ត : ហ៎ាស ! ហ៎ាស ! កាំជណ្តើរនោះ ជាឈើដែលលោកជំទាវជាន់វាព្រឹកល្ងាចៗរាល់ថ្ងៃ ។ ប៉ុន្តែលុះយកមកឆ្លាក់ធ្វើជារូបសំណាកព្រះពុទ្ធ លោកជំទាវបែរជាបត់ជើងសំពះទៅវិញ ។ នេះបានសេចក្តីថា លោកជំទាវសំពះកាំជណ្តើររបស់ខ្លួនទេឬ ?

ជំទាវស្រែន : យី ! អ៊ូ ! ខ្ញុំយល់ហើយ យ៉តឯងផ្តាញ់ខ្ញុំ ។

តេជោយ៉ត : ខ្ញុំមិនមែនជាអ្នកផ្តាញ់ទេ (ច្រៀង) លើកកាំជណ្តើរជាន់ឡើងរាល់ថ្ងៃ ខ្ញុំឆ្លាក់ក្រឡៃ ស្រែនក្រាបសំពះ ខ្ញុំជាបាវព្រាវបម្រើក្នុងផ្ទះ ពេលនេះគួរណាស់ស្រែនឈប់ប្រកែក ។

ជំទាវស្រែន : (ច្រៀងបន្ត) សង្គមវណ្ណៈ ឆ្លាក់ជាប់ចិត្តស្រីអើយពេលនេះ ស្មារតីភ្លឺស្វាងចំឡែក ប្រស្នាអ្នកប្រុសខ្ញុំច្បាស់អនេក អូនឈប់ប្រកែកស្មោះស្ម័គ្រស្នេហាអើយ ... ។

តេជោយ៉ត : និយាយលាក់បាំងអីស្រែនក្នុងដែនកំពង់ស្វាយទាំងមូល ខ្ញុំសម្លឹងរកនារីឱ្យមានលក្ខណៈល្អគ្រប់យ៉ាងដូចស្រែនគ្មានសោះ ។ ដូច្នេះហើយទើបខ្ញុំចេះទទួចស្តីដណ្តឹងស្រែន លើសពីនេះទៅទៀត លោកគ្រូជាអ្នកមានគុណធ្លាប់ចិញ្ចឹមខ្ញុំ ដោយសេចក្តីសប្បុរសជាទីបំផុត ។ អស់ពីលោកគ្រូទៅ ខ្ញុំពុំចង់ឱ្យស្រែនបានទៅលើបុរសណាផ្សេងៗទៀតទេ ព្រោះក្រែងប៉ះលើមនុស្សមិនល្អ នាំឱ្យអនាគតរបស់ស្រែនធ្លាក់ទៅក្នុងការឈឺចាប់ដោយប្រការផ្សេងៗណា ។

ជំទាវស្រែន : ខ្ញុំអាណិតនិងស្រឡាញ់យ៉តលើសដើមទៅទៀត ។ ប៉ុន្តែដោយសារមានគំនិតប្រកាន់វណ្ណៈ ទើបចេះតែប្រកែក ។ ឥឡូវនេះ ខ្ញុំលែងស្មាក់ស្មើរក្នុងចិត្តហើយ ។ ជាពិសេសការប្រកាន់ពូជសាសន៍ គឺជាគំនិតអយុត្តិធម៌

បំផុត ។ ឧទាហរណ៍ដូចរូបអ្នកដែលមានដើមកំណើតជាជនជាតិភាគតិច ប៉ុន្តែស្មារតីស្នេហាជាតិរបស់យ៉តខ្ពង់ខ្ពស់ជាទីបំផុត អឺ ... វីរភាពរបស់អ្នកឧត្តុង្គឧត្តមណាស់សម្រាប់ទំព័រសាវតារបស់ជនគរកម្ពុជាយើងនេះណ៎ា !

នាងម៉ែ : បងយ៉ត ! ខ្ញុំសូមជូនពរបងមុនថ្ងៃរៀបការឱ្យហើយ សូមបងទាំងពីរប្រកបតែនឹងសុភមង្គល វិបុលសុខរហូតអវសានៃជីវិត ។

ជំទាវស្រែន : ហ៊ឺ ! នាងម៉ែបានមាត់បានកណាស់តើហ៎ា !

នាយទិន : ន៎ែ បងប្អូនទាំងអស់គ្នា ជំទាវស្រែនព្រមរៀបការជាមួយតេជោយ៉តហើយណា ។ ដូច្នេះ សូមអ្នកភ្លេងប្រគំឡើង ដើម្បីអបអរចំពោះការភ្ញាក់រលឹកឥតប្រកាន់វណ្ណៈនិងពូជសាសន៍របស់ជំទាវស្រែនផង ។

(ដកស្រង់ដោយកត់ត្រាចេញពីល្ខោនបាសាក់សំម្តែងតាមវិទ្យុ តេជោយ៉ត របស់លោក ទី ជីហួត)

សំណួរ

១. ចូរអ្នកធ្វើការសង្ខេបរឿងនាកទី ១៨ ។

២. ចូរអ្នកធ្វើការវិភាគតួអង្គតេជោយ៉ត ជំទាវស្រែន នាងម៉ែ និងឧកញ៉ាព្រហ្មស្រី ។

៣. តើអត្ថបទនេះជាប្រភេទអ្វី ? អត្ថបទប្រភេទនេះ មានរចនាបថយ៉ាងដូចម្តេច ?

៤. ចូរអ្នកបង្ហាញពីតួនាទីរបស់តួអង្គនាយតយនិងទិនក្នុងវគ្គដកស្រង់នេះ ។ តើតួអង្គទាំងពីរខាងលើចាំបាច់ឬទេក្នុងការសម្តែង ? ហេតុអ្វី ?

៥. ដោយផ្អែកតាមនាកទី ១៥ដល់ទី ១៨ ចូរអ្នកធ្វើការសិក្សាអំពី :


- អត្ថន័យ : ប្រធានរឿង មូលបញ្ហារឿង គំនិតដឹកនាំ(ឧត្តមគតិអ្នកនិពន្ធ) ។
- អត្ថរូប : វចនវិធី សន្ទេហវិធី វឌ្ឍនវិធី វឌ្ឍមានវិធី និងបដិវិធី ។
- អត្ថរស : តថរស សច្ចរស កុសលរស សង្គមរស ។

៦. តើរវាងជំទាវស្រែននិងនាងម៉ែ មានលក្ខណៈដូចគ្នានិងលក្ខណៈខុសគ្នាយ៉ាងណាខ្លះ ? ឧត្តមភាពរបស់នារីទាំងពីរនេះស្ថិតត្រង់ណា ? ចូរបង្ហាញ ។

៧. តើស្ថានភាពជាកត្តាកំណត់លើវីរជន ឬវីរជនជាកត្តាកំណត់លើស្ថានភាព ? តើតេជោយ៉តក្នុងវគ្គដកស្រង់នេះ អាចចាត់ទុកជាវីរជនបានដែរឬទេ ? ព្រោះអ្វី ?

៨. តើសេចក្តីស្នេហារវាងជំទាវស្រែននិងតេជោយ៉ត បានផ្តល់ជាផលវិបាកយ៉ាងណាខ្លះ ? ហេតុអ្វី ?

លក្ខណៈពិសេសរបស់ល្ខោន



ក. សិក្សាពាក្យគន្លឹះ

- ចតុមុខ (ន) : មុខបួន ។
- ចៅអធិការ (ន) : ភិក្ខុជាមេវត្ត ។
- ទស្សនីយភាព (ន) : អ្វីដែលគួរឱ្យចង់មើល ចង់ឃើញភាពដែលគួរមើលគួរឃើញ ។
- នាដ្យកថា (ន) : រឿងល្ខោន ។
- បរម (គុ) : ឧត្តម ខ្ពង់ខ្ពស់ ប្រសើរ ល្អប្រពៃ ក្រៃលែង ។
- ប្រវឹញ្ច (កិ) : បញ្ឆោត បោកប្រាស់ ឆបោក ។
- ពុទ្ធប្រវត្តិ (ន) : ប្រវត្តិរបស់ព្រះពុទ្ធ ។
- វេទមន្ត (ន) : មន្តអាគម មន្តសម្រាប់ផ្ចឹ ស្តោះ ធ្វើអំពើ ខាប់ ជបជាដើម ។
- សន្និដ្ឋាន (កិ) : រួមគំនិតជាមួយការយល់ជាក់ ចូលចិត្ត ការយល់ឃើញស៊ប់ ។
- សាសនា (ន) : ការប្រៀនប្រដៅ ពាក្យប្រៀនប្រដៅ បណ្តាំ ពាក្យផ្តាំផ្ញើ ។
- អរិយធម៌ (ន) : ធម៌ដែលនាំឱ្យកើតសេចក្តីសុខចម្រើន ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់ល្អ ។
- អាណានិគម (ន) : រដ្ឋដែលតាំងនៅក្នុងអំណាចបរទេស ស្រុកចំណុះគេ ។

ខ. អភិវឌ្ឍន៍បំណិន

នៅក្នុងការសិក្សាអត្ថបទនេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងប្រភេទល្ខោននិងលក្ខណៈពិសេសរបស់ល្ខោន ។

គ. អត្ថបទ

តាមអ្នកស្រាវជ្រាវខ្លះថា ល្ខោនជាទស្សនីយភាពមួយ ស្ថិតនៅចំពីមុខទស្សនិកជន ។ សិល្បៈបញ្ចូលគ្រប់ទម្រង់នៃការកំសាន្តសប្បាយ ។ ម្យ៉ាងវិញទៀតតាមការកំណត់ពីបរមបុរាណមក ល្ខោនជាទម្រង់សិល្បៈមួយបែប ដែលនៅក្នុងនោះនាដ្យកថា ... បានត្រូវសម្តែងឡើង ។ នៅប្រទេសកម្ពុជាយើង មានទម្រង់ល្ខោនជាច្រើន(ជាងម្តៃ) ដែលនៅក្នុងនោះទម្រង់ល្ខោនខ្លះរស់វាននៅឡើយ ។ ទម្រង់ខ្លះកំពុងឈានទៅដល់ការបាត់បង់ ។ ឯទម្រង់ខ្លះទៀត បានបាត់បង់រួចទៅហើយនៅសល់តែឈ្មោះនិងព័ត៌មានទាក់ទងតែបន្តិចបន្តួចប៉ុណ្ណោះ ។

ទម្រង់ល្ខោនទាំងនោះមាន : ល្ខោនស្រមោល "ស្បែកធំ" ល្ខោនស្រមោល "ស្បែកតូច" ស្បែកពណ៌ "ស្បែកសម្តែងពេលថ្ងៃ" ល្ខោនខោល (ល្ខោនប្រុស ឬល្ខោនពាក់មុខ) ល្ខោនព្រះរាជទ្រព្យ ល្ខោនមហោរី ល្ខោនចាប៉ីរឿងនិទាន រឿងខ្សែដៀវ ល្ខោនបាសាក់ ល្ខោនពោលស្រី ល្ខោនប្រាមោទ្យ ឬប្រាមោទ័យ ល្ខោនអាប៉េ ល្ខោនគែន ល្ខោនបើកបទ ល្ខោនភ្លេងការ ល្ខោនតុក្កតា ល្ខោននិយាយ ល្ខោនចំរុះ ល្ខោនកំណាព្យ យីកេ អាយ៉ៃរឿង សៀកសម្តែងជារឿង ។

ល្ខោនអាប៉េ : តាមការស្រាវជ្រាវ វង់តន្ត្រីល្ខោនអាប៉េ មានដើមកំណើតនៅខេត្តកំពង់ចាម (ស្រុកមេមត់) នៅខេត្តតាកែវភាគខាងត្បូង នៅកំពត និងនៅព្រះបរមរាជវាំង ។ ទម្រង់ល្ខោនអាប៉េនេះ ក៏មានប្រជាប្រិយភាពណាស់ដែរ ។ ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យប្រជាពលរដ្ឋ ។ ឧបករណ៍ភ្លេងមាន ស្គរដៃ ស្គរយីកេ ឈឹង ទ្រអ៊ូ ក្រាប់ ។

ល្ខោនមហោរី : មានប្រជាប្រិយភាពក្នុងចំណោមប្រជាជនខ្មែរ ។ វង់ល្ខោនមហោរីនេះ មានដើមកំណើតបន្ទាប់ពីវង់តន្ត្រីមហោរី គឺកើតនៅក្នុងព្រះបរមរាជវាំងតែម្តង ។ ល្ខោននេះ អាចសម្តែងរឿងបុរាណខ្លះដូចជា ពុទ្ធប្រវត្តិ ព្រះវេស្សន្តរ ក្រុងសុភមិត្រ ប្រវត្តិសាស្ត្រជាតិ និងពពួកសត្វ (ប្រៀបធៀបមកមនុស្ស) និងរឿងកំប្លុកកំប្លែង ទុក្ខសោក ព្រាត់ប្រាសក្នុងបច្ចុប្បន្នកាលនេះផង ។

ការសម្តែង គឺមានភ្លេងនិងចម្រៀងនាំមុខ បន្ទាប់ពីនោះត្រូវមានអ្នកពោលបន្ថែមបង្ហាញតួអង្គនីមួយៗផង ។ ល្ខោននេះ ច្រើនសម្តែងក្នុងពិធីបុណ្យប្រជាពលរដ្ឋឬថ្វាយព្រះរាជាទតកំសាន្ត ។

ល្ខោនប្រាមោទ្យ ឬបាមោជ្ជ ឬប្រាមោទ័យ ឬបាមោទ័យ : តាមវចនានុក្រមភាគ ១ ភាគ ២ ត្រង់ទំព័រ ៦២៦ បាមោជ្ជ (ប៉ាម៉ោចជៈ ឬប៉ាម៉ោច) ន. (បា.សំ. ប្រាមោទ្យ) សេចក្តីរីករាយសេចក្តីពេញចិត្តខ្លាំង ។ អ្នកខ្លះហៅថា ល្ខោនប្រាមោទ័យ ឬភ្លេងប្រាមោទ័យ ។

ល្ខោនប្រាមោទ័យឬប្រាមោទ្យ ជាទម្រង់ល្ខោនមួយបែបដែលសម្តែងរឿងខ្លីៗប្រកបដោយបរិយាកាសរីករាយ មិនសម្តែងរឿងកំសត់ព្រាត់ប្រាស ឬការប្រើវេទមន្តច្បាំងគ្នាខ្លាំងក្លាអ្វីឡើយ។ តាមអ្នកស្រាវជ្រាវល្ខោនប្រាមោទ្យឬប្រាមោទ័យនេះមានវត្តមាននៅលើទឹកដីកម្ពុជាយើងតាំងពីមុនសម័យអង្គរមកម្ល៉េះ។ តែល្ខោននេះ ទើបតែមានឥទ្ធិពលខ្លាំងនៅសម័យចតុមុខ។ ការសម្តែងសាច់រឿងនីមួយៗច្រើនមានអត្ថន័យស្នេហាពោរពេញទៅដោយកាយវិការទន់ភ្លន់និងពាក្យពេចន៍ផ្អែមល្អែម។ ល្ខោននេះ ច្រើនសម្តែងជូនភ្ញៀវកិត្តិយសនិងទស្សនិកជនទូទៅទស្សនាផងដែរ។

ល្ខោនបាសាក់ : ជាទម្រង់ល្ខោនមួយដែលមានដើមកំណើតនៅខេត្តបាសាក់កម្ពុជាក្រោម។ ដើមឡើយ ល្ខោននេះមានឈ្មោះថា ល្ខោនទ្រើងឃ្លោក ព្រោះគេហាត់រៀនក្រោមទ្រើងឃ្លោក។ លុះមកដល់ឆ្នាំ ១៩៣០ ទើបល្ខោនបាសាក់ចូលមកដល់រាជធានីភ្នំពេញ ហើយសម្តែងជាលើកដំបូងនៅលើទូកប៉ុកចាយ (មុខវត្តឧណ្ណាលោម)។

ល្ខោននេះ សម្តែងរឿងបុរាណដូចជា រឿងស័ង្ខសិល្បជ័យ ព្រះជិនវង្ស ... ។ ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យផ្សេងៗតាមវត្តអារាម ឬតាមស្រុកភូមិ។

កំណត់សម្គាល់ : កាយវិការក្នុងទម្រង់ល្ខោនមានពីរបែប គឺកាយវិការធម្មតាសម្រាប់រំលេចន័យខ្លឹមសាររបស់ពាក្យសំដី និយាយឬចម្រៀង និងកាយវិការក្បាច់ (ក្បាច់គុនចិននិងខ្មែរចម្រុះ) ដែលភាសាបច្ចេកទេសក្នុងទម្រង់ល្ខោនបាសាក់ហៅថា "ហ្គួន"។

ល្ខោនខោល : ជាទម្រង់សិល្បៈល្ខោនម៉្យាងដែលតួរាំសុទ្ធតែប្រុស។ ល្ខោនខោលនេះ មានចំណាស់មិនលើសពីរបាំឬល្ខោនក្បាច់បុរាណខ្មែរឡើយ។ ក្រោយអរិយធម៌ដ៏មហារុងរឿងអង្គរបានធ្លាក់ចុះ ល្ខោននេះស្ទើរតែបាត់បង់ដូចទម្រង់សិល្បៈដទៃទៀតដែរ។ ក្រោយមក គេឃើញល្ខោនខោលនេះ ចាប់កំណើតឡើងវិញនៅវត្តដីរីស ខេត្តបាត់ដំបងនិងវត្តស្វាយអណ្តើក ស្រុកល្វាឯម ខេត្តកណ្តាល។ កាលដើមឡើយ ល្ខោនខោល សម្តែងតែរឿង "**រាមកេរ្តិ៍**"។ តែក្រោយមក ដោយមានប្រជាប្រិយភាពក្នុងចំណោមមហាជន ល្ខោននេះក៏សម្តែងរឿងដទៃទៀតដូចជា រឿងព្រះវេស្សន្តរ រឿងព្រះសុធនកែវមនោហ៍រា ... ។

ល្ខោននេះច្រើនសម្តែងក្នុងពិធីបុណ្យសាសនានៅតាមវត្តអារាម ឬនៅក្នុងព្រះបរមរាជវាំង។

ល្ខោននិយាយ : ជាទម្រង់សិល្បៈម្យ៉ាងដែលមានប្រភពមកពីបរទេស (អឺរ៉ុប)។ ល្ខោននិយាយច្រើនសម្តែងរឿងសម័យទំនើប ទាក់ទងនឹងបញ្ហាវណ្ណៈអ្នកមាននិងអ្នកក្រ កម្មករនិងនិយោជកឬរឿងល្បីកផ្សេងៗ។ ***ឧទាហរណ៍*** : រឿងល្ខោននិយាយដែលគេធ្លាប់បានផ្សព្វផ្សាយរួចមកហើយ មានរឿងថៅកែចិត្តចោរ រឿងសំបុកឥតមេបា រឿងជនកំណាញ់ក្រៅតម្រា ... ។ ល្ខោននេះច្រើនចាក់ផ្សាយតាមវិទ្យុ ដើម្បីឱ្យអ្នកស្តាប់កំសាន្តសប្បាយ។

ល្ខោនយីកេ : អ្នកស្រាវជ្រាវខ្លះបានឱ្យដឹងថា ល្ខោនយីកេនេះមានដើមកំណើតមកពីជ្វា ឬ មល៉ាយូ ហើយទំនងជាចូលមកស្រុកខ្មែរតាមរយៈព្រះបាទជ័យវរ្ម័នទី ២ ឬតាមរយៈជនជាតិចាម។ ល្ខោនយីកេនេះ សម្តែងរឿងបុរាណក៏បាន រឿងទំនើបក៏បាន។ *ឧទាហរណ៍ :* យីកេរឿងទុំទាវ។ គេសម្តែងល្ខោនយីកេ នៅពេលមានបុណ្យទានតាមភូមិ ឬតាមវត្តអារាម ឬនៅពេលទំនេរពីការងារស្រែចំការ។

ល្ខោនស្រមោល (ស្បែកធំនិងស្បែកតូច) : នៅក្នុពិភពលោក គេសង្កេតឃើញមានប្រភេទល្ខោនស្រមោលនេះនៅច្រើនប្រទេសដូចជា អ៊ីរ៉ង់ តួគី ឥណ្ឌា កម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ។

សិល្បៈល្ខោនប្រភេទស្រមោលនៅកម្ពុជាមានពីរប្រភេទ គឺសិល្បៈស្បែកធំនិងសិល្បៈស្បែកតូច ដែលគេនិយមហៅថា "**អាយ៉ង**"។ តាមការសិក្សាស្រាវជ្រាវនិងប្រៀបធៀបទៅនឹងទម្រង់ធ្វើជទៃទៀតរបស់ខ្មែរ គេអាចសន្និដ្ឋានបានថា ល្ខោនស្រមោលនេះមានអាយុមុនសម័យអង្គរឆ្ងាយណាស់។ រូបចម្លាក់ស្បែកធំជារូបចម្លាក់នឹងថ្កល់គ្មានចលនាទេ ឯរូបចម្លាក់ស្បែកតូចវិញមានចលនារស់រវើកអាចបត់ដៃ បត់ជើង ហាមាត់ និយាយបាន។

សិល្បៈស្បែកធំត្រូវគេអនុញ្ញាតឱ្យសម្តែងតែរឿងរាមកេរ្តិ៍មួយគត់ (មានរូបចម្លាក់ទាំងអស់ ១៥៤ផ្ទាំង)។ សិល្បៈស្បែកតូច ឬអាយ៉ងអាចសម្តែងរឿងព្រះជិនវង្ស ព្រះលក្សិណវង្ស សង្ខសិល្បជ័យ ព្រះសុធននាងកែវមនោហ៍រា និងរឿងសម័យ ពិសេសរឿងដែលកើតមាននៅក្នុងសង្គមដូចជាការជិះជាន់ កេងប្រវ័ញ្ចរបស់ចៅកែ និងពួកអាណានិគមមកលើប្រជាជនស្លូតត្រង់ ឬការចំអកពេបជ្រាយ រិះគន់ចំពោះអ្នកជិះជាន់ទៀតផង។

ល្ខោនស្បែកធំសម្តែងក្នុងពិធីផ្សេងៗដូចជា សុំទឹកភ្លៀង ចំរើនព្រះជន្មចៅអធិការឬមាតាបិតាបូជាសពមាតាបិតាឬចៅអធិការវត្តជាដើម។ ឯស្បែកតូចអាចសម្តែងបានក្នុងពិធីបុណ្យទានទូទៅនៅតាមភូមិឬតាមវត្តអារាម។

(ដកស្រង់ចេញពីអរិយធម៌ខ្មែរ សាកលវិទ្យាល័យជាតិគ្រប់គ្រង គ.ស. ២០០៥

សូ មុយឃៀង , ទិត សៀង , ជា ឈិន ទំព័រទី ២៤៨-២៤៨)

សំណួរ


១. តើល្ខោនមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?

២. តើប្រភេទល្ខោនអ្វីខ្លះ ដែលនៅមានគេសម្តែងរាល់ថ្ងៃ ?

៣. តើប្រភេទល្ខោនអ្វីខ្លះ ដែលបាត់បាត់បង់ ? ហេតុអ្វី ?

៤. ចូរអ្នកបញ្ជាក់ន័យខ្លីៗអំពីល្ខោនអាប៉េ ល្ខោនមហោរី ល្ខោនប្រាមោទ្យ ល្ខោនបាសាក់ ល្ខោនខោល ល្ខោននិយាយ ល្ខោនយីកេ ល្ខោនស្រមោល។

រឿង ថៅកែចិត្តចោរ



ក. សិក្សាពាក្យគន្លឹះ

- ចក្រពត្តិ (ន) : ដែលមានអំណាចដ៏ពន្លឺក អ្នកជិះជាន់គេ ។
- នាយទុន (ន) : ពួកអ្នកមានទ្រព្យសម្បត្តិសុកស្តម្ភ អ្នកធ្វើជំនួញ ។
- បទឧក្រិដ្ឋ (ន) : បទល្មើស ឬដំណើរល្មើសដែលប៉ះទៅលើទោសឧក្រិដ្ឋ ។
- បះបោរ (ន) : ការមិនព្រមធ្វើតាមបញ្ជត្តិរបស់រាជការ ។
- មនុស្សធម៌ (ន) : ច្បាប់សម្រាប់ប្រដៅពួកមនុស្សឱ្យប្រព្រឹត្តសុច្ចរិត ។
- យុត្តិធម៌ (ន) : សេចក្តីត្រឹមត្រូវ ទៀងត្រង់ ការគួរតាមច្បាប់ ។
- សែហ្វ (ន) : ងារឋានន្តរសក្តិរបស់ប៉ូលិសឬទាហានកាលពីជំនាន់មុន ។ ប្រែថាលោកនាយ ថៅហ្វាយ ... ។
- អាយ៉ង (ន) : អ្នកសុខចិត្តបម្រើគេ ធ្វើតាមបង្គាប់គេជានិច្ច ។

ខ. អភិវឌ្ឍន៍បំណិន

នៅក្នុងការសិក្សាអត្ថបទល្ខោននេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយសំណួរទាក់ទងនឹងអត្ថន័យ អត្ថរូប និងអត្ថរស ។

គ. សង្ខេបអត្ថបទ

ក្រោយពីបើកឡានបុកឡានថៅកែ អុងប៉ាង ហុងលីបង្កឱ្យស្លាប់មនុស្សបីនាក់និងរបួសជាច្រើនរួចមក ពូហាំបានមករកថៅកែនៅផ្ទះដើម្បីទារប្រាក់ផ្លែឈូលចំនួនមួយម៉ឺនរៀល ដែលថៅកែជួលគាត់ឱ្យប្រព្រឹត្តអំពើនេះ ពេលមកដល់មិនជួបនឹងថៅកែទេ គាត់បានជួបនឹងផានីត។ ពូហាំបាននិយាយរឿងនេះប្រាប់ផានីត។ ផានីតបានបញ្ចុះឱ្យគាត់រត់គេច ព្រោះដឹងថារាជការកំពុងតែរកចាប់គាត់។ ពូហាំមិនព្រមធ្វើតាមផានីតប្រាប់ទេ។ ផានីតបានឱ្យពូហាំពួនរង់ចាំថៅកែ។ ពេលនោះថៅកែបានមកដល់ ពូហាំក៏ស្ទុះទៅស្មាក់ទារលុយ មួយម៉ឺនរៀលតាមការសន្យា តែត្រូវថៅកែបដិសេធធ្វើមិនដឹងមិនឮ រួចប្រាប់ឱ្យពូហាំ រត់គេចខ្លួនដោយឱ្យប្រាក់ ២០០រៀល។ ពូហាំ មិនព្រមក៏បង្កធ្វើឱ្យមានការប្រកែកគ្នាខ្លាំងឮដល់ សុខ គង់ ទ្រី ពួកគេក៏ចេញមកមើល។ ផានីតបានរៀបរាប់រឿងថៅកែឈ្លោះជាមួយពូហាំប្រាប់ពួកគេ។ ថៅកែនៅតែមិនព្រមឱ្យលុយទៅពូហាំ រីឯពូហាំវិញមិនព្រមចេញទៅណាដែរ។ គាត់នៅជជែកទាមទារ ទោះបីថៅកែគំរាមយ៉ាងណាក៏ដោយ។

នាងយ៉ានប្រពន្ធពូហាំ ដោយបាត់ប្តីមិនឃើញមកផ្ទះ ក៏ទៅផ្ទះថៅកែ ចៃដន្យបានជួបពូហាំនិងថៅកែកំពុងឈ្លោះប្រកែកគ្នា។ ថៅកែបាននិយាយកុហកនាងយ៉ានពីការប្រព្រឹត្តអំពើអាក្រក់របស់ពូហាំ។ ហើយធ្វើជាចិត្តល្អប្រាប់នាងយ៉ានថា ឱ្យពូហាំរត់គេចខ្លួនទៅ។ ថៅកែថែមទាំងឱ្យលុយទៅនាងយ៉ាន ៣០០រៀល ហាង ១០០រៀល យាយចាន់ម្តាយនាងយ៉ាន ១០០រៀលនិងមីកាទូចកូននាងយ៉ាន ១០០រៀលទៀត តែត្រូវពូហាំហាមមិនឱ្យទទួលយក។ នាងយ៉ានមិនដឹងសាច់រឿង បានជឿតាមសំដីថៅកែ។ គាត់បានអង្វរឱ្យប្តីរត់គេច ព្រោះគាត់មិនចង់ឱ្យប្តីជាប់គុក តែត្រូវពូហាំបដិសេធនិងថែមទាំងច្រលោតខឹងនឹងនាងយ៉ានជាប្រពន្ធទៀតផង។ ផានីតបានឃាត់ពូហាំ តែត្រូវថៅកែគំរាមបញ្ឈប់ពីការងារ។ ផានីតមិនខ្លាចទេ ថែមទាំងតមាត់យ៉ាងខ្លាំងជាមួយថៅកែទៀតផង។ ឮដល់សុខ ទ្រី មាន គង់ ក៏ចេញមក។ ពេលនោះ ទំនាស់កាន់តែរីកធំឡើងៗ។ ដោយជជែកបើកកកាយកាន់តែខ្លាំង ធ្វើឱ្យអ្នកទាំងអស់ដឹងពីអំពើអាក្រក់របស់ថៅកែ។ អ្នកទាំងអស់ជួយគាំទ្រខាងពូហាំ។ ឃើញហេតុការណ៍ថៅកែបានប្រើល្បិចបំបែកដោយសន្យាឱ្យលុយទៅ សុខ ទ្រី មាន និងគង់ ម្នាក់មួយម៉ឺនរៀល ដោយគ្រាន់តែជាមិនដឹងមិនឮ ពេលមាននគរបាលមកសួរ។ ប៉ុន្តែ ក្រោយពីស្តាប់ការពន្យល់របស់ពូហាំ ផានីត និងនាងយ៉ានរួចមក ពួកគេមិនព្រមធ្វើតាមថៅកែទេ។ ជាចុងក្រោយ ក្រុមនគរបាលបានចូលមកដល់។ ក្រោយពីសាកសួរដឹងរឿងហេតុអស់ហើយ សែហ្វបានបញ្ជូនទៅភ្នាក់ងារនគរបាលឱ្យចាប់ខ្លួនពូហាំនិងថៅកែបញ្ជូនទៅក្រសួងនគរបាលក្នុងគ្រានេះទៅ។

ឃ. អត្ថបទដកស្រង់

ឆាកទី ១ : ជានីតនិងតែកុងហ៊ឺ

គេឃើញជានីតនៅក្មេងរាងស្គម កំពុងកត់ត្រាចុះបញ្ជីសៀវភៅធំមួយទើប ពូហាំ ចំណាស់ពាក់កណ្តាលមនុស្សដើរចូលមកលបៗ។ ជនទាំងពីរឃើញគ្នា សម្លឹងគ្នាយូរបន្តិចទើប ពូហាំនិយាយ :

ពូហាំ : លោកក្មួយមានរឿងអ្វី បានមើលពូតាំងពីក្បាលដល់ចុងជើង ហាក់ដូចជាយើងមិនដែលស្គាល់គ្នា ?

ជានីត : ពូក្រែង ... ក្រែងឡានពូ ...

ពូហាំ : ថៅកែនៅហ្នឹងឬទេ ?

ជានីត : ចេញបាត់ពីព្រលឹមម្ល៉េះ !

ពូហាំ : យី ! ថ្មើរម៉ានទៅគាត់ត្រឡប់វិញ ពូមានរឿងប្រញាប់ជាមួយនឹងគាត់ផង

ជានីត : មើលទៅបន្តិចទៀតគាត់នឹងអញ្ជើញមកវិញហើយ។

ពូហាំ : ចុះពួកអាដែងអស់នោះ កំពុងតែរៀបចំធ្វើឡានអាផាគោឬ ?

ជានីត : បាទ !

ពូហាំ : ទៅមើលពួកអាដែងអស់នោះ មួយស្តែតសិន ! (ដើររួចទុចវិញ) ណ្តើយកុំឱ្យវាឃើញមុខនាំពិបាកចិត្តទេ។

ជានីត : អញ្ជើញអង្គុយទៅពូ (ពូហាំធ្វើតាម) ខ្ញុំឡើងលើផ្ទះសិន (ជានីតក៏ដើរយ៉ាងលឿនចេញពីទីនោះហាក់ដូចជាខ្លាចមិនហ៊ានអង្គុយជាមួយតែកុង)។

ពូហាំ : លោកក្មួយកុំទៅណាអង្គុយនៅទីនេះហើយឱ្យបានពីរនាក់គ្រាន់បានជាគ្នា (ជានីតក៏ត្រឡប់មកអង្គុយវិញ តែធ្វើជាបើកសៀវភៅធ្វើការ)។ តែកុងឡានជក់ខ្លះ ហួចខ្លះច្រៀងខ្លះ ទើបនិយាយថា យី ! ចំតែម្តងហើយ ថៅកែទៅណាក៏ក្រមកម្ល៉េះ។ លោកក្មួយ មាននរណាគេនិយាយថាអ្វីពីខ្ញុំទេ ?

ជានីត : ឮគេនិយាយតែរឿងហ្នឹង !

ពូហាំ : រឿងស្អី រឿងហ្នឹង ?

ជានីត : រឿងពីម្សិលនុ៎ះណា៎ ! ថាលោកពូបើកឡានទៅជល់ឡានអុងប៉ាងហុងលី ... ស្លាប់មនុស្សអស់ ៣នាក់និងមានរបួសជាច្រើន។

ពូហាំ : រួចដូចម្តេចទៀត ?

ជានីត : ថាលោកពូរត់បាត់។ ឥឡូវ ... រាជការប្រកាសឱ្យគេរកចាប់ខ្លួន មានទាំងផ្សាយតាមវិទ្យុផងថា បើនរណាឃើញរូបលោកពូ ឱ្យទៅជម្រាបរាជការ។ ចុះពូងងមកធ្វើអ្វីកន្លែងនេះ តិចគិញមករកមើល ម្តេចមិនគេចឱ្យបាត់ខ្លួនទៅ។

ពូហាំ : (សើច) មុខតែនឹងគេចហើយ តែធ្វើម្តេចឱ្យបានជួបថៅកែបើកលុយសិន ។

ផានីត : ប្រាក់ខែបន្តិច ពូអើយកុំស្តាយ ។ ឆាប់ទៅតិចមានគ្រោះថ្នាក់ធំ បើលោកពូត្រូវការលុយធ្វើសោហ៊ុយខ្លះ ខ្ញុំជួនខ្លះបាន (ផានីតហួតកាបូបចង់រាប់លុយឱ្យតែកុងខ្លះ) ។

ពូហាំ : (រាដៃមិនព្រមទទួលលុយ) ទុកចាយចុះលោកក្មួយ ពូមានហើយ ។ លោកក្មួយឯង មុននឹងមកធ្វើការនៅទីនេះ នៅឯណាពីមុន ?

ផានីត : នៅរៀនវិទ្យាល័យស៊ីសុវត្ថិ ។ ខ្ញុំបានខំណាស់ដែរ តែប្រលងចេះតែធ្លាក់ឥឡូវមិនចង់ត្រឡប់ទៅស្រុកសោះ ព្រោះខ្មាសគេក៏មកសុំធ្វើការនៅទីនេះយកលុយរៀនឈ្នួលយប់ៗទៀត ។

ពូហាំ : ក្មួយឯងអាយុប៉ុន្មានហើយ ?

ផានីត : ចូលឆ្នាំថ្មីនេះទៀត បាន ១៧ហើយ ។

ពូហាំ : នៅក្មេងណាស់ គ្មានទាន់បានដឹងរឿងកន្លះកន្លៀតជីវិតបន្តិចសោះ ។ ពូមកនេះបើកលុយរង្វាន់ មិនមែនបើកប្រាក់ខែទេ ប្រាក់ខែបើកចាយអស់ ១ខែមុនស្រេចទៅហើយ ។

ផានីត : រង្វាន់ដោយពូបានធ្វើការយូរមកហើយឬ ? ខ្ញុំបើធ្វើការយូរៗទៅថៅកែថានឹងឱ្យរង្វាន់ខ្ញុំដែរ គឺប្រាក់ចំណេញដែលត្រូវចែកគ្នាតាមភាគៗនោះឬ ?

ពូហាំ : រង្វាន់នោះឮគ្រាន់តែនិយាយ តែគេមិនដែលចែកទេ ។ រង្វាន់ពូ គឺរង្វាន់ក្តៅៗ ។ គឺថៅកែណាំដែលជាអ្នកបញ្ចុះឱ្យពូបុកឡាន អាហុងលី ឱ្យវាមានគ្រោះថ្នាក់ គេលែងហ៊ានជិះទៀត គេមកជិះឡានយើង ហើយថៅកែសន្យាថា បើពូធ្វើបានគាត់ឱ្យរង្វាន់ ១ម៉ឺនរៀល ។ រឿងនេះ ជារឿងសម្ងាត់កុំនិយាយឱ្យសោះ ។

ផានីត : យី ! អូអីចឹងម្សិលមិញ គឺពូបុកឡានវាដោយចេតនាតែម្តង ។

ពូហាំ : នឹងហើយ ! ដាក់អាមួយម៉ោងមួយរយ ទាន់អាឯងព្រលែងចំកណ្តាលផ្លូវជំនីរ ។

ផានីត : យី ! ពូហ៊ានធ្វើអីចឹង !

ពូហាំ : មិនហ៊ានឯណា "មួយម៉ឺនរៀល" ។

ផានីត : ចុះឥឡូវបើរាជការគេមករកចាប់ពូឯង ?

ពូហាំ : ឱ្យតែបានមួយម៉ឺនរៀលគេចប្រាវឥឡូវ ។ យូរៗភ្លេចខ្លួនបន្តំផ្លាស់ឈ្មោះ ។ [...]

ឆាកទី ៦ : មនុស្សដែលថែមកម្មករ សុខ ទ្រី មាន តង់

ថៅកែ : ចុះពួកអាអស់ទាំងនេះ ទៅណាមកណា ដើរចោលការ ? យី ! ពួកអានេះការនៅដៃវាហ៊ានដើរចោលការ ។

គង់ : ពួកខ្ញុំឮសូរមានការ ជជែកខ្លាំងពេកហាក់ដូចជាមានរឿងអ្វី បានជាបបួលគ្នាមកមើល ។

ថៅកែ: ទៅ ! នាំគ្នាទៅវិញភ្លាមទៅ ?

ទ្រី : បាទ ! សូរសុខទុក្ខលោកបងហាំបន្តិចសិន ។

ថៅកែ: ឃើ ! អាឯងអស់នេះ វាឡើងចាងទាំងអស់គ្នាហើយ ! អញនិយាយអ្វីក៏គ្មាននរណាស្តាប់ដែរ ។ ឥឡូវបើដណ្តើមតែធំទាំងអស់ បានអ្នកណាធ្វើគូលី អ្នកណាធ្វើថៅកែ ? ឬមួយអាឯងអស់នេះ ដូចជាពួកគូលីឯទៀតៗមួយថ្ងៃៗគ្មានធ្វើការអ្វីសោះ ជំនុំគ្នាតែពីគិតបះបោរដំឡើងប្រាក់ខែ ។ អញប្រាប់ឯងមុន ធ្វើជាមួយថៅកែណាទៀតបានជាមួយអញមិនបានជាដាច់ខាត ។ កើតមកជាមនុស្សក្នុងសង្គមវាតែងមានឋានៈខ្ពស់ទាបជាធម្មតា តាមចង្វាក់តាក់តែងមក ។ ចុះបើយើងចេះតែបះបោរ ចង់ស្មើមុខដូចៗគ្នា តើបាននរណាធ្វើមេ នរណាធ្វើកូន ស្តាប់បានទេ អាសុខ អាមាន ?

សុខ : បាទ !

មាន : ព្រះបាទម្ចាស់ !

ថៅកែ: អាគង់ ! អាទ្រី !

គង់ : មិនយល់ មិនដឹងជាថៅកែចង់ថាអ្វីអំបាញ់មិញ ?

ថៅកែ: ណ្តើយ ទៅអាមនុស្សមិនយល់នៅតែមិនយល់ដដែលនេះឯង ។ (កម្មករទាំងអស់រៀបទៅ)

ជានីត : កុំអាលអញ្ជើញទៅបងទាំងអស់គ្នា ។ ខាតការមួយព្រឹកចុះ ចាំជួយស្តាប់ជួយឮរឿងពូហាំផង ។

ថៅកែ: អាជានីត អាណាធ្វើអ្វីឯង ?

ជានីត : ថៅកែឯងហ្នឹង ធ្វើខ្ញុំឱ្យខ្ញុំឆ្អួតចិត្តលើមនុស្សដែលឃើញតែពីលុយ ពីមាន ។ រស់សព្វថ្ងៃរស់សម្រាប់តែគិតធ្វើម៉េចបើកលុយឱ្យហើយ ។ ក្នុងការគិតនេះគ្មានគិតល្អជាទេ គិតតែពីរកល្បិច អយុត្តិធម៌ លេងស្មៀតអាក្រក់គ្រប់យ៉ាង តាំងពីប្រើវិធីសូកប៉ាន់ វិធីកៀងមនុស្សឱ្យចូលដៃជាមួយខ្លួន រហូតដល់ធ្វើគ្រោងការសម្លាប់មនុស្ស ដែលអាចក្លាយទៅជាចំបាំងចក្រពត្តិគ្រប់យ៉ាង ដើម្បីឱ្យតែបានលុយច្រើនៗជាងគេ ។

ថៅកែ: (ស្រែក) អាជានីត ! ចេញពីផ្ទះអញឱ្យរាប់ ។

ជានីត : ខ្ញុំចោទថៅកែឯងពេញទីថា ជាចោរ ចោរជាន់ខ្ពស់ ព្រោះចេះបន្លំតែពិតជាចោរ ចោរអាក្រក់ជាងចោរឯទៀតៗផង ។ ខ្ញុំចោទថៅកែថា ជាមនុស្សសម្លាប់មនុស្សដូចជា សម្លាប់បីនាក់ក្នុងការបុកឡានពីម្សិល ។

ថៅកែ: មិនមែនអញ្ចេះទេ គឺអាហាំ។

ផានីត: មិនមែនពួហាំទេ គឺថៅកែឯងជួលពួហាំឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះ ដល់ពួហាំធ្វើហើយ មិនព្រមឱ្យ ១ម៉ឺនរៀលទៅគាត់ទៀត។ នេះហើយសេចក្តីពិត។ បងចូរដឹង បងមានបងសុខ បងគង់ បងទ្រីជួយស្តាប់ ជួយឮ ថៅកែយើងចិត្តចោរ ចោរប្លន់តែទាំងអស់គ្នា។

ថៅកែ: ទេ! ទេ! អញមិនមែនចោរទេ។ យ៉ានជួយអញផង អាមាន អាគង់ អាសុខ អាទ្រី បើមានពួកគិញមកសួរវឿងអ្វី តោងឯងជួយអញផង ចាំអញឱ្យលុយ។

ពួហាំ: នែ! មិត្តទាំងបួន! យើងជឿថា ឯងទាំងអស់គ្នាភ្លឺភ្នែកខ្លះហើយ ថៅកែនេះគ្មានគិតអាណិតយើង ស្រឡាញ់យើងដូចសំដី តែងនិយាយនោះ គិតតែពីប្រើយើង ដើម្បីយកញើសឈាមយើងទៅពួតឱ្យបានជាលុយ ជួនកាលបោកយើងដូចបោកអញ ជាភស្តុតាងស្រាប់។ លុះអំណាចចង់ចំណេញខ្លាំងពេក ថៅកែមិនញញើតនិងប្រើវិធីអមនុស្សឡើយ ពួកនេះគ្មានចេះស្នេហាជាតិ ដល់តិចតួចទេ មាតុភូមិរបស់គេ គឺ "លុយ" នេះឯង។

យ៉ាន: ពុទ្ធោអើយ!

ថៅកែ: អាបួននាក់ឯងគ្មានដឹងឮអ្វីទេណា៎! បើគេសួរ ចាំអញគិតឱ្យម្នាក់ៗ ៥០០រៀល។

ពួហាំ: លុយ ៥០០រៀល ចាយតែមួយភ្លែតអស់ហើយ។ សេចក្តីយុត្តិធម៌ទៀង បើយើងយកមកដាក់ក្នុងខ្លួនបានហើយ មិនចេះសាបសូន្យទេ។ មិត្តទាំងបួនត្រូវពិចារណាឱ្យមែនទែន។

ថៅកែ: សេចក្តីយុត្តិធម៌មានតែឈ្មោះទេ! ក្នុងលោកនេះ គ្មាននរណាប្រតិបត្តិសេចក្តីយុត្តធម៌បានឡើយ។ ពីព្រោះ ឬមួយតាមការពិតគ្មានសេចក្តីយុត្តិធម៌ទេ ឬមួយជនមួយពួកចេះតែមានរបៀបយល់លើសេចក្តីយុត្តិធម៌ប្លែកគ្នា។ យុត្តិធម៌របស់ជនមួយក្រុមខុសនឹងយុត្តិធម៌របស់ជនមួយក្រុមទៀត។ ទាំងពីរក្រុមធ្វើអំពើផ្ទុយគ្នាស្រឡះតែក្រុមមួយៗសុទ្ធតែប្រកាសខ្លួនថា ខ្លួនធ្វើតាមសេចក្តីយុត្តិធម៌ទាំងអស់។ ដូច្នេះ ទីបំផុតមានតែ "លុយ"ទេ ដែលអាចធ្វើជាអាជ្ញាកណ្តាលកាត់សេចក្តីជជែកនៅលើសេចក្តីយុត្តិធម៌ ឬអយុត្តិធម៌។ យកលុយវិញទៅអាបួននាក់អញឱ្យម្នាក់ៗ មួយពាន់រៀល បើឯងឆ្លើយថា មិនបានដឹងឮអ្វីទេ។

ផានីត: បងទាំងបួន កុំឱ្យគេយកទឹកលុយទិញទឹកចិត្តយើងបាន។ កុំធ្វើជាមនុស្ស "សំបក" សុខចិត្តលក់គំនិតឱ្យគេអស់នៅតែ "សំបកខ្លួន" សម្រាប់ធ្វើការជាអាយ៉ង ចាក់ត្តុកទៅតាមគេញាក់ ដោយកំលាំងលុយ។

ពួហាំ : មិត្តទាំងបួន ពេលនេះថៅកែត្រូវការឯង គេថាឱ្យម្នាក់ៗ ១ពាន់រៀល ដល់គេផុតត្រូវការឯង គេអាចប្រើស្មៀតមួយកាច់ពីឯងម្នាក់ជាងមួយពាន់រៀលវិញផង ពីព្រោះមនុស្សនេះគ្មានជឿលើសេចក្តីយុត្តិធម៌ លើអំពើល្អខ្ពស់ទាបឡើយ ។

យ៉ាន : ឱ ! ឪវាអើយ ! ខ្ញុំទើបតែនឹងដឹងរឿង ថៅកែចិត្តចោរ ជាមនុស្សអាក្រក់ណាស់ ។

ថៅកែ: (និយាយតែម្នាក់ឯង) នៅទីបំផុត ខ្ញុំនៅតែម្នាក់ឯងទេដឹង ! ទេដូច្នេះ មិនកើតទេ អញយកលុយអញចាយទាំងអស់ ឱ្យតែអញបានបក្សពួក គ្រាន់ធ្វើជាគ្នា កុំឱ្យចិត្តអញកំព្រាពេក ។ អាមាន ! អញឱ្យឯង ៣ពាន់រៀល អាឯងថាដូចម្តេច ?

មាន : ថៅកែ ... ថៅកែ ... ចុះអាសុខ ?

ពួហាំ : គេប្រើស្មៀតបំបែកពួកយើង ត្រូវយើងចងគ្នាជាបាច់វេញឱ្យបានទើបផ្តួលពួកជិះជាន់មនុស្សបាន ។

សុខ : ណ្លើយ លុយដែលថៅកែបម្រុងឱ្យពួកខ្ញុំ ថៅកែវេរទៅឱ្យលោកបងចុះ ។

ហាំ : ទេអាសុខ អញមិនព្រមយកលុយនេះទៀតទេ អញសុខចិត្តឱ្យវង្សត្រកូលអញស្លាប់ចុះ ដើម្បីសេចក្តីពិតផ្ទុះឡើង រួចទើបបានដឹងឮគ្រប់ៗគ្នា ហើយរកផ្លូវដោះស្រាយឱ្យបានឃើញ ។

ថៅកែ: អញមិនខ្វីឱ្យអាឯងដែរ លុយអញមាន អញសុខចិត្តដុតចោល ។

ជានីត : លោកអើយជួយស្តាប់ ពីរោះណាស់ មានលុយស៊ូដុតចោល ត្រង់អ្នកក្រមិនព្រមជួយ ។

ថៅកែ: (ចង់រត់ចេញ) នៅជជែកគ្នាជាមួយអាអស់នេះ មិនបានជាការសោះ !

ពួហាំ : ពួកយើងស្មាក់ កុំឱ្យចេញរួច ហ៊ឹមថៅកែចិត្តចោរនាយទុនទុច្ចរិតនេះឱ្យជាប់ (ទាំងអស់គ្នាធ្វើតាមកម្មករទាំងបួន ធ្វើដោយញញើតញញើម) ។

ថៅកែ: ណ្លើយ អាបួននាក់ អញនិយាយជាចុងបង្ហើយចុះ អាសុខ ១ម៉ឺន អាទ្រី ១ម៉ឺន អាគង់ ១ម៉ឺន ។

មាន : ១ម៉ឺន ថៅកែហ៊ានឱ្យមួយម៉ឺន ?

ថៅកែ: អើ ! អញឱ្យ ១ម៉ឺន ។

យ៉ាន : មានអើយ ! លុយបានដោយសំណូក ក្តៅក្រហាយ មានឯងយកទៅក៏ទុកមិនបានយូរដែរ ។ លុយរកបានដោយងាយ ចាយក៏ងាយ ប្រហែលជាមានឯង យកទៅលេងល្បែងចាញ់អស់ផងមើលទៅ ចុះដល់អស់លុយនោះទៅ មានឯងយ៉ាងដូចម្តេចទៅទៀត ក្រៅពីនិកស្តាយថា អញបានភរគេ បានក្បត់មិត្តអ្នកក្រដូចគ្នា ។ រំពឹងលើថៅកែ គេមិនមែនជួយឯងមួយជីវិតទេ គេមើលឃើញតែលុយនឹងគ្នាគេបីបួននាក់ប៉ុណ្ណោះ ។

គង់ : មែន ! ពួកយើងកុំចាញ់បោកថៅកែ កុំចាញ់បោកពួកអានាយទុនមូលធន ដែលជាឈ្លើងជញ្ជក់ឈាម អារកយើង ជិះជាន់យើង បឺតញើស បឺតឈាមយើងគ្រប់ពេលវេលា ។ យើងត្រូវតែរួមគ្នា ពួតដៃគ្នាចងសាមគ្គីឱ្យស្អិតរមួត ហើយពុះពារកសខ្ចៅឱ្យទាល់តែឃើញ ។

ទ្រី : អាគង់និយាយត្រូវ ! ខ្ញុំមិនត្រូវយកលុយ ១ម៉ឺនរបស់ថៅកែ ដើម្បីឱ្យមិត្តអ្នកក្រដូចគ្នាស្លាប់ដោយអយុត្តិធម៌ទេ ។

ជានីត : បងគង់ បងទ្រីនិយាយត្រូវណាស់ ។ ខ្លួនខ្ញុំ ក៏សុំចូលដៃជាមួយនឹងពួកបងៗដែរ ។ យើងទាំងអស់គ្នាតោងរួមដៃគ្នាចង្អុលមុខចោរ ឱ្យចំចោរជាន់ខ្ពស់ដែលចេះប្រើវិធីនិងរឿងរាប់មិនអស់សម្រាប់បំផ្លាញសង្គមខ្មែរ សង្គមមនុស្ស ។ ចោរបែបនេះ ខ្លាំងជាងចោរធម្មតា ដែលលួចប្លន់ឯកជន ព្រោះចោរលួចប្លន់ហុតឈាមខ្មែរគ្រប់គ្នាដោយប្រើវិធីបន្លំ បំបាត់ សូកប៉ាន់ និងអំពើអមនុស្សច្រើនទៀត ។ ចោរនេះ ជាចោរប្លន់ជាតិ ព្រោះចោរបែបនេះមិនខ្លាចនឹងចូលដៃនឹងបរទេស លក់ជាតិខ្មែរដើម្បីខ្លួនបានចំណេញឡើយ ។

ឆាកទី ៧ : ទាំងអស់គ្នាថែមពួកក្រុមនគរបាលចូលមក

សៃហ្វ : អ្នកណាថា ឯណាចោរ ? យើងជាក្រុមនគរបាល ប្រាប់មុខចោរយើងមក យើងចាប់ ។ (ទាំងអស់គ្នាជ្រួលភ័យ)

ភ្នាក់ងារទី ២ : កុំជ្រួលនៅស្ងៀម !

ថៅកែ : អស់លោកមករកចាប់តែកុង ហាំឬ ? ន៎ុះវា ! ខ្ញុំជាថៅកែឡាន ឥឡូវខ្ញុំប្តឹងថែមទៀតព្រោះវាបានបំផ្លាញឡានខ្ញុំឱ្យខូចដែរ ។

ពូហាំ : បាទ ! ខ្ញុំនេះហើយ តែកុងហាំ លោកចាប់ខ្ញុំចុះ ខ្ញុំមិនរត់ទេ ខ្ញុំព្រមទទួលថា បានប្រព្រឹត្តអំពើអមនុស្សធម៌មែន តែសូមលោកជ្រាបថា បើលោកចាប់ខ្ញុំ លោកត្រូវចាប់មនុស្សដែលបានណែនាំខ្ញុំឱ្យធ្វើអំពើឃោរឃៅនេះផង ។ មនុស្សនោះ ខ្ញុំមិនបាច់ជម្រាបលោកទេ ទុកឱ្យពួកទាំងអស់ គេជម្រាបលោកជំនួសខ្ញុំចុះ ព្រោះខ្ញុំជាមនុស្សមានទោស ក្រែងលោកថា សំដីខ្ញុំយកធ្វើការមិនកើត ។

ថៅកែ : (និយាយខ្សឹបៗ) អាបួននាក់អញឱ្យ ២ម៉ឺន ។

សៃហ្វ : តើមនុស្សណាមួយ ?

ជានីត : ថៅកែនេះឯង គាត់បញ្ជះ ពូហាំឱ្យបើកឡានបុកឡានអុងប៉ាង ហុងលី ដោយសន្យាថា ឱ្យពូហាំ ១ម៉ឺនរៀល ។

ថៅកែ: អានេះ វាបង្កាច់ខ្ញុំទេលោក វាស្អប់ខ្ញុំ ព្រោះខ្ញុំមិនព្រមឱ្យឡើងប្រាក់ខែ ។

យ៉ាន : លោកសែហ្វ ! រឿងថៅកែបញ្ចេះនេះ ជារឿងពិត ពួកកម្មករឡានទាំងបួននាក់នេះ ជាសាក្សីស្រាប់ ព្រោះបានដឹងដែរ ។

ពូហាំ : អាមានជម្រាបលោកដោយត្រង់ទៅ ។

ថៅកែ: អាមាន ... នែ ... (ខ្សឹប) ២ម៉ឺនរៀល ។

សែហ្វ: ម្តេចក៏នៅស្ងៀមទាំងអស់គ្នាហើយ មើលឆ្លើយប្រាប់ខ្ញុំឱ្យត្រង់មកថា តើថៅកែនេះបានប្រើតែកុងឱ្យបុកឡានគេមែនឬទេ បើមែនថាមែន បើទេថាទេ (ចង្អុលទៅកម្មករទ្រី) មែនឬអ្នកឯណោះ ?

ថៅកែ: អាទ្រី

ពូហាំ : អាទ្រី

ទ្រី : មែន !

ថៅកែ: វាភរទេ ! វាភរទេ !

សែហ្វ: ចុះអ្នកនេះ ?

ថៅកែ: អាគង់អាណិតអញ !

ពូហាំ : អាគង់អាណិតខ្លួនឯង !

គង់ : មែន !

ថៅកែ: លោកសែហ្វ ! កុំជឿវា វាចូលដៃគ្នា សម្លាប់ខ្ញុំហើយ ។

សែហ្វ: ចុះអ្នកឯណោះទៀត ?

មាន : មែន !

សុខ : មែន !

ថៅកែ: ឱពុទ្ធោអើយ !

សែហ្វ: អ្នកនេះជាប្រពន្ធតែកុងហាំឬ ?

យ៉ាន : ចាស លោក ! ប្តីខ្ញុំបានបុកឡានថៅកែ ហុងលី ព្រោះចង់បានលុយ ១ម៉ឺន ឱ្យខ្ញុំតាមសេចក្តីសន្យារបស់ថៅកែដល់ប្តីខ្ញុំ បានធ្វើអំពើនោះ ហើយថៅកែមិនព្រមបើកលុយ ១ម៉ឺនរៀលនោះឱ្យប្តីខ្ញុំផង ។

សែហ្វ: បាទ ! បាទខ្ញុំ យល់ហើយរឿងនេះ (ចង្អុលទៅជានីត) ចុះលោកប្អូនឯណោះយល់ដូចម្តេចដែរ ?

ថៅកែ: ក្មួយជានីតជួយមាផង ។

ផានីត : ខ្ញុំបាទ បានឱ្យយោបល់ហើយ គឺឈ្មោះនេះឯង ដែលខ្ញុំស្រែកចង្អុលថាចោរនោះ ពេលដែលពួកលោកមកដល់ ។ (ថៅកែអួសដៃមេនគរបាលទៅខ្សឹប) ។

សែហ្វ : តាងនាមក្រសួងនគរបាល ខ្ញុំសម្រេចថា ត្រូវនាំខ្លួនឈ្មោះ ហាំ ទៅក្រសួងនគរបាលជាតិ ទៅចូលចាប់ (ភ្នាក់ងារនគរបាល ក៏ប្រតិបត្តិតាម ចាប់តែពួហាំ) ។

ពួហាំ : អរគុណហើយចិត្តទាំងអស់គ្នា ។ ម៉ែវាថែទាំកូននិងម្តាយឱ្យបានស្រួលផង ។

ថៅកែ : ពួកឯងទាំងអស់ឈប់ធ្វើការពីផ្ទះអញទៅ ទៅណាទៅចុះ ! ពួកអាក្រពើ !

សែហ្វ : ទៅ ! ទៅក្រសួងនគរបាល ។ (ច្រានដៃនិងវាយពួហាំ)

យ៉ាន : (ដោយស្រែកយំ) លោកអើយកុំធ្វើបាបប្តីខ្ញុំ (រត់ចេញទៅ) ។

គង់ : ឱ ! អ្នកក្រអើយ ! តើខែណា ! ឆ្នាំណា ! សតវត្សណា ! ទើបបំរះរួចពីការជិះជាន់បែបនេះ ។ តើកាលណាទើបមានយុត្តិធម៌ ?

សែហ្វ : ឈប់ ! ឈប់និយាយ(ប្រាប់នគរបាល) ចាប់វាភ្លាម ! នគរបាលចូលចាប់គង់ទៀត ។

ផានីត : បញ្ហាស្រដៀងគ្នាបានចោទពេញទំហឹង នៅក្នុងសង្គមខ្មែរសព្វថ្ងៃដែលទើបនឹងរួចពីការជិះជាន់របស់អាណានិគម គ្រាន់តែចាប់ពួហាំទៅដាក់គុក មិនមែនដោះស្រាយបញ្ហាទាំងនេះបានច្បាស់លាស់ទេ នាទីយើងឥឡូវគ្រាន់តែស្តែងឡើងឱ្យលោកអ្នកចាប់អារម្មណ៍ លើបញ្ហាសង្គមខ្មែរខ្លះឱ្យបានច្បាស់ ផ្លូវសម្រាប់ដោះស្រាយ លោកទាំងអស់គ្នាជួយគិតចុះ នៅពេលដែលលោកអ្នកបានមកឃើញរឿងប្រឌិតលើរឿងនៃបញ្ហាខ្លះ នៅសង្គមខ្មែរយើងរួចហើយនេះ ។

(ដកស្រង់និងកែសំរួលពីរឿង ថៅកែចិត្តចោរ ឆ្នាំ ១៩៨៩ ត្រង់ឆាកទី ៤ ដល់ឆាកទី ៧)

សំណួរ

១. ចូរអ្នកធ្វើការវិភាគតួអង្គហាំ ផានីត យ៉ាន ថៅកែ សែហ្វ ។

២. តើកត្តាអ្វីខ្លះ ដែលនាំឱ្យហាំសម្រេចចិត្តលើកឡានបុកឡានថៅកែអុងប៉ាងហុងលី ? ការសម្រេចចិត្តប្រព្រឹត្តបែបនេះបានជះឥទ្ធិពលចំពោះផ្លូវច្បាប់ ផ្លូវសីលធម៌ និងផ្លូវសាសនាយ៉ាងណាខ្លះ ?

៣. តាមរយៈតួអង្គហាំ ផានីត សែហ្វ បានផ្តល់តម្លៃអប់រំយ៉ាងណាខ្លះ ?

៤. ចូរអ្នកធ្វើការបង្ហាញពីវិធីតែងនិពន្ធនៃអត្ថបទល្ខោនខាងលើនេះ ។

៥. ដោយឆ្លុះបញ្ចាំងតាមរយៈសកម្មភាពតួអង្គក្នុងរឿងនេះ ចូរអ្នកបង្ហាញពីសច្ចរស សង្គមរស តថរស វីររស កុសលរស ។

៦. តើអត្ថបទខាងលើ អ្នកនិពន្ធបានបង្ហាញពីប្រធានរឿងអ្វី លើកយកបញ្ហាអ្វីមកចោទនិងស្រាយ ហើយមានគំនិតជីកនាំ(ឧត្តមគតិរឿង)យ៉ាងដូចម្តេច ?



ការតែងនិពន្ធរឿងល្ខោន

អ្នកបានសិក្សារួចមកហើយអំពីវិធីតែងនិពន្ធអក្សរសិល្ប៍។ នៅពេលនេះ អ្នកនឹងត្រូវតាក់តែងរឿងល្ខោនខ្លាតខ្លី។ ដូច្នេះ អ្នកត្រូវស្គាល់ចំណុចសំខាន់ៗមួយចំនួនរបស់រឿងល្ខោន។ ខ្មែរយើងមានល្ខោនច្រើនប្រភេទដូចជា ល្ខោនបាសាក់ ល្ខោនយីកេ ល្ខោនមហោរី ល្ខោននិយាយ ល្ខោនខោល ល្ខោនអាប៉េ ល្ខោនស្រមោល (ស្បែកធំ ស្បែកតូច) ។ល។

អត្ថបទល្ខោន គឺជាអត្ថបទអក្សរសិល្ប៍មួយប្រភេទដែរអ្នកនិពន្ធចងក្រងឡើងមាន ឆាក ឈុត សម្រាប់យកទៅសម្តែងជាសិល្បៈល្ខោន។ អត្ថបទរឿងល្ខោនស្រដៀងគ្នានឹងប្រភេទអត្ថបទរឿងផ្សេងៗទៀតដែរ ចំពោះធាតុសំខាន់ៗដូចជា ចំណោទបញ្ហា តួអង្គ កាលអាកាស និងមូលន័យ។

ទម្រង់សំណេររបស់អត្ថបទល្ខោនខុសពីទម្រង់សំណេររបស់អត្ថបទរឿង។ អត្ថបទល្ខោនចែកជាឈុតនិងឆាក។ នៅខាងដើមអត្ថបទល្ខោននីមួយៗមានបញ្ជីរាយនាមតួអង្គនិងឋានៈ ឬប្រភពកំណើតរបស់តួអង្គ។

អត្ថបទល្ខោនអាចសរសេរជាពាក្យកាព្យ ឬពាក្យរាយ និងជាពំនោល ឬបទសន្ទនារវាងតួអង្គនិងតួអង្គ។ ក្នុងអត្ថបទល្ខោននិយាយ អ្នកនិពន្ធសរសេរសេចក្តីបញ្ជាក់រូប ទឹកមុខ កាយវិការ ឬសំឡេងរបស់តួអង្គដាក់ក្នុងវង់ក្រចក។

ក. អត្ថន័យ

ជារឿងធម្មតាដែលបង្ហាញពីការទាស់ទែងខ្វែងគំនិតគ្នារវាងតួអង្គដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នា។ ដំណើររឿងមានលក្ខណៈតឹងតែង ធូរស្រាលប្រកបដោយជ័យជំនះ បរាជ័យ មានស្លាប់មានរស់ មានកំសត់ មានកំប្លែងលាយឡំគ្នា។ អ្នកអានមិនរំភើបពេក មិនតក់ស្លុតពេក មិនភ័យពេក មិនកើតទុក្ខពេក និងមិនសប្បាយលើសលប់ពេក។

ខ. អត្ថរូប

គេតែងចែករឿងល្ខោនជាឈុត ឆាក ដោយគ្មានចំនួនកំណត់សម្រាប់យកទៅសម្តែង។ រឿងខ្លះមានច្រើនឈុត ឆាក ឯរឿងខ្លះទៀតមានតិច អាស្រ័យទៅតាមទំហំនៃសាច់រឿងវែងឬខ្លី និងអាស្រ័យទៅលើភាពប៉ិនប្រសប់ច្នៃប្រឌិតរបស់អ្នកនិពន្ធម្នាក់ៗ។ ពាក្យពេចន៍ក្នុងដំណើររឿង គឺជាពាក្យសន្ទនារវាងតួអង្គច្រើនរូបដែលគេហៅថា សំវាទវិធី។ អ្នកនិពន្ធគ្មានធ្វើការពណ៌នាពីរូបលក្ខណៈតួអង្គ សកម្មភាពតួអង្គ ឬរៀបរាប់ពីធម្មជាតិឡើយ។ ដំណើររឿងក្តី សកម្មភាពក្តី គឺសម្តែងឡើងតាមរយៈសំវាទវិធីទាំងអស់។

គ. អត្ថរស

អ្នកនិពន្ធបញ្ចូលនូវគំនិត យោបល់ ទស្សនៈ ជំបូន្មានរបស់ខ្លួនទៅក្នុងសកម្មភាពនៃរឿង។ ពាក្យពេចន៍ចរចាដើម្បីរិះគន់ ប្រដៅណែនាំ ទូន្មានអ្នកអាន អ្នកទស្សនា។ ដូច្នេះ គេតែងល្ខោនដោយប្រត្យក្សភាព ដើម្បីបង្កើតប្រត្យក្សរស ពោលគឺគេយកកំហុសគុណវិបត្តិ អំពើឆ្គាំឆ្គងរបស់មនុស្សដែលត្រូវរិះគន់សម្រាប់ណែនាំអប់រំមកបញ្ចូលក្នុងពាក្យសម្តី សកម្មភាព កាយវិការរបស់តួអង្គ យកទៅសម្តែងបង្ហាញទស្សនិជនបានឃើញនឹងភ្នែក។ លក្ខណៈជាតម្លៃឃើញប្រត្យក្សនឹងភ្នែកនេះ ហើយដែលរឿងល្ខោនផ្តល់នូវកុសលនិងការអប់រំ ណែនាំ ទូន្មានប្រជាជន។

លំហាត់

ចូររៀបគ្នាជាក្រុម រួចពិភាក្សាតែងរឿងល្ខោននិយាយ ល្ខោនបាសាក់ យីកេ ខ្នាតខ្លីមួយរឿង។ ក្នុងការតាក់តែងអ្នកត្រូវយកចិត្តទុកដាក់ទៅលើ ៖

- ការរាយឈ្មោះតួអង្គនិងតួនាទី មុខងារនៅខាងដើមរឿង
- ការរៀបចំសាច់រឿងជាឈុត ឆាក
- ការរៀបចំសំណេរជាអត្ថបទសន្ទនារវាងតួអង្គនិងតួអង្គ
- ការបញ្ជាក់សកម្មភាព កាយវិការ ទឹកមុខ សំឡេងតួអង្គដោយសរសេរក្នុងវង់ក្រចក។


សិលាចារឹកនិងវចាំ

	សតវត្សទី៩	សតវត្សទី១០	សតវត្សទី១១	សតវត្សទី១២	សតវត្សទី១៣
អក្សរ					
ព្យញ្ជនៈ					
ស្រៈ					
ព្យញ្ជនៈ					
ស្រៈ					
ព្យញ្ជនៈ					
ស្រៈ					
ព្យញ្ជនៈ					
ស្រៈ					
ព្យញ្ជនៈ					
ស្រៈ					



បើគេនិយាយពីវប្បធម៌ អរិយធម៌ខ្មែរបច្ចុប្បន្ន គេគប្បីដឹងថាជាផលនៃការវិវត្តចេញពីមូលដ្ឋានគ្រឹះមន-ខ្មែរ និងឥណ្ឌាគឺពុំអាចផ្តាច់ចេញពីគ្នាបានឡើយ។ ការសំយោគនៃវប្បធម៌ខាងលើនេះជាហេតុនាំឱ្យវប្បធម៌ អរិយធម៌ខ្មែរសម្បូរបែប។ ប៉ុន្តែមុនពេលសំយោគនៃវប្បធម៌នេះ វាបានផ្តើមឡើងនាសម័យប្រវត្តិសាស្ត្រ ឬមុននេះបន្តិចដែលវប្បធម៌ខ្មែរមានលក្ខណៈជាតិខ្លួនរួចជាស្រេចមកហើយ។ ចំពោះលក្ខណៈពិសេសនេះ ត្រូវបានបន្តដោយសហគមន៍ស្ថិតក្នុងអំបូរមន-ខ្មែរនៅឥណ្ឌូចិន និងម៉ាឡាយូ រហូតមកដល់សព្វថ្ងៃដែលមានរស់នៅតំបន់ខ្ពង់រាបឬតាមតំបន់ព្រៃភ្នំ ហើយពុំអាចទទួលឥទ្ធិពលពីឥណ្ឌា ចិន ឬអឺរ៉ុបនៅឡើយ។ ដូច្នេះ ពួកគេក៏មិនត្រូវបំភ្លេចបំបាត់នូវរាល់តួនាទីជាប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរ ព្រមទាំងកុលសម្ព័ន្ធមនខ្មែរ ដែលកំពុងរស់នៅពាសពេញភូមិភាគអាស៊ីអាគ្នេយ៍នេះដែរ។ ដូចនេះ គេត្រូវស្គាល់ជនជាតិខ្មែរឱ្យបានច្បាស់លាស់ជាជនជាតិចាស់និងមានសារតារដ៏យូរលង់ណាស់មកហើយ។ យ៉ាងនេះហើយទើបអក្សរសាស្ត្រនិងសិល្បៈដែលចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិតខ្មែរ ក៏បានបង្ហាញខ្លួនតាមរយៈសិលាចារឹករាប់ពាន់ផ្ទាំង ក្បាច់សម្តែងរាប់មិនអស់មានអត្ថន័យផ្សេងៗដែលឆ្លុះបញ្ចាំងជីវភាពខ្មែរនាសម័យដើម។ ជាមួយនឹងភាពមិនចេះរីងស្ងួតនៃមរតកវប្បធម៌ដែលបន្សល់ទុកដោយបុព្វបុរសយើងបែបនេះហើយ ទើបជនជាតិខ្មែរមានកិត្យានុភាពល្បីសុសសាយ ពាសពេញទ្វីបលោក។

សិលាចារឹក (ប្រាសាទភិមានអាកាស)



ក. សិក្សាពាក្យគន្លឹះ


- សករាជ (ន) : ការរាប់ថ្ងៃខែឆ្នាំ ឬការរាប់ត្រឹមតែឆ្នាំ តាមកាលកំណត់ដែលតាំងទុកពីមួយរៀងមកដោយមានបុគ្គលអស្ចារ្យណាមួយដែលពួកជនានុជនអ្នកគោរពត្រូវកត់ត្រាទុកមិនឱ្យបាត់ ។
- សច្ចាប្រណិធាន (ន) : តាំងប្រកាសពាក្យពិត ការសំបួងសង្រួង ការប្រកាសពាក្យសម្បថ ។
- ព្រះរតន: (ន) : ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ (ព្រះរតនត្រ័យ) ។
- គម្ពែង (ន) : (ក្លាយឃ្លាតមកពីពាក្យខ្មែរ ក្នុងសម័យបុរាណព្រេងនាយថា កម្រតាង >កម្រតេង > កម្រតែង) មានន័យថាព្រះតេជព្រះគុណ លោកជាម្ចាស់ លោកអ្នកមានបុណ្យច្រើនគួរជាទីគោរព គួរធ្វើសក្ការបូជា លោកអ្នកមានស័ក្តិយសខ្ពង់ខ្ពស់ ។
- អម្ចាស់ (ន) : អ្នកមានអំណាចកាន់កាប់អ្វីៗដែលជារបស់ខ្លួន ឥស្សរជន ម្ចាស់ទ្រព្យ ម្ចាស់បំណុល ម្ចាស់ផ្ទះ ។
- ពាក្យសម្បថ (ន) : ពាក្យសច្ចៈ ការសច្ចៈ ។
- នរក (ន) : ទីអបាយភូមិ ឬអធោលោក ដែលមានរណ្តៅជាលំនៅនៃសត្វមានបាបនៅរងទុក្ខតាមកម្លាំងកម្មដែលខ្លួនធ្វើ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទសិលាចារឹកនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងនឹងអត្ថន័យនៅលើសិលាចារឹក ទម្រង់ព្យញ្ជនៈ ស្រៈ រចនាបថ ។

គ. អត្ថបទ

អត្ថបទសិលាចារឹកដើម



អត្ថបទពាក្យសម្បថដែលសរសេរតាមលំនាំអក្សរខ្មែរបុរាណ

៩៣៣ កកនវមី កេត ភទ្របទ អាទិត្យវារ១នេះគិ រោះហ វន្ទប្រតិជ្ញា១ យេង្ក អំបាល្ល នេះហនា ភាគ តម្រាច ឯក (ទោ ករតីណិ ចត្វារី) ស្បង្ក គបថ វេលា កាត្តៃ ថ្ងាយ អាយុះ នុកតជ្ញ ភក្តីយេង តគុទ្ធ ត ធ្លលើ ព្រះបាទកម្រតេង កំតូន អញ្ច គ្រី សួយ្យីវម្ម៌ទេវ ត សកល ស្ងេយ ព្រះធម្មិរាជ្យនុ ៩២៤ គក ន្ទេក្ខិ តព្រះ ស្តេង ព្រះ រត្ន នុ ព្រាហ្មណាចាយ្យី១ យេង រ្វំ បង្គំ ត កម្រតេង ផ្ទៃ កំរោតទៃតិលេយ រ្វំ ខ្នាង្គិ រ្វំ សំ នុខ្នាង្គ រ្វំ ថ្ងេ ទ្រោហ ប្រការ ផោង១ នៅអំបាល្ល អំវេ ផល ក តជ្ញភក្តិ ត ធ្លលើ ព្រះ បាទ កម្រតេង កំតូន អញ្ច គ្រី សួយ្យីវម្ម៌ទេវ នោះគិបិ យេងឧទ្យោគ ថ្ងេ១ ទហ មានចំបាង្គ យេងឧទ្យោគ ឆ្បាងនុ សវ៉ាត្មណា រ្វំស្ងន្ត អាយុះ ហេតុ ភក្តិ រ្វំ រត លេង ចំបាង្គ១ ទហ អ្សត ចំបាង្គ បិយេង ស្លាប នុ សូយ៌ំវ្យាធិ មុហ្ម្ចិ លេង ផល្លអ្នក ត សូមិភក្តិ មានុយេង្គ១ ទហ អាយុះ យេង អាច ទន្ត ព្រះរាជកាយ្យី វេលា ល្ងោះ ត ព្ធ ស្ងេង បិ ត្យង វស្តុ ត វ្យក្ត ថ្ងេរោះហ វន្ទប្រតិជ្ញា ទិទៃរ១ ទហ យេង្ក អំបាល្ល នេះហ មានុ នុ រ្វំ ថ្ងេ រោះហ វន្ទប្រតិជ្ញា នេះហ រីយ កម្រ តេងផ្ទៃ ករោំ ត ស្ងេយ ព្រះធម្មិរាជ្យ ចំនួរ សុំ លេង ឧយ រាជភយ ត យេង រ្វំ ម្ងាយប្រការ១ ទហ យេងមានុ កបត បិ រ្វំ ផ្តត រោះហ ប្រតិជ្ញា តរោះហ នេះហ លេង យេង ជាត ទ្វាត្រីគនរក តរាប ព្រះ ចន្ទ្រាទិត្យ មាន លេយ ០ ទហ យេង ថ្ងេ រោហាះ វន្ទប្រតិជ្ញា នេះហតគុទ្ធ លេង កម្រតេង ផ្ទៃ ករោំប្រេ បរិបាលន ព្រះ បុនួ្យ ស្រុក ទេក យេង លេង សំបួរណ អ្នៅ ត កុលេ យេង ហេតុ យេង

ស្វាមីភក្តិ ត ធូលី ជ្រះ បាទ កម្រតែង កំតូន អញ្ជ ត្រីសូយ៌្យវម្ម៌ទេវ ត សកល ស្មេយ ជ្រះធម្ម៌រាជ្យ នុ ៩២៤ គក ០ វិយ ផល អ្នក ស្វាមីភក្តិ លេង មាន្ត យេង្ហ អំវិ ឆ្លាហាលោក ទៅលោះហាបរលោក០

អត្ថបទពាក្យសម្បថសរសេរតាមលំនាំអក្សរខ្មែរបច្ចុប្បន្ន :

មហាសករាជ ៩៣៣ ប្រាំបួនកើត ខែភទ្របទ ថ្ងៃអាទិត្យ។ នេះគឺពាក្យសច្ចាប្រណិធានរបស់ទូលព្រះបង្គំទាំងអស់គ្នា។ (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នាជាតំរួតរបស់ភាគ(តំបន់) ថ្នាក់(ឯក ទោ ត្រី ចត្វា) នៅពេលស្បថ (ទូលបង្គំ) យើង (ខ្ញុំ) សូមសច្ចាកាត់ដៃថ្វាយអាយុនិងថ្វាយនូវកតញ្ញូភក្តីភាពដ៏បរិសុទ្ធផ្ទួរផង់ចំពោះព្រះករុណាព្រះបាទសម្តេច ស្រីសូយ៌្យវម្ម៌ទេវៈ(សូរ្យវរ្ម័នទី ១)ដែលបានសោយរាជ្យជាសកលនៅឆ្នាំ ៩២៤ នៃមហាសករាជនៅចំពោះមុខព្រះភ្លើងព្រះរតនៈនិងព្រាហ្មណាចារ្យទាំងឡាយ។ (ទូលបង្គំ) យើង (ខ្ញុំ) មិនបង្គំ(គោរព) គម្តែងផ្ទៃក្រោមដទៃឯទៀត(ក្រៅពីព្រះអង្គ) ឡើយពុំ(ធ្វើជា) ខ្មាំងនិងពុំចំណុះខ្មាំង(ចូលដៃសមគំនិតជាមួយខ្មាំងសត្រូវ) ពុំធ្វើការអ្វីដែលនឹងនាំមកនូវសេចក្តីវិនាស(ចំពោះព្រះអង្គ) ឡើយ។ រាល់អំពើផងទាំងឡាយ ដែលជាផលនៃស្វាមីភក្តីភាព (ទូលបង្គំ) យើង (ខ្ញុំ) ចំពោះព្រះករុណាព្រះបាទ ស្រីសូយ៌្យវម្ម៌ទេវៈ (ទូលបង្គំ) យើង (ខ្ញុំ) នឹងខិតខំប្រឹងធ្វើឱ្យបានសម្រេច។ ទោះបីមានចំបាំង (ទូលបង្គំ) យើង (ខ្ញុំ) ប្តេជ្ញាច្បាំងដោយស្មោះអស់ពីចិត្តដោយឥតស្តាយអាយុជីវិតឡើយ។ ដោយស្វាមីភក្តីភាព(ចំពោះព្រះរាជា) (ទូលបង្គំ) យើង (ខ្ញុំ) មិនរត់ចោលចំបាំងឡើយ។ ទោះគ្មានចំបាំង ប្រសិនបើ (ទូលបង្គំ) យើង (ខ្ញុំ) ស្លាប់ដោយសារជំងឺបៀតបៀន គឺថាសូមឱ្យ (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នាបានទទួលនូវផល(រង្វាន់) ជាអ្នកមានកតញ្ញូភក្តី ចំពោះអម្ចាស់របស់ខ្លួន។ ប្រសិនបើអាយុជីវិតរបស់ (ទូលបង្គំ) យើង (ខ្ញុំ) អាចទាន់ព្រះរាជការ(អាចបម្រើការងាររាជការ) តទៅរហូតដល់ពេលស្លាប់(ក្នុងមុខងារ) (ទូលបង្គំ) យើង (ខ្ញុំ) នឹងបម្រើកិច្ចការនោះ ដោយហេតុថា(ទូលបង្គំ) យើង (ខ្ញុំ) មានស្វាមីភក្តី(ចំពោះព្រះរាជា)។ ប្រសិនបើមានព្រះរាជការ ដែលព្រះមហាក្សត្រ(ទ្រង់ត្រាស់) បន្ទូលប្រើ (ទូលបង្គំ) យើង (ខ្ញុំ) ទៅទីឆ្ងាយដោយសារមានព្រឹត្តិការណ៍ ដែលព្រះរាជាបានព្រះគេនិយាយនោះ (ទូលបង្គំ) យើង (ខ្ញុំ) នឹងរកវិធីស្វែងយល់រឿងនោះឱ្យបានល្អិតល្អន់និងប្តេជ្ញាធ្វើតាមពាក្យសច្ចាប្រណិធានរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនរៀងៗខ្លួន។ ប្រសិនបើក្នុងចំណោម (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នានោះមានអ្នកមិនធ្វើតាមពាក្យសច្ចាប្រណិធាននេះ ចំពោះព្រះមហាក្សត្រដែលសោយរាជ្យដ៏យូរលង់ក្រោយៗទៀត (ទូលបង្គំ) យើង (ខ្ញុំ) មានល្បិចកលមិនគោរពខ្ជាប់ខ្ជួននូវពាក្យសម្បថនេះ សូមឱ្យ(ទូលបង្គំ) យើង (ខ្ញុំ) ធ្លាក់ទៅកើតក្នុងឋានឥរកទាំង ៣២ជាន់ អស់កាលដ៏យូរ ដរាបណានៅព្រះអាទិត្យនិងព្រះចន្ទ។ ប្រសិនបើ (ទូលបង្គំ) យើង (ខ្ញុំ) ទាំងអស់គ្នាបំពេញបានល្អបរិសុទ្ធ តាមពាក្យសច្ចាប្រណិធាននេះ សូមគម្តែងផ្ទៃ

ក្រោមទ្រង់ព្រះមេត្តាព្រះរាជទាន(ប្រើ) ឱ្យ (ទូលបង្គំ) យើង (ខ្ញុំ) បានថែទាំនូវការស្ថាបនាជាកុសលរបស់ស្រុកទេសយើងនិងផ្តល់នូវភាពស្ថិតស្ថេរសម្បូណ៌រុងរឿងនៃវង្សត្រកូលរបស់ (ទូលបង្គំ) យើង (ខ្ញុំ) ដោយហេតុថា (ទូលបង្គំ) យើង (ខ្ញុំ) មានកតញ្ញូភក្តីភាពចំពោះល្អងធូលីព្រះបាទ(គម្លែងផ្ទៃក្រោម) សម្តេចព្រះសួយ្យវរ្ម្មិទេវៈ ដែលព្រះអង្គបានសោយរាជ្យជាសកលនៅឆ្នាំ ៩២៤ នៃមហាសករាជ។ សូមឱ្យផល(រង្វាន់) នៃអ្នកមានស្វាមីភក្តិចំពោះព្រះរាជា ជាអម្ចាស់របស់ខ្លួនកើតមានដល់ (ទូលបង្គំ) យើង (ខ្ញុំ) ចាប់ពីលោកនេះ រហូតដល់បរលោក។

(ដកស្រង់ចេញពីទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំទី ៤៩ លេខ ១ ឆ្នាំ ១៩៩៤)

សំណួរ

១. តើអត្ថបទពាក្យសម្បថនេះ បានតាក់ឡើងនៅពេលណា ? មានបុគ្គលណាជាអធិបតី ? ហើយអ្នកណាជាអ្នកស្បថ ?

២. ចូរបង្ហាញពីប្រធានបទនៃអត្ថបទដកស្រង់ មូលន័យ គំនិតអប់រំ។

៣. តើខ្លឹមសារនៃអត្ថបទនេះ អាចចែកចេញជាប៉ុន្មានផ្នែក ? មានអ្វីខ្លះ ?

៤. រកគំនិតអប់រំតាមរយៈអត្ថបទនេះ។

៥. ចូរអ្នកសាកល្បងអានសិលាចារឹក ដែលសរសេរតាមលំនាំខ្មែរបុរាណនិងប្រែជាភាសាខ្មែរទំនើបខាងលើនេះ។

ក. បង្ហាញពីលក្ខណៈជាតិ ដោយរកអំណះអំណាងជាពាក្យទំនឹមទំនៀម ចំនួនពីរបីឃ្លាដែលមានអត្ថន័យទាក់ទងនឹងខ្លឹមសារនៃអត្ថបទសិលាចារឹកនេះ។

ខ. បកស្រាយពីអត្ថន័យនៃមហាសករាជ។ ក្រៅពីមហាសករាជ តើជាតិខ្មែរធ្លាប់ប្រើសករាជអ្វីទៀត ? ចូរពន្យល់។

គ. បង្ហាញពីសំណេរភាសាខ្មែរសម័យទំនើបនិងពន្យល់ពាក្យដែលមានក្នុងអត្ថបទដើម : ព្រះព្រាហ្មណាចារ្យ៌ ចំបាង អំបាល។

ឃ. ពាក្យ "នេះហ" ត្រូវនឹងសំណេរភាសាខ្មែរទំនើបយ៉ាងដូចម្តេច ? បើគិតតាមសូរវិទ្យាអន្តរជាតិ (API) វិញ តើព្យញ្ជនៈខ្យល់ "ហ" ត្រូវនឹងព្យញ្ជនៈខ្យល់ស្នះ ព្យញ្ជនៈខ្យល់ច្រមុះ ឬព្យញ្ជនៈខ្យល់បង្ហួរ ? ហើយ "នេះហ"ស្ថិតក្នុងទម្រង់ណាមួយ (ពស ពពស ពសព ឬពពសព) ? បើតាមអ្នកធ្លាប់សិក្សាកន្លងមក តើមានពាក្យ ១ព្យាង្គណាខ្លះទៀត ដែលមានសូរចុងព្យាង្គដោយខ្យល់ "ហ"នេះ ? ចូររកឧទាហរណ៍ឱ្យបានប្រាំពាក្យ (ពាក្យ ១ព្យាង្គ)។

របាំបុរាណខ្មែរ



ក. សិក្សាពាក្យគន្លឹះ

- វប្បធម៌ (ន) : ការផ្សាំបណ្តុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីឱ្យបានលូតលាស់ចម្រើនដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗជាដើម ។
- អរិយធម៌ (ន) : ធម៌ដែលនាំឱ្យកើតសេចក្តីសុខចម្រើនខ្ពង់ខ្ពស់ ។
- ប្រារព្ធ (កិ) : តាំងផ្តើម ផ្តួចផ្តើម ផ្គងជាមុន ប្រុងប្រៀប ។
- មហោស្រព (ន) : ការលេងល្បែង ការរីករាយសប្បាយខ្លាំងដោយល្បែងរបាំ ការបញ្ចេញរបស់ប្លែកៗដាក់តាំងជារបៀបយ៉ាងធំឱ្យមហាជនមើល ។
- ប្រជាប្រិយភាព (គុ) : ដែលជាទីស្រឡាញ់របស់ប្រជា ដែលគួរឱ្យប្រជារាស្ត្រស្រឡាញ់ពេញចិត្ត ដែលសម្រាប់ប្រជាពលរដ្ឋទូទៅ ។
- ឧប្បត្តិក (ន) : ការកើត ការចាប់កំណើត ការចាប់ជាតិ ។
- មកុដ (ន) : គ្រឿងប្រដាប់ធ្វើដោយមាសសុទ្ធ មានរាងក្រឡុម មានកំពូលរំលេចដោយក្បាច់រចនាដ៏វិចិត្រដាំត្បូងសម្រាប់ក្សត្រិយ៍ទ្រង់រាជ្យទ្រង់ពាក់ព្រះសិរវាប់បញ្ចូលក្នុងរាជកកុធភណ្ឌ ។
- ក្សត្រីយានី (ន) : ស្ត្រីដែលមានពូជពង្សដ៏ប្រសើរ ស្តេចស្រីដែលមានពូជពង្សដ៏ខ្ពង់ខ្ពស់ ។

ខ. អភិវឌ្ឍន៍បំណិន

អត្ថបទនេះអ្នកនឹងបានស្គាល់ពីរបាំអប្សរា គ្រឿងអលង្ការក្នុងសម្តែងនិងលក្ខណៈជាតិនៅក្នុងរបាំអប្សរា ។

គ. អត្ថបទ

បុព្វបុរសខ្មែរ បានបង្កើតរបាំបុរាណមានភាពល្អឥតខ្ចោះ មានឈ្មោះល្បីល្បាញលើឆាកអន្តរជាតិ ។ គេប្រៀបប្រដូចថា ជាទេវតាបង្កើត ។ អ្នកប្រាជ្ញផ្នែកខាងសិល្បៈបានចាត់ជាបេតិកភណ្ឌវប្បធម៌អរូបីសម្បត្តិរបស់មនុស្សជាតិនៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។

របាំបុរាណនេះជាសិល្បៈសម្រេចឥតកែប្រែឡើយ គឺជាសិល្បៈពិសិដ្ឋ ។ ការតាក់តែងកាយច្រើនបង្ហាញពីភាពខ្ពង់ខ្ពស់ ដែលប្រកបទៅដោយសម្លៀកបំពាក់ភ្លឺចិញ្ចាចចិញ្ចែង មានរស្មីដូចព្រះអាទិត្យ ឬព្រះចន្ទសម្រាប់ពពួកទេវតា ឬពពួកអ្នកស្ថានសួគ៌ ។ ម៉្យាងទៀតសិល្បៈនេះមានលក្ខណៈហួសពីសោភណាទិទ្យា បានផ្តល់ឱ្យទស្សនិកជនរំភើបអណ្តែតត្រសែតទៅរកពិភពនៃក្តីស្ងប់និងត្រជាក់ពេញចិត្ត ។ អ្នកប្រាជ្ញខាងសិល្បៈក៏បានទទួលស្គាល់ទៀតថា ជាសិល្បៈពិសេសខាងកាយវិការ ដែលមានលក្ខណៈប្លែក តែជាសកល ។ ទោះបីជាមានកាយវិការខ្លះ មានការលំបាកយល់ ចំពោះជនសាមញ្ញតែក៏បានផ្តល់ឱ្យគេជក់អារម្មណ៍ពីសម្ផស្សនៃរូបារម្មណ៍ដែរ ។ ក្បាច់ទន់ភ្ញន់អែនអន បានបញ្ចេញក្នុអ្នកទស្សនាឱ្យកើតនូវក្តីស្រមៃ ឬកំពុងស្ថិតក្នុងពិភពសួគ៌ា ហើយផ្តិតយកនូវរូបភាពមួយចំនួន ដែលបង្កឱ្យគេកើតក្តីសុខដុម ។ ឯការរៀបចំឆាកច្រើនមានលក្ខណៈជានិមិត្តរូបដូចជា ការលំអដោយមានជាក់ដើមឈើបញ្ឆរ តែប្រើពណ៌ទឹកមាស ឬទឹកប្រាក់ដែលគេហៅថា ដើមមាសដើមប្រាក់ ហើយបើមានស្លឹកផ្លែផ្កានោះ ក៏ជាមាសឬប្រាក់ដែរ ។ ចំពោះតួសម្តែងត្រូវសម្តែងក្នុងលក្ខណៈជាសត្វក៏ដោយ ក៏សត្វនោះច្រើនស្ថិតក្នុងលក្ខណៈខ្ពង់ខ្ពស់ទៀតដែរ ។

របាំបុរាណខ្មែរ គឺជាសិល្បៈគំនិតដែលប្រើនិមិត្តរូបនិយម ។ ការបង្កើតក្បាច់គឺចេញពីមូលដ្ឋានជីវិតនិងធម្មជាតិ ។ ក្បាច់ទាំងនេះយើងមើលទៅឃើញថា មានលក្ខណៈយឺត ហើយហាក់ដូចជាទន់ជ្រាយ តែធាតុពិតគឺទន់ភ្ញន់ ។ គ្រប់សរសៃទាំងអស់ សុទ្ធតែផ្គុំទៅដោយការប្រឹង គឺអ្នករាំសុទ្ធតែបានប្រើកម្លាំងគ្រប់ដង្ហើម ។

របាំព្រះរាជទ្រព្យមានច្រើនប្រភេទ ហើយក្នុងចំណោមរបាំទាំងនោះមានរបាំមួយ ដែលមានឈ្មោះល្បីល្បាញនិងបានលើកតំកើងកិត្តិយសវប្បធម៌ប្រទេសជាតិ ធ្វើឱ្យពិភពលោកស្គាល់ខ្មែរជាងគេនោះ គឺរបាំអប្សរា ។ សព្វថ្ងៃ គេនិយមសម្តែងរបាំអប្សរានៅពេលប្រារព្ធពិធីបុណ្យជាតិ បុណ្យសាសនា មហោស្រព សិល្បៈធំៗ និងពិធីទទួលស្វាគមន៍ភ្ញៀវជាតិនិងអន្តរជាតិផ្សេងៗ ។ របាំអប្សរានៅរក្សាប្រជាប្រិយភាពរបស់ខ្លួន តាំងពីសម័យបុរាណកាលរហូតមកដល់បច្ចុប្បន្នកាលនេះ ។

របាំនេះបានទទួលការកោតសរសើរស្ទប់ស្ងែង ល្បីរន្ទឺពាសពេញពិភពលោក។ របាំអប្សរា បានបង្កើតជាផ្លូវការតាំងពីឆ្នាំ ១៩៦១ ដោយស្តាព្រះហស្តព្រះមហាក្សត្រយានី **ស៊ីសុវត្ថិកុសមៈនារីរ័ត្ន** ហើយតួឯកអប្សរាទី ១ គឺម្ចាស់ក្សត្រីនរោត្តម បុប្ផាទេវី។ របាំអប្សរាបានឧប្បត្តិកឡើងក្នុងឱកាសដែលព្រះមហាក្សត្រីយានីយាងមកធ្វើទស្សនកិច្ច នៅសាលាបឋមសិក្សា សុធារស។ នាយិកាដែលបានរៀបចំពិធីសិល្បៈកុមារ បានកាត់ក្រដាសធ្វើជាមកុដពាក់ដូចគ្នានឹងមកុដអប្សរាឆ្លាក់ជាប់នឹងជញ្ជាំងប្រាសាទអង្គរវត្តបេះបិទ។ រឿងនេះញុំាងឱ្យព្រះមហាក្សត្រិយានីផ្តួចផ្តើមគំនិត បង្កើតរបាំនេះឡើង ហើយបានប្រសិទ្ធនាមថា "របាំអប្សរា"។ ចំណែកឯពាក្យថា របាំអប្សរានេះ ជាពាក្យផ្សំខ្មែរនិងសំស្ក្រឹត មានន័យថារបាំទេវៈ របាំទេពអប្សរ ឬរបាំទេវតា។ បើនិយាយពីគ្រឿងតុបតែងកាយ មកុដអប្សរានិងក្បាច់រាំជាដើម សុទ្ធតែបានចម្លងតាមគំរូអប្សរានៅតាមជញ្ជាំងប្រាសាទអង្គរវត្តទាំងអស់។ មានន័យថា វាមានតម្លៃនិងរក្សាចរិតជាលក្ខណៈខ្មែរសុទ្ធសាធ។ តាមការសង្កេត មកុដអប្សរាដែលមានតាមជញ្ជាំងអង្គរវត្ត ត្រូវមានកំពូលប្រាំពីរ។ កំពូលនីមួយៗ មានរចនាក្បាច់ថ្នាំងអំពៅ មានសមាមាត្រសមឥតខ្ចោះនឹងសក់វែងប្រះស្មា។ នៅអមត្រចៀក គេរចនាសក់ក្រងម្ខាងបីសរសៃ។ ឯត្រចៀកពាក់រំយោលធ្លាក់ដល់ស្មា។ កមានពាក់សុរង ព្រមទាំងរំលេចដោយរំយោលក្បាច់រចនាតាមម៉ូតផ្សេងៗ។

ចំណែកដើមដៃទាំងសងខាងមានពាក់ស្តំដៃ ហើយកដៃពាក់កង នៅលើទ្រូងឃើញមានសង្វារខ្វែងពីលើអាវនិងស្តំចង្កេះរឹតយ៉ាងតឹង ដែលមានរំយោលភ្ជាប់ទៅនឹងសំពត់ផង។ ភាគច្រើនជើងសំពត់មានរចនាជារាងកន្ទុយត្រី។ ក្រៅពីនេះសំពត់មួយផ្ទាំងទៀត ឃើញមានសៀតត្រង់ចង្កេះខាងស្តាំទម្លាក់ជាយចុះមកក្រោម។ នៅលើជើងមានពាក់កងនិងកងទ្រដល់ដី។ ចំណែកឯជាយសំពត់នៅត្រង់ខាងចង្កេះខាងឆ្វេង រចនាជាផ្តត់អង្កាញ់ៗទម្លាក់ពីចង្កេះដល់ដី។ រីឯតួអប្សរាសព្វថ្ងៃ យើងក៏និយមតុបតែងតាមលំនាំនេះដែរ។

ប៉ុន្តែការតុបតែងសក់និងខ្លួននៅមានកម្រិតពុំទាន់ល្អដូចតួអប្សរាអង្គរវត្តបេះបិទនៅឡើយទេ។

របាំអប្សរា ត្រូវសម្តែងឡើងដោយមានការប្រគំអមជាមួយបទភ្លេងមហោរីព្រះរាជទ្រព្យដែលមានចង្វាក់រាំទន់ភ្លន់ គួរឱ្យចាប់ចិត្តគយគន់ក្រៃលែង។ ទាំងកាយវិការទន់ល្អសល្អន់ គួបផ្សំនឹងដៃចាក់ក្បាច់រាំ ជើងលើកដាក់គ្រវាសមួយៗ ថ្នមៗព្រមគ្នានឹងក្បាលធ្វើចលនារាំងាកវេរឆ្វេងស្តាំចុះឡើងៗ សែនសមឥតខ្ចោះ។ ពិនិត្យច្បាស់ជាងនេះទៅទៀត ម្រាមដៃអប្សរា ងខ្វង់។ ចង្កេះរស់រវើកសមនឹងត្រគាករាងងស្ទើត មិនចាញ់អប្សរាអង្គរប៉ុន្មានឡើយ។

ថ្វីត្បិតតែរបាំអប្សរា មានចលនាសម្តែងមួយៗបែបយឺតៗក៏ពិតមែន ប៉ុន្តែលក្ខណៈនេះបញ្ជាក់ច្បាស់នូវស្ថានភាពសម្បូណ៌សប្បាយ នាសម័យកាលនោះ។ វាបង្ហាញភាពផ្អែមល្ហែម ចិត្តសុខសូប់អារម្មណ៌រួសរាយរាក់ទាក់ បញ្ជាក់ភាពគ្មានកង្វល់។

បើគិតពីធាតុដើមនៃរបាំអប្សរាក៏សមស្របនឹងអត្ថន័យថា របាំទេពអប្សរ ឬទេវតាដែលគ្មានកង្វល់នឹងជីវិតឡើយ។ ការសម្តែងរបាំអប្សរាបានក្លាយជាប្រពៃណីជាតិ។ ជាពិសេសរបាំនេះធ្លាប់ទៅបង្ហាញខ្លួននៅលើផ្ទៃអន្តរជាតិជាច្រើនដូចជា ប្រទេសបារាំង សហរដ្ឋអាមេរិក ជប៉ុន អ៊ីតាលី ជាណឺម៉ាក។ល។ ថ្វីត្បិតតែរបាំអប្សរាពុំបានលើកយកមកសម្តែងជាប្រចាំ ហើយញឹកញាប់ដូចតន្ត្រីសម័យក៏ពិតមែន ប៉ុន្តែរបាំនេះមានលក្ខណៈនិងចរិតជាតិ ពិសេសជ្រាលជ្រៅខុសពីតន្ត្រីសម័យ។ របាំអប្សរាមានតម្លៃបង្កប់ក្នុងអារម្មណ៍ជនជាតិខ្មែរគ្រប់រូប។ វាតំណាងឱ្យដួងព្រលឹងជាតិខ្មែរពិតៗ ដែលបានទទួលការនិយមគាំទ្រនិងកោតសរសើរដល់ទឹកដៃសិល្បៈរបាំអប្សរានេះថា សិល្បករបាំអប្សរាពិតជាទន់ភ្លន់សក្តិសមនឹងឫកពាសុភាពរាបសា ថ្លៃថ្នូរជាសុភាពស្ត្រីខ្មែរពិតៗ។

សព្វថ្ងៃប្រទេសយើងបានបង្កើតមហាវិទ្យាល័យនាដសាស្ត្ររបាំបុរាណ។ នៅទីនោះគេបានហាត់របាំជូនពរ របាំទេពប្រណម្យ របាំមនោរម្យ របាំធ្លិត។ល។ ឯនៅតាមសាលាបឋមសិក្សាមួយចំនួនក៏មានគ្រូសិល្បៈសម្រាប់បង្ហាញរបាំបុរាណដល់កុមារៗទៀតផងដែរ។ នេះបញ្ជាក់ឱ្យឃើញថាសិល្បៈរបាំបុរាណ ពិសេសរបាំអប្សរាមានតម្លៃជាតិខ្ពស់ ព្រោះវាបានរក្សានិងបង្ហាញចរិតលក្ខណៈរបស់ជាតិ ជាតំណាងព្រលឹងជាតិខ្មែរជាច្រើនតំណមកហើយ។

(ដកស្រង់និងកែសំរួលពីសៀវភៅ មគ្គុទ្ទេសក៍នគរ និង"ឧបនិស្ស័យខ្មែរ"របស់ អ្នកស្រីកែវ ណារ៉ុ ២០០៧ ទំព័រ ៣-៤)

សំណួរ

១. តើរបាំអប្សរា ជារបាំអ្វី ? គេសម្តែងរបាំនេះនៅពេលណា ?

២. តើរបាំនេះមានកំណើតតាំងពីពេលណា ? តើអ្នកណាជាអ្នកបង្កើតរបាំនេះមុនគេ ? ហើយការបង្កើតរបាំនេះ ប្រព្រឹត្តទៅតាមវិធីណា ?

៣. ចូរអ្នកបង្ហាញពីទម្រង់និងអត្ថន័យនៃការសម្តែងរបាំអប្សរា ដោយផ្អែកលើអត្ថបទនេះ។

៤. ដោយផ្សារភ្ជាប់ទៅនឹងខ្លឹមសារនៃអត្ថបទ ចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីលក្ខណៈជាតិសំខាន់ៗដែលមាននៅក្នុងរបាំអប្សរា។

៥. ចូរអ្នកប្រៀបធៀបរបាំអប្សរានិងរបាំប្រជាប្រិយណាមួយ ដែលអ្នកធ្លាប់ស្គាល់។ តើរបាំទាំងពីរប្រភេទនេះ មានលក្ខណៈពិសេសក្នុងវប្បធម៌ជាតិយ៉ាងណាខ្លះ ? ចូរពន្យល់។

៦. ចូរអ្នកធ្វើការវិភាគល្បះនេះ "ថ្វីត្បិតតែរបាំអប្សរា មានចលនាសម្តែងមួយៗ បែបយឺតៗ... ប៉ុន្តែលក្ខណៈនេះ បញ្ជាក់ច្បាស់នូវស្ថានភាពសម្បូណ៌សប្បាយនាសម័យកាលនោះ"។

រចាំព្រះរាជទ្រព្យ



ក. សិក្សាពាក្យគន្លឹះ

- សក្ការៈ (ន) : ការធ្វើគោរព សេចក្តីគោរព ការធ្វើបដិសណ្ឋារៈដោយគោរព ។
- នាដកា (ន) : បុរសរាំរចាំ ។
- ឧទ្ទិស (ន) : សំដៅទៅរក សំដៅចំពោះ ឆ្ពោះត្រង់ តម្រង់ទៅរក ។
- អាទិទេព (ន) : ទេព្តាខាងដើម ទេព្តាមុនបង្អស់ ។
- និរសាសន្តិភាព (ន) : អ្នកនាំពាក្យឬសកម្មភាពដែលបង្ហាញនូវសន្តិភាព ។
- សន្តិភាវការិនី (ន) : តួអង្គនៃការសម្តែងដែលតំណាងនូវសន្តិភាព ។
- ឆោះ (ន) : តួអង្គតំណាងមនុស្សដែលមានរូបមិនល្អ ។
- ឆ្លែល (កិ) : ហើរក្រវែលបណ្តើរ គន់មើលបណ្តើរ ហើរហាក់ផ្ទៀងផ្ទង ។
- និមិត្តរូប (ន) : តំណាង ។

ខ. អភិវឌ្ឍន៍បំណិន

តាមរយៈអត្ថបទនេះ អ្នកនឹងបានស្គាល់រចាំព្រះរាជទ្រព្យ ស្វែងយល់ពីនិមិត្តរូបសំខាន់ៗ តាមកាយវិការសម្តែង និងចំណុចពិសេសចំពោះលក្ខណៈជាតិដែលមាននៅក្នុងរចាំនេះទៀតផង ។ មិនតែប៉ុណ្ណោះ និងមើលឃើញពីតម្លៃវប្បធម៌ជាតិថែមទៀតផង ។

គ. អត្ថបទ

របាំព្រះរាជទ្រព្យ ជារបាំក្បាច់បុរាណខ្មែរ និងជាទម្រង់សិល្បៈសក្ការៈ (សិល្បៈទេវៈ)មួយដែលមានវ័យចំណាស់ ដ៏យូរលង់ណាស់មកហើយនៅក្នុងចំណោមទម្រង់សិល្បៈសក្ការៈ ហើយក៏ជាទម្រង់សិល្បៈដែលមានតម្លៃពិតខាងស្មារតីនិងខាងបច្ចេកទេសកំរិតខ្ពស់ក្នុងចំណោមទម្រង់សិល្បៈទស្សនីយភាពនៅកម្ពុជា។ កាលដើមឡើយ នាសម័យមហានគរ នាដការ នាដការិនី ប្រចាំប្រាសាទមានតួនាទីសម្រាប់រាំឧទ្ទិសដល់អាទិទេពឬរាំថ្វាយទេវៈរាជា គឺជានិរាសនន្តិភាពពីស្ថានមនុស្សលោក ទៅស្ថានទេវតា និងជាសិល្បការិនីសន្តិភាព ឬជាសន្តិភាវការិនីខាងផ្លូវដួងចិត្ត គំនិត ដែលធ្លាប់បានរាំផ្សព្វផ្សាយសីលធម៌ និងគុណធម៌ ដើម្បីសេចក្តីសុខ សន្តិភាពខ្មែររាប់ពាន់ឆ្នាំមកហើយ។

ចំពោះការរៀបរាប់ការសម្តែងនៃរបាំខាងលើនេះ តួអង្គមានបួនក្រុមហើយដោយផ្អែកតាមលក្ខណៈរូបសម្បត្តិពីកំណើត គេអាចចែកតួសម្តែងជាបួនក្រុមដែរ មានក្រុមនាងតំណាងឱ្យស្ត្រីភេទ ក្រុមនាយរោងតំណាងឱ្យបុរស។ ក្រុមយក្សតំណាងឱ្យពពួកយក្សពួកដោះ ជាមនុស្សដែលមានរូបមិនល្អ។ ក្រុមស្ងាពីដើមឡើយច្រើនពួកកុមារីរាំ តែក្រោយមកជ្រើសរើសកុមារារាំវិញ ព្រោះអាចរាំបានស្ថិតស្ថេរជារៀងរហូត។ ចំណែកកាយវិការនៃការសម្តែងរបស់តួអង្គបួននេះវិញ បានបង្ហាញឱ្យឃើញថា តួអង្គបួននេះមានក្បាច់រាំប្លែកៗគ្នា ប្រព្រឹត្តទៅដោយប្រើម្រាមដៃនិងម្រាមចង្កុលដៃ ហើយម្រាមដៃនិងម្រាមចង្កុលដៃ ជីបជាប់គ្នា ដែលតំណាងឱ្យត្រួយផ្កាឬផ្កាក្រពុំ។ ពេលយកក្បាច់នេះមកដាក់ចុងដង្ហើមមានន័យថា "ខ្ទុំ"។ ដើម្បីឱ្យបានន័យថា "ខ្ទុំ" គេត្រូវប្រើកម្លាំងនិងដង្ហើមចង្វាក់ (Rythme) ៥។ ដំបូងត្រូវលើកដៃ ហើយលាបាតដៃ រួចផ្ងារជីប រួចបានលើកយកមកដាក់លើទ្រូងចុងដង្ហើម ...។ ខ្ទុំនេះ គឺប្រៀបដូចផ្កា។ ធម្មតាភាគច្រើននៃផ្កា គឺល្អទាំងរូប ល្អទាំងក្លិន។ ដូច្នេះខ្លួនខ្ទុំដែលប្រដូចទៅនឹងផ្កា ព្រោះយល់ថាខ្លួនឯងល្អ គឺល្អទាំងរូប ល្អទាំងឈ្មោះ ល្អទាំងចិត្ត គឺជាលំអនៃគ្រួសារនិងសង្គមដែលហាក់ដូចជាផ្កាសម្រាប់ធម្មជាតិ ហើយនឹងរោយទៅវិញនៅថ្ងៃណាមួយមិនខាន។ កាយវិការចង្កុលឬការដុះពន្លក សម្រាប់បង្ហាញប្រាប់ពីន័យដែលត្រូវអធិប្បាយ។ បើគេនិយាយពីអ្វីៗដែលស្ថិតនៅជិត គេចង្កុលទៅខាងមុខបន្តិច។ តែបើចង់និយាយពីអ្វីដែលនៅឆ្ងាយគេត្រូវលើកដៃចង្កុលទៅមុខបន្តិចទៀត។ ឯចំពោះអ្នកដែលតូចជាង ដូចជាប្អូនកូនចៅជាដើម គេយកក្បាច់នេះចង្កុលទៅខាងចំហៀងខ្លួន។ ចំពោះអ្នកដែលធំជាង មានមាតាបិតាជាដើមគេលើកក្បាច់នេះស្មុយខ្ពស់ទៅលើ។ រីងកាយវិការពត់កដៃដោយប្រើម្រាមដៃ ៤ ង មានសភាពដូចស្លឹក គេបានយកស្លឹកមកបាំងថ្ពាល់នៅ

ពេលអៀនខ្មាស តែបើយកស្លឹកមកបាំងនៅខាងលើភ្នែក មានន័យថាយំ។ មនុស្សដែលយំ មិនចង់ឱ្យអ្នកដទៃមើលឃើញទេ ព្រោះការយំឬមានទុក្ខ មុខមិនដែលល្អឡើយ។ ជាមួយនឹងម្រាមចង្អុលឬម្រាមកណ្តាល ម្រាមចង្អុល ឬម្រាមកណ្តាលប្រឹង ងស្មើត ឯម្រាមបីទៀតខិនគួបគ្នាគឺការបែកមែកសម្រាប់ប្រើក្នុងន័យផ្សេងៗ ដូចជាប្រើសម្រាប់សម្គាល់ថាស្នែងសត្វជាដើម។ ម្រាមដៃទាំងប្រាំជីប គឺជាផ្កា ព្រោះវាមានលក្ខណៈដូចជាផ្កាមែន។ ម្រាមដៃបួនក្តាប់ ដោយឱ្យម្រាមមេប្រឹងនោះ គឺជាផ្លែឈើក្តឹបសម្រាប់ប្រើកាន់ដំបងឬដាវលំពែងក្នុងពេលប្រយុទ្ធ។ ម្រាមកណ្តាល និងម្រាមមេខិនគួបគ្នា គឺជាផ្លែចាស់បន្តិចទៀតនឹងត្រូវទុំជ្រុះ។ បន្ទាប់មកគេផ្ទាត់លាឃ្លាតចាកពីគ្នានោះ គឺជាផ្លែទុំជ្រុះ។ គេច្រើនប្រើក្បាច់នេះនៅពេលរាំជិតបញ្ចប់របាំ ដូចជារបាំទេពមនោរម្យ។ មានន័យថាលាគ្នាមុននឹងហោះទៅកាន់ឋានសួគ៌។ ពេលហោះអ្នករបាំរាំឆ្វែលចុះឆ្វែលឡើង លើកដៃពត់កោងទៅលើនិងម្ខាងទៀត ងកោងត្រង់កួយដៃ ដែលជាការប្រឹងហាត់ពត់ខ្លាំងណាស់ទើបមានលក្ខណៈល្អបណ្តាច់។ ចំពោះការខឹង ការស្អប់ ការស្រឡាញ់ ប្រព្រឹត្តទៅដោយលើកដៃចង្អុលឱ្យខ្លាំងឬបានបន្ថែមជើងទន្ទ្រាំទៀតនោះ គឺជាសញ្ញានៃសេចក្តីស្រឡាញ់។ ការយំប្រព្រឹត្តទៅចំពោះតួនាងដែលជាស្ត្រីភេទ តួនាងដែលជាស្ត្រីភេទមានភាពទន់ភ្លន់នោះ គេយកដៃបាំងលើភ្នែក ដោយមិនលើកបើកភ្លៀកឡើយ។ តួនាយរោងគឺជាបុរសភេទត្រូវមានភាពសង្ហាស្ងាហាប់ ទោះបីជាគេយំក៏ដោយក៏ត្រូវរក្សាលក្ខណៈរឹងប៉ឹងដែរ គឺគេយកដៃបាំងមុខ ដោយកន្ទែកម្រាមមេដៃនិងចង្អុលឱ្យទាល់តែតឹងរួចបើកភ្លៀកចេញបន្តិច។ តួស្រាយំ គេមិនប្រើបាតដៃ ឬសន្លឹកបាំងមុខទេ គឺគេយកម្រាមមេដៃនិងម្រាមចង្អុលដៃជីបជាប់គ្នា រួចកាច់កដៃក្លិចចុះក្រោមដោយដាក់បាំងមុខដែរ។ តួយក្សយំ គេនៅតែតំណាងឱ្យលក្ខណៈកាចខ្លាំងដដែល គឺគេឈរកន្ទែកជើងដោយខិនក្បាលបន្តិចរួចក្តាប់ដៃហើយយកកំភួនដៃបាំងមុខដែរ។ ចំពោះការរៀបចំនាកច្រើនមានលក្ខណៈជានិមិត្តរូបដូចជាការលំអដោយមានដាក់ដើមឈើបញ្ឈរគេតែងប្រើពណ៌ទឹកមាសឬប្រាក់ដែលគេហៅថា ដើមមាសដើមប្រាក់។ ចំពោះផ្លែផ្កានៃដើមឈើនោះក៏ជាមាសឬប្រាក់ដែរ។ ចំពោះឧបករណ៍ភ្លេងវិញ ជាឧបករណ៍ភ្លេងពិណពាទ្យដែលមាន រនាតឯក រនាតធុង រនាតដែកដែលបច្ចុប្បន្នមិនសូវឃើញគេប្រើទេ។ ក្រៅពីនេះនៅមានរនាតថោង បច្ចុប្បន្នក៏មិនសូវប្រើដែរមាន គងធំ ឬគងវង់ធំ គងតូចឬគងវង់តូច សំភោរ ស្គរធំមួយគូ ឈិង និងក្រាប់។ របាំបុរាណមានលក្ខណៈល្អពិសេសមួយទៀត គឺនៅត្រង់ប្រើដងខ្លួនឱ្យស្ថិតក្នុងលំនឹង (Equilibre) គឺមិនផ្ទៀងមិនភ្លូកឬកាច់ចង្កេះក្រវិកក្រវក់ចុះឡើងឡើយ។ គេតែងរំកិលខ្លួនដូចអណ្តែតលើអាកាស ហើយត្រូវហាត់ចេះទប់ខ្លួនឱ្យ

មានលំនឹងកុំឱ្យរង្គើ។ ដងខ្លួននោះត្រូវទន់ភ្លន់អែនអនដូចពស់វារ។ បញ្ហានេះក៏ជាលក្ខណៈពិសេសដែលជនសាមញ្ញពិបាកធ្វើបានឡើយ។ ក្រុមស្ងាពីដើមឡើយច្រើនពួកកុមារីរាំ តែមកដល់រាជ្យព្រះករុណានរោត្តមសីហនុ (១៩៤០-៤១) សម្តេចព្រះមាតារបស់ព្រះអង្គគឺក្រោយមកលោកជា សម្តេចព្រះមហាក្សត្រិយានីស៊ីសុវត្ថិមុនីវង្សកុសមៈនារីរ័ត្នសីរីវឌ្ឍនា លោកគ្រប់គ្រងវិញ ព្រះអង្គបានជ្រើសរើសកុមារារាំវិញ ព្រោះអាចរាំបានស្ថិតស្ថេរជារៀងរហូត។

(ដកស្រង់និងកែសម្រួលចេញពី "ឧបនិស្ស័យខ្មែរ" កែវ ណារ៉ុ ២០០៧និង http//km.wikipedia.org/wiki)

សំណួរ

១. តើរបាំព្រះរាជទ្រព្យ គេអាចចែកតួអង្គសម្តែងជាប៉ុន្មានក្រុម ? ចូររៀបរាប់លក្ខណៈសម្តែងនៃក្រុមនីមួយៗ។

២. តើអ្វីទៅដែលហៅថានិមិត្តរូប ? តើនិមិត្តរូបសំខាន់ៗ តាមរយៈកាយវិការ ការសម្តែងនៃតួអង្គក្នុងរបាំព្រះរាជទ្រព្យនេះ មានចំណុចពិសេសចំពោះលក្ខណៈជាតិយ៉ាងណាខ្លះ ?

៣. បើនិយាយពីទម្រង់សិល្បៈខ្មែរ តើរបាំនេះស្ថិតក្នុងទម្រង់ទីប៉ុន្មាន ? ហេតុដូចម្តេចបានជាអ្នកយល់បែបនេះ ? ចូរអ្នកបកស្រាយ ដោយបញ្ជាក់ឧទាហរណ៍តាមការស្រាវជ្រាវរបស់អ្នក។

៤. ដោយផ្សារភ្ជាប់ទៅនឹងខ្លឹមសារនៃអត្ថបទខាងលើនេះ ចូរអ្នកធ្វើការប្រៀបធៀបរបាំព្រះរាជទ្រព្យ និងរបាំអប្សរា។

៥. ចូរអ្នកធ្វើការបកស្រាយ ពីអត្ថន័យនៃការប្រើប្រាស់ឧបករណ៍ភ្លេងខ្មែរ ក្នុងវប្បធម៌ខ្មែរដែលមានឧបករណ៍ : គងវង់ធំ សំភោរ ស្គរធំ ស្គរជ្វា ស្រឡៃ ឈឹង ក្រាប់។

៦. តាមរយៈកាយវិការសម្តែង "ខ្ញុំ" និមិត្តរូប "ក្លិន" ប្រដូចទៅនឹង "ផ្កា" ក្នុងធម្មជាតិ។ តើនិមិត្តរូបនេះ បានផ្សារភ្ជាប់ទៅនឹងសោភ័ណមនុស្សក្នុងសង្គមយ៉ាងណាខ្លះ ?

ពិធីចូលម្លប់



ដូចជាកោរជុកដែរ ចូលម្លប់ជាពិធីដែលស្ទើរតែបាត់បង់ពីប្រពៃណីទៅហើយ។ តាមដែលដឹងមកអាចពោលថា នៅសល់តែបីតំបន់ប៉ុណ្ណោះទេនៅប្រទេសកម្ពុជា ដែលគេប្រតិបត្តិនៅឡើយ។ ពុំមានន័យថា នៅទីដទៃទៀតបាត់បង់រហូតទាល់តែសូន្យសុងនោះទេ ប៉ុន្តែជាការកម្រពេកនឹងរាប់ថាជាទំនៀមដែលនៅរស់រវើកពុំបាន។ ក្នុងតំបន់ទាំងបីនោះក្រុមភូមិមួយចំនួននៅស្រុកស្រែអំបិល ខេត្តកោះកុងប្រតិបត្តិខ្លាំងក្លាជាងគេ បន្ទាប់មក គឺក្រុមភូមិមួយចំនួនទៀតនៃស្រុកបាធាយ ខេត្តកំពង់ចាម។ បន្ទាប់មកទៀត ទើបភូមិខ្លះនៅស្រុកសូទ្រនិគម ខេត្តសៀមរាប។ បើក្រឡេកមើលលើផែនទីឃើញថាទីតាំងស្រុកទាំងបីនេះនៅដាច់ឆ្ងាយពីគ្នាស្រឡះ ពុំអាចគិតថាមានការឆ្លងពីមួយទៅមួយទេ គឺពិតជាពីដើមឡើយ ប្រពៃណីនេះគេប្រកាន់ទូទៅពេញទាំងប្រទេស។ មុននឹងស្តាប់អត្ថបទនេះ ចូរឆ្លុះសង្កេតរូបភាពខាងលើដែលបង្ហាញពីពិធីចូលម្លប់ :

តទៅនេះចូរអ្នក ចូរអ្នកស្តាប់អត្ថបទ "ចូលម្លប់" ហើយត្រៀមឆ្លើយនិងសំណួរខាងក្រោមនេះ ៖

១. តាមរយៈខ្លឹមសារនៃអត្ថបទនេះ តើពិធីចូលម្លប់មាននៅក្នុងខេត្តណាខ្លះ ?

២. បើតាមប្រពៃណី តើគេត្រូវឱ្យកូនស្រីនៅវ័យណាដែលត្រូវចូលម្លប់ ? ហើយរយៈពេលនៃការចូលម្លប់នេះ មានការឯកភាពគ្នាឬទេ ? ចូររៀបរាប់ ។

៣. ចូរប្រាប់ពីគ្រឿងរណ្តាប់និងអត្ថន័យនៃគ្រឿងរណ្តាប់នៃពិធីចូលម្លប់ ដែលគេនិយមប្រារព្ធធ្វើនៅតាមខេត្តនីមួយៗ ។

៤. តើពេលដែលនៅក្នុងម្លប់ គេបានប្រកាន់ត្រណមយ៉ាងណាខ្លះ ?

៥. តើស្បូវកញ្ជើតំណាងឱ្យអ្វី ? ហើយរណ្តាប់ស្បូវកញ្ជើនេះ មាននាទីសំខាន់អ្វីខ្លះចំពោះពិធីចូលម្លប់ ?

៦. ចូរអ្នកបង្ហាញពីអត្ថន័យនៃពាក្យឬកន្សោមពាក្យ "មេ ម្លប់ ស្រា ស្លឹកម្ហូ" ។

៧. តើអ្នកយល់យ៉ាងណា ចំពោះប្រពៃណីពិធីចូលម្លប់របស់ជនជាតិខ្មែរ ?



ការរៀបរាប់ពីលំនាំនៃការសម្តែងរបាំបុរាណ

ដោយផ្អែកលើខ្លឹមសារនៃអំណានរបស់មេរៀននេះ ចូរអ្នកធ្វើការសរសេររៀបរាប់អំពីលំនាំនៃរបាំបុរាណណាមួយ ដែលអ្នកពេញចិត្ត។ អ្នកអាចពិនិត្យមើលគំរោងខាងក្រោម :

គំរោងតែង

ក. ផ្តើមសេចក្តី

- លំនាំបញ្ហា : លក្ខណៈទូទៅនៃរបាំប្រពៃណីខ្មែរ
- ចំណូលបញ្ហា : ការបង្ហាញប្រធានបទ (របាំប្រពៃណីណាមួយ)
- ចំណោទបញ្ហា : បំផុសសំណួរដោយភ្ជាប់នឹងគំនិតប្រធានបទ។

ខ. តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី : ឃ្លាដែលត្រូវនិយាយភ្ជាប់ពីផ្តើមសេចក្តីចូលមកតួសេចក្តី។
- ពន្យល់ពាក្យ : ករណីពាក្យពិបាកដែលត្រូវឱ្យនិយមន័យ ឬជាការពន្យល់តាមន័យធម្មតា។
- ពន្យល់ន័យប្រធានបទ : ជាការសរុបន័យនៃការពន្យល់ពាក្យ ដើម្បីជួយសម្រួលន័យប្រធានឱ្យកាន់តែងាយយល់ថែមទៀត។
- បកស្រាយ : លើកយកប្រធានបទមកធ្វើការបកស្រាយ ដោយឆ្លុះឱ្យឃើញពីគំនិតសំខាន់និងអំណះអំណាងគាំទ្រស្របតាមគំនិតសំខាន់នីមួយៗ។
  - គំនិតសំខាន់ទី ១ : សេចក្តីលំអិតគាំទ្រ (*ឧទាហរណ៍ :* ព្រឹត្តិការណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ អក្សរសិល្ប៍)
  - គំនិតសំខាន់ទី ២ : សេចក្តីលំអិតគាំទ្រ (*ឧទាហរណ៍ :* ព្រឹត្តិការណ៍ក្នុងសង្គម ប្រវត្តិសាស្ត្រ អក្សរសិល្ប៍)

  (តែគេអាចបង្ហាញគំនិតសំខាន់ជាមុនឱ្យអស់លទ្ធភាព ទើបលើកយកឧទាហរណ៍ឬអំណះអំណាងជាក្រោយក៏បាន)
- សរុប : ជាការសរុបនៃការបកស្រាយគំនិតប្រធានឡើងវិញ។

គ. បញ្ចប់សេចក្តី


- សន្និដ្ឋានគំនិតប្រធាន : ផ្តល់តម្លៃចំពោះវប្បធម៌ជាតិយ៉ាងណាខ្លះ ? ឬស្មារតីជាតិនិយមយ៉ាងណាខ្លះ ?

  មតិផ្ទាល់ខ្លួន : មតិផ្ទាល់របស់អ្នកធ្វើតែងសេចក្តីក្នុងការទាញតម្លៃវិជ្ជមានឬតម្លៃអប់រំដែលមាននៅក្នុងប្រធានបទខាងលើ។

មេរៀនទី



ប្រពៃណីទំនៀមទម្លាប់





បើគេនិយាយដល់ជនជាតិខ្មែរ គេនឹងនឹកឃើញភ្លាមនូវសមិទ្ធផលវប្បធម៌មិនចេះរីងស្ងួតនិងសម្បូណ៌បែប ហើយបន្សល់ទុកនៅគ្រប់ទិសទីលើទឹកដីកម្ពុជាយើងនេះ។ ដោយឡែកតែទំនៀមទម្លាប់ប្រពៃណីដែលជាផ្នែកមួយនៃវប្បធម៌របស់ជនជាតិខ្មែរ ក៏បានស្តែងចេញតាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ននេះ ហើយមានទំនៀមទម្លាប់ប្រពៃណីច្រើនណាស់បានផ្សារភ្ជាប់ទៅនឹងផ្តត់គំនិតខ្មែរ ចិត្តគំនិតខ្មែរ ព្រមទាំងបានឆ្លុះបញ្ចាំងពីលក្ខណៈជាតិខ្មែរ។ ដោយបានមើលឃើញពីតម្លៃមរតកជាតិខាងលើនេះហើយ ទើបមានកុលបុត្រកុលធីតាខ្មែរតែងតែធ្វើការសិក្សាស្រាវជ្រាវនិងចងក្រងវប្បធម៌ប្រពៃណីខ្មែរនេះជាបន្តបន្ទាប់ ដើម្បីបន្សល់ទុកជាកេរដំណែលដល់កូនខ្មែរជំនាន់ក្រោយឱ្យបានស្គាល់និងបានយល់ដឹងបន្ថែមទៀត។

ស្របជាមួយនឹងស្មារតីនៃការសិក្សាស្រាវជ្រាវនេះ អ្នកនឹងបានសិក្សាបន្ថែមទៀតនូវទំនៀមទម្លាប់ប្រពៃណីមុនពេលរៀបការ ពិធីចម្រើនអាយុ ព្រមទាំងស្គាល់ពីអត្ថន័យនៃរឿង ចំណុចសំខាន់ៗដែលទាក់ទងនឹងអ្នកនិពន្ធនិងស្នាដៃ អត្ថរស ពិធីមួយចំនួនក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរ ជាពិសេសស្គាល់ពីអត្តសញ្ញាណជាតិតាមរយៈពិធីទាំងនោះផង។

ប្រពៃណីខ្មែរនាសម័យអាណានិគមនិយម



ក. សិក្សាពាក្យគន្លឹះ

- ស្រី (ន) : គូកំណាន់ចិត្តលួចលាក់ មិនពេញច្បាប់ជាប្រពន្ធ ។
- ភួយគ (ន) : ភួយដែលត្បាញពីសរសៃសំឡីគ ។
- សំពត់ព្រៃ (ន) : សំពត់សូត្រដោយបែបជាព្រៃលាត ព្រៃផ្កា ។ សំពត់អំបោះដោយបែបក៏ហៅព្រៃខ្លះដែរ ព្រៃអំបោះ ។
- លេងមែនទែន (គុ) : ដែលប្រើកម្លាំងទាំងកំរោល បំពារបំពានរំលោភលើផ្លូវច្បាប់ ។
- ភូមិត្បូង (ន) : ភូមិដែលនៅទិសខាងត្បូង ធៀបនឹងចំណុចកណ្តាលនៃផ្លូវ ឬទីបុរាណស្ថានណាមួយ ដែលមានទីតាំងចំណាស់ជាងគេ ។
- បណ្ណាការ (ន) : ជំនួន ភ័ស្តុភារ តង្វាយ ច្រើននិយាយក្លាយជាបណ្តាការ ។
- នាម៉ឺន (ន) : មន្ត្រីមានបណ្តាសក្តិ ១០ហ៊ូពាន់ គឺសក្តិមួយម៉ឺន ។
- សាស្ត្រាទាវឯក (ន) : សាស្ត្រាល្បែង ដែលបានចារ ឬកត់ត្រារឿងទាវឯក (ទុំទាវ) ។
- អ្នងប៉ាងថាវ (ន) : ឈ្មោះនាយទុនជនបទជាជនជាតិចិនគ្រប់គ្រងជាតិចិនទាំងឡាយក្នុងភូមិស្រុក នាសម័យកាលអាណានិគមនិយម ។

- គូលី (ន) : មនុស្សដែលស៊ីឈ្នួលធ្វើការ ។ ពាក្យនេះមានដើមកំណើតនៅប្រទេសហិណ្ឌូ ឬចិន គេបានយកពាក្យនេះទៅប្រើក្នុងប្រទេសអង់គ្លេសតមកដល់ប្រទេសបារាំងសែស ទើបផ្សាយមកក្នុងប្រទេសឥណ្ឌូចិន មានស្រុកខ្មែរជាដើម ។
- ដឹកញ្ជីបន្ទុំឈ្មោល (កិ) : បញ្ចុកបន្ទុំ គឺនាំយកទៅឱ្យផឹកស៊ី ដើរលេងសប្បាយ ហើយនិយាយល្បួងបញ្ចុះបញ្ចូលឱ្យងាកទៅតាមគោលបំណងរបស់ខ្លួន ។
- ល្បុក្កតោ (ន) : ដំបងខ្លីមួយប្រភេទ សម្រាប់កាន់អបផ្ចាប់នឹងកំភួនដៃ ជាគ្រឿងការពារ រងដំបងវែងឬបុកបុះការពារខ្លួន ។ ឈ្មោះស្មៀតគុនដែលមានល្បុក្កតោជាគ្រឿងការពារ ។
- បែកអំពិលអំពែក (គុ) : ដែលមើលឃើញដូចផ្កាភ្លើងក្នុងភ្នែកនៅពេលដែលមានការប៉ះទង្គិចភ្នែកឬក្បាលយ៉ាងខ្លាំង ។
- ដាវ (ន) : គ្រឿងសាស្ត្រាធ្វើដោយដែក តួវែង មានមុខតែម្ខាង ខ្នងអែនដងខ្លីមានរបាំងសម្រាប់រងដៃ ។
- ហាប (ន) : ទម្ងន់មួយរយនាឡិ ឬពីរចុង(៦០គីឡូក្រាម) អង្ករមួយហាប ថ្លឹងឱ្យគ្រប់មួយហាប ។
- តៅ (ន) : ល្ហែរង្វាស់អនុភាគនៃថាំងគឺកន្លះថាំង(ពីរតៅជាមួយថាំង) អង្ករមួយតៅ រង្វាស់ឬប្រដាប់ឯទៀតៗ ដែលមានសណ្ឋានស្រដៀងនឹងតៅក៏ហៅតៅបានខ្លះដែរ ក្រុសមួយតៅ តៅត្បាល់កិន ។
- ត្រង់សេ(លេណដ្ឋាន)(ន) : គុហាដែលកើតឯងក្នុងរូងភ្នំ រូង ទីសម្រាប់ពួន រូងដែលគេជីកសម្រាប់ចូលលាក់ពួនអាត្មាការពារភ័យអន្តរាយ ។
- ភាវនាធម៌ (ន) : ការចម្រើន ការនឹកចំពោះត្រង់អារម្មណ៍ដ៏ល្អតែមួយដដែលៗ ឱ្យច្រើនៗគឺនឹកហើយនឹកទៀតរឿយៗ ជាអនេក ការរំពឹងស្មឹងស្មាធិ៍តាំងភាវនា ។
- ចេតិយ (ន) : ទីដែលគេគោរពបូជា គឺទីណាមួយ ទោះមានដើមឈើធំ ជាប្រធានជាទីសម្គាល់ក្តី មានថ្មធំៗជាទីចំណាំក្តី ដែលអ្នកផងគេសន្មត គេជឿថាទីស័ក្តិសិទ្ធិ គេតែងធ្វើសក្ការបូជាគោរពក៏ហៅចេតិយទាំងអស់ តែក្នុងប្រទេសយើងសព្វថ្ងៃនេះ ចំពោះតែគារវវត្ថុ ដែលគេធ្វើដោយឥដ្ឋជាដើម សម្រាប់តម្កល់សារីរិកធាតុ នៃព្រះសម្មាសម្ពុទ្ធជាដើមនោះ ទើបហៅថា ចេតិយ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយសំណួរទាក់ទងនឹងអត្ថន័យរបស់រឿង ចំណុចសំខាន់ៗទាក់ទងនឹងអ្នកនិពន្ធនិងស្នាដៃអត្ថរស វិភាគតួអង្គដោយផ្អែកលើអត្ថបទ ព្រមទាំងសិក្សាពីសង្គមបរិយាកាស។

គ. អត្ថបទ : លឹមទៅពោធិ៍ចិនតុង

លឹមទៅពោធិ៍ចិនតុងបានដប់ថ្ងៃ ព្រឹត្តិការណ៍ច្រើនចំឡែកបានកើតឡើងរវាងគ្រួសារនាងហោង និងមេឃុំផាន់។ អ្នកភូមិដើមអំពិលបានយកចិត្តទុកដាក់គ្រប់គ្នាពីរឿងនេះ។ គ្រួសារនាងហោងដែលបានទទួលគ្រោះថ្នាក់ផ្ទាល់បានប្រជុំគ្នា។ ពួស្វាយប្រមូលប្រពន្ធនិងកូនស្រីគាត់ មកសួរដណ្តឹងរកផ្លូវដោះស្រាយ។

- ក្រហោង មេឃុំផាន់មកពីអាទិត្យមុននិយាយអ្វីខ្លះ ?
- គាត់បានមកបញ្ជោរគ្រួសារយើង។ គាត់ថាខ្ញុំមុខស្រស់ រាងសម ម្រាមដៃដូចបន្លាក្រូច កំភួនជើងតូចល្អ មិនគួរឡើយនៅធ្វើស្រែទេ។ រួបរាងខ្ញុំសមជាអ្នកក្រុងធ្វើឃុនអ្នកម្នាងធ្វើលោកជំទាវ លោកស្រី បើមិនដល់ប្រពន្ធទីមួយហោចណាស់ក៏បានធ្វើប្រពន្ធទី ៣ ឬស្រីលោកថៅហ្វាយដែរ។ គាត់ថាលោកថៅហ្វាយស្រឡាញ់ខ្ញុំ សរសើរភួយគដែលខ្ញុំត្រូវគេកេណ្ឌឱ្យត្បាញជូនលោក ថាលោកសម្រាន្តមិនលក់ បាយមិនឆ្ងាញ់ ហើយចង់លែងប្រពន្ធលោកទាំងពីរ ហើយដេកយប់ថ្ងៃស្រមៃឃើញខ្ញុំនៅនែបនិត្យនឹងលោកជានិច្ច។ គាត់ថាគួរណាស់តែខ្ញុំជួយជីវិតលោកថៅហ្វាយផង។ រួចពីសរសើរគ្រប់ គាត់បានហុចកញ្ចប់ម្សៅនិងទឹកអប់ សាប៊ូ ក្រអូប សំពត់ព្រៃបីម៉ែត្រ ព្រមទាំងផ្លែក្រូច ម្ទាស់ នំចិនមួយកញ្ចប់ផង ហើយថាជាជំនូនលោកថៅហ្វាយផ្ញើមកជូន។
- ក្រហោងឯងបានប្រាប់គាត់ដូចម្តេចវិញ ? (ពួស្វាយបានបញ្ជាក់)
- ខ្ញុំជម្រាបគាត់ថា ខ្ញុំជិតការហើយ។ សូមកុំឱ្យមកវិលវល់ទៀត ខ្ញុំបានបង្វិលប្រដាប់ប្រដាទៅគាត់ទាំងអស់ តែព្រឹកមិញនេះគាត់មកទៀត មានប៉ូលិសពីរនាក់មកផង។ គាត់កំហែងចង់ចាប់ខ្ញុំ។ ខ្ញុំបានអង្វរគាត់ថាកុំអាលប្រញាប់ពេក។ គាត់បានប្រាប់ខ្ញុំថា លើកទីបីគាត់លេងមែនទែនហើយ។

រឿងក្រហោងនេះពិបាកណាស់ តើម៉ែវាគិតដូចម្តេច ? មីងពតគិតមួយស្របក់ឆ្លើយ :

- ពីម្សិលមិញ យាយចាន់ភូមិត្បូងបានជួបអញ ។ គាត់បានឱ្យយោបល់ថាយើងមានសំណាងគួរណាស់តែផ្តាច់ពីអន្ទិតលឹម ហើយលើកក្រហោងឱ្យទៅលោកថៅហ្វាយ ។ គាត់ថាបើកូនគាត់វិញ គាត់ជូនលោកថៅហ្វាយស្រេច មិនឱ្យវាទៅកាយដី ត្រាំភក់ដល់ណាទេ ។
- ម៉ែវាឯងយល់ស្របតាមយាយចាន់ឬ ?
- ចំណែកអញគ្មានយោបល់ទេ ។ បើក្រហោងវាចង់នៅកាយដីនៅជាមួយអន្ទិតលឹមក៏នៅទៅ បើចង់បានស្រណុកមានសំពត់មាសពេជ្រពាក់និងគេ ទៅនៅជាមួយថៅហ្វាយទៅ ។ មេឃុំជាន់គេសុខចិត្តសងបណ្ណាការទៅតាឆែតវិញ ។
- ចំណែកអញមិនយល់ស្របតាមឯងទេ ។ អញអ្នកស្រែមិនចង់ឱ្យកូនថៅទៅនាម៉ឺនទេ ។ ឯងមិនឮក្រហោងប្រាប់ទេថា លោកថៅហ្វាយមានប្រពន្ធពីររួចទៅហើយ ហើយនៅមានកៀនកោះទៀតតាមអញដឹង មីខ្វែនភូមិក្រសាំងនេះ ក៏ស្រីមេឃុំជាន់នាំឱ្យលោកដែរ ។ ណ្លើយមុននឹងសម្រេចអញចង់ដឹងក្រហោងសិន តើឯងគិតដូចម្តេច ?
- យើងបានទទួលជំនួននិងពាក្យតាឆែតរួចហើយ នៅជាងមួយខែទៀតយើងនឹងរៀបការ ។ បងលឹមបានទាំងមកនៅផ្ទះយើងកាលចំរូតអស់មួយខែ ។ ខ្ញុំបានស្គាល់ចិត្តគាត់ ឃើញថាគាត់អាចជាទីជម្រករបស់ខ្ញុំបាន ។ យើងប្រាកដនៅជាមួយគ្នាយ៉ាងសុខ កុំថាលោកថៅហ្វាយតង់តែកុងប្ញីយ៍ក៏ខ្ញុំមិនអាចបែកចិត្តពីបងលឹមបានឡើយ ។ ឪមិនចាំទេ យប់មួយបងលឹមបានខ្ចីសាស្ត្រាទាវ-ឯកយកមកមើល ។ ព្រឹកឡើងខ្ញុំនិងគាត់ជាន់អង្ករពីរនាក់ ខ្ញុំបានប្រាប់គាត់ពីដំណើរអាចារ្យឆេង ហើយបានពន្យល់ខ្ញុំអំពីសេចក្តីស្នេហាស៊ូស្លាប់រវាងទាវនិងឯក ។ ខ្ញុំបានសន្យាថា ខ្ញុំសុខចិត្តប្តូរផ្តាច់រស់នៅជាមួយគាត់ ដូចទាវបានប្តូរផ្តាច់ជាមួយនឹងឯក ប្រកែកមិនព្រមធ្វើស្នំមហេសីព្រះរាមា ។
- អញក៏ពេញចិត្តណាស់ដែរ (ពូស្វាយបានកាត់) ។ អន្ទិតលឹមត្រីមត្រូវស្រឡាញ់ការងារ ។ វាន្លាតនិយាយត្រូវតាមគំនិតអញ ។ ម៉ែវាចាំទេ កាលថ្ងៃសីលមួយយើងមកពីវត្តវិញ អាចារ្យឆេងបានមកជំហរអួតពន្យល់យើងថា យើងរាស្ត្រត្រូវទទួលធ្វើការចិញ្ចឹមអ្នករាជការ ស្តេចមន្ត្រី ដូចដៃជើងនឿយហត់សម្រាប់ក្រពះ ហើយយើងនឿយហត់វេទនា ព្រោះយើងមិនបានកសាងពីជាតិមុនឱ្យបានក្រាស់ក្រែល ។ ចំពោះរឿងនេះ អន្ទិតលឹមមានយោបល់ផ្ទុយ បានឆ្លើយថា ៖ "យើងមិនត្រូវអណ្តែតអណ្តូងលើរឿងដែលមិនពិតនោះទេ ។ យើងមិនអាចជជែកឃើញជាក់ស្តែងថា ជាតិមុនកើតជាអ្វី ហើយជាតិក្រោយក៏មិនដឹងទៅជាអ្វីដែរ ។ យើងត្រូវពិនិត្យមើលប្រវត្តិមនុស្សនៅលើដីនេះ ដែលមានហេតុភេទជាក់ស្តែង ។ យើងឃើញ

ហើយថារាស្ត្រក្រីក្រសព្វថ្ងៃ គឺត្រូវពួកបារាំងជប៉ុនជិះជាន់ ។ ក្តីសុខ ក្តីសម្បូណ៌បានពិតប្រាកដ ដល់មនុស្ស បើកាលណាមនុស្សខំធ្វើការទាំងអស់គ្នាពិតៗ ហើយគ្មានអ្នកមានអ្នកក្រ" ។ សំដីវានេះចំជាត្រូវ អញដេកគិតទៅរឹតឃើញកាន់តែត្រូវកាន់តែពិត ។ នៅស្រុកយើងនេះ អ៊ុងប៉ាងថាវត្រូវជើងបារាំងសែស បានយកប្រាក់មកបុលចងការ ហើយរាល់ឆ្នាំ អ្នកភូមិយើងបានលក់ស្រែឱ្យគាត់ធ្លាក់ទៅជាខ្ញុំគាត់ ។ នៅស្រុកយើងសព្វថ្ងៃ ពួកអ៊ុងប៉ាងថាវ បានត្រូវកងទ័ពជប៉ុនទិញឈើចំណេញរាប់លានរៀល ឯចំណែកយើងជារាស្ត្របានត្រូវពួកវាចាប់កេណ្ឌគូលី ។ ក្រៅពីនិយាយត្រូវ អន្ទិតលឹមមានរូបឆោមមិនចាញ់កំលោះស្របាលៗវាទេនៅភូមិយើង ។ មើលម៉ែវាយល់ឃើញយ៉ាងដូចម្តេច ?

- អញយល់ដូចឪវាដែរ ។
- អញស្មានថាឯងត្រូវយាយចាន់ភូមិតបូងទាក់បានហើយ ឯងដឹងទេយាយចាន់នេះជាអ្នកដឹកញ្ជីបន្ទុំឈ្មោល កុំទៅជឿគាត់ផ្តេសផ្តាស ។ មីខ្វែនភូមិដើមក្រសាំងធ្លាក់ខ្លួនអាវាសែ សព្វថ្ងៃដោយកញ្ជាស់ចាន់មកបោកយកទៅឱ្យថីផែនទីដំបូង ។ តើឥឡូវយើងស្របគ្នាស្រឡាញ់លឹមហើយ ដូចនេះយើងត្រូវឱ្យក្រហោងគេចពីក្រញាំមេឃុំផាន់ ។ អញបានស្នើដន្លងយើងរួចហើយ ថាឱ្យក្រហោងទៅនៅសំងំលាក់ខ្លួនឯផ្ទះគាត់ទម្រាំដល់ថ្ងៃការ ។ តើឯងយល់ដូចម្តេច ?
- ខ្ញុំយល់ស្របពេញទីតាមឪវា ។ ខ្ញុំអាចជួយថែទាំគាត់ផង ។
- បើដូចនោះ ស្នែកទៅនៅជាមួយចុះ ។

ក្រោយពីលឹមចេញទៅធ្វើគូលីជប៉ុន តាង៉ែតចាប់នឿយឡើងវិញ ។ គាត់ឃ្លាលគោរែកទឹក ។ ឯចំណែកយាយម៉ុកក៏ត្រូវធ្វើការសព្វសារពើក្នុងផ្ទះ ។ ពួស្វាយបានមកលេងនឹងគាត់ជាញឹកញាប់និយាយពីរឿងនាងហោងនិងរកមធ្យោបាយបង្វែងជានាងហោងពីមេឃុំផាន់ ។

ដូចសេចក្តីសម្រេចគ្រួសារពួស្វាយ នាងហោងបានមកនៅជាមួយតាង៉ែត យាយម៉ុក ។ ចាប់តាំងពីនាងហោងមកលាក់ខ្លួនពួននៅផ្ទះគាត់ យាយតាចាស់ៗរីកមុខរីកមាត់ នាងហោងបានជំនួសដៃយាយម៉ុកស្ទើរគ្រប់កិច្ចការក្នុងផ្ទះ ។ នាងបោសសំអាតផ្ទះ រៀបចំបាយទឹក ។ រាល់យប់នាងដងទឹកដាក់ផ្តិលទុកបៀតសសរទ្រុង ហើយរៀបហិបស្លាជិតដំណេកយាយតា ។ នាងបានឆ្លៀតចុះទៅជីពេលស្ងាត់ជាក់ចំបើងមើលភ្នក់ភ្លើងគោ ។ ក្រោយពីបោសសំអាតនិងថែឆ្នាំងអំបែង នាងហោងបានរវៃគរាល់ៗល្ងាចស្ទើរតែគ្មានឈប់ ។

យាយម៉ុកពេញចិត្តកូនប្រសាគាត់ពន់ពេក គាត់បានលួកមាត់ខ្សឹបប្រាប់ប្តីគាត់ថា "ឪវាឃើញទេ នាងហោងឧស្សាហ៍ធ្វើការណាស់។ វាស្រឡាញ់កូនយើងពិត ម៉ែ្លៗវារាប់ថ្ងៃគិតពេលអន្ទិតលឹមត្រលប់មកវិញ។ វាសួរដំណឹងលឹមតែញឹក"។

តែសេចក្តីរីករាយយាយតា មិនបានយូរទេ។ មួយអាទិត្យក្រោយ នាងហោងមកលាក់ខ្លួនជាមួយពូស្វាយបានមកត្រហេបត្រហាបទាំងថ្ងៃត្រង់ឡើងទៅហៅយាយតានិយាយប្រាប់ស្ទើរតែដាក់ក្តិតដល់កន្ទេលមិនទាន់ ៖

- អ្នកដន្លងដឹងទេ។ ពីព្រឹកមិញនេះ មេឃុំផាន់បាននាំប៉ូលិសបីនាក់ ប្រជាប់សុទ្ធតែកាំភ្លើងមករកចាប់ក្រហោង។ ឥលូវទៅវិញហើយ តែបានស្រែកប្រាប់អ្នកភូមិថា ឱ្យជួយរកក្រហោងពួនផង។ មេឃុំផាន់ថាម៉េចអីចឹងហើយ បើដូចនោះ ឃើញក្រហោងនៅផងមិនបានទេ ត្រូវឱ្យវាគេចទៅនៅឆ្ងាយ។

ដំណឹងនេះធ្វើឱ្យតាង៉ែត ខឹងញ័រច្រលោតស្ទុះក្រោកចូលទៅក្នុងរើសយកដាវមួយចេញមក។ គាត់និយាយដោយក្រោធថា ៖ អាផាន់នៅឯណា គ្នាវាប៉ុន្មាននាក់។ វាចង់ល្បងចាស់ឬ ? គុនដំបងឬ ល្បុក្កតោប្រាប់មក។ អញឱ្យទាំងអាផាន់ទាំងប៉ូលិស អញវាយវាឱ្យបែកអំពិលអំពែក វាចង់ស្លាប់ឬ ? ដាវនេះគឺកេរខ្មោចឪ ដែលបានកាន់យកទៅនៅទ័ពអាចារ្យស្វាយបារាំង។ មកនាងហោងកូនស្រីឪទៅជាមួយឪឱ្យអាផាន់ចាប់ល្បងមើល។

ថាដល់ឃ្លានេះ គាត់ស្ទុះចុះទៅដី។ យាយម៉ុកបានឃាត់ថា "ឪវាអើយ ! កុំខ្លាំងពេកឈប់ទៅមេឃុំផាន់ទៅបាត់ហើយ។ ស្តាប់ដន្លងយើងនិយាយវិញ"។

លុះដល់តាង៉ែតរំសាយខឹង ពូស្វាយបានចាប់និយាយ តាមខ្ញុំធ្លាប់ស្គាល់ ផាន់មិនទុកឱ្យយើងសុខទេ។ យើងទទឹងមុខគាត់មិនបានទេ គាត់បានចាប់ពង្រាត់កូនគេបួនដងហើយ។ កញ្ជាស់ចាន់ទៀតក៏ឆ្នើមណាស់ដែរ ដើរតែបោកលួងលោមដឹកញីបន្សុីឈ្មោល។ យើងត្រូវរកវិធីឱ្យក្រហោងចេញពីភូមិនៅនេះទៀតមិនបានទេ។ តាមយោបល់ខ្ញុំ ស្នើឱ្យដន្លងទៅលក់អង្ករភ្នំពេញ នាំក្រហោងទៅជាមួយផង ដល់ត្រលប់មកវិញត្រូវនៅសំរាកតាមស្រុកចំការទិញបន្តែ ត្រឡាច ល្ពៅ ឃ្លោក សម្រាប់ការកូនយើង។ ត្រូវសំរាកនៅចំការយូរបន្តិច បង្អង់ជិតថ្ងៃការចាំមក ហើយពេលនោះអន្ទិតលឹមត្រលប់ពីពោធិ៍ចិនតុងវិញ។

សេចក្តីស្នើពូស្វាយបានទទួលយោបល់គ្រប់គ្នា។ តាង៉ែត យាយម៉ុក នាងហោងបានទទួលរួមគ្នាខំធ្វើអង្ករ។ តែពីរយប់គាត់បាន ៥ហាប ផ្ទុកដាក់រទេះរួចស្រេចគាត់ក៏បបួលគ្នាទាំងបីនាក់បររទេះគោមកឡើងថ្នល់ខាងលិចភូមិ ហើយបរសំដៅទៅភ្នំពេញ។ នៅលើថ្នល់រទេះឡានឈ្នួល រទេះឡានសឹក

ជប៉ុន រទេះឡានតូចរបស់បារាំងខ្មែរ បានលើកទឹចុះទឹឡើងនាបបង្ហើលរទេះគោឱ្យធ្លាក់ថ្នល់។ នាង ហោងនិងយាយម៉ុកជិះរទេះ។ នាងហោងបរ តាង៉ែតដើរមុខរទេះគោ វេលាដែលមានរទេះឡានជែង ឬចៀសរទេះគាត់ បរបានមកដល់ចាក់អង្រែក្រោម តាង៉ែតបញ្ឈប់រទេះគាត់ឱ្យគោស៊ីស្មៅ ហើយ បបួលកូនប្រពន្ធបាយថ្ងៃនៅលើសាលាឆទានមួយគ្មានជញ្ជាំង។

ថ្ងៃរសៀលតាង៉ែតចាប់គោទឹមឡើងបរទៅទៀត។ គាត់បរបណ្តើរគាត់ខឹងរោលរាលបណ្តើរ។ គាត់ប្រាប់ប្រពន្ធកូនថា ៖ ថ្នល់អស់នេះសុទ្ធតែអញស្ពារ អញកាប់ អញលើក អញរែកដីចាក់ទាំង អស់។ គ្មានរណាធ្វើក្រៅពីរាស្ត្រទេ។ ដល់ឥលូវបានចាក់ជ័រស្អាត គេបែរជាឃាត់ឃាំងមិនឱ្យអ្នកស្រែ បររទេះគោផង ដោយគេថាដែកកង់ជីកខូងដីឱ្យនាប់ខូចថ្នល់។ ធម្មតារាស្ត្រមិនដែលបានបេះផ្លែផ្កា ពីញើសឈាមរបស់ខ្លួនទេ។ តាង៉ែតនិយាយត្រង់នេះបន្តិចត្រង់នោះបន្តិចឱ្យចប់តាមផ្លូវ។ មកដល់ ក្បាលស្ពានជ្រោយតាអោកចូលទីក្រុង តាង៉ែតហុចខ្សែគោទៅឱ្យនាងហោងវិញ ហើយរអ៊ូប្រាប់ ប្រពន្ធកូនថា ៖ អាផាន់ហ៊ានប្រមាថមើលងាយអញមែន។ វាប្រើអំណាចមកចាប់កូនប្រសាយើង នាំឱ្យយើងអំពល់មកលក់អង្ករភ្នំពេញ ក្នុងស្រុកគេមានសង្គ្រាម។

ពេលនេះភ្នំពេញស្ងាត់មានមនុស្សដើរមួយៗ រទេះឡានសឹកជប៉ុនបានធ្វើជាម្ចាស់ក្រុងភ្នំពេញ បើកលឿនច្រវាត់មើលតែហោះវូចុះវូឡើង ចេញពីបន្ទាយមួយទៅបន្ទាយមួយដែលបោះនៅគ្រប់ សាលារៀនក្រុងភ្នំពេញ។ អ្នកក្រុងមានធនធានបានបណ្តោះកូន ទ្រព្យសម្បត្តិ ហើយជួលផ្ទះនៅស្រែ ចំការគេចគ្រាប់បែក។ ឯចំណែកអ្នកក្រុងទ័លក្រវិញ មិនដឹងរត់ទៅពួននៅកន្លែងណា ក៏នៅរកស៊ីធ្វើ គូលីរងគ្រាប់បែក ចាំតែស្លាប់នៅភ្នំពេញ។ ខ្លះស៊ីឈ្នួលចាំយាមផ្ទះឱ្យគេ។ អ្នកចំការភាគច្រើនឈប់ យកបន្លែមកលក់ផ្សារភ្នំពេញ ហើយអ្នកស្រែក៏មិនសូវដឹកអង្ករ ស្លឹក អុសមកលក់ដែរ។

ហេតុនេះវេលាឃើញរទេះអង្ករតាង៉ែត ចិន វៀតណាម ខ្មែរត្រេកអរណាស់ចេញពីផ្ទះមកដណ្តើម គ្នាទិញ។ ខ្លះទិញមួយចុង ខ្លះទិញបីតៅ ខ្លះទិញដប់ហាប។ តែមួយដង្ហវពីរវត្តតាកែវមកស្ពានកូនកាត់ តាង៉ែតលក់អង្ករដាច់អស់។ គាត់ត្រេកអរលាន់មាត់ប្រាប់ប្រពន្ធកូនថា ៖ ចម្លែកណាស់លើកនេះ លក់ នាប់ដាច់ ហើយមិនឿយពពាយនាយមួយម៉ាត់ផង។

គាត់បរសំដៅទៅផ្សារស៊ីលិប សំរាកឈប់យប់នៅកន្លែងខាងត្បូងផ្សារ។

ពេលយប់ ភ្នំពេញស្ងាត់ជាងពេលថ្ងៃទៅទៀត។ រាជការបានគ្របចង្កៀងតាមផ្លូវកុំឱ្យមានពន្លឺ ចាំងឆ្ងាយការពារកុំឱ្យយន្តហោះមើលដឹងជាទីក្រុង។ តាង៉ែតគ្មានហ៊ានទៅឆ្ងាយពីរទេះគាត់ទេ។ គាត់ បបួលកូនប្រពន្ធគាត់សំរាក ដើម្បីនឹងយកកម្លាំងបររទេះ ព្រឹកត្រលប់ទៅចំការវិញ។

លុះព្រឹកឡើងតាង៉ែតបានដាស់ប្រពន្ធគាត់ឱ្យដាំបាយ រៀបចំប្រដាប់ប្រដាដាក់រទេះ ហើយគាត់ ក៏បររទេះយកអង្ករមួយតៅប្រគេនលោកក្មួយគាត់ដែលគង់នៅវត្តប្រលោម។

ភ្នំពេញមិនបានសុខសប្បាយជាទេ លោះថ្ងៃតិចណាស់អ្នកក្រុងមិនរត់ចូលរួងត្រង់សេ។ ស្មើរ រាល់ព្រឹកល្ងាច យប់កញ្ចែឮដូចឆ្កែលួ បញ្ចេញសូរស័ព្ទប្រាប់អ្នកក្រុងឱ្យរត់ពួនលាក់ខ្លួនគេចគ្រាប់បែក ថា មានយន្តហោះអាមេរិចកាំងមកទម្លាក់គ្រាប់បែកសម្លាប់។ នៅលើចិញ្ចើមថ្នល់មានជីករួងត្រង់សេ ក្រងិចក្រងក់ទុកសម្រាប់ឱ្យអ្នកដំណើររត់ចូលពួន នៅពេលយន្តហោះខ្មាំងមកដល់។ តាង៉ែតឃើញ ស្ថានការណ៍ដូចនេះបារម្ភជាខ្លាំងក្នុងចិត្ត។ គាត់មិនធ្លាប់រត់គេចគ្រាប់បែក។ បើកញ្ចែស្រែក គាត់មិន ដឹងជារត់ចោលរទេះគោយ៉ាងណា ហើយមិនដឹងជានាំប្រពន្ធកូនរត់ទៅខាងណា។ គាត់បរទេះបណ្តើរ គាត់គិតបណ្តើរ។ គាត់ខំដេញគោឱ្យដើរលឿនលើផ្លូវក្រោយវត្តបុទុម រួចបត់តាមផ្លូវវាលមេរុខាង ជើងវាំង។ ដល់ជ្រុងខាងត្បូងវាលមេរុផ្លូវផ្សារស៊ីញ្វែក គាត់កាច់រទេះគាត់តម្រង់ទៅជើងចំមុខវត្ត ប្រលោម។ មកដល់មុខវត្តប្រលោមបៀតរូបស្តេចគំលង់ តាង៉ែតបញ្ឈប់រទេះ។ កំពុងយកអង្ករមួយ ល្អីពីរទេះ ស្រាប់តែឮសំឡេងឆ្កែលួ មុនដំបូងលើយៗ បន្តិចទៅខ្លាំងឡើងៗប្រាប់ថាមានយន្តហោះ អាមេរិចកាំងមកទម្លាក់គ្រាប់បែក។ យាយម៉ុកភ័យឆោឡោស្រែកឪវាយើងទៅខាងណា ?

តាង៉ែតទម្លាក់អង្ករចោលនាំប្រពន្ធកូនគាត់ចូលទៅវត្តចោលរទេះ ចោលគោ។ កញ្ចែឈប់ ស្រែក សូរស័ព្ទសន្ធឹកយន្តហោះបានបញ្ចេញឮសូរក្អុលធ្ងន់ ហើយមួយស្របក់ក្រោយគេឮមាត់មនុស្ស ច្របូកច្របល់គ្នា ៖

- លើកនេះមែនទែនហើយ សូរនេះមិនមែនយន្តហោះជប៉ុន បបួលគ្នាក្រាបប្រយ័ត្ន។
- មើលគ្រោះថ្នាក់មិនឃើញទេ ញាតិញោមអើយខំភាវនាធម៌ទៅ!

យាយម៉ុកភ័យស្ទាំងបានទន្ទេញញាប់មាត់ថា "ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ"។

នាងហោងភ័យញ័រមាត់ បានខ្សឹបសួរតាង៉ែតថា បើយើងមានគ្រោះថ្នាក់ តើបងលឺមទុក្ខសោក យ៉ាងណាទៅ ? តើម៉ែឪខ្ញុំព្រួយដូចម្តេចទៅ ?

តាង៉ែតបានកម្លាលើកទឹកចិត្តប្រពន្ធគាត់ថា "កុំភ័យព្រួយហួសពេក វាគ្មានអ្វីទេ ខំនឹកគុណ រតនត្រ័យ។ ស្រេចលើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ"។

យន្តហោះកាន់តែមកជិត សូរញ័រកក្រើកដី។ សំឡេងខ្សឹបខ្សាវច្របូកច្របល់ក៏ផុសចេញឡើងពី ត្រង់សេ ៖

- មកមែនហើយ ខំក្រាបឱ្យស្រួល ប្រយ័ត្នកុំយកជើមទ្រូងដាក់ផ្ទាល់នឹងដី។
- មកដល់ដប់។
- ហេតុអ្វីក៏ជប៉ុនមិនឡើងទៅដេញបាញ់ ?
- កុំព្រួយអ្វី គេមិនទម្លាក់លើវត្តទេ។ គេទម្លាក់លើឃ្លាំងកាំភ្លើងរំសេវ តែលើបន្ទាយទាហាន។

គ្រាប់បែកគ្មានស្គាល់វត្តអារាម គ្មានស្គាល់សង្ឃ គ្មានស្គាល់គ្រហស្ថ គ្មានស្គាល់ផ្សារ គ្មានស្គាល់បន្ទាយឡើយ។ សង្គ្រាមបង្ហិនបង្ហោចគ្រប់គ្នា។ ក្នុងពេលច្របូកច្របល់ ខ្លះយំ ខ្លះបន់ទេពតា បន់ព្រះ ខ្លះស្រែករកម៉ែឪដួនតា យន្តហោះបោះពួយ ចុះលឿនរំ ហើយត្រលប់ឡើងទៅវិញ ជំរុះគ្រាប់បែកធ្លាក់ចំចេតិយមុខរូបស្តេចគំលង់។ ដីថ្ពល់ស្មើរាបក៏បានប្រែទៅជាស្នាមភ្លោះជ្រៅ ចេតិយក៏បានរលាយបាក់បែកខ្ទេចខ្ទី។ អ្នកនៅជ្រកកោនពួនពីងផ្ញើជីវិតនឹងចេតិយ ខ្លះខ្ចាតដាច់ពីគ្នាហើយ ខ្លះត្រូវដុំថ្មសង្កត់លើ។ តាង៉ែត យាយម៉ុក នាងហោងបានខ្ចាតចេញពីគ្នាមិនដឹងខ្លួន។ គ្រាប់បែកបានលើកនាងហោងគ្រវែងចោលទៅឆ្ងាយ ហើយបានទាំងនាំដុំថ្មមួយយកទៅសង្កត់ជើមទ្រូងនាងទៀត។ នាងមានឈាមចេញពីមាត់។ នាងនិយាយមិនចេញ ហើយបែបចង់ហាមាត់ស្រែកហៅគេឯង ឬនឹកដល់គូសំឡាញ់ ឬនឹកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។

ការបន់ស្រន់ទាំងប៉ុន្មានជួយនាងមិនបាន។ នាងក៏ចាកឋានទៅជាមួយម៉ែឪក្មេកនាងព្រមនឹងប្រជាជនចិន វៀតណាម ខ្មែរជាច្រើនរូបទៀត។

សង្គ្រាមចក្រពត្តិបានកម្ទេចផ្ទះច្រើនខ្នងនៅក្រុងភ្នំពេញ បានធ្វើឱ្យកូនកំព្រាឪពុកម្តាយ បានធ្វើឱ្យម្តាយព្រាត់កូន បានធ្វើឱ្យអ្នកមានផ្ទះ រកផ្ទះជ្រកគ្មាន។

(ដកស្រង់ចេញពីរឿង តូលីកំណែន បោះពុម្ពដោយក្រសួងអប់រំ ទំព័រទី ២៤-២៧ ឆ្នាំ ១៩៨៧)

សំណួរ

១. ចូរអ្នកបង្ហាញពីអត្ថន័យសំខាន់ៗដែលទាក់ទងនឹងប្រពៃណី ទំនៀមទម្លាប់ខ្មែរ :
   - តួនាទីសាមីខ្លួនខាងប្រុសមុនពេលមង្គលការ។
   - តួនាទីឪពុកម្តាយខាងប្រុស ខាងស្រីមុនពេលមង្គលការ។

២. តើទស្សនៈរបស់ពូស្វាយ មីងពត អាចចាត់ទុកជាទស្សនៈតាងឱ្យមាតាបិតាខ្មែរបានដែរឬទេ ? ព្រោះអ្វី ? ហើយទស្សនៈនេះជាទស្សនៈវិជ្ជមាន ឬអវិជ្ជមាន ?


៣. បើតាមទស្សនៈរបស់អ្នកនិពន្ធបានបង្ហាញឱ្យឃើញពីផ្លូវអាណាចក្រនិងពុទ្ធចក្រ។ តើការបង្ហាញបែបនេះបានជះឥទ្ធិពលទៅលើផ្នត់គំនិតខ្មែរយ៉ាងណាខ្លះ ? ហេតុអ្វី ?

៤. បើផ្អែកទៅតាមដំណើររឿងនេះ គេអាចចាត់ទុកជាអក្សរសិល្ប៍បែបអ្វី ? ចូរអ្នករកអំណះអំណាងគាំទ្រ។

៥. ចូរបង្ហាញពីលក្ខណៈជាតិ លក្ខណៈមនុស្ស លក្ខណៈសង្គមតាមរយៈរឿងខាងលើនេះ។

៦. ចូរអ្នកធ្វើការសិក្សាពីសង្គមបរិយាកាសនិងគំនិតអ្នកនិពន្ធក្នុងការលើកយកតថភាពនាសម័យអាណានិគមមកឆ្លុះបញ្ចាំង។

ទៅពេលស្លាប់



ក. សិក្សាពាក្យគន្លឹះ

- តាយហោង (កិ) : ស្លាប់ខុសធម្មតា ស្លាប់ដោយត្រូវគេពិឃាត ឬស្លាប់ដោយលង់ទឹក ។
- គាស់ (កិ) : ជីករំលើង ធ្វើឱ្យរលើក ឱ្យកក្រើក ឱ្យហើប ។
- ស្លាប់តាមកាល (កិ) : ស្លាប់តាមកាលកំណត់ ដោយចាស់ជរា ។
- សុំខមាទោស (ន) : ការសុំឱ្យអត់ទោស ពាក្យសុំឱ្យអត់ទោស ឬលើកទោសចោល ។
- បន្ទូង (ន) : របស់ដែលគេដាក់ប្តូងឱ្យបព្វជិតទស់យក ។ របស់ដែលគេរៀបបញ្ជូនឱ្យបុគ្គលអ្នករំលាងខន្ធទៅហើយ ។
- ទៀនកល្ប (ន) : ទៀនមួយប្រភេទធំខ្លឹ សម្រាប់អុជជូនដំណើរបុគ្គល ដែលជិតនឹងទទួលមរណភាព (ប្រើតាមសណ្តាប់ស្រុក ចំពោះតែអ្នកដែលត្រូវការ) ។
- ទៀនគោល (ន) : ទៀនធំលញ់ដោយក្រមួន ទម្ងន់តាំងពី ១តម្លឹងឡើងទៅសម្រាប់ប្រើក្នុងពិធីបុណ្យ និងមង្គលការផ្សេងៗ ឬបិទនៅត្រែទេសនាដោយសន្មតថាជាគោល លើអស់ទៀនទាំងពួង ។

- ស្លាត្រួយ (ន) : កញ្ចប់ស្លឹកចេកស្រស់ខ្ចាស់កន្លាស់រាងតូចស្រួចចុងដើមស្មើគ្នាមានដាក់មួសា្លខាងក្នុង សម្រាប់ប្រើក្នុងការបុណ្យទានតាមរណ្តាប់ខ្មែរសម័យបុរាណ ។
- ព្រះចូឡាមណី (ន) : ឈ្មោះព្រះចេតិយមួយនៅឋានត្រៃត្រិង្ស ជាទីបញ្ចុះព្រះកេសាព្រមទាំងស្មៅតព្រះកេសនៃព្រះសក្យមុនីសម្មាសម្ពុទ្ធ ហៅឱ្យពេញថា ព្រះចូឡាមណីចេតិយនៅឋានត្រៃត្រិង្ស ។
- ហត្ថ (ន) : ឈ្មោះរង្វាស់ប្រវែងខ្មែរបុរាណ ដែល ១ហត្ថមានកន្លះលួក ឬប្រមាណជាកន្លះម៉ែត្រ ។
- ព្រះបត់ (ន) : គំនូរព្រះពុទ្ធរូបជាដើម ដែលគួរនឹងផ្ទាំងសំពត់អាចបត់ឬមូរបាន ។
- ក្អម (ន) : របស់ធ្វើអំពីដីសម្រាប់ដាក់ទឹក មានកស្តួចរាងធំក្លែង ដូចផ្លែឃ្លោកសាយដៀវ ។
- អាចម៍បំណះ (ន) : បន្ទះដីដែលរលើកធ្លាក់តម្រួតៗប៉ះលើគ្នាព្រោះភ្លូរ ។
- ចំអាសទឹក (កិ) : លាងជម្រះរូបសពដែលទើបនឹងស្លាប់ ។
- ខ្សែបាស (ន) : ឈ្មោះខ្សែអំបោះនៅសម្រាប់ទាក់ចងរុំសាកសពតាមកិច្ចតាមក្បួនយោគី ។
- សំសារវដ្ត (ន) : ដំណើរអន្ទោលទៅមក ដំណើរអន្ទោលកើតស្លាប់មិនឈប់មិនស្រាក ។
- ស្នប (ន) : សំពត់ដែលរុំសាកសព ។
- កោដ្ឋ (ន) : របស់សម្រាប់ដាក់សព ដាក់ធាតុ ។
- ឈាបនដ្ឋាន (ន) : ទីសម្រាប់ធ្វើឈាបនកិច្ច កន្លែងរំលាយសព ។
- ពពិល (ន) : ប្រដាប់ធ្វើដោយលោហជាតិមានសណ្ឋានស្រដៀងនឹងស្លឹកពោធិ៍ សម្រាប់បិទទៀនអុជកាន់ហុចបន្តគ្នាបង្កិលបក់ផ្សែងចូលជុំវិញមនុស្ស ឬរបស់អ្វីដើម្បីកើតស្រីសួស្តី ។
- អាចារ្យយោគី (ន) : អាចារ្យប្រមុខនៃអ្នកភ្ជុកទាំង ៤ នាក់ក្នុងការធ្វើឈាបនកិច្ច ឬរបស់អាចារ្យនាំសព ។
- លាជ (ន) : គ្រាប់ធញ្ញជាតិមានស្រូវជាដើម ដែលផ្ទុះបែកវីកព្រោះលីង ។

- ប៉ាន (ន) : ព្រៃសម្រាប់តម្កល់ ឬបញ្ចុះសព សម្រាប់កប់ខ្មោច ទីសម្រាប់រំលាយសព ឈាបនដ្ឋាន ។
- ស្បូវ (ន) : ស្មៅមួយប្រភេទ ស្លឹកវែងៗរឹងគគ្រាត មានពីរប្រភេទ គឺស្បូវភ្លាំងស្បូវស្លឹកធំៗប្រើការក្រងប្រក់ផ្ទះ ស្បូវរណាស ស្បូវស្លឹកល្អិតៗបើទាស់ប្រើការក្រងផ្ទះបានតែមិនសូវជាប់ ។
- ឧត្តរាព័ត៌ឬឧត្តរាវដ្ត (ន) : ដំណើរទៅរិលទៅខាងឆ្វេង ដើរជាឧត្តរាព័ត៌ ដើរវិលទៅឆ្វេងជុំវិញទីណាមួយ ។
- សព (ន) : ខ្មោចស្រស់ រួបបុគ្គលស្លាប់ សាកខ្មោច ។
- សំបួរមាស (ន) : ដើមតូច ផ្កាតូចៗ ពណ៌លឿង ក្លិនក្រអូបឆ្ងិតគេច្រើនដាំប្របមាត់ទ្វាររបងផ្ទះ ឬដាំធ្វើជារបងផ្ទះក៏មាន ។
- ប្រគេន (កិ) : ឱ្យ លើកឱ្យដល់ដៃក្នុងហត្ថបាស ប្រគេនចង្ហាន់លោក ។
- វិញ្ញាណក្ខន្ធ (ន) : កងវិញ្ញាណដែលរាប់បញ្ចូលក្នុងខន្ធ ៥ (រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ) ។
- ចេតិយ (ន) : ទីដែលគេគោរពបូជា គឺទីណាមួយទោះមានដើមឈើធំជាប្រធានជាទីសម្គាល់ក្តី មានថ្មធំៗជាទីចំណាំក្តី ។ល។ ដែលអ្នកផងគេសន្មត គេជឿថាជាទីស័ក្តិសិទ្ធិ គេតែងធ្វើសក្ការបូជាគោរពក៏ហៅចេតិយទាំងអស់ តែក្នុងប្រទេសយើងសព្វថ្ងៃចំពោះតែគារវវត្ថុដែលគេកដោយឥដ្ឋជាដើម សម្រាប់តម្កល់សារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាដើមនោះទើបហៅថាចេតិយ ។
- ឧទ្ទិសកុសល (កិ) : សំដៅទៅរក សំដៅចំពោះ ឆ្ពោះត្រង់ តម្រង់ទៅរក បម្រុងត្រង់ បម្រុងចំពោះ ធ្វើបម្រុង ឬដើម្បីឧទ្ទិសចំពោះព្រះសង្ឃ ។

អត្ថបទ

នៅក្នុងគ្រួសារខ្មែរ ក៏ដូចជាគ្រួសារជាតិសាសន៍ដទៃទៀត កាលបើមានមនុស្សស្លាប់គេតែងរៀបចំធ្វើបុណ្យ ជូនដំណើរខ្មោចនោះតាមទំនៀមទម្លាប់ដែលប្រែប្រួលទៅតាមសម័យកាលនិងប្លែកគ្នាខ្លះតាមតំបន់នីមួយៗ ។ ខ្មែរចាត់ទុកពិធីបុណ្យខ្មោច ឬបួជាសពជាករណីយកិច្ចមួយ ដែលគ្រួសារសពត្រូវបំពេញ ។ កាលណាគេរំលងប្រពៃណី ដោយទុកឱ្យឪពុកម្តាយ ជីដូនជីតាបងប្អូនស្លាប់ដូចសត្វធាតុនោះ នឹងត្រូវទទួលការរិះគន់ពីសង្គមហើយនឹងមានការស្តាយក្រោយជាពុំខាន ។

ការស្លាប់មានច្រើនបែបយ៉ាងណាស់ ដូចជាស្លាប់ដោយលង់ទឹក ចងក រន្ទះបាញ់ គ្រោះថ្នាក់ផ្សេងៗជាដើម។ មនុស្សដែលស្លាប់បែបនេះ ហៅថា "ខ្មោចតាយហោង" គឺស្លាប់មិនតាមកាលដែលគេពុំអាចប្រុងប្រៀបទុកជាមុនបាន។ តាមទំនៀមគេពុំយកខ្មោចតាយហោងទៅបូជាទេ គេយកទៅកប់សិនចាំបានពេលល្អទើបគាស់យកឆ្អឹងមកធ្វើបុណ្យវិញ។ ប៉ុន្តែសព្វថ្ងៃ គេពុំសូវយកទៅកប់ទេ ដោយខ្លះដឹកប់ផងហើយដោយទំនៀមទម្លាប់ប្រែប្រួលផង គេក៏យកខ្មោចប្រភេទនេះ មករៀបចំធ្វើបុណ្យបូជាដែរ។ ឯមនុស្សស្លាប់តាមកាល ដូចជាស្លាប់ដោយមានជំងឺមើលពុំជា ឬស្លាប់ដោយចាស់ជរា (ទុំជ្រុះ) គេអាចប្រុងប្រៀបរៀបចំជាមុនបាន ដូចមានសេចក្តីអធិប្បាយខាងក្រោយនេះ។

នៅពេលជិតស្លាប់ គេនិមន្តព្រះសង្ឃ ៤អង្គ ឬ ១អង្គក៏បាន មកសូត្រធម៌ឱ្យអ្នកជំងឺស្តាប់។ តែត្រូវរកអាចារ្យម្នាក់នៅជួយមើលខុសត្រូវរហូតដល់ដង្ហើមចុងក្រោយ។ នៅពេលនោះដែរមិត្តភក្តិបងប្អូនកូនចៅក្តី ដែលបានប្រព្រឹត្តមិនគប្បីចំពោះអ្នកនោះត្រូវមកសុំខមាទោស។ បន្ទាប់មក គេឱ្យអ្នកជំងឺទន្ទេញធម៌ថា **ពុទ្ធោអរហំ** ហើយឱ្យតាំងស្មារតីឱ្យនឹងក្នុងអំពើល្អដែលខ្លួនបានធ្វើហើយកុំឱ្យខ្ញល់ខ្ចាយជំពាក់ចិត្តទៅលើគ្រួសារ លើទ្រព្យសម្បត្តិជាដើម។ នៅខណៈនោះគេនាំរៀបចំគ្រឿងបន្លងមានគ្រឿងបរិភោគ ឧបភោគ និងរបស់ផ្សេងៗសម្រាប់ថ្វាយព្រះសង្ឃនៅពេលស្លាប់ទៅ។ ប្រដាប់ប្រដាទាំងនោះត្រូវយកទៅបង្ហាញអ្នកជម្ងឺឱ្យបានឃើញ ហើយត្រេកអរនឹងកុសលផលបុណ្យនោះផង ចំណែកអាចារ្យក៏រៀបចំលញ់ ទៀនកល្ប ទៀនគោល ធ្វើស្លាត្រួយ ទង់ព្រលឹង និងសុពារបាត ៦សន្លឹក (ជាបន្ទះធ្វើដោយមាស ឬប្រាក់ ឬទង់ហ៊ូ ឬស្លឹកវឹត ឬក្រដាសក៏បានទុកដាក់ដល់ពេលស្លាប់នៅត្រង់ថ្ងាស ក្បាល បបូរមាត់ លើចង្កាក្នុងដៃប្រណម្យ និងលើដើមទ្រូង)។ គេអុជទៀនកល្បនៅពេលជិតដាច់ខ្យល់ និងនៅពេលស្លាប់។ ឯស្លាត្រួយគឺស្រទាប់ស្លឹកចេកដែលគេដោតស្លា ម្ហូ ធួប ហើយដែលគេធ្វើទុកសម្រាប់ឱ្យអ្នកជំងឺកាន់ថ្វាយដល់ ព្រះចូឡាមណី (ចេតិយនៅឋានត្រៃត្រឹង្ស ដែលបញ្ចុះព្រះកេសា និងស្មៅតព្រះកេសរបស់ព្រះពុទ្ធ) នៅពេលដែលកម្លាំងកាន់តែខ្សោយទៅ គេធ្វើទង់ព្រលឹងដោយកំណាត់សំពត់សរែងប្រហែល ១ហត្ថនៃអ្នកជំងឺ។ នៅលើទង់ព្រលឹងនោះ ជួនកាលគេទុកទំនេរ ជួនកាលគេចារគាថា ជួនកាលទៀតគេគូររូបព្រះចូឡាមណី។ នៅតាមតំបន់ខ្លះ គេគូររូបក្រពើតំណាងក្រុងពាលី។ គេដាក់ទង់ព្រលឹងនោះនៅក្បាលគ្រែអ្នកជិតស្លាប់ ហើយបន្តអំបោះពីទង់ព្រលឹងទៅដល់រូបព្រះពុទ្ធ ឬព្រះចូឡាមណី។ គេមានជំនឿថា លុះអ្នកនោះស្លាប់ទៅទង់ព្រលឹងនេះឯងនឹងទ្រព្រលឹងរហូតដល់ពេលចាប់ភពជាថ្មី។ នៅជុំវិញនិងនៅខាងលើអ្នកជំងឺ គេចងកំណាត់សំពត់ស ឬព្រះបត់(បដាដែលគេគូរជីវប្រវត្តិព្រះពុទ្ធ)។

លុះមនុស្សនោះផុតដង្ហើមទៅហើយ អាចារ្យចូលទៅបិទភ្នែក និងមាត់ខ្មោច ហើយយកសុពារបាតទាំង ៦ សន្លឹកមកដាក់តាមកន្លែងដែលត្រូវដាក់។ រំពេចនោះគេយកទៀនកល្បមកអុជបិទនៅក្បាលគ្រែ ហើយយកទៀនគោល ៥ ទៀតមកអុជតាំងពីពេលជិតស្លាប់នោះត្រូវអុជបន្តទៅកូនចង្កៀងប្រេងកាតជំនួសវិញ។ បន្ទាប់មកគេរៀប ទៀនត្បូង ដែលមានស្រួវពន្លៃ ១ ល្អឺ ប្រាក់ ១ បាត សំពត់ស ៥ ហត្ថ ចេកទុំ ១ ស្ទឹត និងចង្កៀងប្រេងកាតនោះដាក់តម្កល់នៅចុងជើងខ្មោច។ នៅក្រោមកន្លែងតម្កល់ទៀនត្បូងនោះ គេដាក់ថ្ម ១ ដុំនិងទឹក ១ ក្អម។ តាមជំនឿគេថា ការអុជបន្តភ្លើងទៀនកល្បមកចង្កៀងប្រេងកាតជានិមិត្តរូបនៃជីវិតដែលរលត់ពីរូបមួយទៅបន្តក្នុងរូបមួយថ្មីទៀត។ តាមទំនៀមទម្លាប់នៅតំបន់ខ្លះ គេយកដីអាចម៍បំណះមួយដុំដាក់ក្នុងល្អឺស្រូវជាការសម្គាល់ថា រូបកាយនឹងត្រូវក្លាយជាដីវិញ ហើយក្នុងពេលដ៏នាប់នឹងដុំផ្សំផ្សេីតបានជារូបកាយមនុស្សជាថ្មី។ នៅមុខផ្ទះខ្មោចមានដោតទង់ក្រពើមួយ ឬមួយគូជាសញ្ញាឱ្យដឹងថានៅផ្ទះនោះមានមនុស្សស្លាប់ថ្មីៗ។ មុននឹងដាក់ខ្មោចទៅក្នុងមឈូស តាមទំនៀមទម្លាប់គេត្រូវលើកខ្មោចនោះចំអាសទឹកសិន។[1] ហើយលាបទឹកអប់សិតសក់ (សិតទៅក្រោយ ៣ ដង រួចសិតមកមុខ ៣ ដងដើម្បីជាប្រស្នាថា ការរិលកើតស្លាប់ត្រឡប់ចុះឡើងក្នុងភព ៣)។ បន្ទាប់មកគេយកសំពត់ស ៤ ហត្ថស្លៀកឱ្យខ្មោចដាក់ថ្នក់មកខាងមុខ សំពត់ស ៤ ហត្ថទៀតស្លៀកដាក់ថ្នក់ទៅខាងក្រោយវិញ(ដើម្បីជាប្រស្នាថាមានអវិជ្ជាបិទក្រោយនិងតណ្ហាចាក់ស្រេះគ្នា)សំពត់ ៤ ហត្ថទៀត ពានាពាក់ពីលើស្មាខាងស្តាំ។ រួចហើយគេយកខ្សែបាស ចងខ្មោចត្រង់ក-កដៃនិងកជើង។ ការចងខ្មោចបែបនេះមានទំនាក់ទំនងទៅនឹងផ្លូវធម៌ថា មនុស្សយើងមានចំណងលោកិយ ៣ ប្រការគឺ : ប្រពន្ធឬប្តី កូននិងទ្រព្យសម្បត្តិ។ បើអ្នកណាផុតពីចំណងនេះបាននឹងរួចផុតពីសំសារវដ្ត។ តមកទៀតគេយកមាស ឬប្រាក់មួយកាក់ទៅបង់ក្នុងមាត់ខ្មោច (ដើម្បីជាគ្រឿងពិចារណាថា នៅពេលស្លាប់គេពុំអាចយកទ្រព្យសម្បត្តិទៅផងបានទេ សូម្បីតែប្រាក់មួយកាក់ក្នុងមាត់នេះក៏យកទៅពុំបានដែរ)។ នៅទីបញ្ចប់ គេយកសំពត់សប្រវែងមួយចំអាម ៤ ជ្រុង គ្របមុខឱ្យខ្មោច រួចលើកខ្មោចដាក់លើស្មប (សំពត់រុំខ្មោចប្រវែង ១២ ហត្ថ)។ លុះរុំខ្មោចរួចហើយ គេចងខ្សែបាសម្តងទៀតទើបដាក់ទៅក្នុងក្តារមឈូស។ ខណៈនោះគេនិមន្តព្រះសង្ឃបង្សុកូល។ ចំពោះគ្រួសារក្រខ្សត់ ពិធីបូជាសពអាចប្រព្រឹត្តនៅថ្ងៃនោះ។ ចំពោះគ្រួសារអ្នកមានគ្រាន់បើ អាចតម្កល់សពនោះទុកក្នុងរវាង ពីរ ឬបីថ្ងៃទៀត។ ចំណែកសពស្តេចឬព្រះសង្ឃថៅអធិការវត្ត គេតម្កល់ដាក់ក្នុងកោដ្ឋទុកយូរថ្ងៃទើបបូជា។

---

(១) : ការចំអាសទឹកឱ្យខ្មោច តាមជំនឿពួកព្រាហ្មណ៍ថាជាការលាងបាបនៅពេលស្លាប់។ កាលនៅរស់មនុស្សនោះលាងបាបខ្លួនឯងមួយឆ្នាំម្តងនៅក្នុងទន្លេគង្គា។ តាមជំនឿខ្មែរយើងវិញថាការផ្តួតទឹកឱ្យខ្មោចគឺជាការដឹងគុណដល់អ្នកនោះ ខ្លះថាធ្វើឱ្យជ្រះក្លិនមិនល្អក្នុងពេលតម្កល់។

ក្បួនដង្ហែ និងពិធីរំលាយសព លុះថ្ងៃឈាបនកិច្ចមកដល់ គេត្រូវរៀបក្បួនដង្ហែសពនោះឆ្ពោះទៅកាន់ឈាបនដ្ឋាន។ មុននឹងរំកិលសពចេញពីទីតម្កល់ គេនិមន្តព្រះសង្ឃបង្សុកូល ជួនកាលគេប្រារព្ធពិធីបង្វិលពពិល ៣ជុំ ជុំវិញមឈូស។ បន្ទាប់មកទៀតតាមទំនៀមទម្លាប់នៅពេលរំកិលសពចេញទៅអាចារ្យយោគីយកភ្នែមទឹកទៅស្រោចរំងាប់ដុំថ្ម រួចទាត់ទម្លាក់ចោលទៅដីនូវភ្នែមទឹកនិងដុំថ្មនោះ (ប្រហែលមានន័យធ្វើរូបឱ្យបែកធ្លាយទៅ)។ ឯក្បួនដង្ហែសពមានរបៀបដូចតទៅនេះ

- ព្រះសង្ឃសូត្រព្រះអភិធម្ម។
- ព្រះសង្ឃមាតិកា ជួនកាលព្រះសង្ឃនៅជាមួយសពមានសូត្រធម៌ផង។
- អាចារ្យយោគីកាន់ទង់ព្រលឹង។
- វង់ស្លេងខ្មោច (បើមាន)
- អ្នកប្រាយលាជ (ក្មេងស្រីស្លៀកពាក់ស ជាកូន ឬសាច់ញាតិរបស់សពបាចលាជទៅស្តាំម្តងឆ្វេងម្តង ដោយទន្ទេញធម៌បណ្តើរផង ហើយមើលទៅមុខជានិច្ច។ គ្រាប់លាជដែលបាចនៅដីជាតំណាងឆ្អឹងនៃខ្មោចដែលនៅរាយប៉ាយលើដី)។
- អ្នកបួសមុខភ្លើង (ក្មេងប្រុសជាកូន ឬសាច់ញាតិរបស់សពកោរសក់ ស្លៀកស ពានាស) នៅជុំវិញក្បាលមានខ្សែស្បូវភ្លាំង ឬស្មៅផ្លងចងបន្តពីមឈូសមក។ គេថាខ្សែស្បូវភ្លាំងនោះជានិមិត្តរូបនៃនាគជីវិត ដែលបន្តគ្នាដូចច្រវាក់ (Chaine d'existence) ហើយការបួសមុខភ្លើងនេះគឺជាកិច្ចតបស្នងសងគុណមួយដែរ។
- អ្នកភ្ជុក (អ្នកដុតខ្មោច) ៤នាក់សែងមឈូសយកជើងទៅមុខ (សព្វថ្ងៃគេនិយមដាក់មឈូសហែលើរថយន្ត)។
- អ្នកទទួលទៀនត្បូង (ក្មេង ឬអ្នកបំរើពេញចិត្តរបស់សព)។
- គ្រួសារនិងញាតិមិត្តរបស់សព។

លុះដល់ទីប៉ាន់ាហើយគេហែប្រទក្សិណ ៣ជុំជាឧត្តរាព័ត៌ (ពីខាងឆ្វេងនៃប៉ាន់ា) រួចហើយដាក់មឈូសលើជើងថ្កូរយកក្បាលទៅទិសខាងលិច។ គេបើកគំរបមឈូសឡើង អាចារ្យក៏បើកស្មប បើកកន្សែងគ្របមុខ (កូនចៅសពខ្លះយកកន្សែងនេះទុកឡើងថានាំឱ្យមានសិរីសួស្តីរកស៊ីមានបាន) រួចកាត់ចំណងខ្សែបាសហើយនិមន្តលោកបង្សុកូល។ បន្ទាប់មកទើបញាតិមិត្តនាំគ្នាយកផ្កា ទៀនធូប ទៅដាក់លើសពសុំខមាទោសជាចុងក្រោយ។ រួចហើយអាចារ្យយោគីនិងអ្នកភ្ជុក ៤នាក់ អុជចន្លុះមួយដើមម្នាក់ដើរព័ទ្ធជុំវិញមឈូស ៣ជុំជាឧត្តរាព័ត៌ ហើយអាចារ្យក៏ដុតភ្លើងបូជាសពនោះទៅ។ ចំពោះសពអ្នករដ្ឋការគេនិយមសូត្រសុន្ទរកថាថ្លែងពីជីវប្រវត្តិសពនិងវិយោគទុក្ខនៃញាតិមិត្តមុនពេលបូជា។ នៅ

ពេលដែលភ្លើងកំពុងឆេះសព គេនិមន្តលោកបំបួសអ្នកបួសមុខភ្លើងហើយនិមន្តទេសនាមុខភ្លើងទៀត។ គេអាចផ្សឹកអ្នកបួសមុខភ្លើងនៅពេលបួជាសពរួច ជួនកាលគេទុករហូតដល់ព្រឹកស្អែកទើបដាក់ផ្ទួស។ លុះ ៥ ឬ ៦ម៉ោងក្រោយមក រូបនៃសាកសពក៏ឆេះសុសអស់។ អ្នកភ្លុកយកសំពត់គ្របមឈូស ចោលរំលងភ្លើង ៣ដង ដើម្បីរំងាប់ចង្រៃឧបទ្រព។ យោគីយកទឹកមន្ត (ទឹកសំបួរមាស)មួយផ្ដិល អ្នកភ្លុកកាន់ក្អមទឹកម្នាក់មួយដើរប្រទក្សិណជាឧត្តរាព័ត៌ ៣ជុំ ហើយលត់ភ្លើង បន្ទាប់មកគេបាចគ្រាប់ស្រូវ សណ្តែក លូនៅលើគំនរធ្យូងនិងផេះដើម្បីប្រារព្ធពិធីប្រែរូប។ ឯគ្រាប់ធញ្ញជាតិដែលបាចនោះជានិមិត្តរូបនៃការស្លាប់ដែលជាសំណាបនៃជីវិតថ្មី។

ពិធីប្រែរូបប្រព្រឹត្តទៅ ៣ដង (ដើម្បីឱ្យពិចារណាទៅតាមភពទាំង ៣)។ ដំបូងយោគីយកចបប្រមូលធ្យូងធ្វើជារូបមនុស្សមានក្បាលទៅខាងកើតហើយសួរថាល្អ ឬទេ ? អ្នកភ្លុកឆ្លើយថាមិនល្អទេក៏ធ្វើរូបមនុស្សម្តងទៀតមានក្បាលទៅខាងលិចហើយសួរដូចមុនទៀត គេឆ្លើយថា នៅមិនទាន់ល្អទេ។ លើកទី ៣ អាចារ្យធ្វើរូបមនុស្សមានក្បាលទៅទិសខាងកើតវិញរួចសួរបញ្ជាក់ថាល្អហើយឬនៅ គេឆ្លើយថាល្អហើយ ទើបយកស្លឹកចេកមួយផាងគ្របលើរូបនោះ ហើយយកសំពត់ស ៥ហាត្ថមកដាក់លើស្លឹកចេក។ នៅទីបញ្ចប់គេនិមន្តលោកបង្សុកូល ឬគេឱ្យយោគីបង្សុកូលនាកយកសំពត់សនោះទៅ។ លំដាប់មកទើបគ្រួសារសពនាំគ្នារើសធាតុយកមកលាងទឹកឃ្មុរ ទឹកសំបួរមាស និងទឹកដូងខ្ចី។ នៅពេលដែលរើសធាតុ កូនចៅណារើសបានប្រាក់កាក់ ឬធ្មេញរបស់សពគេចាត់ទុកប្រាក់ ឬធ្មេញនោះថាជាអំណោយពិសេសរបស់សពដល់កូនចៅនោះហើយត្រូវថែរក្សាឱ្យបានគង់វង្ស។ ឯធាតុដែលលាងស្អាតហើយគេយកទៅដាក់ក្នុងកោដ្ឋតូចមួយ ដែលគេយកទៅតាំងនៅក្នុងផ្ទះ។

នៅយប់ថ្ងៃដដែលគេនិមន្តព្រះសង្ឃសូត្រមន្តទេសនាហើយព្រឹកស្អែកគេធ្វើចង្ហាន់ប្រគេនលោកទៀត ដើម្បីបញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធនៃសព។ លុះដល់ខួប ៧ថ្ងៃ បន្ទាប់មកខួប ១០០ថ្ងៃគេប្រារព្ធធ្វើបុណ្យដូចនេះទៀត។ ក្រោយពីបានធ្វើបុណ្យខួប ១០០ថ្ងៃហើយ គេអាចទុកធាតុនៅក្នុងផ្ទះតទៅទៀតក៏បាន ឬក៏យកទៅបញ្ចុះក្នុងចេតិយនៅវត្តក៏បាន។ អំណើះតទៅមុខទៀតគេគ្រាន់តែរំលឹកគុណ ដោយធ្វើបុណ្យឧទ្ទិសកុសលតាមពេលវេលាជាប្រពៃណីតទៅ។

ចំពោះការកាន់ទុក្ខ គ្រួសារផ្ទាល់នៃសពនិយមកោរសក់ ស្លៀកពាក់សឬខ្មៅ ឬស្លៀកខ្មៅពាក់ស។ ជាទូទៅគេកាន់ទុក្ខចំនួន ១០០ថ្ងៃ ប៉ុន្តែមានអ្នកខ្លះកាន់រហូតដល់ ១ឆ្នាំក៏មាន។

សេចក្តីសង្កេត

- **សម័យហ្វូណន**

ក្នុងករណីកាន់ទុក្ខគេត្រូវកោរសក់និងកោរពុកមាត់ ។ ឯវិធីរំលាយសពមាន ៤ យ៉ាងគឺ :

១. បោះចោលសពទៅក្នុងទន្លេ

២. បូជាដោយភ្លើង

៣. យកសពទៅកប់

៤. យកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី ។

ក្នុងករណីបូជាភ្លើង គេតែងប្រមូលធាតុដែលនៅសល់យកទៅដាក់ក្នុងកោដ្ឋមួយចិទជិត ហើយយកទៅបោះចោលក្នុងទឹកទន្លេ ។ បើជាព្រះមហាក្សត្រកោដ្ឋនោះធ្វើពីមាស បើជានាម៉ឺនសព្វមុខមន្ត្រីគេប្រើកោដ្ឋប្រាក់ ហើយបើជារាស្ត្រសាមញ្ញគេប្រើកោដ្ឋដី ។

- **សម័យចេនឡា**

អ្នកដំណើរចិនឈ្មោះ ម៉ាតួលីន បានសរសេរទុកថាក្នុងករណីមានទុក្ខពួកកូនចៅនៃសពត្រូវកោរសក់យំស្រែកយ៉ាងខ្លាំង ហើយអត់បាយអស់រយៈពេល ៧ ថ្ងៃទៀតផង ។ សពត្រូវគេយកទៅបូជា ហើយគេប្រមូលធាតុដាក់ក្នុងកោដ្ឋធ្វើពីមាស ឬពីប្រាក់ហើយបោះចោលទៅក្នុងទឹកដ៏ជ្រៅ ។ ពួកអ្នកក្រគេប្រើកោដ្ឋធ្វើពីដី ហើយមានលាបពណ៌ផ្សេងៗ ។ មានអ្នកខ្លះទៀតពេលមានមនុស្សស្លាប់ គ្រាន់តែយកទៅដាក់ចោលក្នុងព្រៃភ្នំទុកឱ្យសត្វស៊ីជាការស្រេច ។

(ដកស្រង់អត្ថបទ "ហ្វូណនជារដ្ឋខ្មែរ ឬពុំមែនទេ" របស់លោកត្រឹងងា
ចុះផ្សាយក្នុងព្រឹត្តិប័ត្រខ្មែរ-មន លេខ ៥ សីហា ១៩៧៣ ត្រង់ទំព័រ ២៥)

- **សម័យអង្គរ**

លោក ជីវតាក្វាន់ បានកត់សម្គាល់ឃើញថា ពេលមានមនុស្សស្លាប់គេឥតមានដាក់ក្តារមឈូសទេ គេយកតែកន្ទេលក្រាលពីក្រោម យកកំណាត់សំពត់ក្រាលពីលើ ហើយគេយកទៅព្រៃ ។ លុះសែងដល់ក្រៅក្រុង ដល់កន្លែងណាមួយស្ងាត់ គេដាក់ខ្មោចនោះចោលហើយត្រឡប់មកវិញដើម្បីទុកឱ្យសត្វមកស៊ី ។ ប៉ុន្តែ លោក ជីវតាក្វាន់ ក៏បានសង្កេតឃើញថាមានគេយកខ្មោចទៅដុតបូជាខ្លះៗហើយ ។ ពេលកាន់ទុក្ខគេឥតស្លៀកពាក់សទេ តែគ្រាន់តែកោរសក់ (ប្រុសៗ) ឬកាត់សក់ (ស្រីៗ) ។

• **សម័យបច្ចុប្បន្ន**

ខ្មែរយើងសព្វថ្ងៃឃើញថានិយមប្រើវិធីបូជាជាងគេ ឯខ្មែរនៅកម្ពុជាក្រោមច្រើននិយមយកសព ទៅកប់អស់មួយរយៈពេលរួច ទើបគេធ្វើបុណ្យ "លើកសព" រីសធាតុដាក់ក្នុងកោដ្ឋយកទៅដាក់ក្នុង ផ្នះ ឬយកទៅតម្កល់ក្នុងចេតិយដែរ ។

(ដកស្រង់ចេញពីអរិយធម៌ខ្មែររបស់អ្នកស្រី ត្រឹងងា ឆ្នាំ ១៩៧៥ ទំព័រ ១២៧-១៣៤)

សំណួរ

១. តាមប្រពៃណីនៃការស្លាប់ តើជនជាតិខ្មែរបានរៀបចំពិធីជាប៉ុន្មានដំណាក់ ? អ្វីខ្លះ ?

២. តើគេនិយមធ្វើអ្វីខ្លះ ?

ក. មុនពេលស្លាប់ ?

ខ. ពេលស្លាប់ ?

គ. ក្រោយពេលស្លាប់ ?

៣. ចូរអ្នកបង្ហាញពីអត្ថន័យនៃ "កោដ្ឋ"ក្នុងទំនៀមទម្លាប់ខ្មែរ ។

៤. តើការប្រើទង់ព្រលឹងមានអត្ថន័យយ៉ាងណាខ្លះចំពោះអ្នកស្លាប់ ? ចូរបង្ហាញ ។

៥. តើពិធីរំលាយសព មានចំណុចសំខាន់ៗអ្វីខ្លះគួរកត់សម្គាល់ ?

៦. ចូរអ្នករកលក្ខណៈជាតិតាមរយៈប្រពៃណីនៅពេលស្លាប់ ។

៧. តើការធ្វើពិធីបុណ្យឱ្យអ្នកស្លាប់នៅសម័យចេនឡានិងសម័យអង្គរមានលក្ខណៈយ៉ាងណាខ្លះ ?

៨. តើអត្ថបទនេះ បានផ្តល់តម្លៃអប់រំយ៉ាងណាខ្លះចំពោះអ្នក ?



ពិធីចម្រើនអាយុ

ពាក្យថា "ចម្រើនអាយុ" ជាពាក្យហៅទូទៅ។ របៀបធ្វើមានទំនងផ្សេងៗគ្នា ឯឈ្មោះហៅក៏ដូរតាមប្រភេទពិធី ឬតាមតំបន់ផងក៏សឹងមាន។ បើគេធ្វើរបៀបសង្ខេបបន្តិច តែងឮគេហៅថា "បុណ្យបច្ច័យបួន" ជាពិសេសនៅទីក្រុងភ្នំពេញនិងតំបន់ជុំវិញនោះ។ នៅទីដទៃទៀតខ្លះពុំថាក្រុងឬជនបទឡើយ ជួនកាលគេធ្វើកិច្ចនោះវែងឆ្ងាយហៅថា "ចន្ទសុក្រគីរីសូត្រ" ឬបើធ្វើកិច្ចនោះទូលំទូលាយជាងបន្តិចទៅទៀតហៅថា "ឆាកមហាបង្សុកូល"។ តែទោះជាកិច្ចទាំងនោះវែងឬខ្លី តិចឬច្រើន ក៏គំនិតជាគោលនោះ ផ្តោតសំខាន់ទៅលើការចម្រើនដល់អាយុកាលឬការស្លាប់របស់សាមីខ្លួន ហើយបន្ទាប់មកការកើតសាជាថ្មីឡើងវិញ។ ពិធីនេះគេអាចធ្វើពីខែផល្គុនដល់ខែពិសាខ ប៉ុន្តែភាគច្រើនគេនិយមប្រារព្ធនៅខែចេត្រច្រើនជាងគេ។ នេះប្រហែលជាមកពីកិច្ចខ្លះនៅក្នុងនោះ មានន័យប្រហាក់ប្រហែលគ្នានឹងកិច្ចខ្លះនៃពិធីចូលឆ្នាំ ដែលតែងតែធ្វើឡើងក្នុងខែចេត្រនេះឯងដូចជាស្រង់ទឹកព្រះ ពូនភ្នំខ្សាច់ជាដើម។ គេតែងពូនភ្នំខ្សាច់ក្នុងបុណ្យចន្ទសុក្រគីរីសូត្រ ហើយម្យ៉ាងទៀតពិធីចម្រើនអាយុណាមួយក៏តែងតែមានកិច្ចស្រោចទឹកដែរ។[(១)]

ចូរអ្នកស្តាប់អត្ថបទចម្រើនអាយុ ហើយត្រៀមឆ្លើយនឹងសំណួរខាងក្រោមនេះ

១. តើអ្វីទៅដែលហៅថាពិធីចម្រើនអាយុ ?

២. តើការធ្វើពិធីចម្រើនអាយុភាគច្រើនគេត្រូវធ្វើឱ្យមនុស្សវ័យណា ? ហើយគេប្រារព្ធពិធីនេះឡើងដើម្បីអ្វី ?

៣. តើពិធីចម្រើនអាយុនេះ ទាមទារឱ្យតែអ្នកជិតស្និទ្ធ (សាច់ឈាមបង្កើត) ជាអ្នកផ្តើមប្រារព្ធជូនចំពោះសាមីពិធី ឬក៏អ្នកដទៃក៏បំពេញកិច្ចនេះជូនបានដែរ ? ហេតុអ្វី ?

៤. ចូរអ្នកកំណត់អត្ថន័យនៃ :

- បុណ្យបច្ច័យបួន
- ឆាកមហាបង្សុកូល
- ចន្ទសុក្រគីរីសូត្រ

៥. តើពិធីចម្រើនអាយុនិងពិធីបុណ្យខួបថ្ងៃកំណើតដូចគ្នាដែរឬទេ ? ចូរពន្យល់។

៦. ចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីចំណុចសំខាន់ៗដែលជាគំនិតអ្នកនិពន្ធមានក្នុងអត្ថបទនេះ។

៧. តាមរយៈពិធីចម្រើនអាយុនេះ ចូរអ្នកបង្ហាញឱ្យឃើញពីអត្តសញ្ញាណជាតិខ្មែរ។

---

(១) : អាំង ជូលាន , ព្រាប ចាន់ម៉ារ៉ា , ស៊ុន ចាន់ដឹប "ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ" ទំព័រ ៦៧ ឆ្នាំ ២០០៧



ការស្រាវជ្រាវ

ការស្រាវជ្រាវមានច្រើនប្រភេទ។ ការស្រាវជ្រាវអាចធ្វើទៅតាមការសាកសួរព័ត៌មានដោយផ្ទាល់មាត់ ទៅលើមនុស្សចាស់ទុំច្រើនគ្នា ដែលធ្លាប់ដឹងឮហេតុការណ៍ ឬរឿងរ៉ាវដែលកន្លងផុតទៅតាមរយៈឯកសារដែលមានស្រាប់ ឬក៏តាមរយៈការរុករកក្នុងធម្មជាតិ។ ពេលនេះអ្នកនឹងសិក្សាអំពីសំណេរស្រាវជ្រាវដែលទាក់ទងទៅនឹងជំនឿ ដែលមានប្រភពតាមការស្រាវជ្រាវ ឬដកស្រង់ចេញពីសៀវភៅនានា។ ដូច្នេះអ្នកត្រូវ :

- កំណត់ប្រធានបទ ដែលត្រូវស្រាវជ្រាវឱ្យបានច្បាស់លាស់។
- កំណត់ទីតាំងរកឯកសារ (បណ្ណាល័យ មជ្ឈមណ្ឌលតំកល់ឯកសារនានា) ដើម្បីរកឯកសារពិគ្រោះ។
- អានមាតិកាអត្ថបទរបស់សៀវភៅ ដើម្បីរកចំណងជើងដែលទាក់ទងនឹងប្រធានបទរបស់អ្នក។
- អានអត្ថបទដែលអ្នករកឃើញដោយប្រុងប្រយ័ត្ន ដើម្បីយកខ្លឹមសំខាន់ៗដែលទាក់ទងនឹងប្រធានបទរបស់អ្នក។
- ស្រង់ប្រភពឯកសារ ដូចជាចំណងជើងសៀវភៅ ឈ្មោះអ្នកនិពន្ធ ទីកន្លែង និងឆ្នាំបោះពុម្ពផ្សាយ ព្រមទាំងទំព័រអត្ថបទ។

ចូរពិនិត្យមើលគំរោងខាងក្រោម ៖

- **ផ្តើមសេចក្តី**
  - ប្រាប់ពីប្រធានបទនិងចំណងជើងនៃការស្រាវជ្រាវលើប្រធានបទនោះ។
- **តួសេចក្តី**
  - ផ្តល់សេចក្តីពន្យល់និយមន័យចាំបាច់លើពាក្យគន្លឹះ ប្រធានបទ ប្រធានបទរងជាដើម។
  - ស្រង់ឧទាហរណ៍ក្នុងឯកសារយោង(ឯកសារដែលយើងកំពុងពិគ្រោះក្នុងសំណេរស្រាវជ្រាវនេះ) ក្នុងករណីនេះត្រូវចុះលេខយោងប្រាប់ពីប្រភព ... ។
  - រកឧទាហរណ៍មកបន្ថែម។
  - ពន្យល់លក្ខណៈពិសេសនៃផ្នែកនីមួយៗ។
- **បញ្ចប់សេចក្តី**
  - វាយតម្លៃលើលទ្ធផលនៃការស្រាវជ្រាវ។
  - ភ្ជាប់បញ្ជីឯកសារពិគ្រោះ។

ចូរអ្នកពិនិត្យមើលសំណេរស្រាវជ្រាវគំរូដូចខាងក្រោមនេះ

ប្រធាន : ចូរអ្នកធ្វើការស្រាវជ្រាវអំពីប្រពៃណីទំនៀមទម្លាប់តាមរយៈរឿងទុំទាវ ។

ប្រពៃណីទំនៀមទម្លាប់ ជាផ្នែកមួយនៃវប្បធម៌ជាតិ ដែលជនជាតិខ្មែរតែងតែប្រកាន់តាំងពីដើមរៀងមក ។ ក្នុងវិស័យនេះបានឆ្លុះបញ្ចាំងតាមរយៈជីវភាពរស់នៅរបស់ប្រជារាស្ត្រខ្មែរ និងក្នុងស្នាដៃអក្សរសិល្ប៍នានា ដែលកវីនិពន្ធយើងបានចងក្រងជាប្រធានបទ ដើម្បីបង្ហាញពីតថភាពសង្គមក្នុងសម័យកាលនីមួយៗ ដល់អ្នកសិក្សាអ្នកអាន ។ ចំណែករឿងទុំទាវវិញ កវីនិពន្ធយើងក៏បានផ្សារភ្ជាប់វិស័យប្រពៃណីទំនៀមទម្លាប់នៅសម័យលង្វែក ដែលបង្កប់ជាមួយនូវលក្ខណៈជាតិខ្មែរតាំងពីបុរាណកាលមកម្ល៉េះ ។

តើតាមរយៈរឿងទុំទាវ បានបង្ហាញពីប្រពៃណីទំនៀមទម្លាប់យ៉ាងណាខ្លះ ?

ដើម្បីជាមូលដ្ឋាន នៃការសិក្សាទៅលើវិស័យទំនៀមទម្លាប់ ក្នុងស្នាដៃខាងលើនេះយើងគប្បីស្វែងយល់ន័យនៃកន្សោមពាក្យ "ទំនៀមទម្លាប់"ជាមុនសិន ។ បើតាមវចនានុក្រមសម្តេចសង្ឃរាជជួនណាតភាគទីមួយនិងភាគទីពីរ ពាក្យ "ទំនៀម" មានថ្នាក់ពាក្យជានាម គឺសំដៅទៅលើបវេណី ធម្មតា សណ្តាប់ សណ្តាប់ធ្នាប់ ទម្លាប់ បែបបទ ក្នុងន័យថាធ្វើតាមទំនៀម ។ រីឯ "ទម្លាប់" មានថ្នាក់ពាក្យជាកិរិយា គឺធ្វើឱ្យធ្លាប់ ឱ្យថ្នឹក ទម្លាប់ខ្លួន ទម្លាប់ចិត្ត ទម្លាប់ដៃ ទម្លាប់មាត់ជាដើម ។ បើថ្នាក់ពាក្យជានាមវិញមានន័យថាការដែលធ្លាប់លំអាន ដែលធ្លាប់តែមានមក ដូចជាទម្លាប់ចាស់បុរាណធ្វើតាមទម្លាប់ពីមុនមក មានទម្លាប់ពីនាយមកជាដើម [(១)] ។ ដូចនេះ កន្សោមពាក្យ "ទំនៀមទម្លាប់"មានន័យថាលំអាន ទំនៀមទម្លាប់ បវេណី ធម្មតា សណ្តាប់ សណ្តាប់ធ្នាប់ ទម្លាប់ បែបបទ ក្នុងន័យថាធ្វើឱ្យធ្លាប់ ឱ្យថ្នឹក ទម្លាប់ខ្លួន ទម្លាប់ចិត្ត ទម្លាប់ដៃ ទម្លាប់មាត់ជាដើម ។ បើថ្នាក់ពាក្យជានាមវិញមានន័យថាការដែលធ្លាប់ លំអានដែលធ្លាប់តែមានមក ដូចជាទម្លាប់ចាស់ពីបុរាណ ធ្វើតាមទម្លាប់ពីមុនមក មានទម្លាប់ពីនាយមកជាដើម ។

អ្នកនិពន្ធរឿងទុំទាវ បានលើកយកផ្នត់គំនិតសង្គម ដែលផ្សារភ្ជាប់ទៅនឹងទំនៀមទម្លាប់អភិរក្សនិយមមួយមកធ្វើជាប្រភពនៃទំនាស់របស់រឿងនោះគឺផ្នត់គំនិត "នំមិនធំជាងនាឡិ" ។ បើផ្អែកតាមរឿងនេះ យើងអាចសន្និដ្ឋានបានថា នៅសម័យលង្វែកកូនប្រុសស្រីគ្មានសិទ្ធិក្នុងការជ្រើសរើសគូស្រករទេ ។ យើងអាចពិចារណាឱ្យស៊ីជម្រៅជាងនេះទៅលើប្រពៃណីជ្រើសរើសគូស្រកររបស់យុវជននាសម័យលង្វែក ព្រោះវាបានជ្រួតជ្រាបចូលទៅក្នុងសង្គមខ្មែរនាសម័យនោះទៅហើយ ។ យ៉ាងណាមិញ ចំពោះម្តាយទាវនិងអរជួនគឺជាលក្ខណៈតួអង្គនិមិត្តរូបដែលតំណាងឱ្យមាតាបិតាខ្មែរស្តែងពីការប្រកាន់

(១) វចនានុក្រមសម្តេចសង្ឃរាជជួនណាតភាគ ១និងភាគ ២

ទំនៀមទម្លាប់ខាងលើនេះ។ ដោយហេតុថា ឪពុកម្តាយខ្មែរបានចាត់ទុកការទុកដាក់កូនថៅឱ្យមានគួស្រករថា ជាភារកិច្ចដ៏ចម្បងមួយរបស់ខ្លួន ទោះបីការសម្រេចចិត្តនោះមិនសមស្របតាមឆន្ទៈកូនយ៉ាងណាក៏ដោយ។ ដូចករណី ម្តាយទាវក៏បានធ្វើការសម្រេចចិត្តលើកទាវឱ្យទៅម៉ឺនងួនដែលនាងមិនស្រឡាញ់ ហើយគំរាមថា "មិនដែលសោះឡើយទាវអើយនំច្រឡើសបើសធំម្តេចជាងនាឡិ កូនគោកៀចកាចដោយព្រៃវាលរោលរាលឈឺខ្លួនជួនដល់ស្លាប់"។ អ្វីៗម្តាយជាអ្នកសម្រេច មេគ្រួសារជាអ្នកកំណត់ កូន ឬអ្នកក្រោមបង្គាប់គ្មានសិទ្ធិសម្រេចឡើយ។ ទំនាស់នេះជាសំពាធខាងផ្លូវចិត្តដែលនាំទាវផ្លាប់តែទន់ភ្លន់សុភាពស្តាប់តាមបង្គាប់ម្តាយ តែពេលនេះនាងបែរជាហ៊ានជំទាស់ម្តាយដោយចេញមុខផ្ទាល់ថា "ថាបើម៉ែព្រមលួមនឹងគេ កូនម៉ែទំនេរមានប្រុសស្រីលើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្លឹងខ្ញុំ"។ ចំពោះប្រការនេះ កូនប្រុស ឬកូនស្រីនិងម្តាយឪពុកតែងមានការមិនចុះសម្រុងគ្នា រហូតឈានទៅជាសោកនាដ្យកម្មគួរឱ្យរន្ធត់ ជួនកាលទៀត សង្គមទាំងមូលបានដាក់ទណ្ឌកម្មខាងផ្លូវចិត្ត ទៅលើយុវជនដែលជំនះប្រឆាំងនឹងការសម្រេចចិត្តរបស់ម្តាយឪពុកថែមទៀត។ ជាក់ស្តែងប្តីប្រពន្ធណាដែលរស់នៅជាមួយគ្នាដោយឥតខាន់ស្លាពុំបានរៀបការត្រឹមត្រូវ ពួកគេគ្មានសិទ្ធិចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍អ្នកដទៃទៀតផង។ ជាពិសេសគេមិនអនុញ្ញាតឱ្យធ្វើជាអ្នកកំដរសាមីខ្លួនប្រុសស្រី ជាអ្នកបង្ហិលពពិល ឬជាអ្នកកាន់ជំនួនបណ្ណាការទេ ហើយថែមទាំងត្រូវបាត់បង់កិត្តិយស ជាភ្ញៀវក្នុងពិធីមង្គលការនោះថែមទៀត។

ជាមួយនឹងប្រពៃណីទំនៀមទម្លាប់ ក្នុងស្មារដៃខាងលើនេះ នៅសម័យលង្វែកគេឃើញថាខ្មែរសម័យនោះ តែងតម្រូវឱ្យកូនស្រីពេញវ័យត្រូវចូលម្លប់ នេះជាពិធីសម្រាប់នារីគ្រប់ការ។ តាមពិតទំនៀមទម្លាប់ចូលម្លប់នេះមានតាំងពីយូរលង់ណាស់មកហើយក្នុងសង្គមខ្មែរ តែពុំមានឯកសារណាបញ្ជាក់ប្រាប់ថា សង្គមខ្មែរយើងបានអនុវត្តការចូលម្លប់នេះពីពេលណាមកទេ។ លុះមកដល់សម័យលង្វែកសតវត្សទី ដប់ប្រាំមួយ ទើបគេឃើញមានភស្តុតាងខ្លះៗ ដែលបញ្ជាក់ពីការចូលម្លប់នេះតាមរយៈតួអង្គនាងទាវក្នុងរឿងទុំទាវ។ ពិធីនេះបានទទួលការនិយមពីសង្គមខ្មែររហូតដល់រជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស (ប្រហែលរវាង គ.ស. ១៩៣០ដល់ ១៩៤០) ទើបបានសាបរលាបជាបណ្តើរៗទៅតាមពេលវេលានៃការរីកចម្រើនវិទ្យាសាស្ត្រ និងលក្ខខណ្ឌចាំបាច់ផ្សេងៗទៀតនៃសង្គម[២]។ ក្នុងពិធី គេតម្រូវឱ្យនារីដែលពេញវ័យត្រូវរស់នៅក្នុងបន្ទប់មានការកាត់ផ្តួងសក់[៣] រៀនវិជ្ជាមេផ្ទះ និងរបៀបប្រាស្រ័យទាក់ទង ដែលចាត់ទុកជាការត្រៀមខ្លួនឈានចូលទៅក្នុងនាក

(២)អរិយធម៌ខ្មែរ (វប្បធម៌និងសង្គមធម៌សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) លោក សួ មុយយៀង លោក ជា ឈិន

(៣)សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី ១០ ឆ្នាំ ១៩៨៨

ជីវិត។ "ចាំទៅដល់ផ្ទះប្រាប់ទាវគ្រប់ ទាវនៅក្នុងម្លប់សមស្រណោះ នាងជាម្តាយទាវមានរបស់ កូន ស្រស់រូបស្រេចដាច់ស្រីផង"។

ក្នុងដំណើរឿងនេះ បានបញ្ជាក់ទៀតថា អរជូនបានចូលស្តីដណ្តឹងនាងទាវឱ្យម៉ឺនងួនជាកូន ដោយមានអ្នកផ្លូវចៅមហា និងមានមេបាដោយមានអំណោយភស្តុភារទៅជាមួយផង។ ចំពោះ ប្រពៃណីនេះ ជាវប្បធម៌របស់ខ្មែរ ជាព្រលឹងជាតិខ្មែរដែលបានប្រកាន់ទុកកន្លងមក។ ពិធីមង្គលការជា ប្រពៃណីមួយ ដែលមានបញ្ញត្តិប្រហែលគ្នានឹងកាតព្វកិច្ចផង។ ប្រសិនបើ កំលោះក្រមុំណាបានប្រព្រឹត្ត សហាយស្មន់អន្ទកវនឹងគ្នា ប្រពៃណីខ្មែរបានចាត់ទុកថា ក្រមុំកំលោះនោះបានប្រព្រឹត្តកន្លងប្រពៃណី ខ្មែរ "ខុសមេបា" ហើយជាអ្នកគ្មានសិរីសួស្តី និងគ្មានកិត្តិយសឡើយ។ អ្នកមិនបានរៀបអាពាហ៍ ពិពាហ៍តាមប្រពៃណីខ្មែរ គេមិនឱ្យចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍អ្នកដទៃដូចជា ធ្វើជាមេបា អាចារ្យ មហា កាន់ថង់រងចូលរួមបង្ហិលពពិលជាដើមឡើយ។ កំហុសនេះមិនមានត្រឹមតែបុរសនារីនោះ ប៉ុណ្ណោះទេ គឺមានរហូតដល់កូនចៅទៀត។ បើមានកូនស្រី ឬចៅស្រីគេមិនហ៊ានចូលស្តីដណ្តឹងទេ។ បើមានកូនប្រុស ឬចៅប្រុសគេក៏មិនហ៊ានឱ្យកូនដែរពីព្រោះគេយល់ថាត្រកូលគ្មានខាន់ស្លាជាត្រកូល អបលក្ខណ៍។ បើក្រមុំកំលោះ បានរៀបអាពាហ៍ពិពាហ៍តាមសេចក្តីសម្រេចរបស់លោកមេបា គឺជា ត្រកូលមានខាន់ស្លា ជាត្រកូលឧត្តុង្គឧត្តម។ ដូចនេះ អាពាហ៍ពិពាហ៍មានសារៈសំខាន់ក្នុងជីវភាពនារី គ្រួសារ និងសង្គម[៤]។ យ៉ាងនេះហើយ ទើបសម័យលង្វែកគេឃើញអរជូនទោះបីជាមានបុណ្យសក្តិ ប៉ុនណាក៏ដោយ ក៏ត្រូវតែបំពេញកិច្ចនេះឱ្យបានត្រឹមត្រូវដែរ។ តួយ៉ាងក្នុងរឿងនេះបានបង្ហាញ ឱ្យឃើញថា "អធិប្បាយនិយាយខាងចែចូវ ជាអ្នកនាំផ្លូវតាមជូនតា ឱ្យទៅស្រដីខាងមេបា នាងទាវតើ ថាប្រការម្តេច។ ប្រពន្ធអរជូនជំនួនស្រាប់ ភ្ញុំគ្នាប្រញាប់រាន់ រំពេច យកសព្វភោជ្យផលថ្កល់និងវេច រៀបរួចស្រាប់ស្រេចត្រាច់ចរចេញ"។ មុនពេលរៀបការ គេត្រូវធ្វើពិធីចែចូវជាមុនសិន ដូចករណី អំណះអំណាងខាងលើនេះ អរជូនចាត់ឱ្យមានអ្នកចូលចែចូវ។ ចំពោះអ្នកចែចូវ ឪពុកម្តាយខាងប្រុស ជាអ្នករក ដោយមិនអភព្វគួ ទៅទាក់ទងខាងកូនស្រីជាមុន គឺត្រូវមើលថ្ងៃខែឆ្នាំធាតុនិងពង្សជាដើម។ ប្រសិនបើជាត្រូវគ្នាហើយ ទើបមានការចូលស្តីដណ្តឹងជាក្រោយ។ ក្នុងពិធីស្តីដណ្តឹងនេះ ដោយដឹងថា ខាងស្រីបើកផ្លូវឱ្យហើយ ខាងប្រុសត្រូវរៀបចំចូលស្តីដណ្តឹងតទៅទៀត។ មនុស្សមានភារៈចូលស្តី ដណ្តឹងគេហៅថា "ឈ្មោយ"[៥] ហើយអ្នកដែលតំណាងគ្រួសារខាងស្រីគេហៅថា "មេបា"។ ពិធីនេះ ប្រព្រឹត្តទៅត្រូវធ្វើបីលើក គឺលើកទីមួយមេបាខាងស្រីពុំទាន់សម្រេចអ្វីនៅឡើយទេ គ្រាន់តែឱ្យខ្លួនដើរ

(៤-៥)អរិយធម៌ខ្មែរ (វប្បធម៌និងសង្គមសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន)

លោក សូ មុយឃៀង លោក ទិត សៀង

ជណ្តើរឡើងចុះ។ លើកទីពីរមេបា គ្រាន់តែអនុញ្ញាតឱ្យពីងពាក់អាស្រ័យគ្នា ហើយលើកទីបីមេបាអនុញ្ញាតឱ្យនាមកូនប្រុសមកជាមួយនឹងមាតាបិតាញាតិសន្តាន ដើម្បីបង្ហាញរូបសម្បត្តិកូនប្រុសដល់មេបានិងញាតិសន្តានខាងកូនស្រី។ ពេលគ្រួសារ និងសាច់ញាតិពេញចិត្តលើសាមីខ្លួនទាំងសងខាង ហើយខាងស្រីក៏អនុញ្ញាតឱ្យរៀបចំស៊ីស្លាភ្ជាប់ពាក្យ។ រីឯពិធីមង្គលការវិញ ត្រូវប្រព្រឹត្តទៅនៅគេហដ្ឋានខាងស្រី ដូចករណីអរជួនក៏បានចាត់ឱ្យគេរៀបពិធីផ្សេងៗ ក្នុងនោះមានពិធីធ្វើធ្មេញជាដើមដូចជា "ចាត់រកអាចារ្យខ្មែរធ្វើធ្មេញ អាចារ្យមួយដេញថ្លៃជោគជា ឫក្សរួមខ្ចីយខ្ចល់តម្កល់ពារ រួបរួមមូលគ្នាជាយូរទៅ"។

សរុបសេចក្តីមក ក្នុងរឿងទុំទាវពិតជាបានផ្សារភ្ជាប់ទៅនឹងប្រពៃណីទំនៀមទម្លាប់ខ្មែរសម័យលង្វែកពិតៗ ដែលឆ្លុះបញ្ចាំងពីផ្នត់គំនិតខ្មែរតាំងពីបុរាណកាលមកម្ល៉េះ។ ប្រពៃណីនេះហើយ ដែលជាមូលដ្ឋានគ្រឹះក្នុងការលើកតម្លៃជាតិខ្មែរ អត្តសញ្ញាណជាតិខ្មែរ ខុសពីជាតិសាសន៍ដទៃ ក្នុងគំនិតអភិរក្សប្រកបទៅដោយអត្តិភាពនៃមរតករបស់ជាតិសាសន៍ខ្មែរដែលមានវប្បធម៌ដ៏យូរលង់ណាស់មកហើយនោះ។

ឆ្លងតាមការស្រាវជ្រាវខាងលើនេះ យើងឃើញថា គំនិតប្រធានបទបានឱ្យយើងស្វែងយល់ពីអត្ថន័យសំខាន់ៗ នៃពិធីផ្សេងៗដែលជាប្រពៃណីទំនៀមទម្លាប់ខ្មែរនាសម័យលង្វែកតាមរយៈអក្សរសិល្ប៍។ ការស្រាវជ្រាវនេះ ទោះបីនៅមានកម្រិតក៏ពិតមែន ប៉ុន្តែក៏មានសារប្រយោជន៍ចំពោះអ្នកសិក្សា អ្នកអានបន្ថែមទៀត នូវពុទ្ធិមួយកម្រិតទៀតនូវភាពសម្បូរបែបនៃមរតកវប្បធម៌ជាតិ។

ការស្រាវជ្រាវនេះ យោងតាមឯកសារពិគ្រោះ :

១. វចនានុក្រមសម្តេចសង្ឃរាជជួនណាត ភាគ ១ ភាគ ២ បោះពុម្ពលើកទី ៥ ដោយពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១១ គ.ស. ១៩៦៧។

២. អរិយធម៌ខ្មែរ (វប្បធម៌និងសង្គមធម៌សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) លោក សូ មុយយៀង លោក ទិត សៀង លោក ជា ឈិន គ.ស. ២០០៥។

៣. សិក្សាអត្ថបទទុំទាវ រាមកេរ្តិ៍ កម្មវិធីសិក្សាអក្សរសិល្ប៍ថ្នាក់ទី ១០ ឆ្នាំ ១៩៨៨។

៤. រឿងទុំទាវ ព្រះបទុមត្ថេរ សោម របស់ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥១៤។

៥. អរិយធម៌ខ្មែរ អ្នកស្រី ត្រឹង ងា គ.ស. ១៩៧៥។

៦. បទអត្ថាធិប្បាយរឿងទុំទាវ ក្រសួងអប់រំ បោះពុម្ពផ្សាយដោយគ្រឹះស្ថានបោះពុម្ព ឆ្នាំ ១៩៨៩។

លំហាត់

ចូរអ្នកធ្វើសំណេរស្រាវជ្រាវស្តីពី :

ក. ពិធីចូលម្ហប់

ខ. ពិធីចម្រើនអាយុ

គ. ពិធីបង្វិលពពិលក្នុងមង្គលការ

លំណែនាំ

- អ្នកចែកគ្នាជាក្រុមស្រាវជ្រាវ ក្រុមនីមួយៗមានចំនួនប្រាំនាក់ ហើយជ្រើសរើសប្រធានបទដែលអ្នកពេញចិត្ត មកធ្វើការស្រាវជ្រាវ ។
- ក្រុមនីមួយៗត្រូវប្រមូលឯកសារ (បណ្ណាល័យ កាសែត គេហទំព័រនានា ...) ។
- អនុវត្តតាមការណែនាំ និងគំរោងស្រាវជ្រាវ ។

កំណាព្យ



ជនជាតិខ្មែរ មានអាយុកាលរាប់ពាន់ឆ្នាំមកហើយ ដែលបានបន្សល់ទុកនូវកេរដំណែលវប្បធម៌ប្រកបទៅដោយអត្ថន័យ បង្កប់លក្ខណៈជាតិពិតៗ។ មិនតែប៉ុណ្ណោះ បុព្វកវីនិពន្ធយើងក៏បានរួមចំណែកយ៉ាងសកម្មក្នុងការថែរក្សាមរតកទាំងនោះ ព្រមទាំងបង្កើតស្នាដៃយ៉ាងច្រើនថែមទៀតជាពាក្យរាយ ជាពាក្យកាព្យស្របទៅតាមតថភាពនៃជីវិត ដែលជនជាតិខ្មែរធ្លាប់បានឆ្លងកាត់និងអនុវត្តកន្លងមក។

ជាមួយនោះកំណាព្យខ្មែរ ដែលមានអាយុកាលដំណាលនឹងមនុស្សខ្មែរ ក៏មានតួនាទីយ៉ាងសកម្មក្នុងការប្រលោមលួងលោមអារម្មណ៍របស់ខ្មែរ ប្រកបដោយអត្ថន័យអប់រំ បានប្រាកដចេញជារូបរាងឡើង។ កំណាព្យទាំងនោះមានលក្ខណៈពីរោះណែងណងល្ហុងល្ហាយ មានរូបារម្មណ៍យ៉ាងអាថិកំបាំង ហើយមានអត្ថន័យជ្រាលជ្រៅ ព្រមទាំងបង្កប់នូវតម្លៃអប់រំ សីលធម៌ សុជីវធម៌ របៀបរបបរស់នៅ ការរកទទួលទាន។ កូនខ្មែរបានយកគំរូនិងអនុវត្តតាមអ្វីដែលល្អជារៀងរហូតមក។

នៅក្នុងមេរៀននេះ អ្នកនឹងបានសិក្សាពីកាព្យរូបារម្មណ៍វិធី កំណាព្យបទទ្វេមាត្រ កំណាព្យការសុំសន្តោសប្រណី ប្រពៃណី អាពាហ៍ពិពាហ៍ខ្មែរ និងការតែងកំណាព្យ។



កាព្យរូបារម្មណ៍វិធី

១ . វិធីបំផ្លើស

វិធីបំផ្លើស មានលក្ខណៈពិសេសមួយ គឺកវី ឬអ្នកនិពន្ធប្រើពាក្យសំដីឱ្យលើសពីការពិត តែក្នុងគោលបំណងបង្ហាញសច្ចភាពណាមួយឱ្យមានកម្រិតខ្ពស់បំផុត ឬទាបបំផុតប៉ុណ្ណោះ។ ម្យ៉ាងទៀតជាសិល្បវិធីរបស់កវីក្នុងការទាក់ទាញអារម្មណ៍អ្នកអាន អ្នកស្តាប់ឱ្យមានការពិចារណាទៅលើបញ្ហាដែលខ្លួនចង់បង្ហាញ។

ឧទាហរណ៍ទី ១ : ក្នុងសង្គមថាស់ នគរថ្កើងណាស់ ថ្កើងថ្កានហួសពេក
ផ្ទះថ្មក៏ច្រើន លូតកប់ហួសមេឃ មានសប្បាយពេក
ក្រវែកទុក្ខក្តុក។

ពាក្យថា "ផ្ទះលូតកប់ហួសមេឃ" ជាពាក្យបំផ្លើស ពីព្រោះធម្មតាគ្មានអ្វីដែលលូតហួសមេឃនោះទេ តែកវីយកពាក្យនេះមកប្រើ ដើម្បីបង្ហាញឱ្យឃើញភាពខុសគ្នាខ្លាំងរវាងអ្នកមាននិងអ្នកក្រ។ អ្នកមាន មានផ្ទះរាប់ជាន់ រាប់មិនអស់ ឯអ្នកក្រកតែខ្ទមនៅគ្មាន។

ឧទាហរណ៍ទី ២ : អកទោចទួញយំ តាមដងព្រៃភ្នំ ឃើញភាពទារុណ
មនុស្សស្លាប់គរច្រើន កើនហួសបួកគុណ រុយមួសញាក់គ្រុន
ខ្លាចខ្មោចមនុស្សលង។

ពាក្យថា "រុយមួសញាក់គ្រុន ខ្លាចខ្មោចមនុស្សលង" ជាពាក្យបំផ្លើសរបស់កវី តែការបំផ្លើសនេះរឹតតែបញ្ជាក់ឱ្យឃើញច្បាស់នូវអំពើទារុណកម្ម កាប់សម្លាប់របស់បនប្រល័យពូជសាសន៍យ៉ាងសាហាវព្រៃផ្សៃបំផុត ធ្វើឱ្យស្លាប់ប្រជាជនខ្មែរច្រើនហួសប្រមាណ សូម្បីតែរុយមួសភ័យខ្លាចខ្មោចមនុស្សដែរ។

មើលដែនដីខ្មែរ



មេឃភ្លឺខ្មៅជិត ផ្គរលាន់ក្នុងចិត្ត រងំឥតសូរ
ស្ទឹងជន់ស្ងួតចែស ភ្នំប្រេះជាអូរ ទឹកភ្នែកជន់ជោរ
ហូរលិចភូមិឋាន។
បក្សីប្រែជើរ ម្រឹគប្រែហោះហើរ ត្រីលង់ស្លាប់ប្រាណ
ខ្មមក្លាយជាផ្ទះ វិនាសវិមាន យំសោកស្រែកឃ្លាន
ទួញថ្ងូរក្នុងចិត្ត។

ផ្កាវីកខុសកាល ទឹកសាចពេញវាល ស្មៅស្រពោនស្ងួត
ក្រួសថ្មក្រៀមក្រំ យំសោកអាណិត ត្រកួនព្រលឹត
លេងឫទ្ធិឡើងទ្រើង ។
វេស្សវ័ណអង់អាច អាងឫទ្ធិអំណាច ប្រឹងលើកតំកើង
ហ៊ឹងនិងគង្គក់ ពីភក់ចំបើង ឱ្យរុងរឿងថ្កើង
ឡើងស្មើចន្ទ្រា ។
ហ៊ឹងអរភ្លេចគិត ភ្ញាក់ទាំងងងឹត ឥតគិតពិចារ
លោតលេងភ្លើង ក្រហាមភ្លឺថ្លា ព្រាត់ប្រាសខ្លោចផ្សា
ទើបនឹកស្តាយក្រោយ ។
ស្រណោះផ្គរលាន់ ផ្គរស្រែករន្ថាន់ ប្រាប់ជាអំណោយ
ហ៊ឹងក្អាត់មិនស្តាប់ លុះស្លាប់ថ្ពោះឆ្អោយ បែរងាកមើលក្រោយ
កោះត្រើយហួសឆ្ងាយ ។
និងផ្តាំពពក ព្រះពាយពុំយក សំឡេងឆ្លងឆ្លើយ
ខំហែលទឹកភ្នែក យំស្រែកខ្វើយៗ ខ្លាចហើយរាងហើយ
ភ្លើងកលមាយា ។
ភ្លើងគឺចិត្តកាច នៃពាលកំណាច បនក្បត់ឫស្យា
មានពិសពើតស្អិត ជាងភ្លើងធម្មតា សុទ្ធធាតុហឹង្សា
ឆេះទាំងកាយចិត្ត ។
ស្រណោះភ្លៀងធ្លាក់ បែកញើសសស្រាក់ គេរេមើលងាយ
ទឹកញើសជន់ជោរ ដូចអូរប្រឡាយ ខំគាស់កកាយ
ក្រោមការបញ្ជា ។
ទឹកញើសហូរអស់ សាច់ឈាមស្រស់ៗ ស្រក់ពីអាត្មា
ស្រូវពេញវាលស្រែ ដំណាំផ្លែផ្កា ទ្រុឌទ្រោមរបូបា
បាត់ភាពសោភ័ណ ។ [...]

(ដកស្រង់ពីកំណាព្យមើលផែនដីខ្មែរ របស់លោក ជួន ម៉ែន ទំព័រទី ៩-១២)

២ . ទិពីពន្ធាន

វិធីនេះស្ថិតនៅត្រង់ការចេះនិយាយពង្វាងដោយប្រើកន្សោមពាក្យក្នុងការសម្គាល់បញ្ញត្តិណាមួយ។ កវីមិនប្រើពាក្យមួយម៉ាត់ចំតែម្តងក្នុងការសម្គាល់បញ្ញត្តិនោះទេ។

ឧទាហរណ៍ទី ១ : ពន្លឺរាជនីនៃរាត្រី ហាក់មានបេតីករុណាទាន
ស្រោចស្រង់មនុស្សសត្វដែលស្រេកឃ្លាន សេរីដែលមានគ្រប់រូបា។

"ពន្លឺរាជនីនៃរាត្រី" មានន័យថា "រស្មីស្តេចស្រីនៃពេលយប់" គឺកវីពោលសំដៅដល់ពន្លឺព្រះចន្ទ តែកវីមិនប្រើពាក្យចំថា ពន្លឺលោកខែ ឬពន្លឺព្រះចន្ទចំៗតែម្តងទេ លោកនិយាយពង្វាងថា "ពន្លឺរាជនីនៃរាត្រី" វិញ។

ឧទាហរណ៍ទី ២ : បិសាចក្អែកខ្មៅខ្លៅសាមាន្យ ចិត្តជួតិរច្ឆានខ្មៅចំបែង
សម្លាប់ជាតិខ្មែរគ្មានរអែង បំផ្លាញជាតិឯងទៅជាផេះ។

កវីបានយកពាក្យ "បិសាចក្អែកខ្មៅខ្លៅសាមាន្យ" ដើម្បីសម្គាល់ពួកបនប្រល័យពូជសាសន៍ខ្មែរក្រហម ដោយកវីមិនប្រើចំតែម្តងទេ។

អួននៅបង្គើយ

ព្រលឹងមាសអើយ អួននៅបង្គើយ តែឆ្ងាយសែនសល់
បងតែងស្វែងគោង ឈរឈោងមិនដល់ ចិត្តកាយខ្វាយខ្វល់
ហាក់បានហើយបាត់។
ព្រលឹងមាសអើយ ស្នេហ៍បងមិនស្បើយ រូបអួនរសាត់
ជាចន្ទតារា បុប្ផាផាយផាត់ ឬជារូបសត្វ
កិន្នរថ្មើមថ្លៃ។
ឬជាកញ្ញា លើសលប់លោកា ល្អដូចស្រមៃ
ស្រមោលតម្រែក ឃ្លានស្រេកយប់ថ្ងៃ បានហើយដោះដៃ
ដកហើយហុចវិញ។
ព្រលឹងមាសអើយ ឬអួនជាត្រើយ ចិត្តទោសទោម្ខេញ
ជោរ នាច ទៅមក រលករលេញ រលើមបំពេញ
សមុទ្រវិជ្ជា។

ព្រលឹងបងអើយ ចាប់ផុតចាប់ផើយ កោះត្រើយវេទនា
រលកអារម្មណ៍ ផ្សាយផ្សំដូចជា រូបរាងពុំងា
អន្ទោលតាមកាម ។

ន័យនេត្រស្រស់ស្រី បំភ្លឺលោកិយ ទឹកភ្នែករហាម
តែនៅញញឹម សង្ឃឹមដើរតាម រកស្នេហ៍ឃើញស្ទាម
សប្បាយកាយា ។

ព្រលឹងមាសអើយ ដៃអូនកៀកកើយ តឹងដូចតណ្ហា
អង្អែលឱបរឹត ឱ្យចិត្តសង្កា រកសុខឯណា
ក្នុងការរស់នៅ ។

ព្រលឹងមាសអើយ ស្នេហាគ្មានស្បើយ ឃ្លានគ្មានជម្រៅ
ឃ្លានលេងឃ្លានយំ ឃ្លានធំធេងទៅ ទំពាសំពៅ
អ្នកមានអ្នកក្រ ។

ឯណារូបសិទ្ធិ ឯណាការពិត ឯណាខ្មៅស
ខុសត្រូវកុហក អាក្រក់ឬល្អ ល្អដូចបវរ
ស្រស់ស្រីកល្យាណ ។

ព្រលឹងមាសអើយ កាលកើតស្លាប់ហើយ ចាស់ឥតស្រាកស្រាន្ត
តែអូននៅខ្ចី ប្រឹមប្រិយសុខសាន្ត ដូចចិត្តបងបាន
ពុំចេះចាស់ឡើយ ។

ស្លាប់ទៅនៅទៀត ស្លាប់មែនតែឆ្លៀត រកកោះរកត្រើយ
ហែលតាមស្រីស្រស់ ពុំអស់ពុំហើយ អូននៅបង្កើយ
ឯត្រើយសួគ៌ា ។

បានតាមលោភៈ បាត់តាមទោសៈ អន្ទោលតាមគ្នា
ចាំងដូចរស្មា អាត្មាជាប់ជា បងនិងពុំងា
ខ្លួនរកខ្លួនឯង ។

(ដកស្រង់ពីសៀវភៅ ចិត្តក្រមុំ របស់លោក កេង វ៉ាន់សាក់ ទំព័រទី ២៤-២៧)

៣ . វិធីត្រឡប់

វិធីត្រឡប់ គឺជាបដិរូបមួយបែបដែលស្ថិតនៅត្រង់ការប្រើពាក្យឆ្លុះគ្នា ហើយន័យសេចក្តីផ្សេងគ្នា ។

ឧទាហរណ៍ទី ១ : ធ្វើបុណ្យបានបុណ្យ ធ្វើបាបពីមុន បាបវិលមកសង
ស្តប់គេ គេស្តប់ មិនចប់សំណង ប្រសិនស្នេហ៍ស្នង
គេស្នេហ៍វិញដែរ ។

(ដកស្រង់ពីសៀវភៅ គុកកាមកិលេស របស់លោក កេង វ៉ាន់សាក់ ទំព័រទី ១៧)

ឧទាហរណ៍ទី ២ : ហួរគ្រប់តំបន់ មិនចេះបង្អន់ ស៊ីផ្ទះ ផ្ទះស៊ី
ភ័យខ្លាចខ្លះដែរ ប៉ុន្តែមមី ខំរស់វក់វី
ពុំដឹងខ្លួនឡើយ ។

(ដកស្រង់ពីសៀវភៅ គុកកាមកិលេស របស់លោក កេង វ៉ាន់សាក់ ទំព័រទី ៧២)

ឧទាហរណ៍ទី ៣ : ស្លាប់ពីកំណើត ស្លាប់ធំតាមកើត ស្លាប់កើតរចល់
ដេកភ្ញាក់ ភ្ញាក់ដេក តម្រេកខ្វាយខ្វល់ លុះបានស្តប់ស្តល់
ស្លាប់ទៅកើតវិញ ។

(ដកស្រង់ពីសៀវភៅ គុកកាមកិលេស របស់លោក កេង វ៉ាន់សាក់ ទំព័រទី ៨១)

ឧទាហរណ៍ទី ៤ : ផ្គរលាន់ក្លួងៗឆ្លងឆ្លើយគ្នា ចិត្តវែងវេទនាជាប្រក្រតី
ឱបខ្ទើយ ខ្ទើយឱបមិនស្រដី តែខ្ទើយមេត្រីយកអាសា ។

(ដកស្រង់ពីសៀវភៅ ចិត្តក្រមុំ របស់លោក កេង វ៉ាន់សាក់ ទំព័រទី ២)

លំហាត់

១. តើអត្ថបទកាព្យ "មើលផែនដីខ្មែរ" តែងជាបទអ្វី ? ចូរនិយាយពីធាតុសំខាន់ៗនៃបទនេះផង ។

២. ចូរសង្ខេបអត្ថបទកាព្យ "មើលផែនដីខ្មែរ" ។

៣. ចូរបង្ហាញរូបារម្មណ៍វិធីក្នុងកំណាព្យ "មើលផែនដីខ្មែរ" នេះ ។

៤. តើអត្ថបទកាព្យ "មើលផែនដីខ្មែរ" នេះនិយាយពីអ្វី ?

៥. ដូចម្តេចដែលហៅថា ចំណាប់ជួន ? ផ្ចួន ? រណ្តំ ? ចូរលើកឧទាហរណ៍ក្នុងអត្ថបទខាងលើមកបញ្ជាក់ផង ។

៦. ចូរសង្ខេបអត្ថបទកាព្យខាងលើជាពាក្យរាយ ។

៧. តើអត្ថបទកាព្យនេះនិយាយពីអ្វី ?

កំណាព្យបទទ្វេមាត្រ

កំណាព្យបទទ្វេមាត្រ គឺជាបទដែលកវីប្រើកាព្យមាត្រពីរ។ មួយជាកាព្យមាត្របទមូលដ្ឋាន ហើយបន្ថែមកាព្យថ្មីមួយទៀតលើបទមូលដ្ឋានទាំងអស់នោះ។

១ . បទនាគបរិព័ន្ធ


បទនាគបរិព័ន្ធ គឺពាក្យកាព្យដែលកវីយកពាក្យបីព្យាង្គនៅខាងចុងឃ្លាដើមនិងពាក្យបីព្យាង្គនៅឃ្លាដើមបន្ទាប់គឺ

- ពីរព្យាង្គជួនគ្នា
- មួយព្យាង្គចុងរណ្តំគ្នា
- ព្យាង្គទី ២ ជួននឹងព្យាង្គទី ៣

បទនាគបរិព័ន្ធ ពាក្យ ៨: បទនេះមានរង្វាស់កាព្យ ចំណាប់ជួន ចង្វាក់ ដូចបទពាក្យ ៨ធម្មតាដែរ តែប្លែកគ្នាត្រង់ ៖

- ព្យ ៦-១-១ ═ ព្យ ១-២-១
- ព្យ ៧-១-១ ═ ព្យ ២-២-១
- ព្យ ៨-១-១ ├─ ព្យ ៣-២-១
- ព្យ ៦-២-១ ═ ព្យ ១-៣-១
- ព្យ ៧-២-១ ═ ព្យ ២-៣-១
- ព្យ ៨-២-១ ├─ ព្យ ៣-២-១
- ព្យ ៦-៥-១ ═ ព្យ ១-៤-១
- ព្យ ៧-៣-១ ═ ព្យ ២-៤-១
- ព្យ ៨-៣-១ ├─ ព្យ ៣-៤-១ ។

គំនូសតាង



ឧទាហរណ៍ :

មេឃមីរទូទឹមទាបស្រទំទន់ ស្រទំទៅគយគន់ពពកដាស
ពពកដុំដូចភ្នំខៀវខាប់ក្រាស់ ខៀវខាប់ក្រៃផ្លែប្រាសប្រែលិចបាត់ ។
ប្រែលិចបែបក្រហមអមលាយលឿង អមលាយលយប្រឿងៗមេឃស្រងាត់
មេឃស្រងូតឆ្នូតវែងតែងរសាត់ តែងរសាយក្លាយបាត់គួរស្រណោះ ។

(អៀង សាយ មេកាព្យ ទំព័រទី ២៥)

២ . បទយតិភង្គ

បទយតិភង្គនេះ គឺជាបទនានាដែលកវីបានយកព្យាង្គចុងទៅភ្ជាប់នឹងព្យាង្គដើមនៃឃ្លាបន្ទាប់ដោយប្រើសញ្ញាយតិភង្គ ។ ទំនាក់ទំនងបែបនេះត្រូវធ្វើឱ្យបានគ្រប់ឃ្លាទាំងអស់នៅក្នុងឈុះនីមួយៗ ។ វិធីបែបនេះ យើងឃើញមានច្រើនបំផុតនៅក្នុងរឿង កាកី ដែលជាស្នាដៃព្រះអង្គឌួង ។ កវីយកបទនេះមកប្រើ ដើម្បីពណ៌នាពីចលនា មនោសញ្ចេតនា ដែលមានភាពរអាក់រអួល ឬពីក្បាច់ចម្លាក់លៀនលិប ដើម្បីធ្វើឱ្យមានចលនារស់រវើកឡើង ។

ឧទាហរណ៍ទី ១ :

ទាំងបីជាប់ច- ម្លាក់លាយលេចលំ- អរអស់ត្រួយត្រ- បកបទុមទែង
ចិញ្ចែងមានមួ- លីលើលាយល ជជាយរ្ងាយរ្ងាក់ ។

(ដកស្រង់ពីសៀវភៅ កាកី របស់ព្រះអង្គឌួង ទំព័រទី ៣)

ឧទាហរណ៍ទី ២ :

កកៀកកាន់ថ- នានៃបានប- ខ្ញុំទីមមូលមេ- ថុនធម្មត្រេកត្រ-
អាលក៏ស្ងិទ្ធស្នេ- ហាហើយអស់ង- មោះមានសង្កា ។

(ដកស្រង់ពីសៀវភៅ កាកី របស់ព្រះអង្គឌួង ទំព័រទី ៣៩)

ឧទាហរណ៍ទី ៣ :

សហាយនិរណាយថាកចំ- បែងបែកលាកលំ- នៅនេះទាល់ទៅបាត់បង់ ។


(ដកស្រង់ពីសៀវភៅ កាកី របស់ព្រះអង្គឌួង ទំព័រទី ៣)

៣ . បទដាប់ទង

បទជាប់ទង គឺជាបទពាក្យ ៩ ធម្មតាគ្រាន់តែបន្ថែម ៖

- ព្យ ៣-១-១ ⟹ ព្យ ៤-១-១
- ព្យ ៦-១-១ ⟹ ព្យ ៧-២-១

គំនួសតាង



ឧទាហរណ៍ :

ស្មៅចិញ្ចៀន	រៀនដុះផុង	ក្នុងវារី
នៅសល់ពី	ទីទឹកស្មាន	បានពីរធ្នាប់
ខ្យល់បក់បោក	ខោកឥតស្រាក	ងាករេញាប់
នៅមិនងាប់	ជាប់រហូត	លូតឡើងបាន ។
ជាតិបណ្ឌិត	ពិតពីរោះ	ឈ្មោះឥតអាក់
មានឧបសគ្គ	ស្មាក់រារាំង	ទាំងប៉ុន្មាន
ប្រឹងរុញច្រាន	ឈានឥតខ្សោយ	ដោយក្លាហាន
ត្រាតែប្រាណ	បានរួចទុក្ខ	សុខដូចស្មៅ ។

(ព្រះឥន្ទមុនី សេក នាង)

អ៊ា-ចាន់-ត្រោ

- ទករលឹក ស៊ឹករន្ឋែន សែនស្រមៃ
  អា-លេក-ប៉ៃ ដៃស្រម៉ែល ដែលស្រណោះ
  ម៉ែក-គួរ-ប៊ិន មិនគួរបាត់ ស្ងាត់ក្រៀមក្រោះ
  នឹកឃើញអស់-ណោះដោយស្មឹក នឹកកន្លង ។
- អែ-ដួង-ខោ ង៉ោពេញបិះ ជះរស្មី
  សែនបេតី ក្តីស្នេហ៍ស្និទ្ធ បិទស្នេហ៍-ស្នង
  តាន់ដួងចែ បែមិនស្និទ្ធ ចិត្តមួម៉ង
  បែ-សែន-ស្នង បងសែនស្និទ្ធ ចិត្តចន្ទ្រផ្លា ។
- អ៊ា-ចាន់-ត្រោ ឱដួងខែ ឯមេឃា
  រៀមកំព្រា ស៊ា-រ-ង៉ែន សែនទុក្ខា
  ប្រើ-សិន-ប ប្រសិនបាន ប្រាណជីវ៉ា
  ទាបកាយា ប្តា-វ៉ា-ចូ ប្តូរយោបល់ ។
- ប្រួន-សិន-ណ ប្រសិនអ្នក ជាក់ជាស្មោះ
  ពៅស្រណោះ ប៉ោះ-ស្រ-និត គិតសល់វ៉ែល
  រា-ធា-នៀម មៀម-ឱ្យ-គ្រិន-មិនឱ្យខ្វល់
  កែវកុំឆ្ងល់-គាល់ពុំឆ្ងាយ កាយចិត្តទេ ។


(ជ័យ ចាប ឱដ្ឋស្រុកខ្មែរ ទំព័រទី ៩)

លំហាត់

១. ចូរអ្នកតែងកំណាព្យបទទ្វេមាត្រ ដោយបទនីមួយៗឱ្យបានពីរៗវគ្គ គឺបទនាគបរិព័ទ្ធពាក្យ ៨ , បទយតិភង្គពាក្យ ៨ , បទជាប់ទងពាក្យ ៩ ។

២. ចូរអ្នកស្រាវជ្រាវរកកំណាព្យបទទ្វេមាត្រ បទផ្សេងៗទៀតឱ្យបាន ៣បទ ដោយបង្ហាញពីកាព្យមាត្រ ចំណាប់ជួន ផ្ទួន រណ្តំ របស់បទទាំងនោះផង ។

ការសុំសន្តោសប្រណី



ក. សិក្សាពាក្យគន្លឹះ

- ចម (ន ឬគុ) : កំពូល ដែលជាធំផ្តាច់ ដែលជាចម្បងលើសលែង ។
- ចក្រពត្តិ (ន) : បរមក្សត្រដែលមានបុណ្យអំណាចដ៏ពន្លឹក មានចក្រកើតសម្រាប់បុណ្យ ។
- ល្អងធូលី (ព្រះបាទ)ពាក្យសម្រាប់និយាយក្រាបបង្គំទូលក្សត្រីយ៍ទ្រង់រាជ្យ ដោយបន្ទាបខ្លួនអ្នកនិយាយហាក់ដូចជាយកសិរសាទៅក្រាបក្រោមល្អងធូលីដែលជាប់នៅព្រះបាទ ។
- ទណ្ឌកម្ម (ន) : ការធ្វើទោសផ្តាលតាមដំណើរធ្វើខុសនឹងវិន័យបញ្ញត្តិ ។
- ពន្ធ (ន) : សួយ អាករដែលប្រជានិករត្រូវបង់តាមកំណត់ ។ ពន្ធដារ : ពន្ធគ្រប់មុខ ។
- គយ (ន) : អាករព្រះរាជធានីដែលហូតយកពីសារពើទំនិញដែលនាំចូលទៅមក ។
- ដំបារមាស (ន) : ផ្ទាំងមាស ។
- ឱង្ការ (ន) : ពាក្យប្រើជំនួសព្រះបរមនាមនៃព្រះមហាក្សត្រថា "ព្រះរាជឱង្ការ"សំដៅសេចក្តីថា "ព្រះរាជា ឬព្រះករុណាជាអម្ចាស់ជីវិតលើតួង" ។
- សួយ (ន) : អាករ មុខអាករ ពន្ធខ្លួន ពន្ធដែលត្រូវហូតយកក្នុងទីតំបន់មួយៗ មុខគយ មុខភាស៊ី ។ "សួយសារអាករ" អាករដែលនាំឡើងមានសំបុត្រជាផ្លូវរាជការអមផង ។

ខ. អភិវឌ្ឍន៍បំណិន

ពេលអានអត្ថបទកាព្យខាងក្រោមនេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងនឹងការសង្ខេបអត្ថបទកាព្យឱ្យទៅជាពាក្យរាយ តួអង្គ ធាតុសំខាន់ៗនៃកំណាព្យ និងតម្លៃអប់រំនៃអត្ថបទ ។

គ. អត្ថបទ

ស្តេចសៀមព្រះនាមសុរិយាបានលើកទ័ពចូលមកឈ្លានពានទឹកដីខ្មែរដោយយកលេសថាមកទទួលព្រះនាងមហាយិកាដែលតេជោដំឱនាំយកមកពីប្រទេសសៀមកាលគ្រាមុន ។ វេលានោះព្រះរាជាខ្មែរព្រះនាមបទុមសូរ្យវង្សបានបញ្ជាឱ្យតេជោដំឱនចេញច្បាំងតទល់ ។ តេជោដំឱនជាមេទ័ពល្បីល្បាញរបស់ប្រទេសខ្មែរនាសម័យនោះបានត្រិះរិះដោយល្បិចកលល្អិតល្អន់ដើម្បីយកជ័យជំនះលើសត្រូវ ។ តេជោដំឱនក៏បានប្រកាសសង្គ្រាមដោយមានការវាយប្រយុទ្ធគ្នាជាបុគ្គល គឺតេជោដំឱននិងព្រះចៅសុរិយា ។ តេជោដំឱនបានទទួលជ័យជំនះ រួចចាប់ស្តេចសុរិយាទុកជាឈ្លើយសឹក ។ ព្រះវាំងណាជាបិតាព្រះនាងមហាយិកានិងជាឧបរាជរបស់នគរសៀមទ្រង់យាងមកប្រទេសខ្មែរដើម្បីសុំការលើកលែងទោសស្តេចសុរិយាពីព្រះមហាក្សត្រខ្មែរ ។



[...]សូមក្រាបទូលបង្គំមួលពីយើងខ្ញុំ ចំពោះចំព្រះបទុមចមភារា
ចមភារាជបូរីរម្យកម្ពុជា ជាមហៃមហិន្ទ្រធរនរោត្តម ។
ចក្រពត្តិត្រាធិរាជអាណាចក្រ មកុដក្លាវធរារៈបុរីរម្យ
ខ្ញុំវាំងណារាជវង្សាថ្វាយបង្គំ សូមជ្រាបចំក្នុងព្រះទ័យព្រះទ្រង់សក្តិ ។
សេចក្តីរៀបដោយសុភាពពីយើងខ្ញុំ ក្រាបបង្គំល្អងធូលីរឿងធុរៈ
ថៅសុរិយាក្លារិទ្ធីហើយមកធ្លាក់ មកទិនទាក់នៅក្នុងទោសនៃទណ្ឌកម្ម ។
អស់យើងខ្ញុំនឹងបណ្តោយក៏ពុំបាន ហាក់ដូចប្រាណអ្នករាជវង្សមើលចំណាំ
ហើយអាណាពេញអាណិតឱរាវុំ មានបណ្តាំជាបន្តិចទៅខ្ញុំផង ។
សូមទានទោសព្រះអង្គប្រោសក្នុងគ្រានេះ សូមទានរិះទ្រង់ករុណាបានជាឆ្គង
សូមចុះចូលសូមចុះចាញ់ពេញគន្លង សូមរ៉ាប់រងសូមទទួលជាកលនី ។
ទាំងនគរទាំងទឹកដីព្រៃព្រឹក្សា ទាំងពន្ធដារទាំងរាជការគយអ្វីៗ
សូមប្រគបសូមប្រគល់គ្រប់ទិសទី សូមភូមីស្តេចអត់ទោសប្រោសប្រណី ។
សូមនាំសារដំបារមាសថ្វាយព្រះអង្គ សូមសូរិវង្សថៅសូរិយាវិលបូរី

ទោសខុសនោះអនុគ្រោះព្រះចក្រី សូមអភ័យលើកថាកចោលដោយមេត្តា ។
ឯព្យាបាទធ្វើលំអិតផ្សារពោធិ៍សាត់ និងចែងចាត់ជាសំណងសងក្សត្រា
ខេត្តចាន់បូណ៌នោះថ្វាយមកព្រះចក្រា តាំងរាជការថៅហ្វាយស្រុកខ្មែរត្រួតចុះ ។
ក្រាបទូលថ្វាយទ្រព្យប៉ុន្មានតាមបញ្ជី សូមភូមីស្តេចទទួលដោយស្រួលស្រុះ
យើងលើកថ្វាយមកសម្តេចទ្រង់យស ដោយស្ម័គ្រស្មោះកុំរង្កៀសព្រះទ័យា ។
ឯសួយសារដំបារមាសតើប៉ុន្មាន សូមក្សត្រក្សាន្តតាំងជាច្បាប់សន្យាគ្នា
និងនាំថ្វាយតាមសញ្ញាព្រះរាជា លួមធានារ៉ាប់រងបានមិនធ្ងន់ពេក ។
ចប់សំបុត្រផុតសេចក្តីតែប៉ុណ្ណេះ ព្រះអង្គរិះក្នុងព្រះទ័យហើយទ្រង់ត្រេក
មានឱង្ការតម្រាស់ថាយើងសង្កេត អាណិតពេកនឹងបន្ទូលក្រុមវាំងណា ។
និយាយមកពេញហៅត្រូវផ្លូវសេចក្តី ព្រះចក្រីឱ្យអញ្ជើញថៅសូរិយា
ស្តេចមកដល់ហើយគង់នៅលើអាស្ន ឆ្វេងក្សត្រាគំនាប់គ្នាតាមសណ្តាប់ ។
ព្រះបទុមសូរិវង្សពង្សចក្រី បន្ទូលខ្ចីបណ្តោយន័យសម្តែងប្រាប់
ថាព្រះបងគ្រានេះហោងមានសារច្បាប់ ពីអណ្តាប់ញាតិវង្សាក្រុំវាំងណា ។
សូមព្រះអង្គទៀងទតមើលសេចក្តីចុះ ត្រូវឬខុសពីព្រះទ័យព្រះជេដ្ឋា
មានព្រះសង្ឃទាំងបួនអង្គគង់ប្រសិទ្ធីយ៉ា ខុសត្រង់ណាសូមលុបចោលតាមព្រះទ័យ ។
បើត្រូវហើយសូមឡាយព្រះហស្តលេខា ហើយក្សត្រាក្សាន្តស្បថស្បានតាមវិន័យ
ឯខាងខ្ញុំនោះកុំឱ្យព្រះអង្គភ័យ នឹងលកលៃបទយ៉ាងណាចេះតែបាន ។
ឯព្រះថៅព្រះចមជាតិអង្គចុល្លចក្រ ឈ្បៀងព្រះភក្ត្រស្តេចទៀងទតន័យសារសាន
ចប់ទាំងមូលហើយបន្ទូលតាមលំអាន ពាក្យប៉ុន្មានខ្ញុំក៏ព្រមតាមទាំងអស់ ។
ហើយព្រះអង្គទ្រង់ចុះហត្ថប្រថាប់ត្រា ក្នុងសញ្ញាព្រមចុះចូលឥតចន្លោះ
រួចស្បថស្បានជាឡាក់ថានពិតចំពោះ មិនពីរុះមិនប្រែប្រួលជាសត្រូវ ។
រួចវិលទៅឯប្រាសាទទីអាស្រ័យ ជួបក្សត្រថ្លៃពីស្រុកសៀមទាំងអស់កូវ
ព្រមមន្ត្រីមកពីនាយច្រើនខ្នួលខ្នៅ គាល់ព្រះថៅព្រះចមពង្សដោយសាទរ ។
ឯព្រះបុទុមបរមរាជអាណាចក្រ ព្រះអង្គដាក់ឱ្យជំនុំពីនគរ
សៀមចំណុះចុះចាញ់នេះគិតរិះរក៍ សួយអាករតើគិតយកប្រការណា ។
ពេញបន្ទោកខុសពីថោកពេកកន្លង កុំបីប៉ងដល់កាសប្រាក់ជាសួយសារ
យើងបង្គាប់បង្ហន់ឆាប់ព្រះចេស្តា ឱ្យវាំងណានាំមកថ្វាយរាល់រដូវ ។

ទីប្រឹក្សាឱនក្រាបទូលព្រះចមពង្ស ថាសូមទ្រង់ដាក់សួយសារនោះឯងកូវ
ងៀតកន្ធរនិងជាលទឹកជាតម្រូវ មួយរយកូវហែមកថ្វាយព្រះចក្រា ។
ងៀតកន្ធរមួយរយជាលនោះជាក់ច្បាស់ ឱ្យពលព្រះយកទៅស៊ីតាមចិន្តា
ឯទឹកជាលទាំងមួយរយថ្វាយក្សត្រា លាងបាទាជាជម្រះសោះមន្ទិល ។
ស្តេចទ្រង់ស្តាប់សព្ទជំនុំកងសេនា ត្រូវចិន្តាអង្គសម្តេចព្រះទ្រង់សីល
ឱ្យតែងសារសព្ទសញ្ញាតតបវិល សោះមន្ទិលជាបន្ទាត់កត់សញ្ញា ។
ព្រះឱង្ការថ្លាពិសេសព្រះបុទុម ជាបរមចមបូរីរាជខេមរា
ថ្វាយព្រះចៅព្រះចោមជាតិវង្សសុរិយា និងវាំងណារាជវង្សាផងទាំងឡាយ ។
យើងព្រមព្រៀងន័យទីទៀងកិច្ចសញ្ញា ដាក់ពន្ធដារចំពោះលើបុរីអាយ
ទឹកមួយរយជាលជាតិជាក់ដាក់ខ្ចល់ខ្ចាយ ហើយឱ្យថ្វាយងៀតកន្ធរយជាលផង ។
ឱ្យវាំងណានាំទៅថ្វាយរាល់រដូវ បើមិនទៅព្រះអង្គឯងតាមបំណង
មហេសីជួសក៏សឹងបានឥតសៅហ្មង កិច្ចនេះហោងចង់ឱ្យជួបនឹងយីកា ។
សោះរលឹកនឹកអាល័យមកក្រៃពេក ដោយតម្រេកបានជួនជួបព្រះភក្ត្រា
ហេតុនេះស្តេចទ្រង់សម្រេចកិច្ចសញ្ញា ឱ្យវាំងណាឬមហេសីនាំសួយថ្វាយ ។
ខេត្តចន្ទបូណ៌ព្រមទទួលជាសំណង ចាត់មេកងនាំទាហានបីរយប្លាយ
ទៅត្រួតត្រាកិច្ចរាជការផងទាំងឡាយ មានថៅហ្វាយខេត្តមួយនាក់ដាក់ងារថា ។ ...

(ដកស្រង់ និងកែសម្រួលពីរឿងតេជោជំនិនរបស់លោកតាមាស ទំព័រ ២៥០-២៥៣)

សំណួរ

១. តើអត្ថបទខាងលើដកស្រង់ពីរឿងអ្វី ? អ្នកនិពន្ធឈ្មោះដូចម្តេច ?
២. ចូរសង្ខេបអត្ថបទកាព្យខាងលើឱ្យទៅជាពាក្យរាយ ។
៣. ចូរស្រង់ឈ្មោះតួអង្គក្នុងអត្ថបទដកស្រង់ខាងលើដោយប្រាប់មុខងារ និងឋានានុក្រមផង ។
៤. តើសៀមបានសារភាពដូចម្តេចខ្លះ ? ហើយសន្យាដូចម្តេចខ្លះដែរចំពោះមុខព្រះរាជាខ្មែរ ?
៥. តើអត្ថបទខាងលើបានបង្ហាញពីអំណាចមហាក្សត្រខ្មែរបែបណាខ្លះ ?
៦. តើអត្ថបទខាងលើសរសេរជាបទអ្វី ? ចូរបង្ហាញធាតុសំខាន់ៗនៃបទកំណាព្យនេះ ។

ប្រពៃណីអាពាហ៍ពិពាហ៍របស់ខ្មែរ



ក. សិក្សាពាក្យគន្លឹះ

- អាពាហ៍ពិពាហ៍ (ន) : មង្គលការគូប្រុសស្រីដែលនាំមកហើយត្រឡប់ទៅវិញ ។ ប៉ុន្តែតាមប្រពៃណីខ្មែរ គេនាំកូនប្រុសមកកាន់លំនៅកូនស្រីមុន គឺអាវាហមង្គល ហើយនាំកូនស្រីទៅរោងកូនប្រុសវិញ គឺវិវាហមង្គល ។ សង្គមខ្មែរបច្ចុប្បន្នគេនិយមធ្វើត្រឹមតែអាវាហមង្គល ប៉ុណ្ណោះ ។
- ចែចូវ (កិ) : នាំសំដីទៅមក ។
- អភ័ព្វ (គុ) : ដែលមិនគួរ ពុំគួរដល់កិច្ចការ ដែលពុំអាច ដែលឥតសំណាងល្អ មានសំណាងតិច ដែលឃ្លាងចាកប្រយោជន៍ ឬឃ្លាងចាកមគ្គផល ។
- មេអណ្តើក (ន) : អ្នកនាំការឱ្យបុរសស្ត្រី គឺអ្នកដែលនាំការចុះឡើងពីប្រុសទៅស្រី ដើម្បីឱ្យបានគ្នាជាប្តីប្រពន្ធ (ឱ្យបានគ្នាជាសហាយស្មន់) ។
- ដណ្តឹង (កិ) : សាកសួរឱ្យដឹង ។ ធ្វើរបៀបចងព័ន្ធ ចងស្ពានមេត្រីក្នុងការផ្សំកូនប្រុសស្រី មុនរៀបមង្គលការ ។

- មេបា (ន) : មេនិងបា ។ ដែលជាប្រធានក្នុងដំណើរនិយាយកិច្ចការផ្សេងៗជាមួយនឹងអ្នកផ្លូវចៅមហាក្នុងមង្គលការ ។ ខ្មោចចំបួរជួរ (ឧទាហរណ៍ ខ្មោចមេបា មេបាចាស់ទុំ) ។
- ពិគ្រោះ (កិ) : ប្រឹក្សាគ្នា គិតគ្នា សាកសួរគ្នាឱ្យអស់អាថ៌សេចក្តី ។
- ថង់រង (ន) : ប្រដាប់មានសណ្ឋានស្រដៀងនឹងហិបស្លា តែខ្ពស់ជាង មានរាងបួនជ្រុងសម្រាប់រងទ្រស្លាមួយក្នុងពិធីអាពាហ៍ពិពាហ៍ ។
- រណ្តាប់ (ន) : វត្ថុសម្រាប់ធ្វើទាន ឬសម្រាប់ទទួលភ្ញៀវ គ្រឿងទេយ្យទាន ទ្រនីបគ្រូ គ្រឿងបណ្ណាការ ។
- បញ្ជាប់ពាក្យ (កិ) : ជូនរបស់ទ្រព្យអ្វីមួយទៅមាតាបិតាខាងស្រី ទុកជាភស្តុតាងរបស់បញ្ជាំចិត្តភ្ជាប់មេត្រីក្នុងការចងព័ន្ធ ។
- បណ្ណាការ (ន) : ជំនូន ភស្តុភារ តង្វាយ ។
- សែន(ព្រេន) (កិ) : ដាក់ភោជនាហារសំបូងសង្រួងចំពោះមរតកបុគ្គល ឬដាក់ក្រយាបូជាពោលពាក្យអំពាវនាវចំពោះខ្មោចបិសាច ។
- កន្ទោង (ន) : ចាន ភាជន៍ធ្វើដោយស្លឹកសម្រាប់ដាក់ភោជនាហារ ដាក់ស្លាបារីបាន ។
- បុកល័ក្ខ (ន) : ឈ្មោះបទភ្លេងបុរាណខ្មែរមួយមេ គេលេងនៅពេលបុកល័ក្ខស្រម៉ក្នុងពិធីធ្វើធ្មេញក្នុងសម័យដើម ដែលហៅតាមទម្លាប់ថា ពិធីមង្គលធ្វើធ្មេញបំពេញល័ក្ខ ។
- ជាវ (ន) : លក់ឬទិញ (ពាក្យគោរព) ។
- ប្រាក់ណែន (ន) : ឈ្មោះប្រាក់ដុំមួយបែបរូបសណ្ឋានស្រដៀងនឹងស្នូកជ្រូក ទម្ងន់ ១០ តម្លឹង ឬ ១០តម្លឹង ២ជី ចាយជាប្រាក់រាយចំនួន ១៥រៀល ឬ ១៦ រៀល ដោយចុះឡើងតាមកាល តាមសម័យ ។ សព្វថ្ងៃនេះលែងចាយហើយ ។
- ខ្ពស្លា (ន) : សំណុំផ្កាស្លា ។
- ពេលា (ន) : កាល កាលតួច ។
- ពពិល (ន) : ប្រដាប់ធ្វើដោយលោហជាតិ មានសណ្ឋានស្រដៀងនឹងស្លឹកពោធិ៍ សម្រាប់បិទទៀនអុជកាន់ហុចបន្តគ្នាបង្វិលបក់ផ្សែងចូលជុំវិញមនុស្សឬរបស់អ្វីមួយ ដើម្បីឱ្យកើតសិរីសួស្តី ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទនេះ អ្នកគប្បីអានដោយយកចិត្តទុកដាក់ ហើយត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងនឹងអត្ថន័យ និងលក្ខណៈជាតិរបស់ខ្មែរ។

គ. អត្ថបទ

នៅក្នុងសង្គមខ្មែរ ពិធីរៀបមង្គលការ ជាប្រពៃណីមួយដែលមានបញ្ញត្តិប្រហែលនឹងកាតព្វកិច្ចដែរ ព្រោះអ្នកដែលបានគ្នាជាប្តីប្រពន្ធ ត្រូវតែរៀបការ បើគេចវេះពិធីនេះនឹងត្រូវគេចាត់ទុកថាជាអ្នកគ្មានសិរីសួស្តី គ្មានកិត្តិយស។

នេះជាទម្រង់មង្គលការតាមប្រពៃណីខ្មែរ ដែលយើងលើកយកមកអធិប្បាយដោយសង្ខេប :

១ . មុនពេលរៀបការ

ក. ពិធីចែចូវ

ជំបូងបង្អស់ឪពុកម្តាយ ឬអាណាព្យាបាលខាងប្រុសបានចាត់ស្រីម្នាក់ ដែលស្គាល់ទុកចិត្តមិនអភព្វ ដែលគេឱ្យឈ្មោះអ្នកនោះថា អ្នកឃ្មាយ ឬមេអណ្តើក ហើយធ្លាប់ស្និទ្ធស្នាលនឹងគ្រួសារខាងស្រី។ លុះបានដឹងថានាងនោះ(កូនក្រមុំ) នៅទំនេរហើយ ដឹងថាថ្ងៃ ខែ ឆ្នាំត្រូវគ្នាល្អ ទើបគេចូលទៅចែចូវដល់ឪពុកម្តាយ ឬអាណាព្យាបាលរបស់កូនស្រីនោះ។ ឯពិធីចែចូវត្រូវប្រព្រឹត្តទៅអស់ ៣លើក។ ក្នុងមួយលើកៗត្រូវមានស្លា មួយ ថ្នាំជក់ កំដរដៃទៅជាមួយផង។ ក្នុងការចែចូវ គេពុំនិយាយគ្នាត្រង់ៗទេ គឺនិយាយបញ្ចឹតបញ្ចៀង។ នៅលើកទី ៣ កាលបើខាងស្រីបើកផ្លូវឱ្យដើរ ជណ្តើរឱ្យឡើងហើយ អ្នកចែចូវក៏ត្រឡប់យកព័ត៌មាននេះ មកប្រាប់ខាងប្រុសវិញ។ ពិធីចែចូវនៅលើកទី ៣នេះគេហៅថា "ស៊ីស្លាដក់"។

ខ. ពិធីស្តីដណ្តឹង

ក្រោយដែលបានចាត់មនុស្សឱ្យទៅនិយាយចែចូវ បានដឹងថាគេបើកផ្លូវឱ្យចូលហើយ ខាងប្រុសត្រូវរៀបចំគិតគូររឿងស្តីដណ្តឹងតទៅទៀត។ មុននឹងចូលទៅដណ្តឹងថ្ងៃណាៗ ត្រូវឱ្យព័ត៌មានទៅខាងស្រីជាមុនសិន។ ពិធីដណ្តឹងត្រូវប្រព្រឹត្តទៅ ៣ដងដែរ។ មនុស្សដែលមានភារកិច្ចទៅដណ្តឹងកូនស្រីគេហៅថា "អ្នកផ្លូវថៅមហា ឯអ្នកដែលតំណាងឱ្យគ្រួសារខាងស្រីគេឱ្យឈ្មោះថា "មេបា"។

- លើកទី ១ : នៅថ្ងៃដែលគេបានកំណត់ទុក មនុស្សស្រី ៣នាក់ ដែលមានគួស្រករសុខនឹងគ្នា ត្រូវខាងប្រុសពឹងឱ្យធ្វើជាអ្នកផ្លូវទៅដណ្តឹង ដោយមានថង់រង ១គួ ស្លា ថ្នាំជក់ ឬស្លាជ្វា ចេកទុំ នំអន្សម នំគម នំបត់ រៀបជាគូៗ ទៅជូនខាងស្រីផង។ លើកនេះមេបាខាងស្រី ពុំទាន់សម្រេចអ្វីទេ ថាចាំពិគ្រោះគ្នាមើលសិន។
- លើកទី ២ : ដោយលើកទីមួយ ពុំទាន់សម្រេច គេឱ្យអ្នកផ្លូវ ៣នាក់ទៅដណ្តឹងជាលើកទី ២ ទៀត ដោយមានថង់រង ១គួ មានកន្សែងច្របុចក្រាលពីលើមាន ស្លា មួ ស្លាជ្វា ទៀន ១គូ ស្រាមួយដប ចេកទុំ នំអន្សម នំគម នំបង់ខ្លាញ់។ ខាងស្រីមិនទាន់សម្រេចទៀត ថាចង់ឱ្យអ្នកផ្លូវប្រុសៗមកម្តងវិញ ព្រោះក្រែងអ្នកផ្លូវស្រីៗទទួលការគ្រប់ជំពូកមិនបាន ម្យ៉ាងទៀតចង់ឱ្យនាំកូនប្រុសមកមើលផង។ ពិធីនេះគេហៅថា "ស៊ីស្លាកន្សែង"។
- លើកទី ៣ : លើកនេះគេឱ្យស្រី ៣នាក់(អ្នកផ្លូវ) ប្រុស ៣នាក់(អ្នកមហា) ឱ្យនាំរណ្តាប់ដែលមានថង់រងមួយគួ ស្លាមួថ្នាំ ស្លាជ្វា ទៀន ស្រា ចេកទុំ នំអន្សម នំគម នំបត់ នំបង់ខ្លាញ់ នំកន្ទ្រាំ នំក្រូច អង្ករ ត្រីសាច់ បន្លែ និងផ្លែឈើផ្សេងៗជាគូៗ ព្រមទាំងគ្រឿងមាស ពេជ្រ និងសម្លៀកបំពាក់ទៅជូនខាងស្រី ហើយនាំកូនប្រុសទៅជាមួយផង។ ក្រោយពីបានសន្ទនារវាងអ្នកផ្លូវ ថៅមហា និង មេបារួចសព្វគ្រប់ហើយ មេបាខាងស្រីសុំពិនិត្យសាមីខ្លួនប្រុស ព្រមទាំងបញ្ជាក់សួរអំពីគំនិត មារយាទសាមីខ្លួនប្រុសនោះផង។ ចំណែកឯអ្នកផ្លូវថៅមហាក៏អាចសុំមើលសាមីខ្លួនស្រីវិញដែរ។ នៅពេលនោះ សាមីខ្លួនស្រីក៏ចេញមកជម្រាបសួរភ្ញៀវ ហើយជួនកាលមានពិធីបំពាក់ចិញ្ចៀនទៅវិញទៅមករវាងគូដណ្តឹងផង។ ...បន្ទាប់មកអ្នកមហាក៏លើកគ្រឿងស្លាបញ្ជាប់ពាក្យជូនទៅមេបាស្រីពិសា។ ពិធីនេះ ហៅថា "ស៊ីស្លាបញ្ជាប់ពាក្យ"។ ដោយមេបាមិនទាន់អស់ចិត្ត អំពីគំនិតមារយាទរបស់សាមីខ្លួនប្រុស ទើបមានទំនៀមថា ត្រូវឱ្យសាមីខ្លួនប្រុសមកនៅបម្រើអនាគតឪពុកម្តាយក្មេករហូតដល់ពេលរៀបការ ប៉ុន្តែធ្វើតែកិច្ចការក្រៅផ្ទះគឺពុំទាន់មានសិទ្ធិចូលទៅនៅក្នុងផ្ទះបាននៅឡើយទេ។ ចំណែកទំនាក់ទំនងរវាងគូដណ្តឹងក៏ត្រូវគោរពច្បាប់យ៉ាងតឹងរ៉ឹង។

គ. ពិធីជូនកំណាត់

ចំពោះថ្ងៃខែរៀបមង្គលការដែលគេជ្រើសរើសនិងគន់គូរដោយម៉ត់ចត់ ហើយគេពុំរើសខែណាដែលមាន ២៩ថ្ងៃ(ខែឈ្មោល)ឬខែណាដែលព្រះសង្ឃចូលវស្សាទេ។ គេត្រូវយកទៅចុះក្នុងផែនក្រដាសមួយសន្លឹក ហើយរៀបរណ្តាប់កំដរដៃផងមាន ស្លាមួ ចេកទុំ រងស្លាដែលដាក់គ្រឿងគ្រប់

សព្ទ។ រួចហើយអ្នកផ្តួរ ត្រូវយកក្រដាសកំណត់ពេលវេលានិងរណ្តាប់ទៅជូនមេបាខាងស្រី។ មេបាខាងស្រីក៏បើកក្រដាសកំណត់ពេលានោះអានជូនភ្ញៀវស្តាប់។ ក្រោយពីបានជូនក្រដាសពេលាជូនទៅមេបារួចហើយ អ្នកផ្តួរក៏ជូនស្លាកំណត់ទៅមេបាពិសា ពិធីនេះហៅថា "ស៊ីស្លាកំណត់"។

នៅទីបញ្ចប់ អ្នកផ្តួរសុំឱ្យមេបាបង្គាប់នូវគ្រឿងបណ្ណាការសព្ទសារពើដែលត្រូវជូននិងប្រើប្រាស់ក្នុងឱកាសធ្វើមង្គល។

ចាប់ពីពេលនេះទៅ សាមីខ្លួនប្រុសអាចជួយធ្វើការក្នុងផ្ទះអនាគតឪពុកម្តាយក្មេក ឬអាណាព្យាបាលបាន។ ចំណែកឯសាមីខ្លួនស្រីជាអ្នករៀបចំដំណេកនិងបាយទឹកឱ្យ ហើយកាលណាមានជំងឺនាង មានសិទ្ធិជួយមើលថែទាំថែមទៀតផង។

២ . ពេលរៀបការ

តាមប្រពៃណីបុរាណ ពិធីរៀបមង្គលការប្រព្រឹត្តទៅចំនួន ៣ថ្ងៃ គឺថ្ងៃចូលរោង ថ្ងៃស៊ីស្លាកំណត់ និងថ្ងៃសំពះ។

ក. ថ្ងៃចូលរោង

នៅថ្ងៃទី ១ គ្រួសារខាងប្រុសត្រូវមកសង់រោងការនៅផ្ទះខាងស្រី។ រោងការច្រើនតែសង់អំពីឫស្សីប្រក់ស្បូវមាន ៣ល្វែង។ ល្វែងមួយសម្រាប់ចុងភៅធ្វើម្ហូបអាហារ ល្វែងមួយទៀតសម្រាប់លៀងភោជនាហារ ហើយល្វែងមួយទៀតជាល្វែងផ្កាស្លាសម្រាប់កូនកំលោះស្នាក់នៅរហូតដល់ថ្ងៃចុងក្រោយនៃពិធីការ។ នៅមុខរោងផ្កាស្លាមានសង់រានទេវតាផង។ លុះសង់និងតុបតែងលំអរោងរួចហើយ គេនាំគ្នាជញ្ជូនភស្តុភារបណ្ណាការចូលរោងមង្គលការ ហើយគេរៀបចំធ្វើម្ហូបអាហារនិងធ្វើនំផ្សេងៗ ជាពិសេសនំអន្សមនិងនំគម។ តាមជំនឿលទ្ធិព្រាហ្មណ៍សាសនា គេថានំអន្សមជានិមិត្តរូបលិង្គឥសូរ ឯនំគមជានិមិត្តរូបយោនីនាងឧមា ហើយអវត្តមាននំទាំងពីរប្រភេទនេះក្នុងពិធីមង្គលការនឹងនាំឱ្យគ្មានកូនចៅដល់គូស្វាមីភរិយាថ្មីឡើយ។

ខ. ថ្ងៃស៊ីស្លាកំណត់

នៅវេលាព្រឹកថ្ងៃទី ២ គេហៅកូនកំលោះ ដោយមានភ្លេងខ្មែរកំដរផងមកកាន់ផ្ទះខាងស្រី។ កូនកំលោះនោះត្រូវចូលទៅនៅក្នុងរោងផ្កាស្លា។ ចំណែកនៅលើផ្ទះការ មានធ្វើពិធីសែនព្រេនជម្រាបជូនតាអំពីការរៀបចំទុកដាក់កូនចៅឱ្យមានគូស្រករនិងពិធីស៊ីស្លាកំណត់។

នៅពេលរសៀលថ្ងៃដដែលនោះពិធីកាត់សក់កូនស្រី ប្រព្រឹត្តទៅនៅលើផ្ទះការ ឯពិធីកាត់សក់កូនប្រុសនៅក្នុងរោងផ្កាស្លា។ សព្វថ្ងៃគេអាចកាត់សក់កូនប្រុសស្រីរួមគ្នា នៅលើផ្ទះការក៏បាន។ តាមទំនៀមជាងកាត់សក់ត្រូវកាន់កន្ត្រៃកាន់ក្រាស់ច្រៀងរាំជាមុនសិន។ សក់ដែលគេកាត់ត្រូវដាក់ក្នុងកន្ទោងស្លឹកចេកមួយ ហើយត្រូវយកទៅចោល ដើម្បីឱ្យអស់ចង្រៃឧបទ្រព។ បន្ទាប់មក គេរៀបតង្វាយក្រុងពាលី ដើម្បីជូនព័ត៌មាននៃពិធីការនេះដល់ម្ចាស់ទឹកម្ចាស់ដី។ ឯពិធីសូត្រមន្តក៏ប្រព្រឹត្តទៅនៅផ្ទះការផង នៅរោងផ្កាស្លាផង។ ប៉ុន្តែគេអាចសូត្រមន្តរួមគ្នានៅលើផ្ទះការក៏បាន។ នៅពេលសូត្រមន្តនេះ សាមីខ្លួនទាំងពីរនាក់ត្រូវចេញមកស្តាប់ហើយទទួលទឹកមន្ត ដើម្បីឱ្យជ្រះចង្រៃនិងរោគាផ្សេងៗ ហើយឱ្យបានសេចក្តីសុខចម្រើន។

នៅវេលាយប់ គេរៀបចំផ្លែឈើ គឺខ្ចប់នំជាកញ្ចប់ៗតាមទំនៀមបុរាណទុកជូនមេបា។ បន្ទាប់មកគេធ្វើពិធីបុកល័ត្ត ធ្វើធ្មេញឱ្យសាមីខ្លួនស្រី។ បន្ទាប់មកទៀតមានជាវ ឬកាត់ខាន់ស្លាជាប្រាក់សុទ្ធ ១ណែនទម្ងន់ ១៦រៀល។ លុះទៀបភ្លឺ គេរកស្រី ៣នាក់ដែលមានគូស្រករប្រកបនឹងគ្នាឱ្យរៀបដោតផ្កាស្លាដោយយកខ្ពស្លាដែលដាក់សូត្រមន្តពីថ្ងៃរសៀលនោះមកដោតជា ៣ជុំ គឺស្លាទី ១ត្រូវដោតស្លា ២១ផ្លែ ម្ជូ ២១សន្លឹក(ផ្កាស្លាច្បង) ផ្កាស្លាទី ២ត្រូវដោតស្លា ១២ផ្លែ ម្ជូ ១២សន្លឹក(ផ្កាស្លាកណ្តាល) ផ្កាស្លាទី ៣ត្រូវដោតស្លា ៦ផ្លែ ម្ជូ ៦សន្លឹក(ផ្កាស្លាពៅ)។

គ. ថ្ងៃសំពះ

នៅថ្ងៃទី ៣លុះភ្លឺស្រាងៗឡើង សាមីខ្លួនប្រុសនិងសាមីខ្លួនស្រីត្រូវរៀបចំស្លៀកពាក់តាមបែបបុរាណ។ អាចារ្យអ្នកកាន់ពេលា ត្រូវនាំកូនប្រុសទៅថ្វាយបង្គំវានទេពតា ហើយត្រូវអង្គុយបែរមុខទៅទិសខាងកើត ចាំយកពេលានៅទីនោះ។ លុះពេលាល្អដល់ហើយ (ពេលាដែលព្រះអាទិត្យរះ) អាចារ្យវាយឃ្មោះ ៣ដង ហើយកូនកំលោះក៏ក្រាបថ្វាយបង្គំព្រះអាទិត្យ ៣ដងដែរ។ ការយកពេលាក្នុងពិធីការនេះ គឺការយកពេលដ៏បរិសុទ្ធដែលជាពេលមង្គល ដើម្បីជាប្រផ្នូលឱ្យគូស្វាមីភរិយាបានទទួលសេចក្តីចម្រើនរុងរឿងទៅអនាគត។ កាលបើបានពេលាល្អហើយ គេដង្ហែកូនកម្លោះទៅសំពះផ្កាស្លានៅលើផ្ទះការ។ ដំបូងអាចារ្យកាន់ជាវលើកផ្លូវ បន្ទាប់មកមហា ៣នាក់ អ្នកកាន់ទៀប ២នាក់ អ្នកកាន់ផ្កាស្លា ៣នាក់ អ្នកកាន់រងប្រាក់ខាន់ស្លាប្រាក់ស្នាប់ទឹកដោះ អាចារ្យកូនកំលោះអ្នកបាំងឆត្រឱ្យកូនកំលោះក្រោយបំផុត គឺពួកស្តេង។ លុះមែទៅដល់មាត់ជណ្តើរ គេវាយឃ្មោះ ៣ដង ជាសញ្ញាអនុញ្ញាតឱ្យកូនកំលោះឡើងលើផ្ទះបាន។ នៅពេលនោះមានក្មេងប្រុសឬស្រីម្នាក់ដែលត្រូវជាប្អូន ឬ

ជំនិតនិងសាមីខ្លួនស្រី បានមកទទួលដោយកាន់ទឹកមួយផ្តិលមកលាងជើងឱ្យកូនកំលោះ ព្រមទាំងជូនស្លាមួយម៉ាត់ផង។ ចំណែកកូនប្រុសនោះក៏បានឱ្យប្រាក់កាក់ដល់ក្មេងនោះវិញ ហើយក្មេងនោះក៏ដឹកដៃកូនប្រុសឡើងលើផ្ទះ។ គេឱ្យសាមីខ្លួនប្រុសអង្គុយលើកន្ទេលបែរមុខទៅកើតចាំមេបានិយាយការ។ នៅពីមុខមានរៀបពានផ្កាស្លា ពានទៀនពេលា ទៀប ២ដាក់បាយខុន ក្បាលជ្រូក ១ឬមាន់ស្ងោរ ១ នំអន្សម នំគម។ បន្ទាប់មកគេឱ្យកូនកំលោះសំពះស្លាព្រះពរ(ម្ហូដែលគេមួរចំនួន ៣ត្រួយ) ដែលដាក់លើខ្នើយ។ តមកទៀតអ្នកផ្លូវស្រីម្នាក់អុជទៀនបិទនៅរង ហើយកាន់រងនោះទៅអញ្ជើញកូនស្រីឱ្យចេញមកផ្ទឹម។ ពេលនោះគេរាំច្រៀងបើកវាំងនន។ សាមីខ្លួនកូនក្រមុំត្រូវអង្គុយផ្ទឹមជិតកូនកំលោះខាងឆ្វេង។ នៅតាមតំបន់ខ្លះគេរាំកាន់ដាវ រាំបើកគ្របទៀបរួចហើយ គេយកដាវទៅដាក់លើម្រាមដៃកូនកំលោះកូនក្រមុំ។ ជួនកាលអាចារ្យដាក់អកកំបោរនិងប្រណាក ដើម្បីជានិមិត្តរូបនៃការរួមសំបាច់គ្នា។ ក្រោយមកគេប្រារព្ធពិធីបង្វិលពពិលនៅជុំវិញគូស្វាមីភរិយា។ អ្នកកាន់ពពិលបង្វិលមានប្រុស ៥នាក់ ស្រី ៤នាក់ ដែលជាអ្នកមានខាន់ស្លា ហើយមិនអភ័ព្វគូ។ គេហុចពពិលបន្តគ្នាពីដៃស្តាំទៅដៃឆ្វេង ហើយអាចារ្យសូត្រធម៌ជយន្តោបណ្តើរ។ លុះចប់ពិធីនោះហើយ អាចារ្យត្រូវសូត្រឱ្យពរផ្កាស្លា។ ឯពួកមេបាត្រូវចងដៃកូនប្រុសស្រីដោយអំបោះស ព្រមទាំងឱ្យពរសព្វសាធុការរៀងៗខ្លួន។ រួចហើយគេស្រាយផ្កាស្លាកណ្តាលនិងផ្កាស្លាពៅឱ្យញាតិមិត្តបាចឱ្យពរដល់គូស្វាមីភរិយា។ លុះចប់ហើយសាមីខ្លួនប្រុសស្រីងើបអង្គុយបែរមុខរកគ្នា ហើយគេវាយឃ្មោះឱ្យកូនក្រមុំនិងកំលោះចូលក្នុងបន្ទប់ ពេលនោះសាមីខ្លួនប្រុសដើរតាមសាមីខ្លួនស្រីដោយតោងជាយស្បៃរបស់សាមីខ្លួនស្រី។ នៅក្នុងបន្ទប់ សាមីខ្លួនស្រីត្រូវបញ្ចុកស្លាមួយដល់សាមីខ្លួនប្រុស ឬអុជបារីឱ្យជក់ រួចហើយទាំងពីរនាក់ត្រូវផ្លាស់គ្រឿងសំអាងចេញ ហើយទៅអង្គុយកណ្តាលទីប្រជុំ។ លំដាប់នោះមានការកាន់ដាវច្រៀងរាំសាកន្ទេល។ លុះចប់ពិធីនេះហើយគូស្វាមីភរិយាត្រូវចេញទៅបម្រើមេបាក្នុងការលៀងភោជនាហារ។ សម័យបុរាណគេលៀងភ្ញៀវ ២លើកធំៗ គឺនៅល្ងាចថ្ងៃស៊ីកំណត់និងព្រឹកថ្ងៃសំពះ។

លុះយប់ប្រហែលម៉ោង ៨-៩ គេប្រារព្ធពិធីផ្សំដំណេកនៅក្នុងបន្ទប់ដេករបស់គូស្វាមីភរិយាថ្មី។ គេជ្រើសរើសស្ត្រីមានវ័យចំណាស់ ២នាក់ឱ្យរៀបចំពិធីនេះ។ ត្រូវមានចំអាប ១ថាស បង្អែម ១ថាស បាយសី ១ ដួងខ្ចី ១។ ដំបូងគេអុជទៀនធូបសែនដូនតា ហើយជួសទឹកដួងខ្ចីបញ្ចុកកូនប្រុស ៣ស្លាបព្រា។ បន្ទាប់មកគេឱ្យសាមីខ្លួនស្រីបកចេកបញ្ចុកសាមីខ្លួនប្រុស ឯសាមីខ្លួនប្រុសត្រូវបញ្ចុកសាមីខ្លួនស្រីវិញ ជានិមិត្តរូបនៃការឱ្យចេះស្រឡាញ់គ្នារហូតមួយជីវិត។

៣ . ក្រោយពេលរៀបការ

ក្រោយពេលរៀបការបាន ៣ ថ្ងៃ គេនាំស្វាមីភរិយាថ្មីនេះដោយយកផ្កាស្លាឆ្នុង ចំអាប បង្អែមស្លាបារីទៅថ្វាយបង្គំសុំពរពីព្រះសង្ឃឯវត្ត ហើយឱ្យលោកបាចផ្កាស្លានេះ ដើម្បីប្រសិទ្ធពរឱ្យបានសុខចម្រើនតទៅ ។

តាមច្បាប់អត្រានុកូលដ្ឋាន ឪពុកម្តាយទាំងសងខាង ត្រូវនាំកូនប្រុសស្រីទៅសាលាសង្កាត់ ដើម្បីសុំចុះសំបុត្រអាពាហ៍ពិពាហ៍ ដោយមានសាក្សី ២នាក់ផង ។ ចាប់ពីពេលនេះតទៅ គេមានឈ្មោះជាប្តីប្រពន្ធពេញច្បាប់ហើយ ។

ថ្ងៃក្រោយមកទៀត គេនាំស្វាមីភរិយាថ្មីនេះដើរសាកសួរញាតិមិត្តទាំងខាងប្រុស ទាំងខាងស្រី ។

សម្គាល់ : នៅសម័យមុន នៅក្នុងសង្គមខ្មែរពិធីរៀបមង្គលការជាប្រពៃណីមួយ ដែលមានបញ្ញត្តិប្រហែលគ្នានឹងកាតព្វកិច្ចដែរ ។ ប្រសិនបើកំលោះក្រមុំណាបានប្រព្រឹត្តសហាយស្មន់អន្ទកវនិងគ្នា ប្រពៃណីខ្មែរបានចាត់ទុកថាក្រមុំកំលោះនោះបានប្រព្រឹត្តកន្លងប្រពៃណីខ្មែរ "ខុសមេបា" ហើយអ្នកគ្មានសីរីសួស្តីនិងគ្មានកិត្តិយសឡើយ ។ អ្នកមិនបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ គេមិនឱ្យចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍អ្នកដទៃដូចជា ធ្វើជាមេបា អាចារ្យ មហាកាន់ថង់រង ចូលរួមបង្ហិលពពិលជាដើមឡើយ ។ កំហុសនេះមិនមានត្រឹមតែបុរសនារីប៉ុណ្ណោះទេគឺមានរហូតដល់កូនចៅទៀត ។ បើមានកូនស្រី ឬចៅស្រីគេមិនហ៊ានចូលស្តីដណ្តឹងទេ ។ បើមានកូនប្រុស ឬចៅប្រុសក៏គេមិនហ៊ានឱ្យកូនដែរ ពីព្រោះគេយល់ថា ត្រកូលគ្មានខាន់ស្លាជាត្រកូលអបលក្ខណ៍ ។

បើកូនក្រមុំកំលោះដែលបានរៀបអាពាហ៍ពិពាហ៍តាមសេចក្តីសម្រេចរបស់លោកមេបា គឺជាត្រកូលមានខាន់ស្លា ជាត្រកូលឧត្តុង្គឧត្តម ។

ដូច្នេះអាពាហ៍ពិពាហ៍មានសារៈសំខាន់ណាស់ក្នុងជីវភាពគ្រួសារនិងសង្គមខ្មែរ ។

(ដកស្រង់និងកែសម្រួលពីអរិយធម៌ខ្មែរ របស់អ្នកស្រី ត្រឹង ងា)

សំណួរ

១. តើដំណាក់កាលធំៗនៃអាពាហ៍ពិពាហ៍ខ្មែរមានអ្វីខ្លះ ?

២. តើគេជ្រើសរើសមនុស្សប្រភេទណា ដើម្បីចូលទៅស៊ើបសួរ (ចែចូវ) ព័ត៌មានខាងកូនក្រមុំ ?

៣. ចូររៀបរាប់ចំណុចសំខាន់ៗក្នុងថ្ងៃសំពះ ។

៤. តើទំនៀមរៀបចំដោតផ្កាស្លា ៣ ទាក់ទងទៅនឹងរឿងអ្វី ?

៥. ចូររាប់ឈ្មោះបទចម្រៀងក្នុងពិធីរៀបអាពាហ៍ពិពាហ៍ឱ្យបាន ៥បទដោយបញ្ជាក់ថា បទនោះច្រៀងក្នុងពិធីអ្វី ?

៦. តើអ្នកយល់ដូចម្តេចចំពោះប្រពៃណីរៀបមង្គលការរបស់ជូនតាខ្មែរយើង ?

ការតែងកំណាព្យ

១ . បឋមថ្នាក់

ក. រង្វាស់កាព្យ

- ១វគ្គមាន៤ឃ្លា , ១ឃ្លាមាន៨ព្យាង្គ

ខ. ចំណាប់ជួន

- សេចក្តីពន្យល់


ជួនក្នុងវគ្គ

- ព្យ ៨-ឃ ១ ⟹ ព្យ ៤-ឃ ២
- ព្យ ៨-ឃ ១ ⟹ ព្យ ៨-ឃ ៣
- ព្យ ៨-ឃ ១ ⟹ ព្យ ៤-ឃ ៤

ជួនឆ្លងវគ្គ

- ព្យ ៨-ឃ ៤-វ ១ ⟹ ព្យ ៨-ឃ ១-វ ២
- ព្យ ៨-ឃ ៤-វ ១ ⟹ ព្យ ៨-ឃ ២-វ ២

- គំនូសតាង



ឧទាហរណ៍ :

វិនាសទីមួយការស្អប់ធម៌ត្រូវ	ទ្រុស្តសីលអាស្រូវច្រើនធ្វើបំពាន
ជាហេតុទាន់ហាន់និងជាប្រធាន	នាំសត្វឱ្យមានក្តីវិនាសពិត ។
វិនាសទីពីរគឺការគប់មិត្ត	ដែលមានគំនិតអសប្បុរស
គ្មានមេត្តានៅក្នុងខ្លួនសោះ	ជាហេតុនាំឆ្ពោះវិនាសជាក់ស្តែង ។

(ដកស្រង់ពីរបាយការណ៍បូកសរុបលទ្ធផលនៃការស្រាវជ្រាវបទស្នូតកំណាព្យ)

គ. ចង្វាក់

សង្កត់សំឡេងលើព្យាង្គ ២ ៤ និង ៦គ្រប់ឃ្លា ។

ឃ. បរិយាកាស

គេនិយមស្មូតនៅតាមវត្តអារាមនៅក្នុងប្រទេសកម្ពុជាពេលបុណ្យភ្ជុំបិណ្ឌនិងក្នុងទិវាចងកំហឹង ។

ង. របៀបស្មូត

របៀបស្មូតមានបីបែប គឺ

- បែបបរាភវសូត្រ
- បែបសំស្ក្រឹត
- បែបសម្រាយ

ច. អត្ថបទ

បញ្ចសីលា

ធម៌សុខទីមួយមេត្តាគ្រប់ទី
សព្វសត្វជីវីកុំប៉ងពាធា
ប្រមាថសម្លាប់ផ្តិលផ្តាច់ជន្មា
ត្រូវមានសទ្ធាការពារជីវិត ។
ធម៌សុខទីពីរកុំប៉ុនប៉ងគិត
លង់ក្នុងគំនិតគិតគន់គ្នាន់គ្នេរ
កេងកិបប្រវ័ញ្ចលួចសម្បត្តិគេ
គួរកុំវៀចវេរលោភលន់ចង់បាន ។
ធម៌សុខទីបីនាំក្តីក្សេមក្សាន្ត
គឺត្រូវប្រមាណកុំគិតប្រមាថ
រំលោភសេពកាមនិងស្រីរូបស្អាត
ដែលស្ថិតក្នុងជាតិមានគេរក្សា ។
ធម៌សុខទីបួនត្រូវកាន់ចិន្តា
កុំពោលវាចាកុហកបញ្ឆោត
ស្តីពាក្យពុំពិតឬគិតចាក់ដោត
បង្កនាំក្រោធព្រោះតែមុសា ។
ធម៌សុខទីប្រាំកុំសេពសុរា
អាភៀនកញ្ឆាគ្រឿងញៀនស្រវឹង
នាំបាត់ស្មារតីវង្វេងកើតខឹង
គិតខុសលែងដឹងកើតទោសពេកពន់ ។
បញ្ចសីលាធម៌ល្អលើសលន់
នាំសុខគ្រប់ជនទាំងមនុស្សទេពតា
ប្រកាន់ឱ្យខ្ជាប់កើតក្តីសុខា
សត្វលើលោការស់សុខសាន្តហោង ។

(របាយការណ៍បូកសរុបលទ្ធផលនៃការស្រាវជ្រាវបទស្មូតកំណាព្យទំព័រ ៣-៤)

២ . បទពាក្យ ៨

ក. រង្វាស់កាព្យ

- មួយវគ្គ មាន ៤ឃ្លា
- មួយឃ្លា មាន ៨ព្យាង្គ

ខ. ចំណាប់ចួន

- សេចក្តីពន្យល់


ចួនក្នុងល្បះ

- ព្យ ៨-ឃ ១ ⟼ ព្យ ៥-ឃ ២
- ព្យ ៨-ឃ ២ ⟼ ព្យ ៨-ឃ ៣
- ព្យ ៨-ឃ ៣ ⟼ ព្យ ៥-ឃ ៤

ចួនឆ្លងល្បះ

- ព្យ ៨-ឃ ៤-វ ១ ⟼ ព្យ ៨-ឃ ២-វ ២

- គំនូសតាង



ឧទាហរណ៍ :

មកដល់សេចក្តីគិតមានអាល័យ	ដែលអាលោះនឹកថ្លៃសោកសែនសល់
ហើយសែនណែនទ្រូងខ្ញុំទ្រាំទុក្ខទល់	ទ្រាំទុក្ខទៀបដាច់ខ្យល់ខ្ចាត់ពីកាយ ។
ពីកើតមករៀមមិនដែលទុក្ខដូច្នឹង	ទុក្ខដូច្នេះសមនឹងទ្រូងប្រេះខ្លាយ
ទ្រូងបែកខ្ចាត់បាត់ជន្មចេញពីកាយ	ទុក្ខក្រំផ្សាពុំរសាយសាន្តទុក្ខា ។

(ប្រជុំពាក្យកាព្យទំព័រទី ១២០)

សម្គាល់ : របៀបតែងកាព្យបទពាក្យ ៨មាន ៤បែប ។

គ. ចង្វាក់

សង្កត់សំឡេងលើព្យាង្គទី ៣ និងទី ៥ គ្រប់ឃ្លា

ឃ. បរិយាកាស

បទពាក្យ ៨ ប្រើដោយសេរី ។

ង. រចៀបស្មូត

មានបទពណ៌នា បែបរាស់ ... ។

៣ . បទពាក្យ ៩

ក. រង្វាស់កាព្យ

- មួយវគ្គ មាន ៤ឃ្លា
- មួយឃ្លា មាន ៩ព្យាង្គ

ខ. ចំណាប់ចួន

- សេចក្តីពន្យល់


ចួនក្នុងវគ្គ

- ព្យ ៩-ឃ ១ វ ១ ⟹ ព្យ ៣ ឬព្យ ៦-ឃ ២-វ ១
- ព្យ ៩-ឃ ២ វ ១ ⟹ ព្យ ៩-ឃ ៣-វ ១ ⟹ ព្យ ៣ ឬព្យ ៦-ឃ ៤-វ ១

ចួនឆ្លងវគ្គ

- ព្យ ៩-ឃ ៤-វ ១ ⟹ ព្យ ៩-ឃ ១-វ ២

- គំនូសតាង



គ. ចង្វាក់

ទម្លាក់សំឡេងលើព្យាង្គទី ៣ និងព្យាង្គទី ៦ គ្រប់ឃ្លា ។

ឃ. បរិយាកាស

បទពាក្យ ៩ ប្រើសម្រាប់បញ្ចេញនូវមនោសញ្ចេតនា ឬការឆ្លើយឆ្លងលែបខាយបែបស្ដីបន្ទោស គំហក កំហឹង ។ ជាធម្មតាគេក៏អាចប្រើគ្រប់បរិយាកាសបានដូចជា បទពាក្យ ៧ ពាក្យ ៨ ដែរ ។

ង. អត្ថបទ

ស្ដាយដួងចន្ទ្រា

ខ្ញុំស្រឡាញ់ដួងចន្ទ្រាពេញបូណ៌មី　　រឿងរង្សីភ្លឺត្រចះច្បាស់មេឃា
ស្អាតបរិសុទ្ធមូលក្រឡង់ក្នុងនភា　　ខ្ញុំនិន្ទ្រាមិនលក់ឡើយពេលរាត្រី ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាភ្លឺត្រជាក់　　ពន្លឺប្រាក់ស្រោបដួងចិត្តជនប្រុសស្រី
ឱ្យសប្បាយត្រើតត្រើនចិត្តឥតខ្វល់អ្វី　　ភ្លេចក្រក្រីក្តីសោកសៅក្នុងជីវិត ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាមូលក្រឡង់　　ហាក់ដូចវង់ភក្ត្រកល្យាណគូស្នេហ៍ស្និទ្ធ
នាងញញឹមខ្ញុំសង្ឃឹមសប្បាយចិត្ត　　ហាក់បានជិតរឹតរួមរក្សស្ម័គ្រកន្ទិដ្ឋា ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាសាក្សី　　នៃសេចក្តីស្មោះស្ម័គ្រចិត្តស្និទ្ធស្នេហា
នៃក្រមុំនិងកំលោះគូសង្សារ　　ដែលប្រាថ្នាបានជាគូរួបរួមកាយ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាល្បែងក្មេង　　ម្ដាយពោលលេងឱ្យកូនតូចពនសុំបាយ
សុំសម្ល ទឹកបំពង់ ចេកដួងស្វាយ　　កូនសប្បាយញ៉ាំចិបៗសើចក្អឹកៗ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាមានពោធិ៍ធំ　　ជីដូនខ្ញុំប្រាប់ដូច្នោះមកជាញឹក
មើលទៅឃើញមានឫសគល់ដើមមែកស្លឹក　　ក្រោមពោធិ៍ព្រឹក្សដូនចាស់រវៃអំបោះ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅសសាង្គ　　ព្រះឥន្ទ្រស្ពាងរូបទន្សាយទុកនៅនោះ
រំលឹកកាលពោធិសត្វគិតសង្គ្រោះ　　ព្រាហ្មណ៍ដោយស្ទុះលោតចូលភ្លើងជាអាហារ ។
ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅលោកខែ　　នៅស្រុកខ្មែរពិធីដ៏ថ្លៃថ្លា
អកអំបុកងើយមើលចំដួងចន្ទ្រា　　បន់ទេពតាសូមខេមរាបានថ្កើងថ្កាន ។

(ដកស្រង់ពីកំណាព្យ បុប្ផាខ្មៅ របស់លោក គយ សារុន ទំព័រទី ៤១-៤៤)


មេរៀនទី

៩ ទំនាក់ទំនងរវាងអក្សរសិល្ប៍ខ្មែរនិងបរទេស



ទំនាក់ទំនង គឺជាការទាក់ទងគ្នាក្នុងសង្គម ដែលមានសារៈសំខាន់បំផុតសម្រាប់ពិភពលោកទាំងមូល ដែលពុំអាចខ្វះបាន។ ការមានទំនាក់ទំនងល្អរវាងគ្នានឹងគ្នា រវាងប្រទេសនិងប្រទេស រវាងកិច្ចការមួយទៅកិច្ចការមួយ។ល។ តែងនាំមកនូវមិត្តភាពនិងការស្រឡាញ់រាប់អានកាន់តែជិតស្និទ្ធ កាន់តែរឹងមាំនិងប្រកបដោយការយោគយល់ អធ្យាស្រ័យល្អជានិច្ច។ ទំនាក់ទំនងល្អតែងនាំមកនូវការផ្លាស់ប្តូរផ្នត់គំនិតថ្មីៗ ការច្នៃប្រឌិតកាន់តែខ្ពស់ទាំងផ្នែកវប្បធម៌ អរិយធម៌ សេដ្ឋកិច្ច សង្គមកិច្ច ឬនយោបាយ ដែលនាំឱ្យសង្គមកាន់តែមានភាពជឿនលឿន រីកចម្រើនខ្លាំងក្លា។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីទំនាក់ទំនងរវាងអក្សរសិល្ប៍ខ្មែរនិងអក្សរសិល្ប៍បរទេសតាមរយៈអត្ថបទមួយចំនួន។ ទន្ទឹមនឹងនេះ អ្នកនឹងសិក្សាផងដែរអំពី អ្នកនិពន្ធនិងកាលបរិច្ឆេទរឿង ខ្លឹមសារសំខាន់ៗនៃអត្ថបទ កំណត់ពីអត្ថន័យ អត្ថរូប និងអត្ថរសរបស់រឿង និយាយបកស្រាយន័យរបស់សុភាសិតបានត្រឹមត្រូវ សរសេរអត្ថបទប្រៀបធៀបចំណុចខុសគ្នាសំខាន់ៗមួយចំនួនក្នុងរឿងរាមកេរ្តិ៍និងរឿងរាមាយណៈ។



ក. សិក្សាពាក្យគន្លឹះ

- រាជបុរោហិត (ន) : ព្រាហ្មណ៍ជាគ្រូរបស់ព្រះរាជា ។
- អារាធនា (ន) : សេចក្តីពេញចិត្ត ការរាប់រក ។
- រាជសីហ៍ (ន) : ស្តេចសីហៈ ឬស្តេចសិង្ហ តោ ។
- ភាជន៍ (ន) : គ្រឿងចាន ឆ្នាំង ក្អមធ្វើពីដីឥដ្ឋសម្រាប់ដាក់អាហារចំណី ។
- មធុបាយាស (ន) : ពំនួតបាយពណ៌ស គឺផ្សំដោយទឹកដោះគោ ទឹកឃ្មុំ ... ។
- ប្រទាន (កិ) : ឱ្យ ។
- ទសមាស (ន) : គំរប់ ១០ខែ ។
- ប្រសូត (កិ) : កើត ។
- រាក្សស (ន) : យក្ស ឬបិសាចដែលអាស្រ័យតាមមាត់ទឹក ឬដងព្រៃ ។
- អសុរ (ន) : អមនុស្សមួយពួក ទីទៃពីពួកទេវតា (ពួកយក្ស) ។
- យក្ខិនី (ន) : យក្ខ ឬយក្សស្រី ។
- ពលិកម្ម (ន) : ការបូជាជីវិត ការលះបង់ជីវិត ។
- រាជសុណិសា (ន) : កូនប្រសាព្រះរាជា កូនប្រសាស្តេច ។

- រាជាភិសេក (កិ) : ពិធីស្រោចទឹកក្តស់ ទឹកស័ង្ខតាំងព្រះរាជាឱ្យពេញជាក្សត្រទ្រង់រាជ ។
- រាជបរិពារ (ន) : រាជបរិវារ បរិវាររបស់ព្រះរាជា ។
- វិស្ណុ (ន) : ទេវតា អាទិទេព ។
- អវតារ (ន) : ដំណើរឆ្លងចុះពីលំដាប់មួយទៅលំដាប់មួយទៀតតៗគ្នា ។
- ព្យូហយាត្រា (ន) : ក្បួនដង្ហែ ។
- សត្យវាចា (ន) : វាចា សំដី ឬពាក្យពិត ។
- អយ្យកោ (ន) : ជីតា ។
- ប្រតិស្ឋាន (ន) : ការស្ថិត ស្ថិតនៅ ការតាំងនៅ ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទខាងក្រោមនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ហើយកត់ចំណាំសេចក្តីលំអិត ខ្លឹមសារសំខាន់ៗនៃអត្ថបទដកស្រង់ ដើម្បីឆ្លើយនឹងសំណួរមួយចំនួនទាក់ទងនឹងអ្នកនិពន្ធ កាលកំណត់តែងនៃរឿង សង្គមបរិយាកាសនៃរឿង ខ្លឹមសារសំខាន់ៗក្នុងកាន្ទនីមួយៗ ព្រមទាំងបង្ហាញពីអត្ថរសនៃរឿងឱ្យបានត្រឹមត្រូវ ។

គ. អត្ថបទដកស្រង់

កាន្ទទី ១ : ពាលកាន្ទ

កាន្ទទី ១ ឈ្មោះពាលកាន្ទ ដែលរៀបរាប់អំពីបុព្វប្រវត្តិរបស់ព្រះរាម ចាប់តាំងពីជីវប្រវត្តិរបស់ព្រះបាទទសរថ ដែលជាអម្ចាស់ក្សត្រសុរិយវង្ស ។ ព្រះរាជវង្សក្សត្រនេះ សោយរាជ្យមហានគរឈ្មោះឰយុធ្យា តាំងនៅតាមមាត់ទន្លេសយ៌ូក្នុងដែនកោសលរដ្ឋ នគរនេះមានទទឹង ១០យោជន៍ បណ្តោយ ១២យោជន៍ ។

ព្រះបាទទសរថទ្រង់ប្រារព្ធធ្វើពិធីអស្វមេធបូជាសេះស ចំពោះព្រះអគ្គីដើម្បីសុំបុត្រ ។ ក្នុងពិធីនេះ ព្រះបាទទសរថទ្រង់អញ្ជើញឥសីដ៏មានឈ្មោះល្បីក្នុងព្រាហ្មណ៍សាសនាដូចជា សិដ្ឋមុនីជារាជបុរោហិត ព្រះទេពមុនី ជាភូឈួយបុរោហិត ព្រះសុយញ្ញមុនី ព្រះជាលីមុនី ព្រះកស្សបមុនី ហើយនិងព្រះឫស្សស្រឹង្គមុនី ។ ក្នុងពិធីនេះទៀតទ្រង់បានអញ្ជើញក្សត្រនគរជិតខាងជាច្រើនមកជាអធិបតីដូចជា

- ព្រះជនកសុរិយវង្ស គ្រងរាជ្យនគរមិថិលានៃដែនវិទេហៈ
- ព្រះថៅនគរពារាណសី នៃដែនកាសី
- ព្រះបាទអស្វបតី គ្រងរាជ្យកេកយៈជនបទ

- ព្រះថៅលោមបាទ គ្រងនគរអង្គតរាស្ត្រ
- ព្រះថៅមគធរាស្ត្រ ហើយនិងស្តេចគ្រងរាជ្យនៅជនបទក្នុងបូព៌ាប្រទេស សន្ធិប្រទេស លោវិទេស សុរាស្ត្រ ហើយនិងទក្ខិណទេស។

នៅខណៈដែលប្រារព្ធធ្វើពិធីអស្សមេធនេះ នៅឯទេវលោក ពួកទេវតាទាំងឡាយ បានចូលទៅគាល់ព្រះព្រហ្ម ដើម្បីសុំប្រហារ ទសកណ្ឌរាវណៈ ដែលធ្វើទុក្ខបុកម្នេញពួកឥសីនិងព្រាហ្មណ៍។ ព្រះព្រហ្មអារាធនាព្រះនារាយណ៍ ដែលមកក្នុងទីប្រជុំនោះដែរ ឱ្យចុះមកស្ថានមនុស្សលោក ដើម្បីប្រហារទសកណ្ឌ។

នៅក្នុងពិធីនេះ មានមនុស្សម្នាក់ខ្លួនខ្ចៅធំដំបង មុខក្រហម ស្លៀកពាក់ក្រហម មានរោមជុះពេញខ្លួនដូចរាជសីហ៍ មានពុកមាត់និងសក់ល្អ កាន់ភាជន៍មធុបាយាសផុសឡើងកណ្តាលគំនរឆើកភ្លើង ហើយសម្តែងថា ខ្លួនជាទូតនៃប្រជាបតីនាំបាយមធុបាយាសមកថ្វាយព្រះមហេសីព្រះបាទទសរថសោយ។ ព្រះបាទទសរថចែកបាយនេះទៅជា ៤ចំណែក ប្រទានឱ្យព្រះនាងកៅសល្យា អគ្គមហេសីមួយចំណែក ព្រះកែកេយីមហេសីទីពីរមួយចំណែក ហើយនិងព្រះនាងសុមិត្រាមហេសីពៅមួយចំណែក។ លំដាប់មកនាងទាំងបីក៏មានគភ៌។

ពពួកទេវតា បែងភាគរបស់ខ្លួនទៅកើតជាបរិវារនៃព្រះនារាយកាឡា គឺមាន : ព្រះព្រហ្មបានសាងជម្ពូវានៈ ព្រះឥន្ទ្របានសាងពាលី"វ៉ាលីន" ព្រះអាទិត្យបានសាងសុគ្រីព"សុគ្រីវៈ" ព្រះពាយុបានសាងហនុមាន "ហនុមាន" ព្រះវិស្វកម្មបានសាង "នលៈ" ព្រះព្រហស្បតិបានសាង "តារៈ" ព្រះកុវេរៈបានសាង "គន្ធមាទន៍" ព្រះបញ្ជរបានសាង "សព្ទ" និងព្រះអស្ទិនបានសាង "មេន្ទៈនិងទ្វិនៈ"។

លុះគ្រប់ទសមាសា ព្រះនាងកៅសល្យាបានប្រសូត "ព្រះរាម" នាងកែកេយីបានប្រសូតព្រះភរត "ភិរុត" និងព្រះនាងសុមិត្រាបានប្រសូតព្រះលក្ស្មណ៍ "លក្ស្មណៈ" ព្រមទាំងព្រះសុត្រុឃន៍ "សុត្រុត"។

កាលដែលព្រះរាមមានព្រះជន្ម ១៦វស្សា ឥសីវិស្វាមិត្របានចូលមកទូលសុំព្រះបាទទសរថឱ្យព្រះរាមទៅជួយបង្ក្រាបពួករាក្សស ដែលជាពួកយក្សមានចិត្តអាក្រក់ឈ្មោះ មារិចៈនិងសុវាហុ អសុរៈទាំងពីរនេះជាកូនរបស់យក្ខិនីឈ្មោះ តារកា ដែលតែងតែប្រហារមនុស្សស៊ីជាអាហារនៅក្នុងនគរពីរទៀបឆ្នេរទន្លេសយ៊ូ។ យក្ខិនីនេះជាកូនរបស់ស្តេចយក្សឈ្មោះ សុកេតុ ហើយជាមហេសីស្តេចយក្សឈ្មោះ សុន្ទាសូរ។ កាលស្វាមីស្លាប់ទៅ នាងតារកានិងកូនឈ្មោះ មារិចៈ នាំគ្នាទៅធ្វើទុក្ខសេដ្ឋីឈ្មោះ អគ្គសត្យមុនី។ ឥសីខឹងដាក់បណ្តាសាឱ្យនាងតារកាទៅជាភ្នែក ហើយមារិចៈទៅជារាក្សសៈ។

ព្រះរាមយាងទៅជាមួយឥសីវិស្វាមិត្រ ហើយប្រហារនាងតារកាចោលទៅ។ ក្រោយមកនោះមារិចៈនិងសុវាហុ លើកទ័ពទៅសងសឹកជំនួសម្តាយ ប៉ុន្តែត្រូវព្រះរាមប្រហារចោលអស់។

ឥសីវិស្វាមិត្របានដំណឹងថា ព្រះបាទជនក នៅក្រុងមិថិលា រៀបធ្វើពិធីលើកធ្នូ ព្រះអង្គនាំព្រះរាម ព្រះលក្ស្មណ៍ទៅរួមក្នុងពិធីនោះ។ នៅតាមផ្លូវទៅក្រុងមិថិលា ឥសីនិងសិស្សបានទៅដល់នគរឈ្មោះ វិសលា ហើយសំណាក់នៅនឹងព្រះរាជាឈ្មោះ សុមតី អស់មួយយប់។ តមកព្រះអង្គយាងទៅដល់អាស្រមឥសីឈ្មោះ គោតមឬសី ដែលជាយាឈ្មោះ អហាលយា។ ព្រះអង្គជ្រាបនូវប្រវត្តិរបស់គោតមឬសី ដែលមានវិវាទជាមួយនឹងព្រះឥន្ទ្រ។ រឿងនេះដូចតទៅ ៖

ថ្ងៃមួយ ព្រះឥន្ទ្រក្លែងខ្លួនគោតមឬសីចូលទៅសាហាយស្មន់នឹងនាងអហាលយា។ ព្រះគោតមឬសីយាងមកទាន់ ក៏ដាក់បណ្តាសាឱ្យព្រះឥន្ទ្ររញ្ជិលិង្គ ហើយឱ្យនាងអហាលយារងទុក្ខទោសនៅតែក្នុងអាស្រម បរិភោគតែខ្យល់ចេញទៅណាពុំរួច ទាល់តែព្រះរាមបានយាងមកដល់អាស្រមទើបអស់បាប។ ហេតុដូច្នេះហើយ ទើបព្រះរាមយាងចូលទៅក្នុងអាស្រម ជួយសង្គ្រោះនាងអហាលយានេះ។

លុះដល់នគរក្រុងមិថិលា ព្រះស្តានន្ទមុនី ជាបុរោហិតរបស់ព្រះជនក ហើយជាបុត្ររបស់ព្រះគោតមព្រហ្មនិងអហាលយា ក៏ចេញមកទទួលព្រះរាម។ ព្រះបាទជនកទ្រង់ដំណាលរឿងធ្នូសរ ហើយនិងដំណើររបស់នាងសីតាថ្វាយព្រះរាម ព្រះលក្ស្មណ៍ស្តាប់ :

ប្រវត្តិធ្នូ : ធ្នូនេះជារបស់ព្រះឥសូរ។ ទេវតាបាននាំមកថ្វាយសម្តេចទេវរាជសុរិយវង្ស ជាមហារាជនគរមិថិលា។ ខណៈមួយនោះព្រះទក្សមុនីធ្វើពលិកម្ម ហើយបានអញ្ជើញព្រះឥសូរចូលមករួបរួមផង។ ព្រះឥសូរក្រោធខឹង ក៏យាងទៅទំលាយពិធីនោះបាញ់ព្រះទក្សបង្ក្រាបទេវតានឹងធ្នូនេះ។ ព្រះឥសូរប្រទានធ្នូនេះទៅដល់ទេវតាឈ្មោះ ទូយទេវៈ។ ទូយទេវៈនាំយកធ្នូនេះមកធ្វើទុកនៅនឹងបុព្វបុរសព្រះជនក ដើម្បីថែទាំ។

ជីវប្រវត្តិនាងសីតា : នៅដើមវស្សន្តរដូវ ព្រះជនកប្រារព្ធធ្វើពិធីច្រត់ព្រះនង្គ័ល។ ខណៈនោះព្រះអង្គវីសបានទេពកញ្ញាមួយ ដែលផុសឡើងតាមគន្លងនង្គ័លយកមកចិញ្ចឹម ធ្វើជារាជបុត្រីដាក់ឈ្មោះថា នាងសីតា។ លុះនាងសីតា ចម្រើនវ័យពេញក្រមុំ ព្រះបាទជនកប្រារព្ធធ្វើពិធីលើកធ្នូសរនេះ ដើម្បីជ្រើសរើសនូវរាជសុណិសា។ ខណៈនោះព្រះរាជបុត្រស្តេច ១០១នគរ ចូលមកសំដែងឫទ្ធិបារមីលើកធ្នូសរ តែពុំអាចធ្វើឱ្យរង្គើឡើយ ហើយនាំគ្នាខឹងឡោមព័ទ្ធក្រុងមិថិលាអស់មួយឆ្នាំ។ ព្រះបាទជនកមានព្រះកង្វល់ ហើយយាងទៅសុំពលទេពតាឱ្យចុះមកជួយកំចាត់ ក្សត្រទាំងឡាយបរាជ័យរត់អស់។ ក្រោយនោះ ព្រះរាមដែលមកដល់ក្រោយគេជាមួយឥសីវិស្វាមិត្រនិងព្រះលក្ស្មណ៍ ក៏លើករតនធ្នូចាប់យឺតខ្សែ បណ្តាលឱ្យបាក់ចំកណ្តាលដង។ ព្រះជនកទតឃើញដូច្នេះក៏រីករាយ ហើយទ្រង់បញ្ជូនរាជទូតឱ្យទៅអញ្ជើញព្រះបាទទសរថមកធ្វើពិធីរាជាភិសេក ផ្សំផ្គុំព្រះរាមនិងនាងសីតា ព្រះលក្ស្មណ៍និងនាងឧរមិលា ជារាជបុត្រីព្រះបាទជនកដែរ ព្រះភរតជាគូនឹងនាងមានទវី ជារាជធីតាព្រះបាទស្រីធវជ្រៈ ហើយនិងព្រះសុត្រុឃន៍ជាមួយនាងសរុតកេរ្តិ៍ជារាជបុត្រីព្រះបាទស្រីធវជ្រៈដែរ។

ព្រះបាទស្រីធវជ្រៈនេះ ជាបងព្រះជនក គ្រងរាជ្យនគរសង្កាសយា។ លុះរៀបរាជាភិសេក រួចហើយ ព្រះបាទទសរថក៏លាព្រះជនកនាំព្រះរាមនិងនាងសីតា ព្រមទាំងរាជបរិពារវិលមកនគរ ក្រុងពួយុធ្យាវិញ។

លុះមកដល់កណ្តាលផ្លូវ ព្រះបាទទសរថបានជួបនឹងព្រាហ្មណ៍ម្នាក់កាចសាហាវឈ្មោះ បរសុរាម ឬរាមបរសុ។ ព្រាហ្មណ៍នេះជាត្រកូល ភឫគុ ហើយជាកូនរបស់ព្រាហ្មណ៍ឈ្មោះ ជមទគ្និ។ រាមបរសុសំឡុតព្រះបាទទសរថ ហេតុដូចម្តេចបានជាហ៊ានយកឈ្មោះរបស់ខ្លួនទៅដាក់ឱ្យកូនឯងថា ព្រះរាមដែរ។ ហើយកំហែងព្រះរាមថា បើអាចកាច់ធ្នូរបស់ខ្លួនបាក់ ទើបខ្លួនស្គាល់ថាជាវិស្ណុអវតារ។

ព្រះរាមទទួលយកធ្នូរបស់ព្រាហ្មណ៍កំលោះយឺតឡើងបម្រុងបាញ់សម្លាប់ព្រាហ្មណ៍ ប៉ុន្តែគិតថា បរសុរាមជាព្រាហ្មណ៍គួរឱ្យគោរព បើនឹងសម្លាប់ជាការមិនគួរ។ ដូច្នេះគួរឱ្យព្រាហ្មណ៍ជ្រើសរើសយក ទណ្ឌកម្មមួយក្នុងទណ្ឌកម្មពីរ គឺកម្ទេចស្ថានសួគ៌របស់ព្រាហ្មណ៍ដែលបម្រុងនឹងបាន និងទំលាយនូវ ចំណេះវិជ្ជាទាំងឡាយរបស់ព្រាហ្មណ៍ ដែលសម្រេចហើយ។ ព្រាហ្មណ៍គិតថាស្ថានសួគ៌កម្រកបាន។ ដូច្នេះសុំឱ្យព្រះរាមធ្វើទណ្ឌកម្ម រំលាយចំណេះវិជ្ជារបស់ខ្លួនចោល ហើយអនុញ្ញាតឱ្យទៅនៅស្ថានសួគ៌ចុះ។ ព្រះរាមក៏សម្រេចតាមបំណង។ តមក ព្យូហយាត្រាក៏បានទៅដល់ក្រុងពួយុធ្យា។

កាន្ឋទី ២ : អយុធ្យាកាន្ឋ

លុះមកដល់នគរ ព្រះបាទទសរថប្រារព្ធធ្វើពិធីរាជាភិសេកព្រះរាមឱ្យឡើងជាព្រះយុវរាជ។ នាងទាសីគមម្នាក់ឈ្មោះមន្ថរាបានដឹងរឿងនេះក៏ទៅញុះញង់នាងកៃកេយី ដើម្បីជំទាស់ក្នុងរឿងនេះ។ នាងកៃកេយីបានរំលឹកនឹកឃើញដល់សត្យវាចារបស់ខ្លួន ដែលបានធ្វើជាមួយនឹងព្រះបាទទសរថ នៅពេលដែលមានជ័យជំនះលើស្តេចអាទិត្យសុរិយា។ នាងកៃកេយីបានចូលមកសុំព្រះបាទទសរថរាជស្វាមី ដើម្បីឱ្យព្រះភរតៈបុត្ររបស់ខ្លួនឡើងជាព្រះយុវរាជ។ នាងសុំឱ្យនិរទេសព្រះរាមចេញពីនគរទៅនៅព្រៃចំនួន ១៤ឆ្នាំ។ សេចក្តីសម្រេចកើតមានឡើងក្នុងខណៈនោះ។ ដូច្នេះព្រះរាម នាងសីតា ព្រមទាំងព្រះលក្ឃ្មណ៍នាំគ្នាចេញពីនគរ ដើម្បីចូលព្រៃទៅបួសជាឫសី។ ក្សត្រទាំងបីយាងទៅដល់ឆ្នេរទន្លេគង្គា។ នៅទីនោះគុហៈ "កូវ៉ន" ជាមេនៃអ្នកនេសាទ បាននាំកូនចៅយកទូកក្តារមកចម្លងក្សត្រទាំងបី ទៅដាក់ត្រើយនាយ។ ក្សត្រទាំងបីបានទៅដល់សំណាក់អាស្រមបទរបស់ឥសីឈ្មោះ ភរទ្វាជៈ នៅតំបន់មួយឈ្មោះ ប្រយាគ ហើយក៏សំណាក់នៅទីនោះអស់មួយរាត្រី។ តមកព្រះអង្គយាងទៅដល់ភ្នំ ចិត្រកូដ សំណាក់នៅក្នុងអាស្រមឥសី វាល្មិកិ។

នៅឯក្រុងពួយុធ្យាវិញ ព្រះបាទទសរថកាលបើព្រាត់រាជបុត្រជាទីស្នេហា ក៏កើតទុក្ខព្រួយធ្លាក់ខ្លួនឈឺរហួតដល់ស្លាប់។ ខណៈនោះព្រះភរតៈ គង់នៅជាមួយព្រះសុត្រុឃ្ន នៅនគរកេកយៈ ជាមួយនឹងអយ្យកោព្រះនាមព្រះបាទ អសូបតិ។ ក្សត្រទាំងពីរបានដំណឹងថា ព្រះរាមបានទទួលរាជាភិសេក

មានចិត្តរីករាយយាងត្រឡប់មកក្រុងពួយុធ្យាវិញ។ លុះមកដល់ទីក្រុង ព្រះភរតៈដឹងច្បាស់ថា ព្រះចិតាសុគត ហើយព្រះរាមត្រូវនិរទេស ក៏ទៅជាខឹងនឹងព្រះមាតាគិតប៉ងប្រហារ ប៉ុន្តែព្រះសុត្រុយន៍បានឃាត់កុំឱ្យធ្វើដូច្នោះ។ តមកព្រះវិសិដ្ឋមុនីជារាជបុរោហិតនិងព្រះរាមទេវមុនី ភូឈួយបុរោហិតបានអញ្ជើញព្រះភរតៈថ្វាយព្រះភ្លើងចំពោះសពព្រះបាទទសរថ។

រំលងមកបានពីរថ្ងៃ ពួកអាមាត្យមន្ត្រីព្រមព្រៀងគ្នាអញ្ជើញព្រះភរតៈគ្រងរាជសម្បត្តិ ប៉ុន្តែព្រះអង្គពុំព្រមសោះ។ ទ្រង់សម្រេចធ្វើដង្ហែពីក្រុងពួយុធ្យា ដើម្បីលើកកងទ័ពទៅកាន់ភ្នំចិត្រកូដ មួយអន្លើនិងព្រះសុត្រុយន៍ នាងកោសល្យា កៃកេយី និងនាងសុមិត្រា។ លុះទៅដល់ជើងភ្នំចិត្រកូដ ព្រះភរតៈឱ្យបញ្ឈប់ទ័ព ហើយទ្រង់យាងទៅរកព្រះរាមនៅលើភ្នំ។ ឃើញតែព្រះភរតៈ ព្រះរាម ព្រះលក្ខ្មណ៍ និងនាងសីតានាំគ្នាខ្សឹកខ្សួល។ ព្រះភរតៈសុំអញ្ជើញឱ្យព្រះរាមយាងទៅគ្រងរាជ្យវិញ ប៉ុន្តែក្សត្រអង្គនេះប្រកែកដាច់អហង្ការ។ ព្រភរតៈក្រាបបង្គំទូលសុំសុពណ៌បាទុកអំពីព្រះរាម ដើម្បីជាតំណាងត្រឡប់ចូលទៅកាន់នគរវិញ។ លុះមកដល់នគរពួយុធ្យា ព្រះភរតៈពុំព្រមនៅក្នុងរាជវាំងឡើយ ហើយក៏តាំងទីនៅតំបន់ឈ្មោះ នន្ទិគ្រាមក្នុងដែនកោសល។ ព្រះអង្គចាត់ឱ្យរាជសុពណ៌បាទុករបស់ព្រះរាមទៅប្រតិស្ឋាននានាក្រោមស្មេតច្ឆត្រ។ ក្សត្រទាំងពីរ គឺព្រះភរតៈនិងសុត្រុយន៍ កាន់ភេទជាទីយោគីដោយប្រគល់កិច្ចការរដ្ឋប្រទានចំពោះរាជបុរោហិត។ ចំណែកឯព្រះរាមវិញ ក្រោយនោះទ្រង់ជ្រាបថា ក្រុងខរ ដែលជាប្អូនរាវណៈ បានមកតាំងទីនៅក្បែរជលសារ ហើយធ្វើបាបពួកឥសីជាខ្លាំង។ ព្រះរាមលាឥសីវាល្មិកទៅតាំងទីនៅជិតក្រុងខរ ដើម្បីបានឱកាសការពារឥសី។ ត្រីក្សត្របានចេញពីចិត្រកូដមហាគីរីធ្វើដំណើរទៅនមស្ការឥសីព្រះនាម អត្រិមុនីនិងនាងអគ្គសួយា ហើយបន្តដំណើរទៅដល់ព្រៃឈ្មោះ ទណ្ឌក: ឋិតនៅជិតស្ថានជាព្រំដែនរបស់ក្រុងខរ។

(ដកស្រង់ចេញពីរឿងរាមាយណៈឥណ្ឌា កាន្ទទី ១និងកាន្ទទី ២ របស់លោក លាង ហាប់អាន)

សំណួរ

១. ចូរប្រាប់ឈ្មោះតួអង្គសំខាន់ៗក្នុងកាន្ទទី ១និងកាន្ទទី ២។

២. តើអត្ថបទដកស្រង់ក្នុងកាន្ទទី ១និងកាន្ទទី ២ និយាយពីអ្វី ?

៣. ចូរប្រៀបធៀបអត្ថបទដកស្រង់ក្នុងកាន្ទទី ១និងកាន្ទទី ២ នៅនឹងអត្ថបទដកស្រង់ ដែលអ្នកបានសិក្សាក្នុងមេរៀនមុនក្នុងរឿង រាមកេរ្តិ៍ ខ្សែទី ១និងខ្សែទី ២។

៤. តើរាមកេរ្តិ៍និងរឿងរាមាយណៈ មានទំនាក់ទំនងនិងឥទ្ធិពលទៅលើគ្នាដូចម្តេចខ្លះ ?

៥. តើតួអង្គព្រះរាមក្នុងរឿងរាមកេរ្តិ៍ខុសពីព្រះរាមក្នុងរឿងរាមាយណៈដូចម្តេចខ្លះ ?

ទិដ្ឋភាពវប្បធម៌ខ្មែរក្នុងរឿងហង្សយន្ត



ក. សិក្សាពាក្យគន្លឹះ

- អគ្គមហេសី (ន) : មហេសីធំចម្បង (អគ្គទេវី) របស់ព្រះរាជា ។
- អានុភាព (ន) : អំណាច តេជៈ ។
- សេវកាមាត្យ (ន) : មន្ត្រីអ្នកគាល់បម្រើរាជា ។
- អធិដ្ឋាន (កិ) : បួងសួង ។
- អាសនៈ (ន) : ទីអង្គុយ កន្លែងអង្គុយ ។
- សក្កទេវរាជ (ន) : ព្រះឥន្ទ្រាធិរាជ ។
- បដិសន្ធិ (កិ) : ចាប់កំណើត ។
- ហឫទ័យ (ន) : បេះដូង ដួងចិត្ត ។
- ប្រតិព័ទ្ធ (កិ) : ស្រឡាញ់ជាប់ចិត្ត ។
- ពេជ្ឈឃាត (ន) : អ្នកពិឃាតឬសម្លាប់មនុស្សទោស ។

- ព្រះឧទរ (ន) : ពោះ ។
- ព្រះហស្ត (ន) : ដៃ ។
- អាមាត្យ (ន) : មន្ត្រីស្និទ្ធបម្រើរាជា ។
- ទ្រង់ព្រះកន្សែង (កិ) : យំ ។
- ព្រះបាទា (ន) : ជើង ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអ្នកអានអត្ថបទដកស្រង់នេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ ហើយកត់ចំណាំសេចក្តីលំអិតសំខាន់ៗនិងខ្លឹមសារនៃរឿងទាំងមូល ដើម្បីឆ្លើយនឹងសំណួរមួយចំនួនទាក់ទងនឹងអត្ថន័យអត្ថរូប និងអត្ថរសនៃរឿងឱ្យបានត្រឹមត្រូវ ។

គ. អត្ថបទ

- **ប្រភពនិងរចនាបទរឿង :** រឿងហង្សយន្តនេះគ្មានក្នុងគម្ពីរបញ្ញាសជាតកបាលី ឬគម្ពីរបាលីណាទេ ។ តាមការពិនិត្យផ្ទៀងផ្ទាត់ក្នុងគម្ពីរបញ្ញាសជាតក ២ យើងឃើញមានរឿងទី ១៥ ដែលមានតួអង្គឯកឈ្មោះ **សុវណ្ណកុមារ** ដូចក្នុងរឿងហង្សយន្ត ហើយឈ្មោះនេះជាចំណងជើងរឿង តែផ្ទៃរឿងនិងអត្ថន័យខុសគ្នាស្រឡះ មានតែឈ្មោះតួអង្គពោធិសត្វមួយប៉ុណ្ណោះដែលស្របគ្នា ។

រចនាបថរឿងហង្សយន្ត ជាអត្ថបទកំណាព្យបែបចាស់បុរាណ គឺមានបទកាកគតិ ព្រហ្មគតិ ពំនោល ភជុង្គលីលា គឺជាអត្ថបទល្បែងសម្រាប់អានកំសាន្តអារម្មណ៍លេងរបស់ជនានុជនខ្មែរយើងនៅសម័យកណ្តាល គឺជាអត្ថបទគ្មានឈ្មោះ គ្មានកវីនិពន្ធ គ្មានកាលបរិច្ឆេទ គឺគ្មានបានប្រាប់ថ្ងៃ ខែ ឆ្នាំ ដែលបានតាក់តែងរឿង តែតាមទម្រង់ភាសានិងទម្រង់រចនាបថកំណាព្យកាព្យឃ្លោង រឿងហង្សយន្ត ច្បាប់ពុទ្ធសាសនបណ្ឌិតដែលមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរយកមកបោះពុម្ពឡើងវិញនេះ និពន្ធឡើងប្រហែលនៅចន្លោះសតវត្សទី ១៧-១៨ ។

តែតាមការស្រាវជ្រាវរបស់ព្រះមហា **រស់ ឈុត** និងអ្នកស្រី **ឈុន ខុន** លើកាលបរិច្ឆេទរឿងហង្សយន្ត ដោយប្រៀបធៀបលើសាស្ត្រាស្លឹករឹតនានានិងសៀវភៅបោះពុម្ពទាំងឡាយនៅស្រុកខ្មែរបានបញ្ជាក់ឱ្យឃើញនាមអ្នកនិពន្ធ ពេលវេលាតែងរឿង ក្នុងរជ្ជកាលស្តេចគ្រងរាជ្យ ពោលគឺរឿងហង្សយន្ត និពន្ធឡើងដោយចៅយមបុណ្យភក្តិ **ឧក** នៅក្នុងមហាសករាជ ១៥៩០ ដែលត្រូវនឹងឆ្នាំមមែ នព្វស័ក គ.ស. ១៦៦៨ ក្នុងរាជ្យព្រះជ័យចេស្តាវាមាឥសូរសុរិយោវង្ស ។ ដូចនេះរឿងហង្សយន្ត ជាផលិតកម្មអក្សរសាស្ត្រក្នុងសតវត្សទី ១៧ ស្រករគ្នានឹងរឿង **ខ្សែសង្វ** របស់ឧកញ៉ា សុភា

ធិបតី "អ៊ុក" ដែរ។ តែរឿងហង្សយន្ត នៃពុទ្ធសាសនបណ្ឌិត ដែលមជ្ឈមណ្ឌលឯកសារស្រាវជ្រាវអរិយធម៌ខ្មែរយកមកបោះពុម្ពផ្សាយឡើងវិញនោះ បាត់លំនាំដើមអ្នកនិពន្ធបានជាគ្មានបញ្ជាក់នាមកវី និងពេលវេលាតែងរឿង។

តាមកាលបរិច្ឆេទ ដែលបានដោះស្រាយរួចមកហើយ រឿងហង្សយន្ត ជាការរៀបរៀងក្នុងជំនាន់រឿង ខ្សែសង្វ របស់ឧកញ៉ាសុភាធិបតី "អ៊ុក" តែហេតុអ្វីបានជាអ្នកនិពន្ធប្រែរឿងនេះក្នុងជំនាន់ហ្នឹងមកជាពាក្យខ្មែរវិញណា... មានន័យថា រឿងនេះមុនជារបស់ខ្មែរ រួចមានគេលួចប្រែទៅជាសៀម ដូចនេះហើយដើម្បីកុំឱ្យបាត់សម្បត្តិអក្សរសាស្ត្រខ្មែរ អ្នកនិពន្ធខ្មែរត្រូវបកប្រែមកជា "ពាក្យខ្មែរវិញ"។

រឿងហង្សយន្ត មានទម្រង់រួបរាងបែបរឿង ជាតក គឺតួអង្គឯកជាពោធិសត្វ ចុះមកចាប់បដិសន្ធិនៅស្ថានមនុស្សលោកដូចឃើញក្នុងផ្តើមសេចក្តីរឿងស្រេច ៖

និទានកាលសម្តេច	ព្រះសពេ៌ជ្ញ សម្ពុទ្ធា
ស្តេចសាងបារមិតា	ពុំទាន់ត្រាស់ជាពង្សពុទ្ធ។
អន្ទោលទៅដោយខ្នាត	ព្រះយកជាតិជាក់ប្រាកដ
ជាស្តេចស្តែងសន្ធត	នាមព្រះសុវណ្ណកុមារ។
ព្រះអង្គគ្រាច់រង្គាត់	នៅក្នុងវដ្តសង្សារ
ស្តេចសាងព្រះសម្ភារ	ពុំទាន់ទុំព្រះបារមី។

ឯតួអង្គឯកស្រី ជាកន្សែសារពេជ គឺជាអគ្គមហេសីព្រះបរមពោធិសត្វ ហើយដល់ទីបញ្ចប់ គឺតួអង្គឯកប្រុសសជាតិជាពុទ្ធអង្គ តួអង្គស្រីជានាងពិម្ពា។ ឯតួអង្គឯទៀត ក៏សជាតិជាលំដាប់តៗគ្នាទៅទៀតតាមកម្មផលរបស់ខ្លួនម្នាក់ៗ។

- ចំណងជើងរឿង : បណ្តារឿងល្បែងខ្មែរនានា កវីនិពន្ធតែងយកឈ្មោះតួអង្គឯកក្នុងរឿងមកដាក់ជាចំណងជើងរឿង ប្លែកតែរឿង ហង្សយន្ត កវីនិពន្ធយើងត្រឡប់យកយានជំនិះគ្មានវិញ្ញាណ ដែលហោះហើរលើអាកាសបាន ដោយគ្រឿងយន្តមកធ្វើជាចំណងជើងរឿងវិញ។ តាមការសង្កេតឃើញថា តួអង្គក្នុងរឿងល្បែងជាច្រើនតែងហោះហើរលើអាកាស អាស្រ័យលើមន្តអាគម សិល្ប៍សាស្ត្រ ឬដំបងសិល្ប៍ ច្រត់សិល្ប៍ ឬយក្ស សត្វឥន្ទ្រី សេះឬដំរីហោះ។ ពោលគឺការហោះហើយលើអាកាស អាស្រ័យលើមន្តសិល្ប៍សាស្ត្រនិងសត្វមានវិញ្ញាណដែលមានឥទ្ធិឫទ្ធិ ជាអច្ឆរិយៈហួសអ្វីដែលជាភាពមនុស្ស ផ្ទុយទៅនឹងរឿងហង្សយន្ត សុវណ្ណកុមារហោះហើរលើអាកាសបានអាស្រ័យទៅលើយានជាគ្រឿងឆ្នៃប្រឌិត ដោយសិប្បករជារូបហង្ស

ដោយបន្ថែមគ្រឿងយន្តជាឧបករណ៍ហោះហើរបានដូចជា យន្តហោះសព្វថ្ងៃ។ ធាតុទាំងនេះបង្ហាញថា កវីនិពន្ធខ្មែរយើងមានអារម្មណ៍ប្រឌិតអ្វីដែលច្នៃស្ថាបនាឡើង ដោយប្រាជ្ញា ចំណេះវិជ្ជានៃសិប្បករ ឬវិស្វករ បែបអ្នកនិពន្ធបារាំង ស៊ុល វែន ដែរ។

អ្វីទៅសត្វហង្ស ហើយអ្វីទៅដែលហៅថាយន្ត ?

ពាក្យ "ហង្ស" ជាពាក្យបាលី "ហំសា" ជាពាក្យសំស្ក្រឹត គឺសំគាល់សត្វស្លាបមានសណ្ឋានបែបសត្វក្ងានព្រៃ គឺជាយានជំនិះព្រះព្រហ្ម។

ពាក្យ "យន្ត" ជាពាក្យបាលី ឯ "យន្ត្រ" ជាពាក្យសំស្ក្រឹត គឺសំគាល់អ្វីដែលជាគ្រឿងចក្រត្រូវនឹងពាក្យបារាំងថា "ម៉ាស៊ីន"។

ក្នុងបណ្តាអត្ថបទអក្សរសាស្ត្រនានា យើងប្រទះឃើញ ហង្សយន្តមានក្នុងអត្ថបទល្បែងពីរ គឺមួយក្នុងរឿង ព្រះជិនវង្ស និងមួយទៀតឃើញក្នុងរឿង ហង្សយន្តនេះឯង។ តែហង្សយន្តក្នុងរឿងបន្ទាប់នេះ មានសារៈសំខាន់ក្នុងស្ថាបនារឿង បានសេចក្តីថា មានការប្រទាក់ក្រឡាជាទំនាក់ទំនងរឿងរចនាឡើងនៅលើជុំវិញយានជំនិះនេះឯង ពោលគឺតួអង្គឯក សុវណ្ណកុមារចេញទៅរៀនវិជ្ជាសិល្ប៍សាស្ត្រនឹងគ្រូទិសាបាមោក្ខក៏ដោយហង្សយន្ត បានជួបស្នេហ៍ស្និទ្ធជាមួយនឹងនាង បទុមកេសរក៏ដោយសារហង្សយន្ត រួចខ្លួនពីស្លាប់ក៏ដោយសារហង្សយន្ត ព្រាត់ប្រាស់ប្រពន្ធក៏ដោយសារនេះខ្សែហង្សយន្ត ហើយទីបញ្ចប់បានត្រឡប់ចូលទៅនគរវិញក៏ដោយសារហង្សយន្ត។

ប្រសិនបើកវីនិពន្ធរឿងនេះមានគំនិតរក្សានិយម បែបកវីនិពន្ធនានានៅសម័យនោះ គួរតែដាក់ចំណងជើងថា "រឿងព្រះសុវណ្ណកុមារ" ដែលជាតួអង្គឯក។ តែផ្ទុយទៅវិញកវីនិពន្ធមានគំនិតឆ្នៃប្រឌិតបានយកយានជំនិះជាគ្រឿងយន្តមកឱ្យចំណងជើងរឿងទៅវិញ ពោលគឺរឿងហង្សយន្តនេះឯង។

- **ដំណើររឿងហង្សយន្ត**

ក្នុងកាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គ ព្រះអាទិត្យវង្សា អគ្គមហេសីព្រះនាមពិម្ពាជាស្តេចមានអានុភាពជាងស្តេចទាំង ១០១ មានព្រះស្នំ ៦ពាន់ តែងគាល់បម្រើ សោយរាជ្យនៅក្រុងទេពបុរី។ ព្រះស្នំទាំង ៦ពាន់នោះ សឹងពុំមានបុត្រាមួយសោះ។ ពួកសេវកាមាត្យ ខ្លាចសាបសូន្យព្រះនគរ ក៏ក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ព្រះនគរយើង បើឥតពីព្រះអង្គទៅនឹងពុំមានក្សត្រណាមួយសោយរាជ្យតទៅឡើយ"។ ព្រះរាជា ទ្រង់ត្រាស់បង្គាប់ព្រះនាងពិម្ពាព្រះអគ្គមហេសី ឱ្យប្រដាប់ផ្កាភ្ញីបួជាពួកទេវតា ឱ្យទាន ចាំសីលអធិដ្ឋានសូមព្រះរាជបុត្រាមួយព្រះអង្គ។ ព្រះនាងក៏ទ្រង់ធ្វើតាមព្រះរាជបញ្ជា។ ដោយអំណាចបុណ្យបារមីនៃព្រះនាង ក៏កក្រើកទៅដល់អាសនៈនៃសក្កទេវរាជ។ ទ្រង់បើកទិព្វចក្ខុមើលហេតុសព្វគ្រប់ ទ្រង់អារាធនាព្រះបរមពោធិសត្វ ដែលជាទេវបុត្រមួយ

ព្រះអង្គ ឱ្យចុះមកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាងពិម្ពា។ លុះព្រះគភ៌គ្រប់ ១០ខែហើយ ក៏ប្រសូតព្រះរាជបុត្រ ១ព្រះអង្គ មានសម្បុរដូចមាស។ ពួកព្រាហ្មណ៍ថ្វាយព្រះនាមថា "ព្រះសុវណ្ណកុមារ"។ លុះមានព្រះជន្ម ១៦វស្សា ព្រះវររាជបិតាទ្រង់ឱ្យនាំព្រះរាជធីតានៃស្តេចទាំង ១០១មកថ្វាយ តែព្រះរាជកុមារពុំសព្វព្រះរាជហឫទ័យសោះ ទ្រង់ទូលព្រះវររាជបិតាថានឹងស្វែងរកព្រះអគ្គមហេសីផ្ទាល់ព្រះអង្គ។ គ្រានោះ មានជាងពីរនាក់ ជាងម្នាក់ចេះធ្វើប្រាសាទនិងក្បាច់រចនាផ្សេងៗ ម្នាក់ទៀតចេះធ្វើរូបសត្វដូចជា រូបគ្រុឌ ក្អែកជាដើម។ មានខ្សែទាញ អាចជិះហោះដ៏អាកាសបាន។ ព្រះរាជា ទ្រង់ព្រះរាជបញ្ជាឱ្យជាងពីរនាក់នេះធ្វើហង្សយន្តមួយ ជាព្រះទីន័ងសម្រាប់គង់ហោះទៅកាន់ទីផ្សេងៗ។ លុះជាងពីរធ្វើហើយ ព្រះរាជាទ្រង់គង់លើហង្សយន្តទៅកាន់ទីនានា មានព្រៃហិមពាន្តជាដើម។

ឯព្រះរាជកុមារ ទ្រង់មានព្រះបំណងចង់ចេញទៅរៀនសិល្បៈសាស្ត្រ ក៏ទ្រង់ចូលទៅទូលលាព្រះវររាជមាតាបិតា។ ទ្រង់អនុញ្ញាត ហើយប្រគល់ហង្សយន្តដល់ព្រះរាជកុមារ។ ទ្រង់គង់លើហង្សយន្តនោះ ហោះទតព្រៃព្រឹក្សាចំនួន ៣សប្តាហ៍ ចូលដល់នគរបញ្ចាល ទ្រង់ទុកហង្សយន្តលើឈើធំ ១ដើម ហើយយាងចូលទៅសំណាក់ផ្ទះថៅព្រាហ្មណ៍ហោរាម្នាក់ ដែលជាបុរោហិតព្រះថៅក្រុងបញ្ចាល សុំរៀនសិល្បសាស្ត្រ។ មិនយូរប៉ុន្មាន ព្រះសុវណ្ណកុមារ រៀនចេះសិល្បសាស្ត្រយ៉ាងស្ទាត់ជំនាញ។ ព្រាហ្មណ៍ហោរា បានសុំព្រះអង្គធ្វើជាកូនធម៌ តែងនាំព្រះអង្គទៅគាល់ព្រះថៅក្រុងបញ្ចាលរាល់ថ្ងៃ។

ឯព្រះថៅក្រុងបញ្ចាល ព្រះអង្គមានព្រះរាជធីតាមួយព្រះអង្គ ព្រះនាមបទុមកេសរ មានព្រះជន្ម ១៦វស្សា មានព្រះរូបល្អលើស្ត្រីក្នុងព្រះនគរនោះ។ ថ្ងៃមួយ ព្រះនាងទ្រង់ទតឃើញព្រះសុវណ្ណកុមារកំពុងយាងក្បែរប្រាសាទ មានព្រះទ័យចាប់ប្រតិព័ទ្ធចំពោះព្រះអង្គ អន្ទះអន្ទែងក្នុងព្រះទ័យ ផ្ទុំពុំលក់ មានព្រះឆវីវណ្ណសៅហ្មងខុសធម្មតា។ ស្រីបម្រើម្នាក់សួរព្រះនាងៗប្រាប់ថា "ទ្រង់មានសេចក្តីប្រតិព័ទ្ធចំពោះព្រះសុវណ្ណកុមារយ៉ាងខ្លាំង" រួចទ្រង់ប្រាប់ឧបាយឱ្យស្រីនេះ ទៅទូលព្រះសុវណ្ណកុមារ។ ស្រីបម្រើ ក៏ទៅទូលព្រះសុវណ្ណកុមារៗ សន្យាថានឹងមកកាន់ប្រាសាទព្រះនាងក្នុងពេលរាត្រី។ លុះពេលរាត្រី ព្រះសុវណ្ណកុមារ គង់លើហង្សយន្ត ទៅកាន់ប្រាសាទព្រះនាងបទុមកេសរ ហើយយប់ក្រោយតែងតែយាងមកយ៉ាងនេះ ដរាបព្រះនាងទ្រង់គភ៌។

ព្រះថៅក្រុងបញ្ចាលទ្រង់ជ្រាបថា ព្រះរាជធីតាមានគភ៌ ទ្រង់ធ្វើឧបាយឱ្យចាប់ព្រះសុវណ្ណកុមារបានឱ្យពេជ្ឈឃាជនាំទៅសម្លាប់។ ព្រះរាជកុមារបញ្ឆោតពួកពេជ្ឈឃាជ ឱ្យនាំព្រះអង្គទៅក្បែរគល់ឈើដែលទុកហង្សយន្ត ព្រះអង្គឡើងគង់លើហង្សយន្តនោះ ហោះមកកាន់ប្រាសាទព្រះនាងបទុមកេសរ ឱ្យព្រះនាងគង់លើហង្សយន្ត ហោះទៅត្រង់មុខប្រាសាទព្រះថៅក្រុងបញ្ចាល ស្រែកលាពីលើអាកាស ហើយទៅកាន់ក្រុងទេពបុរីវិញ។

លុះយាងទៅបាន ១សប្តាហ៍ ព្រះនាងបទុមកេសរទ្រង់ឈឺព្រះឧទរនឹងប្រសូតព្រះរាជបុត្រ។ ព្រះរាជកុមារ ចុះហាង្សយន្តឈប់ក្បែរឆ្នេរសមុទ្រ។ ព្រះនាង កាលបើប្រសូតរួចហើយ ទ្រង់រងាញាក់ ព្រះអង្គស្ទើរសន្លប់បាត់ស្មារតី ព្រះចក្រីទ្រង់ក្រឡេកមើលឃើញសំពៅមួយបើកកណ្តាលសមុទ្រ ក៏គង់ហាង្សយន្តទៅយកភ្លើង លុះត្រឡប់មកវិញភ្លើងក៏ឆេះខ្សែហាង្សយន្ត ក៏ធ្លាក់ព្រះអង្គក្នុងសមុទ្រទៅ។

រីឯព្រះនាងទេវី ចាំមើលព្រះស្វាមីពុំឃើញមក ទ្រង់ប៉ីព្រះរាជបុត្រទ្រង់ព្រះកន្សែងក្នុងព្រៃ លុះនឿយព្រះកាយពល យាងទៅទៀតពុំបានក៏ដោះចិញ្ចៀនព្រះទម្រង់ ចងភ្ជាប់នឹងព្រះហស្តព្រះរាជបុត្រ ហើយផ្តេកលើកម្រាលព្រះពស្ត្រ ក្រោមឈើក្រស្នាមួយដើម ហើយត្រាច់រកព្រះស្វាមីទៀត។

ថ្លែងពីព្រះសុវណ្ណកុមារ ទ្រង់ហែលក្នុងមហាសមុទ្រ ត្រូវនាយសំពៅម្នាក់រើសបាន។ ក្រោយមក មាននាយសំពៅម្នាក់ទៀតរើសបានរូបហាង្សយន្ត។

ថ្ងៃមួយមានក្សត្រមួយព្រះអង្គ ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងក្រុងពារាណសី ទ្រង់យាងទៅក្រសាលព្រៃហិមពាន្ត លុះយាងទៅទៀបឈើក្រស្នា ទតឃើញព្រះរាជកុមារនោះ ក៏រើសយកមកចិញ្ចឹមសន្មតព្រះនាមថា "ថៅក្រីស្នកុមារ"។

រីឯព្រះនាងទេវី កាលបើមិនជួបព្រះស្វាមី ក៏ត្រឡប់មកដើមក្រស្នាវិញពុំឃើញព្រះរាជបុត្រ ទ្រង់សោកសន្លប់បាត់ស្មារតី លុះដឹងស្មារតីវិញ ទតមើលឆ្វេងស្តាំ ឃើញជីទក់ទី ដឹងថាមាននរណារើសព្រះរាជបុត្រ ក៏យាងទៅតាមស្នាមទ័ពព្រះបាទពារាណសី ដរាបដល់ផ្ទះជួនចាស់តាចាស់នៅក្បែរព្រះនគរ។ គាត់ជាអ្នកក្រងផ្កាថ្វាយព្រះរាជា។ ព្រះនាង សុំជួនចាស់តាចាស់ធ្វើជាកូនធម៌ ហើយក្រងផ្កាថ្វាយព្រះរាជារាល់ថ្ងៃ ជំនួសជួនចាស់។

លុះថៅក្រីស្នកុមារ បានព្រះជន្ម ១៦វស្សា ព្រះបាទព្រហ្មទត្តទ្រង់ជ្រើសរើសព្រះធីតានៃក្សត្រនានា រហូតដល់កូនសេដ្ឋីគហបតី ឱ្យធ្វើជាអគ្គជាយា តែព្រះរាជកុមារពុំសព្វព្រះរាជហឫទ័យសោះ។ ស្រាប់តែអាមាត្យម្នាក់ ក្រាបទូលព្រះរាជា អំពីរូបសម្បត្តិរបស់ថៅយាយមាលា។ ព្រះរាជាទ្រង់ឱ្យនាំព្រះនាងបទុមកេសរនោះមក។ ព្រះរាជកុមារគ្រាន់តែឃើញព្រះនាងភ្លាម មានព្រះទ័យប្រតិព័ទ្ធយ៉ាងខ្លាំង។ ព្រះអង្គអភិសេកព្រះរាជកុមារនិងព្រះបទុមកេសរ តាមព្រះរាជប្រពៃណី ឱ្យគង់លើប្រាសាទមាសមួយដ៏ល្អឆើត។ ក្នុងយាមទី ១នៃរាត្រីនោះ ព្រះកុមារ ទ្រង់ចូលក្រឡាព្រះបន្ទំនាងបទុមកេសរ ស្រាប់តែមានទេពតាមួយអង្គមកបណ្តាលឱ្យមេឆ្នាំដើរទៅជិតកូនវា។ កូនឆ្នាំនិយាយថា នរណាអេះ ហ៊ានដើរលើក្បាលអញ។ មេវាឆ្លើយថា កូនកុំនិយាយដូច្នេះ យើងជាសត្វតិរច្ឆាន

ចំណង់បើមនុស្ស ម្តេចគេហ៊ានយកម្តាយឯងធ្វើភរិយា។ ព្រះរាជកុមារទ្រង់ព្រះសណ្តាប់ដូច្នោះ ក៏ត្រឡប់មកក្រឡាបន្ទំវិញ។ យាមទី ២ ទ្រង់ចូលទៅទៀត ស្រាប់តែមេនិងកូនពពែនិយាយពាក្យដូច្នោះទៀត។ ថ្ងៃមួយ ព្រះសុវណ្ណកុមារបានទៅដល់សាលាសំណាក់។ ព្រះសុវណ្ណកុមារបានទតរឿងរ៉ាវនៅលើសាលាឆទាន ទ្រង់តុកក្តួលចិត្តក្រៃលែង។ ពេលនោះព្រះនាងបទុមកេសរ ក៏ទ្រង់ព្រះកន្សែងសោយសោក ឯថៅក្រីស្នកុមារក៏ដូច្នោះដែរ ទាំងបីព្រះអង្គទ្រង់សោកាសន្ធប់នៅទីនោះ។ ព្រះរាជាព្រហ្មទត្ត ឱ្យអាមាត្យទៅទូលសួរអំពីរឿងសោកានៃក្សត្រទាំងបីព្រះអង្គ។ ព្រះសុវណ្ណកុមារមិនហ៊ានទូលត្រង់ទេ ទ្រង់ត្រាស់ថា ត្បិតយើងជាបងព្រះបទុមកេសរព្រាត់គ្នា ទើបតែនឹងបានជួបក្នុងគ្រានេះ។

ក្សិណនោះ ថៅក្រីស្នកុមារ យកហាង្សយន្តមកថ្វាយព្រះសុវណ្ណកុមារជាព្រះបិតា។ ព្រះអង្គទ្រង់រៀបចំហាង្សយន្តបានល្អដូចដើម ហើយប្រទានរង្វាន់ជាច្រើនដល់នាយសំពៅទាំងពីរ ព្រមទាំងយាយមាលា។ ក្នុងរាត្រីនោះ ថៅក្រីស្នកុមារ ទ្រង់សរសេរព្រះរាជសារមួយច្បាប់ បិទនៅទ្វារប្រាសាទ ក្រាបថ្វាយបង្គំលាព្រះបាទព្រហ្មទត្ត ហើយព្រះសុវណ្ណកុមារ ព្រះនាងបទុមកេសរ ហើយថៅក្រីស្នកុមារ ក៏ទ្រង់ឡើងគង់ហាង្សយន្ត ហោះទៅកាន់ក្រុងទេពបុរី ជាជាតិភូមិរបស់ព្រះអង្គដោយសិរីសួស្តី។

(ដកស្រង់ពីសៀវភៅ ហាង្សយន្ត របស់មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ

រៀបរៀងដោយលោក ឃឹង ហុកឌី ចោះពុម្ពឆ្នាំ ១៩៨៦ ទំព័រ ៨-៩)

សំណួរ

១. តើរឿងហាង្សយន្តមានតួអង្គសំខាន់ៗណាខ្លះ ? ចូររៀបរាប់ឈ្មោះ។

២. ហេតុអ្វីបានជាអ្នកនិពន្ធដាក់ឈ្មោះថា ហាង្សយន្ត ?

៣. តើរឿងហាង្សយន្តមានអត្ថន័យដូចម្តេច ?

៤. ផ្គែកតាមការស្រាវជ្រាវរបស់ព្រះមហា រស់ ឈុត និងលោកស្រី ឈុន ខុន តើរឿងនេះ មានអ្នកនិពន្ធឈ្មោះអ្វី ? តែងឡើងនៅឆ្នាំណា ? ក្នុងរជ្ជកាលស្តេចណា ?



ការបកស្រាយន័យសុភាសិត

អ្នកធ្លាប់បានសិក្សារួចមកហើយអំពីពាក្យស្លោកនិងសុភាសិត។ ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីការនិយាយបកស្រាយន័យរបស់សុភាសិត។

សុភាសិត ជាពាក្យមកពីបាលី។ "សុ ប្រែថា ល្អ" "ភាសិត ប្រែថា សំដីឬពាក្យ"។ បានសេចក្តីថា ជាពាក្យសំដីដែលពោលពីរោះ ល្អ ដែលនិយាយត្រូវ ថាត្រូវ។

សុភាសិត គឺជាប្រភេទអត្ថបទតូចៗ ខ្លីៗ ច្រើនជាពាក្យកាព្យ ពាក្យចួន ហើយមានលក្ខណៈស្រដៀងគ្នានឹងពាក្យទំនីមទំនៀម ធ្វើឱ្យមហាជនងាយស្តាប់ ងាយចាប់បាន និងចងចាំជាពាក្យពីរោះ ពាក្យត្រូវ មានលំនាំជាពាក្យប្រដៅទូន្មាន។

សុភាសិត មានន័យអរូបិយបិតនៅក្នុងឧបមានវិធីសម្រាប់ពិចារណា វិះគិត ល្អិតល្អន់ ទើបយល់ន័យសេចក្តីបាន។ បុព្វបុរសខ្មែរយើង បានប្រើវិធីបង្កើតសុភាសិតនិងការបកស្រាយតាមវិធីពីរយ៉ាង ៖

- **ន័យត្រង់ឬអត្ថានុរូប** : សម្រាប់ណែនាំទូន្មានដូចជា
  - ចេះពីរៀន មានពីរក
  - ឈើកោងវល្លិព័ទ្ធ មនុស្សខ្ជាត់ព្រាត់កុំយកខ្លួនបៀត
  - អ្នកមានរក្សាខ្សែត់ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅដូចសំពៅពីងសំប៉ាន
  - ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឱ្យយក។ល។
- **ន័យធៀបឬអត្ថបដិរូប** : មានប្រើឧបមានវិធី ប្រៀបធៀប មតិយោបល់អ្វីមួយទៅនឹងវត្ថុណាមួយ ដើម្បីជាគ្រឿងពិចារណាដូចជា
  - អូសទូកកុំឱ្យល្ងាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក
  - ឆើយស្កក ឱនដាក់គ្រាប់
  - សន្សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា
  - ចង់ឆ្លាញ់ឱ្យរកអន្លក់ ចង់ស្រណុកឱ្យនឿយពីក្មេង

លំហាត់

ចូរប្អូនចាប់ដៃគូក្នុងក្រុមពីរៗនាក់ រួចជ្រើសរើសប្រធានបទរបស់សុភាសិតដូចខាងក្រោមណាមួយមកនិយាយបកស្រាយន័យរបស់វា :

- ចេះពីរៀន មានពីរក
- ឆើយស្កក ឱនដាក់គ្រាប់
- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ
- ស្រឡាញ់កុំទៅញឹក រលឹកសឹមទៅម្តង។

ប្រៀបធៀបចំណុចសំខាន់ៗមួយចំនួនក្នុងរឿងរាមកេរ្តិ៍និងរឿងរាមាយណៈ

អ្នកធ្លាប់សិក្សារួចមកហើយអំពីសំណេរប្រៀបធៀប ។ សំណេរប្រៀបធៀបជាប្រភេទសំណេរម៉្យាងដែលតម្រូវឱ្យយើងសរសេរបង្ហាញពីចំណុច ឬលក្ខណៈដូចគ្នាផងនិងលក្ខណៈខុសឬផ្ទុយគ្នាផង ។ ជួនកាលក៏មានតម្រូវឱ្យរកតែចំណុច ឬលក្ខណៈខុសគ្នា ហើយជួនកាលទៀតក៏តម្រូវឱ្យសរសេរតែចំណុច ឬលក្ខណៈដូចគ្នាតែមួយក៏មាន អាស្រ័យតាមប្រធានបទនីមួយៗ ។

ក្នុងមេរៀននេះ អ្នកនឹងសិក្សាពីសំណេរប្រៀបធៀបទាំងលក្ខណៈដូចនិងលក្ខណៈឬចំណុចខុសគ្នាមួយចំនួនផងដែរ នៅក្នុងរឿងរាមកេរ្តិ៍និងរឿងរាមាយណៈ នៅខ្សែទី ១ ខ្សែទី ២ និងកាន្ទទី ១ កាន្ទទី ២ ។

ចូរអ្នកអានអត្ថបទគំរូខាងក្រោម :

មុននឹងប្រៀបធៀបចំណុចសំខាន់ៗ(អត្ថន័យ អត្តរូប អត្ថរស) នៃរឿងទាំងពីរបាន អ្នកគប្បីស្វែងយល់ពីស្ថានភាពទូទៅនៃរឿងរាមាយណៈជាមុនសិន ដើម្បីងាយស្រួលប្រៀបធៀបភាពខុសគ្នាខ្លះៗក្នុងរឿងរាមាយណៈនិងរឿងរាមកេរ្តិ៍ ។

១ . អ្នកនិពន្ធនិងកាលកំណត់តែង

រឿងរាមាយណៈ គម្ពីរដើមជាភាសាបាលីសំស្ក្រឹតតែងជាកាព្យឆន្ទ ហើយជាស្នាដៃរបស់ឥសីឈ្មោះ **វាល្មិកិ** ។ រឿងនេះកើតនៅក្នុងប្រទេសឥណ្ឌាក្នុងសតវត្សទី ៣មុនគ. ស. ។ បារាំងសែសម្នាក់ឈ្មោះ **Alfred Roussel** បានបកប្រែរឿងទាំងមូលនេះ មកជាភាសាបារាំងបោះពុម្ពផ្សាយក្នុងគ. ស. ១៩០៣ ។ រឿងរាមាយណៈដើមមានកាព្យ ២៤ ០០០ស្លោក ហើយចែកជាកាន្ទចំនួន ៧កាន្ទគឺមាន :

- ពាលកាន្ទ
- អយោធ្យាកាន្ទ
- អរណ្យកាន្ទ
- កីស្កិន្ធាកាន្ទ
- សុន្ទរកាន្ទ
- យុទ្ធកាន្ទ
- ឧត្តរកាន្ទ

២ . តួអង្គ

យើងមិនចាំបាច់យកឈ្មោះតួអង្គយក្ស ដែលមានចំនួនដ៏ច្រើនលើសលប់ ក្នុងរាមាយណៈមកបញ្ជាក់ទេ ហើយយើងគ្រាន់តែយកឈ្មោះតួអង្គក្នុងរាជវង្សរបស់ព្រះរាម មកប្រៀបធៀបផ្ទឹមអក្ខរាវិរុទ្ធនិងសូរស័ព្ទហៅ ក៏ឃើញខុសគ្នាខ្លះពីរឿងរាមកេរ្តិ៍របស់អ្នកអង្គម្ចាស់វឌ្ឍនាយាវង្ស ដែលបោះពុម្ពដោយក្រុមពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩៣៧ ដែរ ។

ឧទាហរណ៍ :

រាមាយណៈ	រាមកេរ្តិ៍
- រាមា	ព្រះរាម
- ព្រះភរត: Bharata	ព្រះភិរុត
- ឥសីវិស្វាមិត្រ Visvamitra	ឥសីពិស្វាមិត្រ
- ព្រះលក្ឃ្មណ: Lakshmana	ព្រះលក្ឃ្មណ៍
- ព្រះនាងកៃកេយី Kaikeyi	ព្រះនាងកៃកេសី
- ព្រះនាងកៅសល្យា Kausalya	ព្រះនាងកោសកល្យា
- ព្រះនាងសុមិត្រា Sumitra	ព្រះនាងសមុទ្រ
- ព្រះសុត្រុឃ្ន: Sutrughna	ព្រះសុត្រុត

ពោលគឺរឿងទាំងពីរមានលក្ខណៈខុសគ្នាទាំងតួអង្គ ទាំងផ្នែកអត្ថន័យ អត្ថរូប ក៏ដូចជាអត្ថរស ។

៣ . ដំណើររឿង

- រឿងរាមាយណៈ ចាប់រៀបរាប់តាំងតែពីបុព្វប្រវត្តិរបស់ព្រះរាជវង្សានុវង្សរបស់ព្រះរាម រហូតដល់ព្រះរាមប្រសូតជីងក្តីធំខ្លួននៅជាមួយឥសីវិស្វាមិត្រ បង្ក្រាបនាងយក្ខិនីតារកា ។
- ចំណែករឿងរាមកេរ្តិ៍ខ្មែរវិញ អ្នកនិពន្ធពុំបានប្រាប់ពីសាវតារប្រវត្តិនៃព្រះរាមឡើយ ។ អ្នកអានមើលទៅឆ្ងាយបន្តិច ទើបដឹងថាព្រះរាមជាបុត្រព្រះនាងមហេសីនាមអ្វី ហើយព្រះភិរុត សុត្រុត និងព្រះលក្ឃ្មណ៍ទៀតជារាជបុត្រក្សត្រីជាមហេសីអង្គណា នាមអ្វី ? រឿងចាប់ភ្លាមនិយាយពីព្រះរាមធំដឹងក្តីហើយត្រូវទៅជួយបង្ក្រាបយក្សឈ្មោះកាកនាសូរ ដែលមកបំផ្លាញហោមពិធីរបស់ឥសីពិស្វាមិត្រ ។ យើងពុំដឹងថាតើយក្សក្អែកនេះមានភេទជាស្រី ឬប្រុសផង ហើយតើហេតុអ្វីក៏បានទៅជាក្អែកយ៉ាងនេះ ? ។ល ។

ដូច្នេះក្នុងរឿងរាមកេរ្តិ៍ ដំណើររឿងមានអន្លើខ្លះហាក់ដូចជាឋិតក្នុងការអាថ៌កំបាំង ទាល់តែមើលឱ្យឆ្ងាយតៗទៅមុខ ទើបដឹងដំណើរប្រវត្តិរឿងខាងក្រោយវិញ ឬមួយទាល់តែដឹងរឿងបែបរាមាយណៈខ្លះទើបឆាប់យល់។

ការពុំរៀបរាប់ដំណើររឿងក្តី ឈ្មោះតួអង្គឱ្យដូចជា រឿងរាមាយណៈដើមក្តី គឺរឿងរាមកេរ្តិ៍ចង់បង្ហាញនូវលក្ខណៈពិសេសប្លែក ដែលពុំមែនផ្តិតយក ឬចម្លងតាមទាំងស្រុងនូវរឿងបែបឥណ្ឌានេះឡើយ ហើយម្យ៉ាងទៀតមកពីអ្នកនិពន្ធ តាក់តែងរឿងតាមចិត្តគំនិតខ្មែរ ខ្មែរពុំជឿនូវទ្រឹស្តីលទ្ធិបែបពួកព្រាហ្មណ៍នោះឯង ហើយខ្មែរយកព្រះរាមមកដើរតួ ដើម្បីបង្ហាញនូវលក្ខណៈចរិយា សកម្មភាពរបស់មនុស្ស ពុំមែនជាលក្ខណៈចរិយាអស្ចារ្យ បែបទេវៈនោះឡើយ។

៤ . លក្ខណៈខុសគ្នានៃរឿងរាមាយណៈនិងរាមកេរ្តិ៍

ក. ក្នុងផ្នែកអត្ថន័យ

លក្ខណៈនិងឧត្តមគតិរឿង :

- រឿងរាមាយណៈ បានទ្រទ្រង់រូបលក្ខណៈនិងសកម្មភាពតាំងពីដើមដល់ចប់របស់ព្រះរាម តម្កល់តម្កើងថា ជាតួអង្គប្រកបដោយវិមល (ប្រាសចាកនូវបាប មន្ទិលនានា) ហើយជាតំណាងអាទិទេពវិស្ណុអវតារ ចុះមកសង្គ្រោះលោកឱ្យផុតអំពីការរាតត្បាតចង្រៃនៃពួករាក្សៈដែលជាយក្សអាក្រក់មានទោសទណ្ឌកម្ម ត្រូវតែប្រហារចោលដោយធ្នូសរព្រហ្មាស្ត្រ។

ព្រះរាមប្រហារយក្សក្តី សុទ្ធសឹងតែអនុវត្តទៅតាមទេវតាបញ្ជា ដោយសារពពួកទមិឡចង្រៃនេះមានទោសទណ្ឌដែលបណ្តាលមកពីការរុករាតត្បាតលោកៈ ឬដោយមានបុព្វហេតុកម្មពីជាតិមុន។

ឧទាហរណ៍ : ការសម្លាប់ពាលី ព្រោះស្តេចស្វានេះ ត្រូវបណ្តាសាអាទិទេព ដោយមកពីបំពានបំពានខុសច្បាប់ប្រពៃណីលើរូបកាយប្អូនថ្លៃ ដែលជាប្រពន្ធសុគ្រីពជាបងប្អូនរបស់ខ្លួន ហើយសម្លាប់យក្សនានា ក៏ព្រោះតែពពួកនេះមានកំហុស។ សម្លាប់នាងតារកា យក្ខិនី ក៏ព្រោះតែនាងបាននាំកូនឈ្មោះ មារិចៈ ទៅរាតត្បាតធ្វើទុក្ខឥសី (ជាអ្នកកាន់សីលតំណាងទេវៈ) នាមអគ្គសត្យមុនី។

ព្រះរាមបំផ្លាញភូមិវិជ្ជារបស់ព្រាហ្មណ៍ឈ្មោះ បរសុរាម ឬរាមបរសុ ក៏ព្រោះហ៊ានមកប្រមាថចេស្តាព្រះអង្គ។ ព្រះរាមធ្វើទណ្ឌកម្មនាងសុរបនខា ក៏ព្រោះតែនាងយក្ខិនីនេះក្លែងខ្លួនជាទេពអប្សរមកប្រលោមស្នេហាចំពោះព្រះអង្គ រួចហ៊ានស្ទុះទៅទះតប់លើរាងកាយព្រះនាងសីតាថែមទៀត ឬមួយគេតែងរឿងបញ្ចៀសគ្រួសារព្រះរាមឱ្យផុតពីទោសកំហុសទាំងអស់។ *ឧទាហរណ៍ :* រឿងនាងកែកេយីក្នុងរាមាយណៈ គឺឥតខុសឥតមានចិត្តលោភលន់ទេ ក្នុងការទាមទាររាជសម្បត្តិឱ្យព្រះភរតៈជា

បុត្រ។ នាងគម ឈ្មោះមន្តរាសោះ ដែលជាខ្ញុំស្រីបម្រើចិត្តអាក្រក់ មកនិយាយញុះញង់បំបែកបំបាក់បញ្ឆូលចិត្តនាងកែកេយីឱ្យស្តុងតាម ដើម្បីទាមទាររាជសម្បត្តិឱ្យកូន គឺព្រះភរតៈ ដោយសំអាងទៅលើពាក្យសន្យា ថានឹងប្រទានរាជសម្បត្តិនោះ។ល។

- ចំណែករឿងរាមកេរ្តិ៍វិញ : អ្នកនិពន្ធបានរៀបរៀងលក្ខណៈសកម្មភាពរបស់ព្រះរាមស្របទៅតាមមនុស្សនិយម ដោយពុំបានទ្រទ្រង់លើកតម្កើងតួអង្គនេះ ជាអាទិទេពដែលគ្មានឆ្គងនោះឡើយ។ ពីខ្សែ ១ដល់ដើមខ្សែ ៣ ព្រះរាមមានលក្ខណៈល្អស្អាតបរិសុទ្ធ គឺប្រកបដោយវិចារណញ្ញាណមានការលះបង់ ប្រកាន់ខន្តី មេត្តាករុណា សន្តោស ហើយមានសុភវិនិច្ឆ័យកាន់សច្ចៈខ្ជាប់ខ្ជួន។ ប៉ុន្តែចាប់ពីខ្សែទី ៤ដល់ ១០ ព្រះរាមមានលក្ខណៈជាមនុស្សផ្ទុងខ្លួនលង់ទ្រនេស ដោយចាញ់កលឃក្សទៅជាចេះយំខ្សឹកខ្សួល រង្វេងស៊ុង តប់ប្រមល់ឃកកំហឹងទល់កំហាល់ប្រើឧបាយកលសងសឹកយ៉ាងកំឡៅ។ ហើយចាប់ពីខ្សែ ៧៥ដល់ ៨០ ព្រះរាមមានអាកប្បកិរិយា លក្ខណៈអន់ថយរហូតដល់ខ្សោយជាងមនុស្សសាមញ្ញ ទាំងខាងផ្លូវកាយវាចាចិត្ត សន្សំរឿងជាមួយកូនក្មេងល្អិតល្អោច (កូនឯង) ចេះប្រើឧបាយកលបោកបញ្ឆោតនាងសីតាខូចទឹកចិត្ត។

សរុបសេចក្តីទៅ ឧត្តមគតិនិងដំណើររឿងទាំងពីរ គឺខុសគ្នាស្រលះ ឥតដូចគ្នាឡើយ។

២. ក្នុងផ្នែកអត្ថរូប

និពន្ធវិធី : រឿងរាមាយណៈ តែងជាកាព្យបែបសំស្ក្រឹតមានចំនួន ២៤ ០០០ស្លោកចែកជា ៧កាន្ឌ គឺមាន ៖

១. ពាលកាន្ឌ

២. អយុធ្យាកាន្ឌ

៣. អរណ្យកាន្ឌ

៤. កីស្កិន្ធាកាន្ឌ

៥. សុន្ទរកាន្ឌ

៦. យុទ្ធកាន្ឌ

៧. ឧត្តរកាន្ឌ

ឯរឿងរាមកេរ្តិ៍តែងជាកាព្យ ពាក្យបែបខ្មែរ លំនាំបែបបទល្ខោន ហើយគ្មានចែកជាវគ្គ ជាកាន្ឌដូចរឿង រាមាយណៈឡើយ។ ឈ្មោះបទខ្លះក្នុងរាមកេរ្តិ៍ខ្មែរមានដូចតទៅ :

បទសំរើប

សំណាខរ

សំណារខម

សំណាស្តេចលេលា

សំណាខ្មែរ

សំណាស្ងៀម

សំណាសៀមសុទ្ធ

សំណារ

សំណាលា

សំណាមន

សម្តេចភាណ

សម្តេច

សម្តេចលេលា

សម្តេចលា

ជើត

ជើតហើយច្រះ

ជើតច្រះ

ជើតហើយច្រះជុក

ជើតបទខឹងមាំ

ជើតបទរាយ

ជើតរាយ

ជើតបទរាយជោន

ជើតភ្លេងបទរាយ

ជើតឱតបទរាយ

និយាយបទឱត

ជើតបទថយ៉ាយ

ជើតបទឡើងរថ

បទបម្រើ

បទប្រគំ

បទនា

បទទ្រង់គ្រឿង

បទឆ្នានបទជុំព្រៃ

បទច្រះជុក

បទដណក

បទឱត

ឱតបទពិលាប

ឱតបទរាយ

ឱតបទរាយ

ឱតបទនិយាយ

ឱតបទរាយភិលាប

បទឱតលោម

បទរាយ

បទត្រះ បទរាយ

បទស្មើ បទរាយ

បទក្លម់ បទរាយ

បទក្លម់ បទពិលាប

និយាយបទរាយ

និយាយជើតបទរាយ

និយាយឯកបទ

បទពិលាប ។

គ. ក្នុងផ្នែកអត្ថរស

- រឿងរាមាយណៈ ជារឿងប្រកបដោយអច្ឆរិយភាព គឺអស្ចារ្យតាំងតែងពីលក្ខណៈ សកម្មភាពរបស់តួអង្គ (តួយក្សក្តី មនុស្សក្តី) រហូតដល់ដំណើររឿង ក៏សុទ្ធសឹងប្រាសចាកនូវតថភាពច្រើន។ ដូច្នេះតម្លៃបិតនៅលើអច្ឆរិយរសនេះឯង។
- ចំណែករឿងរាមកេរ្តិ៍វិញ អ្នកនិពន្ធពិតមែនតែយកហេតុភេទដំណើរអស្ចារ្យរបស់តួអង្គខ្លះមកពណ៌នា ក៏គង់លក្ខណៈទូទៅរបស់រឿងប្រកបដោយការពិត ដែលជាតថភាពហើយបិតនៅជារឿងរបស់សង្គមមនុស្សនេះឯង។ ដូច្នេះតម្លៃជាមូលដ្ឋានបិតនៅលើតថរសនិងសង្គមរសនេះឯង។ ទិបត្តិទំនាស់តួអង្គមានតឹង មានធូរ មានចាញ់ មានឈ្នះ ប្រកបដោយនាដ្យភាព ដែលផ្តុំយអំពីការទាស់ទែងគ្នា ក្នុងរាមាយណៈផ្តល់នូវជ័យជំនះដាច់ខាតចំពោះព្រះរាម ធ្វើឱ្យពពួកអ្នកបដិបក្ខចាញ់ដៃស្លាប់រង្គាល បង្កើតបានទារុណភាពយ៉ាងរន្ធត់។

ដូច្នេះរឿងរាមកេរ្តិ៍ មានតម្លៃបិតនៅលើនាដ្យរស។ ឯរឿងរាមាយណៈ ជារឿងបែបទារុណភាពបិតលើតម្លៃ ទារុណរស។

តាមរយៈនៃការសិក្សាប្រៀបធៀបនៃលក្ខណៈរឿង ជាទូទៅរបស់រាមាយណៈនិងរាមកេរ្តិ៍ ព្រមទាំងការលើកយកអត្ថបទជាភស្តុតាងមកពិនិត្យបែបនេះ នាំឱ្យយើងឃើញកាន់តែច្បាស់ថា រឿងរាមកេរ្តិ៍ខ្មែរជារឿងរបស់មនុស្ស បិតនៅក្នុងសភាពវិបត្តិទាស់ទែងគ្នាខ្វែងគំនិតគ្នាបែបមនុស្ស។ គឺលក្ខណៈពិសេសក្នុងផ្នែកអត្ថន័យ អត្ថរូប និងអត្ថរសនេះហើយ ដែលធ្វើឱ្យរឿងរាមកេរ្តិ៍ មានសភាពជារឿងរបស់ខ្មែរបែបជាតិនិយម (ខេមរនិយម) ផ្តុំយអំពីរឿងរាមាយណៈ។ រាមកេរ្តិ៍ជាមូលដ្ឋាននៃវប្បធម៌ អារ្យធម៌ខ្មែរ ដែលទ្រទ្រង់នូវអក្សរសិល្ប៍បុរាណក្នុងគោលខេមរនិយមនិងមនុស្សនិយមនេះឯង។

សំណួរ

១. តើរឿងរាមាយណៈមានប៉ុន្មានកាន្ត ? ចុះរឿងរាមកេរ្តិ៍ ?

២. ចូរបង្ហាញត្រួសៗអំពីលក្ខណៈខុសគ្នា(អត្ថន័យ អត្ថរូប អត្ថរស)នៃរឿងរាមាយណៈនិងរឿងរាមកេរ្តិ៍។

៣. ចូរបង្ហាញពីលក្ខណៈខុសគ្នារវាងតួអង្គរាមាក្នុងរឿងរាមាយណៈនិងព្រះរាមក្នុងរឿងរាមកេរ្តិ៍។

លំហាត់

ចូរបួនសរសេរតែងសេចក្តីប្រៀបធៀបលក្ខណៈដូចនិងលក្ខណៈខុសគ្នាក្នុងរឿង រាមកេរ្តិ៍ខ្សែទី ១-២ និងរឿងរាមាយណៈឥណ្ឌាកាន្ដទី ១-២ នូវចំណុចសំខាន់ៗដូចខាងក្រោម :

- តួអង្គ រាមា ក្នុងរាមាយណៈនិងព្រះរាម ក្នុងរឿងរាមកេរ្តិ៍
- ដំណើររឿង ឬតួរឿង ក្នុងខ្សែទី ១និងទី ២ ក្នុងរឿងរាមកេរ្តិ៍និងរឿងរាមាយណៈ កាន្ដទី ១ និងកាន្ដទី ២ ។
- ឧត្តមគតិរឿងទាំងពីរ ។

ដើម្បីសរសេរបង្ហាញពីលក្ខណៈដូចនិងខុសគ្នា អ្នកត្រូវប្រើសំនួនដូចខាងក្រោម :

- សំនួនប្រៀបធៀបលក្ខណៈដូចគ្នា : .....ក៏ .....ដែរ , ដូច ស្មើ ប្រហាក់ប្រហែល ស្រដៀង ស្រដៀងគ្នានឹង ..... ។ល។
- សំនួនប្រៀបធៀបលក្ខណៈខុសគ្នា : ប៉ុន្តែ ផ្ទុយទៅវិញ មិនដូច ..... មិនដូចនឹង .....ទេ ផ្ទុយពីនេះ ..... ខុសគ្នាស្រឡះពី .....បែរជា .....ទៅវិញ ។ល។

នៅពេលអ្នកសរសេរចប់ អ្នកត្រូវពិនិត្យផ្ទៀងផ្ទាត់មើលសំណេររបស់អ្នកឡើងវិញ ដោយប្រើប្រាស់សំណួរខាងក្រោម :

- តើសំណេររបស់អ្នកមានខ្លឹមសារត្រឹមត្រូវស្របនឹងប្រធានបទ ហើយឬនៅ ?
- តើសំណេររបស់អ្នកមានភាពត្រឹមត្រូវតាមទម្រង់វេយ្យាករណ៍ដែរឬទេ ?
- តើការប្រើប្រាស់ពាក្យពេចន៍ ឃ្លា ល្បះ បានត្រឹមត្រូវហើយមានកំហុសអក្ខរាវិរុទ្ធដែរឬទេ ?
- តើការប្រើប្រាស់សំនួនប្រៀបធៀបត្រឹមត្រូវ សមហេតុផលដែរឬទេ ?

មេរៀនទី ១០

អក្សរសិល្ប៍បរទេស



ការសិក្សាអក្សរសិល្ប៍ជាតិធ្វើឱ្យយើងស្វែងយល់ពីតថភាពសង្គមរបស់ខ្លួន ដែលមានតាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន។ ការសិក្សាស្នាដៃអក្សរសិល្ប៍អន្តរជាតិ ឬអក្សរសិល្ប៍បរទេសក៏អាចធ្វើឱ្យយើងបានដឹងពីសង្គមខាងក្រៅ ជាពិសេសបណ្តាប្រទេសដែលមានអរិយធម៌ដ៏ចំណាស់។

ក្នុងមេរៀននេះ អ្នកនឹងបានសិក្សាអំពីជីវប្រវត្តិរបស់អ្នកនិពន្ធ កាលកំណត់តែង សង្គមបរិយាកាស ខ្លឹមសារសំខាន់ៗ អំពីអត្ថរស ការហូរចូលនិងការទទួលយកវប្បធម៌បរទេសនិងទំនាក់ទំនងរវាងអរិយធម៌ខ្មែរនិងអរិយធម៌បរទេស។

មរណភាពដ៏ក្លាហានរបស់ហាំលែត



ក. សិក្សាពាក្យគន្លឹះ

- គជ (ន) : វត្ថុជាដុំដូចជាពក មានសាច់រឹងដូចកែវ កើតមានក្នុងសរីរាង្គកាយ ឬ ក្នុងក្បាលនៃសត្វទាំងឡាយ ។
- មនសិការ (ន) : ការធ្វើទុកក្នុងចិត្ត ការកំណត់ទុកក្នុងចិត្ត ដំណើរយកចិត្តទុកដាក់ ។
- អន្ទាក់ (ន) : ប្រដាប់ធ្វើដោយខ្សែ ឬដោយចម្រៀកផ្តៅជាដើម មានក្រវិលរួតបានសម្រាប់ទាក់ សម្រាប់ដាក់ឱ្យជាប់សត្វទេបាទ ចតុប្បាទជាដើម ។
- ទុយ៌ិស (គុ) : ដំណើរខូចយស ។
- បន្ទាល (កិ) : ធ្វើឱ្យទាល ។
- មច្ចុរាជ (ន) : ស្តេចសេចក្តីស្លាប់ សេចក្តីដែលទុកដូចជាស្តេច ព្រះយមរាជ ។
- ជ័យភណ្ឌ (ន) : ទ្រព្យ របស់ គ្រឿងប្រើប្រាស់ គ្រឿងប្រដាប់ បានទទួលក្រោយពេលឈ្នះសង្គ្រាម ។
- អង្គទូត (ន) : អង្គការផ្នែកខាងទូត មុខក្រសួងទូតព្រមទាំងបុគ្គលិកនៃស្ថានទូតផង ។
- និរន្តរ៍ (កិ.វិ) : ដែលឥតមានចន្លោះ ជានិច្ច ឥតស្រាក ឥតឈប់ ឥតល្ហែ ។
- អមតៈ (គុ) : ដែលមិនស្លាប់ ដែលមិនដាច់ មិនស្រាក (ដែលមានជានិច្ច) ។

- ទស្សនីយភាព (ន) : ភាពដែលគួរមើល គួរឃើញ អ្វីៗដែលគួរឱ្យចង់មើលចង់ឃើញ ។
- បាបធម៌ (ន) : ធម៌លាមក អាក្រក់ គឺជាសភាវៈដែលជាជំនួយចិត្ត នាំចិត្តឱ្យហ៊ានធ្វើអំពើអាក្រក់ ដូចយ៉ាងសេចក្តីច្រណែនឈ្នានីស ឥតអៀនខ្មាស ឥតរាងរអាទៅរកអំពើអាក្រក់ ។
- ភេរវកម្ម (ន) : អំពើដែលគួរឱ្យខ្លាច គួរឱ្យតក់ស្លុត អំពើចលាចលជ្រួលច្របល់ ដែលបណ្តាលមកពីការធ្វើឃាតកម្មដោយសម្លាប់ជាដើម ។
- អភិជន (ន) : មនុស្សខ្ពង់ខ្ពស់ ជាតិ វង្ស ត្រកូល ជាតិភូមិ ។
- អពមង្គល (ន) : សេចក្តីមិនចម្រើន ហេតុដែលនាំឱ្យវិនាស ឱ្យអាប់ឱន ។
- បុស្បក (ន) : ទីអាសនៈ ឬវេទិកាមានសណ្ឋានជាបល្ល័ង្កខ្ពស់ ទ្រដោយជើងកោសច្រើនថ្នាក់ មានសសរបួន រាងបួនជ្រុងស្រដៀងនឹងបារាំកំពូល ដំបូលមានរាងច្រឡោ សណ្ឋានដូចកំពូលប្រាសាទក៏មាន រាងមូលជាកន្សោមតាឱ ឬកន្សោមផ្កាក៏មាន វិចិត្រចនាដោយផ្កាវំយោលផ្សេងៗតាមគួរដល់ប្រកប ប្រើជាទីសម្រាប់គង់នៃព្រះមហាក្សត្រក្នុងព្រះរាជពិធីរាជាភិសេកនៅវេលាថ្វាយព្រះសិទ្ធរស (ស្រោចទឹក) និងសម្រាប់ប្រើក្នុងពិធីស្រោចទឹកចម្រើនព្រះជន្មនៃសម្តេចព្រះសង្ឃនាយកជាដើម ។

ខ. អភិវឌ្ឍន៍បំណិន

ពេលអានអត្ថបទដកស្រង់នេះ ចូរអ្នកអានដោយយកចិត្តទុកដាក់ ដើម្បីត្រៀមឆ្លើយទៅនឹងសំណួរទាក់ទងនឹងប្រវត្តិអ្នកនិពន្ធនិងស្នាដៃរបស់លោក កាលបរិច្ឆេទ និងខ្លឹមសារសំខាន់ៗមួយចំនួន ។

គ. អត្ថបទដកស្រង់

ព្រះរាជា : រៀបកែវស្រាដាក់លើតុឱ្យពេញទៅ ។ បើហាំលែតប៉ះបានមុនគេ ឬទីពីរ ឬបើទ្រង់អាចសងបាននៅស្មៀតទីបី ចូរឱ្យកាំភ្លើងធំបាញ់ប្រកាសជោគជ័យថ្វាយទ្រង់ ។ ព្រះរាជានឹងសោយមួយកែវ ដើម្បីសុខភាពដ៏បវរបស់ហាំលែត ហើយព្រះអង្គនឹងដាក់ទៅក្នុងកែវនូវគជដ៏មានតម្លៃលើសគជទាំងអស់របស់ព្រះរាជាបួនព្រះអង្គ ដែលបានសោយរាជ្យជាបន្តបន្ទាប់នៅលើរាជបល្ល័ង្កនៃដាណឺម៉ាកនេះ ។ យកកែវមកឱ្យខ្ញុំ ហើយចូរវាយឃ្មោះប្រកាសទៅត្រៃ ឱ្យត្រៃប្រកាសទៅកាំភ្លើងធំ ឱ្យកាំភ្លើងធំប្រកាសទៅមេឃ ហើយឱ្យមេឃប្រាប់មកផែនដីវិញថា "ព្រះរាជាសោយសុរា ដើម្បីជោគជ័យដល់ហាំលែត" ។

ទៅ! ចាប់ផ្តើមទៅ។ ឯលោកអាជ្ញាកណ្តាល សូមលោកផ្តោតភ្នែកប្រុងប្រយ័ត្នរបស់លោក ទៅលើគូប្រយុទ្ធនេះឱ្យមែនទែន។

ហាំលែត : ទៅយើង ឡាយើក។

ឡាយើក : យាងព្រះអង្គម្ចាស់ ... (ចាប់ផ្តើមចាក់សាប)

ហាំលែត : មួយហើយ មួយហើយ។

ឡាយើក : នៅទេ។

ហាំលែត : វិនិច្ឆ័យ។

អូសរិច : មែនហើយ ប៉ះច្បាស់ក្រឡែតណាស់។

ឡាយើក : ឆាប់ណាស់ន៎! ម្តងទៀត។

ព្រះរាជា : ឈប់សិន! ឱ្យកែវមកខ្ញុំ! ហាំលែត គជដ៏មានតម្លៃនេះជារបស់ឯងហើយ! ខ្ញុំឱ្យដើម្បីសុខភាពរបស់ឯង! យកកែវនេះទៅថ្វាយទ្រង់ ... (នៅពេលនោះស្នូរត្រែបន្លឺឡើង ហើយបន្ទាប់មកកាំភ្លើងធំគ្រហឹមក្អឺល)។

ហាំលែត : ទូលបង្គំចង់ចេញស្មៀតថ្មីមួយទៀតសិន។ យកកែវនេះចេញ! ទៅ! នេះប៉ះមួយទៀតហើយ! តើលោកថាម៉េចទៅមើល៍?

ឡាយើក : ព្រះអង្គម្ចាស់ប៉ះទូលបង្គំមែនហើយក្រាបទូល! ព្រះអង្គម្ចាស់ប៉ះទូលបង្គំមែនហើយ! ទូលបង្គំសូមសារភាព។

ព្រះរាជា : (ចំពោះព្រះរាជនី) កូនយើងមុខតែឈ្នះ។

ព្រះរាជនី : វាប៉ោងខ្លាំងណាស់ទៅហើយព្រះអង្គ បន្តិចទៀតវាមុខតែអស់ខ្យល់ហើយ (និយាយទៅកាន់ហាំលែត) មកនេះមកកូន យកស្បែនេះជូតថ្ងាសសិនទៅកូន ព្រះរាជនីនឹងសោយយ៉ាងរីករាយ ដើម្បីជ័យជំនះរបស់កូន។

ហាំលែត : ព្រះរាជនីល្អណាស់!

ព្រះរាជា : មហេសីសម្លាញ់កុំសោយអី!

ព្រះរាជនី : ខ្ញុំម្ចាស់ចង់សោយស្រានេះព្រះករុណា សូមព្រះរាជទានទោសក្រាបទូល! (លើកកែវផឹក)។

ព្រះរាជា : (និយាយតែឯង) គឺកែវស្រាពុល! ហួសពេលហើយ!

ហាំលែត : ទូលបង្គំនៅតែមិនហ៊ានទទួលព្រះរាជទានទេ ព្រះរាជនីចាំបន្តិចទៀតសិន!

ព្រះរាជនី : មកកូនប្រុស ឱ្យម្តាយជូតមុខឱ្យ!

ឡាយើក : (និយាយតិចៗទៅព្រះរាជា) ព្រះករុណា ម្តងនេះទូលបង្គំនិងវាយហើយ ។ (និយាយតែឯង) ថ្វីបើមនសិការស្តីបន្ទោសខ្ញុំយ៉ាងណាក៏ដោយ ។

ព្រះរាជា : ខ្ញុំមិនជឿថា ...

ហាំលែត : ទៅយើងទឹកទីបី ឡាយើក ។ លោកកំប្តុកកំប្លែងលេងនឹងខ្ញុំទេ ។ ខ្ញុំសូមបញ្ចេញឱ្យអស់ពីកម្លាំងលោកមក ! តើលោកចង់ទុកខ្ញុំជាកូនក្មេងកំសាកឬ ? (បន្តការប្រយុទ្ធ)

ឡាយើក : ព្រះអង្គម្ចាស់មានព្រះបន្ទូលអ្វីចឹឬ ? ទៅ ! បើអ្វីចឹង ! (រុញសាបទៅមុខ)

អូសរិច : អត់អីទាំងសងខាង ។

ឡាយើក : ឥឡូវដល់វេនព្រះអង្គម្ចាស់ហើយណា៎ ! (ឡាយើកធ្វើឱ្យហាំលែតមានរបួសហើយនៅក្នុងការប្រឡូកដ៏វីវក់ សាបក៏របួតពីដៃទាំងអស់គ្នា នៅពេលចាប់មកវិញ សាបទាំងពីរក៏ត្រូវប្តូរដៃ ហើយហាំលែតក៏ធ្វើឱ្យឡាយើករបួសវិញដែរ) ។

ព្រះរាជា : បំបែកចេញពីគ្នា ! គេវក់ខ្លាំងណាស់ហើយ ។

ហាំលែត : ទេ ! ទៅម្តងទៀត ។

អូសរិច : ឱ ! ទេពតាអើយ សូមមើលព្រះរាជនី អូ ! (ព្រះរាជនីឡើងស្លេកស្លាំងហើយកំពុងឈឺចុកចាប់)

ហូរេសយោ : របួសទាំងពីរនាក់ ! ព្រោះឈាមហូរហើយ ! (សួរទៅហាំលែត) ព្រះអង្គម្ចាស់ម៉េចក៏ទៅជាយ៉ាងនេះ ?

អូសរិច : មែនហើយ ! ម៉េចក៏ទៅជាយ៉ាងនេះឡាយើក ...?

ឡាយើក : ចង់ដឹងថាម៉េចឬអូសរិច ? គឺថាខ្ញុំធ្លាក់ចូលក្នុងអន្ទាក់របស់ខ្លួនឯងផ្ទាល់ហើយ ! ខ្ញុំនិងស្លាប់ដោយសារអំពើក្បត់របស់ខ្ញុំខ្លួនឯង ។

ហាំលែត : ព្រះរាជនីកើតអីហ្នឹង ?

ព្រះរាជា : ព្រះនាងសន្លប់ ព្រោះតែឃើញឈាមច្រើនពេក !

ព្រះរាជនី : ទេ ... ទេ ! កែវនេះ ... កែវចង្រៃនេះ ! ឱហាំលែតកូនសម្លាញ់ម្តាយ ! កែវ ! កែវ ! ខ្ញុំត្រូវថ្នាំបំពុលហើយ ។ (ព្រះរាជនីចូលទិវង្គត)

ហាំលែត : អ៎ា ! ឧក្រិដ្ឋកម្ម ! បិទទ្វារឱ្យអស់ ! ចូររកមនុស្សក្បត់ ។ វានៅឯណា ?

ឡាយើក : វានៅទីនេះ ហាំលែត ! រូបឯងត្រូវតែស្លាប់ហើយ ! នៅលើលោកនេះគ្មានថ្នាំបន្សាបណាអាចជួយឯងបានទេ ។ ឯងអាចរស់មិនបានដល់កន្លះម៉ោងទៀតទេ ។ ឧបករណ៍ទុរយសដែលនាំឱ្យឯងស្លាប់ វានៅក្នុងដៃខ្ញុំ ។ ឯងមើលសាបនោះទៅមើល៍ វាឥតត្រូវគេបន្ទាលមុខទេ ! ចុងរបស់វាមានជាតិពិស ។ ការច្នៃប្រឌិតដ៏អប្រិយនេះបានធ្លាក់មកលើខ្លួនខ្ញុំវិញហើយ ។ ឱ ! ចូរឯងមើលមកនេះ ! ខ្ញុំដួលដេកលើដីហើយ គឺដេករហូតលែងងើប ។ ... ម្ហាយរបស់ឯងក៏ត្រូវថ្នាំបំពុល ។ ខ្ញុំគ្មានកម្លាំងនឹងបើកមុខវាទេ ... ព្រះរាជា ព្រះរាជាតែមួយអង្គគត់អ្នកដៃដល់ ។

ហាំលែត : អាវុធពេញដោយជាតិពិស ជាតិពុល ចូរបញ្ចេញស្នាដៃឯងទៅ ។ (ចាក់ព្រះរាជា)

ពួកអ្នកហែហម : អំពើក្បត់ ! អំពើក្បត់ !

ព្រះរាជា : ជួយខ្ញុំផងមិត្តទាំងឡាយ ការពារខ្ញុំផង ។ ខ្ញុំគ្រាន់តែរបួសទេ ។

ហាំលែត : អាមេបំពុលអប្រិយ អាស្តេចទុរយស (ចាប់បង្ខំឱ្យផឹកថ្នាំពុលដែលនៅសល់ក្នុងកែវ) លេបអានៅសល់នេះទៅ ។ ឯងមានឃើញគជ់នៅខាងក្នុងនោះទេ ទៅតាមមាតាអញទៅ ។ (ព្រះរាជផុតដង្ហើម)

ឡាយើក : វាសមនឹងទទួលវាសនានេះហើយ ! កែវនេះជាទឹកពុលដែលវារៀបចំឡើងដោយដៃវាផ្ទាល់ ។ ហាំលែតដ៏ថ្លៃថ្នូរ ចូរយើងប្តូរការអភ័យទោសនេះឱ្យគ្នាទៅវិញទៅមក ។ សូមកុំឱ្យមរណភាពរបស់ខ្ញុំនិងរបស់ឪពុកខ្ញុំ ដាក់ជាទោសកំហុសអ្វីទៅលើរូបឯង ហើយមរណភាពរបស់ឯងក៏សុំកុំឱ្យមានទោសមកលើខ្ញុំ ។ (ស្លាប់)

ហាំលែត : សូមព្រះជាម្ចាស់អភ័យទោសឱ្យឯង ! ខ្ញុំក៏ទៅតាមឯងដែរ ។ ខ្ញុំស្លាប់ហើយ ហូរេសយោ ។

- ព្រះរាជនីអភ័ព្វ សូមថ្វាយបង្គំលាហើយ ។
- លោកទាំងអស់ដែលជាទស្សនិកជន លើឆាកពេញទៅដោយឈាមនេះ រូបភាពប្រកបដោយឧក្រិដ្ឋកម្មនេះ ធ្វើឱ្យលោកញាប់ញ័រ ។
- តើខ្ញុំនៅមានពេលឬទេ ? ប៉ុន្តែមច្ចុរាជ អាជ្ញាក៏គ្មានធម៌មេត្តានៃយុត្តិធម៌ជាន់ខ្ពស់ អនុវត្តភារកិច្ចរបស់ខ្លួនដោយគ្មានពន្យារពេល គ្មានសម្រាកឡើយ ... ខ្ញុំត្រូវតែចុះញ៉ែម ។
- ហូរេសយោ ខ្ញុំស្លាប់ហើយ ឯងឯទៀ ឯងនៅរស់ ! ចូរឯងនិយាយដោះសាឱ្យខ្ញុំផង ។ ដោះសាពីបុព្វហេតុខ្ញុំនៅចំពោះមុខអ្នកដែលចោទប្រកាន់ខ្ញុំ !

ហ្វរេសយោ : ទេ ! កុំស្មានថាទូលបង្គំធ្វើដូចនោះឡើយ ។ កើតមកជាជាតិដាណឺម៉ាក ទូលបង្គំមានបេះដូងនៃជនជាតិរ៉ូម៉ាំងបុរាណ នៅសល់ថ្នាំពុលប៉ុន្មានដំណក់ដែរតើ ?

ហាំលែត : បើឯងជាមនុស្ស ប្រគល់កែវនោះមកឱ្យខ្ញុំ ! ឱ្យវាមកខ្ញុំ ! ម្ចាស់ថ្លៃអើយ ខ្ញុំចង់បានវា ។ (ត្រវាត់កែវចោលទៅដី) ឱ ! ហ្វរេសយោជាទីស្នេហា ! អ្នកមានស្វាមីភក្តិណាស់ ប្រសិនបើការពិតនៅស្ថិតក្នុងភាពងងឹតឈ្លប់ដូចពេលនេះទេនោះ ដល់ខ្ញុំស្លាប់ទៅ តើឈ្មោះខ្ញុំនឹងត្រូវគេស្អប់ខ្ពើមយ៉ាងណា ! ចូរឯងកុំប្រញាប់ទៅក្រេបសុភមង្គលនៅស្ថានសួគ៌អី ពន្យារពេលពីរបីថ្ងៃទៀតសិនទៅ ចូរឯងស៊ូទ្រាំរស់នៅដោយពិបាកក្នុងពិភពអប្រិយនេះបន្តិចទៀតសិនទៅ ដើម្បីនិយាយរឿងអភ័ព្វរបស់ខ្ញុំប្រាប់ដល់អ្នកផងឱ្យគេដឹង ។ (ឮសូរទ័ពដើរពីចម្ងាយលាយឡំដោយសម្រែកគឹកកង) សំឡេងសង្គ្រាមអីហ្នឹង ? (អូសរិចដើរចេញទៅ ចូលមកវិញ)

អូសរិច : ព្រះយុវក្សត្រ ផ័រធីនប្រាស យាងត្រឡប់មកវិញហើយ នាំទាំងជ័យជំនះនិងជ័យភណ្ឌមកពីប៉ូឡូញផង ។ ព្រះអង្គដែលបញ្ជូឱ្យបាញ់កាំភ្លើង គោរពតាមទំនៀមទម្លាប់ទ័ព ដើម្បីជាកិត្តិយសចំពោះការមកដល់នៃអង្គទូតប្រទេសអង់គ្លេស ។

ហាំលែត : អូ ! ខ្ញុំដាច់ខ្យល់ឥឡូវហើយ ហ្វរេសយោ ។ ថ្នាំពុលនេះសកម្មណាស់ ! វាផ្តាច់ជីវិតខ្ញុំឥឡូវហើយ ! ខ្ញុំអត់មានពេលនៅចាំស្តាប់ដំណឹងពីប្រទេសអង់គ្លេសទេ ។ ប៉ុន្តែខ្ញុំទាយទុកថា គេនឹងជ្រើសរើស ផ័រធីនប្រាស ឱ្យឡើងសោយរាជ្យហើយ ។ សំឡេងជិតស្លាប់របស់ខ្ញុំ សូមបោះឆ្នោតថ្វាយព្រះអង្គដែរ ។ សូមឯងទូលព្រះអង្គម្ចាស់ជំនួសខ្ញុំផង ពីស្ថានភាពផ្សេងៗ ដែលបណ្តាលឱ្យខ្ញុំប្រកាន់អាកប្បកិរិយាដូចនេះ ... ក្រៅពីនេះ ... គឺជាការសូបស្ងាត់ជានិច្ចនិរន្តរ៍ ... (ព្រះអង្គចូលទីវង្គត)

ហ្វរេសយោ : ឥឡូវបេះដូងដ៏ថ្លៃថ្នូរបំផុតនោះបែកធ្លាយទៅហើយ ! ព្រះអង្គម្ចាស់ជាទីស្នេហាលាហើយ ! សូមក្រុមតន្ត្រីនៃពពួកទេពតាចុះយាងព្រះអង្គម្ចាស់ទៅកាន់ទីសម្រាកអមត: ! ... ប៉ុន្តែហេតុអ្វីក៏ស្គរវិតកាន់តែមកជិតដូច្នេះ ? (ផ័រធីនប្រាសនិងទូតអង់គ្លេសចូលមកក្នុងឆាកជាមួយអ្នកហែហមទាំងអស់ ។ ស្គរវាយគគ្រឹកគគ្រេង ទង់នានាលាតត្រដាង)

ជីនធីនប្រាស : នៅឯណាទៅ ទស្សនីយភាពដ៏គួរឱ្យតក់ស្លុតនោះ ?

ហូរេសយោ : តើព្រះអង្គម្ចាស់រកអ្វី ? ប្រសិនបើ ព្រះអង្គម្ចាស់ច្រណែនដោយឃើញបាបធម៌និងភេរវកម្មមកប្រមូលផ្តុំគ្នាគួរឱ្យរន្ធត់នោះ ព្រះអង្គម្ចាស់បានមកជួបប្រទះវានៅទីនេះហើយ ។

ជីរធីនប្រាស : ការសម្លាប់នេះត្រូវតែស្រែករកការសងសឹក ស្តេចផ្តាច់ការដ៏អង់អាច ... ឱ មច្ចុរាជ ! តើមានពិធីបុណ្យអ្វីនៅក្នុងវិមាននរករបស់ឯង បានជាដៃប្រឡាក់ឈាមរបស់ឯង សម្លាប់តែម្តងអស់ព្រះអង្គម្ចាស់អីច្រើនយ៉ាងនេះ !

ទូត : ទស្សនីយភាពនេះគួរឱ្យព្រឺក្បាលមែន ហើយរាជសារដែលយើងនាំមកពីប្រទេសអង់គ្លេស ក៏មកដល់យឺតពេលដែរ ។ ត្រចៀកដែលបម្រុងនឹងស្តាប់យើងនោះលែងមានវិញ្ញាណ បិទរហូតលែងបើកឡើងវិញហើយ ។ ប្រសិនបើខ្ញុំនិយាយទូលព្រះរាជាថា ព្រះរាជបញ្ជាព្រះអង្គបានត្រូវអនុវត្តរួចរាល់អស់ហើយ គឺថារ៉ូសេនក្រេននិងគីលដេនស្ទើនបានអស់ហើយ តើអ្នកណានឹងអរគុណដល់យើង ?

ហូរេសយោ : គឺប្រាកដជាមិនមែនព្រះរាជាទេ ដែលអរគុណដល់លោកនោះ ទោះបីអណ្តាតព្រះអង្គនៅមានជីវិតក៏ដោយ ! ព្រះអង្គមិនមែនឱ្យបញ្ជាសម្លាប់ពួកវានោះទាល់តែសោះ ។ ប៉ុន្តែបើបានជាអញ្ជើញមកជុំគ្នាដូច្នេះ ហើយសូមព្រះអង្គម្ចាស់ដែលនឹងយាងមកពីធ្វើសង្គ្រាមនៅប្រទេសប៉ូឡូញនិងលោកខាងនេះពីប្រទេសអង់គ្លេស ដើម្បីបានស្តាប់សេចក្តីពន្យល់ពីបញ្ហាពេញដោយឈាមនេះ សូមបញ្ជាឱ្យលើកព្រះសពទាំងនេះដាក់លើគ្រែតុបតែងលំអវិចិត្រឡើង ដើម្បីបង្ហាញឱ្យប្រជាជាតិទាំងអស់បានឃើញផង ។ នៅពេលនោះខ្ញុំនឹងអធិប្បាយឱ្យពិភពលោកទាំងមូលបានដឹងពីបុព្វហេតុលាក់លៀមពីមុនមកនៃមហន្តរាយទាំងនេះ ។ អស់លោកនឹងបានឮខ្ញុំនិយាយពីអំពើដ៏ឃោរឃៅស្រែកឈាមនិងព្រៃផ្សៃនៃការរួមផ្សំគំនិតដែលចៃដន្យបានជំរុញ ទាល់តែធ្លាយទៅដល់អំពើមនុស្សឃាត ហើយនៅក្នុងដំណោះស្រាយក្នុងទារុណភាពនេះ លោកនឹងឃើញថា ឧក្រិដ្ឋកម្មមិនសម្រេចបែរជាធ្លាក់មកលើក្បាលរបស់អ្នកបង្កហេតុទៅវិញ ។ គឺមានតែខ្ញុំម្នាក់ឯងប៉ុណ្ណោះដែលបានដឹងការពិតដ៏គួរឱ្យសោកស្តាយនេះ ។

ជ័រធីប្រាស : ឆាប់ឡើងអ៊ីចឹង ! ដើម្បីបានស្តាប់រឿងនេះ ហើយសូមប្រមូលអភិជននៃរដ្ឋ ទៅចំពោះខ្ញុំៗ សូមទទួលទាំងឈីចាប់នូវអំណោយនៃវាសនានេះ ។ ប៉ុន្តែ ដោយខ្ញុំធ្លាប់មានសិទ្ធិពីអតីតកាលនៅលើរាជាណាចក្រនេះ ដូច្នេះហើយបាន ជាអត្ថប្រយោជន៍តម្រូវឱ្យខ្ញុំទាមទារ ។

ហ្គូរេសយោ : ទូលបង្គំក៏មានពាក្យនិយាយអំពីរឿងនេះដែរ ហើយទូលបង្គំសូមនាំមកថ្វាយ ព្រះអង្គម្ចាស់នូវសំណូមពរនៃជនដែលមានសំឡេងជាអាទិភាព ដែលមុខតែ នឹងប្រទាញឱ្យអ្នកដទៃទាំងអស់យល់ព្រមតាមមិនខាន ។ ប៉ុន្តែសូមព្រះអង្គកុំ ពន្យារពេលទៅទៀត ហើយនៅក្នុងឱកាសពេញដោយវិបត្តិនេះ ដែលស្មារតី ទាំងឡាយកំពុងភ្ញាក់ផ្អើលភ័យនិងព្រួយបារម្ភសូមព្រះអង្គម្ចាស់ប្រុងប្រយ័ត្ន ពីរឿងអពមង្គលដែលការភ័ន្តច្រឡំនិងល្បិចផ្សេងៗអាចនឹងបណ្តាលឱ្យកើត មានឡើងទៀតបាន ក្រាបទូល !

ជ័រធីនប្រាស : សូមនាយទាហានបួនរូបចូលមកសែងព្រះអង្គម្ចាស់ហាំលែត ចាត់ទុកព្រះអង្គ ដូចជា អ្នកចម្បាំងដែលគួរតម្កល់ក្នុងគ្រែបុស្បក ។ ប្រសិនបើព្រះអង្គបាន សោយរាជ្យ រាជបល្ល័ង្កនេះនឹងបានស្គាល់ព្រះមហាក្សត្រដ៏ធំមួយមិនខាន ។ នៅតាមផ្លូវដែលគេសែងគ្រែព្រះអង្គទៅ ចូរបន្លឺភ្លេងដំណើរ ហើយសូមរៀប ពិធីដង្ហែព្រះសពឱ្យសមនឹងកិត្តិយសនៃអ្នកចម្បាំង ។ លើកព្រះសពឡើងទិដ្ឋ ភាពបែបនេះសមតែនៅក្នុងសមរភូមិទេ ប៉ុន្តែឥឡូវនេះ ត្រូវតែប្តូរទីកន្លែង ។ ទៅយើងសូមបញ្ជាឱ្យកងទ័ពបាញ់កាំភ្លើងជាទូទៅឡើង ! (ចេញទាំងអស់គ្នា ក្រោមបទភ្លេងដំណើរ ហើយគេឮសូរកាំភ្លើងបាញ់តាមបញ្ជា) ។

(សំរួលពីសៀវភៅអក្សរសិល្ប៍បរទេសកម្រិតទី ៣ ថ្នាក់ទី ៩និងទី ១០ បោះពុម្ពឆ្នាំ ១៩៨៧ ទំព័រ ១១៣-១២៣)

សំណួរ

១. តើអ្នកនិពន្ធរឿងហាំលែតឈ្មោះអ្វី ? ចូរនិយាយពីប្រវត្តិរបស់អ្នកនិពន្ធរូបនេះ ។

២. តើរឿងហាំលែតនិពន្ធនៅឆ្នាំណា ? តើសម័យនោះស្ថិតក្នុងបរិយាកាសសង្គមបែបណា ?

៣. ចូរបង្ហាញអត្ថរសនៅក្នុងអត្ថបទនេះ ។

៤. តើអត្ថបទនេះបានបង្ហាញខ្លឹមសារសំខាន់ដូចម្តេចខ្លះ ?

៥. តួអង្គហាំលែតស្លាប់មែន ប៉ុន្តែឧត្តមគតិរបស់តួអង្គនេះបានទទួលជ័យជំនះយ៉ាងត្រចះត្រចង់ ។ ចូរបង្ហាញតាមរយៈអត្ថបទខាងលើ ។

ដំណើរស្វែងរកនាងសីតា



ក. សិក្សាពាក្យគន្លឹះ

- អង្គកបិ (ន) : ស្វា
- ប៉ម (ន) : គ្រឹហាខ្ពស់ស្រឡះមានសណ្ឋានមូល ឬកាច់ជ្រុងមានជញ្ជាំងចោះជាប្រហោងព័ទ្ធជុំវិញធ្វើទុកនៅត្រង់មុំកំពែង បន្ទាយ ឬទីណាមួយសម្រាប់ពួនយាមល្បាតឃ្លាំ ឬលាក់ខ្លួនពួនចាំបាញ់តយុទ្ធនឹងខ្មាំងសត្រូវ ។
- គូទឹក (ន) : ស្នាមស្ពោះព័ទ្ធជុំវិញបន្ទាយឬវាំង ។
- ចារបុរស (ន) : អ្នកស៊ើបការណ៍សម្ងាត់ ។
- ព្រះនិវេសន៍ (ន) : ព្រះរាជដំណាក់
- ហឫទ័យ (ន) : ចិត្ត ដួងចិត្ត
- ឈ្លើយ (ន) : មនុស្សដែលគេចាប់បានក្នុងទ័ព ឬសត្វដែលគេចាប់បានពីក្នុងព្រៃដោយមានផ្នាក់ ។
- កាឡា (កិ) : ប្លែងខ្លួន និម្មិតខ្លួនឱ្យប្លែកពីប្រក្រតី ។

ខ. អភិវឌ្ឍន៍បំណិន

នៅពេលអានអត្ថបទនេះ អ្នកត្រូវអានដោយយកចិត្តទុកដាក់ត្រៀមឆ្លើយនឹងសំណួរដែលទាក់ទងទៅនឹងប្រវត្តិអ្នកនិពន្ធ កាលកំណត់តែង ខ្លឹមសារសំខាន់ៗ និងអត្ថរស។

គ. អត្ថបទ

[...] ព្រះទេវសាគរ ដោយសព្វព្រះទ័យនិងវីរភាពឥតមានពីររបស់អង្គកបិ ក៏ទ្រង់បញ្ជាឱ្យមេនក:បពិត ដែលស្ថិតនៅឯបាតសមុទ្រឡើបឡើងផុតពីផ្ទៃទឹក ដើម្បីឱ្យពានរដ៏អង់អាចក្លាហានបានជាកន្លែងសម្រាកសម្រាប់ យកជំហរលោតទៅមុខតទៅទៀត។ ប៉ុន្តែនៅពេលដែលកំពូលចាប់ផ្តើមលេចប្លឹមចេញបន្តិចមក ហានុមានស្មានតែឧបសគ្គថ្មីមួយមកទៀត ក៏ស្ទុះទៅឈូសរហូតក្រឡាប់ភ្នំបះជើងឡើងមកលើវិញ។ ឯភ្នំអស់សំណើចក៏សើចយ៉ាងរីករាយ ហើយអញ្ជើញស្តេចកបិសម្រាកនៅលើកំពូលភ្នំរបស់ខ្លួន។ ក្នុងពេលនោះ **គីរីមេនក:**និទានរឿងរបស់ខ្លួនប្រាប់ហានុមាន "កាលពីព្រេងនាយ នៅសម័យដែលសត្វទាំងឡាយចេះនិយាយ ភ្នំទាំងអស់សុទ្ធតែមានស្លាបហោះហើរទៅនេះទៅនោះបានដូចជាសត្វមេអំបៅដ៏ធំមួយ។ ប៉ុន្តែដោយហេតុថាក្នុងដំណើរហោះហើរឆៀងរាបដ៏សប្បាយរីករាយនោះ កាលបើចុះមកជាន់ផែនដីភ្នំក៏សង្កិនពួកតាបស ឬឥសី ដែលកំពុងស្ងួងនៅក្នុងសំណាក់ធម៌។ ព្រះទេវ: ព្រះនេត្រមួយពាន់ទ្រង់ក៏បាញ់រន្ទះមកផ្តាច់ស្លាបភ្នំទាំងនោះអស់។ ចាប់តាំងពីពេលនោះមកភ្នំទាំងឡាយត្រូវនៅជាប់នឹងដីរហូត។ មានតែ**មេនក:**តែមួយនេះទេ ដែលមិនត្រូវកាំរន្ទះ ដោយខ្លួនបានផ្តួលខ្លួនមកក្នុងសមុទ្រទាន់"។

ដូចនេះនៅពេលនេះ**មេនក:**ចង់ជួយហានុមានដោយសុខចិត្តឱ្យខ្លឹស្លាបរបស់ខ្លួនយកទៅប្រើ។ ហានុមាន ដោយហេតុថាខ្លួននៅមានកំលាំងពេញបរិបូរនៅឡើយ ក៏ប្រកែកមិនព្រមទទួលយក។ គេគ្រាន់តែយកចុងម្រាមដៃស្ទាបភ្នំដោយមិត្តភាព ហើយគេក៏ចាប់ចេញដំណើរតទៅទៀត។ ព្រះទេវ: ទាំងឡាយ ដោយសព្វព្រះទ័យនិងមេនក: ក៏ទុកឱ្យភ្នំនេះស្ថិតនៅលើផ្ទៃទឹកដូចនេះរៀងរហូតទៅ។ ព្រះអង្គបានរៀបចំឧបសគ្គពិសោធដ៏លំបាកពីរទៀត សម្រាប់ឱ្យហានុមានសាកល្បងឆ្លងកាត់។ ដំបូងព្រះអង្គឱ្យព្រះមាតានៃពួកសុរសា ទៅបង្កវឿងនឹងហានុមាន ដោយកាឡាខ្លួនជារក្សសីម្នាក់យ៉ាងធំសំបើម។ នាងរក្សសីបានឃាំងផ្លូវអាកាសជិតស្ទូង ហើយរង់ចាំត្របាក់លេបហានុមាន។ ទោះចង់បំពេញភារកិច្ចថ្វាយព្រះរាមក៏ធ្វើមិនកើត "ទោះយ៉ាងម៉េចក៏បាឯងត្រូវតែចូលតាមមាត់អញដែរ"។

នាងរក្សសី និយាយហើយ ក៏បើកកន្ត្រើតក្នុងដែលពេញច្រូងច្រាងទៅដោយធ្មេញស្រួចៗ ហើយនាងចាត់ទុកថា ជាមាត់របស់នាង។ រំពេចនោះ ហនុមានបំប៉ោងខ្លួនធំឡើងៗ ហើយសម្រុកចូលទៅស្រាប់តែរងូមមាត់ដែលពីមុនតូចនៅឡើយ រីកឡើងធំអស្ចារ្យ។ ប៉ុន្តែហនុមានក៏ធំឡើងទៀត ឯមាត់ក៏ឡើងពេញអស់ភាគបួននៃមេឃ។ ការប្រកួតប្រជែងនេះនឹងគ្មានទីបញ្ចប់ទេ។ មួយរំពេចនោះ ហនុមានបំព្រួញខ្លួនឱ្យតូចប៉ុនមេដៃ ហើយស្ទុះចូលទៅក្នុងភាពងងឹតស្លុងនៃមាត់ដ៏ធំអស្ចារ្យ បីដូចសត្វឃ្មុំទះស្លាបក្នុងស្រទាប់ផ្កា ហើយតែក្នុងប៉ប្រិចភ្នែកក៏ចេញមកកាន់ពន្លឺថ្ងៃជាថ្មីវិញ។ នាងសុរសោសើចសរសើរល្បិចហនុមានជាខ្លាំង ហើយអនុញ្ញាតឱ្យគេបន្តដំណើរទៅទៀត។ នៅពេលនោះរក្សសីសម្ងិកាលោតសង្កត់ទៅលើអង្គកបិ ប៉ុន្តែចាប់មិនជាប់ បែរជាទៅក្រសោបបានស្រមោលវិញ។ ហនុមានចាប់អារម្មណ៍ហាក់ដូចមានអ្វីប្រទាញប្រទង់នៅពីក្រោយខ្នង។ រក្សសីសម្ងិកា ក៏បំប៉ោងខ្លួនឱ្យធំជាងមុន ដើម្បីត្របាក់លេបហនុមាន។ ម្តងនេះហនុមានស្ទុះយ៉ាងរហ័ស ហើយខ្លាំងនឹងក្រចកទាល់តែរក្សសីធ្លាយពោះធ្លាក់ទៅក្នុងរលកកំពុងកញ្ជ្រោលបោកបាច។ ពួកទេពតានាំគ្នាអបអរសាទរនឹងជ័យជំនះនេះ។

កោះចាប់ផ្តើមមើលពីចម្ងាយ ហនុមានប្រែមកយករូបរាងដូចធម្មតា ហើយបន្ទាបខ្លួនលើកំពូលទ្វីបលង្កា។

មួយរំពេចនោះ គេចុះដើរតម្រង់ទៅកាន់ទីក្រុង ដែលស្ថិតនៅទីឆ្នេរមួយការពារដោយប៉មនិងគូទឹក។ ហនុមានចូលទៅក្នុងទីក្រុង ហើយដើរទស្សនាក្រោមពន្លឺព្រះចន្ទ។ ភ្លាមនោះ អ្នកតាចាស់ស្រុកដ៏ធំស្តើមស្តែ ស្រាប់តែផុសឡើងនៅពីមុខហនុមានរាំងផ្លូវជាប់។ ប៉ុន្តែហនុមានទះមួយកំភ្លៀងបះជើងច្រោង ហើយនៅពេលដែលដួលនៅនឹងដីនោះ អ្នកតាបាននឹកឃើញទំនាយពីអតីតមួយដែលថាទីក្រុងលង្កានឹងត្រូវរលាយក្នុងពេលឆាប់ៗនេះ។

គ្រប់ទិសទីហនុមានឮ ហើយឃើញទាំងអស់ពីសោភ័ណស្រស់បញ្ចង់នៃសម្ផស្សរាត្រី ដែលនាំឱ្យទាក់ចិត្តរឹតតែខ្លាំងឡើង។ ប៉ុន្តែទោះនៅទីណាក៏ស្តេចពានរមិនប្រទះឃើញសីតាកល្យាណីក្សត្រីយ៍ដែលខ្លួនខំដើររកសោះ។

ដោយអាចប្រែកាឡាតាមទំនើងចិត្តបាន ទីបំផុតពានរក៏ចូលទៅក្នុងបរិវេណនៃព្រះនិវេសស្ថានព្រះរាជា។ អង្គកបិគេចរួចទាំងអស់ពីកងល្បាតដ៏គួរស្បើមដៃពួករាក្សស: ដែលយាមទ្វារនិងទីធ្លា ហើយដើរលុកលុយពីប្រាសាទមួយទៅប្រាសាទមួយ ឆ្លងកាត់តាមកំរាលព្រំស្មៅ ដែលសត្វកាសែល

កំពុងកំរើកខ្ញែៗកាត់ទ្រុងពួកសត្វស្លាបកម្រៗ ដែលកំពុងដេក កាត់តាមថែវដ៏អ៊ូអរអឺងកងទៅដល់សំបុកពួកស្រីរបាំនិងក្រុមអ្នកតាមសរសើរ ។ ទីបំផុតពានរចូលរហូតទៅដល់ព្រះនិវេសន៍នៃព្រះចមក្សត្រា ចូលដល់ភ្លាមក៏ឈប់ង៉ក់ពីមុខរទេះបុស្បុក ភាន់ភាំងស្មារតី ដោយការស្ងើចសរសើរចំពោះរទេះវេទមន្ត ស្នាព្រះហស្តរបស់ព្រះទេវៈវិស្វកម៌: ដែលអាចបរហោះផ្លេកផ្លោះក្នុងលំហអាកាសបានអួសទាញដោយសត្វលា ក្បាលជាពិកាក: ហើយដឹកនាំអង្គម្ចាស់របស់ខ្លួនទៅគ្រប់ទីកន្លែងបានតាមទំនើងហឫទ័យ ។ ពេលដែលប្រវាឡើងទៅលើព្រះរាជរថទេពបានហើយ ហនុមានភ្ញោចច្រមុះតាមហិតក្លិនទឹកក្រអូប ដែលសាយភាយពេញក្នុងបន្ទប់ ។ ពានរដើរតាមក្លិននេះ ក៏ចូលទៅដល់មហាសាលនៅទីនោះ ពិធីជប់លៀងបានចប់សព្វគ្រប់អស់ហើយ ហើយនៅកណ្តាលចំណោមស្រីស្រឡាងដែលដេកលក់សន្ធឹងសន្ធៃ ឯនេះខ្លះឯនោះខ្លះ នោះក្រុងរាវណៈព្រះរាជានៃពួករាក្សស: អង្គម្ចាស់ដ៏ស្បើមនៃរាជនិវេសន៍នេះ ក៏កំពុងលង់លក់យ៉ាងស្កប់ស្កល់ដែរ ។

ហនុមានមិនអាចទប់ចិត្ត មិនឱ្យគយគន់ទិដ្ឋភាពលង់ក្នុងដំណេករបស់ខ្លានៃរាក្សស:នេះបានទេ ដែលអស្ចារ្យហើយភ្លើតភ្លើនផងគួរឱ្យខ្លាចក្នុងភាពស្រឹងនិងស្រមុកខ្លរខ្លាររបស់ខ្លួន ។

[...] មួយរំពេចនោះ ក្រសែភ្នែកស្តេចពានរប្រទះឃើញក្សត្រីយ៍មួយអង្គនៅឆ្ងាយដាច់ពីគេឯងទ្រង់កាយដោយស្បៃសូត្រភ្លឺផ្លេកដូចមាសសែនសមសួន ។ ប្រាកដជាព្រះសីតាហើយ ហនុមាននឹកក្នុងចិត្តរួចហើយហនុមានក៏លោតដាំទឹងទាញកន្ទុយមកថែថើបលោតផ្លោះផ្លោតៗ ហើយស្រវាឡើងតាមសសរទៅលើរានហាល ។ ឱខុសទេ ! ពិតជាមិនមែននាងសីតា ។ ព្រាត់ពីព្រះស្វាមី ហនុមានគិតក្សត្រីយ៍សីតាឯណាមកជប់លៀងទាល់តែស្រឹង ហើយដេកលក់យ៉ាងនេះកើត ។ គិតឃើញដូចនេះហើយ អង្គកបិយើងក៏វិលមករកគំនិតម៉ត់ចត់វិញ ។ ពានរនឹកស្តាយដោយចូលមកលុកលុយបន្ទប់សម្ងាត់ផ្ទាល់ខ្លួនរបស់ក្រុងរាវណៈ តែបន្ទាប់មកក៏បានធូរចិត្តបន្តិចទៅវិញ ព្រោះគិតថាខ្លួនធ្វើនេះក្នុងបំណងល្អ ដើម្បីបម្រើ "សម្ព័ន្ធមិត្ត" រាមៈរបស់ខ្លួន ។

ហនុមានបន្តការសុះសែងរកតទៅទៀតនៅតែមិនឃើញអង្គក្សត្រីយ៍ ក៏អស់សង្ឃឹម ។ ពានរចង់សម្លាប់ខ្លួន តែមកនឹកឃើញថាបើខ្លួនស្លាប់មិត្តភក្តិទាំងអស់ដែលរង់ចាំនៅលើឆ្នេរក៏នឹងស្លាប់ផងដែរ ។ គិតឃើញដូចនេះ ហនុមានខំរកតទៅទៀតនៅក្នុងបន្ទប់នានានិងសួនច្បារ ។ ទីបំផុត ហនុមានក៏ប្រទះឃើញសួនអសោកដ៏តូចមួយ ដែលពីមុននេះឥតបានទាក់ទាញភ្នែករបស់គេសោះ ។ ហនុមានលោតផ្លោតទៅលើជញ្ជាំង រួចផ្លោះពីទីនោះទៅលើដើមឈើ ។ នៅនឹងគល់ឈើមួយដើម មានខ្មមតូច

មួយសង់ឡើងកណ្តាលរុក្ខជាតិពណ៌បៃតង។ គេក្រឡេកភ្នែកទៅក៏ស្គាល់ច្បាស់ជានាងសីតាកំសត់ ផ្ទំផ្ទាល់នឹងដីរាងកាយក្សត្រីយ៍គ្មានគ្រឿងលំអអ្វីទាល់តែសោះ ទឹកមុខស្លេកស្លាំងមិនរៀបរយប្រៀប ដូចជាពាក្យមួយមាត់ខ្វះសេចក្តីអធិប្បាយ ហើយគេបានឱ្យន័យមួយដែលមិនមែនជាន័យពិតរបស់ វា។ ហនុមានស្ងើចសរសើរនាងយ៉ាងស្ងៀមស្ងាត់នឹកទៅសែនអាណិតនាង ហើយគិតទៅដល់វាសនា ដ៏ចម្លែករបស់នាង។ នាងកើតចេញពីអាចម៍បំណះ ដែលជានង្គ័លកាយគាស់រំលើងឡើង។ រាងកាយ នាងសឹងរុំព័ទ្ធទៅដោយធូលីភ្លឺផ្លេក បីដូចលម្អងផ្កាឈូក ហើយក៏មានការខិតខំតស៊ូច្រើនណាស់មក ហើយដែរក្នុងការដណ្តើមយកក្សត្រីយ៍ដ៏ឧត្តមនេះ។ ឥឡូវនេះពួកមេឆ្មាំដ៏ស្បើមអស់នោះនាំគ្នាអង្គុយ ហ៊ុមព័ទ្ធដើមឈើ ដែលនាងផ្អែក។ បើចូលទៅជិតនាងឱ្យបានជាសម្ងាត់មុខជាមិនអាចធ្វើទៅកើតទេ។

ហនុមានលាក់ខ្លួនទៅក្នុងស្លឹកធំៗនិងក្រាស់ស៊ុបទ្រុបនៃដើមសឹមជន: រង់ចាំឱកាសល្អ ហើយ រាត្រីកាលក៏កន្លងទៅ។ មួយរំពេចនោះនៅពេលភ្លឺព្រាងៗមានហេតុដ៏គគ្រឹកគគ្រេងមួយកើតឡើង។ រាវណៈចមចក្រស្រឹងស្នេហ៍ បានចូលមកក្នុងសួនច្បារជាមួយពួកស្រីស្នំស្រីង្គារពួកបុត្រីព្រះទេវៈនិង គន្ធរ: ហើយទៅជួបនឹងឈ្លើយដែលកំពុងទ្រុឌទ្រោមរបស់ខ្លួន។

(ដកស្រង់និងកែសម្រួលពីរឿងរាមាយណៈ សៀវភៅអក្សរសិល្ប៍បរទេសក្រសួងអប់រំ)

សំណួរ

១. ចូរនិយាយពីជីវប្រវត្តិអ្នកនិពន្ធរឿងរាមាយណៈនិងស្នាដៃរបស់លោក។

២. តើរឿងរាមាយណៈនិពន្ធនៅសម័យណា ?

៣. តើកាលអាកាសក្នុងសាច់រឿងនេះ មានតួនាទីអ្វីខ្លះ ?

៤. តើប្រផ្នូលនិងការរំពូករឿងដើមក្នុងរឿងមាននៅកន្លែងណា ? ចូរបង្ហាញ។

៥. ចូរបង្ហាញពីអត្ថរសដែលមាននៅក្នុងអត្ថបទ។

៦. តើភាតរភាពរវាងទេវៈសាគរនិងហនុមាន រវាងហនុមាននិងព្រះរាមកើតឡើងដោយសារអ្វី ? មានប្រយោជន៍អ្វីខ្លះ ?

រឿងប៉ូលវីរហ្សីនី



ចូរអ្នកស្តាប់អត្ថបទដកស្រង់រឿង ប៉ូលវីរហ្សីនី ហើយឆ្លើយនឹងសំណួរខាងក្រោម ៖

១. តើដំណើររឿងនេះប្រព្រឹត្តទៅនៅប្រទេសណា ? ទីកន្លែងណា ?

២. តើក្នុងអត្ថបទនេះមាននិយាយពីប្រផ្នូលអ្វីខ្លះ ?

៣. ចូរវិភាគតួអង្គប៉ូលនិងវីរហ្សីនី តាមរយៈអត្ថបទនេះ ។

៤. ចូរបង្ហាញពីអត្ថរូបនិងអត្ថរស ដែលមាននៅក្នុងអត្ថបទដកស្រង់ខាងលើនេះ ។

៥. តើអ្នកយល់ដូចម្តេចចំពោះមរណភាពរបស់តួអង្គប៉ូលនិងវីរហ្សីនី ?

៦. ប្រសិនបើជួបគ្រោះថ្នាក់ដូចនាងវីរហ្សីនី តើអ្នកធ្វើដូចម្តេច ?



ការបញ្ចេញមតិផ្ទាល់ខ្លួន

ការបញ្ចេញមតិផ្ទាល់ខ្លួន គឺការផ្តល់គំនិតយោបល់ ដែលមនុស្សម្នាក់ៗយល់ឃើញពីអ្វីមួយ។ គំនិតទាំងនោះត្រូវមានហេតុផលនិងមានអំណះអំណាងច្បាស់លាស់ គាំទ្រ ដើម្បីឱ្យស្តាប់អាចជឿបាន។

ខាងក្រោមនេះ គឺជាការបញ្ចេញមតិរបស់មនុស្ស ៣នាក់ស្តីអំពី "ថ្ងៃបុណ្យសង្ឃរ ឬថ្ងៃបុណ្យនៃសេចក្តីស្រឡាញ់" ដែលកំពុងតែមានប្រជាប្រិយភាព ចំពោះយុវវ័យនៅតាមរាជធានី តាមទីក្រុងនានាទូទាំងប្រទេសកម្ពុជា។

សានី : ថ្ងៃទី ១៤ ខែ កុម្ភៈ កាលដើមឡើយប្រជាពលរដ្ឋខ្មែរ ពិសេសពួកយុវវ័យពុំសូវដឹងថាជាថ្ងៃបុណ្យអ្វីទេ ពោលគឺទើបតែប៉ុន្មានឆ្នាំចុងក្រោយនេះ យុវវ័យស្ទើរតែគ្រប់រូប ពិសេសយុវវ័យនៅទីប្រជុំជននិងទីក្រុងបានស្គាល់ថ្ងៃនេះថា ជាថ្ងៃបុណ្យសង្ឃរ។

ដានួ : បើតាមខ្ញុំដឹងខ្លះៗមកថា ក្នុងថ្ងៃបុណ្យនេះ មានយុវវ័យមួយចំនួននាំគ្នាប្រព្រឹត្តអំពើមិនគប្បី ផ្ទុយពីទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិយើង ក៏មានដែរ។

បញ្ញា : នោះគឺជាការយល់ច្រឡំរបស់ពួកយុវវ័យមួយចំនួនទេ។ ការពិតបុណ្យនេះ គឺចាប់ផ្តើមឡើងតាំងពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២៦៩ នៃគ្រិស្តសករាជ ដោយជនជាតិរ៉ូម៉ាំងម្នាក់ឈ្មោះ វ៉ាឡង់ទីន (Valintine) មូលហេតុគាត់បាត់បង់ជីវិត ដោយសារការប្រឆាំងដាច់ខាតមិនលះបង់គ្រិស្តសាសនា។ ក្រោយមកថ្ងៃ ១៤ កុម្ភៈ នេះត្រូវបានគេឧទ្ទិសបូជាសម្រាប់សេចក្តីស្រឡាញ់សម្រាប់គូស្នេហ៍គ្រប់រូប។ ថ្ងៃនោះត្រូវបានគេកំណត់ដើម្បីធ្វើពាក្យកាព្យនិងកាដូមានដូចជា ផ្កាជាដើម។ ថ្ងៃបុណ្យវ៉ាលីនថាយ បច្ចុប្បន្នបង្ហាញសេចក្តីស្រឡាញ់ទៅកាន់មិត្តភក្តិនិងជាថ្ងៃមនុស្សគ្រប់រូបបង្ហាញសេចក្តីស្រឡាញ់ទៅកាន់មិត្តភក្តិនិងអ្នកជាទីស្រឡាញ់។ ថ្ងៃបុណ្យនេះត្រូវបានគេទទួលស្គាល់ទូទាំងពិភពលោក។

សានី : ចំពោះថ្ងៃបុណ្យសង្ឃរនៅប្រទេសយើងវិញ ប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញពួកយុវវ័យនិយមយ៉ាងខ្លាំង។ គេបានជូនផ្កា កាដូ វត្ថុអនុស្សាវរីយ៍ និងផ្ញើសារជូនពរគ្នាទៅវិញទៅមក ព្រមទាំងចំណាយពេលដើរកំសាន្តជាមួយនិងគូស្នេហ៍និងមិត្តភក្តិនៅក្នុងទីក្រុង រហូតមានយុវវ័យខ្លះឈានចូលដល់ទំនាក់ទំនងផ្លូវភេទដែលជាទង្វើខុសឆ្គងខ្លាំងណាស់។

ដានូ : ខ្ញុំយល់ថា អ្នកមានគំនិតបង្កើតឈ្មោះ "ថ្ងៃបុណ្យសង្សារ" ពិតជាមានចេតនាធ្វើឱ្យយុវជន យុវនារីចាប់អារម្មណ៍លើចំណងស្នេហារបស់គូសង្សារតែម្យ៉ាងគត់ ។ ប៉ុន្តែអត្ថន័យនៃថ្ងៃបុណ្យ ១៤ កុម្ភៈនេះល្អប្រសើរណាស់ ។ ខ្ញុំយល់ស្របនឹងមតិរបស់បញ្ញាដែលបានលើកឡើងមុននេះ ។ វប្បធម៌របស់ជាតិសាសន៍នីមួយៗមានលក្ខណៈនិងតម្លៃល្អប្រពៃសម្រាប់ពួកគេ ប៉ុន្តែវាអាចមិនល្អសម្រាប់ជាតិយើង ។

បញ្ញា : វប្បធម៌បរទេសហូរចូលមកប្រទេសយើងមានតាំងពីដើមគ្រិស្តសករាជមកម្ល៉េះ ។ យើងមានគំនិតជាតិនិយម ជាការល្អប្រសើរណាស់ ប៉ុន្តែបើជាតិនិយមជ្រុលអាចនាំឱ្យមានវិបត្តិសង្គម ព្រមទាំងធ្វើឱ្យបាត់បង់នូវការគាំទ្រជាសកលទៀតផង ។ ទស្សនវិស័យនៃគំនិតជាតិនិយមពិតប្រាកដ គឺជាគំនិតស្រឡាញ់ប្រទេសជាតិរបស់ខ្លួន ស្រឡាញ់ជនជាតិ ស្រឡាញ់ទឹកដី ស្រឡាញ់ប្រវត្តិសាស្ត្រ ស្រឡាញ់វប្បធម៌ទាំងអស់របស់ជាតិ ទោះបីសម្បត្តិវប្បធម៌លទ្ធកម្មក្តី សម្បត្តិវប្បធម៌ជាតិក្តី ។ គំនិតនេះស្របនឹងព្រលឹងខ្មែរតាំងពីបុរាណកាលមក ដែលតែងតែប្រដៅកូនចៅជំនាន់ក្រោយ "ឱ្យនាំគ្នាកសាងសម្បត្តិវប្បធម៌ទាំងឡាយឱ្យលូតលាស់ឡើង ដោយចេះច្បិចយកវប្បធម៌ជាតិសាសន៍ដទៃមកបញ្ចូលក្នុងវប្បធម៌ខ្លួន កុំធ្វើតាមជាតិសាសន៍គេទាំងដុល គឺត្រូវយកមកច្នៃ កែទម្រង់ស្របទៅនឹងចំណង់ចំណូលចិត្តខ្មែរ ..." ។

សានី : បញ្ញាពូកែនិយាយណាស់ ! ចេះរកពាក្យឱ្យចំហើយសម ដែលយើងមិនអាចបដិសេធបាន ។ ខ្ញុំគិតថា ថ្ងៃបុណ្យសង្សារនេះដូចជាពិបាកនឹងកែច្នៃឱ្យមកជាខ្មែរណាស់ ព្រោះថាផ្ដត់គំនិតយុវវ័យផុយស្រួយណាស់ គេងាយនឹងរងគ្រោះដោយសារការអួសទាញ ធ្វើឱ្យគេខកបំណងទៅជាឈឺចាប់ អាចនឹងបង្កផលវិបាកឱ្យគ្រួសារនិងសង្គមផងដែរ ។

ដានូ : ខ្ញុំក៏យល់ដូចសានីដែរ ! យុវវ័យប្រៀបដូចជាសត្វមមាច ទោះបីដឹងថាភ្លើងហើយក៏គេនៅតែហើរទៅចូលដែរ ព្រោះគេមិនខ្លាចភ្លើង យ៉ាងណាមិញ យុវវ័យ គឺជាវ័យដែលកំពុងតែមានមោទនភាពចំពោះភាពសង្ហា អង់អាច បង្ហូតបួក បញ្ចេញរាងឱ្យអ្នកដទៃចាប់អារម្មណ៍ចំពោះខ្លួន ។

បញ្ញា : មតិរបស់សានីនិងដានូ គឺមិនខុសទេ ព្រោះថា យុវវ័យកំពុងពេញស្រឡាញ់ខ្លួនឯង ទោះជាបែបនេះក៏ដោយ ក៏ខ្ញុំមានជំនឿថា គេយល់ដឹងពីអត្ថន័យពិតប្រាកដរបស់វប្បធម៌បរទេសមួយនេះដែលពីមុនយើងហៅថា ថ្ងៃបុណ្យសង្សារ ឱ្យទៅជាបុណ្យនៃ

សេចក្តីស្រឡាញ់វិញបាន ដោយមានខ្ញុំ មានមិត្តទាំងពីរ មានអ្នកដទៃទៀតដូចជា មាតាបិតា លោកគ្រូអ្នកគ្រូ ព្រះសង្ឃ សហគមន៍ រាជរដ្ឋាភិបាល ដែលព្រមព្រៀងគ្នាតាមរយៈការអប់រំផ្ទាល់ ផ្សព្វផ្សាយតាមទូរទស្សន៍ សារព័ត៌មាន វិទ្យុ ដោយយើងជួយបង្វែរឱ្យគេងាកទៅរកសេចក្តីគោរពស្រឡាញ់អ្នកមានគុណដូចជា មាតាបិតា ជីដូនជីតា លោកគ្រូអ្នកគ្រូ ចាស់ព្រឹទ្ធាចារ្យ ចាប់ផ្តើមនិងផ្តល់ជូនពួកគេវិញនូវសព្ទសាធុការពរ ផ្តល់ជូនការស្រឡាញ់ដ៏ស្មោះស្ម័គ្រ។ យើងសង្ឃឹមថាតទៅ ថ្ងៃទី ១៤ កុម្ភៈ គឺជា "ថ្ងៃបុណ្យនៃសេចក្តីស្រឡាញ់" យ៉ាងពិតប្រាកដ។

ជានួ : អរគុណណាស់ចំពោះមតិដ៏ល្អរបស់បញ្ញានិងសានី។ ខ្ញុំក៏រួមចំណែករៀបចំខ្លួន ដើម្បីជួយឱ្យបានសម្រេចតាមមតិរបស់អ្នកទាំងពីរ ដើម្បីអភិវឌ្ឍវិស័យវប្បធម៌ជាតិឱ្យថ្កុំថ្កើងរុងរឿងជានិច្ចនិរន្តរ៍។

សំណួរ

១. តើថ្ងៃបុណ្យសង្ក្រានមានប្រភពមកពីប្រទេសណា ?

២. ពួកបរទេសគេហៅថា "ថ្ងៃបុណ្យសង្ក្រាន" ព្រោះអ្វី ?

៣. តើថ្ងៃបុណ្យសង្ក្រានអាចបំបាត់ព្រលឹងជាតិខ្មែរដែរឬទេ ? ព្រោះអ្វី ?

៤. តើប្អូនមានទស្សនៈបែបណាចំពោះការហូរចូលនៃវប្បធម៌បរទេស ? ចូរលើកឧទាហរណ៍។

លំហាត់

ចូរនិយាយពីការហូរចូលនិងការទទួលយកវប្បធម៌បរទេស ព្រមទាំងផលវិជ្ជមាននិងអវិជ្ជមានរបស់វាផង គឺ

- បញ្ហាបច្ចេកវិទ្យា (អេឡិចត្រូនិច)
- បញ្ហាចម្រៀង របាំ ការស្លៀកពាក់ ក្រុមសិល្បករ សិល្បការិនីបរទេស (កូរ៉េ អាមេរិចកាំង)



ការស្រាវជ្រាវ

ការស្រាវជ្រាវមានច្រើនប្រភេទ ។ ការស្រាវជ្រាវអាចធ្វើតាមរយៈការសាកសួរព័ត៌មានផ្ទាល់មាត់ទៅលើមនុស្សចាស់ទុំច្រើនគ្នា ដែលធ្លាប់ដឹងឮបញ្ហាហេតុការណ៍ ឬរឿងរ៉ាវដែលកន្លងផុតទៅ តាមរយៈការរុករកក្នុងទឹក ក្នុងព្រៃ ក្នុងសមុទ្រ ឬក្រោមដីជាដើម ។

ពេលនេះ អ្នកនឹងសិក្សាអំពីសំណេរស្រាវជ្រាវតាមរយៈឯកសារ ។ ក្នុងការស្រាវជ្រាវតាមរយៈឯកសារ ឬសៀវភៅផ្សេងៗអ្នកត្រូវ ៖

- កំណត់ប្រធានបទ ដែលត្រូវស្រាវជ្រាវឱ្យច្បាស់ ។
- កំណត់ទីតាំងរកឯកសារដូចជា បណ្ណាល័យ ឬមជ្ឈមណ្ឌលតម្កល់ឯកសារនានា ដើម្បីរកឯកសារពិគ្រោះ ។
- អានមាតិកាអត្ថបទរបស់សៀវភៅ ដើម្បីរកចំណងជើងអត្ថបទ ដែលទាក់ទងទៅនឹងប្រធានបទរបស់អ្នក ។
- អានអត្ថបទដែលអ្នករកឃើញដោយប្រុងប្រយ័ត្ន ដើម្បីយកខ្លឹមសារសំខាន់ៗ ដែលទាក់ទងនឹងប្រធានបទរបស់អ្នក ។
- ស្រង់ប្រភពឯកសារដូចជា ចំណងជើងសៀវភៅ ឈ្មោះអ្នកនិពន្ធ ទីកន្លែង ឆ្នាំបោះពុម្ពផ្សាយ និងទំព័រអត្ថបទ ។

ចូរពិនិត្យគម្រោង

១ . សេចក្តីផ្តើម

ប្រាប់ប្រធានបទនិងបំណងនៃការស្រាវជ្រាវលើប្រធានបទនោះ ។

២ . តួសេចក្តី

- ផ្តល់សេចក្តីពន្យល់ និយមន័យ ចាំបាច់លើពាក្យគន្លឹះ ប្រធានបទ ប្រធានបទរង ។ល ។
- ស្រង់ឧទាហរណ៍ក្នុងឯកសារយោង (ឯកសារដែលយើងកំពុងពិគ្រោះសំណេរស្រាវជ្រាវនោះ) ក្នុងករណីនេះត្រូវចុះលេខយោង ប្រាប់ប្រភព ។
- រកឧទាហរណ៍មកបន្ថែម ។
- ពន្យល់លក្ខណៈពិសេសផ្នែកនីមួយៗ ។

៣ . សេចក្តីបញ្ចប់

- វាយតម្លៃលើលទ្ធផលនៃការស្រាវជ្រាវ
- ភ្ជាប់បញ្ជីឯកសារពិគ្រោះ

ចូរអ្នកពិនិត្យសំណេរស្រាវជ្រាវគំរូដូចខាងក្រោម :

ប្រធាន : ចូរស្រាវជ្រាវអំពីទំនាក់ទំនងរវាងអរិយធម៌ខ្មែរនិងអរិយធម៌បរទេស ។

គម្រោងអធិប្បាយ

១ . ផ្តើមសេចក្តី

- ជាតិសាសន៍ណាក៏ដោយ ពុំដែលមានអរិយធម៌សុទ្ធសាធតែឯកឯងឡើយ ... ។
- ជនជាតិខ្មែរ ដែលធ្លាប់មានអរិយធម៌ល្បីល្បាញ ...ក៏តែងបានទទួលឥទ្ធិពលអរិយធម៌បរទេសច្រើនដែរ
- តើជនជាតិខ្មែរបានទាក់ទងជាមួយជនជាតិណាខ្លះ ? ហើយទទួលឥទ្ធិពលអ្វីខ្លះ ?

២ . តួសេចក្តី

ក. ពន្យល់ពាក្យ

- អរិយធម៌ : ធម៌ទាំងឡាយណាដែលជាសភាពនិងតម្លៃនៃការលួតលាស់ ដុះដាល រីកចម្រើនល្អប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរក្នុងការរស់នៅរបស់មនុស្សក្នុងសង្គម ដែលប្រកបដោយរបៀបរៀបរយល្អ គ្រឿងប្រដាប់ប្រើប្រាស់គ្រប់គ្រាន់ ជំនឿ ចំណេះ ចំណង់ចំណូលចិត្តគ្រប់បែបយ៉ាងក្នុងគោលដៅស្វែងរកសុខៈ ។
- អរិយធម៌មានមែកធាង គឺវប្បធម៌ និងសង្គមធម៌

ខ. បកស្រាយប្រធាន

- ខ្មែរមានអរិយធម៌ដើមរបស់ខ្លួន
  - ជឿព្រលឹង អារក្ស អ្នកតា
  - ទុកស្ត្រីជាធំ
  - បាចទឹកបញ្ចូលស្រែ
  - ផ្សាំងសត្វ
  - កប់ខ្មោចក្រោមថ្មជុល ក្នុងក្រឡ
  - ភាសាមានអន្តរបទ ។ល ។

ឥទ្ធិពលអរិយធម៌បរទេសមកលើអរិយធម៌ខ្មែរ ។ ខ្មែរធ្លាប់បានទាក់ទងនិងទទួលឥទ្ធិពលពីបរទេសតាំងពីដើមនៃគ្រិស្តសករាជ រហូតមកដល់សព្វថ្ងៃដូចជា :

- ឥទ្ធិពលឥណ្ឌា (សតវត្សទី ២)
  - ទស្សនៈរាជានិយម
  - សាសនា
  - ភាសា អក្សរ អក្សរសិល្ប៍
  - សិល្បៈ ទំនៀមទំលាប់ ច្បាប់ ...
- ឥទ្ធិពលចិន (សតវត្សទី ៣)
  - ជំនួញ
  - ល្បាយជាតិសាសន៍ ល្ងោន ...
- ឥទ្ធិពលចាម-ជ្វា (សតវត្សទី ៤)
  - ស្ថាបត្យកម្ម
  - ក្បាច់លំអ (រាហូ)
- ឥទ្ធិពលថៃ-វៀតណាម (សតវត្សទី ១៣)
  - ពាក្យពេចន៍
- ឥទ្ធិពលអឺរ៉ុប (សតវត្សទី ១៦)
  - វិទ្យាសាស្ត្រ បច្ចេកទេស
  - ទំលាប់ (ចាប់ដៃ ស្លៀកពាក់)
  - លទ្ធិប្រជាធិបតេយ្យ កិច្ចការរដ្ឋបាល ...
  - អរិយធម៌បរទេសជាឧបករណ៍ផ្សេផ្សំអរិយធម៌ខ្មែរវីរកដុះដាល
  - ខ្មែរ-មន ជាដៃគូកសាងអរិយធម៌ក្នុងកុលសម្ព័ន្ធនៅអាស៊ីអាគ្នេយ៍

លោក ម៉ូរីសស្តែ អភិរក្សអង្គរបានសរសេរថា "មិនមែនដូចអ្នកខ្លះបានយល់នោះទេថា ជាប្រជារាស្ត្រមួយដែលមានដើមកំណើតជាឥណ្ឌាសុទ្ធសាធ ហើយដែលបានមកតាំងនៅក្នុងតំបន់គ្មានមនុស្ស ឬក៏បានកំចាត់ពួកអ្នកស្រុកអាយ ដោយការសម្លាប់រង្គាល ឬការនិរទេសទាំងហ្វូងនោះទេ" ប្រជារាស្ត្រខ្មែរ គឺជាអ្នកស្រុកដើម ដែលបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា ។

លោក ក្រូ លៀ បានសរសេរក្នុងសៀវភៅគាត់ថា "អរិយម៏អូស្ត្រូអាស៊ី ឬអរិយធម៏ខ្យល់រដូវ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាជាមូលដ្ឋានរួមនៅខាងដើមទេ ប្រទេសឥណ្ឌា ក៏ដូចជាប្រទេសចិនដែរមិនអាចផ្សព្វផ្សាយឥទ្ធិពលអរិយធម៏របស់ខ្លួនបានដូចដែលខ្លួនបានធ្វើរួចមកហើយនោះទេ។ គ្រាប់ពូជត្រូវការដីមានជីជាតិ ដើម្បីដុះដាល។ ...

សន្និដ្ឋាន :

- ខ្មែរ ច្នៃផ្សំឥទ្ធិពលអរិយធម៏បរទេសឱ្យមកជាលក្ខណៈជាតិ
- ទស្សនៈដែលមិនត្រូវចំណូលចិត្តខ្មែរបោះបង់ចោល
- អរិយធម៏ខ្លះ (ទស្សនៈខ្លះ) ត្រូវសាបរលាប ...

៣ . សេចក្តីបញ្ចប់

ការស្រាវជ្រាវអំពីទំនាក់ទំនងអរិយធម៏ខ្មែរនិងអរិយធម៏បរទេសបានបង្ហាញថា ខ្មែរជាជាតិមួយចំណាស់ជាងគេនៅអាស៊ីអាគ្នេយ៏ ដែលដូនតាបន្សល់ទុកមក។ ជនជាតិដទៃទៀតដែលជាអ្នកជិតខាងយើង ដែលរស់នៅភូមិភាគអាស៊ីអាគ្នេយ៏ជីគោកសព្វថ្ងៃ គឺសុទ្ធតែបានមកដល់ក្រោយ (លើកលែងតែជនជាតិចាមចេញ)។

ការស្រាវជ្រាវនេះយោងតាមឯកសារពិគ្រោះ ៖

- សៀវភៅ "អរិយធម៏ខ្មែរ" រៀបរៀងឡើងដោយ លោក សួ មុយឃៀង លោក ទិត សៀង និងលោក ជា ឈិន បោះពុម្ពនៅគ.ស ២០០៥ ទំព័រទី ៣២៩-៣៣១។
- សៀវភៅ "អរិយធម៏ខ្មែរ" របស់អ្នកស្រី ត្រឹង ងា បោះពុម្ពឆ្នាំ ១៩៧៥ ទំព័រ ៨-១១។

លំហាត់

១. ចែកគ្នាជាក្រុមស្រាវជ្រាវ ដែលក្រុមនីមួយៗមានសមាជិក ១០នាក់ ជ្រើសរើសប្រធានបទណាមួយដែលខ្លួនពេញចិត្ត មកធ្វើការស្រាវជ្រាវទៅតាមប្រធានបទនោះ។


២. ក្រុមនីមួយៗត្រូវរកឯកសារ ឬខ្ជឹងកសារពីបណ្ណាល័យសម្រាប់ការងារស្រាវជ្រាវ ដោយអនុវត្តតាមការណែនាំនិងគម្រោងស្រាវជ្រាវខាងលើ។

យើងបម្រើសេវាកម្ម :

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

WE SERVE :

- book and teaching-aid development
- printing
- distribution to schools



មានលក់ :

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ
សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង
សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

SELLING :

textbooks , teacher's manuals ,
workbooks , supplementary readers ,
teaching-aids and stationary !

IBC INTERNATIONAL BOOK CENTER
$ 3.20

9 789995 001391